# ខោនធី SANTA CLARA COUNTY

# គម្រោងផែនការរដ្ឋបាលដើម្បីការបោះឆ្នោត

តារាងមាតិកា


សេចក្តីផ្តើម ..... 4

ផ្នែកទី 1 – ផែនការរដ្ឋបាលបោះឆ្នោត ..... 6

ដំណើរការបោះឆ្នោតតាមសំបុត្រ (VBM) ..... 6

ការបោះឆ្នោតដែលអាចធ្វើបានតាមសំបុត្រ ..... 7

ទីតាំងទម្លាក់សន្លឹកឆ្នោត ..... 9

មណ្ឌលបោះឆ្នោត ..... 12

ការចុះឈ្មោះអ្នកបោះឆ្នោត ..... 13

សន្លឹកឆ្នោតជំនួសថ្មី ..... 14

ការបោះឆ្នោតបណ្តោះអាសន្ន ..... 14

ការបោះឆ្នោតដែលអាចធ្វើបាននៅក្នុងមណ្ឌលបោះឆ្នោត ..... 15

ជំនួយផ្នែកភាសា ..... 16

ការពិចារណាដាក់នៅតាមមណ្ឌលបោះឆ្នោត ..... 17

សមាសភាពមន្ត្រីបោះឆ្នោត ..... 18

បញ្ជីបោះឆ្នោតអេឡិចត្រូនិក (បញ្ជីបោះឆ្នោតអេឡិចត្រូនិក) ..... 20

ការផ្សព្វផ្សាយ ..... 21

ការពិគ្រោះយោបល់ជាសាធារណៈ ..... 21

តារាងពេលវេលាអភិវឌ្ឍផែនការរដ្ឋបាលបោះឆ្នោត (EAP) ..... 23

សេចក្តីជូនដំណឹងជាសាធារណៈ ..... 23

គណៈកម្មការទទួលបានការប្រឹក្សាផ្នែកភាសានិងការចូលរួមបោះឆ្នោត ..... 24

ផ្នែក 2 – ផែនការអប់រំនិងផ្សព្វផ្សាយ ..... 26

ភាគទី 1៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត – ទូទៅ ..... 26

ការប្រើប្រព័ន្ធផ្សព្វផ្សាយ ..... 26

ផែនការវត្តមានសហគមន៍ និង សម្ភារៈអប់រំអ្នកបោះឆ្នោត ..... 28

កម្មវិធីបញ្ជូនសារដោយផ្ទាល់ ..... 29

ធនធានអប់រំដល់អ្នកបោះឆ្នោតមាននៅលើគេហទំព័រ ROV ..... 29

ភាគទី 2៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត – សហគមន៍ដែលនិយាយភាសាមានភាគតិច ..... 30

ធ្វើការកំណត់ដល់សហគមន៍ដែលនិយាយភាសាមានភាគតិច ..... 30

សហគមន៍ដែលនិយាយមានភាសាភាគតិចដែលត្រូវផ្តល់សេវាជូន ..... 30

សិក្ខាសាលាអប់រំអ្នកបោះឆ្នោតសម្រាប់សហគមន៍ដែលនិយាយភាសាមានភាគតិច ...................................... 31
ការប្រើប្រព័ន្ធផ្សព្វផ្សាយកំណត់គោលដៅទៅលើសហគមន៍ដែលនិយាយភាសាមានភាគតិច ...................... 31
មន្ត្រីបោះឆ្នោត ........................................................................................................................ 32
ផ្នែកទី 3៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត - អ្នកបោះឆ្នោតដែលមានពិការភាព.............................................. 33
វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ពីសេចក្តីត្រូវការរបស់អ្នកបោះឆ្នោតមានពិការភាព ............................ 33
ការផ្សព្វផ្សាយសេវាទៅដល់សហគមន៍ដែលជនមានពិការភាព ...................................................................... 34
សេវាកម្មសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព......................................................................................... 34
សិក្ខាសាលាអប់រំអ្នកបោះឆ្នោតសម្រាប់សហគមន៍មានពិការភាព ........................................................... 35
សម្ភារៈពង្រាងត្រូវបានប្រើក្នុងការអប់រំដល់អ្នកបោះឆ្នោតដែលមានពិការភាព ............................................. 35
មន្ត្រីបោះឆ្នោត ........................................................................................................................ 35
ផ្នែកទី 4៖ ព័ត៌មានស្តីពីមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោត ............................................................ 36
ទីតាំងមណ្ឌលបោះឆ្នោត........................................................................................................ 36
ទីតាំងទម្លាក់សន្លឹកឆ្នោត ........................................................................................................ 37
វិធានការបង្ការ........................................................................................................................ 37
ផែនការបម្រុង........................................................................................................................ 38
ផ្នែកទី 5៖ ផែនការសន្តិសុខ និង សិទ្ធិឯកជនភាពសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ................................ 39
ការរចនានិងប្លង់មណ្ឌលបោះឆ្នោត ........................................................................................ 39
សន្តិសុខក្នុងការបោះឆ្នោត ...................................................................................................... 39
ផ្នែកទី 6 – ថវិកា ........................................................................................................................ 40

# សេចក្តីផ្តើម

ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California (VCA), ឬ សេចក្តីព្រាងច្បាប់របស់ព្រឹទ្ធសភា (SB) 450 (Allen, D-26) ត្រូវបានអនុម័តកាលពីថ្ងៃទី29 ខែកញ្ញា ឆ្នាំ 2016 ដោយធ្វើការបន្ថែមនូវផ្នែក 4005 ទៅដល់ការបោះឆ្នោត California, ធ្វើការអនុញ្ញាតដល់ខោនធីទាំងឡាយដែលទទួលបានការអនុញ្ញាតផ្អែកលើការយល់ព្រមរបស់គណៈកម្មការអ្នកគ្រប់គ្រង ដើម្បីរៀបចំការបោះឆ្នោតណាមួយតាមសំបុត្រដោយភ្ជាប់ជាមួយនឹង លក្ខខណ្ឌតម្រូវជាក់លាក់នានា។ ស្ថិតក្រោមច្បាប់ VCA អ្នកបោះឆ្នោតទាំងអស់គប្បីត្រូវផ្ញើសន្លឹកឆ្នោតចាប់ផ្តើម 29 ថ្ងៃមុនការបោះឆ្នោត ហើយ ខោនធីនីមួយៗដោយទទួលយកនូវធាតុចូលពីសាធារណជន គប្បីបង្កើតឲ្យមានទីតាំងទម្លាក់សន្លឹកឆ្នោត និង មណ្ឌលបោះឆ្នោតនៅទូទាំងខោនធី ដែលអ្នកបោះឆ្នោតអាចនឹងបោះបាន។ ការធ្វើច្បាប់នេះគឺជាផ្នែកមួយនៃការធ្វើកំណែទម្រង់ការបោះឆ្នោត ដើម្បីផ្លាស់ប្តូររបៀបរៀបចំការបោះឆ្នោត ដើម្បីបង្កើនការចូលរួមរបស់អ្នកបោះឆ្នោត និង ភ្ជាប់ទំនាក់ទំនងជាមួយអ្នកបោះឆ្នោតដោយធ្វើការពង្រីកនូវជម្រើសរបស់អ្នកបោះឆ្នោត។

មុនមានច្បាប់ VCA ការបោះឆ្នោតត្រូវបានធ្វើឡើងទៅតាមការិយាល័យបោះឆ្នោតគំរូតាមបែបប្រពៃណី។ នេះគឺជាប្រភេទគំរូរួមនៃការបោះឆ្នោតតាមសំបុត្រនិងរដ្ឋបាលការិយាល័យបោះឆ្នោត។ ក្រមបោះឆ្នោត §12261(a) បានកំណត់ដល់មន្ត្រីបោះឆ្នោតនៅតាមខោនធីឲ្យបង្កើតមណ្ឌលបោះឆ្នោតដោយមានអ្នកបោះឆ្នោតអតិបរមា 1,000 នាក់ ហើយមណ្ឌលនីមួយៗត្រូវតែមានទីតាំងបោះឆ្នោតខុសៗគ្នា (ដែលត្រូវដើរតួជាទិន្នន័យអាចឲ្យខោនធី និងរដ្ឋរាយការណ៍ពីលទ្ធផលបោះឆ្នោតដោយមណ្ឌលបោះឆ្នោតនីមួយៗផងដែរ)។ មានតែមណ្ឌលដែលនៅមានកម្រិតជារូបវន្តទាំងនោះទេ ដែលអាចដាក់បញ្ចូលទៅក្នុងបញ្ជីនៃអ្នកបោះឆ្នោតតាមសំបុត្រអចិន្ត្រៃយ៍បាន ។ មណ្ឌលផ្សេងដែលចង់បោះឆ្នោតតាមសំបុត្រត្រូវដាក់ពាក្យសុំស្នើនៅពេលបោះឆ្នោតម្តងៗ។ អ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតតាមសំបុត្រតម្រូវឲ្យបោះឆ្នោតនៅតាមទីតាំងបោះឆ្នោតតាមការកំណត់របស់គេ ដែលស្ថិតនៅផ្សេងពីបរិវេណបោះឆ្នោតនិងប្រភេទសន្លឹកឆ្នោតរបស់គេ។

នៅក្នុងឆ្នាំ 2002 ការបោះឆ្នោត California បានពង្រីកវិសាលភាពឲ្យមានការបោះឆ្នោតតាមសំបុត្រ និងបានអនុញ្ញាតឲ្យបុគ្គលគ្រប់គ្នាក្លាយជាអ្នកបោះឆ្នោតតាមសំបុត្រអចិន្ត្រៃយ៍។ ការពង្រីកវិសាលភាពនេះ បានបង្កើតឲ្យមានការផ្លាស់ប្តូរនៅក្នុងឥរិយាបថអ្នកបោះឆ្នោត ដែលបច្ចុប្បន្ននេះអ្នកបោះឆ្នោតភាគច្រើន ស្ថិតនៅក្នុងខោនធី Santa Clara កំពុងត្រូវបានស្នើសុំបោះឆ្នោត ដោយវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតដែលបានកំណត់។ អ្នកទាំងនោះដែលបានចុះឈ្មោះជាអ្នកបោះឆ្នោតតាមសំបុត្រអចិន្ត្រៃយ៍ ត្រូវបានផ្ញើជូននូវសន្លឹកឆ្នោតប្រមាណជា 29 ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយមានពេលរហូតដល់បិទបញ្ចប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដើម្បីផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោត មិនថាស្ថិតនៅតាមការិយាល័យបោះឆ្នោត ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត ឬ ដោយតាមសំបុត្រនោះទេ ។

ដោយការអនុវត្តច្បាប់ VCA ការបោះឆ្នោតនឹងត្រូវធ្វើឡើងតាមគំរូថ្មីនៅមណ្ឌលបោះឆ្នោត។ ជាមួយនឹងគំរូថ្មី *គ្រប់*អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះជាអ្នកបោះឆ្នោតតាមសំបុត្រ ហើយទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រនោះ ចាប់ផ្តើម 29 ថ្ងៃមុនកាលវិភាគបោះឆ្នោត។ អ្នកបោះឆ្នោតអាចនឹងផ្ញើសន្លឹកឆ្នោតរបស់គេ ត្រឡប់មកវិញតាមវិធីណាមួយក្នុងវិធីបី៖ តាមប្រៃសណីយ៍ (បានបង់ថ្លៃប្រៃសណីយ៍) តាមទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយ ឬ នៅតាមមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធី។ អ្នកបោះឆ្នោតក៏អាចជ្រើសរើសមិនផ្ញើសន្លឹកឆ្នោតរបស់គេត្រឡប់មកវិញតាមប្រៃសណីយ៍ក៏បាន ហើយជំនួសឲ្យការទទួលបានសន្លឹកបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមការិយាល័យរបស់មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោត (ROV) ឬ នៅតាមមណ្ឌលបោះឆ្នោត *ណាមួយ* នៅក្នុងខោនធី Santa Clara។

គំរូមណ្ឌលបោះឆ្នោតនឹងមិនផ្លាស់ប្តូរច្រើនទេសម្រាប់អ្នកបោះឆ្នោតតាមសំបុត្រអចិន្ត្រៃយ៍នាពេលបច្ចុប្បន្ននេះ ។ វាផ្លាស់ប្តូរជាសំខាន់តែទៅលើនីតិវិធីសម្រាប់អ្នកបោះឆ្នោត ដែលគួរតែទៅកាន់ទីតាំងបោះឆ្នោតដែលបានកំណត់របស់ខ្លួននៅថ្ងៃបោះឆ្នោតដើម្បីបោះឆ្នោត។ បច្ចុប្បន្ននេះ ជាជាងឲ្យអ្នកបោះឆ្នោតមានទីតាំងទៅបោះឆ្នោតតែមួយកន្លែងនោះ មណ្ឌលបោះឆ្នោតនឹងបើកទ្វារទទួលអ្នកបោះឆ្នោត *ទាំងអស់* ដែលបានចុះឈ្មោះនៅក្នុងខោនធី។

ផែនការរដ្ឋបាលការបោះឆ្នោត (EAP) នេះដាក់បញ្ចូលនូវខ្លឹមសារចាំបាច់ដើម្បីស្វែងយល់ពីផលប៉ះពាល់ដែលនឹងកើតការផ្លាស់ប្តូរនេះ។ ក្រោយពីពង្រាង EAP ត្រូវបានបញ្ចប់ ROV នឹងស្នើសុំមតិសាធារណៈ មតិត្រឡប់ និងសំណូមពរនានាមុននឹងបិទបញ្ចប់ផែនការនេះ។ ដោយធ្វើការបិទផ្សាយពីពង្រាងដែលត្រូវបានធ្វើការកែសំរួលជាបន្តបន្ទាប់នីមួយៗនោះ សាធារណៈជននឹងត្រូវផ្តល់នូវរយៈពេលផ្តល់មតិជាសាធារណៈ ដើម្បីផ្តល់មតិត្រឡប់អំពី EAP និងការកែសំរួល រួមទាំងទីតាំងដែលត្រូវបានជ្រើសរើសជាមណ្ឌលបោះឆ្នោត និង ទីតាំងទម្លាក់សន្លឹកឆ្នោតផងដែរ។ ក្រោយបញ្ចប់រយៈពេលផ្តល់មតិពីសាធារណៈជនរួចមក ផែនការ EAP ចុងក្រោយរបស់ខោនធីនឹងត្រូវទទួលយកជាផ្លូវការ ហើយបញ្ជូនទៅកាន់រដ្ឋលេខាធិការនៃរដ្ឋ California (SOS) ដើម្បីធ្វើការអនុម័ត។

ដើម្បីឲ្យកាន់តែប្រាកដថាសហគមន៍ត្រូវបានផ្តល់ព័ត៌មានយ៉ាងទូលំទូលាយពីការផ្លាស់ប្តូរទៅច្បាប់ VCA នោះ ROV បានបង្កើតទាំងគណៈកម្មការទទួលបានការប្រឹក្សាពីការបោះឆ្នោត (VAAC) និង គណៈកម្មាធិការប្រឹក្សាផ្នែកភាសា (LAAC)។ គោលបំណងរបស់ VAAC គឺដើម្បីផ្តល់ប្រឹក្សា ផ្តល់ជំនួយ និងផ្តល់អនុសាសន៍ទាក់ទងការចូលរួមដំណើរការបោះឆ្នោតដោយមនុស្សចាស់ជរា និងបុគ្គលមានពិការភាព។ បេសកកម្មរបស់ VAAC គឺត្រូវផ្តល់ដល់អ្នកបោះឆ្នោតទាំងអស់នូវឱកាសបោះឆ្នោតដោយឯករាជ្យនិងដាច់ដោយឡែក។ គោលបំណងរបស់ LAAC គឺត្រូវផ្តល់ឱវាទ ផ្តល់ជំនួយ និងផ្តល់អនុសាសន៍ពីបញ្ហាពាក់ព័ន្ធនឹងការទទួលបានជំនួយផ្នែកភាសាចំពោះដំណើរការបោះឆ្នោត ដោយអ្នកបោះឆ្នោតដែលនិយាយភាសាជាចម្បងដែលមិនមែនជាភាសាអង់គ្លេស។ វាជាបេសកកម្មរបស់ LAAC ដើម្បីជួយជម្រុញឲ្យទទួលបានឱកាសជំនួយផ្នែកភាសា។ គណៈកម្មាធិការទាំងពីរផ្តល់ការណែនាំដ៏សំខាន់ដល់ ROV និងជាធាតុផ្សំគន្លឹះទាំងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត និងរដ្ឋបាលបោះឆ្នោតសម្រាប់ខោនធី។ ROV ទទួលយកពាក្យសុំចូលជាសមាជិកទាំងពីរសម្រាប់ LAAC ឬ VAAC ជាប្រចាំ។ ដើម្បីដាក់ពាក្យសុំចូលជាសមាជិកមកកាន់គណៈកម្មការទាំងពីរបាន ពាក្យសុំអាចរកបាននៅលើគេហទំព័ររបស់ ROV៖ www.sccvote.org/voterschoice។

ROV ក៏មានគម្រោងបង្កើតនូវសម្ព័ន្ធភាពអប់រំនិងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ដើម្បីពង្រីកនូវកម្មវិធីអប់រំដល់អ្នកបោះឆ្នោតរបស់ខ្លួន ដើម្បីជូនដំណឹងដល់ពលរដ្ឋក្នុងលំនៅដ្ឋានអំពី VCA និងឱកាសសម្រាប់ការចូលរួមរបស់សហគមន៍ ។ EAP រួមបញ្ចូលនូវព័ត៌មានត្រឡប់និងព័ត៌មានពីគណៈកម្មាធិការទាំងនេះ និងព្រមទាំងអង្គការដៃគូនានាផ្សេងទៀត។ ការទទួលបានការគាំទ្រពីសហគមន៍នឹងមានសារៈសំខាន់ដល់ការអនុវត្ត VCA ឲ្យបានជោគជ័យ ហើយវិធីសាស្ត្រថ្មីរបស់រដ្ឋបាលបោះឆ្នោតនៅក្នុងខោនធី Santa Clara ។

ការបោះឆ្នោតលើកដំបូងនឹងត្រូវរៀបចំឡើងក្រោមនៅច្បាប់ VCA គឺការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីនៅថ្ងៃទី 3 ខែមីនា ឆ្នាំ 2020 ។ ឯកសារនេះផ្តល់ការណែនាំដល់ខោនធី Santa Clara ពីរបៀបធ្វើផែនការដើម្បីអនុវត្តច្បាប់ VCA សម្រាប់ការបោះឆ្នោតនេះ និងការបោះឆ្នោតនៅពេលអនាគត។ ដើម្បីជាឯកសារយោង រាល់វាក្យសព្ទបច្ចេកទេស ឬការជាក់លាក់ក្នុងការបោះឆ្នោត នឹងត្រូវផ្តល់និយមន័យនៅក្នុងសន្ទានុក្រមនៅក្នុងសេចក្តីបន្ថែម A និងបញ្ជីសំណួរដែលគេសួរជាញឹកញាប់អាចរកបាននៅក្នុងសេចក្តីបន្ថែម R។

# ផ្នែកទី 1 – ផែនការគ្រប់គ្រងការបោះឆ្នោតរដ្ឋបាល

ខោនធីនីមួយៗដែលកំពុងអនុវត្តច្បាប់ស្ដីពីការជ្រើសរើសរបស់អ្នកបោះឆ្នោត (VCA) ត្រូវធ្វើពង្រាងផែនការរដ្ឋបាលបោះឆ្នោត (EAP) ដោយមានព័ត៌មានចាំបាច់នានាដើម្បីស្វែងយល់ពីការដែលការផ្លាស់ប្ដូរជះឥទ្ធិពលមកលើអ្នកបោះឆ្នោត។ EAP នឹងត្រូវបែងចែកជាពីរផ្នែក៖ ផ្នែកទី 1 - ផែនការបោះឆ្នោត និងផ្នែកទី 2 - ផែនការអប់រំ និង ការផ្សព្វផ្សាយ។

## ដំណើរការបោះឆ្នោតតាមសំបុត្រ (VBM)

EAP បានដាក់បញ្ចូលនូវព័ត៌មានស្ដីអំពីមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោត និង ម៉ោងធ្វើការ ការបង្កើតទាំងគណៈកម្មការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC) និងគណៈកម្មការទទួលបានការប្រឹក្សាបោះឆ្នោត (VAAC) ផែនការអប់រំនិងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ធាតុចូលពីសាធារណជន និង ការបង្ហាញឲ្យមានការពិចារណា និងខ្លឹមសារពាក់ព័ន្ធផ្សេងទៀត។

នៅតាមមណ្ឌលបោះឆ្នោតគំរូ អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះរួច នោះនិងក្លាយជាអ្នកបោះឆ្នោតតាមសំបុត្រហើយនឹងត្រូវបានបញ្ជូនកញ្ចប់បោះឆ្នោតទៅតាមប្រៃសណីយ៍។ កញ្ចប់បោះឆ្នោតនឹងត្រូវបានបញ្ជូនទៅកាន់អ្នកបោះឆ្នោតនៅក្នុងស្រោមសំបុត្រពណ៌ស ដែលនឹងផ្ទុកនូវឯកសារដូចខាងក្រោម៖

- ស្រោមស្រោមសំបុត្រពណ៌ខៀវសម្រាប់ផ្ញើបញ្ជូនត្រឡប់មកវិញ
- សន្លឹកឆ្នោតផ្លូវការ ដែលអាចមានកាតសន្លឹកឆ្នោតជាច្រើន អាស្រ័យទៅលើចំនួននៃការប្រកួតសម្រាប់ការបោះឆ្នោត
- ក្រដាសមួយសន្លឹកស្ដីពីការណែនាំអំពីរបៀបបំពេញ និងផ្ញើសន្លឹកឆ្នោតត្រឡប់មកវិញ
- ក្រដាសមួយសន្លឹកដោយមានព័ត៌មានអំពីទីតាំងមណ្ឌលបោះឆ្នោត & ប្រអប់ទម្លាក់សន្លឹកឆ្នោត និងម៉ោងធ្វើការ
- ស្ទីកឃឺដែលសរសេរថា "ខ្ញុំបានបោះឆ្នោតហើយ"
- ក្រដាសមួយសន្លឹកបន្ថែមទៀតមានផ្ទុកព័ត៌មានបន្ថែម ប្រសិនបើចាំបាច់នោះ

សន្លឹកឆ្នោតទាំងអស់នឹងត្រូវផ្ញើតាមសេវាប្រៃសណីយ៍ United States ចាប់ផ្ដើមឡើងក្នុងរយៈពេល 29 ថ្ងៃ មុនថ្ងៃបោះឆ្នោត។ អ្នកបោះឆ្នោតគួរចាប់ផ្ដើមទទួលបាននូវកញ្ចប់កញ្ចប់ឆ្នោតតាមប្រអប់សំបុត្រចាប់ពីក្រោយពេលនោះតទៅ។

ក្រោយពីពួកគេបានបំពេញសន្លឹកឆ្នោតតាមសំបុត្ររួចរាល់ហើយ អ្នកបោះឆ្នោតនឹងអាចសន្លឹកឆ្នោតរបស់គេត្រឡប់មកវិញតាមសំបុត្រធម្មតាដាក់ក្នុងស្រោមសំបុត្រផ្តល់ជូនដែលមានបិទតែមបង់ថ្លៃរួច ឬ ដោយការផ្ញើសន្លឹកឆ្នោតត្រឡប់ទៅកាន់មណ្ឌលបោះឆ្នោត ឬ ទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយក៏បានដែរ។ មណ្ឌលបោះឆ្នោតទាំងអស់នឹងដើរតួជាទីតាំងទម្លាក់សន្លឹកឆ្នោត ខណៈដែលទីតាំងទម្លាក់សន្លឹកឆ្នោតមួយចំនួននឹងស្ថិតនៅដាច់តែឯង ហើយត្រូវបានបោះទីតាំងនៅជុំវិញខោនធីទៅតាមតំបន់ដែលបានកំណត់។

ប្រសិនបើអ្នកបោះឆ្នោតមិនបានទទួលបានសន្លឹកឆ្នោតទាន់ពេល ឬ ក្នុងករណីពួកគេធ្វើឲ្យមានកំហុសនៅលើសន្លឹកឆ្នោតរបស់គេ ពួកគេអាចស្នើសុំប្ដូរសន្លឹកឆ្នោតរបស់គេនោះបាន ។ កញ្ចប់បោះឆ្នោតតាមសំបុត្រថ្មីនឹងត្រូវផ្ញើទៅពួកគេដោយមានសន្លឹកឆ្នោតថ្មីមកជាមួយ ។ ប្រសិនបើពួកគេត្រូវការប្ដូរសន្លឹកឆ្នោតថ្មីក្នុងរយៈពេលតិចជាងប្រាំពីរថ្ងៃ មុនថ្ងៃបោះឆ្នោតនោះ ពួកគេនឹងត្រូវទៅកាន់ការិយាល័យមន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត (ROV) ឬ ទៅកាន់មណ្ឌលបោះឆ្នោតណាមួយក៏បានដើម្បីទទួលយកសន្លឹកឆ្នោតថ្មី ។

ចំពោះអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ដែលនិយាយភាសាចម្បងមែនជាភាសាអង់គ្លេសនោះ សន្លឹកឆ្នោតនឹងមានធ្វើជាប្រាំបីភាសា៖ ភាសាចិន, ភាសាអេស្ប៉ាញ,ភាសាតាកាឡុក, ភាសាវៀតណាម, ភាសាខ្មែរ, ភាសាកូរ៉េ, ភាសាហ៊ីនឌី, និងភាសាជប៉ុន។ ក្នុងចំណោមភាសាទាំងនេះ អ្នកបោះឆ្នោតអាចបញ្ជាក់ពីភាសាដែលគេពេញចិត្តនៅលើទម្រង់ចុះឈ្មោះនៅពេលគេចុះឈ្មោះបោះឆ្នោត។ សន្លឹកឆ្នោតនិងឯកសារបោះឆ្នោតផ្ញើតាមប្រៃសណីយ៍នឹងត្រូវបញ្ជូនទៅកាន់ពួកគេជាភាសាដែលគេពេញចិត្ត។ អ្នកបោះឆ្នោតក៏អាចស្នើសុំផ្លាស់ប្តូរភាសាដែលគេពេញចិត្តបានដែរដែរ ដោយធ្វើការទាក់ទងមកកាន់ការិយាល័យ ROV តាមទូរសព្ទ ((408) 299-VOTE), ទូរស័ព្ទ ((408) 998-7314), អ៊ីម៉ែល (voterinfo@rov.sccgov.org), ដោយផ្ទាល់ ឬ តាមរយៈទម្រង់ស្នើសុំសកម្មភាពបោះឆ្នោត (VARF)។ អ្នកបោះឆ្នោតអាចមកយកទម្រង់ VARF នៅការិយាល័យ ROV ឬ វាអាចត្រូវបានផ្ញើតាមអ៊ីម៉ែល, ទូរស័ព្ទ ឬ ផ្ញើតាមប្រៃសណីយ៍ទៅកាន់ពួកគេ។ ជាការជំនួស VARF អាចរកបាននៅលើគេហទំព័រ ROV ហើយក៏អាចរកបាននៅក្នុងសេចក្តីណែនាំព័ត៌មានស្តីអំពីការបោះឆ្នោត (CVIG) ។

## ការបោះឆ្នោតដែលអាចធ្វើបានតាមសំបុត្រ

អ្នកបោះឆ្នោតក៏អាចស្នើសុំឯកសារបោះឆ្នោតក្នុងទម្រង់ដែលអាចប្រើបានដោយធ្វើការទាក់ទងទៅកាន់ការិយាល័យ ROV ។ ក្រោយពីអ្នកបោះឆ្នោតធ្វើសំណើសុំនោះរួចមក ពួកគេត្រូវបានដាក់ចូលទៅក្នុងបញ្ជីឈ្មោះអចិន្ត្រៃយ៍ ហើយនឹងអាចទទួលបានឯកសារបោះឆ្នោតដែលត្រូវបានផ្ញើឲ្យពួកគេគ្រប់ការបោះឆ្នោត។ ពួកគេត្រូវដកចេញពីបញ្ជីឈ្មោះតែក្នុងករណីដែលពួកគេអសកម្ម ប្តូរចេញពីខោនធី មាននៅលើបញ្ជីឈ្មោះជនប្រព្រឹត្តិបទឧក្រិដ្ឋ ឬ ទទួលមរណភាពតែប៉ុណ្ណោះ។

ជម្រើសដែលគេអាចទទួលបានមួយទៀតដែលអ្នកបោះឆ្នោតអាចស្នើសុំបាននោះគឺត្រូវប្រើប្រព័ន្ធបោះឆ្នោតតាមសំបុត្រដែលអាចចូលបានពីចម្ងាយ (RAVBM) ។ ប្រព័ន្ធ RAVBM ត្រូវបានកំណត់សម្រាប់ការប្រើប្រាស់សម្រាប់តែអ្នកដែលបានចុះឈ្មោះរួចដោយមានពិការភាព ក៏ដូចជាសម្រាប់តែយោធានិងអ្នកបោះឆ្នោតនៅក្រៅប្រទេសប៉ុណ្ណោះ[1] ។ គោលបំណងនៃប្រព័ន្ធ RAVBM គឺមិនមែនដើម្បីបោះឆ្នោតតាមអ៊ីនធើណិតទេ ។ អ្នកបោះឆ្នោតតាម RAVBM ត្រូវបានផ្ញើអ៊ីម៉ែលទៅឲ្យដោយមានតំណភ្ជាប់ ដើម្បីចូលទៅកាន់សន្លឹកឆ្នោតផ្លូវការ ព្រមទាំងសេចក្តីណែនាំនានាអំពីពីរបៀបទាញយកសន្លឹកឆ្នោត ព្រីន ចេញបំពេញ និងផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតរបស់គេមកកាន់ ROV ឲ្យបានត្រឹមថ្ងៃបោះឆ្នោត ។ ដោយប្រើប្រាស់តំណភ្ជាប់ អ្នកបោះឆ្នោតត្រូវទាញយកសន្លឹកឆ្នោតទៅកាន់ឧបករណ៍អេឡិចត្រូនិករបស់ខ្លួនដើម្បីអាន និងគូសលើសន្លឹកឆ្នោតរបស់ខ្លួនទៅតាមលក្ខណៈលទ្ធភាពដែលអាចចូលប្រើបាស់រៀងៗខ្លួន ។ ដូចគ្នាទៅនឹងអ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយដែរ មានមធ្យោបាយបីយ៉ាងដែលអ្នកបោះឆ្នោត RAVBM អាចផ្ញើត្រឡប់មកវិញនូវសន្លឹករបស់គេបាន៖ តាមសំបុត្រធម្មតា ដោយការទម្លាក់សន្លឹកឆ្នោតរបស់គេនៅតាមប្រអប់ទម្លាក់សន្លឹកឆ្នោត ឬ ដោយការបញ្ជូនត្រឡប់មកកាន់មណ្ឌលបោះឆ្នោតណាមួយក៏បាន ។

1 សូមមើលទៅលើក្រមបោះឆ្នោត California §303.3

មិនថាការជ្រើសរើសយកវិធីបញ្ជូនមកវិញណាមួយទេ សន្លឹកឆ្នោតត្រូវតែផ្ញើមកវិញដាក់ក្នុងស្រោមសំបុត្រ ។ សូមណែនាំដល់អ្នកបោះឆ្នោតថា សូមប្រើស្រោមសំបុត្រពណ៌ខៀវបញ្ជូនត្រឡប់ដែលត្រូវបានដាក់បញ្ចូលក្នុងស្រោមសំបុត្របោះឆ្នោតតាមសំបុត្ររបស់ពួកគេ ។ ពួកគេស្នើសុំស្រោមសំបុត្រផ្ញើត្រឡប់សន្លឹកឆ្នោតជំនួសថ្មីបាន ដោយទូរសព្ទមកកាន់ប្រព័ន្ធឥតគិតថ្លៃរបស់ ROV តាមលេខ (866) 430-8683 ឬ អាចមកយកដោយផ្ទាល់នៅការិយាល័យ ROV ឬ នៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន ។ ស្រោមសំបុត្របញ្ជូនសន្លឹកឆ្នោតត្រឡប់ជំនួសថ្មីនឹងមាននៅតាមប្រអប់ទម្លាក់សន្លឹកឆ្នោតផងដែរ ។ អ្នកបោះឆ្នោតក៏អាចជ្រើសរើសប្រើស្រោមសំបុត្រផ្ទាល់ខ្លួនបានផងដែរ ប៉ុន្តែត្រូវតែដាក់មកជាមួយនូវទំព័រសម្បថរបស់អ្នកបោះឆ្នោតដែលបានចុះហត្ថលេខា និងព្រីនភ្ជាប់មកជាមួយនឹងសន្លឹកឆ្នោតរបស់ពួកគេ ។ ទំព័រពាក្យសម្បថរបស់អ្នកបោះឆ្នោត ព្រមទាំងសន្លឹកឆ្នោត ត្រូវទាញយកពីតំណភ្ជាប់ក្នុងអ៊ីម៉ែល RAVBM ។ ប្រសិនបើការបញ្ជូនសន្លឹកឆ្នោតរបស់អ្នកផ្ញើឡើងតាមសំបុត្រធម្មតា ស្រោមសំបុត្របញ្ជូនសន្លឹកឆ្នោតត្រឡប់ពណ៌ខៀវមិនតម្រូវឲ្យមានបិទតែមអ្វីឡើយ ខណៈដែលការបញ្ជូនត្រឡប់មកវិញដោយប្រើស្រោមសំបុត្រផ្ទាល់ខ្លួនត្រូវមានបិទតែមគ្រប់គ្រាន់ ។

សម្រាប់អ្នកបោះឆ្នោតដែលកំពុងស្នាក់នៅមន្ទីរពេទ្យនិងមានពិការភាព ក៏ដូចជាអ្នកបោះឆ្នោតដែលត្រូវស្ថិតនៅក្នុងផ្ទះដោយសារភាពបន្ទាន់ផ្នែកវេជ្ជសាស្ត្រ នីតិវិធីបញ្ជូនសន្លឹកឆ្នោតបន្ទាន់ត្រូវបានប្រើប្រាស់នៅពេលអ្នកបោះឆ្នោតត្រូវការសន្លឹកឆ្នោត និងមិនអាចទាញយកសន្លឹកឆ្នោតរបស់ខ្លួនដោយផ្ទាល់បាន ។ ពាក្យស្នើសុំបោះឆ្នោតមុនកាលកំណត់ (ឧបសម្ព័ន្ធ B) តម្រូវឲ្យបំពេញ និងផ្ញើត្រឡប់មកវិញ ដើម្បីផ្ទៀងផ្ទាត់ពីបច្ចុប្បន្នភាពការចុះឈ្មោះ និងហត្ថលេខា ដោយផ្ទៀងផ្ទាត់តាមរយៈប្រព័ន្ធគ្រប់ព័ត៌មានបោះឆ្នោត (EIMS) របស់ ROV ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះត្រូវបំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទនៅលើការបោះឆ្នោតមុនកាលកំណត់ ។ ប្រសិនបើអ្នកបោះឆ្នោតមិនអាចចុះហត្ថលេខាលើពាក្យស្នើសុំរបស់ខ្លួនបានទេនោះ ឲ្យនរណាម្នាក់ដែលអាចជួយអ្នកបោះឆ្នោតដោយគូស “X” ។ អ្នកតំណាងជួយដល់អ្នកបោះឆ្នោតគួរសរសេរ "ត្រូវបានធ្វើជាសាក្សីដោយ" និងសរសេរឈ្មោះ និងចុះហត្ថលេខារបស់គេ និងផ្ញើត្រឡប់មកវិញនូវពាក្យស្នើសុំបោះឆ្នោតមុនកាលកំណត់ទៅកាន់ការិយាល័យកណ្តាលរបស់ ROV នៅលើផ្លូវ Berger Drive ។ ការិយាល័យ នឹងផ្ទៀងផ្ទាត់ព័ត៌មានអ្នកបោះឆ្នោត និងហត្ថលេខានៅក្នុង EIMS និងនៅពេលផ្ទៀងផ្ទាត់រួច សន្លឹកឆ្នោតអាចត្រូវចេញជូនដល់អ្នបោះឆ្នោត និងកញ្ចប់បោះឆ្នោតតាមសំបុត្រពេញលេញមួយត្រូវរៀបចំឡើង ។ អ្នកតំណាងជួយដល់អ្នកបោះឆ្នោតនៅពេលនោះ អាចយកសន្លឹកឆ្នោតទៅឲ្យអ្នកបោះឆ្នោតទៅតាមទីតាំងរបស់គេ ។ នៅពេលបំពេញចប់សព្វគ្រប់ សន្លឹកឆ្នោតអាចត្រូវផ្ញើត្រឡប់ទៅការិយាល័យកណ្តាលរបស់ ROV, មណ្ឌលបោះឆ្នោត ឬ ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតណាមួយ ដើម្បីដំណើរការរួមជាមួយនឹងសន្លឹកឆ្នោតបោះតាមសំបុត្រផ្សេងទៀត ។

អ្នកបោះឆ្នោតដែលជាប់ឃុំឃាំងនៅក្នុងពន្ធនាគារខោនធីក៏អាចប្រើនីតិវិធីបញ្ជូនសន្លឹកឆ្នោតបន្ទាន់បានដែរ ។ អ្នកបោះឆ្នោតដែលជាប់ឃុំឃាំងនៅក្នុងពន្ធនាគាររដ្ឋឬសហព័ន្ធមិនមានសិទ្ធិកំណត់ដោយច្បាប់ឲ្យបោះឆ្នោតបានឡើយ ។

# ទីតាំងទម្លាក់សន្លឹកឆ្នោត

យោងទៅតាមរបាយការណ៍ក្នុងការចុះឈ្មោះបោះឆ្នោតខែកុម្ភៈ ឆ្នាំ 2019 ចេញដោយរដ្ឋលេខាធិការ (SOS) ចំនួនប្រជាជនអ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងខោនធី Santa Clara មានប្រមាណជា 1.2 លាននាក់ ។ បច្ចុប្បន្ននេះ ប្រមាណជា 910,000 នាក់នៅក្នុងខោនធីដែលបានចុះឈ្មោះបោះឆ្នោត ។ ROV ប្រមើលមើលថា ចំនួនអ្នកចុះឈ្មោះបោះឆ្នោតនឹងកើនឡើងដល់ 1 លាននាក់ត្រឹមការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីនៅខែមីនា ឆ្នាំ 2020 ។ ការប្រើប្រាស់ចំនួននេះ ក្រមបោះឆ្នោត California ដាក់កំហិតឲ្យខោនធីត្រូវផ្តល់ទីតាំងទម្លាក់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោត៖

យ៉ាងហោចណាស់ត្រូវមាន (1)ទីតាំងទម្លាក់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលចុះឈ្មោះរួចចំនួនរាល់15,000 នាក់ ដោយមានរយៈពេល 28 ថ្ងៃ មុនថ្ងៃបោះឆ្នោតហើយរួមទាំងថ្ងៃបោះឆ្នោតផងដែរមានចំនួនសរុបទាំងអស 29 ថ្ងៃ។ សូមមើលសេចក្តីបន្ថែម C សម្រាប់ផែនទីនៃព្រំប្រទល់ទីតាំងទម្លាក់សន្លឹកឆ្នោត។

ប្រើប្រាស់ចំនួនអ្នកដែលបានចុះឈ្មោះបោះឆ្នោតដែលត្រូវបានប្រមើលមើលដោយ (ROV) យ៉ាងតិចបំផុតក៏ត្រូវការទីតាំងទម្លាក់សន្លឹកឆ្នោតយ៉ាងតិចបំផុតដែលត្រូវតែមាន 67 កន្លែងដែរ ។ ROV គម្រោងផែនការឲ្យមានទីតាំងទម្លាក់សន្លឹកឆ្នោតមួយនៅគ្រប់មណ្ឌលសរុបឱ្យមានទីតាំងប្រអប់ឆ្នោតគោលដៅចំនួន 91 ។ សូមមើលឧបសម្ព័ន្ធ D សម្រាប់បញ្ជីថ្មីនៃទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតដែលត្រូវបានស្នើឡើង ហើយនិងម៉ោងនៃប្រតិបត្តិការទៅតាមទីតាំងរបស់គេ។

| ផ្នែកព្រំប្រទល់ | លក្ខខណ្ឌតម្រូវជាអប្បបរមា | ចំនួន[2] ដែលបានស្នើឡើង |
|---|---|---|
| ទីតាំងទម្លាក់សន្លឹកឆ្នោត (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 15k) | 67 | 91 |

ដើម្បីកំណត់ទីតាំងណាប្រសើរបំផុតសម្រាប់ដាក់ប្រអប់ទម្លាក់សន្លឹកឆ្នោតនោះ ROV បានប្រើប្រាស់លក្ខខណ្ឌចំនួន 14 ដែលត្រូវបានកំណត់ដោយ SOS និងក្រមបោះឆ្នោតដើម្បីជួយកំណត់ទៅលើទីតាំងប្រសើរបំផុតសម្រាប់ទីតាំង មណ្ឌលបោះឆ្នោត ។ លក្ខខណ្ឌតម្រូវទាំង 14 ជួយដល់ ROV ក្នុងការផ្តល់ឲ្យខោនធីនូវទីតាំងដែលងាយស្រួលចេញចូលបំផុតដែលមានសម្រាប់ដាក់ប្រអប់ទម្លាក់សន្លឹកឆ្នោតផងដែរ។ លក្ខខណ្ឌតម្រូវរួមមាន៖

1. ទីតាំងស្ថិតនៅជិតមធ្យោបាយធ្វើដំណើរសាធារណ
2. ទីតាំងនៅជិតសហគមន៍ប្រើប្រាស់ការការបោះឆ្នោតតាមរយៈសំបុត្រដែលមានចំនួនតិច
3. ទីតាំងនៅជិតមជ្ឈមណ្ឌលប្រមូលផ្តុំប្រជាជន
4. ទីតាំងនៅជិតសហគមន៍ភាសាភាគតិច
5. ទីតាំងនៅជិតកន្លែងសម្រាប់អ្នកបោះឆ្នោតចំពោះអ្នកដែលមានពិការភាព
6. ទីតាំងនៅជិតសហគមន៍ដែលមានអត្រាម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប

---

2ព្រំប្រទល់ដែលត្រូវព្រៀងឡើងដោយ ROV គឺផ្អែកទៅលើចំនួនប្រជាជនដែលត្រូវបានប៉ាន់ស្មាន ហើយក្នុងបំណងប្រើប្រាស់ជាគោលការណ៍ណែនាំ។ ចំនួនដែលត្រូវបានកំណត់ដោយ VCA គួរតែត្រូវបានគិតដល់ ដោយសារតែវាបម្រើឲ្យអ្នកបោះឆ្នោត "រហូតដល់ទៅ 15,000 នាក់"។ នេះមានន័យថា ចំនួនអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកនៅក្នុងព្រំប្រទល់នីមួយៗជានិច្ចកាលមិនបន្ថែមទៅលើចំនួនសរុបដែលត្រូវបានកំណត់ដោយ VCA នោះទេ។

7. ទីតាំងនៅជិតសហគមន៍ដែលមានប្រាក់ចំណូលតិច
8. ទីតាំងនៅជិតសហគមន៍ដែលមានអត្រាចុះឈ្មោះបោះឆ្នោតកម្រិតទាប
9. ទីតាំងនៅជិតតំបន់ប្រជាជនរស់នៅក្នុងភូមិសាស្ត្រដាច់ស្រយាល រួមទាំងតំបន់អភិរក្សជនជាតិដើមអាមេរិកផងដែរ
10. ទីតាំងងាយស្រួលចេញចូលបាន និងមានចំណតឥតគិតថ្លៃ
11. ចម្ងាយនិងពេលវេលាធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោត
12. តម្រូវការសម្រាប់វិធីផ្សេងទៀតសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព ដែលពុំអាចទទួលបាននូវការជ្រើសរើសនៃការបោះឆ្នោតតាមរយៈសំបុត្រ
13. លក្ខណៈចរាចរណ៍នៅក្បែរមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោត
14. សេចក្តីត្រូវការសម្រាប់មណ្ឌលបោះឆ្នោតចល័ត

ROV អនុលោមទៅតាមលក្ខខណ្ឌតម្រូវច្បាប់ស្តីពីជនអាមេរិកាំងដែលមានពិការភាព (ADA) សម្រាប់ប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការ សម្រាប់ការធ្វើដំណើរ និងដង់ស៊ីតេ ដើម្បីទទួលអ្នកបោះឆ្នោតដែលមានពិការភាពឲ្យបានកាន់តែប្រសើរ។ ប្រអប់ទម្លាក់សន្លឹកឆ្នោតនឹងត្រូវដាក់ទៅតាមទីតាំងរបស់គេចាប់ផ្តើមឡើង 29 ថ្ងៃ មុនថ្ងៃបោះឆ្នោត។ នៅត្រឹមថ្ងៃទី 27 មុនថ្ងៃបោះឆ្នោត ប្រអប់ទម្លាក់សន្លឹកឆ្នោតទាំងអស់គប្បីតម្លើង និងរៀបចំឲ្យបានរួចរាល់ដើម្បីប្រើប្រាស់ ។ ដើម្បីធានាឱ្យអ្នកបោះឆ្នោតទាំងអស់អាចចូលបានប្រអប់ទម្លាក់សន្លឹកឆ្នោតគប្បីត្រូវបានរចនាឡើងឲ្យមានមុខងារដូចខាងក្រោម[3]៖

- ដើម្បីការពារការបាក់បែកនិងចូលដោយគ្មានការអនុញ្ញាតនោះ ហិបទម្លាក់សន្លឹកឆ្នោតណាដែលដាក់នៅខាងក្រៅមិនមានដាក់បុគ្គលិកប្រចាំការនោះ ត្រូវសង់ពីសម្ភារៈដែលជាប់ធន់អាចទប់ទល់នឹងការបំផ្លេចបំផ្លាញ ការរុះរើ និងអាកាសធាតុអាក្រក់បាន។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវមានប្រហោងរន្ធបើកចំហ ដែលមិនធំល្មមឲ្យសន្លឹកឆ្នោតអាចត្រូវបានគេផ្លាស់ប្តូរដោយគ្មានការអនុញ្ញត ឬ ត្រូវយកចេញបាននោះទេ។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវបានរចនាឡើងតាមលក្ខណបច្ចេកទេសដែលការប៉ះពាល់ណាមួយដោយគ្មានការអនុញ្ញាតអាចផ្តល់ឲ្យឃើញនូវស្លាកស្នាមជាភស្តុតាង ដែលអាចឲ្យដឹងបានថាមានការប៉ះពាល់ដោយគ្មានការអនុញ្ញាតបានកើតឡើង។ មន្ត្រីបោះឆ្នោតអាចប្រើស្កុតបិទបង្ហាញភស្តុតាងពីការផ្លាស់ប្តូរដោយគ្មានការអនុញ្ញាតបានសម្រាប់គោលបំណងនានាផ្នែកនេះ។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវផ្តល់នូវស្លាកសញ្ញាបង្ហាញជាក់លាក់ឲ្យដឹងពីកន្លែងដែលសន្លឹកឆ្នោតត្រូវស៊កបញ្ចូល។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតនីមួយៗត្រូវបានកំណត់ផ្តល់ឲ្យជាចំនួនលេខសម្គាល់ជាពិសេស ដែលស្ថិតនៅចំពីលើហិបទម្លាក់សន្លឹកឆ្នោត ហើយត្រូវតែងាយស្រួលចំណាំ សម្រាប់អ្នកប្រមូលសន្លឹកឆ្នោតដែលត្រូវបានចាត់តាំង ក៏ដូចជាសាធារណជនផងដែរ។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវដាក់សញ្ញាសម្គាល់ឲ្យបានច្បាស់និងងាយស្រួលឃើញ ថាជា "ប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការ"។
- ផ្នែកខាងក្រៅនៃប្រអប់ទម្លាក់សន្លឹកឆ្នោត ត្រូវតែងាយស្រួលធ្វើប្រតិបត្តិការដោយមិនភ្ជាប់តឹង សង្កត់ ឬ ធ្វើឲ្យភ្លាត់កដៃឡើយ។
- ផ្នែកខាងក្រៅនៃប្រអប់ទម្លាក់សន្លឹកឆ្នោត ត្រូវឲ្យមានសម្ពៀតមិនលើសពីប្រាំ (5) ផោនឡើយ សម្រាប់ឲ្យអ្នកបោះឆ្នោតធ្វើប្រតិបត្តិការបាន។

---

[3] សូមមើលក្រមបោះឆ្នោត §20132

- ប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវតែអាចធ្វើប្រតិបត្តិការបាននៅកំពស់ដែលអាចឈោងដល់ក្នុងចន្លោះពី 15 ទៅ 48 អ៊ីញ ពីឥដ្ឋ ឬផ្ទាល់ដីសម្រាប់បុគ្គលប្រើប្រាស់ទោះជនពិការក៏អាចប្រើប្រាស់បាន (នេះនឹងមិនអនុវត្តចំពោះប្រអប់ទម្លាក់សន្លឹកឆ្នោត ដែលត្រូវប្រើដោយអ្នកបើកបរយានយន្តឡើយ)។
- ស្លាកសញ្ញាប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវតែជាប្រភេទពណ៌ខុសពីគេ ដែលផ្ទុយពីផ្ទៃខាងក្រោយ ហើយ "មិនត្រូវមានចំណាំង" ឡើយ។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតទាំងឡាយត្រូវតែរចនាឡើងតាមលក្ខណៈបច្ចេកទេសដែលសាធារណៈជននឹងយល់ថាពួកវាមានលក្ខណៈផ្លូវការនិងមានសន្តិសុខ។
- ប្រអប់ទម្លាក់សន្លឹកឆ្នោតនីមួយៗនៅទូទាំងខោនធី ទាំងមានបុគ្គលិកនិងគ្មានបុគ្គលិកចាត់តាំងឲ្យមើល ត្រូវតែមានលក្ខណៈដូចគ្នា ហើយត្រូវមានការរចនាដូចគ្នា កំណត់ពណ៌ ហើយមានស្លាកសញ្ញាដើម្បីឲ្យសាធារណៈជនងាយស្រួលចំណាំ។
- ហិបទម្លាក់សន្លឹកឆ្នោតផ្អែកទៅលើការប្រើប្រាស់និងតម្រូវការរបស់ខោនធី Santa Clara ។

ចំណុចសំខាន់ៗមួយចំនួនត្រូវចងចាំអំពីប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការៈ

- មិនត្រូវការបិទស្ដែមដើម្បីផ្ញើសន្លឹកឆ្នោតត្រឡប់មកទម្លាក់ក្នុងប្រអប់ទម្លាក់សន្លឹកឆ្នោតឡើយ។
- បោះឆ្នោតតាមរយៈសំបុត្រ សន្លឹកឆ្នោតនឹងមិនទទួលយកឡើយនៅក្រោយម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត។
  - ប្រអប់ទម្លាក់សន្លឹកឆ្នោតនឹងត្រូវចាក់សោនៅម៉ោង 8:00 យប់គត់នៅថ្ងៃបោះឆ្នោត។
  - ករណីលើកលែងតែមានក្នុងករណីដែលអ្នកបោះឆ្នោតស្ថិតនៅក្នុងតម្រង់ជួររួចហើយដើម្បីទម្លាក់សន្លឹកឆ្នោតរបស់គេ នៅពេលដែលមណ្ឌលបោះឆ្នោតបិទ ឬ ម៉ោងត្រូវបានបន្ថែមតាមបង្គាប់របស់តុលាការ។
- ការផ្លាស់ប្តូរប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការដោយគ្មានការអនុញ្ញាតគឺជាបទឧក្រិដ្ឋ។[4]។
- ការជូនដំណឹងនឹងត្រូវបិទនៅលើប្រអប់ទម្លាក់សន្លឹកឆ្នោតនីមួយៗ ដើម្បីផ្តល់ការណែនាំដល់មន្ត្រីបោះឆ្នោតក្នុងករណីប្រអប់បោះឆ្នោតពេញ ត្រូវបានផ្លាស់ប្តូរដោយគ្មានការអនុញ្ញាត ឬ ត្រូវបានធ្វើឲ្យខូចខាត។
- ប្រអប់ឆ្នោតត្រូវតែមានលេខទូរស័ព្ទការិយាល័យ ROV និងលេខទូរស័ព្ទមិនអស់ថ្លៃទៅកាន់ទាំង ROV ឬ SOS ដើម្បីផ្តល់ដំណឹងក្នុងករណីណាដែលប្រអប់ឆ្នោតត្រូវបានប្តូរផ្លាស់ដោយគ្មានការអនុញ្ញាត ឬ ត្រូវបានខូចខាតដោយប្រការណាមួយនោះ[5]។

ដើម្បីឲ្យច្បាស់ប្រាកដថាអ្នកបោះឆ្នោតដែលនិយាយភាសាចំបងមិនមែនជាភាសាអង់គ្លេសប្រើប្រាស់បាននោះ ប្រអប់ឆ្នោតត្រូវតែសរសេរសម្គាល់ថា "ប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការ" គ្រប់ភាសាទាំងប្រាំបីៈ ភាសាចិន, ភាសាអេស្ប៉ាញ, ភាសាតាកាឡុក, ភាសាវៀតណាម, ភាសាខ្មែរ, ភាសាកូរ៉េ, ភាសាហិុនឌី, និងភាសាជប៉ុន។

បន្ថែមលើនេះទៀត ប្រអប់ទម្លាក់សន្លឹកឆ្នោតនីមួយៗនឹងមានសញ្ញាណែនាំដល់អ្នកបោះឆ្នោតថាមានផ្ដល់ជូននូវស្រោមសំបុត្របញ្ជូនសន្លឹកឆ្នោតត្រឡប់បន្ថែម ប្រសិនបើចាំបាច់ ។ អ្នកបោះឆ្នោតត្រូវបានណែនាំឲ្យអនុវត្តតាមការណែនាំនៅលើស្រោមសំបុត្រដែលរួមបញ្ចូលទាំងការបំពេញឈ្មោះរបស់គេ អាសយដ្ឋានទីលំនៅ ថ្ងៃខែឆ្នាំកំណើត និងការផ្តល់នូវហត្ថលេខារបស់គេ ។ ប្រសិនបើប្រើប្រអប់ទម្លាក់សន្លឹកឆ្នោត សន្លឹកឆ្នោតត្រូវបញ្ជូនត្រឡប់មកវិញមាននៅក្នុងស្រោមសំបុត្រជាមួយនឹងព័ត៌មាននិងហត្ថលេខារបស់អ្នកបោះឆ្នោត ។ លេខទូរស័ព្ទមិនអស់ថ្លៃ នឹងត្រូវផ្តល់ការណែនាំដល់អ្នកបោះឆ្នោតឲ្យទូរស័ព្ទប្រសិនបើពួកគេមានសំណួរ ឬ ត្រូវការជំនួយបន្ថែម ។

[4] សូមមើលក្រមបោះឆ្នោត California §18500

[5] សូមមើលក្រមបោះឆ្នោត California §20132

# មណ្ឌលបោះឆ្នោត

ច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោត (VCA) នឹងនាំមកនូវការផ្លាស់ប្តូរថ្មីនិងគួរឲ្យរំភើបជាខ្លាំង។ មណ្ឌលបោះឆ្នោតនឹងបើកដំណើរការរហូតដល់ទៅ 11 ថ្ងៃ ហើយនឹងត្រូវបំពាក់ដោយគ្រឿងបរិក្ខារបោះឆ្នោតថ្មីនិងអាចប្រើប្រាស់បានងាយស្រួលជាងមុន ជំនួយផ្នែកភាសា និងផ្តល់ការចុះឈ្មោះដោយមានលក្ខខណ្ឌ (CVR) និងបោះឆ្នោតនៅក្នុងថ្ងៃតែមួយ ។ បន្ថែមពីលើនេះទៀតនោះ អ្នកបោះឆ្នោតនឹងមិនតម្រូវឲ្យដាក់កម្រិតអាចបោះឆ្នោតបានតែក្នុងការិយាល័យតែមួយនោះទេ តែផ្ទុយទៅវិញគេមានជម្រើសដើម្បីមើលទីតាំងមណ្ឌលបោះឆ្នោតណាមួយនៃទីតាំងប្រមាណទាំង 110 ដែលមាននៅទូទាំងខោនធី Santa Clara ។

ស្ថិតនៅក្រោមច្បាប់ VCA មណ្ឌលបោះឆ្នោតតម្រូវឲ្យបើកទ្វារច្រើនថ្ងៃជាងអ្វីដែលបានអនុវត្តពីមុនមកនៅតាមការិយាល័យបោះឆ្នោតពីដើមនោះ។ មណ្ឌលបោះឆ្នោតត្រូវធ្វើប្រតិបត្តិការក្រោមរយៈពេលបោះឆ្នោតមុនកាលកំណត់ចំនួនពីរ៖ (1) ដប់ថ្ងៃមុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលថ្ងៃបោះឆ្នោតផងដែរសម្រាប់រយៈពេលសរុបចំនួន 11ថ្ងៃ និង (2) បីថ្ងៃមុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផងមានរយៈពេលសរុបចំនួនបួនថ្ងៃ។ ក្រមបោះឆ្នោត California ដាក់កំរិតឲ្យខោនធីត្រូវផ្តល់ទីតាំងទម្លាក់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោត៖

- ចាប់ផ្តើមឡើងពីរយៈពេលដប់ (10) ថ្ងៃមុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតដែលមានរយៈពេលសរុបចំនួនដប់មួយ (11) ថ្ងៃ មណ្ឌលបោះឆ្នោតមួយមានអ្នកបោះឆ្នោត 50,000 នាក់ដែលត្រូវតែមានដំណើរការ។
- ចាប់ផ្តើមឡើងពីរយៈពេលបី (3) ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតមានរយៈពេលសរុបចំនួនបួនថ្ងៃ (4) ថ្ងៃ។ មណ្ឌលបោះឆ្នោតមួយមានអ្នកបោះឆ្នោតចំនួន 10,000 នាក់ដែលមានត្រូវតែដំណើរការ។

ដើម្បីផ្តល់សេវាដល់អ្នកបោះឆ្នោតឲ្យបានកាន់តែប្រសើរ ខោនធី Santa Clara មានគម្រោងធ្វើប្រតិបត្តិការមណ្ឌលបោះឆ្នោតដំណើរការរយៈពេល 11 ថ្ងៃ ពីរបន្ថែមទៀត និងមណ្ឌលបោះឆ្នោតដំណើរការ 4 ថ្ងៃ ចំនួនប្រាំបីបន្ថែមទៀត ដោយផ្អែកលើចំនួននៃអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកត្រឹមការបោះឆ្នោតបឋមសម្រាប់ជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា ឆ្នាំ 2020 ។ ROV បានបង្កើតផែនទីចំនួនពីរ ដែលបែងចែកខោនធីទៅតាមតំបន់ដោយមានអ្នកបោះឆ្នោតចំនួន 50,000 នាក់ និង 10,000 នាក់នៅក្នុងផែនទីនីមួយៗ (សូមមើលសេចក្តីបន្ថែម E)។ ផែនទីទាំងនេះបានជួយដល់ដំណើរការនៃការស្វែងរកទីតាំងមណ្ឌលបោះឆ្នោត។ ផែនទីដោយមានព្រំប្រទល់ជុំវិញតំបន់ដែលមានអ្នកបោះឆ្នោតចំនួន 50,000 នាក់ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលត្រូវដំណើរការរយៈពេល 11 ថ្ងៃ ខណៈដែលផែនទីមានព្រំប្រទល់ជុំវិញតំបន់មានអ្នកបោះឆ្នោតចំនួន 10,000 នាក់ត្រូវបានប្រើប្រាស់ដើម្បីដាក់មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃ។

ម៉ោងដំណើរការសម្រាប់មណ្ឌលបោះឆ្នោតទាំងអស់អាចខុសៗគ្នាអាស្រ័យទៅលើទីតាំងអំពីកាលបរិច្ឆេទនៅមុនថ្ងៃបោះឆ្នោត[6]។ នៅថ្ងៃបោះឆ្នោតមណ្ឌលបោះឆ្នោតទាំងអស់នឹងបើកដំណើរការទទួលអ្នកបោះឆ្នោតពីម៉ោង7:00 ព្រឹក ដល់ម៉ោង 8:00 យប់ ទៅតាមការកំណត់របស់ក្រមបោះឆ្នោត[7]។ ដើម្បីមើលបញ្ជីឈ្មោះមណ្ឌលបោះឆ្នោតដែលអាចនឹងបង្កើតឡើងបាននោះ ROV កំពុងតែធ្វើការពិចារណា សូមមើលសេចក្តីបន្ថែម F ។ នៅពេលធ្វើការបោះពុម្ពផ្សាយ មណ្ឌលបោះឆ្នោតទាំងអស់ស្ថិតក្រោមការពិចារណានោះ អាចត្រូវមានការកែប្រែ។

[6] ROV នៅតែកំពុងស្ថិតក្នុងដំណើរការនៃការធ្វើលទ្ធកម្មមណ្ឌលបោះឆ្នោត ហើយទីតាំង និងម៉ោងដំណើរការជាក់លាក់ទាំងអស់មិនទាន់មាននៅឡើយទេនៅពេលធ្វើការបោះពុម្ពផ្សាយនោះ។

[7] ក្រមបោះឆ្នោត §4005

| ផ្នែកព្រំប្រទល់ | អប្បបរមា លក្ខខណ្ឌតម្រូវ | ចំនួន[8] ដែលបានឡើង |
|---|---|---|
| មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 11 ថ្ងៃ (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 50k) | 20 | 22 |
| មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃ (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 10k) | 80 | 88 |

តួលេខដែលបានផ្តល់ក្នុងតារាងត្រូវបានផ្អែកទៅលើចំនួនដែលត្រូវបានព្យាករណ៍នៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច។ ការគណនាជាក់ស្តែងនឹងត្រូវកំណត់ក្នុងរយៈពេល 88 ថ្ងៃ មុនការបោះឆ្នោតដោយអនុលោមទៅតាមក្រមបោះឆ្នោត[9]។

ពីមុនមក ROV មើលឃើញពីការលូតលាស់ព្យាករណ៍ខ្ពស់ខ្លាំងនៅក្នុងការចុះឈ្មោះក្នុងអំឡុងឆ្នាំបោះឆ្នោតប្រធានាធិបតី។ គិតត្រឹមខែកក្កដា ឆ្នាំ 2019 មានអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនៅក្នុងខោនធី Santa Clara ប្រមាណជា 910,000 នាក់ ។ ROV ប្រមើលថាចំនួនអ្នកដែលបានចុះឈ្មោះបោះឆ្នោតនឹងកើនឡើងដល់ 1 លាននាក់នៅត្រឹមការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា ឆ្នាំ 2020 ។ ការចុះឈ្មោះអ្នកបោះឆ្នោតត្រូវបានប្រមើលមើលថានឹងកាន់តែកើនឡើងនៅត្រឹមការបោះឆ្នោតសាកលទូទៅប្រធានាធិបតី ខែវិច្ឆិការ 2020 ។ ដើម្បីធានាឲ្យប្រាកដនូវដំណើរមិនប្រែប្រួលរវាងការបោះឆ្នោត ក៏ដូចជាដើម្បីការរក្សានូវទីតាំងមណ្ឌលបោះឆ្នោតឲ្យមានចំនួនគ្រប់គ្រាន់នោះ ROV បានជ្រើសរើសដោយផ្អែកទៅលើចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតប្រមាណ 1.1 លាននាក់ ត្រឹមការបោះឆ្នោតសាកលខែវិច្ឆិកា ។ នេះនឹងផ្តល់លទ្ធភាពឲ្យ ROV អាចរក្សាទុកបាននូវចំនួនទីតាំងមណ្ឌលបោះឆ្នោតឲ្យនៅដដែលសម្រាប់ការបោះឆ្នោតទាំងពីរ ពោលគឺការបោះឆ្នោតខែមីនា និងខែវិច្ឆិកា បន្ថែមទៅលើចំនួនទីតាំងមិនប្រែប្រួល ធ្វើឲ្យមានស្ថេរភាពសម្រាប់អ្នកបោះឆ្នោតក្នុងចំណោមការផ្លាស់ប្តូរផ្សេងៗ ដែលនឹងកើតឡើងនៅពេលអនុវត្តច្បាប់ VCA ។

| ចំនួនអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត | ចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច | ចំនួនអ្នកបោះឆ្នោតដែល មានសិទ្ធិបោះឆ្នោត ប៉ុន្តែមិនបានចុះឈ្មោះ | ចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចតាមការគ្រោងទុក |
|---|---|---|---|
| 1,200,000 | 910,000 | 290,000 | 1,000,000 |

## ការចុះឈ្មោះអ្នកបោះឆ្នោត

មណ្ឌលបោះឆ្នោតនឹងអាចផ្តល់នូវសេវាកាន់តែច្រើនជាងមុនដែលផ្តល់ដោយការិយាល័យបោះឆ្នោតគំរូពីដើម។ មួយនៃសេវាដែលត្រូវបានពង្រីកផ្តល់ឲ្យនៅតាមមណ្ឌលបោះឆ្នោតនោះគឺការចុះឈ្មោះអ្នកបោះឆ្នោត។ នៅពេលនេះអ្នកបោះឆ្នោតនឹងមានលទ្ធភាពចុះឈ្មោះបោះឆ្នោត ធ្វើបច្ចុប្បន្នភាពការចុះឈ្មោះ និងការបោះឆ្នោតដោយមានលក្ខខណ្ឌនៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន។ ស្រោមសំបុត្រអ្នកបោះឆ្នោតទាំងឡាយណាដែលត្រូវបានរកឃើញថាមានលក្ខណៈសម្បត្តិអាចបោះឆ្នោត

[8] ព្រំប្រទល់ដែលត្រូវព្រៀងឡើងដោយ ROV គឺផ្អែកទៅលើចំនួនប្រជាជនដែលត្រូវបានប៉ាន់ស្មាន ហើយក្នុងបំណងប្រើប្រាស់ជាគោលការណ៍ណែនាំ។ ចំនួនដែលត្រូវបានកំណត់ដោយ VCA គួរតែត្រូវបានគិតដល់ ដោយសារតែវាបម្រើឲ្យអ្នកបោះឆ្នោត "រហូតដល់ទៅ 50,000 នាក់"។ នេះមានន័យថា ចំនួនអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកនៅក្នុងព្រំប្រទល់នីមួយៗជានិច្ចកាលមិនបន្ថែមទៅលើចំនួនសរុបដែលត្រូវបានកំណត់ដោយ VCA នោះទេ។ ចំនួនត្រូវបានស្មើឡើងដូចបង្ហាញនេះ ជាចំនួនគោលដៅអប្បបរមាត្រូវជ្រើសរើស ។ ROV នឹងពិចារណាទៅលើទីតាំងបន្ថែមទៅតាមតម្រូវការដើម្បីផ្តល់ឲ្យបានគ្របដណ្តប់គ្រប់គ្រាន់ទៅដល់តំបន់នានាដែលអាចនឹងមានតម្រូវការគាំទ្រ ។

[9] ក្រមបោះឆ្នោត §12223

ក្រោមក្នុងចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ (CVR) នោះនឹងត្រូវទទួលបានសន្លឹកឆ្នោតព្រមទាំងស្រោមសំបុត្រ CVR ចំនួនមួយ។

CVR គឺជាកម្មវិធីសម្រាប់សមាជិកនៃសហគមន៍ដែលមិនបានចុះឈ្មោះបោះឆ្នោតក្រោយពីការបិទបញ្ចប់ការចុះឈ្មោះបាន 15 ថ្ងៃ ដើម្បីទៅកាន់មណ្ឌលបោះឆ្នោតទៅចុះឈ្មោះនិងបោះឆ្នោតក្នុងថ្ងៃតែមួយ។ អ្នកបោះឆ្នោតក៏អាចប្រើប្រាស់ CVR ដើម្បីធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ឬ គណបក្សនយោបាយណាមួយរបស់ខ្លួនក្រោយពីការបិទបញ្ចប់ការចុះឈ្មោះបាន 15 ថ្ងៃបានផងដែរ។ ក្រោយពីសន្លឹកឆ្នោត CVR ដែលបំពេញរួចត្រូវបានបញ្ជូនទៅកាន់ការិយាល័យ ROV ភ្លាម អ្នកបោះឆ្នោតដែលមានសក្តានុពលក្នុងការបោះឆ្នោតត្រូវពិនិត្យវាយតម្លៃពីលក្ខណៈសម្បត្តិដែលអាចបោះឆ្នោតបាន។ សន្លឹកឆ្នោតនឹងអាចបើកនិងរាប់បានតែនៅពេលការផ្ទៀងផ្ទាត់បញ្ជាក់ថាអ្នកបោះឆ្នោតបំពេញបានទៅតាមលក្ខខណ្ឌតម្រូវទាំងអស់ស្តីពីការមានសិទ្ធិបោះឆ្នោតបាន។ ស្រោមសំបុត្រ CVR នឹងដើរតួជាលិខិតថ្លែងសច្ចាអំពីការចុះឈ្មោះបោះឆ្នោត ហើយអ្នកបោះឆ្នោតអាចកាត់ចេញនូវបង្កាន់ដៃរបស់ខ្លួនចេញពីស្រោមសំបុត្រ ធ្វើដូច្នេះពួកគេអាចតាមដានដឹងពីស្ថានភាពនៃសន្លឹកឆ្នោតរបស់គេនៅលើគេហទំព័ររបស់ ROV[10]។

## សន្លឹកឆ្នោតជំនួសថ្មី

មណ្ឌលបោះឆ្នោតបច្ចុប្បន្ននឹងមានលទ្ធភាពផ្តល់សន្លឹកឆ្នោតជំនួសថ្មីទៅដល់អ្នកបោះឆ្នោតទៅតាមការស្នើសុំ។ អ្នកបោះឆ្នោតអាចស្នើសុំសន្លឹកឆ្នោតនៅឯមណ្ឌលបោះឆ្នោតក្រោយពីការផ្ទៀងផ្ទាត់ដឹងថា សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតដូចគ្នា មិនទាន់បានទទួលពីអ្នកបោះឆ្នោតនៅឡើយដោយ ROV[11]។ ប្រសិនបើ ROV មិនអាចកំណត់បានថាសន្លឹកឆ្នោតត្រូវបានទទួលពីអ្នកបោះឆ្នោតហើយឬនៅទេនោះ ROV នឹងអាចអនុញ្ញាតឲ្យអ្នកបោះឆ្នោតបោះជាបណ្តោះអាសន្នសិនបាន។

## ការបោះឆ្នោតបណ្តោះអាសន្ន[12]

នៅគ្រប់មណ្ឌលបោះឆ្នោតទាំងអស់ អ្នកបោះឆ្នោតអាចបោះឆ្នោតបណ្តោះអាសន្នបាន។ អ្នកបោះឆ្នោតសំអាងថាត្រូវបានចុះឈ្មោះរួច ប៉ុន្តែការចុះឈ្មោះរបស់ខ្លួននិងលក្ខណៈសម្បត្តិអាចទទួលបានមិនអាចត្រូវបានកំណត់ភ្លាមៗដោយបុគ្គលិក ROV បាននោះ ត្រូវតម្រូវឲ្យបោះសន្លឹកឆ្នោតបណ្តោះអាសន្ន។ ROV ត្រូវតែមានការណែនាំដល់អ្នកបោះឆ្នោតពីសិទ្ធិរបស់គាត់ត្រូវបោះឆ្នោត និងផ្តល់អ្នកបោះឆ្នោតនូវៈ

- សន្លឹកឆ្នោតបណ្តោះអាសន្នព្រមជាមួយនឹងសេចក្តីណែនាំទាក់ទងនឹងដំណើរការនិងនីតិវិធីសម្រាប់ការបោះឆ្នោតសន្លឹកឆ្នោតបណ្តោះអាសន្ត។
- ការបញ្ជាក់ជាលាយលក្ខណអក្សរទាក់ទងនឹងការចុះឈ្មោះរបស់អ្នកបោះឆ្នោត និងលក្ខណៈសម្បត្តិដែលមានសិទ្ធិបោះឆ្នោតត្រូវតែមានចុះហត្ថលេខាដោយអ្នកបោះឆ្នោត។

---

[10] គេហទំព័រតាមដានសន្លឹកឆ្នោតបោះតាមសំបុត្រៈ https://eservices.sccgov.org/rov?tab=ab

[11] ក្រមបោះឆ្នោត §4005

[12] ក្រមបោះឆ្នោត §14310

ដើម្បីបោះឆ្នោតបណ្តោះអាសន្នបាន អ្នកបោះឆ្នោតត្រូវតែអនុវត្ត (ចុះហត្ថលេខា) នៅចំពោះមុខបុគ្គលិក ROV ការបញ្ជាក់ជាលាយលក្ខណអក្សរបញ្ជាក់ថាអ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតហើយបានចុះឈ្មោះនៅក្នុងខោនធី Santa Clara ។ អ្នកបោះឆ្នោតត្រូវបិទភ្ជិតសន្លឹកឆ្នោតនៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្នសម្រាប់ការផ្ញើត្រឡប់មកកាន់ការិយាល័យកណ្តាលរបស់ ROV។

ក្នុងអំឡុងពេលស្ទង់មតិផ្លូវការ បុគ្គលិកត្រូវតែផ្ទៀងផ្ទាត់អាសយដ្ឋានរបស់អ្នកបោះឆ្នោត និងត្រូវផ្ទៀងផ្ទាត់ប្រាកដពីហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្ន ប្រៀបធៀបធៀបទៅនឹងហត្ថលេខានៅសេចក្តីថ្លែងសច្ចានៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកបោះឆ្នោត ឬ ហត្ថលេខាមួយផ្សេងទៀតនៅក្នុងសំណុំឯកសារចុះឈ្មោះរបស់អ្នកបោះឆ្នោត។ ភាពខុសគ្នាក្នុងការចុះហត្ថលេខាជំនួសឲ្យគ្រឹះសម្រាប់នាម ឈ្មោះកណ្តាល ឬ ឈ្មោះទាំងពីរមិនធ្វើឲ្យសន្លឹកឆ្នោតគ្មានសុពលភាពនោះទេ។ បុគ្គលិកក៏ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌតម្រូវដែលអាចមានសិទ្ធិមុននឹងបើកនិងរាប់សន្លឹកឆ្នោត។

អ្នកបោះឆ្នោតណាដែលបោះឆ្នោតសន្លឹកឆ្នោតបណ្តោះអាសន្នអាចហែកបង្កាន់ដៃបាន ដូច្នេះហើយគេអាចតាមដានពីស្ថានភាពនៃសន្លឹកឆ្នោតរបស់ពួកគេនៅលើគេហទំព័ររបស់ ROV បាន [13]។ អ្នកបោះឆ្នោតអាចទាក់ទងមកកាន់ ROV ប្រើគេហទំព័រ[14] ដើម្បីស្វែងរកមើលថាតើសន្លឹកឆ្នោតរបស់ពួកគេត្រូវបានរាប់ឬអត់ ហើយប្រសិនបើមិនត្រូវបានរាប់ទេនោះ តើអ្វីទៅជាមូលហេតុដែលវាមិនត្រូវបានរាប់។ វារំពឹងថាចំនួនសន្លឹកឆ្នោតបណ្តោះអាសន្នដែលបោះនឹងថយចុះគួរឲ្យគត់សម្គាល់ជាមួយនឹងការអនុវត្តប្រព័ន្ធបោះឆ្នោតថ្មីនិងប្រើសៀវភៅបោះឆ្នោតអេឡិចត្រូនិក។

## ការបោះឆ្នោតដែលអាចធ្វើបាន

មន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត ខោនធី Santa Clara (ROV) មានបំណងធានាឲ្យថាលទ្ធភាពចូលរួមរបស់អ្នកបោះឆ្នោតត្រូវបានពិចារណាពេញមួយដំណើរការរៀបចំផែនការនិងការអនុវត្តច្បាប់ VCA ។ លទ្ធភាពអាចបោះឆ្នោតបានគឺជាប្រធានបទដ៏ធំនៃការពិចារណាខណៈដែល ROV ពិចារណាជ្រើសរើសមណ្ឌលបោះឆ្នោត និងការបណ្តុះបណ្តាលនិងការចាត់តាំងមន្ត្រីបោះឆ្នោតដើម្បីផ្តល់ឲ្យស្របទៅតាមតម្រូវការរបស់អ្នកបោះឆ្នោត។ ROV នឹងត្រូវប្រើប្រាស់នូវម៉ាស៊ីនបោះឆ្នោតថ្មី ព្រមជាមួយនឹងកម្មវិធីដែលបានបង្កើតពីមុនមក ដូចជាការបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) ដើម្បីលើកកម្ពស់បទពិសោធន៍ការបោះឆ្នោតប្រកបដោយសុវត្ថិភាព អាចចូលរួមបាន និងដោយឯករាជ្យសម្រាប់គ្រប់អ្នកបោះឆ្នោតទាំងអស់ ។ ខោនធី Santa Clara និងកំពុងបានបន្តផ្តល់ឲ្យអាចបោះឆ្នោតបាននៅតាមមណ្ឌលបោះឆ្នោតទាំងអស់[15]។

ROV នឹងប្រើសម្រង់មតិកំណត់ពីភាពអាចបោះឆ្នោតបានរបស់រដ្ឋលេខាធិការដ្ឋ California ដើម្បីកំណត់ពីវត្ថុនិទ្ទស្សន៍នៃសម្ភារៈបរិក្ខារនៅតាមមណ្ឌលបោះឆ្នោតដែលត្រូវទៅតាមស្តង់ដា និងសម្ភារៈបរិក្ខារនៅតាមមណ្ឌលទាំងនោះដែលនឹងតម្រូវឲ្យមានកែតម្រូវ។ ការកែសម្រួលទាំងអស់នឹងត្រូវកត់សម្គាល់នៅក្នុងប្រព័ន្ធបញ្ជូន ព្រមទាំងសៀវភៅព័ត៌មានសម្រាប់មណ្ឌលបោះឆ្នោតដោយមានផែនទីផង រូបភាព និងរូបថត ដែលនឹងត្រូវផ្តល់ទៅឲ្យអ្នកគ្រប់គ្រងទទួលបន្ទុកការរៀបចំនិងដំណើរការសម្ភារៈបរិក្ខារ។ ការកែតម្រូវទាំងឡាយត្រូវបានរំពឹងថានឹងឆ្លើយតបទៅតាមច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព (ADA)[16] និងអាចដាក់បញ្ចូលខ្លឹមសារស្តីពីទីតាំងចំណត, ជម្រាលជនពិការ, ទ្វារ, ច្រកដើរ និងអ្វីផ្សេងៗទៀតដែលមានចែងនៅច្បាប់ ADA ។

---

[13] គេហទំព័រតាមដានសន្លឹកឆ្នោតបោះតាមសំបុត្រ https://eservices.sccgov.org/rov?tab=ab

[14] គេហទំព័រតាមដានសន្លឹកឆ្នោតបោះតាមសំបុត្រ https://eservices.sccgov.org/rov/?tab=pb

[15] ក្រមបោះឆ្នោត §19240

[16] គេហទំព័រច្បាប់ស្តីពីពលរដ្ឋអាមេរិកាំងដែលមានពិការភាព (Americans with Disabilities Act): https://www.ada.gov/

មណ្ឌលបោះឆ្នោតនីមួយៗនៅក្នុងខោនធី Santa Clara នឹងត្រូវបំពាក់ឲ្យមានយ៉ាងហោចណាស់ (3) ប៉ុន្តែអាចរហូតដល់ (6) នូវម៉ាស៊ីនគូសសន្លឹកឆ្នោត (BMD) ដែលអាចប្រើប្រាស់បាន ។ ឧបករណ៍ ប្រព័ន្ធគ្រប់គ្រងការបោះឆ្នោត ICX BMD នឹងផ្តល់នូវបទពិសោធន៍ប្រកបដោយឯករាជ្យភាពសម្រាប់អ្នកបោះឆ្នោតមួយចំនួនដែលមានពិការភាព ។ ឧបករណ៍ BMDs សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ នឹងមានមុខងារស្របទៅតាមច្បាប់ ADA និងឧបករណ៍បន្ថែមជាមួយនឹងជម្រើសវិធីសាស្ត្របោះឆ្នោតផ្សេងៗជាច្រើន ។ -ឧបករណ៍ទាំងនេះនឹងត្រូវបញ្ចូលកម្មវិធីដោយមានប្រភេទសន្លឹកឆ្នោតទាំងអស់ និងភាសាគ្រប់កំណែប្រែ។

ប្រព័ន្ធបោះឆ្នោតរបស់ខោនធី Santa Clara មានមុខងារជាច្រើន ដែលអាចផ្តល់នូវបទពិសោធន៍ការបោះឆ្នោតឱ្យបានកាន់តែងាយស្រួលជាងមុន ។ ប្រព័ន្ធនេះអនុញ្ញាតឲ្យមានផ្ទាំងចូលអាចមើលឃើញ ស្តាប់ជាសម្លេង និងស្ទាបបាន ដែលអាចប្រើប្រាស់នៅក្នុងការរួមបញ្ចូលគ្នាទៅតាមការពេញចិត្តរបស់អ្នកបោះឆ្នោតណាមួយ ដើម្បីចលនាចុះឡើង និងគូសលើសន្លឹកឆ្នោត ។ ទាក់ទងនឹងការកែសម្រួលអេក្រង់ឲ្យងាយស្រួលមើលនោះ ទំហំនៃតួអក្សរលើអេក្រង់អាចត្រូវបាបនប្តូរ ហើយទំហំអេក្រង់អាចត្រូវបានប្តូរទៅកាន់ពណ៌សលើផ្ទៃខាងក្រោយពណ៌ខ្មៅបាន ។ បន្ថែមទៅលើការកែសម្រួលលើអេក្រង់ ប៊ូតុងចុចរបស់ឧបករណ៍បោះឆ្នោតតាមរយៈសម្លេង (ATI) អាចត្រូវបានភ្ជាប់ជាមួយបាន ។ ឧបករណ៍ ATI ត្រូវបានបំពាក់ដោយមុខងារបោះឆ្នោតដោយប្រើសម្លេងបិទបើកចុះឡើងបាន ដែលធ្វើឲ្យអ្នកបោះឆ្នោតអាចស្តាប់នូវសន្លឹកឆ្នោតរបស់គេ កំណត់ល្បឿនសម្លេងបាន (បើចាំបាច់) និងកំណត់ជម្រើសរបស់គេ ។ ATI ក៏មានប៊ូតុងធំៗជាច្រើនសម្រាប់ប្តូរទៅអក្សរស្ទាបនិងការបញ្ចូល “Sip and Puff” ឬ ដងឧបករណ៍អេឡិចត្រូនិកសម្រាប់ការជ្រើសរើស ។ អ្នកបោះឆ្នោតដែលមិនអាចប្រើមុខងារទាំងនេះដោយខ្លួនឯងបាន អាចនឹងត្រូវការឱ្យមានមនុស្សដល់ទៅពីរនាក់ដើម្បីជួយពួកគេក្នុងដំណើរការបោះឆ្នោតទាំងមូលបាន។ បន្ថែមលើនេះទៀត ROV ផ្តល់ការសែតសម្លេងព័ត៌មានណែនាំសម្រាប់អ្នកបោះឆ្នោតរបស់ខោនធី (CVIG), ផ្តល់ឲ្យទៅតាមការស្នើសុំ។

ក្នុងករណីដែលមានឧបករណ៍ BMD មួយ ឬច្រើនមិនដំណើរការ ឬខូច ROV នឹងផ្តើមបង្កើតភ្លាមៗនូវនីតិវិធីដើម្បីជំនួសឲ្យឧបករណ៍ណាមួយដែលខូចទៅតាមភាពចាំបាច់ ។ ដំណើរការជំនួសនឹងត្រូវធ្វើជាអាទិភាពដោយម៉ាស៊ីនដែលដំណើរការមាននៅតាមទីតាំង តម្រូវការសមត្ថភាព និងកម្រិតធ្ងន់ធ្ងរនៃការខូច។ អនុបាតប្រតិបត្តិការគាំទ្រគឺទីតាំងគាំទ្រមួយ (1) មានបី (3) ក្រុមសម្រាប់ក្រុមមណ្ឌលបោះឆ្នោតចំនួនប្រាំមួយ (6)។

សេវាដែលអាចទទួលបានបន្ថែម ដែលនឹងផ្តល់ឲ្យបាននៅតាមមណ្ឌលបោះឆ្នោតនីមួយៗគឺការបោះឆ្នោតនៅក្រៅការដ្ឋានបោះឆ្នោត ហើយមានអ្នកស្វាគមន៍ដែលនឹងត្រូវទទួលការបណ្តុះបណ្តាលឲ្យចេះវាយតម្លៃនិងណែនាំបង្ហាញពីតម្រូវការរបស់អ្នកបោះឆ្នោតទាំងអស់តាមរយៈដំណើរការរបស់មណ្ឌលបោះឆ្នោត។

## ជំនួយផ្នែកភាសា

គោលដៅរបស់ ROV គឺដើម្បីឲ្យមណ្ឌលបោះឆ្នោតនីមួយៗផ្តល់នូវទម្រង់មួយចំនួននៃការជំនួយខាងភាសា [17]។ សម្រាប់ខោនធី Santa Clara ភាសាទាំងនេះនឹងរាប់បញ្ចូលនូវ៖

- អង់គ្លេស
- ចិន
- អេស្ប៉ាញ
- តាកាឡុក
- វៀតណាម
- ខ្មែរ
- កូរ៉េ
- ហិណ្ឌូ
- ជប៉ុន

[17] ក្រមបោះឆ្នោត §12303

អាស្រ័យទៅលើតម្រូវការតាមសហគមន៍ជាក់លាក់ ROV នឹងព្យាយាមជ្រើសរើសបុគ្គលិកដែលចេះពីរភាសា ដែលអាចនិយាយភាសាចំបងទាំងឡាយនៅក្នុងសហគមន៍នោះ។ ទោះបីជាយ៉ាងណាក៏ដោយ តំបន់ដែលតម្រូវឲ្យមានភាសាជាក់លាក់ចាំបាច់នឹងត្រូវកំណត់ក្នុងករណីបុគ្គលិកចេះពីរភាសាមិនទំនេរនោះ បុគ្គលិកមណ្ឌលបោះឆ្នោតនឹងត្រូវទាក់ទងទៅកាន់ ROV ហើយភ្ជាប់អ្នកបោះឆ្នោតទៅកាន់បុគ្គលិកការិយាល័យចេះពីរភាសា ឬ ទៅកាន់ទូរស័ព្ទសេវាបកប្រែភាសារបស់ខោនធី ។

ដោយរួមគ្នាទាំងទិន្នន័យផែនទីនិងភាសាបានពីបណ្ដុំអ្នកបោះឆ្នោត ROV អាចកំណត់គោលដៅជំនួសបុគ្គលិកនិយាយពីរភាសានៅតាមទីតាំងដែលពួកគេនឹងផ្ដល់សេវាដល់សហគមន៍បានប្រសើបំផុតតាមមធ្យោបាយដែលមានប្រសិទ្ធិភាពខ្ពស់បំផុត។ ធ្វើការកំណត់គោលដៅដាក់មន្ត្រីបោះឆ្នោតដែលចេះនិយាយពីរភាសាទៅកាន់មណ្ឌលបោះឆ្នោតដែលស្ថិតនៅក្នុងសហគមន៍ដែលនិយាយភាសាជាក់លាក់នោះ នឹងធ្វើឡើងក្នុងករណីមិនមានមន្ត្រីបោះឆ្នោតចេះនិយាយពីរភាសាឲ្យបានគ្រប់ភាសាឲ្យប្រចាំការនៅតាមមណ្ឌលបោះឆ្នោតនីមួយៗនៅទូទាំងខោនធីទាំងមូល។

សម្ភារៈបោះឆ្នោតទាំងអស់នឹងមានជាបួនភាសាទៅតាមការកំណត់របស់សហព័ន្ធ។ សន្លឹកឆ្នោតផ្លូវការ, CVR និង ស្រោមសំបុត្របណ្ដោះអាសន្ន ហើយនិងស្លាកសញ្ញាមណ្ឌលបោះឆ្នោតទាំងអស់នឹងត្រូវមានទាំងបួនភាសាទៅតាមការកំណត់របស់សហព័ន្ធភាសាពីរដែលត្រូវបានកំណត់ដោយរដ្ឋមានភាសាខ្មែរនិងភាសាកូរ៉េ ក៏ដូចជាភាសាជប៉ុននិងហ៊ីនឌីដែរ ដែលមិនត្រូវបានតម្រូវប៉ុន្តែបានផ្ដល់ជាប្រវត្តិសាស្រ្តមកហើយដោយខោនធី។

នៅពេលដែលបុគ្គលិកការងារចេះនិយាយពីរភាសាមិនទំនេរទេនោះ បុគ្គលិកមណ្ឌលបោះឆ្នោតអាចទូរស័ព្ទទៅកាន់ការិយាល័យ ROV ហើយអាចនិយាយទៅកាន់បុគ្គលិកម្នាក់ក្នុងចំណោមបួននាក់ដែលចេះនិយាយពីរភាសាបាន។ បន្ថែមលើនេះទៀត យើងក៏អាចបំពេញទៅតាមសំណើភាសាណាមួយដែលយើងទទួលបានតាមរយៈសេវាបកប្រែតាមទូរសព្ទរបស់ខោនធីបានដែរ។

ព័ត៌មានបោះឆ្នោតទាំងអស់នឹងអាចរកបានជាបួនភាសាទៅតាមការតម្រូវរបស់សហព័ន្ធទាំងទម្រង់ព្រីនជាក្រដាស និងអេឡិចត្រូនិក (កុំព្យូទ័រឃ្យូរដៃមានផ្ទុកសេចក្ដីណែនាំព័ត៌មានស្ដីពីការបោះឆ្នោតរបស់ខោនធី (CVIG) ដូចទៅតាមអ្វីដែលបានប្រើនៅតាមមណ្ឌលបោះឆ្នោតមុនកាលកំណត់ក្នុងខែមិថុនា និង វិច្ឆិកា ឆ្នាំ 2018) ។ ស្លាកសញ្ញាទាំងឡាយនឹងត្រូវបិទនៅតាមមណ្ឌលបោះឆ្នោតទាំងអស់ដើម្បីបង្ហាញពីជំនួយផ្នែកភាសាដែលអាចផ្ដល់បាន។

## ការពិចារណាដាក់នៅតាមមណ្ឌលបោះឆ្នោត

ROV ត្រូវបានប្រើប្រាស់លក្ខខណ្ឌតម្រូវដែលត្រូវបានកំណត់ទាំង 14 ដូចគ្នា ដែលត្រូវបានកំណត់ដោយរដ្ឋលេខាធិការ ដូចទៅនឹងការបង្ហាញនៅក្នុងផ្នែក កន្លែង**ទីតាំងទម្លាក់សន្លឹកឆ្នោត** ។ ទិន្នន័យដែលប្រមូលបានពីប្រភពដែលមានមួយចំនួន (ឧ.ទា. ការស្ទង់មតិសហគមន៍អាមេរិកកាំង, មូលដ្ឋានទិន្នន័យអ្នកបោះឆ្នោតរបស់ ROV, តាមចំណតរថយន្ត VTA) ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងទៅដល់លក្ខខណ្ឌតម្រូវមួយចំនួននៃលក្ខខណ្ឌទាំងនេះ ។ លក្ខខណ្ឌតម្រូវទាំងនេះរាប់បញ្ចូលទាំងមធ្យោបាយធ្វើដំណើរសាធារណៈ លំនាំចរាចរណ៍ មណ្ឌលប្រជាជន ភាសាជនជាតិមានភាគតិច កម្មសិទ្ធិភាពលើយានយន្តមានកម្រិតតិច ចំណូលទាប ការប្រើប្រាស់ការការបោះឆ្នោតតាមសំបុត្រមានកម្រិតទាប និងការចុះឈ្មោះអ្នកបោះឆ្នោតមានចំនួនតិច (សូមមើលឧបសម្ព័ន្ធ G សម្រាប់ទិន្នន័យផែនទីដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់គោលដៅទីតាំងមណ្ឌលបោះឆ្នោតនិងប្រអប់ទម្លាក់សន្លឹកឆ្នោត) ។

ឧបករណ៍ដែលមានស្រាប់ហៅថា "DOTS" ត្រូវបានអភិវឌ្ឍឡើង ដើម្បីជួយដល់ ROV កំណត់ទៅលើទីតាំងឲ្យបានប្រសើរបំផុតសម្រាប់មណ្ឌលបោះឆ្នោតទាំងនោះ។ គំរូត្រូវបានបែងចែកខោនធីទៅជាប្រព័ន្ធកំណត់ទីតាំងរាងការេទំហំ 0.5 ម៉ែល៍ ។ ប្រព័ន្ធកំណត់ទីតាំងនីមួយៗត្រូវបានកំណត់ពិន្ទុចាប់ពីមួយទៅប្រាំសម្រាប់លក្ខខណ្ឌនីមួយៗក្នុងតាងខាងលើ ។ ពិន្ទុនីមួយៗរបស់វាត្រូវតែបានបន្ថែមដើម្បីអាចឱ្យទទួលបានពិន្ទុសរុបនៅផ្នែកខាងចុង ។ ទីតាំងមណ្ឌលបោះឆ្នោតនិងប្រអប់ទម្លាក់សន្លឹកឆ្នោត នៅពេលនោះត្រូវបានដាក់នៅខាងលើនៃពិន្ទុផែនទី ។ ទីតាំងដែលស្ថិតនៅក្នុង ឬ ក្បែរ មានពិន្ទុខ្ពស់ក្នុងប្រព័ន្ធកំណត់ទីតាំង ត្រូវបានផ្តល់ការពេញចិត្តពីព្រោះវាត្រូវច្រើនបានចំនួនទៅតាមលក្ខខណ្ឌតម្រូវ ។

ធាតុចូលដែលបានមកពីសាធារណៈជនក៏ត្រូវបានពិចារណាដាក់ចូលទៅក្នុងដំណើរការនេះ ។ ការពិចារណាសំខាន់បំផុតពីមតិត្រឡប់ពីសាធារណជនដែលទទួលបាន រួមបញ្ចូលទាំងភាពប្រកៀកប្រកិតទៅនឹងមជ្ឈមណ្ឌលប្រជាជន លំនាំចរាចរណ៍ សហគមន៍ប្រើភាសាជនជាតិដែលមានភាគតិច អ្នកបោះឆ្នោតដែលមានពិការភាព និងប្រព័ន្ធរថយន្តសាធារណៈ ។ ROV បានបន្ថែមនូវសារៈសំខាន់បន្ថែមទៀត ដល់សហគមន៍ជិតៗដែលមានប្រវត្តិការចុះឈ្មោះអ្នកបោះឆ្នោត និងការប្រើប្រាស់ការបោះឆ្នោតតាមសំបុត្រមានភាគតិច ដោយថាសហគមន៍ទាំងនេះនឹងអាចទាញយកផលប្រយោជន៍បានប្រសើរបំផុតពីសេវាដែលត្រូវផ្តល់ដោយមណ្ឌលបោះឆ្នោត ដូចជាការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ ឬ ការបោះឆ្នោតដោយមកផ្ទាល់ ។ លក្ខខណ្ឌតម្រូវដែលត្រូវបានជ្រើសរើសដោយសាធារណជន និងបុគ្គលិក ROV ត្រូវបានផ្តល់ទម្ងន់ខ្ពស់ជាងនៅក្នុងដំណើរការអភិវឌ្ឍឧបករណ៍នៅនឹងកន្លែង ។ លក្ខខណ្ឌតម្រូវផ្សេងទៀត ដូចជាភាពទំនេរ, ថ្លៃឈ្នួល, ទម្រង់នៃបន្ទប់ និងលទ្ធភាពទទួលបានការចតយានយន្ត ត្រូវបានវាយតម្លៃទៅតាមលក្ខណៈជាក់ស្តែង ។

ROV បានធ្វើការដើម្បីធ្វើឲ្យប្រាកដថាមានវិសាលភាពគ្រប់គ្រាន់នៅក្នុងតំបន់ដែលមានពលរដ្ឋរស់នៅច្រើន តំបន់ជាប្រវត្តិសាស្ត្រមានចំនួនពលរដ្ឋចេញទៅបោះឆ្នោតមានចំនួនតិច, និងតំបន់ទាំងឡាយដែលជាសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ។ បន្ថែមលើនេះទៀត ព្រំប្រទល់មណ្ឌលបោះឆ្នោតត្រូវបានបង្កើតឡើងដើម្បីជួយកំណត់ចម្ងាយនិងពេលវេលាដែលអ្នកបោះឆ្នោតត្រូវធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោត ។ ជំនួសឲ្យមណ្ឌលបោះឆ្នោតចល័ត ROV មានគម្រោងឲ្យមានមណ្ឌលបោះឆ្នោតបន្ថែមទៅលើចំនួនអប្បរមាតាមលក្ខខណ្ឌតម្រូវ និង ដាក់មណ្ឌលទាំងនោះឲ្យនៅជិតគ្នានៅពាសពេញតំបន់ទាំងនេះ ដើម្បីផ្តល់សេវាឲ្យបានកាន់តែប្រសើរឡើងដល់សហគមន៍ក្នុងមូលដ្ឋាន ។ ផ្អែកទៅលើការពិនិត្យជាក់ស្តែងទៅលើសគមន៍ទាំងឡាយនៅខាងក្រៅនៃតំបន់មានពលរដ្ឋចំរុះជាតិសាសន៍រស់នៅធំៗ តំបន់អាគ្នេយ៍នៃខោនទី Santa Clara ត្រូវបានកំណត់ថាជាសហគមន៍ដែលអាចទទួលបានអត្ថប្រយោជន៍ពីមណ្ឌលបោះឆ្នោតបន្ថែម ។

## សមាសភាពមន្ត្រីបោះឆ្នោត

ROV នឹងជួលមន្ត្រីបោះឆ្នោត (ត្រូវបានកំណត់ដោយក្រមបោះឆ្នោតថាជាក្រុមប្រឹក្សាបោះឆ្នោត[18]) ឲ្យនៅប្រចាំការនៅតាមមណ្ឌលបោះឆ្នោត។ មន្ត្រីបោះឆ្នោតនឹងមានមកពីសហគមន៍ចំរុះគ្នាជាច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបង្កើនដល់កម្រិតអតិបរមានូវជំនាញចាំបាច់ដល់ដំណើរការអ្នកបោះឆ្នោតចូលបោះ[19]។ បុគ្គលិកមណ្ឌលបោះឆ្នោតគប្បីបង្ហាញនូវបទពិសោធន៍ផ្នែកសេវាអតិថិជន សមត្ថភាពជំនាញពីរភាសា មានយកចិត្តទុកដាក់ខ្ពស់ចំពោះពិពិធភាព និង បរិយាប័ន គុណភាពភាពជាអ្នកដឹកនាំ សមត្ថភាពជំនាញបច្ចេកវិទ្យា និង ចំណាប់អារម្មណ៍ក្នុងតួនាទីស៊ីវិលនៃការចូលរួមក្នុងសហគមន៍។ ពួកគេនឹងត្រូវបណ្តុះបណ្តាលពីបច្ចេកវិទ្យា

[18] ក្រមបោះឆ្នោត §4005

[19] ក្រមបោះឆ្នោត ផ្នែកទី 12 , មាត្រា 1 នៃជំពូក 4

មណ្ឌលបោះឆ្នោតថ្មី ពីរបៀបដំណើរការអ្នកបោះឆ្នោត និងការគ្រប់គ្រងពិនិត្យទៅលើចំនួនមនុស្សច្រើនកុះករ។ ប្រធានបទបណ្តុះបណ្តាលសេវាអតិថិជនបន្ថែមទៀតនឹងត្រូវដាក់បញ្ចូលនូវលទ្ធភាពដែលអាចប្រើប្រាស់បានសម្រាប់មនុស្សចាស់ និងអ្នកបោះឆ្នោតដែលមានពិការភាព ការធ្វើបរិយាប័ន និងការទំនាក់ទំនងទៅតាមលក្ខណៈសមរម្យ។ ROV នឹងជ្រើសរើសបេក្ខជនដែលមានគុណសម្បត្តិប្រសើរបំផុត ដោយផ្អែកទៅលើភាពអាចទទួលយកបាន និងតម្រូវការនានារបស់សហគមន៍។ មន្ត្រីបោះឆ្នោតដែលបានជាប់ក្នុងការជ្រើសរើសនឹងត្រូវផ្តល់ដំណឹងឲ្យដឹងផងដែរពីលទ្ធភាពក្នុងការងារស្ម័គ្រចិត្តថ្មី ហើយអាចនឹងត្រូវបានជ្រើសរើសប្រសិនបើពួកគេបំពេញបានទៅតាមការប្តេជ្ញាចិត្តតម្រូវការជ្រើសរើសបុគ្គលិកនោះ។

សមាសភាពមន្ត្រីបោះឆ្នោតនឹងមាននិយោជិតខោនធីជាអ្នកជំនួយបន្ថែម និងអ្នកស្ម័គ្រចិត្តដែលទទួលបានប្រាក់ឧបត្ថម្ភ ។ អ្នកគ្រប់គ្រងនិងស្មៀន នឹងត្រូវបានជួលជាបុគ្គលិកការងារខោនធីស៊ីប្រាក់ម៉ោង និងអ្នកធ្វើបដិសណ្ឋារកិច្ចភាគច្រើនជាបុគ្គលិកទទួលបានប្រាក់ឧបត្ថម្ភ (ឧ.ទា. មន្ត្រីបោះឆ្នោតពីមុនមក សិស្សវិទ្យាល័យ) ។ បុគ្គលិកមណ្ឌលបោះឆ្នោតទាំងអស់នឹងត្រូវបានបណ្តុះបណ្តាលទៅតាមតួនាទី ហើយនឹងធ្វើការចន្លោះប្រហែលពីមួយថ្ងៃ (បុគ្គលិកទទួលបានប្រាក់ឧបត្ថម្ភ) ទៅច្រើនថ្ងៃ បើមិនទេ គ្រប់ថ្ងៃបោះឆ្នោតទាំងអស់ ។ ព្រឹត្តិការណ៍ផ្សព្វផ្សាយរបស់ ROV នឹងរាប់បញ្ចូលទាំងការជ្រើសរើសបុគ្គលិករៀបចំការបោះឆ្នោតដែលគេអាចបំពេញពាក្យសុំនៅនឹងកន្លែងដែលនឹងត្រូវដាក់ជូនទៅខោនធីដើម្បីអនុម័តឯកភាព ។

ការដាក់បុគ្គលិកប្រចាំការនៅតាមមណ្ឌលបោះឆ្នោតនឹងត្រូវពឹងផ្អែកទៅលើទំហំមណ្ឌលបោះឆ្នោតនិងភាពជិតទៅនឹងថ្ងៃបោះឆ្នោត។ គម្រោងគឺត្រូវមានមន្ត្រីបោះឆ្នោតពី ប្រាំមួយ (6) ទៅ ដប់ប្រាំ (15) នាក់នៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ បុគ្គលិកច្រើនបន្ថែមទៀតនឹងត្រូវដាក់ទៅកាន់មណ្ឌលបោះឆ្នោតដែលមានទំហំធំជាងគេ ហើយក្នុងអំឡុងពេលមមាញឹកជាងគេ ហើយនិងនៅពេលថ្ងៃបោះឆ្នោតមកដល់។ នឹងមានការខិតខំប្រឹងប្រែងជ្រើសរើសមន្ត្រីបោះឆ្នោតដែលចេះពីរភាសាឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានដើម្បីគាំទ្រដល់តម្រូវការផ្នែកភាសានៅតាមខោនធី។

## បញ្ជីបោះឆ្នោតអេឡិចត្រូនិក (បញ្ជីបោះឆ្នោតអេឡិចត្រូនិក)

ដើម្បីអនុវត្តការផ្លាស់ប្តូរឲ្យមានប្រសិទ្ធិភាពទៅតាមច្បាប់ VCA នោះ មណ្ឌលបោះឆ្នោតនឹងត្រូវធ្វើបច្ចុប្បន្នភាពទៅលើ បញ្ជីបោះឆ្នោតអេឡិចត្រូនិក[20]។ បញ្ជីបោះឆ្នោតអេឡិចត្រូនិក មានបញ្ចូលគ្នានូវឧបករណ៍អេឡិចត្រូនិក និងកម្មវិធីប្រើប្រាស់ដើម្បីធានាសន្តិសុខការទំនាក់ទំនងជាអេឡិចត្រូនិករវាងមណ្ឌលបោះឆ្នោត និង ប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោត (EIMS) នៅតាម ROV ។ EIMS នៅតាម ROV នៅពេលនោះនឹងបញ្ជូនព័ត៌មានទៅកាន់ VoteCal។ VoteCal ជាមូលដ្ឋានទិន្នន័យចុះឈ្មោះបោះឆ្នោតប្រមូលផ្តុំទូទាំងរដ្ឋដែលមានទំនាក់ទំនងនិងផ្លាស់ប្តូរព័ត៌មានជាមួយនឹងការគ្រប់គ្រង និងប្រព័ន្ធផ្សេងទៀតរបស់រដ្ឋដូចជាក្រសួងអប់រំកែប្រែឡើងវិញ និងស្ថានិតិសម្បទារ ក្រសួងសុខាភិបាលសាធារណៈ និងក្រសួងយានយន្ត ។ បច្ចេកវិទ្យា VCA ថ្មីនេះ នឹងធ្វើប្រតិបត្តិការទាំងនៅលើកុំព្យូទ័រយួរដៃ ឬ ថែបផ្លេត ប៉ុន្តែនឹង *"ធ្វើឲ្យពិបាក"*; មានន័យថា <u>មានតែ</u> កម្មវិធី បញ្ជីបោះឆ្នោតអេឡិចត្រូនិកទេ ដែលត្រូវបានអនុម័តដោយ ROV ដែលនឹងអាចមានដំណើរការលើឧបករណ៍បាន។

បញ្ជីបោះឆ្នោតអេឡិចត្រូនិក មានផ្ទុកបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានចុះរួចជាអេឡិចត្រូនិក (សន្ទស្សន៍បញ្ជីឈ្មោះ) ដែលអាចនឹងត្រូវបញ្ជូននិងប្រើប្រាស់នៅតាមមណ្ឌលបោះឆ្នោត។ សន្ទស្សន៍បញ្ជីឈ្មោះផ្លូវការនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះអាចបោះឆ្នោតបាន។ វាត្រូវបានប្រើជាចម្បងដើម្បីផ្ទៀងផ្ទាត់ភាពសមស្របរបស់អ្នកបោះឆ្នោត ដើម្បីទទួលបានសន្លឹកឆ្នោត និងរក្សាទុកប្រវត្តិអ្នកបោះឆ្នោតស្ទើរតែភ្លាមៗដើម្បីជៀសវាងកុំឲ្យមានការបោះឆ្នោតពីរដងបាន។

ស្ថិតក្រោមគំរូ VCA ថ្មី បញ្ជីបោះឆ្នោតអេឡិចត្រូនិក នឹងត្រូវរក្សាទុកក្នុងប្រអប់មិនជ្រាបទឹកចាក់សោរដោយសុវត្ថិភាព ហើយត្រូវបានទុកនៅខាងក្នុងទ្រុងចាក់សោរសុវត្ថិភាពមួយជាន់ទៀត ដោយចាក់យ៉ាងម៉ត់ចត់ ហើយកូនសោរចាក់ចូលត្រូវបានផ្តល់ឲ្យបុគ្គលិកដើម្បីរក្សាទុកប្រចាំថ្ងៃ។ ក្នុងម៉ោងដំណើរការ ទិន្នន័យត្រូវបានរក្សាទុកនៅក្នុងផ្នែកនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។ បញ្ជីបោះឆ្នោតអេឡិចត្រូនិក ត្រូវបានបញ្ចូលកម្មវិធីដោយឲ្យអ្នកអាចចូលប្រើប្រាស់បានមានតែអ្នកប្រើប្រាស់ដែលត្រូវបានអនុញ្ញាត ដើម្បីចូលទៅកាន់ប្រព័ន្ធប្រើប្រាស់បណ្តាញភ្ជាប់ដែលមានសុវត្ថិភាពទៅកាន់បណ្តុំផ្ទុកទិន្នន័យមេលើខ្លៅដែលមានសុវត្ថិភាព។ បណ្តុំផ្ទុកទិន្នន័យមេលើខ្លៅរក្សាទុកមូលដ្ឋានទិន្នន័យ និងការតភ្ជាប់ទៅកាន់ប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោតសម្រាប់ការបញ្ជូនបច្ចុប្បន្នភាពព័ត៌មានទៅកាន់ទិន្នន័យអ្នកបោះឆ្នោត។ សម្រាប់ព័ត៌មានបន្ថែមទៀតស្តីពីសន្តិសុខទិន្នន័យរបស់អ្នកបោះឆ្នោតនៅក្នុង បញ្ជីបោះឆ្នោតអេឡិចត្រូនិក អាចរកបាននៅក្នុង **ផ្នែកសន្តិសុខក្នុងការបោះឆ្នោត ភាគទី 2៖ ផែនការអប់រំ និង ផ្សព្វផ្សាយ** ។

បញ្ជីបោះឆ្នោតអេឡិចត្រូនិក អាចត្រូវបានប្រើដើម្បីផ្ទៀងផ្ទាត់ទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោត រួមមានឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ភាសាដែលពេញចិត្ត គណបក្សអាទិភាព មណ្ឌល និងស្ថានភាពបោះឆ្នោតតាមសំបុត្រ។ បន្ថែមលើនេះទៀត បញ្ជីបោះឆ្នោតអេឡិចត្រូនិក <u>មិន</u> រក្សាទុកព័ត៌មានអ្នកបោះឆ្នោះ លេខប័ណ្ណបើកបរ, ឬ ឯកសារយោងនានាដែលទាក់ទងនឹងលេខសន្តិសុខសង្គម។ បញ្ជីបោះឆ្នោតអេឡិចត្រូនិក ផ្តល់ការស្វែងរកស្ទើរតែភ្លាមៗ និង ព័ត៌មានស្តីពីស្ថានភាពរបស់អ្នកបោះឆ្នោត ជាពិសេស ការបង្កើតបាននូវបទពិសោធន៍បោះឆ្នោតកាន់តែប្រសើរសម្រាប់ទាំងអ្នកបោះឆ្នោតនិងមន្ត្រីបោះឆ្នោត ROV ។

[20] ក្រមបោះឆ្នោត §2183

# ការផ្សព្វផ្សាយ

## ការពិគ្រោះយោបល់ជាសាធារណៈ

ក្នុងកិច្ចខិតខំប្រឹងប្រែងឲ្យមានការចូលរួមជាបរិយាប័ននៅក្នុងដំណើរការផែនការរដ្ឋបាលបោះឆ្នោត (EAP) នោះ ខោនធី Santa Clara បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈចំនួនដប់ពីរ (12) លើកដូចតទៅ៖ កិច្ចប្រជុំពីរលើក (2) សាធារណៈជនទូទៅ៖

| | | |
|---|---|---|
| ទូទៅ<br>ថ្ងៃទី 12 ខែមិថុនា ឆ្នាំ 2019<br>2:00-3:30 រសៀល | សេវាសង្គម ខោនធី Santa Clara<br>បន្ទប់ 116 | 379 Tomkins Ct.<br>Gilroy, CA 95020 |
| ទូទៅ<br>ថ្ងៃទី 13 ខែកក្កដា ឆ្នាំ2019<br>1:00-2:30 រសៀល | មន្រ្តីកាន់បញ្ជីឈ្មោះអ្នកបោះឆ្នោត<br>សាលប្រជុំ | 1555 Berger Drive, Bldg. 2<br>San Jose, CA 95112 |

- កិច្ចប្រជុំពីរលើក (2) ជាមួយនឹងសាធារណជនពាក់ព័ន្ធនឹងការព្រួយបារម្ភពីលទ្ធភាពទទួលបាន៖

| | | |
|---|---|---|
| លទ្ធភាពទទួលបាន<br>ថ្ងៃទី 13 ខែមិថុនា ឆ្នាំ 2019<br>5:00-7:00 ល្ងាច | មជ្ឈមណ្ឌលរដ្ឋាភិបាលខោនធី<br>បន្ទប់ 157 | 70 W. Hedding St.<br>San Jose, CA 95110 |
| លទ្ធភាពទទួលបាន<br>ថ្ងៃទី 10 ខែកក្កដា ឆ្នាំ2019<br>11:00 ព្រឹក-12:30 ល្ងាច | មជ្ឈមណ្ឌលរស់នៅដោយឯករាជ្យ Silicon Valley<br>បន្ទប់គណៈកម្មការ | 25 N. 14th St. Suite 1000<br>San Jose, CA 95112 |

- កិច្ចប្រជុំប្រាំបីលើក (8) ជាមួយនឹងសាធារណជនមកពីសហគមន៍ភាសាគោលដៅពាក់ព័ន្ធទៅនឹងការព្រួយបារម្ភពីលទ្ធភាពទទួលបានផ្នែកភាសា៖

| | | |
|---|---|---|
| វៀតណាម<br>ថ្ងៃទី 17 ខែមិថុនា ឆ្នាំ 2019<br>6:30-8:00 ល្ងាច | Tully San Jose សាខាបណ្ណាល័យ<br>បន្ទប់សហគមន៍ | 880 Tully Rd.<br>San Jose, CA 95111 |
| ខ្មែរ<br>ថ្ងៃទី 18 ខែមិថុនា ឆ្នាំ 2019<br>5:30-7:00 ល្ងាច | មជ្ឈមណ្ឌលរដ្ឋាភិបាលខោនធី<br>បន្ទប់ 157 | 70 W. Hedding St.<br>San Jose, CA 95110 |
| តាកាឡុក<br>ថ្ងៃទី 21 ខែមិថុនា ឆ្នាំ 2019<br>4:30-6:00 ល្ងាច | បណ្ណាល័យ Milpitas<br>សាលប្រជុំ | 160 N. Main St.<br>Milpitas, CA 95035 |
| អេស្ប៉ាញ<br>ថ្ងៃទី 24 ខែមិថុនា ឆ្នាំ 2019 | មជ្ឈមណ្ឌលសហគមន៍ Mayfair<br>បន្ទប់ លីនខុន | 2039 Kammerer Ave.<br>San Jose, CA 95116 |

| | | |
|---|---|---|
| 4:00-5:30 ល្ងាច | | |
| ចិន<br>ថ្ងៃទី 25 ខែមិថុនា ឆ្នាំ 2019<br>5:30-7:00 ល្ងាច | មជ្ឈមណ្ឌលសហគមន៍ Quinlan<br>បន្ទប់សង្គម | 10185 N. Stelling Rd.<br>Cupertino, CA 95014 |
| កូរ៉េ<br>ថ្ងៃទី 27 ខែមិថុនា ឆ្នាំ 2019<br>2:00-3:30 រសៀល | មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោត<br>សាលប្រជុំ | 1555 Berger Drive, អាគារ 2<br>San Jose, CA 95112 |
| ហិណ្ឌី<br>ថ្ងៃទី 8 ខែកក្កដា ឆ្នាំ2019<br>7:30-9:00 ល្ងាច | មជ្ឈមណ្ឌលសហគមន៍ឥណ្ឌា<br>បន្ទប់ Gita & Ashok Vaish | 525 Los Coches St.<br>Milpitas, CA 95035 |
| ជប៉ុន<br>ថ្ងៃទី 11 ខែកក្កដា ឆ្នាំ2019<br>4:30-6:00 ល្ងាច | សាខាបណ្ណាល័យ Joyce Ellington<br>បន្ទប់សហគមន៍ | 491 E. Empire St.<br>San Jose, CA 95112 |

កាលវិភាគនិងសេចក្តីជូនដំណឹងជាសាធារណៈសម្រាប់កិច្ចប្រជុំ EAP ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រយ៉ាងហោចណាស់ 10 ថ្ងៃ មុនថ្ងៃប្រជុំ។ សេចក្តីជូនដំណឹងជាសាធារណៈត្រូវបានបានផ្សព្វផ្សាយនៅខាងក្រៅមជ្ឈមណ្ឌលរដ្ឋាភិបាលខោនធីដែលមានអាសយដ្ឋាន 70 W. Hedding Street, San Jose, CA 95110។ បន្ថែមលើនេះទៀត ROV បានប្រើកម្មវិធី Nextdoor, Facebook, Twitter, និង Instagram ដើម្បីផ្សព្វផ្សាយពីកិច្ចប្រជុំនេះ។ សេចក្តីបន្ថែម H រួមមានសេចក្តីជូនដំណឹងទាំងអស់ពីកិច្ចប្រជុំដែលទាក់ទងនឹងការអភិវឌ្ឍ EAP។

នៅក្នុងកិច្ចប្រជុំ EAP ប្រធានបទគោលដៅមានៈ

- ទីតាំងដែលមានសក្តានុពលជាមណ្ឌលបោះឆ្នោត
- ទីតាំងដែលមានសក្តានុពលដាក់ប្រអប់ទម្លាក់សន្លឹកឆ្នោត
- តម្រូវការលទ្ធភាពទទួលបានផ្នែកភាសាផ្សេងៗ
- តម្រូវការលទ្ធភាពផ្សេងៗដែលអ្នកបោះឆ្នោតត្រូវការដើម្បីបោះបាន
- សំណូមពរនានាសម្រាប់ផ្សព្វផ្សាយដល់សហគមន៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយនិងព្រឹត្តិការណ៍នានា

ក្នុងចំណោមសម្ភារៈនានាដែលបានផ្តល់ជូននៅកិច្ចប្រជុំ គឺ ប័ណ្ណព័ត៌មានពីការជ្រើសរើសមណ្ឌលបោះឆ្នោត និង ការស្ទង់មតិជ្រើសរើសទីតាំង (ត្រូវបានបង្ហាញក្នុងសេចក្តីបន្ថែម I) ដើម្បីជួយប្រមូលព័ត៌មាននិងសំណូមពរនានាសម្រាប់ទីតាំងដែលមានសក្តានុពលជាមណ្ឌលបោះឆ្នោត)។ ធាតុចូលទាំងអស់ដែលបានទទួលពីកិច្ចប្រជុំត្រូវបានរៀបចំចងក្រងជាឯកសារនៅក្នុងរបាយការណ៍កិច្ចប្រជុំ (សេចក្តីបន្ថែម J)។

# តារាងពេលវេលាអភិវឌ្ឍផែនការរដ្ឋបាលបោះឆ្នោត (EAP) [21]

| | |
|---|---|
| បោះពុម្ពផ្សាយពង្រាងសំណើ EAP | ថ្ងៃទី 16 ខែកក្កដា ឆ្នាំ 2019 |
| ការផ្តល់មតិយោបល់ពីសាធារណជនទៅលើពង្រាង EAP មានរយៈពេល 14 ថ្ងៃ | ថ្ងៃទី 16 ខែកក្កដា ឆ្នាំ 2019 ដល់ថ្ងៃទី30 ខែសីហា ឆ្នាំ 2019 |
| សេចក្តីជូនដំណឹងដល់ជាសាធារណៈរយៈពេល 10 ថ្ងៃ នៃសវនាការដើម្បីពិចារណាទៅលើពង្រាង EAP | ថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2019 |
| សវនាការសាធារណៈលើកទីមួយ ពីការពិចារណាទៅលើពង្រៀង EAP | ថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2019<br>ម៉ោង 5:30-7:30 ល្ងាច<br>70 W. Hedding St.<br>San Jose, CA 95110<br>អង្គជំនុំជម្រះរបស់គណៈកម្មការអ្នកគ្រប់គ្រង |
| សវនាការសាធារណៈលើកទីពីរ ពីការពិចារណាទៅលើពង្រៀង EAP | 4 កញ្ញា 2019<br>ម៉ោង 6-8 ល្ងាច<br>70 W. Hedding St.<br>San Jose, CA 95110<br>អង្គជំនុំជម្រះរបស់គណៈកម្មការអ្នកគ្រប់គ្រង |
| រយៈពេលដើម្បីកែសម្រួលពង្រាង EAP ក្រោយពីសវនាការសាធារណៈ | ថ្ងៃទី 30 ខែសីហា ឆ្នាំ 2019 ដល់<br>ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2019 |
| បោះពុម្ពផ្សាយ EAP ដែលកែសម្រួលរួចគ្រប់ភាសាទាំងអស់ | ថ្ងៃទី 11 ខែតុលា ឆ្នាំ 2019 |
| ការផ្តល់មតិយោបល់ពីសាធារណជនទៅលើខ្លឹមសារ EAP ដែលត្រូវបានកែសម្រួលរួចមានរយៈពេល 14 ថ្ងៃ | ថ្ងៃទី 11 ខែតុលា ឆ្នាំ 2019 ដល់<br>ថ្ងៃទី 25 ខែតុលា ឆ្នាំ 2019 |
| អនុម័ត និង បោះពុម្ពផ្សាយ EAP ចុងក្រោយ | ថ្ងៃទី 15 ខែវិច្ឆិកា ឆ្នាំ 2019 |
| ផ្នែកស្តីពីការអប់រំនិងការផ្សព្វផ្សាយនៃ EAP ត្រូវបញ្ជូនទៅកាន់រដ្ឋលេខាធិការដើម្បីសុំការយល់ព្រម | ថ្ងៃទី 15 ខែវិច្ឆិកា ឆ្នាំ 2019 |

# សេចក្តីជូនដំណឹងជាសាធារណៈ

តាមរយៈកម្មវិធីបអ្នកញ្ជូនសារពីរនាក់ សាធារណជននឹងត្រូវបានជូនដំណឹងឲ្យជ្រាបថាអ្នកបោះឆ្នោតទាំងអស់នឹងទទួលបានសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍។ សេចក្តីជូនដំណឹងនឹងជម្រាបដល់អ្នកបោះឆ្នោតថាការបោះឆ្នោតតាមសន្លឹកឆ្នោតដែលត្រូវបានផ្ញើមកតាមប្រៃសណីយ៍ នឹងត្រូវធ្វើឡើង ហើយជម្រាបថាអ្នកបោះឆ្នោតអាចបោះឆ្នោតរបស់គេបានតាមមធ្យោបាយមួយក្នុងចំណោមកម្មវិធីបី៖ ដោយផ្ញើតាមប្រៃសណីយ៍ (តែមដែលបានបង់ថ្លៃរួច) នៅតាមទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយ ឬ ក៏នៅតាមមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធី។ សេចក្តីជូនដំណឹងនឹងរួមបញ្ចូលទាំងតំណភ្ជាប់ទៅកាន់ទីតាំងដែលអ្នកបោះឆ្នោតអាចចូលទៅមើលកាលបរិច្ឆេទ ទីតាំង និងពេលវេលា ដែលទីតាំងមណ្ឌលបោះឆ្នោត និងប្រអប់ទម្លាក់សន្លឹកឆ្នោតនឹងត្រូវបើកដំណើរការ ក៏ដូចជាកាលបរិច្ឆេទសម្រាប់សំណើសុំសន្លឹកឆ្នោតបោះតាមសំបុត្រនៅក្នុងទម្រង់មួយដែលអាចបោះបាន ឬ ជាភាសាមួយ

[21] តារាងពេលវេលាគឺជាការប៉ាន់ស្មាន ហើយវាអាចនឹងមានការផ្លាស់ប្តូរ។

ក្នុងចំណោមភាសាទាំងប្រាំបីដែលបានផ្តល់ជូន ក្រៅពីភាសាអង់គ្លេស ។ ព័ត៌មានបន្ថែមដែលត្រូវបានផ្តល់តាមសំបុត្រដោយផ្ទាល់រួមមាន៖ ខ្លឹមសារទាក់ទងទៅនឹងការបញ្ជាក់ពីលំនៅដ្ឋាន និង ការផ្ទៀងផ្ទាត់ព័ត៌មានស្តីពីការបោះឆ្នោត សំបុត្រត្រូវឆ្លើយតប ព័ត៌មានស្តីពីមណ្ឌលបោះឆ្នោតសំខាន់ៗ សេចក្តីណែនាំព័ត៌មានលម្អិតស្តីពីការបោះឆ្នោតរបស់រដ្ឋនិងខោនធី និងសេចក្តីណែនាំស្តីពីការធ្វើបច្ចុប្បន្នភាពលើឈ្មោះ និង/ឬ គណបក្សរបស់ខ្លួន ។ សេចក្តីជូនដំណឹងនឹងផ្តល់ដល់អ្នកបោះឆ្នោតផងដែរនូវតំណភ្ជាប់ទៅកាន់គេហទំព័រ ROV, លេខទូរស័ព្ទ និង លេខទូរស័ព្ទមិនគិតថ្លៃដើម្បីស្នើសុំជំនួយតាម (866) 430-VOTE ។

សំបុត្រផ្ទាល់លើកទីមួយនឹងត្រូវផ្ញើមកប្រមាណជា 90 ថ្ងៃ មុនការបោះឆ្នោត (E-90) បន្តដោយសំបុត្របន្ទាប់ត្រូវបានផ្ញើមកប្រមាណជា 29 ថ្ងៃ មុនការបោះឆ្នោត (E-29) ។

បន្ថែមទៅលើសំបុត្រទាំងពីរដែលតម្រូវដោយក្រមបោះឆ្នោតនោះ ROV ក៏នឹងរៀបចំសំបុត្រទីបីសម្រាប់អ្នកបោះឆ្នោតដែលចុះឈ្មោះយឺតពេល ហើយមិនបានទទួលសេចក្តីណែនាំព័ត៌មានស្តីពីការបោះឆ្នោត ។ សំបុត្រផ្ទាល់មួយនេះនឹងត្រូវផ្ញើមកប្រមាណជា 15 ទៅ 10 ថ្ងៃ មុនការបោះឆ្នោត សេចក្តីជូនដំណឹងជាសាធារណៈ និងព័ត៌មានទាំងអស់ដែលពាក់ព័ន្ធដល់ច្បាប់ VCA នឹងត្រូវចុះផ្សាយនៅលើគេហទំព័ររបស់របស់ ROV ក្នុងទម្រង់ដែលអាចទទួលបាន។

## គណៈកម្មការភាពងាយស្រួលនៃផ្នែកភាសា និង គណៈកម្មាធិការប្រឹក្សាកម្មវិធីងាយស្រួលក្នុងការបោះឆ្នោត

មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោត (ROV) ខោនធី Santa Clara បានបង្កើតគណៈកម្មការប្រឹក្សាពីរតាមរយៈដំណើរការសម្របសម្រួលនៃការអភិវឌ្ឍដំណើរការផ្ទៃក្នុង ភាគីពាក់ព័ន្ធ និង ធាតុចូលពីសាធារណជន ព្រមទាំងតាមរយៈមតិត្រឡប់ពីខោនធីនានា ដែលបានអនុវត្តច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត (VCA)។ គណៈកម្មាធិការទីមួយគឺគណៈកម្មាធិការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC) ដែលនឹងប្រមូលធាតុចូលពីសហគមន៍និយាយភាសាដែលមានភាគតិចនានាពីមធ្យោបាយទាំងឡាយដែលមណ្ឌលបោះឆ្នោតគំរូអាចជួយផ្តល់សេវាបានប្រសើរជាងមុនដល់អ្នកបោះឆ្នោត ដែលនិយាយភាសាជាចំបងក្រៅពីអង់គ្លេសនោះ។ គណៈកម្មាធិការទីពីរគឺជាគណៈកម្មាធិការទីប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC) ដែលនឹងប្រមូលធាតុចូលពីអ្នកបោះឆ្នោតពាក់ព័ន្ធនឹងការព្រួយបារម្ភទៅលើភាពដែលអាចបោះឆ្នោតបាន ដូចជាមនុស្សចាស់ជរា ឬ អ្នកបោះឆ្នោតដែលមានពិការភាព ដើម្បីធានាថាតម្រូវការក្នុងការបោះឆ្នោត និងការព្រួយបារម្ភនានារបស់ពួកគេត្រូវបានដោះស្រាយ។

សមាជិកភាពសម្រាប់គណៈកម្មាធិការទាំងនេះ នឹងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈការធ្វើបណ្តាញនិងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមផ្សេងៗរាប់តាំងពីអង្គការមិនរកកម្រៃ និងអង្គការផ្អែកលើមូលដ្ឋានសហគមន៍ ដើម្បីក្រុងទាំងឡាយនៅក្នុងខោនធី Santa Clara។ កិច្ចប្រជុំលើកដំបូងទាំងរបស់ LAAC និង VAAC ត្រូវបានប្រើប្រាស់ដើម្បីបង្កើតគណៈកម្មាធិការ និងកំណត់គោលដៅរបស់គណៈកម្មាធិការនីមួយៗ។ កាលបរិច្ឆេទ ពេលវេលា និង ទីតាំង នៃកិច្ចប្រជុំមួយចំនួនដំបូងរបស់គណៈកម្មាធិការនីមួយៗមានដូចខាងក្រោម៖

| គណៈកម្មាធិការប្រឹក្សាការទទួលបានភាសា (LAAC) | | |
|---|---|---|
| **ថ្ងៃទី** | **ទីតាំង** | **ម៉ោង** |
| ថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 | មជ្ឈមណ្ឌលមិនស្វែងរកកម្រៃ Sobrato<br>1400 Parkmoor Ave., San Jose, CA 95126 | 3:00 – 5:00 រសៀល |
| ថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2019 | មជ្ឈមណ្ឌលមិនស្វែងរកកម្រៃ Sobrato<br>1400 Parkmoor Ave., San Jose, CA 95126 | 3:00 – 5:00 រសៀល |
| ថ្ងៃទី 17 កក្កដា ឆ្នាំ 2019 | មជ្ឈមណ្ឌលមិនស្វែងរកកម្រៃ Sobrato<br>1400 Parkmoor Ave., San Jose, CA 95126 | 2:00 – 4:00 រសៀល |

| គណៈកម្មាធិការប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC) | | |
|---|---|---|
| **ថ្ងៃទី** | **ទីតាំង** | **ម៉ោង** |
| ថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2019 | សាលប្រជុំ ROV<br>1555 Berger Dr. Bldg. 2, San Jose, CA 95112 | 3:00 – 5:00 រសៀល |
| ថ្ងៃទី 18 ខែមិថុនា ឆ្នាំ 2019 | សាលប្រជុំ ROV<br>1555 Berger Dr. Bldg. 2, San Jose, CA 95112 | 3:00 – 5:00 រសៀល |
| ថ្ងៃទី 16 ខែកក្កដា ឆ្នាំ 2019 | មជ្ឈមណ្ឌលរស់នៅដោយឯករាជ្យ Silicon Valley<br>បន្ទប់គណៈកម្មការ<br>25 N. 14th St., Suite 1000, San Jose, CA 95112 | 10:00am – 12:00pm |

បញ្ជីនៃកិច្ចប្រជុំទាំងអស់របស់ LAAC និង VAAC នឹងត្រូវចុះផ្សាយ និងរក្សាទុកនៅលើគេហទំព័រ ROV www.sccvote.org/voterschoice. របៀបវារៈនិងរបាយការណ៍កិច្ចប្រជុំ LAAC អាចឃើញនៅក្នុងសេចក្ដីបន្ថែម K ហើយរបៀបវារៈនិងរបាយការណ៍កិច្ចប្រជុំ VAAC នៅក្នុងសេចក្ដីបន្ថែម L។

# ផ្នែកទី 2 – ការអប់រំ និង ផែនការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត

ច្បាប់ស្តីពីសកម្មភាពនៃការជ្រើសរើសរបស់អ្នកបោះឆ្នោត (VCA) កំណត់ដល់ខោនធីណាដែលកំពុងអនុវត្តច្បាប់ VCA ឲ្យអនុវត្តផងដែរនូវផែនការអប់រំ និង ផែនការផ្សព្វផ្សាយ ដែលផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីវិធានការនៃច្បាប់ VCA។ កាន់តែជាក់លាក់ជាងនេះទៅទៀត ច្បាប់ក៏តម្រូវឲ្យការផ្សព្វផ្សាយតាមគោលដៅឲ្យទៅដល់អ្នកបោះឆ្នោតដែលនិយាយភាសាសំខាន់ដែលក្រៅពីភាសាអង់គ្លេស ក៏ដូចជាអ្នកបោះឆ្នោតដែលមានពិការភាព ដើម្បីអប់រំដល់សហាគមន៍ពីសេវាដែលមានផ្តល់ជូន ។

មន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត (ROV) ខោនធី Santa Clara មានក្រុមផ្សព្វផ្សាយនិងកម្មវិធីដែលមានស្រាប់ ហើយឧស្សាហ៍ចូលរួមក្នុងព្រឹត្តិការណ៍មួយចំនួនពេញមួយឆ្នាំដើម្បីរក្សាវត្តមានក្នុងសហាគមន៍ ក៏ដូចជាដើម្បីផ្តល់សេវាចុះឈ្មោះអ្នកបោះឆ្នោតនិងការអប់រំដល់អ្នកបោះឆ្នោតជាទូទៅ ។ ផ្នែកស្តីពីការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោតនៃ EAP បង្ហាញជាគ្រោងនូវរបៀបដែល ROV នឹងទាញយកឥទ្ធិពលពីវិធីសាស្ត្រផ្សព្វផ្សាយនិងរួមជាមួយនឹងវិធីថ្មី ដើម្បីឲ្យបានទៅដល់សហាគមន៍ដើម្បីអប់រំដល់សាធារណជនអំពីច្បាប់ VCA ។ សកម្មភាពផ្សព្វផ្សាយនឹងត្រូវរៀបចំឡើងដោយមានគោលដៅបង្កើតភាពជាដៃគូជាមួយនឹងសហាគមន៍ ពង្រីកឱកាសចូលរួមរបស់ពលរដ្ឋ និង ការធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍របស់អ្នកបោះឆ្នោតជាមួយនឹងគំរូមណ្ឌលបោះឆ្នោត ។

## ភាគទី 1៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត – ទូទៅ

បន្ថែមទៅលើព្រឹត្តិការណ៍ទាំងឡាយដែល ROV បានចូលរួម និង បានធ្វើការផ្សព្វផ្សាយកន្លងមក បន្តការអប់រំនិងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោតត្រូវបានធ្វើផែនការដើម្បីគ្របដណ្តប់ទៅលើប្រជាសាសន៍របស់ខោនធីឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ មានផែនការជាច្រើនដើម្បីកៀរគរដល់សហាគមន៍ទាំងឡាយដែលមានប្រវត្តិសាស្ត្រដែលប្រជាជនមិនបានទទួលសេវាជិតដល់។

សហាគមន៍មួយចំនួនដែល ROV មានគម្រោងផ្សព្វផ្សាយទៅដល់នោះរួមមាន សហាគមន៍មនុស្សចាស់ សហាគមន៍ជនជាតិដើម/ភាសា សហាគមន៍យុវវ័យ សហាគមន៍និស្សិត សហាគមន៍មិនសូវទទួលបានការយកចិត្តទុកដាក់ និងក្រុមពលរដ្ឋរស់ក្នុងសហាគមន៍ជុំវិញ ។ ROV ក៏មានផែនការទាក់ទងជាមួយនឹងអង្គការតាមសហាគមន៍ (CBOs) ជាង 100 ដើម្បីរៀនសូត្រពីការងារដែលអង្គការទាំងនោះផ្តល់ដល់សហាគមន៍របស់ពួកគេ និងរបៀបដែលក្រុមពង្រីកសេវារបស់ ROV អាចចូលរួមបាន។ គោលដៅគឺត្រូវធ្វើការជាមួយនឹង CBOs និងសហាគមន៍ទាំងអស់ដើម្បីធានាឲ្យបាននូវកម្មវិធីអប់រំអ្នកបោះឆ្នោតមួយប្រកបដោយជោគជ័យ។

### ការប្រើប្រព័ន្ធផ្សព្វផ្សាយ

ROV នឹងផ្តល់នូវព័ត៌មានអំពីគំរូមណ្ឌលបោះឆ្នោត ដំណើរការបោះឆ្នោតតាមសំបុត្រ ជម្រើសបោះឆ្នោតមុនកាលកំណត់ និងឱកាសធ្វើការនៅតាមមណ្ឌលបោះឆ្នោតក្នុងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយចាប់ផ្តើមនៅចុងរដូវក្តៅ ឬ ដើមរដូវស្លឹកឈើជ្រុះឆ្នាំ 2019 ។ យុទ្ធនាការតំណាងឲ្យការវិនិយោគដ៏ធំធេងនៅក្នុងការខិតខំប្រឹងប្រែងអប់រំសាធារណជនពីការផ្លាស់ប្តូរដែលនឹងចូលមកដល់នៅក្នុងគំរូនិងចំនួនបោះឆ្នោតចំពោះការផ្សព្វផ្សាយដ៏ធំបំផុតធ្វើឡើងជាប្រវត្តិសាស្ត្ររបស់ ROV។ ប្រព័ន្ធផ្សព្វផ្សាយទាំងឡាយរាប់បញ្ចូលដោយមិនកំណត់មានដូចខាងក្រោម៖

1. ស្ថានីយ៍ទូរទស្សន៍នៅក្នុងស្រុកនិងខ្សែកាបតាមសហាគមន៍
    a. Comcast
    b. Univision
    c. Telemundo
    d. Namaste TV
    e. Crossing TV

2. កាសែត (តាមតំបន់និងសហគមន៍)
    a. The Mercury News
    b. Metro
    c. Morgan Hill Times
    d. Gilroy Dispatch
    e. El Observador
    f. Epoch Times
    g. India West
    h. Korea Times
    i. Nichi Bei Weekly
    j. Philippine News
    k. San Jose State Spartan Daily
    l. សារព័ត៌មានសាកលវិទ្យាល័យ Santa Clara
    m. Stanford Daily
    n. Viet Nam Daily
    o. World Journal
    p. N & R
    q. China Press
    r. JWeekly
    s. Spotlight
    t. Bayspo Magazine
    u. Daily Post
    v. India Current
3. វិទ្យុ
    a. KBAY/KEZR
    b. KFOX
    c. KRTY/KLIV
    d. សម្លេងនៃក្តីសង្ឃឹម
    e. Sing Tao
    f. Univision
    g. Vien Thao
    h. Celina Rodriguez
    i. China Press
    j. Radio Zindagi
4. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនិងគេហទំព័រសម្រាប់ ROV និង ខោនធី
    a. ROV Facebook គេហទំព័រ: https://www.facebook.com/sccvote
    b. County Facebook គេហទំព័រ: https://www.facebook.com/county.of.santa.clara
    c. ROV Twitter គេហទំព័រ: https://twitter.com/sccvote
    d. County Twitter គេហទំព័រ: https://twitter.com/SCCgov
    e. ROV Instagram គេហទំព័រ: www.instagram.com/sccvote
    f. កម្មវិធី Nextdoor: (ស្រាវជ្រាវសម្រាប់ការទំនាក់ទំនងនិងប្រព័ន្ធផ្សព្វផ្សាយខោនធី Santa Clara)
    g. បញ្ជីការងារព្រឹត្តិបត្រព័ត៌មានខោនធី
5. ROV YouTube: https://www.youtube.com/sccvote
6. ប្រព័ន្ធរថយន្តសាធារណៈ:ផ្ញើសារនៅលើរថយន្តក្រុងអាជ្ញាធរដឹកជញ្ជូន Valley
7. ការផ្សព្វផ្សាយតាមរយៈសិទ្ធិប្រើយីហោសម្ព័ន្ធកីឡាធំៗមានមូលដ្ឋាននៅក្នុងខោនធី Santa Clara
8. តាមដានពាណិជ្ជកម្មតាមទូរទស្សន៍នៅតាមការិយាល័យសាខារបស់ក្រសួងយានយន្ត

9. ការចែករំលែកសម្ភារៈផ្សព្វផ្សាយជាមួយក្រុមទាំងឡាយដូចជាដៃគូសហគមន៍ អង្គការជួយសង្គ្រោះជនពិការ មន្ត្រីជាប់ឆ្នោត មណ្ឌលពិសេស មណ្ឌលសិក្សាធិការ អង្គការតាមសហគមន៍ និងអង្គការសាសនានៅទូទាំងខោនធី
10. សេចក្តីប្រកាសអំពីសេវាសាធារណៈ (PSAs) នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់បន្ថែមទៅលើយុទ្ធនាការផ្សាយពាណិជ្ជកម្មនៅតាមសារព័ត៌មានដែលមាន។ PSAs ទាំងនេះនឹងក្តោបទៅលើប្រធានបទរួមមានព័ត៌មានទូទៅស្តីពីច្បាប់ VCA, ព័ត៌មានជាភាសាជាក់លាក់អំពីច្បាប់ VCA និងប្រព័ន្ធទូរស័ព្ទផ្តល់ជំនួយទាន់ហេតុការណ៍ដោយមិនអស់ប្រាក់ និងជម្រើសនានាដែលអាចទទួលបាននៅតាមមណ្ឌលបោះឆ្នោតនិងការបោះឆ្នោតតាមសំបុត្រពីចម្ងាយ ។

ROV នឹងប្រើផងដែរនៃប្រព័ន្ធសោតទស្សន៍ ដែលនឹងត្រូវចែកចាយឲ្យបានទូលំទូលាយក្នុងទម្រង់ដែលអាចទទួលបាន ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីការបោះឆ្នោតដែលខិតជិតចូលមកដល់។ គោលដៅគឺត្រូវពង្រីកសេវាទៅដល់អ្នកបោះឆ្នោតនៅក្នុងខោនធីទាំងអស់ រាប់បញ្ចូលទាំងអ្នកបោះឆ្នោតដែលមានពិការភាព ដូចជាអ្នកទាំងនោះដែលជាជនគរ ឬ ថ្លង់ និងអ្នកបោះឆ្នោតដែលមើលមិនឃើញ ឬពិការភ្នែក។

## ផែនការវត្តមានសហគមន៍ និង សម្ភារៈអប់រំអ្នកបោះឆ្នោត

ROV បន្តចូលរួមនៅក្នុងព្រឹត្តិការណ៍សហគមន៍រាប់រយពេញមួយឆ្នាំ។ ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីការផ្លាស់ប្តូរនៅក្នុងរបៀបធ្វើការបោះឆ្នោតនោះ ព័ត៌មានស្តីពី VCA កំពុងត្រូវបានបន្ថែមទៅក្នុងកម្មវិធីពង្រីកសេវាផ្សេងៗ។ ROV ក៏កំពុងតែធ្វើការយ៉ាងសកម្មជាមួយនឹង CBOs ពីវិធីផ្តល់ព័ត៌មានឲ្យបានប្រសើរបំផុតដល់សហគមន៍របស់គេពីគំរូការបោះឆ្នោតថ្មី។ សម្ភារៈអប់រំ និងបុគ្គលិកកំពុងត្រូវបានត្រៀមសម្របសម្រួលដល់ការអប់រំអ្នកបោះឆ្នោត។

បទបង្ហាញទាំងឡាយដែលត្រូវបានធ្វើឡើងដល់អង្គការនានា ដែលបានដឹងអំពីមណ្ឌលបោះឆ្នោតគំរូថ្មីដែលនឹងខិតជិតចូលមកដល់ ហើយដែលចង់រៀនបន្ថែមទៀត ដូចជា៖

- សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Cupertino-Sunnyvale
- សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Mountain View-Los Altos
- ក្លឹបប្រជាធិបតេយ្យសតវត្សទី 21st
- ការិយាល័យគោលនយោបាយរបស់ស្ត្រី
- ក្លឹបប្រជាធិបតេយ្យ ខោនធី South
- សមាគមសហគមន៍ Almaden Valley
- ការិយាល័យអប់រំខោនធី Santa Clara
- សម្ព័ន្ធភាព API Justice
- ក្រុមប្រឹក្សាភាពជាអ្នកដឹកនាំសមធម៌ស្ត្រី 2020
- មូលនិធិសហគមន៍ Silicon Valley (SVCF) និងក្រុមប្រឹក្សាមិនរកប្រាក់ចំណេញ Silicon Valley (SVCN) អាហាររួបរួមសហគមន៍
- ចំការផ្លែឈើរួមក្រុង
- ក្មេងស្រីដែលទទួលបានជ័យលាភីក្នុងមុខវិជ្ជាដែលមិនជាប្រពៃណី
- ការិយាល័យសេវាកម្មជួយរកការងារ CalWORKs

ការចាប់ផ្តើមកិច្ចប្រជុំស្តីពីច្បាប់ VCA ត្រូវបានធ្វើឡើង ហើយមានអ្នកចូលរួមជា CBOs មានច្រើនជាងសាមសិបនាក់ ដែលសុទ្ធសឹងតែជាអ្នកមានសក្តានុពលចាប់អារម្មណ៍ជួយ ROV តាមមកម្មវិធីផ្សេងៗ ។ គោលដៅរបស់ ROV គឺត្រូវបណ្តុះបណ្តាល CBOs ទាំងអស់ ដែលចាប់អារម្មណ៍ក្នុងការជួយ ROV ប្រជាពលរដ្ឋក្នុងការអប់រំ ខោនធី ពីមណ្ឌលបោះឆ្នោតគំរូ។

ការផ្សារភ្ជាប់ទៅនឹងសហគមន៍ផ្សេងទៀតបច្ចុប្បន្នកំពុងតែស្ថិតក្នុងដំណើរការធ្វើផែនការក្នុងខណៈដែលកំពុងសរសេរឯកសារនេះ។ នៅពេលបច្ចុប្បន្ននេះ ROV កំពុងបន្តអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយសាធារណជនមានដូចជា ប័ណ្ណព័ត៌មានជ្រើសរើសមណ្ឌលបោះឆ្នោត និងបទបង្ហាញពីច្បាប់ VCA ដើម្បីចែកទៅឲ្យអង្គការនិងបុគ្គលទាំងអស់ ដែលចាប់អារម្មណ៍ក្នុងការអប់រំសហគមន៍របស់គេផ្ទាល់ខ្លួន។ ព័ត៌មានពិស្តារបន្ថែមអំពីផែនការពង្រីកសេវាសហគមន៍ មាននៅក្នុងសេចក្តីបន្ថែម M។

## កម្មវិធីបញ្ជូនសារដោយផ្ទាល់

ROV នឹងទាក់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចម្នាក់ៗនៅក្នុង ខោនធី Santa Clara តាមសំបុត្រពីរ (2) ផ្សេងគ្នា ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីការបោះឆ្នោតនិងការផ្សព្វផ្សាយដែលនឹងចូលមកដល់តាមរយៈប្រព័ន្ធទូរស័ព្ទមិនអស់ប្រាក់ ដែលជាខ្សែទូរស័ព្ទជំនួយដល់អ្នកបោះឆ្នោតទាន់ហេតុការណ៍ (866) 430-VOTE ។ សំបុត្រនឹងផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតស្តីពីការគំរូការបោះឆ្នោតថ្មី, ការបោះឆ្នោតដែលនឹងចូលមកដល់, កន្លែងដែលគេអាចស្វែងរកព័ត៌មានបន្ថែមស្តីពីការផ្លាស់ប្តូរទាំងនេះ តំណភ្ជាប់ទៅកាន់កន្លែងដែលអ្នកបោះឆ្នោតអាចចូលទៅរកបានព័ត៌មានស្តីពីថ្ងៃទី, ទីតាំង, និងម៉ោងដែលទីតាំងមណ្ឌលបោះឆ្នោត និងប្រអប់ទម្លាក់សន្លឹកឆ្នោតនឹងបើកដំណើរការ ។ ព័ត៌មានបន្ថែមដែលត្រូវបានផ្តល់តាមសំបុត្រដោយផ្ទាល់រួមមាន៖ ខ្លឹមសារទាក់ទងទៅនឹងការបញ្ជាក់ពីលំនៅដ្ឋាន និងការផ្ទៀងផ្ទាត់ព័ត៌មានស្តីពីការបោះឆ្នោត សំបុត្រត្រូវឆ្លើយតប ព័ត៌មានស្តីពីមណ្ឌលបោះឆ្នោតសំខាន់ៗ សេចក្តីណែនាំព័ត៌មានលម្អិតស្តីពីការបោះឆ្នោតរបស់រដ្ឋ និងខោនធី និងសេចក្តីណែនាំស្តីពីការធ្វើបច្ចុប្បន្នភាពលើឈ្មោះនិង/ឬគណបក្សរបស់ខ្លួន ។ កម្មវិធីបញ្ជូនសារទីបីនឹងសម្រាប់អ្នកបោះឆ្នោតទាំងឡាយដែលចុះឈ្មោះយឺតពេល ហើយនឹងមិនទាន់ទទួលបានសេចក្តីណែនាំដែលមានផ្ទុកព័ត៌មានស្តីពីការបោះឆ្នោត។ មួយនៃកម្មវិធីបញ្ជូនសារទាំងបីនឹងដាក់បញ្ចូលកម្មវិធីក្រុមការងារនិវាសដ្ឋាន អនុញ្ញាតឲ្យអ្នកបោះឆ្នោតធ្វើបច្ចុប្បន្នភាពព័ត៌មានជាក់លាក់អំពីកំណត់ត្រាបោះឆ្នោតរបស់គេ។ សារដែលផ្ញើរទៅនីមួយៗ នឹងត្រូវបកប្រែជាប្រាំបីភាសា ដើម្បីចែកចាយទៅដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ដែលនិយាយភាសាជាចម្បងដែលមិនមែនជាភាសាអង់គ្លេស ។

## ធនធានអប់រំដល់អ្នកបោះឆ្នោតមាននៅលើគេហទំព័រ ROV

ឯកសារអប់រំផ្សព្វផ្សាយដល់អ្នកបោះឆ្នោតទាំងអស់របស់ ROV រាប់បញ្ចូលទាំងព័ត៌មានស្តីពីច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត ហើយនឹងអាចរកបានជាអេឡិចត្រូនិកនៅលើគេហទំព័រមាន ROV ។ នៅមុនការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា ឆ្នាំ 2020 គេហទំព័រ ROV នឹងមានព័ត៌មានដូចខាងក្រោម៖

- ព័ត៌មានទូទៅស្តីពីច្បាប់ VCA
- ទីតាំងនិងម៉ោងធ្វើការមណ្ឌលបោះឆ្នោត និងប្រអប់ទម្លាក់សន្លឹកឆ្នោត
- ខ្សែទូរស័ព្ទជំនួយដល់អ្នកបោះឆ្នោតដោយមិនគិតថ្លៃរបស់ ROV
- ឯកសារ EAP
- ឯកសារផ្សព្វផ្សាយពី VCA
- វីដេអូ និងបទបង្ហាញពីការអប់រំពី VCA
- កាលវិភាគសិក្ខាសាលា និងការផ្សព្វផ្សាយ

- ផែនទីពាក់ព័ន្ធ VCA
- មានបុគ្គលផ្តល់ជាជំនួយខាងផ្នែកភាសាដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតនិមួយៗ

# ផ្នែកទី 2៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត – សហគមន៍ជនជាតិដែលនិយាយភាសាមានភាគតិច

មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោត (ROV) បានបង្កើតគណៈកម្មាធិការទីមួយគឺគណៈកម្មាធិការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC) នៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 ដើម្បីប្រមូលធាតុចូលពីសហគមន៍ដល់ជនដែលនិយាយភាសាមានភាគតិចពីមធ្យោបាយដែលមណ្ឌលបោះឆ្នោតគំរូអាចផ្តល់សេវាបានកាន់តែប្រសើរដល់អ្នកបោះឆ្នោតដែលនិយាយភាសាជាចម្បងក្រៅពីភាសាអង់គ្លេស។ គណៈកម្មាធិការនេះនឹងផ្តល់មតិត្រឡប់ពីគំនិតផ្សេងៗដូចជាទីតាំងមណ្ឌលបោះឆ្នោត ក៏ដូចជាលក្ខណៈនិងសេវាទាំងឡាយណាដែលនឹង ឬ គួរតែត្រូវបានផ្តល់ជូន។ គណៈកម្មាធិការនឹងស្ថិតនៅប្រចាំការក្នុងអំឡុងពេលនៃវដ្តដំណើរការបោះឆ្នោត ឆ្នាំ 2020 ដើម្បីធ្វើជាកម្មវិធីក្នុងការទទួលដំណឹងពីសហគមន៍ ។

## ធ្វើការកំណត់សហគមន៍ដល់ជនដែលនិយាយភាសាមានភាគតិច

សហគមន៍ជនដែលនិយាយភាសាមានភាគតិចអាចត្រូវបានកំណត់ដោយផ្អែកទៅលើសំណើស្នើសុំយកភាសាដែលគេពេញចិត្តពីក្នុងបញ្ជីអ្នកបោះឆ្នោតនៅក្នុងខោនធី Santa Clara។ ប្រើព័ត៌មាននេះ បូករួមជាមួយនឹងព័ត៌មានជំរឿន និង ព័ត៌មានប្រជាសាសន៍ដែលអាចរកបានជាសាធារណៈផ្សេងទៀត ROV បានបង្កើតផែនទីតំបន់ភាសាដែលប្រើលើសលុប។ ការពង្រីកសេវានឹងត្រូវឆ្ពោះទៅកាន់ទីតាំងគោលដៅទាំងនេះ ដែលជាផ្នែកមួយនៃការអប់រំនិងការពង្រីកសេវាដល់អ្នកបោះឆ្នោតដែលបានគ្រោងទុក។ ROV ក៏កំពុងតែប្រមូលធាតុចូលពីសហគមន៍ភាសាភាគតិចផ្សេងៗ ដើម្បីកំណត់ពីវិធីសាស្ត្រពង្រីកសេវានិងព្រឹត្តិការណ៍សហគមន៍ដែលអាចនឹងមានប្រយោជន៍ចូលរួម។

## សហគមន៍ជនដែលនិយាយភាសាមានភាគតិចដែលត្រូវផ្តល់សេវាជូន

ROV ផ្តល់សេវាជាប្រាំបួនភាសា (9) រួមទាំងអង់គ្លេសផង ។ ភាសាប្រាំតម្រូវដោយសហព័ន្ធមាន៖ អង់គ្លេស, ចិន, អេស្ប៉ាញ, កាតាឡុក, និង វៀតណាម ។ ភាសាពីរដែលត្រូវបានកំណត់ដោយរដ្ឋ៖ ភាសាខ្មែរ និងភាសាកូរ៉េ។ ភាសាដែលនៅសល់ពីរទៀតមានភាសាហ៊ិនឌី និងភាសាកូរ៉េ ជាប្រវត្តិសាស្ត្រត្រូវបានផ្តល់ដោយ ROV ដោយសារតែវត្តមានដ៏ធំនៃសហគមន៍ទាំងនេះនៅក្នុងខោនធី។ សន្លឹកឆ្នោតផ្លូវការ, ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ និងស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្ន, និងស្លាកសញ្ញាទាំងអស់នៅតាមមណ្ឌលបោះឆ្នោតនិងប្រអប់ទម្លាក់សន្លឹកឆ្នោត នឹងត្រូវផ្តល់ទាំងប្រាំបួនភាសា ។ សេចក្តីណែនាំដែលមានផ្ទុកព័ត៌មានស្តីពីការបោះឆ្នោតរបស់ខោនធី (CVIGs) នឹងមានផ្តល់ជូនតែភាសាដែលកំណត់ដោយសហព័ន្ធទៅតាមអ្វីដែលបានអនុវត្តពីមុនមក។ បន្ថែមលើនេះទៀត បុគ្គលិកមណ្ឌលបោះឆ្នោតចេះពីរភាសា នឹងត្រៀមរួចជាស្រេចដើម្បីជួយដល់ភាសាផ្សេងទៀត និងត្រៀមភាសានិយាយនៅក្នុងខោនធី ដូចជាភាសាចិនកាតាំង ភាសាហ្វាស៊ី ភាសាហ្គូចារ៉ា ភាសាណេប៉ាល់ ភាសាព័រទុយហ្គាល់ ភាសាភូចាប៊ី ភាសារុស្ស៊ី ភាសាស៊ីរី ភាសាតាមិល ភាសាតេឡឺ និង ភាសាថៃ។ ដោយផ្អែកលើការផ្គូផ្គង និងកំណត់គោលដៅទៅលើសហគមន៍ជាក់លាក់នោះ ROV នឹងមានបំណងដាក់ជំនួយគាំទ្រផ្នែកភាសាឲ្យបានសមស្របក្នុងទម្រង់ជាមន្ត្រីបោះឆ្នោតចេះពីរភាសានៅក្នុងសហគមន៍ផ្សេងៗ។ នៅពេលបញ្ចប់ការជ្រើសរើសបុគ្គលិកតាមមណ្ឌលបោះឆ្នោតរួច ROV នឹងបង្ហោះព័ត៌មាននៅលើគេហទំព័រទាក់ទងនឹងពីលទ្ធភាពទទួលបាននូវជំនួយផ្នែកភាសាជាបុគ្គលដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតនិមួយៗ ។

ការអនុវត្តបំណងគាំទ្រដល់ភាសាឲ្យបានច្រើនតាមតែអាចធ្វើទៅបានប្រើក្នុងការបោះឆ្នោតថ្មីៗនេះ ដូច្នេះ ROV នឹងកៀរគរអតីតមន្ត្រីបោះឆ្នោត ជាការបន្ថែមចំពោះការអនុវត្តការជ្រើសរើសជាប្រពៃណីក្នុងសហគមន៍ភាសាទាំងនេះ។

## សិក្ខាសាលាអប់រំអ្នកបោះឆ្នោតសម្រាប់សហគមន៍ដែលនិយាយភាសាមានភាគតិច

ROV នឹងផ្តល់ការសិក្ខាសាលាអប់រំដល់អ្នកបោះឆ្នោតជាពីរភាសាគ្រប់ភាសាទាំងប្រាំបួន (9) ដែលបានរៀបរាប់ខាងលើ ។ សិក្ខាសាលាទាំងនេះនឹងផ្តល់ឱកាសដល់សហគមន៍ភាសានៅក្នុងខោនធី Santa Clara ដើម្បីទទួលបានព័ត៌មានអំពីដំណើរការគំរូមណ្ឌលបោះឆ្នោត បន្ថែមទៅលើសម្ភារៈនិងជំនួយដែលមានទៅតាមភាសាជាក់លាក់នីមួយៗ ។ ROV នឹងប្រើធាតុចូលបានពីសមាជិកគណៈកម្មការផ្តល់ប្រឹក្សាដើម្បីទទួលបានជំនួយផ្នែកភាសា (LAAC) ដើម្បីជ្រើសរើសទីតាំងនិងកាលបរិច្ឆេទសិក្ខាសាលា ហើយសិក្ខាសាលាទាំងអស់នឹងមានអ្នកបកប្រែទៅតាមភាសាជាក់លាក់ដើម្បីជួយដល់អ្នកចូលរួម ។ គិតត្រឹមខ្លឹមសារសំណើរនេះ ROV នឹងរៀបចំសិក្ខាសាលាអប់រំអ្នកបោះឆ្នោតជាមួយសេវាសហគមន៍កូរ៉េអាមេរិកកាំងនៅដើមខែតុលា ឆ្នាំ 2019 និងថ្មីៗនេះនៅក្នុងដំណើរការនៃការរៀបចំគម្រោងសិក្ខាសាលាជាមួយនឹងសហគមន៍ចិន, អេស្ប៉ាញ, កាតាឡុក, វៀតណាម, ហ៊ីនឌី, ខ្មែរ និង ជប៉ុន ។

## ការប្រើប្រព័ន្ធផ្សព្វផ្សាយកំណត់គោលដៅទៅលើសហគមន៍ដែលនិយាយភាសាមានភាគតិច

ភាសាភាគតិចមួយចំនួនទៀតនឹងត្រូវផ្តល់នូវព័ត៌មានពីគំរូមណ្ឌលបោះឆ្នោតនិងការបោះឆ្នោតតាមសំបុត្រ ក៏ដូចជានឹងត្រូវផ្តល់ប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់ការិយាល័យមន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត (866) 430-VOTE និងព័ត៌មានទូទៅស្តីពីការបោះឆ្នោត (408) 299-VOTE ។ សារព័ត៌មានភាសាជាក់លាក់ជាច្រើននឹងត្រូវទាញយកប្រយោជន៍ ដោយត្រូវមានវត្តមានភាសាដែលកំណត់ដោយសហព័ន្ធទាំងអស់។ ប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ រាប់បញ្ចូលដោយមិនកំណត់មានដូចខាងក្រោម៖

1. ស្ថានីយ៍ទូរទស្សន៍និងខ្សែកាបតាមសហគមន៍
    a. Univision
    b. Epoch Times
    c. Univision
    d. Namaste TV
    e. Crossing TV (អង់គ្លេស, ភាសាអង់គ្លេស+ 8 ភាសាបន្ថែមទៀត)
2. កាសែត (តាមតំបន់និងសហគមន៍)
    a. El Observador (អេស្ប៉ាញ)
    b. Epoch Times (ចិន)
    c. India West (អង់គ្លេស)
    d. Korea Times (កូរ៉េ)
    e. Nichi Bei Weekly (ជប៉ុន)
    f. Philippine News (តាកាឡុក)
    g. Viet Nam Daily (វៀតណាម)
    h. World Journal (ចិន)
    i. N & R (អង់គ្លេស)
    j. China Press (ចិន)
    k. JWeekly (ជប៉ុន)
    l. Spotlight (អង់គ្លេស)

m. Bayspo Magazine (ជប៉ុន)
n. Daily Post (អង់គ្លេស)
o. India Currents (ហិណ្ឌី)

3. វិទ្យុ
    a. Univision (អេស្ប៉ាញ)
    b. Celina Rodriquez (អេស្ប៉ាញ)
    c. សម្លេងនៃក្តីសង្ឃឹម (ចិន)
    d. Sing Tao (ចិន)
    e. Vien Thao (វៀតណាម)
    f. China Press (ចិន)
    g. Radio Zindagi (ហិណ្ឌី)
4. សារព័ត៌មានផ្សព្វផ្សាយសង្គម និងគេហទំព័រនាយកដ្ឋាន
    a. ROV Facebook គេហទំព័រ: https://www.facebook.com/sccvote
    b. County Facebook គេហទំព័រ: https://www.facebook.com/county.of.santa.clara
    c. ROV Twitter គេហទំព័រ: https://twitter.com/sccvote
    d. County Twitter គេហទំព័រ: https://twitter.com/SCCgov
    e. ROV Instagram គេហទំព័រ: www.instagram.com/sccvote
    f. កម្មវិធី Nextdoor: (ស្រាវជ្រាវសម្រាប់ការទំនាក់ទំនងនិងប្រព័ន្ធផ្សព្វផ្សាយសង្គម ខោនធី Santa Clara)
    g. បញ្ជីជាវ newsfeed ខោនធី
    h. ROV Youtube គេហទំព័រ: https://www.youtube.com/sccvote
    i. ROV គេហទំព័រ: https://www.sccvote.org
5. ព្រឹត្តិបត្រសហគមន៍ភាសាសម្រាប់ជនជាតិមានភាគតិច
6. សេចក្តីប្រកាសអំពីសេវាសាធារណៈ (PSAs) នឹងត្រូវប្រើដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតនៅតាមសហគមន៍និយាយភាសាភាគតិចពីការបោះឆ្នោតដែលនឹងចូលមកដល់ និងពីទូរស័ព្ទជំនួយបន្ទាន់ផ្នែកភាសាដោយមិនគិតថ្លៃ ។ PSAs នឹងត្រូវបកប្រែជាភាសាទាំងឡាយដែលតម្រូវដោយសហព័ន្ធ និង រដ្ឋ ហើយចែកចាយតាមរយៈទូរទស្សន៍ភាសាដែលមានភាគតិច វិទ្យុ កាសែត និង ប្រភពអនឡាញ ។

ឱកាសផ្សេងៗទាំងឡាយដើម្បីផ្តល់សេវាទៅដល់សហគមន៍ភាសាដែលមានភាគតិច ដោយរួមទាំងផ្តល់បុគ្គលិកចេះពីរភាសានៅក្នុងកម្មវិធីផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ ដូចជាកម្មវិធីបើកស្វាគមន៍ដែលបានគ្រោងទុក ដែល ROV នឹងធ្វើបទបង្ហាញពីប្រព័ន្ធបោះឆ្នោតថ្មីដែលនឹងត្រូវតម្លើងនៅតាមមណ្ឌលបោះឆ្នោត។

# មន្ត្រីបោះឆ្នោត

ដើម្បីកំណត់សមាសភាពបុគ្គលិកមណ្ឌលបោះឆ្នោត ROV នឹងជួលមន្ត្រីបោះឆ្នោត (ត្រូវបានកំណត់ដោយក្រុមបោះឆ្នោតថាជាក្រុមប្រឹក្សាបោះឆ្នោត[22])។ ការដាក់បុគ្គលិកប្រចាំការនៅតាមមណ្ឌលបោះឆ្នោតនឹងត្រូវផ្អែកទៅលើទាំងភាពជិតទៅនឹងថ្ងៃបោះ

[22] ក្រមបោះឆ្នោត ផ្នែកទី 12, មាត្រា 1 នៃជំពូក 4

ឆ្នោតនិងទំហំមណ្ឌលបោះឆ្នោត។ តាមគម្រោងត្រូវឲ្យមានពីប្រាំមួយ (6) ទៅដប់ប្រាំ (15) មន្ត្រីបោះឆ្នោតប្រចាំការនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ បុគ្គលិកជាច្រើនបន្ថែមទៀតនឹងត្រូវពង្រាយនៅតាមមណ្ឌលបោះឆ្នោតដែលមានទំហំធំជាងគេ និងក្នុងអំឡុងពេលមមាញឹកជាងគេ ក្នុងខណៈដែលថ្ងៃបោះឆ្នោតជិតចូលមកដល់។ ចាប់ពី 10 ថ្ងៃមុនថ្ងៃបោះឆ្នោតរហូតដល់ 4 ថ្ងៃមុនថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងមានសមាជិកបុគ្គលិកយ៉ាងតិច 6 នាក់ ។ ចាប់ពី 3 ថ្ងៃមុនថ្ងៃបោះឆ្នោតរហូតដល់ 1 ថ្ងៃមុនថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងមានសមាជិកបុគ្គលិកយ៉ាងតិច 11 នាក់ ។ នៅថ្ងៃបោះឆ្នោតនឹងមានសមាជិកបុគ្គលិកយ៉ាងតិច 15 នាក់ នៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។

ក៏មានផែនការត្រូវមានយ៉ាងហោចណាស់មន្ត្រីបោះឆ្នោតម្នាក់ក្នុងមួយភាសា ឬ យ៉ាងតិចបំផុតនោះ មានមន្ត្រីបោះឆ្នោតម្នាក់ចំពោះភាសាដែលប្រើច្រើនជាងគេនៅក្នុងតំបន់នៃមណ្ឌលបោះឆ្នោតនោះ។ ROV នឹងជួលបុគ្គលិកមណ្ឌលបោះឆ្នោតពីសហគមន៍ដែលមានពិពិធភាព ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីបង្កើនជំនាញដែលមានតម្រូវការជាអតិបរមា ដើម្បីដំណើរការអ្នកបោះឆ្នោត ក្នុងខណៈនោះក៏កំពុងត្រូវបានផ្ទៀងផ្ទាត់ ដើម្បីដើរតួជាអ្នកបកប្រែដល់អ្នកបោះឆ្នោតផងដែរ។ ការជ្រើសរើសបុគ្គលិកនឹងចាប់ផ្តើមឡើងដោយការទាក់ទងទៅកាន់មន្ត្រីបោះឆ្នោតចេះពីរភាសាពីមុនមក ក៏ដូចជាដំណើរការដាក់ពាក្យជ្រើសរើសដោយបើកចំហជាទូទៅផងដែរ។

## ភាគ 3៖ ព័ត៌មានទំនាក់ទំនងអ្នកបោះឆ្នោត

មន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត បានបង្កើតគណៈកម្មាធិការប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC) នៅថ្ងៃទី7 ខែមិថុនា ឆ្នាំ 2019 ដើម្បីប្រមូលធាតុចូលពីអ្នកបោះឆ្នោត ដោយពាក់ព័ន្ធនឹងការព្រួយបារម្ភទៅលើលទ្ធភាពដែលអាចបោះឆ្នោតបាន ដូចជាមនុស្សចាស់ជរា ឬ អ្នកបោះឆ្នោតមានពិការភាព ពីមធ្យោបាយនានាដែលគំរូការបោះឆ្នោតថ្មីអាចបម្រើបានប្រសើរបំផុតដល់ពួកគេ។ គណៈកម្មាធិការនេះនឹងផ្តល់មតិត្រឡប់ពីគំនិតផ្សេងៗដូចជាទីតាំងមណ្ឌលបោះឆ្នោត ក៏ដូចជាលក្ខណៈនិងសេវាទាំងឡាយណាដែលនឹង ឬ គួរតែត្រូវបានផ្តល់ជូន។ គណៈកម្មាធិការនេះនឹងស្ថិតនៅដំណើរការរហូតដល់វដ្តបោះឆ្នោត ឆ្នាំ 2020 ក្នុងនាមជាមធ្យោបាយបន្តស្តាប់និងធ្វើការជាមួយសហគមន៍ ។

### វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ពីសេចក្តីត្រូវការរបស់អ្នកបោះឆ្នោតដែលមានពិការភាព

ROV នឹងបន្តធ្វើឲ្យមានការប្រសើរឡើងអាស្រ័យទៅលើសេចក្តីត្រូវការរបស់អ្នកបោះឆ្នោតដែលមានពិការភាពត្រូវឆ្លើយតប ។ ដើម្បីក្នុងការធ្វើដូច្នេះ ROV ត្រូវវិភាគអនុសាសន៍នានាដែលទាក់ទងនឹងអ្នកបោះឆ្នោតមានពិការភាពដែលបានពីប្រភពសំខាន់បួន (4)៖ ទី (1) ពលរដ្ឋមានពិការភាព ទី (2) CBOs ដែលផ្តល់សេវាគាំទ្រដល់អ្នកបោះឆ្នោតដែលមានពិការភាព ទី (3) ខោនធីដែលកំពុងអនុវត្តច្បាប់ VCA និង ទី (4) ការិយាល័យរដ្ឋលេខា។ ដោយសារតែច្បាប់ VCA ធ្វើការផ្លាស់ប្តូរថ្មីទាំងស្រុងទៅលើរបៀបរៀបចំការបោះឆ្នោតនោះ ROV ក៏កំពុងតែចាប់ឱកាសនេះដើម្បីចាប់ផ្តើមដំណាក់កាលថ្មីនៅក្នុងការអភិវឌ្ឍទំនាក់ទំនងជាមួយអ្នកបោះឆ្នោតដែលមានពិការភាព (និង CBOs ដែលគាំទ្រដល់ពួកគេ)។

សិទ្ធិជនពិការរដ្ឋ California និងមជ្ឈមណ្ឌលរស់ដោយឯករាជ្យ Silicon Valley ជាអង្គភាពពីរដែលទាក់ទងដោយផ្ទាល់មកកាន់ ROV ពីបញ្ហាតម្រូវការរបស់អ្នកបោះឆ្នោតដែលមានពិការភាព។ ផ្តើមចេញពីការពូតដៃគ្នានេះ ROV បានបន្តពង្រឹងទំនាក់ទំនងជាមួយអង្គការដូចខាងក្រោម៖

- Vista ជាមជ្ឈមណ្ឌលសម្រាប់ជនពិការភ្នែក និង ភ្នែកដែលចុះខ្សោយ

- ក្រុមប្រឹក្សាស្តីពីពិការភាពដែលមានការអភិវឌ្ឍ – ការិយាល័យ Central Coast
- ជនពិការ
- មជ្ឈមណ្ឌលជនពិការភ្នែក Valley ខោនធី Santa Clara
- មជ្ឈមណ្ឌលភូមិភាគ San Andreas

ដំណាក់កាលថ្មីនេះបញ្ជាក់ពីសារៈសំខាន់នៃធាតុចូលដោយផ្ទាល់ពីអ្នកបោះឆ្នោតមានពិការភាព។ ROV ប្តេជ្ញាចិត្ត/បើកចំហចំពោះការពិនិត្យឡើងវិញ/ធ្វើការស្វែងយល់ទៅលើអនុសាសន៍ទាំងអស់ចេញមកដោយផ្ទាល់ពីអ្នកបោះឆ្នោត។

## ការពង្រីកសេវាទៅដល់សហគមន៍ជនមានពិការភាព

បន្ថែមទៅលើយុទ្ធនាការផ្សព្វផ្សាយទូទៅនោះ ROV នឹងផ្តោតទៅលើការផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតមានតម្រូវការដែលទទួលបាន។ នេះនឹងរាប់បញ្ចូលទាំងព័ត៌មានស្តីអំពីលទ្ធភាពអាចមានយ៉ាងតិចបំផុតនូវឧបករណ៍បោះឆ្នោតដែលអាចប្រើប្រាស់បានចំនួនបីនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ក៏ដូចជាជម្រើសស្នើសុំការប្រើប្រាស់ប្រព័ន្ធបោះឆ្នោតតាមប្រៃសណីយ៍ដែលអាចប្រើបានពីចម្ងាយ (RAVBM)។ ប្រព័ន្ធ RAVBM ត្រូវបានកំណត់សម្រាប់ប្រើប្រាស់ដោយអ្នកបោះឆ្នោតដែលបានចុះឈ្មោះដែលមានពិការភាព ក៏ដូចជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស[23]។

ឱកាសផ្សេងទៀតសម្រាប់ចែកចាយព័ត៌មានរួមមាន៖

1. អង្គការនានាដែលផ្តល់សេវានិងការគាំទ្រដល់មនុស្សចាស់ឬមានពិការភាព ដូចជាមជ្ឈមណ្ឌលរស់នៅឯករាជ្យ Silicon Valley, ក្រុមប្រឹក្សាជនពិការភ្នែក Silicon Valley, មជ្ឈមណ្ឌលជនពិការភ្នែក Santa Clara Silicon Valley រួបរួម និងបង្កើនឱកាស ក្នុងចំណោមអង្គការផ្សេងៗ
2. ដៃគូសហគមន៍ ក្រុង មណ្ឌលពិសេស មណ្ឌលសិក្សាធិការ អង្គការជំនឿសាសនា និងមន្ត្រីព័ត៌មានសាធារណៈនៅទូទាំងខោនធី
3. ជម្រើសដែលអាចបោះឆ្នោតជាច្រើនត្រូវបានគូសបញ្ជាក់នៅឯកម្មវិធី "បើកស្វាគមន៍" ធ្វើការបង្ហាញជាសាធារណៈនិងឱកាសសារព័ត៌មានដើម្បីសាកល្បងមណ្ឌលបោះឆ្នោតគំរូ
4. សេចក្តីប្រកាសអំពីសេវាសាធារណៈតាមវិទ្យុនិងទូរទស្សន៍គូសបញ្ជាក់ពីជម្រើសដែលអាចបោះឆ្នោតបាននៅមណ្ឌលបោះឆ្នោត។
5. សេចក្តីប្រកាសអំពីសេវាសាធារណៈនឹងបានបញ្ជាក់ដាក់ឲ្យប្រើប្រាស់ការអាចចេញចូល, លទ្ធភាពចេញចូល, ច្រកចេញចូលដែលជ្រើសរើសនៅមណ្ឌលបោះឆ្នោត,ក៏ដូចជា, បន្ថែមពីលើនេះភាពមានបម្រុង, ភាពមានប្រើការ, ភាពបានការដែលនៅឆ្ងាយអាចចេញចូលបាន, អាចប្រើប្រាស់បានបោះឆ្នោត, ការបោះឆ្នោត-ដោយតាមរយៈ-ប្រព័ន្ធប្រៃសណីយ៍, បែបបទ, របៀប.

## សេវាសម្រាប់អ្នកបោះឆ្នោតមានពិការភាព

មណ្ឌលបោះឆ្នោតទាំងអស់នឹងត្រូវអនុវត្តទៅតាមច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព (ADA)។ នៅពេលចាំបាច់ ទ្វារទំនេរផ្សេងទៀត ព្រមទាំងច្រកចូលនានា នឹងត្រូវរក្សាទុកសម្រាប់ធានាដល់ការចេញចូលឲ្យបានត្រឹមត្រូវសម្រាប់អ្នកបោះឆ្នោតទាំងអស់។ បន្ថែមលើនេះទៀត ពោលគឺអាស្រ័យលើទំហំ មណ្ឌលបោះឆ្នោតនឹងត្រូវបំពាក់ដោយឧបករណ៍បោះឆ្នោតពីបីទៅប្រាំមួយ

[23] សូមមើលទៅលើក្រមបោះឆ្នោត California §303.3

ដែលត្រូវបានគេស្គាល់ថាជា ឧបករណ៍សំរាប់គូសសញ្ញាលើសន្លឹកឆ្នោត (BMD) ដែលមានលក្ខណៈស្របតាមច្បាប់ ADA ដើម្បីអនុញ្ញាតដល់អ្នកបោះឆ្នោតដែលមានពិការភាពអាចឱ្យបោះឆ្នោតបានដោយឯករាជ្យនិងជាការសម្ងាត់។ សម្រាប់អ្នកបោះឆ្នោតទាំងនោះដែលចង់បោះឆ្នោតនៅក្នុងផ្ទះប្រកបដោយផាសុខភាពពីផ្ទះរបស់គេនោះ ពួកគេនឹងមានជម្រើសផងដែរ ដើម្បីដាក់ពាក្យសុំនិងចូលទៅកាន់ប្រព័ន្ធ RAVBM ។ ជាមួយប្រព័ន្ធ RAVBM អ្នកបោះឆ្នោតនឹងត្រូវផ្ញើតាមអ៊ីម៉ែលតាមតំណភ្ជាប់ដើម្បីទាញយកសន្លឹកឆ្នោតផ្លូវការ ព្រមទាំងសេចក្តីណែនាំពីរបៀបព្រីនចេញ, បំពេញ និងផ្ញើត្រឡប់សន្លឹកឆ្នោតទៅកាន់ ROV វិញ ។ អ្នកបោះឆ្នោតដែលមានពិការភាពក៏អាចស្វែងរកជំនួយតាមរយៈទូរស័ព្ទទាន់ហេតុការណ៍ឥតគិតថ្លៃរបស់ ROV ដែលមានលេខ (866) 430-VOTE បន្ថែមទៅលើលេខ (408) 299-VOTE សម្រាប់ព័ត៌មានទូទៅស្តីពីការបោះឆ្នោត។ ខ្សែទូរស័ព្ទទាំងផ្តល់អ្នកជំនួយផ្នែកភាសា។

## សិក្ខាសាលាអប់រំអ្នកបោះឆ្នោតសម្រាប់សហគមន៍ដល់ជនដែលមានពិការភាព

ROV នឹងរៀបចំសិក្ខាសាលាអប់រំអ្នកបោះឆ្នោតដើម្បីផ្តល់ព័ត៌មានអំពីការជ្រើសរើសដែលអាចទទួលបាន និង ដំណើរការមណ្ឌលបោះឆ្នោត ដើម្បីផ្តល់ដល់មនុស្សចាស់និងអ្នកបោះឆ្នោតដែលមានពិការភាព ។ សិក្ខាសាលានឹងរួមបញ្ចូល ដោយមិនកំណត់ នូវការអប់រំអំពីគំរូមណ្ឌលបោះឆ្នោត ការបង្ហាញពីបរិក្ខារបោះឆ្នោតថ្មី លទ្ធភាពប្រើប្រាស់បាននៃបរិក្ខាបោះឆ្នោត ព័ត៌មានស្តីពីប្រអប់ទម្លាក់សន្លឹកឆ្នោត និងពីជម្រើសនានាដើម្បីទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រដែលអាចទាញយកបាននៅតាមអេឡិចត្រូនិក ។ ROV នឹងប្រើធាតុចូលបានពីសមាជិកគណៈកម្មាធិការប្រឹក្សាពីលទ្ធភាពទទួលបានការបោះឆ្នោត (VAAC) ដើម្បីជ្រើសរើសទីកន្លែងនិងពេលវេលារៀបចំសិក្ខាសាលា ។ ថ្មីៗនេះ ROV បានរៀបចំសិក្ខាសាលាជាមួយមជ្ឈមណ្ឌល Vista សម្រាប់ដល់ជនពិការភ្នែកនិងមានបញ្ហាក្នុងការមើល និងគិតត្រឹមសំណេរនេះ បច្ចុប្បន្ននៅក្នុងដំណើរការនៃការរៀបចំគម្រោងសិក្ខាសាលាជាមួយមជ្ឈមណ្ឌលរស់នៅដោយឯករាជ្យ Silicon Valley, មជ្ឈមណ្ឌលភូមិភាគ San Andreas និងក្រុមប្រឹក្សាស្តីពីពិការភាពដែលមានការអភិវឌ្ឍ ។

## សម្ភារៈពង្រៀងត្រូវបានប្រើក្នុងការអប់រំដល់អ្នកបោះឆ្នោតដែលមានពិការភាព

ROV កំពុងតែផលិតសម្ភារៈជាសម្លេង រូបភាព និងអត្ថបទ ដែលនឹងត្រូវប្រើប្រាស់ដើម្បីចែកចាយព័ត៌មាន និងព័ត៌មានដែលប្រមូលបានពីកិច្ចប្រជុំ VAAC នឹងត្រូវបានប្រើប្រាស់ពេញមួយដំណើរការអភិវឌ្ឍឯកសារផ្សព្វផ្សាយទាំងនេះ ។ សម្ភារៈទាំងនេះនឹងត្រូវផលិតឲ្យមានជាធនធាននៅលើគេហទំព័រ ROV ។

ចំពោះវីដេអូទាំងឡាយដែលត្រូវបានប្រើដើម្បីផ្សព្វផ្សាយ ឬ អប់រំពី VCA ដែលអាចទាញយកបាន ។ ឧទាហរណ៍រាប់បញ្ចូលទាំងវីដេអូផ្សព្វផ្សាយពី VCA ដែលត្រូវបានបង្ហោះនៅគេហទំព័រ ROV និងសវនាការសាធារណៈពី EAP ដែលត្រូវបានដាក់អនឡាញ (និងទាញយកមកបាន) ។ បន្ថែមលើនេះទៀត ROV កំពុងតែកត់ត្រាព័ត៌មានស្តីពី CVA នៅលើប័ណ្ណព័ត៌មានទៅជាអក្សរស្ទាប ។

## មន្ត្រីបោះឆ្នោត

ដើម្បីរៀបចំសម្រាប់ការបោះឆ្នោតបឋមឆ្នាំ 2020 ROV កំពុងអភិវឌ្ឍឯកសារបណ្តុះបណ្តាលជាពិសេសសម្រាប់មន្ត្រីបោះឆ្នោត ។ ឯកសារផ្សព្វផ្សាយជាក់លាក់នានា នឹងផ្តោតទៅលើចំណុចរសើបផ្នែកវប្បធម៌នៅក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកបោះឆ្នោតដែលមានពិការភាព ។ ឯកសារបណ្តុះបណ្តាលផ្សេងទៀត នឹងជួយដល់មន្ត្រីបោះឆ្នោតទៅលើចំណុចបច្ចេកទេសនៃការធ្វើប្រតិបត្តិការនិងភ្ជាប់ទៅកាន់ឧបករណ៍ស្តាប់សម្លេង/រូបភាពដែលអ្នកបោះឆ្នោតដែលមានពិការភាពអាចនាំមកជាមួយពួកគេ និងតម្រូវឲ្យប្រើនៅតាមមណ្ឌលបោះឆ្នោត ។ វីដេអូដែលមានលក្ខណៈចម្រុះវប្បធម៌ត្រូវបានផ្តល់នៅក្នុងការបណ្តុះបណ្តាលមន្ត្រីបោះឆ្នោត ដើម្បីស្វែងយល់

ពីរបៀបផ្តល់សេវាដោយក្តីគោរពទៅដល់បុគ្គលទាំងឡាយដែលមាននិងគ្មានពិការភាព ។ ការបណ្តុះបណ្តាលផ្សេងទៀតរាប់បញ្ចូលទាំងការរៀបចំតម្លើងឲ្យបានត្រឹមត្រូវនូវមណ្ឌលបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតមានពិការភាព ។ មន្ត្រីបោះឆ្នោតទាំងអស់ស្បថថានឹងមានលក្ខណៈរស់រវើកនិងដោយក្តីគោរពចំពោះប្រណីតភាពរបស់អ្នកបោះឆ្នោតម្នាក់ៗដែលជាការប្តេជ្ញាចំពោះពិពិធភាពនៃអ្នកបោះឆ្នោតទាំងអស់ ។ មន្ត្រីបោះឆ្នោតសន្យាធ្វើឲ្យអ្នកបោះឆ្នោតទាំងអស់មានអារម្មណ៍ទទួលបានស្វាគមន៍, គោរព, និងផ្តល់តម្លៃ ។

# ផ្នែកទី 4៖ ព័ត៌មានស្តីពីមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោត

## ទីតាំងមណ្ឌលបោះឆ្នោត

ក្រមបោះឆ្នោត California តម្រូវឲ្យខោនធីត្រូវមានបើកមណ្ឌលបោះឆ្នោតសម្រាប់រយៈពេលការបោះឆ្នោតមុនកាលកំណត់ចំនួនពីរដង។ ការបោះឆ្នោតមុនកាលកំណត់លើកទីមួយតម្រូវឲ្យមណ្ឌលបោះឆ្នោតបើកដំណើរការរយៈពេលដប់ (10) ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផង មានរយៈពេលសរុបចំនួយដប់មួយ (11) ថ្ងៃ។ ការគណនានេះគឺផ្អែកទៅលើការមានមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតក្នុងខោនធីដែលបានចុះឈ្មោះរួចចំនួន 50,000 នាក់។ ការបោះឆ្នោតមុនកាលកំណត់លើកទីពីរ តម្រូវឲ្យមណ្ឌលបោះឆ្នោតបើកដំណើរការរយៈពេលបី (3) ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផងដែលមានរយៈពេលសរុបចំនួនបួន (4) ថ្ងៃ ។ ការគណនានេះគឺផ្អែកទៅលើការមានមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតក្នុងខោនធីដែលបានចុះឈ្មោះរួចចំនួន 10,000 នាក់។

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV បច្ចុប្បន្ននេះកំពុងចាប់ផ្តើមដំណើរការរក្សាឲ្យបាននូវ មណ្ឌលបោះឆ្នោតឲ្យបានប្រហែលជាម្ភៃពីរ (22) ដែលត្រូវបើកដំណើរការសម្រាប់រយៈពេលដប់មួយ (11) ថ្ងៃ និងប៉ែតសិបប្រាំបី (88) មណ្ឌលបោះឆ្នោតដែលដំណើរការរយៈពេលបួនថ្ងៃ (4) ដោយសរុបទាំងអស់មានមួយរយដប់ (110) ទីតាំងមណ្ឌលបោះឆ្នោត ។ ម៉ោងធ្វើការនៅមណ្ឌលបោះឆ្នោតមួយចំនួនអាចនឹងត្រូវដំណើរការជាអន្លើៗដើម្បីបម្រើដល់អ្នកទាំងឡាយដែលមានកាលវិភាគមិនទៀងទាត់ ឬ អាចដោយសារតែភាពទំនេររបស់ទីតាំងផ្ទាល់។ នៅពេលធ្វើការបោះពុម្ពផ្សព្វផ្សាយមានចំនួនទីតាំងជាច្រើនបានបញ្ជាក់ពីភាពទំនេររបស់គេ ប៉ុន្តែការជ្រើសរើសមណ្ឌលបោះឆ្នោតនឹងមិនត្រូវបានសម្រេចរហូតទាល់តែការវិភាគទៅលើធាតុចូលរបស់សាធារណជន និង អាទិភាពរបស់ ROV ត្រូវបានបញ្ចប់ជាមុនសិន។ ផ្អែកទៅលើចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតដែលបានព្យាករណ៍ត្រឹមការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា 2020 ROV នឹងតម្រូវឲ្យមានមណ្ឌលបោះឆ្នោតយ៉ាងតិច 100 សម្រាប់ការបោះឆ្នោតបឋម 2020 និងការបោះឆ្នោតសាកល ។ ដើម្បីផ្តល់សេវាទៅតាមតម្រូវការរបស់ខោនធី ROV ស្នើសុំឲ្យមានមណ្ឌលបោះឆ្នោតប្រមាណជា 110 មណ្ឌល ដប់មណ្ឌលបោះឆ្នោតបន្ថែមទៀតត្រូវបានតម្រូវដោយច្បាប់ VCA ។ ការបំបែកមណ្ឌលបោះឆ្នោតមានដូចខាងក្រោម៖

| ចំនួនមណ្ឌលបោះឆ្នោតដែលត្រូវបានស្មាន | | | |
|---|---|---|---|
| ផ្នែកព្រំប្រទល់ | លក្ខខណ្ឌតម្រូវជាអប្បបរមា[24] | ចំនួន[25] ដែលបានស្នើឡើង | ចំនួនដែលត្រូវបានសម្រេចចុងក្រោយ[26] |
| មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 11 ថ្ងៃ | 20 | 22 | TBD |

[24]ចំនួនមណ្ឌលបោះឆ្នោតដែលតម្រូវក្នុងកម្រិតអប្បបរមាគឺផ្អែកទៅលើចំនួនអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកក្នុងខោនធី Santa Clara ត្រឹមការបោះឆ្នោតបឋមឆ្នាំ 2020។

[25]ព្រំប្រទល់ដែលត្រូវបានព្រាងឡើងដោយ ROV ត្រូវបានផ្អែកទៅលើចំនួនប៉ាន់ស្មាននៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ហើយក្នុងបំណងផ្តល់សេវាទៅតាមគោលការណ៍ណែនាំ ។ ចំនួនដែលត្រូវបានកំណត់ដោយ VCA គួរតែត្រូវបានគិតដល់ ដោយសារតែវាបម្រើឲ្យអ្នកបោះឆ្នោត "រហូតដល់ទៅ 50,000 នាក់"។ នេះមានន័យថា ចំនួនអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកនៅក្នុងព្រំប្រទល់នីមួយៗជានិច្ចកាលមិនបន្ថែមទៅលើចំនួនសរុបដែលត្រូវបានកំណត់ដោយ VCA នោះទេ។

[26] ចំនួនឆ្លុះបញ្ចាំងពីចំនួនដែលត្រូវបានសម្រេចជាចុងក្រោយដោយត្រឹមពេលនៃការបោះពុម្ពផ្សាយ។

| | | | |
|---|---|---|---|
| (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 50k) | | | |
| មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃ (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 10k) | 80 | 88 | TBD |
| **សរុប** | **100** | **110** | **TBD** |

សេចក្តីបន្ថែម E មានផែនទីបង្ហាញព្រំប្រទល់ អ្នកបោះឆ្នោត 50,000 និង10,000 ត្រូវបានប្រើដើម្បីកំណត់ទីតាំងដែលអាចជាមណ្ឌលបោះឆ្នោតបាន។ សម្រាប់បញ្ជីបច្ចុប្បន្ននិងផែនទី ទីតាំងមណ្ឌលបោះឆ្នោតដែលបានស្នើឡើង និងពេលវេលា មើលបាននៅសេចក្តីបន្ថែម F។

## ទីតាំងទម្លាក់សន្លឹកឆ្នោត

មន្ត្រីទទួលបន្ទុកបញ្ជីឈ្មោះអ្នកបោះឆ្នោត (ROV) មានផែនការដំណើរការទីតាំងទម្លាក់សន្លឹកឆ្នោតសរុបចំនួន 91 ទីតាំង។ ផ្អែកលើចំនួនព្យាករណ៍អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចគិតត្រឹមការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា ឆ្នាំ 2020, ROV តម្រូវឲ្យមានទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតយ៉ាងហោចណាស់ចំនួន 67 កន្លែងសម្រាប់ការបោះឆ្នោតបឋមឆ្នាំ 2020 និងការបោះឆ្នោតសាកល ។ ដើម្បីផ្តល់សេវាទៅតាមតម្រូវការរបស់ខោនធីបានកាន់តែប្រសើរ ចំនួន ដែលបានស្នើឡើងឲ្យមានយ៉ាងហោចណាស់ទីតាំងទម្លាក់សន្លឹកឆ្នោតមួយកន្លែងនៅគ្រប់សង្កាត់ក្នុងខោនធី ។ សម្រាប់បញ្ជីបច្ចុប្បន្ននិងផែនទី ទីតាំងទម្លាក់សន្លឹកឆ្នោតដែលបានស្នើឡើង សូមមើលសេចក្តីបន្ថែម D។

| **ចំនួនប៉ាន់ស្មាននៃទីតាំងទម្លាក់សន្លឹកឆ្នោត** | | | |
|---|---|---|---|
| **ផ្នែកព្រំប្រទល់** | **លក្ខខណ្ឌតម្រូវជាអប្បបរមា** | **ចំនួន[27] ដែលបានស្នើឡើង** | **ចំនួនដែលត្រូវបានសម្រេចចុងក្រោយ** |
| ទីតាំងទម្លាក់សន្លឹកឆ្នោត (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 15k) | 67 | 91 | TBD |

## វិធានការបង្ការ

ROV នឹងមានវិធានការបង្ការដូចខាងក្រោមរួចរាល់នៅមុននិងក្នុងអំឡុងពេលបោះឆ្នោត ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោត៖

| **វិធានការបង្ការសន្តិសុខ** | **គោលបំណង** |
|---|---|
| វិធានការសន្តិសុខតាមស្តង់ដារ | ដើម្បីកំណត់ការចូលទៅកាន់សម្ភារៈ & គ្រឿងបរិក្ខារពាក់ព័ន្ធនឹងការបោះឆ្នោត និងដើម្បីបង្ការឲ្យខាងតែបាននូវភាពរអាក់រអួលណាមួយ ដែលអាចកើតឡើងបាននោះ។ |

27ព្រំប្រទល់ដែលត្រូវព្រៀងឡើងដោយ ROV គឺផ្អែកទៅលើចំនួនប្រជាជនដែលត្រូវបានប៉ាន់ស្មាន ហើយក្នុងបំណងប្រើប្រាស់ជាគោលការណ៍ណែនាំ។ ចំនួនដែលត្រូវបានកំណត់ដោយ VCA គួរតែត្រូវបានគិតដល់ ដោយសារតែវាបម្រើឲ្យអ្នកបោះឆ្នោត "រហូតដល់ទៅ 50,000 នាក់"។ នេះមានន័យថា ចំនួនអ្នកបោះឆ្នោតដែលត្រូវបានព្យាករណ៍ទុកនៅក្នុងព្រំប្រទល់នីមួយៗជានិច្ចកាលមិនបន្ថែមទៅលើចំនួនសរុបដែលត្រូវបានកំណត់ដោយ VCA នោះទេ។

| | |
|---|---|
| ការថតចម្លងទុកទិន្នន័យក្នុងបណ្ដាញកុំព្យូទ័រ និងម៉ាស៊ីនមេ | ដើម្បីបង្ការភាពរអាក់រអួលនៃលំហូរព័ត៌មានក្នុងករណីដែលម៉ាស៊ីនផ្ទុកទិន្នន័យមេ ឬ បណ្ដាញមិនដំណើរការ។ |
| គ្រឿងបរិក្ខារបម្រុងទុកសម្រាប់ប្រើប្រាស់នៅក្នុងកន្លែងបោះឆ្នោត | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីគ្រឿងបរិក្ខារណាមួយប្រើលែងកើត។ |
| គ្រឿងបរិក្ខារផ្ទេរទិន្នន័យដើម្បីរក្សាទុក | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីគ្រឿងបរិក្ខារណាមួយបាត់បង់។ |
| បរិក្ខារផ្គត់ផ្គង់បម្រុងទុកសម្រាប់ការបោះឆ្នោត | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីសម្ភារៈការិយាល័យបម្រើការបោះឆ្នោតប្រើប្រាស់លែងកើត ឬ បាត់បង់។ |
| បុគ្គលិកមណ្ឌលបោះឆ្នោតត្រូវនៅប្រចាំការ | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីបុគ្គលិកមណ្ឌលបោះឆ្នោតអវត្តមាន។ |
| នីតិវិធីចំពោះបុគ្គល ឬ វត្ថុសង្ស័យ | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីមានបុគ្គល ឬ វត្ថុគួរសង្ស័យ។ |
| ប្រព័ន្ធហាត្ថកម្ម | ដើម្បីបង្ការភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោតក្នុងករណីគ្រឿងបរិក្ខារអេឡិចត្រូនិកបោះឆ្នោតណាមួយដែលប្រើលែងកើត។ |

សម្រាប់ព័ត៌មានពិស្ដារពីការបំបែកឲ្យកាន់តែលម្អិតពីវិធានការបង្ការសន្តិសុខខាងលើ សូមមើលសេចក្ដីបន្ថែម N។

## ផែនការបម្រុង

ROV នឹងអនុវត្តគ្រប់វិធានការតាមតែអាចធ្វើទៅបានដើម្បីធានាដល់ដំណើរការបោះឆ្នោតមួយដោយរលូន បើទោះជាយ៉ាងណាក៏ដោយ ក្នុងករណីមានភាពរអាក់រអួលកើតឡើង ROV មានវិធានការជាក់លាក់ត្រៀមរួចជាស្រេចដើម្បីបន្តបំពេញការងារក្នុងករណីមានភាពរអាក់រអួល។ ROV បានកំណត់នូវភាពរអាក់រអួលជាគន្លឹះដែលអាចនឹងកើតឡើងមួយចំនួនរួចហើយៈ

- ប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោតដាច់ចរន្តអគ្គិសនី
- ការដាច់ចរន្តអគ្គិសនី
- អាកាសធាតុអាក្រក់ខ្លាំង
- អគ្គិភ័យ ឬ គ្រោះមហន្តរាយផ្សេងៗ
- គ្រឿងបរិក្ខារបោះឆ្នោតមិនដំណើរការ
- សន្លឹកឆ្នោតបញ្ជូនទៅកាន់ម៉ាស៊ីនឈប់ដំណើរការ
- ការភ្ជាប់អ៊ីធើណិតមិនដំណើរការ
- បុគ្គលិកមណ្ឌលបោះឆ្នោតមិនមក
- មណ្ឌលបោះឆ្នោតមិនអាចប្រើបាន

ចំពោះការបំបែកឲ្យលម្អិតនូវភាពរអាក់រអួលទាំងនេះ ដំណោះស្រាយរបស់ ROV និងវិធានការដោះស្រាយបន្ទាន់របស់ ROV សូមមើលសេចក្ដីបន្ថែម O។

# ភាគទី 5៖ ផែនការសន្តិសុខ និង សិទ្ធិឯកជនភាពសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោត

## ការរចនានិងប្លង់មណ្ឌលបោះឆ្នោត

មណ្ឌលបោះឆ្នោតដែលល្អគួរតែមានទំហំ 60’x60’ ដើម្បីធានាដល់លំហូរបានខ្ពស់បំផុតក្នុងខណៈដែលការផ្តល់ទំហំផ្ទៃមានវិសាលភាពសម្រាប់កំណត់កន្លែងបោះឆ្នោតសម្ងាត់។ នឹងមានប្រព័ន្ធកំណត់ជួរដើម្បីបញ្ជូនអ្នកបោះឆ្នោតទៅកាន់បុគ្គលិកសមស្របនោះដែលត្រូវចុះវត្តមានដើម្បីដំណើរការអ្នកបោះឆ្នោតតាមកម្មវិធីបោះឆ្នោតអេឡិចត្រូនិកថ្មី កន្លែងដាក់ម៉ាស៊ីនបោះពុម្ពសន្លឹកឆ្នោតជាកន្លែងដែលសន្លឹកឆ្នោតនឹងត្រូវបោះពុម្ព ហើយកន្លែងដាក់ស្តង់បោះឆ្នោតនិងឧបករណ៍គូសសន្លឹកឆ្នោត។ សេចក្តីបន្ថែម P បង្ហាញពីការរចនាប្លង់ជាទូទៅដែលនឹងត្រូវប្រើជាការណែនាំ ប៉ុន្តែមណ្ឌលបោះឆ្នោតនីមួយៗនឹងទំនងជាត្រូវកែសម្រួលប្លង់សម្រាប់ខ្លួនឯងតាមលក្ខណៈជាក់ស្តែង។

## សន្តិសុខក្នុងការបោះឆ្នោត

ជំហានចាំបាច់ទាំងឡាយដែលត្រូវអនុវត្ត ដើម្បីធានាដល់ការសម្ងាត់ សុចរិតភាព និងសន្តិសុខដល់ទិន្នន័យអ្នកបោះឆ្នោត។ ទិន្នន័យអ្នកបោះឆ្នោតក្នុងខោនធីទាំងអស់ត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យ និងក្នុងម៉ាស៊ីនផ្ទុកទិន្នន័យមេប្រើប្រាស់វិធានការសន្តិសុខដែលត្រូវបានរៀបចំឡើង ដើម្បីការពារទិន្នន័យក្នុងពេលរក្សាវាឲ្យនៅគង់វង់សម្រាប់ប្រើប្រាស់ដោយបុគ្គលិកខោនធី។

នៅការិយាល័យកណ្តាលរបស់មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត(ROV) ប្រព័ន្ធបោះឆ្នោតនឹងស្ថិតនៅដាច់ពីលំហាខាងក្រៅ មានន័យថាវានឹងគ្មានការចូលទៅកាន់បណ្តាញខាងក្រៅឡើយ ។ ការចូលទៅកាន់ប្រព័ន្ធបោះឆ្នោតបានមានតែមួយគត់ គឺការចូលដោយមនុស្សទៅកាន់បន្ទប់ដាក់ម៉ាស៊ីនផ្ទុកទិន្នន័យមេ ដែលរក្សាទុកប្រព័ន្ធ។ ទាក់ទងទៅនឹងសន្តិសុខកុំព្យូទ័រ ប្រសិនបើគ្មានពេលបិទម៉ាស៊ីនកុំព្យូទ័រលើតុដោយសុវត្ថិភាពនោះ បុគ្គលិកគួរចាក់សោរកុំព្យូទ័រដោយការប្រើ Ctrl+Alt+Delete ។ មូលហេតុត្រូវធ្វើបែបនេះគឺ ងាយសង្កត់ប៊ូតុងបិទបើកតែម្តងអាចនឹងមិនគ្រប់គ្រាន់ដើម្បីផ្តាច់ការភ្ជាប់ ហើយបិទវាទាំងស្រុងបាន ។ ប្រសិនបើគ្មានភ្លើងទេ បុគ្គលិកគួរតែរង់ចាំការណែនាំពីជំនួយការអំពីមធ្យោបាយប្រសើបំផុតដើម្បីដោះស្រាយបញ្ហាកុំព្យូទ័រ។

នៅមណ្ឌលបោះឆ្នោត បុគ្គលិកនឹងអាចទាញយកព័ត៌មានស្ទើរតែភ្លាមៗនូវទិន្នន័យចុះឈ្មោះ និងប្រវត្តិអ្នកបោះឆ្នោតទាំងអស់នៅពេលពួកគេមកកាន់មណ្ឌលបោះឆ្នោតណាមួយនោះ។ រាល់ទិន្នន័យអ្នកបោះឆ្នោត ដែលនឹងផ្តល់ឲ្យបាននៅតាមមណ្ឌលបោះឆ្នោត ហើយដែលនឹងត្រូវបញ្ជូនរវាងមណ្ឌលបោះឆ្នោតនិងម៉ាស៊ីនផ្ទុកទិន្នន័យមេរបស់ខោនធីនោះ នឹងត្រូវបម្លែងកូដប្រើប្រាស់បច្ចេកវិទ្យាបម្លែងកូដថ្មី បំផុត។ មានតែឧបករណ៍និងគ្រឿងបរិក្ខារបោះឆ្នោតដាក់លាក់នៅតាមមណ្ឌលបោះឆ្នោតតែប៉ុណ្ណោះ នឹងត្រូវអនុញ្ញាតឲ្យចូលទៅកាន់ទិន្នន័យអ្នកបោះឆ្នោត ហើយទិន្នន័យនឹងត្រូវបំបែកនៅក្នុងការបញ្ជូននិងនៅពេលឈប់ដំណើរការ ។ ការផ្ទេរទិន្នន័យដើម្បីរក្សាទុកនឹងត្រូវបានធ្វើឡើង ក៏ដូចគ្នាទៅនឹងដានសវនកម្មពិស្តារនៃការប្រាស្រ័យទាក់ទងគ្នា និងដំណើរការជួយធានានូវតម្លាភាពនិងសន្តិសុខ។

សន្លឹកឆ្នោតត្រូវបានបំពេញនៅមណ្ឌលបោះឆ្នោតនឹងត្រូវស្កេននិងរាប់ចំនួននៅនឹងកន្លែងប្រើប្រាស់ម៉ាស៊ីនរាប់ចំនួនដែលមិនត្រូវបានភ្ជាប់ទៅនឹងបណ្តាញកុំព្យូទ័រណាមួយឡើយ។ ទិន្នន័យសន្លឹកឆ្នោតនឹងត្រូវបម្លែងកូដនិងរក្សាទុកនៅក្នុងប្រអប់ដែលអាចនឹងយកមកប្រើបានតែដោយយកវាចេញដោយផ្ទាល់ពីក្នុងម៉ាស៊ីន។ ប្រអប់ដែលបានពីម៉ាស៊ីនរាប់សន្លឹកឆ្នោតនឹងត្រូវបញ្ជូនទៅកាន់ការិយាល័យកណ្តាលរបស់ ROV វិញសម្រាប់កត់ត្រាទុកក្រោយពីការបោះឆ្នោតបិទបញ្ចប់នៅម៉ោង 8:00 ល្ងាចនៅថ្ងៃបោះឆ្នោត។

សន្លឹកឆ្នោតបោះតាមសំបុត្រ (VBM) ដែលទទួលបាន ត្រូវបានប្រមូលនៅឯការិយាល័យកណ្តាលរបស់ ROV និងត្រូវបានរក្សាទុកនៅក្នុងបន្ទប់ដាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាពរហូតដល់វាត្រូវរាប់ ។ មុនពេលសន្លឹកឆ្នោតអាចត្រូវបានរាប់ ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត VBM ត្រូវបានផ្ទៀងផ្ទាត់ដើម្បីធានាថាសន្លឹកឆ្នោតពិតជាទទួលបានពីអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ។ ក្រោយពីហត្ថលេខាត្រូវបានផ្ទៀងផ្ទាត់ សន្លឹកឆ្នោតត្រូវបានទាញនិងត្រូវបានរក្សាទុកនៅក្នុងសង្កាត់និងដាក់ជូនដើម្បីរាប់ ។ ក្រោយពីត្រូវបានរាប់ សន្លឹកឆ្នោតបន្ទាប់មកនឹងត្រូវរក្សាទុកដោយសង្កាត់ក្នុងទីតាំងសុវត្ថិភាពដាច់ដោយឡែកពីគ្នា ។

ក្នុងករណីបន្ទាន់កើតឡើងដែលតម្រូវឲ្យបុគ្គលិកត្រូវយកសន្លឹកឆ្នោតចេញពីក្នុងអគារនោះ បុគ្គលិកនឹងត្រូវបិទប្រអប់ហិបឲ្យជិត ហើយយកវាទៅទីតាំងថ្មី។ ក្នុងករណីមិនអាចយកវាចេញពីអគារបានទេនោះ សន្លឹកឆ្នោតនឹងត្រូវដាក់នៅក្នុងបន្ទប់មួយដែលមានសន្តិសុខ។ សន្លឹកឆ្នោតមិនទាន់ប្រើ សន្លឹកឆ្នោតមិនត្រូវបានចេញ គួរតែរក្សាទុកសិនប្រសិនបើគ្មានពេលយកវាចេញទេនោះ។ ប្រសិនបើមានពេល ROV ឬ គម្រោងការណ៍នឹងផ្តល់ដំបូន្មានដល់បុគ្គលិកពីអ្វីត្រូវធ្វើចំពោះសន្លឹកឆ្នោតទទេ សន្លឹកឆ្នោតមិនចេញមិនបាន ។

## ភាគទី 6 – ថវិកា

មន្ត្រីទទួលបន្ទុកបញ្ជីបោះឆ្នោត (ROV) បានព្រៀងថវិកា និងផែនការសម្រាប់ធនធានចាំបាច់ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់អ្នកបោះឆ្នោតអំពីដំណើរការបោះឆ្នោតគំរូថ្មីតាមមណ្ឌលបោះឆ្នោត។ សម្រាប់ជុំបោះឆ្នោតពីរចុងក្រោយស្ថិតនៅក្រោមគំរូការិយាល័យបោះឆ្នោត ខោនធី Santa Clara បានចំណាយជាមធ្យមប្រហែលជា $163,000 សម្រាប់ការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត រួមទាំងការផ្សាយពាណិជ្ជកម្ម ។ ROV បានចំណាយប្រហែលជា $186,000 សម្រាប់ការបោះឆ្នោត ខែមិថុនា ឆ្នាំ 2018 ខណៈដែលទឹកប្រាក់ប្រហែលជា $140,000 ត្រូវបានចំណាយសម្រាប់ការបោះឆ្នោត ខែវិច្ឆិកា ឆ្នាំ 2018 ។ ចំនួនទឹកប្រាក់កាន់តែច្រើនត្រូវបានចំណាយសម្រាប់ការបោះឆ្នោត ខែមិថុនា ដោយសារតែនៅក្នុង ខែមករានៃឆ្នាំនោះ ឯកសារចាំបាច់ទាំងអស់ត្រូវបានទិញសម្រាប់ពេញមួយឆ្នាំ ។ ឯកសារផ្សព្វផ្សាយបន្ថែមទៀតសម្រាប់ការបោះឆ្នោត ខែវិច្ឆិកា ត្រូវបានទិញតាមការចាំបាច់ ។ បន្ថែមលើនេះទៀត ការផ្សព្វផ្សាយសម្រាប់ខែមិថុនាមានរយៈពេលផ្សព្វផ្សាយទូលាយជាងពីខែមិថុនាទៅខែវិច្ឆិកាសម្រាប់ការបោះឆ្នោតខែវិច្ឆិកា។ ឧបសម្ព័ន្ធ Q ផ្តល់នូវតារាងព្រឹត្តិការណ៍ផ្សាយលម្អិតសម្រាប់ការបោះឆ្នោត ខែមិថុនា ឆ្នាំ 2018 និង ខែវិច្ឆិកា ឆ្នាំ 2018 ។

ជាមួយនឹងការអនុវត្តច្បាប់ស្តីពីជម្រើសនៃការបោះឆ្នោត (VCA) ថវិកាសម្រាប់ផ្សព្វផ្សាយនិងការផ្សាយពាណិជ្ជកម្មបានកើនជិតដល់ទៅ $3 លាន សម្រាប់ការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី ខែមីនា ឆ្នាំ 2020 ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងការអប់រំដល់សាធារណជនអំពីការជម្រើសបោះឆ្នោតថ្មីរបស់ពួកគេ ។ ថវិកាគ្រោងទុកមិនរាប់បញ្ចូលការចំណាយសម្រាប់បុគ្គលិក និងការចំណាយពាក់ព័ន្ធនឹងការផ្សព្វផ្សាយផ្សេងទៀតឡើយ។ ការបំបែកលម្អិតសម្រាប់ថវិកា VCA និងការប្រៀបធៀបជាមួយនឹងការបោះឆ្នោតពីរចុងក្រោយ ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | តម្លៃជាក់ស្តែង ខែមិថុនា 2018 (ការិយាល័យបោះឆ្នោតគំរូ) | តម្លៃជាក់ស្តែង ខែវិច្ឆិកា 2018 (ការិយាល័យបោះឆ្នោតគំរូ) | ថវិកា ខែមីនា 2020 (មណ្ឌលបោះឆ្នោតគំរូ) |
|---|---|---|---|
| **ចំណាយសរុបលើការផ្សាយពាណិជ្ជកម្ម** | **$165,521** | **$114,754** | **$1,048,900** |
| ការផ្សាយពាណិជ្ជកម្មតាមកាសែត/ផ្សាយពាណិជ្ជកម្មតាមវិទ្យុ/ប្រព័ន្ធផ្សព្វផ្សាយសង្គម/ការផ្សាយពាណិជ្ជកម្មជាព្រីន | $165,521 | $114,754 | $418,900 |
| ការផ្សាយពាណិជ្ជកម្មថ្មីតាមវិទ្យុ | | | $210,000 |
| Sports Franchises – | | | $420,000 |
| **ប្រភេទការងារផ្សព្វផ្សាយ៖** | **$20,478** | **$25,359** | **$1,837,015** |
| សម្ភារៈផ្សាយពាណិជ្ជកម្មនិងការតាំងបង្ហាញនានា | $3,758 | $3,281 | $97,547 |
| ការផ្សព្វផ្សាយដោយមិនអស់ថ្លៃនៅតាមព្រឹត្តិការណ៍នានា | $11,611 | $12,436 | $162,513 |
| ការផ្សព្វផ្សាយដោយមិនអស់ថ្លៃសម្រាប់ការបែងចែកនៅ CBO | | | $120,180 |
| គ្រឿងបរិក្ខារសម្រាប់ការផ្សព្វផ្សាយ | | | $20,550 |
| ខោនធីបោះពុម្ព/ឯកសារផ្សព្វផ្សាយបោះពុម្ព | $5,109 | $9,643 | $100,000 |
| ថ្លៃឈ្នួលនិងចាក់សាំងរថយន្ត | | | $16,225 |
| ការផ្ញើសំបុត្រ 2 ទៅកាន់អ្នកបោះឆ្នោតម្នាក់ៗ | | | $1,320,000 |

បច្ចុប្បន្ននេះ ពុំមានចំនួនប៉ាន់ស្មាននៃគ្រោងប្រាក់សន្សំក្នុងរយៈពេលខ្លី ហើយការប៉ាន់ស្មាននៃគ្រោងប្រាក់សន្សំក្នុងរយៈពេលវែងមិនដឹងឡើយក្នុងពេលនេះ ។

# តារាងឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងអក្សរកាត់ ........ 43

ឧបសម្ព័ន្ធ B – ពាក្យសុំបោះឆ្នោតមុនកាលកំណត់ ........ 65

ឧបសម្ព័ន្ធ C – ព្រំប្រទល់ទីតាំងហិបទម្លាក់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតចំនួន 15k ដែលបានស្នើឡើង 67

ឧបសម្ព័ន្ធ D – ទីតាំងហិបដាក់សន្លឹកឆ្នោតដែលបានស្នើឡើង ........ 68

ឧបសម្ព័ន្ធ E – ព្រំប្រទល់ទីតាំងមណ្ឌលបោះឆ្នោតដែលមានអ្នកបោះឆ្នោត 50k & 10k ដែលបានស្នើឡើង ... 71

ឧបសម្ព័ន្ធ F – ទីតាំងដែលមានសក្តានុពលជាមណ្ឌលបោះឆ្នោត ........ 73

ឧបសម្ព័ន្ធ G – ផែនទីទិន្នន័យ ........ 76

ឧបសម្ព័ន្ធ H – សេចក្តីជូនដំណឹងជាសាធារណៈ ........ 94

ឧបសម្ព័ន្ធ I – ឯកសារប្រជុំ EAP ........ 106

ឧបសម្ព័ន្ធ J – របៀបវារៈនិងរបាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ EAP ........ 153

ឧបសម្ព័ន្ធ K – របៀបវារៈនិងរបាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់គណៈកម្មាធិការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC) ........ 282

ឧបសម្ព័ន្ធ L – របៀបវារៈនិងកំណត់ហេតុកិច្ចប្រជុំពិគ្រោះយោបល់គណៈកម្មការប្រឹក្សាដើម្បីទទួលបានលទ្ធភាពបោះឆ្នោត (VAAC) ........ 292

ឧបសម្ព័ន្ធ M – គម្រោងអប់រំនិងផ្សព្វផ្សាយពិស្តារ ........ 303

ឧបសម្ព័ន្ធ N – វិធានការបង្ការ ........ 308

ឧបសម្ព័ន្ធ O – ផែនការសង្គ្រោះ ........ 311

ឧបសម្ព័ន្ធ P – គំនូសបង្ហាញទីតាំងមណ្ឌលបោះឆ្នោតដែលបានស្នើឡើង ........ 319

ឧបសម្ព័ន្ធ Q – ព្រឹត្តិការណ៍ផ្សព្វផ្សាយឆ្នាំ 2018 ........ 320

ឧបសម្ព័ន្ធ R – សំណួរដែលគេសួរជាញឹកញាប់ ........ 326

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

គោលបំណងនៃសន្ទានុក្រមនេះគឺដើម្បីផ្តល់ដល់អ្នកអាននូវគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោតឲ្យបានយល់ពីបរិបទនៃដំណើរការបោះឆ្នោតទាំងមូល និងដើម្បីកំណត់និយមន័យពាក្យបច្ចេកទេសមួយចំនួនដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារ ។ ដើម្បីជាការបញ្ជាក់ឲ្យច្បាស់និងយល់ពីលក្ខខណ្ឌតម្រូវដែលស្រដៀងៗគ្នាទាក់ទងទៅនឹងពាក្យបច្ចេកទេសមួយចំនួននោះ សូមមើលគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត ។

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| រាប់ដោយដៃ 1% | ត្រូវបានតម្រូវដោយច្បាប់ឲ្យរាប់សន្លឹកឆ្នោតដោយដៃដើម្បីផ្ទៀងផ្ទាត់ការរាប់សន្លឹកឆ្នោតតាមម៉ាស៊ីនមុនចេញសេចក្តីបញ្ជាក់ការបោះឆ្នោត ។ មួយក្នុងចំណោមជំហានជាច្រើនត្រូវបានបញ្ចូលក្នុងការធ្វើសវនកម្មនិងផ្តល់សុពលភាពលើលទ្ធផលនៃការបោះឆ្នោត ។ |
| ការបិទការចុះឈ្មោះដែលមានរយៈពេល 15 ថ្ងៃ | កាលបរិច្ឆេទផុតកំណត់នៅក្នុងរដ្ឋ California ដែលត្រូវបានកំណត់ដោយច្បាប់ ចុះឈ្មោះបោះឆ្នោតឲ្យបានមុនការបោះឆ្នោតនីមួយៗ ។<br>*(ក្រមបោះឆ្នោត California §2102)* |
| ប័ណ្ណលេខ 8D2 | *សូមមើល ប័ណ្ណបញ្ជាក់ទីលំនៅរបស់អ្នកបោះឆ្នោត ។* |
| សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមាន | ពាក្យបច្ចេកទេសដែលឈប់ត្រូវបានប្រើប្រាស់<br>*សូមមើល ការបោះឆ្នោតតាមសំបុត្រ ។* |
| សន្លឹកឆ្នោតដែលអាចទទួលបាន | សន្លឹកឆ្នោតមានលក្ខណៈជាសាមញ្ញដោយស្នាបលើអេក្រង់អេឡិចត្រូនិក ដែលបង្ហាញឈ្មោះបេក្ខជនចូលរួមប្រកួតនិងវិធានការដែលត្រូវបោះ ដែលអាចទាញយកមកប្រើបានដោយបុគ្គលមានពិការភាព ដោយគ្រាន់តែស្ទាបលើផ្នែកលើអេក្រង់តាមការកំណត់ ឬដោយប្រើប្រាស់ឧបករណ៍ជំនួយ ដូចជាឧបករណ៍ស្តាប់សម្លេង និងបន្ទះអក្សរស្ទាប ឬឧបករណ៍ជំនួយប្រើសម្ពាធខ្យល់ដង្ហើមចេញចូលជាដើម ។ អ្នកបោះឆ្នោតសកម្មមានសិទ្ធិស្របច្បាប់បោះឆ្នោតនិងចុះអត្តលេខាលើញត្តិទាមទារបាន ។<br>*(ក្រមបោះឆ្នោត California §19240)* |
| សេវាកែតម្រូវអាសយដ្ឋាន (ACS) | ទិន្នន័យផ្តល់តាមរយៈសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក ដែលមន្ត្រីរៀបចំការបោះឆ្នោតខោនធីអាចប្រើព័ត៌មានដើម្បីគ្រប់គ្រងនិងធ្វើបច្ចុប្បន្នភាពបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត និងប័ណ្ណបញ្ជាក់ទីលំនៅសម្រាប់ការផ្ញើសំបុត្រ ។<br>*(ក្រមបោះឆ្នោត California §2033)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| អ្នកបោះឆ្នោតសកម្ម | អ្នកបោះឆ្នោតដែល (1) មានព័ត៌មានបច្ចុប្បន្នភាពព័ត៌មាន (2) ដែលទទួលបានឯកសារបោះឆ្នោត និង (3) ដែលបានបោះឆ្នោតថ្មីៗបំផុត ឬ ដែលមានអាសយដ្ឋានត្រូវបានបញ្ជាក់តាមរយៈសំបុត្របញ្ជាក់អាសយដ្ឋានលំនៅដ្ឋាន ។<br>*(ក្រមបោះឆ្នោត California §§2220-2227)* |
| លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ | ដូចអ្នកបានដឹងផងដែរថា ទម្រង់ចុះឈ្មោះបោះឆ្នោត, ប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោត, ពាក្យសុំសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬ ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត ។ បុគ្គលគ្រប់រូបដែលចង់ឲ្យចុះឈ្មោះជាអ្នកបោះឆ្នោតត្រូវបំពេញពាក្យសុំនេះ (លើកលែងទៅតាមការសម្រេចនិងសេចក្តីវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់) ។ សេចក្តីបញ្ជាក់ឲ្យអនុវត្តនឹងត្រូវមានប្រសិទ្ធិភាពក្រោយពីទទួលបានដោយមន្ត្រីរៀបចំការបោះឆ្នោតខោនធីនៅចំថ្ងៃ ឬនៅមុនថ្ងៃទី 15 មុនការបោះឆ្នោត ហើយស្ថិតក្រោមលក្ខខណ្ឌកំណត់និងពេលវាជាក់លាក់ ។ នៅពេលណាអ្នកបោះឆ្នោតប្តូរទីតាំង អ្នកបោះឆ្នោតត្រូវអនុវត្តន៍លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះថ្មី ឬសេចក្តីជូនដំណឹង ឬលិខិតនៃការផ្លាស់ប្តូរដើម្បីឲ្យចុះឈ្មោះឲ្យបានត្រឹមត្រូវ ។<br>*(ក្រមបោះឆ្នោត California §§2100 - 2194.1)* |
| ការបោះឆ្នោតតាមសំបុត្រទាំងអស់ | ការបោះឆ្នោតតាមមូលដ្ឋាន ពិសេស ឬបង្រួមត្រូវបានចែងចែងឡើងទាំងស្រុងតាមរយៈសំបុត (ក្រោមលក្ខខណ្ឌចាំបាច់មួយចំនួន) ។<br>*(ក្រមបោះឆ្នោត California ផ្នែក 4)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ការបញ្ជាក់ទីលំនៅដែលអាចជំនួសបាន (ARC) | និតិវិធីដែលតម្រូវឲ្យមន្ត្រីរៀបចំការបោះឆ្នោតតាមខោនធីផ្ញើសំបុត្រ ប័ណ្ណប្រៃសណីយ៍ ដែលអាចបញ្ជូនបន្តបានទៅកាន់អ្នកបោះឆ្នោតម្នាក់ៗដែលមានឈ្មោះក្នុងបញ្ជី ដែលនៅមិនទាន់បានបោះឆ្នោត ឬប្តូរអាសយដ្ឋានរបស់គេក្នុងរយៈពេលបួនឆ្នាំនិងជាប់ៗគ្នា តម្រូវឲ្យអ្នកបោះឆ្នោតអនុវត្តន៍ដោយឆ្លើយតបទៅប័ណ្ណប្រៃសណីយ៍ បង្ហាញពីការចង់រក្សាទុកជាអ្នកបោះឆ្នោត "សកម្ម" ដដែល ។<br>*(ក្រមបោះឆ្នោត California §2220)* |
| ច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព (ADA) | ច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព (ADA) ចូលជាធរមាននៅក្នុងឆ្នាំ 1990 ។ ច្បាប់ ADA ជាច្បាប់សិទ្ធិពលរដ្ឋដែលហាមឃាត់ការរើសអើងចំពោះបុគ្គលទាំងឡាយដែលមានពិការភាពនៅគ្រប់ផ្នែកទាំងអស់នៃជីវិតជាសាធារណៈ ដោយរាប់បញ្ចូលទាំងការងារ ការសិក្សាតាមសាលារៀន ការធ្វើដំណើរ និងទីធារណៈនិងឯកជននានាដែលបើកស្វាគមន៍សាធារណ ជនជាទូទៅ ។ គោលបំណងនៃច្បាប់ត្រូវធ្វើឲ្យប្រាកដថាមនុស្សមានពិការភាពមានសិទ្ធិនិងឱកាសដូចគ្នាទៅនឹងអ្នករាល់គ្នាផ្សេងទៀតដែរ ។ ADA ផ្តល់ការការពារសិទ្ធិពលរដ្ឋចំពោះបុគ្គលទាំងឡាយណាដែលមានពិការភាពដូចគ្នាទៅនឹងសិទ្ធិទាំងនោះ ដែលត្រូវបានផ្តល់ទៅដល់បុគ្គលទាំងឡាយផ្អែកទៅលើជាតិសាសន៍ ពណ៌សម្បុរ ភេទ សញ្ជាតិដើម អាយុ និងសាសនា ។ វាធានាឲ្យមានឱកាសស្មើគ្នាសម្រាប់បុគ្គលទាំងឡាយណាដែលមានពិការភាពនៅតាមជម្រកស្នាក់នៅរបស់រដ្ឋ ការងារ ការធ្វើដំណើរ សេវារបស់រដ្ឋាភិបាលថ្នាក់រដ្ឋ និងមូលដ្ឋាន និងទូរគមនាគមន៍ ។<br>*សូមមើល __ការបោះឆ្នោតតាមសំបុត្រពីចំងាយ__ (RAVBM) ។* |
| ពាក្យសុំសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត | *សូមមើល __លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ__ ។* |
| ការិយាល័យបោះឆ្នោតដែលត្រូវបោះ | ការិយាល័យបោះឆ្នោតដែលត្រូវបោះ ជាទីតាំងតែមួយគត់ដែលអ្នកបោះឆ្នោតត្រូវបង្ហាញខ្លួន ទទួលបានសន្លឹកឆ្នោត និងបោះឆ្នោតដែលមានអ្នកឈរឈ្មោះទាំងអស់ដែលអ្នកបោះឆ្នោតត្រូវបោះ ។ ការប្រកួតប្រជែងទាំងឡាយណាដែលអ្នកបោះឆ្នោតមិនត្រូវបោះឲ្យនោះ នឹងមិនមាននៅតាមការិយាល័យបោះឆ្នោតដែលអ្នកបោះឆ្នោតត្រូវបោះឡើយ ។ ទីតាំងត្រូវបានជ្រើសរើសទុកមុនជាពិសេសសម្រាប់អ្នកបោះឆ្នោតក្នុងសង្កាត់តែមួយ ក្នុងការបង្កើតទីតាំងបោះឆ្នោតដែលត្រូវបោះ ។ ការិយាល័យបោះឆ្នោតដែលត្រូវបោះប្រើបានសម្រាប់តែ__គំរូការិយាល័យបោះឆ្នោត__ ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
| --- | --- |
| គោលនយោបាយរាប់ឡើងវិញដោយស្វ័យប្រវត្តិ | គោលនយោបាយដែលត្រូវបានយកមកអនុវត្តន៍ដោយគណកម្មការគ្រប់គ្រងរបស់ខោនធី Santa Clara បង្កើតឡើងនូវដំណើរការរាប់សន្លឹកឆ្នោតដោយដៃនៅក្នុងការប្រកួតការបោះឆ្នោតជាក់លាក់មួយចំនួន ដើម្បីជាយន្តការបញ្ជាក់ទៅលើលទ្ធផលនៃការប្រកួតប្រជែងការបោះឆ្នោតក្នុងមូលដ្ឋាន ដោយទំហំនៃការឈ្នះតិចតួច ដែលមិនតម្រូវឲ្យបេក្ខជន ឬដែលមិនទាក់ទាញចំណាប់អារម្មណ៍អ្នកបោះឆ្នោតឲ្យយកចិត្តទុកដាក់លើការរាប់ឡើងវិញឡើយ ។ ធ្វើការរាប់ដោយដៃនៅគ្រប់ការប្រកួតទាំងអស់នៅក្នុងខោនធី Santa Clara ទាំងមូល (លើកលែងតែការប្រកួតប្រជែងសម្រាប់មុខតំណែងថ្នាក់រដ្ឋនិងសហព័ន្ធ) ដែលទំហំនៃការឈ្នះតិចជាង 0.25 ភាគរយនៃចំនួនសន្លឹកឆ្នោតដែលបានបោះ ឬតិចជាង 25 សម្លេង លើកលែងការប្រកួតប្រជែងនោះអាចមានលក្ខណៈទូទាំងប្រទេស ឬទូទាំងក្រុងនៅក្រុង San José ដែលមាស៊ីនរាប់សន្លឹកឆ្នោតអាចត្រូវបានប្រើ ។ គោលនយោបាយតម្រូវឲ្យធ្វើការកត់ត្រាចំនួនសម្លេងឆ្នោត ។<br>*(សៀវភៅណែនាំគោលនយោបាយរបស់គណកម្មការគ្រប់គ្រងរបស់ខោនធី Santa Clara ផ្នែក 3.63)* |
| ហិបទម្លាក់សន្លឹកឆ្នោត | ជាធុងដែលមានសុវត្ថិភាពបង្កើតឡើងដោយមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត/មន្ត្រីរៀបចំការបោះឆ្នោតខោនធីដែលសន្លឹកឆ្នោតបោះតាមសំបុត្រអាចត្រូវបានផ្ញើត្រឡប់មក ។ |
| ទីតាំងទម្លាក់សន្លឹកឆ្នោត (BDL) | ទីតាំងត្រូវបានបង្កើតឡើងដោយមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត ដែលហិបទម្លាក់សន្លឹកឆ្នោតផ្លូវការដាក់អាចដាក់បានទាំងទីតាំងខាងក្នុងនិងខាងក្រៅ ។ |
| សន្លឹកឆ្នោតក្នុងទម្រង់ដែលអាចបោះបាន | *សូមមើល* ***សន្លឹកឆ្នោតដែលអាចបោះបាន*** *។* |
| ឧបករណ៍គូសសន្លឹកឆ្នោត (BMD) | ឧបករណ៍ប្រើប្រាស់ដើម្បីជួយអ្នកបោះឆ្នោតក្នុងការគូសសន្លឹកឆ្នោតរបស់ខ្លួន។ ឧបករណ៍អាចមានទំហំ រៀង ឬទ្រង់ទ្រាយជាច្រើនប្រភេទ ហើយការគូសនៅលើសន្លឹកឆ្នោតត្រូវតែបង្ហាញយ៉ាងជាក់ច្បាស់នូវជម្រើសរបស់អ្នកបោះឆ្នោត ។<br>*(ក្រមបោះឆ្នោត California §14270)* |
| សន្លឹកឆ្នោតតាមតម្រូវការ (BOD) | ប្រព័ន្ធដែលមុខងារបញ្ជាក់ដោយខ្លួនឯង ដែលអនុញ្ញាតឲ្យមន្ត្រីរៀបចំការបោះឆ្នោតខោនធីព្រីនទៅតាមតម្រូវការនូវសន្លឹកឆ្នោតទៅលើគំនរសន្លឹកឆ្នោតផ្លូវការ ដើម្បីផ្តល់ដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះដើម្បីធ្វើការបោះឆ្នោត ។ ប្រព័ន្ធនេះនឹងបន្ថែមទៅលើសន្លឹកឆ្នោតផ្លូវការដែលបានត្រៀមទុក នៅមុនការបោះឆ្នោតទៅតាមតម្រូវការ ។<br>*(ក្រមបោះឆ្នោត California §13004.5)* |
| គណៈកម្មការអ្នកគ្រប់គ្រង (BOS) | អង្គការគ្រប់គ្រងដែលទទួលខុសត្រូវទៅលើប្រតិបត្តិការរដ្ឋបាលរដ្ឋាភិបាលខោនធី Santa Clara ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ប្រព័ន្ធអនឡាញខាល់អាកសិសស៍ | ប្រព័ន្ធអនឡាញត្រូវបានបង្កើតឡើងដោយរដ្ឋលេខាធិការទៅទាមច្បាប់រដ្ឋ ដើម្បីទទួលបាន និងចូលទៅកាន់ព័ត៌មានហិរញ្ញវត្ថុផ្តល់ដោយបេក្ខជនថ្នាក់រដ្ឋ ម្ចាស់ជំនួយ អ្នកបញ្ចុះបញ្ចូល និងអ្នកដទៃផ្សេងទៀត ។ សំណុំឯកសារអនឡាញ ឬអេឡិកត្រូនិកត្រូវមានសម្រាប់អង្គភាពយុទ្ធនាការ ដែលបានរៃអង្គាសប្រាក់ ឬចំណាយប្រាក់ចំនួន $25,000 រាប់ចាប់តាំងពីថ្ងៃទី1 ខែមករា ឆ្នាំ 2000 ។ អង្គភាពបញ្ចុះបញ្ចូលត្រូវដាក់ពាក្យតាមអនឡាញ ឬអេឡិកត្រូនិកភ្លាមៗនូវចំនួនសរុបក្នុងផ្នែកណាមួយនៃការបង់ថ្លៃដែលត្រូវរាយការណ៍ ការចំណាយ ការធ្វើវិភាគទាន អំណោយ ឬរបស់ផ្សេងទៀតក្នុងតម្លៃ $2,500 ឬ ច្រើនជាងនៅក្នុងប្រតិទិនត្រីមាស ។<br>*(ក្រមរដ្ឋាភិបាល California §§84602 & 84605)* |
| ប្រព័ន្ធអនឡាញខាល់ | ជាប្រព័ន្ធរៀបចំការបញ្ចូលទិន្នន័យមានលក្ខណៈជាគេហទំព័រ ដែលអនុញ្ញាតឲ្យរដ្ឋផ្សព្វផ្សាយនូវសេចក្តីថ្លែងការណ៍/របាយការណ៍ ដែលត្រូវបានកំណត់ដោយច្បាប់កំណែទម្រង់នយោបាយរបស់រដ្ឋ California ដើម្បីដាក់តម្កល់តាមអនឡាញជាមួយនឹងរដ្ឋលេខាធិការដោយមិនគិតថ្លៃ ។ អ្នកតម្កល់ត្រូវមានលេខសម្គាល់មានសុពលភាព និងលេខសម្ងាត់ដើម្បីប្រើកម្មវិធីនេះបានដោយមិនគិតថ្លៃ ។ មន្ទាប់មកព័ត៌មានត្រូវផលិតឡើងវិញនៅលើគេហទំព័រ Cal-Access របស់រដ្ឋលេខាធិការសម្រាប់ការមើលជាសាធារណៈ ។<br>*(ក្រមរដ្ឋាភិបាល California §84602)* |
| ក្រមបទបញ្ញា California | ជាឯកសារច្បាប់ដែលរដ្ឋលេខាធិការ California ចងក្រងជាក្រមបទបញ្ញាដើម្បីធានាឲ្យមានលក្ខណៈដូចគ្នានៃកម្មវិធីនិងរដ្ឋបាលនៃច្បាប់បោះឆ្នោតរបស់រដ្ឋ ។ |
| ក្រមបោះឆ្នោត California | ច្បាប់ដែលគ្រប់គ្រងទៅលើរដ្ឋបាលនៃការបោះឆ្នោតនៅក្នុងរដ្ឋ California ។ |
| ក្រមរដ្ឋាភិបាល California | ច្បាប់ដែលកម្រិតការងាររដ្ឋបាលរបស់រដ្ឋាភិបាលនៅទូទាំងរដ្ឋ California ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| អ្នកបោះឆ្នោតដែលត្រូវបានបដិសេធ | ជាអ្នកបោះឆ្នោតអាចត្រូវបានបដិសេធនៅក្នុងមូលដ្ឋានទិន្នន័យអ្នកបោះឆ្នោត ក្រោយពីធ្វើសកម្មភាពដូចខាងក្រោម៖<br>1. មិនមានការឆ្លើយតបចំពោះសំបុត្រផ្ញើទៅសុំឲ្យបញ្ជាក់អាសយដ្ឋាន<br>2. មិនមានកំណត់ត្រាបោះឆ្នោតនៅក្នុងការបោះឆ្នោតប្រធានាធិបតីពីរជុំជាប់ៗគ្នា<br>3. ដោយមរណៈភាព<br>4. ដោយសំណើផ្ទាល់របស់អ្នកបោះឆ្នោត<br>អ្នកបោះឆ្នោតនឹងមិនបង្ហាញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬតារាងបញ្ជីណាមួយដែលត្រូវបានរៀបចំឡើងដោយមន្ត្រីរៀបចំការបោះឆ្នោត ហើយនឹងមិនទទួលបានឯកសារបោះឆ្នោត ។ អ្នកបោះឆ្នោតដែលត្រូវបានបដិសេធមានសិទ្ធិបោះឆ្នោតបានដោយត្រូវបំពេញនូវ ពាក្យសុំចុះឈ្មោះបោះឆ្នោតថ្មី ។ អ្នកបោះឆ្នោតដែលត្រូវបានបដិសេធមិនមានសិទ្ធិចុះហត្ថលេខាលើលើញត្តិទាមទារទេ ។<br>*(ក្រមបោះឆ្នោត California §2183)* |
| បេក្ខជន | បុគ្គលក្លាយជាបេក្ខជនបានក្រោមលក្ខណខណ្ឌដូចខាងក្រោម៖<br>1. ឈ្មោះរបស់បុគ្គលនោះមាននៅលើសន្លឹកឆ្នោតការបោះឆ្នោតបឋម ទូទៅ ពិសេស ឬសន្លឹកឆ្នោតការបោះឆ្នោតដកតំណែង ឬ<br>2. បុគ្គលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឲ្យមន្ត្រីរៀបចំការបោះឆ្នោតបញ្ចូលឈ្មោះរបស់គាត់ជាបេក្ខជននៅលើសន្លឹកឆ្នោតសម្រាប់ការជ្រើសរើសឲ្យឈរឈ្មោះ ឬសម្រាប់ការបោះឆ្នោតដោយសរសេរបញ្ចូលឈ្មោះបេក្ខជនដែលអត់មាននៅលើសន្លឹកឆ្នោតនៅតាមតំណែងដែលត្រូវបោះឆ្នោតថ្នាក់រដ្ឋឬមូលដ្ឋាន ឬ<br>3. បុគ្គលទទួលការបរិច្ចាក ឬធ្វើការចំណាយ (ឬ ផ្តល់ការឯកភាពដល់បុគ្គលណាម្នាក់ដើម្បីទទួលយកនូវការបរិច្ចាក ឬធ្វើការចំណាយ) សម្រាប់ការជ្រើសរើសខ្លួនឲ្យឈរឈ្មោះ ឬសម្រាប់ការបោះឆ្នោតនៅតាមតំណែងដែលត្រូវបោះឆ្នោតថ្នាក់រដ្ឋឬមូលដ្ឋាន ឬ<br>4. បុគ្គលដែលកំពុងកាន់តំណែងដោយការបោះឆ្នោត ។<br>បុគ្គលទាំងឡាយណាដែលឈរឈ្មោះសម្រាប់តំណែងថ្នាក់សហព័ន្ធ មិនមែនជា "បេក្ខជន" ស្ថិតក្រោមច្បាប់កែទម្រង់នយោបាយឡើយ ។<br>*(ក្រមរដ្ឋាភិបាល California §§82007 & 84214)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ការធ្វើសាវនកម្មនិងផ្តល់សុពលភាពលើលទ្ធផលនៃការបោះឆ្នោត (ការធ្វើសាវនកម្មនិងផ្តល់សុពលភាពលើលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ) | ទម្រង់ការច្បាប់ (ជាទូទៅមានរយៈពេល 30 ថ្ងៃចាប់ផ្តើមពីថ្ងៃទីមួយក្រោយថ្ងៃបោះឆ្នោត) សម្រាប់មន្ត្រីរៀបចំការបោះឆ្នោតដើម្បីបំពេញដំណើរការ និងការរាប់សម្លេងឆ្នោតទាំងអស់ដែលទទួលបាន (ដោយរាប់បញ្ចូលទាំងសន្លឹកឆ្នោតបណ្តោះអាសន្ន, សន្លឹកឆ្នោតបោះតាមសំបុត្រនិង សន្លឹកឆ្នោតមានលក្ខខណ្ឌ) រៀបរយឯកសារ រាប់ដោយដៃ (ធ្វើការផ្ទៀងផ្ទាត់) សន្លឹកឆ្នោត បញ្ជាក់លើលទ្ធផល និងចេញលិខិតបញ្ជាក់ការបោះឆ្នោត ។<br>*(ក្រមបោះឆ្នោត California ផ្នែក 15)* |
| អង្គការតាមសហគមន៍ (CBOs) | មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) មានទំនាក់ទំនងជាមួយអង្គការតាមសហគមន៍ (CBOs) ដើម្បីបង្កើនការចុះឈ្មោះអ្នកបោះឆ្នោត និងលើកទឹកចិត្តដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យដោយធ្វើការបោះឆ្នោត ។ |
| ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ | អនុវត្តន៍យ៉ាងត្រឹមត្រូវនូវ លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ ដែលបានផ្ញើមកឲ្យដោយអ្នកចុះឈ្មោះដល់មន្ត្រីរៀបចំការបោះឆ្នោតខោនធីក្នុងអំឡុងពេល 14 ថ្ងៃភ្លាមនៅមុនឬចំថ្ងៃបោះឆ្នោត ហើយដែលអាចកំណត់ថាមានប្រសិទ្ធិភាពក្រោយពីមន្ត្រីរៀបចំការបោះឆ្នោតដំណើរការលិខិតបញ្ជាក់នោះ ដោយកំណត់ទៅលើសិទ្ធិអាចចុះឈ្មោះបានរបស់អ្នកចុះឈ្មោះ និងធ្វើសុពលភាពលើព័ត៌មានរបស់អ្នកចុះឈ្មោះនៅមុន ឬក្នុងអំឡុងរយៈពេល ធ្វើសាវនកម្មនិងផ្តល់សុពលភាពលើលទ្ធផលនៃការបោះឆ្នោត ។ អ្នកបោះឆ្នោតអាចបំពេញទម្រង់ចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌនិងការបោះ (ឆ្នោត) សន្លឹកឆ្នោតបណ្តោះអាសន្ន ។<br>*(ក្រមបោះឆ្នោត California §§2170 - 2173)* |
| សេចក្តីណែនាំព័ត៌មានស្តីពីការបោះឆ្នោតរបស់ខោនធី (CVIG) | កូនសៀវភៅដែលត្រូវបានរៀបចំ បកប្រែ និងបោះពុម្ពដោយមន្ត្រីរៀបចំការបោះឆ្នោតខោនធី ដែលមានផ្ទុកព័ត៌មានសំខាន់ៗដូចជាបញ្ជីឈ្មោះទីតាំងទម្លាក់សន្លឹកឆ្នោតនិងមណ្ឌលបោះឆ្នោតនៃសន្លឹកឆ្នោតផ្លូវការ (សូមមើល សន្លឹកឆ្នោតគំរូ) សេចក្តីថ្លែងការណ៍របស់បេក្ខជន អត្ថបទច្បាប់ ការវិភាគឥតលំអៀង និងទឡ្ហីករណ៍នានាជាការគាំទ្រ ឬប្រឆាំងទៅនឹងវិធានការនៃសន្លឹកឆ្នោតក្នុងមូលដ្ឋាន និងពាក្យស្នើសុំប្តូរសន្លឹកឆ្នោត ។ សេចក្តីណែនាំព័ត៌មានស្តីពីការបោះឆ្នោតរបស់ខោនធី (CVIG) ត្រូវបានផ្ញើចេញក្នុងរង្វង់ 40 ថ្ងៃមុនការបោះឆ្នោត ។ ពីមុនត្រូវបានគេស្គាល់ថា ខិត្តប័ណ្ណសន្លឹកឆ្នោតគំរូ ។ ច្បាប់បកប្រែនៃ VCIG មានជាភាសាអេស្ប៉ាញ ចិន តាកាឡុក និងវៀតណាម ។ ឯកសារនេះមិនដូចគ្នាទៅនឹងសេចក្តីណែនាំព័ត៌មានអំពីការបោះឆ្នោតផ្លូវការរបស់រដ្ឋលេខាធិការឡើយ ។<br>*(ក្រមបោះឆ្នោត California §§13300 - 13317)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| សន្លឹកឆ្នោតដែលអាចទាញយកបាន (ពីបណ្តាញអ៊ីនធឺណិត) | សន្លឹកឆ្នោតដែលទទួលបានតាមរយៈកម្មវិធីបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) របស់ មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត និងថតចម្លងជាអេឡិចត្រូនិកទៅកាន់ឧបករណ៍តាមផ្ទះរបស់អ្នកបោះឆ្នោតសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ។ បន្ទាប់មកអ្នកបោះឆ្នោតត្រូវតែព្រីននិងផ្ញើសន្លឹកឆ្នោតរបស់គេមកកាន់ការិយាល័យមន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោតដើម្បីឲ្យសម្លេងឆ្នោតរបស់គេត្រូវបានរាប់ ។<br>*(ក្រមបោះឆ្នោត California §3007.7)* |
| ការថតជាអេឡិចត្រូនិកដោយផ្ទាល់ (DRE) | *តាមម៉ាស៊ីនបោះឆ្នោត* ហួសសម័យ ។<br>ម៉ាស៊ីនបោះឆ្នោតដែលកត់ត្រាសម្លេងឆ្នោតដោយបង្ហាញសន្លឹកឆ្នោតទទួលបានដោយសមាភាគមេកានិក ឬអេឡិចត្រូអុបទិកដែលអាចត្រូវបានបញ្ជាដោយអ្នកបោះឆ្នោត ដែលដំណើរការទិន្នន័យតាមរយៈកម្មវិធីកុំព្យូទ័រ ហើយដែលកត់ត្រាទិន្នន័យបោះឆ្នោតនិងរូបភាពសន្លឹកឆ្នោតចូលទៅក្នុងអង្គចងចាំ ។ |
| ការបោះឆ្នោតមុនពេល | រយៈពេលមុនថ្ងៃបោះឆ្នោតនៅពេលដែលអ្នកបោះឆ្នោតអាចបោះឆ្នោតបាន ។ រដ្ឋ California "ពុំមានការលើកលែង" ការបោះឆ្នោតមុនកាលកំណត់ទេ ហើយអ្នកបោះឆ្នោតមិនចាំបាច់ផ្តល់ការសុំលើកលែងចំពោះភាពដែលមិនអាចបោះឆ្នោតបាននៅថ្ងៃបោះឆ្នោតនោះទេ ។ នៅក្នុងរដ្ឋ California ការបោះឆ្នោតមុនកាលកំណត់អាចចាប់ផ្តើមបានលឿនបំផុតត្រឹមរយៈពេល 29 ថ្ងៃមុនការបោះឆ្នោត ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធី Santa Clara អាចបោះឆ្នោតមុនកាលកំណត់បាននៅតាមការិយាល័យនៃមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត ឬនៅតាមមណ្ឌលណាមួយនៃមណ្ឌលបោះឆ្នោតទាំងឡាយចាប់ផ្តើមក្នុងរយៈពេលដប់ថ្ងៃមុនថ្ងៃបោះឆ្នោត ។<br>*(ក្រមបោះឆ្នោត California §19209)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) | ត្រូវបានស្នើឡើងដោយមន្ត្រីរៀបចំការបោះឆ្នោត នូវគម្រោងពិស្តារស្តីពីការរៀបចំការបោះឆ្នោតក្រោម ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) ។ គម្រោងរាប់បញ្ចូលនូវការពិចារណានានាដូចជាការជ្រើសរើសទីតាំងទម្លាក់សន្លឹកឆ្នោត និងមណ្ឌលបោះឆ្នោត ផលប៉ះពាល់សារពើពន្ធ និងគម្រោងផ្សព្វផ្សាយជាសាធារណៈ ។ *ពង្រាងគម្រោង* ត្រូវបានចងក្រងឡើងដោយមានធាតុចូលពីសហគមន៍និងត្រូវបានពិនិត្យតាមរយៈដំណើរការសវនាការសាធារណៈ ។ *ពង្រាងគម្រោង* ដែលត្រូវបានកែសម្រួលហើយត្រូវបានបង្ហោះផ្សាយដើម្បីឲ្យសាធារណជនផ្តល់មតិយោបល់ក្រោយពីសវនាការសាធារណៈទៅលើពង្រាងគម្រោងត្រូវបានធ្វើឡើង ដោយបន្ទាប់មកគម្រោងត្រូវបានអនុម័តិជា *ជាចុងក្រោយ* ។ គម្រោងចុងក្រោយដែលត្រូវបានផ្លាស់ប្តូរនិងចេញផ្សាយសម្រាប់ការផ្តល់មតិជាសាធារណៈនោះជា *គម្រោងចុងក្រោយដែលត្រូវបានកែតម្រូវ* ។ គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) ចុងក្រោយត្រូវបានប្រើដើម្បីរៀបចំការបោះឆ្នោតត្រូវបានធ្វើការពិនិត្យវាយតម្លៃហើយអាចត្រូវបានកែសម្រួលឡើងវិញក្នុងរយៈពេលពីរឆ្នាំនៃការប្រើប្រាស់ ហើយរៀងរាល់បួនឆ្នាំបន្ទាប់មកទៀត ។ ផ្នែកស្តីពីការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោតរបស់ EAP ត្រូវបានដាក់ជូនទៅកាន់រដ្ឋលេខាធិការដើម្បីសុំការអនុម័តិ ។ គម្រោងត្រូវបានបកប្រែនិងមាននៅលើគេហទំព័ររបស់មន្ត្រីរៀបចំការបោះឆ្នោត ។<br>*(ក្រមបោះឆ្នោត California §§4000 - 4108)* |
| ជុំបោះឆ្នោត | "ជុំបោះឆ្នោត" ន័យមួយក្នុងចំណោមន័យពីរផ្សេងគ្នា អាស្រ័យទៅលើបរិបទនៃការប្រើប្រាស់វា ។<br>1. "ជុំបោះឆ្នោត" មានន័យថាជារយៈពេលនៃពេលវេលាចាប់ផ្តើមចំនួន 90 ថ្ងៃមុនការបោះឆ្នោត ហើយបញ្ចប់ទៅវិញនៅថ្ងៃបោះឆ្នោត សម្រាប់គោលបំណងនៃការរាយការណ៍ទៅលើការចូលរួមវិភាគទាន ឬការចំណាយដោយឯករាជ្យនូវចំនួនទឹកប្រាក់ $1,000 ឬច្រើនជាងតាមអនឡាញ ឬ ជាអេឡិចត្រូនិកទៅតាមការកំណត់របស់ក្រមរដ្ឋាភិបាល§§ 85309 or 85500 ។ (ក្រមរដ្ឋាភិបាល ផ្នែក 85204) ។<br>2. "ជុំបោះឆ្នោត" មានន័យថាជារយៈពេលចាប់ផ្តើមក្នុងថ្ងៃទី1 ខែមករានៃឆ្នាំសេស ឬសម្រាប់គោលបំណងនៃការមើលទៅលើការចូលរួមវិភាគទាននៅក្នុងយុទ្ធនាការ និងការចំណាយនានានៅលើ Cal-Access ។ |

# សេចក្ដីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| មន្ត្រីរៀបចំការបោះឆ្នោត | ជាសមាជិកនៃគណៈកម្មការមណ្ឌល ត្រូវជាអ្នកបោះឆ្នោតក្នុងរដ្ឋ នឹងមានសមត្ថភាពក្នុងការអាននិងសរសេរភាសាអង់គ្លេស ហើយត្រូវចូលរួមវគ្គបណ្ដុះបណ្ដាលរៀបចំឡើងដោយមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) ដើម្បីបម្រើការនៅតាមការិយាល័យបោះឆ្នោត ឬនៅតាមមណ្ឌលបោះឆ្នោត ។ កាលពីដើមគេស្គាល់ថាជាបុគ្គលិកស្ម័គ្រចិត្ត, មន្ត្រីរៀបចំការបោះឆ្នោតអាចត្រូវបានចាត់តាំងជាស្មៀន ឬជាមន្ត្រីអធិការកិច្ចដោយមានករណីយកិច្ចផ្សេងៗគ្នា ។ មន្ត្រីរៀបចំការបោះឆ្នោតជួយអ្នកបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ផ្ទៀងផ្ទាត់ទៅលើសិទ្ធិ ចេញសន្លឹកឆ្នោតផ្លូវការ និងបំពេញករណីយកិច្ចផ្សេងៗទៀត ។<br>*(ត្រូវបានយោងដោយក្រមបោះឆ្នោតថាជាក្រុមប្រឹក្សាបោះឆ្នោត)* |
| ប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោត (EIMS) | មូលដ្ឋានទិន្នន័យព័ត៌មានស្ដីពីការបោះឆ្នោតរបស់ខោនធី Santa Clara ។ |
| បញ្ជីបោះឆ្នោតអេឡិចត្រូនិក | ប្រព័ន្ធផ្ទុកបញ្ជីឈ្មោះអ្នកបោះឆ្នោតជាអេឡិចត្រូនិកដែលអាចបញ្ជូននិងប្រើប្រាស់នៅតាមមណ្ឌលបោះឆ្នោត ។ នេះជាបញ្ជីផ្លូវការនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះមានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោត ។ វាត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ពីសិទ្ធិរបស់អ្នកបោះឆ្នោតដើម្បីទទួលបានសន្លឹកឆ្នោត និងចាប់យកប្រវត្តិរបស់អ្នកបោះឆ្នោតភ្លាមៗដើម្បីបង្ការការបោះឆ្នោតទ្វេដង ។ បញ្ជីបោះឆ្នោតអេឡិចត្រូនិកមិនអាចត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធបោះឆ្នោតទេ ហើយត្រូវតែមានចរន្តអគ្គិសនីបម្រុងសម្រាប់បន្តប្រតិបត្តិការ ។<br>1. បញ្ជីបោះឆ្នោតអេឡិចត្រូនិកនឹងមានយ៉ាងហោចណាស់នូវទិន្នន័យចុះឈ្មោះរបស់អ្នកបោះឆ្នោតដូចខាងក្រោម៖ ឈ្មោះ អាសយដ្ឋាន/សង្កាត់ គណៈបក្សអាទិភាពស្ថានភាពអ្នកបោះឆ្នោត ថាតើអ្នកបោះឆ្នោតត្រូវបានចេញឲ្យឬក៏អត់នូវ សន្លឹកឆ្នោតបោះតាមសំបុត្រថាតើ សន្លឹកឆ្នោតបោះតាមសំបុត្រ ត្រូវបានកត់ត្រាទៅតាមការទទួលយកបានដោយមន្ត្រីរៀបចំការបោះឆ្នោតដែរឬអត់ និងថាតើអត្តសញ្ញាណរបស់អ្នកបោះឆ្នោតត្រូវបានបញ្ជាក់ហើយឬនៅ (សម្រាប់អ្នកបោះឆ្នោតលើកដំបូងនៅក្នុងការបោះឆ្នោតថ្នាក់សហព័ន្ធតែប៉ុណ្ណោះ) ។<br>2. បញ្ជីបោះឆ្នោតអេឡិចត្រូនិកនឹងមិនត្រូវមានទិន្នន័យចុះឈ្មោះរបស់អ្នកបោះឆ្នោតដូចខាងក្រោម៖ លេខប័ណ្ណបើកបរ ឬឯកសារយោងណាមួយទៅកាន់លេខសន្តិសុខសង្គមឡើយ ។<br>*(ក្រមបោះឆ្នោត California §2183)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ការបញ្ជូនសន្លឹកឆ្នោតបន្ទាន់ | សេវាប្រភេទនេះមានជាពិសេសដើម្បីអនុញ្ញាតឲ្យអ្នកបោះឆ្នោតបោះបានប្រសិនបើគេមិនអាចធ្វើបានជារូបវន្តដោយសារតែភាពបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ដូចជាជំងឺដែលមិនអាចដឹងមុនបាន ការឃុំឃាំងតាមគ្រឹះស្ថានវេជ្ជសាស្ត្រ ពិការភាព ឬគ្រោះថ្នាក់បង្ករជារបួសស្នាម ។ រដ្ឋ California គឺជារដ្ឋមួយក្នុងចំណោមរដ្ឋចំនួន 38 ដែលផ្តល់ឲ្យមាននូវប្រព័ន្ធបញ្ជូនសន្លឹកឆ្នោតបន្ទាន់ ។ |
| សន្លឹកឆ្នោតបញ្ជូនតាមទូរសារ | ច្បាប់ចតចម្លងនៃសន្លឹកឆ្នោតដែលបោះពុម្ពចេញមកតាមទម្រង់ជាច្រើន ដែលអ្នកបោះឆ្នោតអាចស្នើសុំប្រើប្រាស់បាន ដូចជាច្បាប់បកប្រែជាភាសាជាក់លាក់ណាមួយ (សូមមើល សន្លឹកឆ្នោតគំរូ) ឬសន្លឹកឆ្នោតដែលត្រូវបានបោះពុម្ពចេញជាអក្សរខ្នាតធំៗសម្រាប់អ្នកមានបញ្ហាក្នុងការមើលមិនឃើញ ។ អ្នកបោះឆ្នោតអាចស្នើសុំទទួលសន្លឹកឆ្នោតតាមទូរសារតាមសំបុត្របាន ។ សន្លឹកឆ្នោតតាមទូរសារមិនមែនជាសន្លឹកឆ្នោតផ្លូវការទេ ហើយមិនអាចបូកសរុបតាមប្រព័ន្ធបោះឆ្នោតបានឡើយ ។ អ្នកបោះឆ្នោតអាចប្រើសន្លឹកឆ្នោតបញ្ជូនតាមទូរសារជាជំនួយក្នុងការបំពេញសន្លឹកឆ្នោតផ្លូវការរបស់គេ ។ |
| ច្បាប់ជួយអាមេរិកក្នុងការបោះឆ្នោត (HAVA) | អនុម័តិដោយសភានៅក្នុងឆ្នាំ 2002 ដើម្បីជួយធ្វើទំនើបកម្មនិងកំណែទម្រង់ដំណើរការបោះឆ្នោតរបស់ជាតិ ច្បាប់ជួយអាមេរិកក្នុងការបោះឆ្នោត (HAVA) បង្កើតស្តង់ដាអប្បរមាចាំបាច់ថ្មីសម្រាប់រដ្ឋទាំងឡាយដើម្បីអនុវត្តតាមក្នុងផ្នែកគន្លឹះមួយចំនួននៃរដ្ឋបាលបោះឆ្នោត ។ ច្បាប់ផ្តល់នូវមូលនិធិដើម្បីជួយដល់រដ្ឋទាំងឡាយឲ្យបំពេញបានទៅតាមស្តង់ដាថ្មីទាំងនេះ ជំនួសឲ្យប្រព័ន្ធបោះឆ្នោត និងធ្វើឲ្យប្រសើរឡើងនូវរដ្ឋបាលបោះឆ្នោត ។ HAVA តម្រូវឲ្យរដ្ឋទាំងឡាយអនុវត្តន៍នូវកម្មវិធីនិងនិតិវិធីដូចខាងក្រោមៈ<br>1. ការបោះឆ្នោតបណ្តោះអាសន្ន<br>2. ព័ត៌មានស្តីពីការបោះឆ្នោត<br>3. គ្រឿងបរិក្ខារបោះឆ្នោតត្រូវបានធ្វើបច្ចុប្បន្នភាពនិងបង្កើនកម្រិត<br>4. មូលដ្ឋានទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោតទូទាំងរដ្ឋ<br>5. នីតិវិធីកំណត់អត្តសញ្ញាណអ្នកបោះឆ្នោត<br>6. នីតិវិធីបណ្តឹងរដ្ឋបាល |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| អ្នកបោះឆ្នោតអសកម្ម | អ្នកបោះឆ្នោតអាចចាត់ទុកថាអសកម្មប្រសិនបើខោនធីទទួលបាន៖ សេចក្តីបញ្ជាក់ទីលំនៅដែលផ្ញើត្រឡប់មកវិញដោយមិនបញ្ជូនបន្តនូវអាសយដ្ឋាននៅក្នុងខោនធីជាមួយគ្នា ឬព័ត៌មានទទួលបានតាមរយៈសេវាប្រៃសណីយ៍សហរដ្ឋអាមេរិកមូលដ្ឋានទិន្នន័យការផ្លាស់ប្តូរអាសយដ្ឋានថ្នាក់ជាតិ (NCOA) បង្ហាញដល់អ្នកបោះឆ្នោតដែលត្រូវបានប្តូរចេញទៅក្រៅខោនធី ។ អ្នកបោះឆ្នោតនឹងមិនមាននៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬបញ្ជីឈ្មោះណាមួយដែលត្រូវបានរៀបចំឡើងដោយមន្ត្រីរៀបចំបោះឆ្នោត ហើយនឹងមិនទទួលបានឯកសារបោះឆ្នោតឡើយ ។ បន្ថែមលើនេះទៀត អ្នកបោះឆ្នោតអសកម្មដែលមិនបោះឆ្នោតនៅក្នុងការបោះឆ្នោតទូទៅថ្នាក់សហព័ន្ធចំនួនពីរដងជាប់ៗគ្នានោះត្រូវប្រឈមនឹងការបដិសេធចោល ។ អ្នកបោះឆ្នោតអសកម្មក្លាយជាអ្នកបោះឆ្នោតសកម្ម ហើយមានសិទ្ធិបោះឆ្នោតបានអាស្រ័យលើការឆ្លើយតបទៅនឹងប័ណ្ណបញ្ជាក់អាសយដ្ឋាន ដោយធ្វើការចុះហត្ថលេខាលើញត្តិបង្ហាញពីអាសយដ្ឋាន ឬតាមរយៈការបំពេញនូវ ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតថ្មី ។ |
| គណៈកម្មការផ្តល់ឱវាទលើលទ្ធភាពនៃការទទួលបានសេវាភាសា (LAAC) | គណៈកម្មការផ្តល់ឱវាទលើលទ្ធភាពនៃការទទួលបានសេវាភាសា (LAAC) ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាដល់មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) អំពីបញ្ហានានាទាក់ទងទៅនឹងការចូលរួមក្នុងដំណើរការបោះឆ្នោតដោយអ្នកបោះឆ្នោតដែលមានសមត្ថភាពភាសាអង់គ្លេសមានកម្រិត ។ គណៈកម្មាធិការនឹងមានតំណាងពី សហគមន៍ប្រើភាសាជនជាតិភាគតិចនិងបានបង្ហាញបទពិសោធន៍ទទួលបានជំនួយភាសា មានចំណេះដឹងនៃការធ្វើបទបង្ហាញពីឯកសារបោះឆ្នោតដល់អ្នកបោះឆ្នោតប្រើប្រាស់វិធីសាស្ត្រភាសាសុទ្ធ ឬវិធីសាស្ត្រមួយផ្សេងទៀត និង/ឬជាមន្ត្រីរៀបចំការបោះឆ្នោត ឬអ្នកតំណាងរបស់គាត់ ។ ROV នឹងពិភាក្សានិងពិចារណាលើអនុសាសន៍ទាំងឡាយរបស់គណៈកម្មាធិការ ដែលនឹងត្រូវផ្តល់សេវាក្នុងនាមជាទីប្រឹក្សា ។<br>*(ក្រមបោះឆ្នោត California §4005)* |
| សហគមន៍ប្រើភាសាជនជាតិភាគតិច | ជាក្រុមមនុស្សដែលនិយាយភាសាដែលតម្រូវឲ្យផ្តល់សេវាក្រោមច្បាប់សិទ្ធិបោះឆ្នោតសហព័ន្ធ ។ ឯកសារនានា ជំនួយបោះឆ្នោត និងសកម្មភាពផ្សេងៗទៀតទាក់ទងទៅនឹងសហគមន៍ប្រើភាសាជនជាតិភាគតិចត្រូវបានយោងនៅក្នុងច្បាប់ទាំងមូលទាក់ទងទៅនឹង ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) ។<br>*(ការផ្តល់ភាសាជនជាតិភាគតិចនៃច្បាប់សិទ្ធិបោះឆ្នោត)* |
| ទាញយកសន្លឹកឆ្នោតសម្រាប់មណ្ឌលរបស់អ្នក | ស្ថិតក្រោម គំរូការិយាល័យបោះឆ្នោត សង្កាត់ដែលមានបុគ្គលចុះឈ្មោះបោះឆ្នោតចំនួយ 250 នាក់ ឬតិចជាងត្រឹមរយៈពេល 88 ថ្ងៃមុនការបោះឆ្នោត អាចនឹងត្រូវចាត់ជា "សង្កាត់សន្លឹកឆ្នោតតាមសំបុត្រ" ហើយមន្ត្រីរៀបចំការបោះឆ្នោតអាចនឹងផ្តល់ដល់អ្នកបោះឆ្នោតម្នាក់ សន្លឹកឆ្នោតបោះតាមសំបុត្រ ដោយមិនតម្រូវឲ្យដាក់ពាក្យសុំឡើយ ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| គ្រឿងបរិក្ខារផ្ទេទិន្នន័យដើម្បីរក្សាទុក | ឯកសារ និងសម្ភារៈត្រូវបានប្រើដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវលទ្ធភាពទទួលបាន និងការចេញចូលទៅកាន់ទីតាំងបោះឆ្នោត កំណត់ឧបសគ្គចំពោះការបោះឆ្នោត ។ គ្រឿងបរិក្ខារគំរូអាចត្រូវប្រើមានៈ ភ្លើងបន្ថែម ឬបង្គ្រប់ កៅអីបន្ថែមសម្រាប់អ្នកដែលមិនអាចឈរបាន ស្លាកសញ្ញាបង្ហាញច្រកចេញចូល ស្មៀត ជម្រាលជនពិការ ឬកន្ទេលកៅស៊ូដើម្បីគ្របរណែងដែក ឬកុំឲ្យខូចបាតទ្វារ ប្រដាប់ទប់ទ្វារដើម្បីទប់ទ្វារឲ្យបើកចំហរ កោណពណ៌ទឹកក្រូចសម្រាប់គូសបង្ហាញចំណតដែលអាចចតបាន និងប្រព័ន្ធផ្តល់ដំណឹងសម្រាប់ផ្តល់ការបោះឆ្នោតតាមចិញ្ចើមថ្នល់ ។ |
| មណ្ឌលបោះឆ្នោតចល័ត | ប្រតិបត្តិការចល័តត្រូវបានគ្រប់គ្រងដោយមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) ដែលត្រូវទៅតាមលក្ខខណ្ឌដូចគ្នា ហើយផ្តល់សេវាដូចគ្នាទៅនឹងមណ្ឌលបោះឆ្នោតដែរ ។ |
| ការផ្លាស់ប្តូរអាសយដ្ឋានថ្នាក់ជាតិ (NCOA) | ព័ត៌មាន ឬទិន្នន័យមានឈ្មោះនិងអាសយដ្ឋានរបស់បុគ្គលនិងក្រុមគ្រួសារដែលបានបំពេញពាក្យសុំធ្វើការផ្លាស់ប្តូរអាសយដ្ឋានជាមួយនឹងសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក ។<br>*(ក្រមបោះឆ្នោត California §2222)* |
| *ម៉ាស៊ីនស្កេនអុបទិក* | *តាមម៉ាស៊ីនបោះឆ្នោត* ***ហួសសម័យ*** ។<br>ម៉ាស៊ីនបោះឆ្នោតប្រើក្រដាស ដែលស្កេនសញ្ញាអុបទិកដែលអ្នកអាចស្កេនបាននៅលើក្រដាសសន្លឹកឆ្នោតរបស់អ្នកនិងរាប់សម្លេងឆ្នោតជាអេឡិចត្រូនិកនៅពេលសន្លឹកឆ្នោតត្រូវបានស៊កបញ្ចូលរួច ។ |
| *មន្ត្រីរៀបចំការបោះឆ្នោត* | *ពាក្យបច្ចេកទេសដែលឈប់ត្រូវបានប្រើប្រាស់*<br>*សូមមើល* ***មន្ត្រីរៀបចំការបោះឆ្នោត*** ។ |
| *ការិយាល័យបោះឆ្នោតគំរូ* | *គំរូបច្ចុប្បន្នដែល ROV កំពុងផ្លាស់ប្តូរចេញ ។*<br>ពាក្យត្រូវបានប្រើសំដៅលើវិធីសាស្រ្តនិងរដ្ឋបាលបោះឆ្នោតត្រូវបានធ្វើឡើងស្ថិតក្រោមបទបញ្ញត្តិទូទៅនៃ **ក្រមបោះឆ្នោត California** ។ ប្រើប្រាស់ច្រើនទូលំទូលាយតាមការិយាល័យបោះឆ្នោត "តាមសង្កាត់" ត្រូវបានកំណត់ និងដាក់លាក់ទៅតាមមណ្ឌលដោយមិនមានអ្នកបោះឆ្នោតច្រើនជាង 1,000 នាក់តាមសំបុត្រ ។ |
| ការជម្រុះចោលដោយវិជ្ជមាន | ជានីតិវិធីដែលតម្រូវឲ្យអ្នកបោះឆ្នោតធ្វើអ្វីម្យ៉ាងដើម្បីបង្ការកុំឲ្យត្រូវបានប្តូរទៅជាអសកម្ម ឬទៅជាសំណុំឯកសារត្រូវបានបដិសេធ ដូចជាការផ្ញើត្រឡប់វិញនូវប័ណ្ណប្រៃសណីយ៍បង្ហាញពីបំណងចង់រក្សាទុកជាអ្នកបោះឆ្នោតសកម្ម ។<br>*(ក្រមបោះឆ្នោត California §§2220 & 2191)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| មណ្ឌល | តំបន់ភូមិសាស្ត្រក្នុងខោនធី ឬដែនសមត្ថកិច្ចនយោបាយដែលត្រូវបានបង្កើតឡើងដោយអ្នកបោះឆ្នោតនិងត្រូវបានបង្កើតឡើងទៅតាមជំពូក 3 (ចាប់ផ្តើមដោយ ខ 12200) នៃផ្នែក 12 នៃ ក្រមបោះឆ្នោត California ។ នៅក្នុង "ការិយាល័យបោះឆ្នោតគំរូ" អ្នកបោះឆ្នោតទាំងអស់មកពីមណ្ឌលដូចគ្នាត្រូវបានកំណត់ឲ្យទៅកាន់ការិយាល័យបោះឆ្នោតដូចគ្នា ។ នៅក្នុងការបោះឆ្នោតបែប "មណ្ឌលបោះឆ្នោតគំរូ" អ្នកបោះឆ្នោតមកពីមណ្ឌលណាមួយនៅក្នុងខោនធីក៏អាចបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនៅក្នុងខោនធីមួយណាក៏បានដែរ ។ បច្ចុប្បន្ននេះ ROV កំពុងប្តូរពី "ការិយាល័យបោះឆ្នោតគំរូ" ទៅកាន់ "មណ្ឌលបោះឆ្នោតគំរូ" ។ |
| គណៈកម្មការមណ្ឌល | ជាពាក្យជាក់លាក់ត្រូវបានប្រើដោយក្រមបោះឆ្នោត California ។ សម្រាប់ខោនធី Santa Clara បុគ្គលទាំងឡាយណាដែលត្រូវបានចាត់តាំងឲ្យបម្រើការជាមន្ត្រីរៀបចំការបោះឆ្នោត សម្រាប់មណ្ឌលនីមួយៗនៅក្នុងការបោះឆ្នោតណាមួយ នឹងត្រូវបង្កើតគណៈកម្មការមណ្ឌលសម្រាប់មណ្ឌលនិងការិយាល័យបោះឆ្នោតនោះ ។ បុគ្គលដែលមិនអាចអាន ឬសរសេរជាភាសាអង់គ្លេសបាន មិនមានសិទ្ធិធ្វើជាសមាជិកនៃគណៈកម្មការមណ្ឌលណាមួយបានឡើយ ។ សមាសភាពនៃគណៈកម្មការមណ្ឌលត្រូវបានកំណត់ដោយមន្ត្រីរៀបចំការបោះឆ្នោតផ្អែកទៅលើទំហំមណ្ឌលបោះឆ្នោត ។ គណៈកម្មការមណ្ឌលនឹងត្រូវមានយ៉ាងតិចម្នាក់ជាមន្ត្រីអធិការកិច្ច និងពីរនាក់ជាស្មៀន ។ *(សូមមើល មន្ត្រីរៀបចំការបោះឆ្នោត)* |
| ការបញ្ជាក់ទីលំនៅនៅមុនការបោះឆ្នោត | តម្រូវឲ្យបញ្ចប់មិនឲ្យយឺតជាង 90 ថ្ងៃមុនការបោះឆ្នោតបឋមនីមួយៗ ដែលត្រូវបានរៀបចំឡើងនៅក្នុងរដ្ឋ ។ មន្ត្រីរៀបចំការបោះឆ្នោតផ្ញើ *ប័ណ្ណប្រៃសណីនីយ៍*ដែលមិនអាចបញ្ជូនបន្តបានទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយនៅក្នុងខោនធី ។ ប័ណ្ណត្រូវបានបញ្ជូនដោយសរសេរថា "ស្នើសុំឲ្យកែតម្រូវអាសយដ្ឋាន ធានាផ្ញើត្រឡប់មកវិញដោយមិនអស់ថ្លៃតែម" និងមិនត្រូវបញ្ជូនទៅកាន់អ្នកបោះឆ្នោត ប៉ុន្តែត្រូវផ្ញើត្រឡប់ទៅកាន់មន្ត្រីរៀបចំការបោះឆ្នោតខោនធីដោយមានព័ត៌មានកែតម្រូវអាសយដ្ឋានថ្មីណាមួយ ដែលការិយាល័យប្រៃសណីយ៍អាចមាន ។ មន្ត្រីរៀបចំការបោះឆ្នោតខោនធីអាចដកចេញនូវអ្នកបោះឆ្នោតទាំងឡាយណាដែលបានបោះឆ្នោតនៅក្នុងការបោះឆ្នោតដែលត្រូវបានធ្វើឡើងមិនតិចជាង 6 ខែនៅមុនការចាប់ផ្តើមនៃការធ្វើការបញ្ជាក់ ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| សេចក្តីថ្លែងការណ៍របស់បេក្ខជនមុនការបោះឆ្នោត | សេចក្តីថ្លែងការណ៍ទាំងនេះតម្រូវឲ្យបេក្ខជន ឬអ្នកកំពុងស្ថិតក្នុងមុខតំណែងដែលមានគណៈកម្មការគ្រប់គ្រង ឬដែលបានរៃអង្គាស ឬចំណាយប្រាក់ ឬនិងរៃអង្គាស ឬចំណាយប្រាក់ចំនួន $2,000 ឬច្រើនជាងក្នុងអំឡុងប្រតិទិប្រចាំឆ្នាំទាក់ទងទៅនឹងការបោះឆ្នោតទៅកាន់ការិយាល័យឬកាន់កាប់ការិយាល័យ ឬការិយាល័យទទួលបន្ទុក (FPPC ទម្រង់ 460) ។ សេចក្តីថ្លែងការណ៍មុនការបោះឆ្នោតលើកទីមួយត្រូវបានតម្រូវជាអម្មតាដើម្បីឲ្យបំពេញពាក្យស្នើសុំមិនឲ្យយឺតជាង 40 ថ្ងៃមុនការបោះឆ្នោត (សម្រាប់រយៈពេលបិទបញ្ចប់ 45 ថ្ងៃមុនការបោះឆ្នោត) ។ សេចក្តីថ្លែងការណ៍មុនការបោះឆ្នោតលើកទីពីរត្រូវបានតម្រូវជាអម្មតាដើម្បីឲ្យបំពេញពាក្យស្នើសុំមិនឲ្យយឺតជាង 12 ថ្ងៃមុនការបោះឆ្នោត (សម្រាប់រយៈពេលបិទបញ្ចប់ 17 ថ្ងៃមុនការបោះឆ្នោត) ។<br>*(ក្រមរដ្ឋាភិបាលរដ្ឋ California §§84200.5, 84200.7, & 84200.8)* |
| សន្លឹកឆ្នោតបណ្តោះអាសន្ន | ពាក្យត្រូវបានប្រើសំដៅដល់សន្លឹកឆ្នោតដែលត្រូវបានចេញឲ្យអ្នកបោះឆ្នោត ដែលសិទ្ធិបោះឆ្នោតមិនអាចត្រូវបានកំណត់បានភ្លាមៗ ឬដែលជា អ្នកបោះឆ្នោតមានលក្ខខណ្ឌ ។ សន្លឹកឆ្នោតនេះត្រូវបានបំពេញ "ជាបណ្តោះអាសន្ន" ដាក់ចូលស្រោមសំបុត្រពណ៌ផ្កាឈូកបិទជិត ហើយត្រូវបានផ្ទៀងផ្ទាត់នៅឯការិយាល័យមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) មុនវាត្រូវបានបើកនិងរាប់ ។<br>*(ក្រមបោះឆ្នោត California §§4005 & 4310)* |
| រយៈពេលសម្រាប់សាធារណជនផ្តល់មតិយោបល់ | រយៈពេលចំនួនដប់ប្រាំថ្ងៃស្របច្បាប់សម្រាប់សាធារណជនផ្តល់មតិត្រឡប់អំពីពង្រាង ពង្រាងក្រោយការកែសម្រួលខ្លឹមសារចុងក្រោយ និងប្រសិនចាំបាច់ ពង្រាងកែសម្រួលចុងក្រោយ គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) ។ |
| កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ | កិច្ចប្រជុំបើកចំហរ ដែលត្រូវបានផ្តល់ដំណឹងនិងផ្សព្វផ្សាយស្របច្បាប់ ត្រូវបានរៀបចំឡើងដោយមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតដើម្បីទទួលធាតុចូលពីសាធារណជនសម្រាប់បង្កើតឡើងនូវ គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) ។ |
| សវនាការសាធារណៈ | កិច្ចប្រជុំផ្លូវការដែលសមាជិកសាធារណៈបានដឹងពីព័ត៌មានពិតស្តីពីសកម្មភាពរដ្ឋាភិបាលដែលបានគ្រោងទុកដើម្បីអនុវត្តន៍ និងផ្តល់នូវមតិយោបល់របស់គេអំពីវា ។ |
| សេចក្តីប្រកាសអំពីសេវាសាធារណៈ (PSA) | សារជាប្រយោជន៍ដល់សាធារណជនត្រូវបានចែកចាយ ដោយមិនគិតថ្លៃក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបទនិងអាកប្បកិរិយាជាសាធារណៈចំពោះបញ្ហាសង្គម ។ |
| មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) | នាយកដ្ឋានមួយក្នុងខោនធី Santa Clara ទទួលខុសត្រូវការងារគ្រប់គ្រងការចុះឈ្មោះបោះឆ្នោតនិងការបោះឆ្នោត ។ |

# សេចក្តីបន្ថែម A – សទ្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ការបោះឆ្នោតតាមសំបុត្រពីចំងាយ (RAVBM) | ប្រព័ន្ធ និងកម្មវិធីរបស់វា ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងតែមួយគត់នៃការគូសសន្លឹកឆ្នោតជាអេឡិចត្រូនិក សន្លឹកឆ្នោតបោះតាមសំបុត្រ សម្រាប់អ្នកបោះឆ្នោតមានពិការភាព ឬយោធិន ឬអ្នកបោះឆ្នោតដែលស្ថិតនៅក្រៅប្រទេស ដែលនឹងត្រូវព្រីនក្រដាសបោះឆ្នោតដើម្បីប្រគល់ទៅមន្ត្រីរៀបចំការបោះឆ្នោត ។ ប្រព័ន្ធបោះឆ្នោតតាមសំបុត្រដែលអាចធ្វើទៅបានពីចម្ងាយមិនដែលត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធបោះឆ្នោតឡើយ ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ។<br>*(ក្រមបោះឆ្នោត California §3016.5)* |
| សន្លឹកឆ្នោតជំនួសថ្មី | សន្លឹកឆ្នោតដែលត្រូវបានផ្តល់ដល់អ្នកបោះឆ្នោតស្ថិតក្រោមកាលៈទេសៈដូចតៅនេះ៖ សន្លឹកឆ្នោតមិនត្រូវបានទទួល បាត់បង់ គូសខុស ឬត្រូវបានស្នើសុំជាភាសា ឬទម្រង់ផ្សេង ។ ក្រោយការចេញសន្លឹកឆ្នោតលើកទីពីរ ឬសន្លឹកឆ្នោតជំនួសថ្មីដល់អ្នកបោះឆ្នោត សន្លឹកឆ្នោតទីមួយដែលបានចេញត្រូវបានបដិសេធនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោត (EIMS) ដើម្បីការពារការបោះឆ្នោតទ្វេដង ។<br>*(ក្រមបោះឆ្នោត California §4005)* |
| លិបិក្រមបញ្ជីឈ្មោះ | បញ្ជីផ្លូវការនៃអ្នកបោះឆ្នោតដែលមានសិទ្ធិសម្រាប់ការបោះឆ្នោត ដែលអាចមានទម្រង់ជាក្រដាស ឬអេឡិចត្រូនិក ។ បញ្ជីឈ្មោះក្លាយជាលិបិក្រមផ្លូវការនៃអ្នកបោះឆ្នោត ដែលបានបោះឆ្នោតនៅក្នុងការបោះឆ្នោតដែលម្តងនោះត្រូវបានចុះហត្ថលេខាដោយអ្នកបោះឆ្នោត ឬគូសដោយមន្ត្រីរៀបចំការបោះឆ្នោត ។ *នេះមិនដូចគ្នាទៅនឹង* លិបិក្រមបញ្ជីឈ្មោះអ្នកបោះឆ្នោតទេ ។<br>*(ក្រមបោះឆ្នោត California §14109)* |
| សន្លឹកឆ្នោតគំរូ | មាននៅខាងក្នុង សេចក្តីណែនាំព័ត៌មានស្តីពីការបោះឆ្នោតខោនធី (CVIG) ត្រូវបានរៀបចំសម្រាប់ការបោះឆ្នោតនីមួយៗ ។ តម្រូវឲ្យដាក់បញ្ចូលស្ថិតក្រោមច្បាប់រដ្ឋ សន្លឹកឆ្នោតគំរូធ្វើតាមទូរសារជ៍សំខាន់នៃសន្លឹកឆ្នោតផ្លូវការ ប៉ុន្តែសន្លឹកឆ្នោតគំរូមិនមានទំហំដូចគ្នា ឬមិនត្រូវបានព្រីននៅលើក្រដាសដូចគ្នាទៅនឹងសន្លឹកឆ្នោតផ្លូវការទេ ហើយមានកន្លែងទំនេរច្រើនដែលទាំងនេះធ្វើឲ្យវាមិនអាចអានបានដោយម៉ាស៊ីនបោះឆ្នោតឡើយ ។ ច្បាប់បកប្រែមាននៅក្នុងខោនធី Santa Clara ជាភាសាដូចខាងក្រោម៖ ជាភាសាអេស្ប៉ាញ ចិន តាកាឡុក និងវៀតណាម ។<br>*(ក្រមបោះឆ្នោត California §13303)* |
| ធុងសន្លឹកឆ្នោតមានសុវត្ថិភាព / ឧបករណ៍បញ្ជូន | ធុងដែលអាចចាក់សោរបាននិងមានសុវត្ថិភាព ដែលត្រូវបានដាក់ខាងក្នុងហិបឆ្នោត ឬជាធុងដែលមានតែមួយ ។ ប្រសិនបើធុងសន្លឹកឆ្នោតត្រូវបានប្រើប្រាស់ខាងក្នុងហិបឆ្នោត សន្លឹកឆ្នោតត្រូវបានដាក់ចូលដោយផ្ទាល់ទៅក្នុងធុងនោះ ។ ធុងផ្ទុកសន្លឹកឆ្នោតដែលមានសុវត្ថិភាពមិនតម្រូវឲ្យមានគ្រប់ហិបទម្លាក់សន្លឹកឆ្នោតនោះទេ ។ |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
| --- | --- |
| លទ្ធផលផ្លូវការពាក់កណ្តាលផ្តាច់ព្រាត់ | ដំណើរការជាសាធារណៈនៃការប្រមូល ការដំណើរការ និងការរាប់សម្លេងឆ្នោត និងសម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋ ឬទូទាំងរដ្ឋ ការរាយការណ៍លទ្ធផលជូនដល់រដ្ឋលេខាធិការនៅយប់បោះឆ្នោត ។ ការធ្វើសាវនកម្មនិងផ្តល់សុពលភាពលើលទ្ធផលនៃការបោះឆ្នោត ជាផ្លូវការពាក់កណ្តាលផ្តាច់ព្រាត់ អាចរួមបញ្ចូលខ្លះ ឬទាំងអស់នៃ សន្លឹកឆ្នោតបោះតាមសំបុត្រ និង សន្លឹកឆ្នោតបណ្តោះអាសន្ន ទាំងអស់ ។ |
| ហិបទម្លាក់សន្លឹកឆ្នោតដែលមានបុគ្គលិកប្រចាំការ | ហិបទម្លាក់សន្លឹកឆ្នោត ឬធុងផ្ទុកសន្លឹកឆ្នោតមានសុវត្ថិភាពដែលដាក់នៅតាមទីតាំងដែលស្ថិតក្រោមក្រសែភ្នែកបុគ្គលម្នាក់ដែលត្រូវបានជួលនៅតាមទីតាំងនៃហិបទម្លាក់សន្លឹកឆ្នោត ជាបុគ្គលិកក្រុង ឬខោនធី ឬបុគ្គលិកបម្រើការបណ្តោះអាសន្ន ឬជាអ្នកស្ម័គ្រចិត្តដែលទទួលបានការបណ្តុះបណ្តាលសម្រាប់គោលបំណងនៃការត្រួតពិនិត្យហិបទម្លាក់សន្លឹកឆ្នោត ។ ហិបទម្លាក់សន្លឹកឆ្នោតដែលមានបុគ្គលិកប្រចាំការជាទូទៅមិនមានពេញ 24 ម៉ោងក្នុងមួយថ្ងៃទេ ។ |
| ហិបទម្លាក់សន្លឹកឆ្នោតដែលគ្មានបុគ្គលិកប្រចាំការ | ហិបទម្លាក់សន្លឹកឆ្នោតដែលត្រូវបានរក្សាសុវត្ថិភាព ដែលមិនស្ថិតក្រោមក្រសែភ្នែករបស់បុគ្គលណាម្នាក់ដើម្បីត្រួតពិនិត្យឡើយ ។ |
| បោះឆ្នោតតាមសំបុត្រ (VBM) | ផ្តល់ឱកាសដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធី Santa Clara ទាំងអស់ ដើម្បីប្រើប្រាស់សន្លឹកឆ្នោតតាមសំបុត្រនៅមុនពេលចាប់ផ្តើមជំនួសឲ្យការធ្វើដំណើរទៅកាន់ការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ នៅពេលសន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានទទួលដោយ ROV នោះ ហត្ថលេខានៅលើស្រោមសំបុត្រត្រូវបានប្រៀបធៀបទៅនឹងហត្ថលេខានៅលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតដើម្បីឲ្យប្រាកដថាវាត្រូវគ្នា ។ សន្លឹកឆ្នោតបន្ទាប់មកនឹងត្រូវញែកចេញពីស្រោមសំបុត្រ ហើយបន្ទាប់មកទៀតវានឹងត្រូវរាប់ ។<br>*(ក្រមបោះឆ្នោត California §4005)* |
| មណ្ឌលបោះឆ្នោត | ទីតាំងដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំការបោះឆ្នោត ដែលផ្តល់សេវាដល់អ្នកបោះឆ្នោតមកបោះឆ្នោត ទម្លាក់សន្លឹកឆ្នោតបោះតាមសំបុត្ររបស់គេ ចុះឈ្មោះបោះឆ្នោត ឬទទួលនិងបោះឆ្នោតបណ្តោះអាសន្ន ជំនួសថ្មីឬ អាចទទួលបានសន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតមានទំហំធំជាងការិយាល័យបោះឆ្នោតពីដើម នឹងមានឧបករណ៍បោះឆ្នោតច្រើនជាង និងមានមន្ត្រីរៀបចំការបោះឆ្នោតច្រើនជាង ជួយដល់អ្នកបោះឆ្នោត ហើយត្រូវអនុវត្តន៍ទៅតាមបទបញ្ញាដូចគ្នាទៅនឹងបទបញ្ញទាំងឡាយដែលអនុវត្តន៍ចំពោះការិយាល័យបោះឆ្នោតដែរ ។ អ្នកបោះឆ្នោតក្នុងខោនធីអាចមកកាន់មណ្ឌលបោះឆ្នោតណាមួយដើម្បីបោះឆ្នោតក៏បាន ។<br>*(ក្រមបោះឆ្នោត California §§2170, 4005, & 4007)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| មណ្ឌលបោះឆ្នោតគំរូ | *គំរូអនាគតនៃការអនុវត្តការបោះឆ្នោតដែល ROV កំពុងធ្វើការផ្លាស់ប្តូរ ។*<br>ពាក្យត្រូវបានប្រើសំដៅទៅដល់ប្រព័ន្ធរដ្ឋបាលនៃការរៀបចំការបោះឆ្នោតត្រូវបានធ្វើឡើងក្រោម ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត ។ ដោយភាពទូលំទូលាយ ការរួមបញ្ចូលនៃការបោះឆ្នោតតាមសំបុត្រទាំងអស់ ដោយប្រើប្រាស់តំបន់មណ្ឌលបោះឆ្នោតធំជាមុន ។<br>*(ក្រមបោះឆ្នោត California §14428)* |
| VoteCal | *ពីមុនត្រូវបានគេស្គាល់ថា VoteCal ។*<br>ត្រូវបានបង្គាប់ដោយច្បាប់ជួយអាមេរិកក្នុងការបោះឆ្នោត (HAVA) VoteCal គឺជាមូលដ្ឋានទិន្នន័យប្រមូលផ្តុំការចុះឈ្មោះបោះឆ្នោតទូទាំងរដ្ឋត្រូវបានបង្កើតឡើងនិងគ្រប់គ្រងដោយរដ្ឋលេខាធិការ ។ ខោនធីនីមួយៗនៅក្នុងរដ្ឋត្រូវបានភ្ជាប់ដោយប្រព័ន្ធ ហើយអាចប្រើវាដើម្បីពិនិត្យរកមើលការចុះឈ្មោះស្ទួនគ្នា ឬការធ្វើបច្ចុប្បន្នភាពទាំងឡាយណាដែលនឹងច្រានចោលជាមុននូវអ្នកបោះឆ្នោតចេញពីការបោះឆ្នោត ។ VoteCal មានទំនាក់ទំនងនិងផ្លាស់ប្តូរព័ត៌មានជាមួយនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោតរបស់ខោនធី (EIMS) និងប្រព័ន្ធទាំងឡាយផ្សេងទៀតរបស់រដ្ឋដូចជា ក្រសួងអប់រំកែប្រែនិងស្តារនិតិសម្បទារ ក្រសួងសុខភាពសាធារណៈ និងក្រសួងយានយន្ត ។<br>*(ច្បាប់ជួយអាមេរិកក្នុងការបោះឆ្នោត ឆ្នាំ 2002)* |
| ទម្រង់ស្នើសុំសកម្មភាពរបស់អ្នកបោះឆ្នោត (VARF) | ជាទម្រង់សម្រាប់ "អ្នកបោះឆ្នោតក្នុងខោនធី Santa Clara "ដែលបានចុះឈ្មោះ"ដើម្បីៈ<br>1. ប្តូរអាសយដ្ឋានទីលំនៅ ឬអាសយដ្ឋានផ្ញើសំបុត្រ (ប្រសិនបើប្តូរនៅក្នុងខោនធី Santa Clara)<br>2. ប្តូរភាសារបស់អ្នកតាមការពេញចិត្ត (អង់គ្លេស ចិន អេស្ប៉ាញ តាកាឡុក វៀតណាម ហិណ្ឌី ជប៉ុន ខ្មែរ និងកូរ៉េ)<br>3. ប្តូរស្ថានភាពជាអ្នកបោះឆ្នោតតាមសំបុត្រ អចិន្ត្រៃយ៍<br>4. កែកំហុសអក្ខរាវិរុទ្ធ ឬកំហុសផ្សេងៗនៅក្នុងព័ត៌មានចុះឈ្មោះ<br>5. បដិសេធការចុះឈ្មោះអ្នកបោះឆ្នោត<br>6. បដិសេធការចុះឈ្មោះអ្នកបោះឆ្នោតនៃសមាជិកដែលបានទទួលមរណៈភាពនៅក្នុងគ្រួសារ ឬនៅក្នុងផ្ទះទាំងមូល ។<br>*(ក្រមបោះឆ្នោត California §§2150 - 2168)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| គណៈកម្មាធិការអប់រំនិងផ្សព្វផ្សាយអ្នកបោះឆ្នោត (VEOC) | ផ្តល់ឱវាទនិងផ្តល់អនុសាសន៍ដល់មន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត (ROV) នៅលើបញ្ហាពាក់ព័ន្ធនឹងការជម្រុញឱកាសអប់រំនៅក្នុងខោនធី និងធ្វើការបង្កើននូវការចូលរួមរបស់អ្នកបោះឆ្នោតតាមរយៈការផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទង ។ គណៈកម្មាធិការនឹងត្រូវមានសមាសភាពរបស់បុគ្គលនិងតំណាងទាំងឡាយនៃអង្គការសហគមន៍ ដែលនឹងបង្ហាញនូវបទពិសោធក្នុងកម្មវិធីអប់រំនិងផ្សព្វផ្សាយ ឬជាមន្ត្រីរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការនឹងបម្រើក្នុងសមត្ថភាពជាអ្នកផ្តល់ប្រឹក្សាទៅដល់ ROV ។ |
| គម្រោងអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត | តម្រូវឲ្យដាក់បញ្ចូលនូវ គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោតរបស់ខោនធី (EAP) និងត្រូវតែអនុម័តិដោយរដ្ឋលេខាធិការ ។ គម្រោងនេះរៀបរាប់ពីរបៀបដែលមន្ត្រីរៀបចំការបោះឆ្នោតនឹងឆ្លើយតបទៅនឹងបញ្ញត្តិនានានៃ ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) ទាក់ទងនឹងការអប់រំ និងការផ្សព្វផ្សាយ ដោយរាប់បញ្ចូលទាំងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធផ្សព្វផ្សាយសង្គម កិច្ចប្រជុំស្តីពីការអប់រំជាសាធារណៈ និងការទំនាក់ទំនងជាមួយអ្នកបោះឆ្នោតដោយផ្ទាល់ ដើម្បីផ្តល់ព័ត៌មានដល់ពួកគេពីរបៀបបោះឆ្នោតថ្មី និងពីឯកសារផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ និងជំនួយតាមទូរសព្ទដែលមានផ្តល់ជូន ។ |
| សិក្ខាសាលាអប់រំអ្នកបោះឆ្នោត | មន្ត្រីរៀបចំការបោះឆ្នោតខោនធីត្រូវតែរៀបចំយ៉ាងហោចណាស់សិក្ខាសាលាផ្តោតលើការអប់រំអ្នកបោះឆ្នោតចំនួនពីរដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីរបៀបរៀបចំគ្រប់គ្រងការបោះឆ្នោតថ្មី ។ សិក្ខាសាលាកំណត់គោលដៅជាក់លាក់ត្រូវរាប់បញ្ចូលនៃសិក្ខាសាលាអប់រំអ្នកបោះឆ្នោតពីរភាសា (យ៉ាងហោចណាស់មួយសម្រាប់ភាសានីមួយៗតម្រូវដោយខោនធី) ហើយមានការចូលរួមពីជនមានពិការភាពដែលមានសិទ្ធិបោះឆ្នោត ។ |
| ការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត | ការបញ្ជូនព័ត៌មានយ៉ាងសកម្មដោយផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិក អំពីដំណើរការបោះឆ្នោត ។ |
| ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត | *សូមមើល លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ*<br>*(ក្រមបោះឆ្នោត California §2188)* |
| ប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោត | *សូមមើល លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ*<br>*(ក្រមបោះឆ្នោត California §2158)* |
| ទម្រង់ចុះឈ្មោះបោះឆ្នោត | *សូមមើល លិខិតថ្លែងសច្ចាអំពីការចុះឈ្មោះ*<br>*(ក្រមបោះឆ្នោត California §2162)* |

# សេចក្តីបន្ថែម A – សទ្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| សូមមើល ប័ណ្ណបញ្ជាក់ទីលំនៅរបស់អ្នកបោះឆ្នោត | ប័ណ្ណបញ្ជាក់ទីលំនៅរបស់អ្នកបោះឆ្នោត (ប័ណ្ណ 8D2) ត្រូវបានផ្ញើតាមសំបុត្របញ្ជូនបន្តលឿនបំផុតដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ទៅលើអាសយដ្ឋានរបស់អ្នកបោះឆ្នោត ។ ប័ណ្ណនេះត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងសំណុំឯកសារចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជាក់និងកែតម្រូវអាសយដ្ឋានរបស់អ្នកបោះឆ្នោត ដែលអាចត្រូវបានផ្លាស់ប្តូរទីលំនៅ ។<br>*(ការបោះឆ្នោត California §§2191, 2220, & 2240 - 2231)* |
| ប្រព័ន្ធផ្ទៀងផ្ទាត់អ្នកបោះឆ្នោត | ប្រព័ន្ធអេឡិចត្រូនិកសម្រាប់មន្ត្រីរៀបចំការបោះឆ្នោតខោនធីដើម្បីចូលទៅកាន់ទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោតភ្លាមៗនៅតាមមណ្ឌលបោះឆ្នោត ។<br>*សូមមើល បញ្ជីអ្នកបោះឆ្នោតអេឡិចត្រូនិក ។*<br>*(ក្រមបោះឆ្នោត California §359.2)* |
| ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) | ច្បាប់ California ថ្មី(SB450) ត្រូវបានអនុម័តិកាលពីឆ្នាំ 2016ស្នើឡើងដោយមាជិកព្រឹទ្ធសភា Ben Allen ដែលនឹងធ្វើទំនើបកម្មការបោះឆ្នោតនៅក្នុងរដ្ឋ California ដោយអនុញ្ញាតឲ្យខោនធីទាំងឡាយរៀបចំការបោះឆ្នោតស្ថិតក្រោមគំរូថ្មីដែលផ្តល់នូវភាពបទបែននិងភាពងាយស្រួលច្រើនជាងមុនខ្លាំងសម្រាប់អ្នកបោះឆ្នោត ។<br>គំរូការបោះឆ្នោតថ្មីនេះអនុញ្ញាតឲ្យអ្នកបោះឆ្នោតអាចជ្រើសរើសបាននូវរបៀបបោះឆ្នោត ពេលវេលាបោះឆ្នោត និងកន្លែងបោះឆ្នោត ដែលគេចង់បោះដោយ៖<br>1. ផ្ញើសន្លឹកឆ្នោតទៅកាន់គ្រប់អ្នកបោះឆ្នោតទាំងអស់<br>2. ពង្រីករយៈពេលបោះឆ្នោតមុនកាលកំណត់ដោយផ្ទាល់<br>3. អនុញ្ញាតឲ្យអ្នកបោះឆ្នោតបោះបាននៅតាមមណ្ឌលណាមួយក៏បាននៅក្នុងខោនធី<br>ច្បាប់នេះមានបំណងចង់បង្កើនការចូលរួមរបស់អ្នកបោះឆ្នោតដោយអនុញ្ញាតឲ្យខោនធីរៀបចំការបោះឆ្នោតតាមសំបុត្របានស្ថិតក្រោមកាលៈទេសៈជាក់លាក់នានា ។<br>*(ក្រមបោះឆ្នោត California §§3017, 15320, & 4005 - 4008)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| គណៈកម្មាធិការផ្តល់ឱវាទដើម្បីទទួលបានការបោះឆ្នោត (VAAC) | គណៈកម្មាធិការផ្តល់ឱវាទដើម្បីទទួលបានការបោះឆ្នោត (VAAC) ត្រូវបានបង្កើតឡើងដើម្បីផ្តល់ឱវាទដល់ មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) ទៅលើបញ្ហានានាពាក់ព័ន្ធនឹងការធ្វើឲ្យប្រសើរឡើងនូវការទទួលបានការបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព ហើយនឹងត្រូវផ្តល់អនុសាសន៍ដើម្បីបង្កើតមណ្ឌលបោះឆ្នោត និងដើម្បីធ្វើឲ្យប្រសើរឡើងនូវសេវាដល់អ្នកបោះឆ្នោត និងការចេញចូលសម្រាប់បុគ្គលទាំងឡាយដែលមានពិការភាព រាប់បញ្ចូលដោយមិនកំណត់មានអ្នកបោះឆ្នោតដែលមានបញ្ហាកម្សោយការមើល និងអ្នកបោះឆ្នោតដែលថ្លង់ ឬពិបាកស្តាប់ ។ គណៈកម្មាធិការនឹងត្រូវមានសមាសភាពជាអ្នកបោះឆ្នោតដែលមានពិការភាព ដែលបានបង្ហាញនូវបទពិសោធជាមួយនឹងលក្ខខណ្ឌតម្រូវលើលទ្ធភាពដែលអាចចេញចូលបានសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព ឬជាមន្ត្រីរៀបចំការបោះឆ្នោតក្រុង ។ គណៈកម្មាធិការនឹងបម្រើក្នុងសមត្ថភាពជាអ្នកផ្តល់ប្រឹក្សា ។ |
| ឧបករណ៍បោះឆ្នោត | ឧបករណ៍ទាំងឡាយណាដែលត្រូវបានប្រើប្រាស់រួមជាមួយនឹងប័ណ្ណសន្លឹកឆ្នោត ឬប័ណ្ណដើម្បីបង្ហាញពីជម្រើសរបស់អ្នកបោះឆ្នោតដោយការគូស ចាក់ទម្លុះ ឬ ការស៊ើកសន្លឹកឆ្នោត ។<br>*(ក្រមបោះឆ្នោត California ផ្នែក 19)* |
| ម៉ាស៊ីនបោះឆ្នោត | ឧបករណ៍អេឡិចត្រូនិកទាំងឡាយរួមមានដោយមិនកំណត់ ម៉ាស៊ីនស្កេនអុបទិក តាមមណ្ឌល ប្រព័ន្ធកត់ត្រាការបោះឆ្នោតជាអេឡិចត្រូនិកដោយផ្ទាល់ (DRE) ដែលអ្នកបោះឆ្នោតអាចបញ្ចូលសម្លេងឆ្នោតរបស់គេ និងជាមធ្យោបាយការបញ្ចូលក្នុងតារាងបញ្ជីអេឡិចត្រូនិក និងការបញ្ចេញនូវការព្រីនចេញជាក្រដាស ឬអ្វីៗដែលមានរូបរាងអាចប៉ះបានផ្សេងទៀតកំណត់ត្រាដែលមនុស្សអាចអានបាន ផ្តល់នូវចំនួនសរុបនៃសម្លេងឆ្នោតសម្រាប់បេក្ខជននីមួយៗនិងសម្រាប់សម្លេងគាំទ្រឬប្រឆាំងចំពោះវិធានការនីមួយៗ ។<br>*(ក្រមបោះឆ្នោត California ផ្នែក 19)* |
| ប្រព័ន្ធបោះឆ្នោត | ប្រព័ន្ធមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិច និងកម្មវិធីរបស់វា ឬការរួមបញ្ចូលណាមួយនៃសមាធាតុទាំងនេះត្រូវបានប្រើប្រាស់សម្រាប់បោះឆ្នោត បូកសរុបសម្លេងឆ្នោត ឬសម្រាប់ទាំងពីរតែម្តង ។ "ប្រព័ន្ធបោះឆ្នោត" មិនរាប់បញ្ចូលនូវ ប្រព័ន្ធបោះឆ្នោតតាមសំបុត្រពីចំងាយ ឡើយ ។<br>*(ក្រមបោះឆ្នោត California ផ្នែក 19)* |

# សេចក្តីបន្ថែម A – សន្ទានុក្រមនៃពាក្យបច្ចេកទេសនិងពាក្យកាត់នានា

| ពាក្យបច្ចេកទេស/ពាក្យកាត់ | អត្ថន័យ |
|---|---|
| ក្រដាសសវនកម្មសាកល្បងផ្ទៀងផ្ទាត់អ្នកបោះឆ្នោត (VVPAT) | ម៉ាស៊ីនបោះឆ្នោតកត់ត្រាអេឡិចត្រូនិកដោយផ្ទាល់ទាំងអស់ (DRE) ដែលត្រូវបានប្រើក្រោយថ្ងៃទី1 ខែមករា ឆ្នាំ 2006 ត្រូវតែអាចទទួលបានក្រដាសសវនកម្មសាកល្បងផ្ទៀងផ្ទាត់អ្នកបោះឆ្នោត ។ អ្នកបោះឆ្នោតទាំងអស់ដែលបោះឆ្នោតតាមម៉ាស៊ីនបោះឆ្នោតអេឡិចត្រូនិកគប្បីពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់ជម្រើសនៅលើសន្លឹកឆ្នោតរបស់គេនៅលើក្រដាសកំណត់ត្រាដែលបានព្រីនចេញនេះ មុនពេលសម្រេចចិត្តលើសន្លឹកឆ្នោតចុងក្រោយនិងត្រូវបោះរបស់គេ ។ នៅពេលសន្លឹកឆ្នោតត្រូវបានបោះរួច ក្រដាសកំណត់ត្រានៃសន្លឹកឆ្នោតនេះត្រូវបានរក្សាទុកនៅក្នុងម៉ាស៊ីនបោះឆ្នោតជាផ្នែកមួយនៃការធ្វើសវនកម្មសាកល្បងលើការបោះឆ្នោតដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃសម្លេងឆ្នោតដែលត្រូវបានកត់ត្រា ។ ស្របទៅតាមក្រមបោះឆ្នោត California អ្នកបោះឆ្នោតមិនទទួលបានក្រដាសកំណត់ត្រានៃជម្រើសសម្លេងឆ្នោតរបស់គេដែលត្រូវបានព្រីនចេញនោះទេ ។<br>*(ក្រមបោះឆ្នោត California § 19250)* |

## ឧបសម្ព័ន្ធ B – ពាក្យសុំបោះឆ្នោតមុនកាលកំណត់

# ពាក្យសុំបោះឆ្នោតមុនកាលកំណត់

ឈ្មោះ ៖ ______________________________________________ ថ្ងៃខែឆ្នាំកំណើត ៖ ____________________

អាសយដ្ឋាន ៖ ______________________________________________________________________________

ទីក្រុង ៖ ________________________________________ រដ្ឋ ៖ ____________ ហ្ស៊ីបកូដ ៖ ________________

*សូមគូសធីកនូវប្រការខាងក្រោមទាំងអស់ដែលត្រឹមត្រូវ ហើយចុះហត្ថលេខា៖*

## សំណើសន្លឹកឆ្នោតជំនួស

_____ ខ្ញុំសូមអះអាងក្រោមការពិន័យពីការបំពានសម្បថថា ខ្ញុំបានបាត់បង់ បង្ខូច ខូច ឬមិនបានទទួលសន្លឹកឆ្នោតបោះតាមសំបុត្រដើមរបស់ខ្ញុំ ហើយខ្ញុំនឹងមិនបោះឆ្នោតទេ ក្នុងករណីដែលវាត្រូវបានទទួល ឬបានរកឃើញ ។

## សំណើសន្លឹកឆ្នោតឆ្លង

___ ខ្ញុំបានបដិសេធមិនបង្ហាញពីចំណង់ចំណូលចិត្តសម្រាប់គណបក្សនយោបាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ យ៉ាងណាក្តី សម្រាប់ការបោះឆ្នោតបឋមនេះ ខ្ញុំស្នើសុំការបោះឆ្នោតដោយផ្ញើសំបុត្រសម្រាប់គណបក្ស ________ ។

## ការចែកចាយសន្លឹកឆ្នោតបន្ទាន់ - *ត្រូវការបន្ទាប់ពីរយៈពេលថ្ងៃទីប្រាំពីរមុនពេលបោះឆ្នោតប្រសិនបើស្នើសុំតាមសំបុត្រ ។*

_____ ខ្ញុំនឹងមិនអាចទៅមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេដោយសារមានលក្ខខណ្ឌដូចខាងក្រោម ៖

- ជំងឺ ឬពិការភាពដែលបណ្តាលមកពីការចូលសម្រាកនៅមន្ទីរពេទ្យសាស្ត្រ ឃុំ មន្ទីរព្យាបាលពិសេស មន្ទីរថែទាំមនុស្សចាស់ជរា ឬកន្លែងស្នាក់នៅ
- ពិការភាពរាងកាយ និង/ឬ ឧបសគ្គខាងស្ថាបត្យកម្មដែលមានស្រាប់នៅឯមជ្ឈមណ្ឌលបោះឆ្នោតដែលបដិសេធមិនអាចឲ្យរាងកាយចូលទៅកាន់មណ្ឌលបោះឆ្នោត បន្ទប់បោះឆ្នោត ឬឧបករណ៍បោះឆ្នោតដោយសារតែពិការភាពរាងកាយ
- លក្ខខណ្ឌដែលបណ្តាលមកពីអវត្តមានពីមជ្ឈមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោត

ខ្ញុំសូមប្រកាសក្រោមការពិន័យពីការបំពានសម្បថថា អ្វីៗដែលបានរៀបរាប់ខាងលើ គឺជាការពិតនិងត្រឹមត្រូវ ព្រមទាំងអនុញ្ញាតឱ្យអ្នកកាន់សន្លឹកឆ្នោតដើម្បីទទួលបានសន្លឹកឆ្នោតរបស់ខ្ញុំ ។ ខ្ញុំយល់ថា សន្លឹកឆ្នោតនេះត្រូវ

## ឧបសម្ព័ន្ធ B – ពាក្យសុំបោះឆ្នោតមុនកាលកំណត់

តែប្រគល់ទៅការិយាល័យចុះបញ្ជីបោះឆ្នោតវិញ នៅត្រឹមម៉ោង 8 យប់នៅថ្ងៃបោះឆ្នោត ឬត្រូវបានវាយត្រាប្រៃសណីយ៍ជាមួយកាលបរិច្ឆេទនៃការបោះឆ្នោត ហើយបានទទួលមិនលើសពីបីថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

ហត្ថលេខា ៖ ________________________________________ កាលបរិច្ឆេទ ៖ ________________________

**ការចែកចាយសន្លឹកឆ្នោតដែលបានអនុញ្ញាត -** *បញ្ចប់ប្រសិនបើមាននរណាម្នាក់កំពុងរើសសន្លឹកឆ្នោតរបស់មនុស្សម្នាក់ផ្សេងទៀត។*

ខ្ញុំសូមបញ្ជាក់អះអាងនៅក្រោមការពិន័យពីការបំពានសម្បថថា ខ្ញុំមានអាយុយ៉ាងតិច 18 ឆ្នាំ ហើយខ្ញុំគឺជាអ្នកតំណាងដែលមានការអនុញ្ញាតពីអ្នកបោះឆ្នោតដែលខ្ញុំកំពុងបង្ហាញតាមសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនេះ ។

ឈ្មោះជាអក្សរពុម្ព ៖ ______________________________________________________________________

ហត្ថលេខា ៖ ________________________________________ កាលបរិច្ឆេទ ៖ ________________________

# ឧបសម្ព័ន្ធ - ព្រំប្រទល់ទីតាំងប្រអប់ដាក់សន្លឹកឆ្នោត 15k ដលែបានសេនី ឡើង



# ឧបសម្ព័ន្ធ D - ទីតាំងប្រអប់ដាក់សន្លឹកឆ្នោតដែលបានស្នើឡើង

*បញ្ជីឈ្មោះនេះគឺអាចមានការផ្លាស់ប្តូរ។  សម្រាប់ការផ្លាស់ប្តូរ នឹងមានអាទិភាពផ្តល់ជូនចំពោះទីតាំងដែលដូចគ្នា ឬនៅជិតឈ្មោះដែល ចុះបញ្ជី ។

| លេខកូដតំបន់ប្រអប់ដាក់សន្លឹកឆ្នោត | ឈ្មោះទីតាំង | អាសយដ្ឋាន | ម៉ោង |
|---|---|---|---|
| D01 | Palo Alto City Hall – City Clerk Office | 250 Hamilton Ave, Palo Alto, CA 94301 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D01 | Rinconada Library | 1213 Newell Rd, Palo Alto, CA 94303 | 24/7 |
| D02 | Mitchell Park Library | 3700 Middlefield Road, Palo Alto, CA 94303 | 24/7 |
| D04 | Foothill College - Admin. Bldg. 1900 by Flag Pole | 12345 El Monte Rd, Los Altos Hills, CA 94022 | 24/7 |
| D04 | Los Altos Hills Town Hall – City Clerk's Office | 26379 Fremont Rd, Los Altos Hills, CA 94022 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D05 | VTA North Division Coach Terminal | La Avenida and North Yard | 24/7 |
| D07 | Mountain View City Hall – City Clerk's Office | 500 Castro St, Mountain View, CA 94039 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D07 | Mountain View Public Library | 585 Franklin St, Mountain View, CA 94041 | 24/7 |
| D08 | Los Altos City Hall – City Clerk Office | 1 N San Antonio Rd, Los Altos, CA 94022 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D08 | Los Altos Library | 13 S San Antonio Rd, Los Altos, CA 94022 | 24/7 |
| D09 | Woodland Branch Library | 1975 Grant Rd, Los Altos, CA 94024 | 24/7 |
| D10 | Grocery Outlet Bargain Market | 1180 N Fair Oaks Ave, Sunnyvale, CA 94089 | 24/7 |
| D12 | Sunnyvale City Hall – City Finance Office | 650 W Olive Ave, Sunnyvale, CA 94086 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D12 | Sunnyvale Library | 456 W Olive Ave, Sunnyvale, CA 94086 | 24/7 |
| D13 | Fremont Union High School District | 589 W Fremont Ave, Sunnyvale, CA 94087-2556 | 24/7 |
| D17 | De Anza College - Main Quad by Flag Pole | 21250 Stevens Creek Blvd, Cupertino, CA 95014 | 24/7 |
| D18 | Cupertino City Hall – City Clerk Office | 10300 Torre Ave, Cupertino, CA 95014 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D18 | Cupertino Library | 10800 Torre Ave, Cupertino, CA 95014 | 24/7 |
| D19 | 21000 Seven Springs Pkwy, Cupertino, CA 95014 | Westmont Ave, Campbell, CA 95008 | ចុះកាលបរិច្ឆេទ |
| D20 | Saratoga City Hall – City Clerk Office | 13777 Fruitvale Ave, Saratoga, CA 95070 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D20 | Saratoga Library | 13650 Saratoga Ave, Saratoga, CA 95070 | 24/7 |
| D20 | West Valley College - Fox Center | 14000 Fruitvale Ave, Saratoga, CA 95070 | 24/7 |
| D21 | Mission College - Student Drop-off | 3000 Mission College Blvd, Santa Clara, CA 95054 | 24/7 |
| D23 | Santa Clara City Hall – City Clerk Office | 1500 Warburton Ave, Santa Clara, CA 95050 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D23 | Santa Clara County Traffic Court | 1095 Homestead Rd, Santa Clara, CA 95050 | 24/7 |
| D24 | Central Park Library | 2635 Homestead Rd, Santa Clara, CA 95051 | 24/7 |
| D25 | Dwight D Einsenhower Elementary School | 277 Rodonovan Dr, Santa Clara, CA 95051 | 24/7 |

| | | | |
|---|---|---|---|
| D27 | Campbell City Hall – City Clerk Office | 70 N First St, Campbell, CA 95008 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D27 | Campbell Library | 77 Harrison Ave, Campbell, CA 95008 | 24/7 |
| D28 | Monte Sereno City Hall – City Clerk Office | 18041 Saratoga/Los Gatos Rd, Monte Sereno, CA 95030 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D29 | Los Gatos Library | 100 Villa Ave, Los Gatos, CA 95030 | 24/7 |
| D29 | Los Gatos Town Hall – City Clerk Office | 110 E Main St, Los Gatos, CA 95030 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D30 | Milpitas City Hall – City Clerk Office - 1st Floor | 455 E Calaveras Blvd, Milpitas, CA 95035 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D31 | Milpitas Unified School District | 1331 E Calaveras Blvd, Milpitas, CA 95035 | 24/7 |
| D32 | Milpitas Library | 160 N Main St, Milpitas, CA 95035 | 24/7 |
| D33 | Alviso Branch Library | 5050 N Main St, San Jose, CA 95002 | 24/7 |
| D34 | Orchard School District | 921 Fox Ln, San Jose, CA 95131 | 24/7 |
| D36 | Hostetter Park and Ride | N Capitol Ave @ Camino Del Rey | 24/7 |
| D37 | Berryessa Library | 3355 Noble Ave, San Jose, CA 95132 | 24/7 |
| D38 | Rose Garden Library | 1580 Naglee Ave, San Jose, CA 95126 | 8:00 ព្រឹក-8:00 យប់, ចន្ទ-សុក្រ |
| D39 | Santa Clara County Superior Court | 191 N First St, San Jose, CA 95113 | 24/7 |
| D40 | Santa Clara County – 1st Floor | 70 W Hedding St, San Jose, CA 95110 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D41 | Educational Park Branch Library | 1772 Educational Park Dr, San Jose, CA 95133 | 24/7 |
| D42 | Alum Rock Union School District | 2930 Gay Ave, San Jose, CA 95127 | 24/7 |
| D43 | Martin Luther King Library (Indoor Drop-box) | 150 E San Fernando St, San Jose, CA 95112 | 8:00 ព្រឹក-8:00 យប់, ចន្ទ-ព្រហស្បតិ៍<br>8:00 ព្រឹក-6:00 ល្ងាច, សុក្រ<br>9:00 យប់-6:00 ល្ងាច, សៅរ៍<br>1:00 រសៀល-5:00 ល្ងាច, អាទិត្យ |
| D43 | San Jose City Hall – City Clerk Office - T1 & 14th Floor | 200 E Santa Clara St, Wing 2, San Jose, CA 95113 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D43 | San Jose State University - Clark Hall Bldg. & The Villages | 1 Washington Sq, San Jose, CA 95112 | 24/7 |
| D44 | Lee Mathson Middle School | 2050 Kammerer Ave, San Jose, CA 95116 | 24/7 |
| D45 | Dr Roberto Cruz - Alum Rock Branch Library | 3090 Alum Rock Ave, San Jose, CA 95127 | 24/7 |
| D46 | Moreland School District | 4711 Campbell Ave, San Jose, CA 95130-1790 | 24/7 |
| D47 | West Valley Branch Library | 1243 San Tomas Aquino Rd, San Jose, CA 95117 | 24/7 |
| D48 | San Jose City College - Student Center | 2100 Moorpark Ave, San Jose, CA 95128 | 8:00 ព្រឹក-10:00 យប់, ចន្ទ-សុក្រ |
| D48 | Valley Medical Center - Valley Specialty Center | 751 S Bascom Ave, San Jose, CA 95128 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D49 | Willow Glen Branch Library | 1157 Minnesota Ave, San Jose, CA 95125 | 24/7 |

| | | | |
|---|---|---|---|
| D50 | Biblioteca Latinoamericana Branch | 921 S 1st St, San Jose, CA 95110 | 24/7 |
| D52 | Hillview Branch Library | 1600 Hopkins Dr, San Jose, CA 95122 | 24/7 |
| D53 | Mount Pleasant School District | 3434 Marten Ave, San Jose CA 95148 | 24/7 |
| D54 | Campbell Union High School District | 3235 Union Ave, San Jose, CA 95124-2096 | 24/7 |
| D57 | Captain Jason M. Dahl Elementary School | 3200 Water St, San Jose, CA 95111 | 24/7 |
| D58 | Tully Community Library | 880 Tully Rd, San Jose, CA 95111 | 24/7 |
| D61 | Evergreen Valley College - Cafeteria in Gullo 1 | 4750 San Felipe Rd, San Jose, CA 95135 | 24/7 |
| D62 | Cambrian School District | 4115 Jacksol Dr, San Jose, CA 95124 | 24/7 |
| D62 | Union Elementary School District | 5175 Union Ave, San Jose, CA 95124-5434 | 24/7 |
| D63 | Vineland Branch Library | 1450 Blossom Hill Rd, San Jose, CA 95118 | 24/7 |
| D64 | Pearl Avenue Library | 4270 Pearl Ave, San Jose, CA 95136 | 24/7 |
| D65 | Edenvale Branch Library | 101 E Branham Ln, San Jose, CA 95111 | 24/7 |
| D66 | Seven Trees Branch Library | 3590 Cas Dr, San Jose, CA 95111 | 24/7 |
| D67 | Village Square Branch Library | 4001 Evergreen Village Sq, San Jose, CA 95135 | 24/7 |
| D69 | Almaden Branch Library | 6445 Camden Ave, San Jose, CA 95120 | 24/7 |
| D70 | Blossom Hill Park and Ride | Blossom Hill Rd @ Canoas | 24/7 |
| D72 | Santa Teresa Park and Ride | Santa Teresa @ Miyuki Dr | 24/7 |
| D74 | Morgan Hill City Hall – City Clerk Office | 17575 Peak Ave, Morgan Hill, CA 95037 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D74 | Morgan Hill Library | 660 West Main Ave, Morgan Hill, CA 95037 | 24/7 |
| D75 | Nordstrom Elementary | 1505 E Main Ave, Morgan Hill, CA 95037 | 24/7 |
| D76 | Morgan Hill Unified School District | 15600 Concord Cir, Morgan Hill, CA 95037 | 24/7 |
| D77 | Rod Kelley Elementary School | 8755 Kern Ave, Gilroy, CA 95020 | 24/7 |
| D78 | Gilroy City Hall – City Clerk Office | 7351 Rosanna St, Gilroy, CA 95020 | 8:00 ព្រឹក-5:00 ល្ងាច, ចន្ទ-សុក្រ |
| D78 | Gilroy Library | 350 W Sixth St, Gilroy, CA 95020 | 24/7 |
| D79 | Gavilan College - Student Center | 5055 Santa Teresa Blvd, Gilroy, CA 95020 | 24/7 |

# ឧបសម្ព័ន្ធ - មណ្ឌលបោះឆ្នោត 50k & 10k ព្រំប្រទល់ដែលបានស្នើឡើង





ផនៃទីពុំរំបុំរទល់មណុឈហា ៈឆុនា ត
4 ថៃងដៃលៃហានសេនី ទ្បើង
Santa Clara ខមៃថុនា ឆុនាំ 2019
SANTA CLARA COUNTY REGISTRAR OF VOTERS 1850
N
សញ្ញាសម្គាល់
ពង្រា ងស្តី ពី ព្រំ ប្រ ទល់ មណ្ឌ លបោះឆ្នោ ត 10k
ការកំណត់របស់ទីក្រុង
Campbell
Cupertino
Gilroy
Los Altos
Los Altos Hills
Los Gatos
Milpitas
Monte Sereno
Morgan Hill
Mountain View
Palo Alto
San Jose
Santa Clara
Saratoga
Sunnyvale
ផ្លូវ
ហាយវេ
ផ្លូវ លេឿនលឿន
0
3
6
12 ម៉ាយស៍
សចេកុតីបុរកាសបដិសធេ ៖ ព័ត៌មានដលៃហានបុរីនៅ ក្នុងផនៃទីនេះគឺហានមកពីបុរភពផេសងេៗគុនា ។
ទា ៈបីជាយើងខិតខំផុស់ទិន្នន័យលុអំផុតតាមដលៃយើងអាចធេវី ហានក៏ដា យ ក៏យើងមិនអាចទទូលយកទំនួលខុសតុរូវចំពោ ៈកំហុស
ការលុបចា ល ឬភាពតុរឹមតុរូវនទៃីតាំងទៃ ដូចេនះេហើយគុមានការធានាណាមួយដលៃអមជាមួយផនៃទីនេះទេ ។
Sources: Esri, HERE, Garmin, Intermap, increment P Corp., GEBCO, USGS, FAO, NPS, NRCAN, GeoBase, IGN, Kadaster NL, Ordnance Survey, Esri Japan, METI, Esri China (Hong Kong), (c) OpenStreetMap contributors, and the GIS User Community
Redwood City
East Palo Alto
ALAMEDA
SANTA CLARA
BURNT HILLS
SAN MATEO
SANTA CRUZ MOUNTAINS
SIERRA AZUL
Morgan Hill
San Martin
Gilroy
Watsonville
Freedom
Scotts Valley
Capitola
Aptos
Twin Lakes
101
280
880
680
237
87
85
17
25
156

# ឧបសម្ព័ន្ធ F ទីតាំងដែលមានសក្តានុពលសម្រាប់ជាមណ្ឌលបោះឆ្នោត

❖ បញ្ជីនេះអាចផ្លាស់ប្តូរបាន។ ចំពោះការផ្លាស់ប្តូរណាមួយអាទិភាពនឹងត្រូវបានផ្តល់ទៅទីតាំងស្រដៀងគ្នាឬជិតនឹងទីតាំងដែលបានចុះបញ្ជី។

| មណ្ឌលបោះឆ្នោត | អាសយដ្ឋាន | ទីក្រុង |
|---|---|---|
| 1st Baptist Church Gilroy | 8455 Wren Ave | Gilroy, CA 95020 |
| Alexander Rose Elementary School | 250 Roswell Dr | Milpitas, CA 95035 |
| Almaden Community Center | 6445 Camden Ave | San Jose, CA 95120 |
| Andrew Hill High School | 3200 Senter Rd | San Jose, CA 95111 |
| Bella Terra Senior Apartments | 235 East Dunne Ave | Morgan Hill, CA 95037 |
| Belwood Cabana Club | 100 Belwood Gate Way | Los Gatos, CA 95032 |
| Berryessa Branch Library - Community Room | 3355 Noble Ave | San Jose, CA 95132 |
| Braly Park Building | 704 Daffodil Ct | Sunnyvale, CA 94086 |
| Calabazas Park Building | 6852 Rainbow Dr | San Jose, CA 95129 |
| Cambrian Branch Library | 1780 Hillsdale Ave | San Jose, CA 95124 |
| Campbell Community Center - Roosevelt Room | 1 W Campbell Ave | Campbell, CA 95008 |
| Campbell Union High School District - Board Room | 3235 Union Ave | San Jose, CA 95124 |
| Capitol Park | 800 Peter Pan Ave | San Jose, CA 95116 |
| Children Health Council | 2280 Kenwood Ave | San Jose, CA 95128 |
| Christ the Good Shepherd Lutheran | 1550 Meridian Ave | San Jose, CA 95125 |
| Chung Tai Zen Center of Sunnyvale | 750 E Arques Ave | Sunnyvale, CA 94085 |
| Church of Scientology of San Jose | 1865 Lundy Ave | San Jose, CA 95131 |
| City of Morgan Hill City Hall | 17575 Peak Ave | Morgan Hill, CA 95037 |
| Columbia Middle School - Library | 739 Morse Ave | Sunnyvale, CA 94085 |
| Cubberley Community Center - Gym A | 4000 Middlefield Rd | Palo Alto, CA 94303 |
| Dhammakaya Center MH | 280 Llagas Rd | Morgan Hill, CA 95037 |
| Easterbook Discovery School | 4835 Doyle Rd | San Jose, CA 95129 |
| Edenvale Branch Library | 101 Branham Ln | San Jose, CA 84111 |
| Edenvale Community Center | 330 Branham Ln | San Jose, CA 95111 |
| Elks Lodge | 444 W Alma Ave | San Jose, CA 95110 |
| Fair Oaks Park | 540 N Fair Oaks Ave | Sunnyvale, CA 94085 |
| Gilroy Police - Community Room | 7301 Hanna St | Gilroy, CA 95020 |
| Grass Farm Garden Accents | 11155 Lena Ave | Gilroy, CA 95020 |
| Hillview Branch Library | 1600 Hopkins Dr | San Jose, CA 95122 |
| Houge Park Community Center | 3952 Twilight Dr | San Jose, CA 95118 |
| John Sinnott Elementary School | 2025 Yellowstone Ave | Milpitas, CA 95035 |
| Kirk Community Center | 1601 Foxworthy Ave | San Jose, CA 95118 |
| Leigh High School | 5210 Leigh Ave | San Jose, CA 95124 |
    a. អ្នកចូលរួម៖ តំណាងមកពី Silicon Valley at Home ត្រូវបានដឹកនាំដោយការិយាល័យនាយកគ្រប់គ្រង City of San Jose ទាក់ទងមកកាន់ ROV ដើម្បីធ្វើការរួមគ្នាទៅលើទីតាំងមណ្ឌលបោះឆ្នោតនិងដាក់ហិបទម្លាក់សន្លឹកឆ្នោតដែលមានសក្តានុពល បានទាក់ទងមកកាន់ក្រុមហ៊ុនសាងសង់លំនៅដ្ឋាន ដើម្បីតាមសាកសួរឲ្យដឹងក្រែងពួកគេមានលក្ខខណ្ឌតម្រូវកំណត់ទៅលើសិទ្ធិទទួលបាន ។ បានសាកសួរអំពីក្រុមហ៊ុនសាងសង់លំនៅដ្ឋានគួរឲ្យចាប់អារម្មណ៍មួយ ។ អាចនឹងត្រូវពង្រីកវិសាលភាពចាប់ពី City of San Jose ទៅដល់ North and South County ។ ចំពោះការយល់ឃើញរបស់ពួកគេ សមត្ថភាពដើម្បីភ្ជាប់ទំនាក់ទំនងជាមួយនឹងពលរដ្ឋក្នុងមូលដ្ឋានក្នុងការជួយគាំទ្រដល់ការសាងសង់លំនៅដ្ឋាន និងការអភិវឌ្ឍ គឺជាអ្វីដែលមានសារៈសំខាន់ ។ គាត់នៅតែធ្វើការទៅលើទីតាំងស្រាវជ្រាវ គម្លាតដែលអាចមាន និងមានចំណាប់អារម្មណ៍ចំពោះការប៉ាន់ប្រមាណទៅលើទីតាំងដែលមានគុណវិបត្តិ ។ ដើម្បីបង្កើនចំនួនអ្នកមកបោះឆ្នោតនោះ ប្រហែលជាការពិនិត្យទៅលើមណ្ឌលនិងតំបន់ហ្ស៊ីបកូដដែលជាប្រពៃណីមានចំនួនអ្នកមកបោះឆ្នោតតិចតួច ។ ចុះទៅកាន់តំបន់ទាំងនេះនិងទៅចូលរួមក្នុងសហគមន៍ និងព្រឹត្តិការណ៍របស់ពួកគេអាចជួយបង្កើនការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកបោះឆ្នោតបាន ។ តើអ្នកមានបញ្ជី ឬផែនទីលម្អិតទីតាំងនៃការិយាល័យបោះឆ្នោតពីមុនមកទេ?
    b. បុគ្គលិក ROV៖ សូមអរគុណដល់អនុសាសន៍ដ៏ល្អទាំងឡាយស្តីពីការិយាល័យបោះឆ្នោត ។ យើងផ្ញើវាជូនអ្នកតាមអ៊ីម៉ែល ។
2. អ្នកចូលរួម៖ តើមានលក្ខខណ្ឌតម្រូវអ្វីខ្លះ ស្ថិតនៅពីក្រោយមណ្ឌលបោះឆ្នោតចល័ត?
    a. បុគ្គលិក ROV៖ ខោនធីខ្លះប្រើប្រាស់វា ហើយខ្លះមិនប្រើវាទេ ។ ជាធម្មតាមណ្ឌលបោះឆ្នោតចល័តត្រូវបានប្រើប្រាស់នៅតាមខោនធីដែលមានផ្ទៃដីធំ ប៉ុន្តែមិនមែនដោយសារមានអ្នកបោះឆ្នោតច្រើននោះទេ ។ ទោះជាយ៉ាងណាក៏ដោយ វាជាអ្វីមួយសម្រាប់ ROV ដើម្បីធ្វើការពិចារណា ។ ប្រសិនចាំបាច់នោះ យើងនឹងយកសម្ភារៈទាំងអស់ ហើយរៀបចំតម្លើងវានៅតាមទីតាំងដែលយើងមិនអាចផ្តល់មណ្ឌលបោះឆ្នោតបាន ។
3. អ្នកចូលរួម៖ អានការសិក្សារបស់សាកលវិទ្យាល័យ Rutgers University នៅក្នុងឆ្នាំ 2016៖ ភាគច្រើននៃមនុស្សដែលមានពិការភាព ដែលទទួលបានសន្លឹកឆ្នោតតាមសំបុត្រនោះមិនប្រើវាទេ ។ មានបញ្ជីបង្ហាញពីមូលហេតុ និងនិយាយអំពីតម្រូវការនៃការផ្សព្វផ្សាយដើម្បីពន្យល់ពីសន្លឹកឆ្នោត (ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ឬមធ្យោបាយអប់រំផ្សេងៗទៀត) ។ ការសិក្សានោះលើកឡើងថា សមត្ថភាពយល់ដឹងនិងអានសន្លឹកឆ្នោតជួយបង្កើនការចេញមកបោះឆ្នោត ។ មានពីរចំណុច មួយគឺការប្រមូលមនុស្សឲ្យមកបោះឆ្នោត និងមួយទៀតគឺការឆ្លើយតបទៅនឹងតម្រូវការនៃអ្នកដែលចេញមកបោះឆ្នោត ។ តើអ្វីទៅជាអាទិភាពរបស់អ្នកស្ថិតក្នុងពេលនេះ? លទ្ធភាពដែលអាចចូលរួមបាននិងការធ្វើឲ្យការបោះឆ្នោតកាន់តែធំមែនទេ?
    a. បុគ្គលិក ROV៖ ពិតណាស់ តើអ្នកដឹងពីការបោះឆ្នោតតាមសំបុត្រពីចម្ងាយទេ (RAVBM)? យើងមាន RAVBM ដែលអ្នកបោះឆ្នោតជាយោធា ជាអ្នកនៅក្រៅប្រទេស និងអ្នកមានពិការភាពអាចប្រើប្រព័ន្ធអនឡាញបាន ។ អ្នកបោះឆ្នោតអាចទាញយកសន្លឹកឆ្នោតរបស់គេ ពីគេហទំព័រចេញពីតំណភ្ជាប់ដែល

បានផ្ញើឲ្យតាមអ៊ីម៉ែល ព្រីនសន្លឹកឆ្នោតនោះ ហើយផ្ញើវាត្រឡប់មក ROV វិញតាមប្រៃសណីយ៍ ។ សេចក្តីណែនាំត្រូវបានផ្តល់ពីរបៀបអនុវត្តន៍ដំណើរការ RAVBM ។ ROV ក៏នឹងផ្តល់ជូននូវឧបករណ៍សម្រាប់គូសសញ្ញាលើសន្លឹកឆ្នោតដែលអាចទទួលបាននៅតាមគ្រប់មណ្ឌលបោះឆ្នោតផងដែរ ។

b. បុគ្គលិក ROV៖ អ្នកបោះឆ្នោតចេញមកបោះឆ្នោតក៏អាស្រ័យទៅលើការអប់រំរបស់ខោនធីនោះដែរ ។ ផ្នែកនៃផែនការគឺធ្វើការបង្កើននូវការខិតខំផ្សព្វផ្សាយនិងស្វែងរកដៃគូ ធ្វើដូចនេះយើងអាចអប់រំដល់ពលរដ្ឋនៅក្នុងខោនធីជាមួយនឹងកម្មវិធីសម្ព័ន្ធភាពអប់រំនិងផ្សព្វផ្សាយអ្នកបោះឆ្នោត (VEOC) បាន ។ យើងមានកម្មវិធី “ការបណ្តុះបណ្តាលគ្រូបង្គោល” ដែលយើងនឹងចុះទៅតាមសហគមន៍ និងបង្រៀនដល់សមាជិកនៃសាធារណជន ឬអង្គភាពនានាពីរបៀបអប់រំដល់អ្នកជាសមាជិកដូចគ្នាអំពីច្បាប់ VCA ។

c. អ្នកចូលរួម៖ ការសិក្សាបានបង្ហាញថាមានចំនួនប្រជាជនច្រើនខ្លាំងណាស់ បើទោះបីជាជម្រើសទាំងនេះត្រូវបានផ្តល់ឲ្យក៏ពិតមែន តម្រូវការធាតុចូលដើម្បីយល់ ហើយពួកគេជាច្រើននៅតែពេញចិត្តធ្វើដំណើរទៅកាន់ការិយាល័យបោះឆ្នោត ដើម្បីសុំឲ្យគេជួយដោយផ្ទាល់ដដែល ។

d. បុគ្គលិក ROV៖ មែនហើយ ខ្ញុំសូមធ្វើការកោតសរសើរ ។ យើងមានមណ្ឌលបោះឆ្នោតត្រូវចុះទៅមើល ហើយពួកគេនឹងមិនត្រូវបានរឹតត្បិតត្រឹមតែការិយាល័យបោះឆ្នោតមួយដូចមុនទៀតទេ ។ យើងមានមន្ត្រីបោះឆ្នោត និងបុគ្គលិកផ្សេងទៀតដែលអាចជួយបានផងដែរ ។ យើងនឹងផ្សព្វផ្សាយព្រមទាំងមានការបោះឆ្នោតតាមសំបុត្រពីចម្ងាយជូនផងដែរ ។ យើងនឹងមានព័ត៌មានដែលអាចទទួលបានដោយផ្តល់ជូនតាមទូរសព្ទផងដែរ ។ សូមអរគុណដល់អ្នកជាពន្លឺកសម្រាប់ព័ត៌មាននេះ! តើអ្នកមានគំនិតអ្វីខ្លះទេចំពោះទីតាំង ឬតំបន់ជាក់លាក់ណាមួយ ដែលអាចនឹងមានបុគ្គលដែលមានពិការភាពច្រើនដែលអ្នកគិតថាយើងចាំបាច់ត្រូវយកចិត្តទុកដាក់នោះ?

e. អ្នកចូលរួម៖ សហគមន៍ជនមានពិការភាពរស់នៅរាយប៉ាយតាមមន្ទីរស្នាក់នៅនិងមជ្ឈមណ្ឌលជំនួយខុសៗគ្នា ហើយអ្នដឹងពីវា ប៉ុន្តែយើងនឹងបន្តពិនិត្យទៅលើចំណុចនេះដែរ ។

4. អ្នកចូលរួម៖ តើមានការិយាល័យបោះឆ្នោតប៉ុន្មាន ដែលយើងមានកាលពីឆ្នាំទៅមិញ? តើយើងនឹងបង្កើនវាទេ?

a. បុគ្គលិក ROV៖ យើងមានមណ្ឌលបោះឆ្នោតចំនួន 849 កន្លែងចុងក្រោយនេះ ប៉ុន្តែស្ថិតក្រោមច្បាប់ VCA ចំនួនមណ្ឌលនោះនឹងត្រូវធ្លាក់ចុះ ។ យើងនឹងមានប្រហែលជា 25 មណ្ឌលបោះឆ្នោត ដំណើរការសម្រាប់រយៈពេល 11 ថ្ងៃ (10 ថ្ងៃមុនការបោះឆ្នោត និងបន្ថែមថ្ងៃបោះឆ្នោតមួយថ្ងៃទៀត) ប្រៀបធៀបទៅ មួយមណ្ឌលបោះឆ្នោតមានអ្នកបោះឆ្នោត 50,000នាក់ ហើយបន្ថែមមណ្ឌលបោះឆ្នោតចំនួន 100 ទៀត ដែលដំណើរការរយៈពេល 4 ថ្ងៃ (3 ថ្ងៃមុនថ្ងៃបោះឆ្នោត បន្ថែមថ្ងៃបោះឆ្នោតមួយថ្ងៃទៀត) ដោយមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតចំនួន 10,000 នាក់ ។ យើងរំពឹងថានឹងមានអ្នកបោះឆ្នោតជាងមួយលាននាក់នៅឆ្នាំក្រោយនេះ ហើយយើងមានគោលបំណងផ្តល់មណ្ឌលបោះឆ្នោតឲ្យបានច្រើនជាងច្បាប់កំណត់ ។ ផ្នែក GIS Mapping Division របស់យើង កំពុងតែបានធ្វើការកំណត់ទីតាំងសម្រាប់មណ្ឌលបោះឆ្នោតរបស់យើង ដោយបំបែកជា 14 លក្ខខណ្ឌតម្រូវទៅតាមចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ។ ចំនួនមណ្ឌលបោះឆ្នោតស្មើនឹងចំនួនការិយាល័យបោះឆ្នោតមិនសំខាន់ដូចការប្តូរទៅកាន់ច្បាប់ VCA ទេ ដោយសារតែអ្នកអាចបោះឆ្នោតបាននៅគ្រប់កន្លែងដែលអ្នកចង់ ឬនៅកន្លែងដែលងាយស្រួលបំផុតសម្រាប់អ្នក ។ វាជាការពិតណាស់ដែលពលរដ្ឋអាចត្រូវធ្វើដំណើរឆ្ងាយជាងមុនចេញពីផ្ទះរបស់គេទៅកាន់មណ្ឌលបោះឆ្នោត ប៉ុន្តែបច្ចុប្បន្ននេះពួកគេមានជម្រើសរហូតដល់ទៅរយៈពេល 11 ថ្ងៃដើម្បីទៅកាន់មណ្ឌលបោះឆ្នោតនៅពេលគេឈប់សម្រាកអាហារថ្ងៃត្រង់ដែលស្ថិតនៅក្បែរកន្លែងធ្វើការរបស់គេ ឬនៅជាប់និងសាលាកូនៗរបស់គេ ។ល។

5. អ្នកចូលរួម៖ តើមានភាពខុសគ្នារវាងការិយាល័យបោះឆ្នោតនិងមណ្ឌលបោះឆ្នោតទេ?
    a. បុគ្គលិក ROV៖ ការិយាល័យបោះឆ្នោតកំពុងត្រូវបានប្តូរទៅជាមណ្ឌលបោះឆ្នោត បន្ថែមទៅលើការបញ្ចូលនូវសេវាជាច្រើនដែលត្រូវបានផ្តល់នៅតាមទីតាំងនីមួយៗទៀត ។ មណ្ឌលបោះឆ្នោតនីមួយៗនឹងផ្តល់សេវាទៅដល់តំបន់ធំជាងមុន ។
    b. អ្នកចូលរួម៖ វាមិនគួរស្ថិតក្នុងហ្គារ៉ាសរថយន្តដូចលើកមុនមែនទេ?
    c. បុគ្គលិក ROV៖ គ្មានទៀតទេ ។ ច្បាប់ VCA មានលក្ខខណ្ឌតម្រូវសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗរាប់បញ្ចូលទាំងទំហំ មានចំណតរថយន្ត អនុលោមទៅតាមច្បាប់ ADA និងសន្តិសុខ ។ នឹងមានគ្រឿងបរិក្ខារ និងមនុស្សមកកាន់មណ្ឌលច្រើនជាងមុន 3-5 ដង ។ យើងកំពុងតែសហការជាមួយអ្នកអភិវឌ្ឍន៍និងក្រុង ដើម្បីស្វែងរកមណ្ឌលបោះឆ្នោតឲ្យបានគ្រប់គ្រាន់និងដែលអាចចេញចូលបានស្រួល ។ យើងក៏មានបញ្ជីមណ្ឌលដែលមានសក្តានុពលជាង 500 ដែលត្រូវបានពិចារណា ប៉ុន្តែមកដល់ពេលនេះមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានអ្វីៗទៅតាមច្បាប់ VCA បន្ថែមទៅលើតម្រូវការដែលយើងមាន ។ យើងចង់បាននូវសំណូមពរទាំងឡាយណាដែល ROV អាចនឹងវាយតម្លៃវាថាជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពល ។
6. អ្នកចូលរួម៖ ដូច្នេះ អ្វីដែលជាគំនិតនោះគឺថាមណ្ឌលបោះឆ្នោតធំមួយសម្រាប់អ្នកបោះឆ្នោតចំនួន 10,000 នាក់មែនទេ?
    a. បុគ្គលិក ROV៖ ត្រឹមត្រូវហើយ ប៉ុន្តែចាប់ផ្តើមត្រឹមថ្ងៃសៅរ៍មុនថ្ងៃបោះឆ្នោត (ប្រហែលជាមានមណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃចំនួន 100 មណ្ឌល) ។ តាមបទពិសោធន៍ប្រមូលបានពីខោនធីផ្សេងៗមកនោះ នឹងស្ទើរតែគ្មានជួរទាល់តែសោះឡើយនៅសប្តាហ៍ទីមួយ ហើយវត្តមានចូលរួមនឹងចាប់ផ្តើមកើននៅចុងសប្តាហ៍មុនថ្ងៃបោះឆ្នោត ។ វានឹងត្រូវការពេលមួយចំនួនដើម្បីឲ្យអ្នកបោះឆ្នោតស៊ាំទៅនឹងការផ្លាស់ប្តូរ ប៉ុន្តែអ្វីដែលប្រសើរបំផុតនោះគឺថា ពួកគេនឹងមកទទួលអត្ថប្រយោជន៍ពីរយៈពេលដែលផ្តល់ឲ្យចំនួន 11 ថ្ងៃដើម្បីបោះឆ្នោត ។
7. អ្នកចូលរួម៖ គ្រប់ការបោះឆ្នោតទាំង រយៈពេលបីឬបួនសប្តាហ៍មុនការបោះឆ្នោត ROV ផ្ញើចេញនូវសន្លឹកឆ្នោតគំរូ និងទិសដៅនានាដែលយើងត្រូវទៅ ។ តើនឹងមានបញ្ជីប្រកាសឈ្មោះមណ្ឌលបោះឆ្នោតទាំងអស់ដូចគ្នានេះទេ?
    a. បុគ្គលិក ROV៖ សេចក្តីណែនាំដែលមានផ្ទុកព័ត៌មានស្តីពីការបោះឆ្នោត (CVIG) បច្ចុប្បន្ននេះនឹងបញ្ចូលនូវបញ្ជីប្រកាសឈ្មោះមណ្ឌលបោះឆ្នោតទាំងអស់ ព្រមជាមួយនឹងម៉ោងដំណើរការរបស់មណ្ឌលនីមួយៗផងដែរ ។ សន្លឹកឆ្នោតបោះតាមសំបុត្រដែលអ្នកទទួលបានតាមប្រៃសណីយ៍នោះ នឹងមានបញ្ជីប្រកាសឈ្មោះមណ្ឌលបោះឆ្នោត និងម៉ោងដំណើរការរបស់វាផងដែរ ។ ការប្រកាសបញ្ជីឈ្មោះដូចគ្នានេះនឹងត្រូវធ្វើឡើងតាមប្រព័ន្ធអនឡាញផងដែរ ។
8. អ្នកចូលរួម៖ ទាក់ទងនឹងលក្ខខណ្ឌតម្រូវស្តីពីការកំណត់ទីតាំង ដូចជាចម្ងាយទៅកាន់មធ្យោបាយធ្វើដំណើរសាធារណៈ សហគមន៍និយាយភាសាភាគតិច សហគមន៍មានចំណូលទាប ។ល។ យើងនិយាយពីដំណើរការស្មើភាពនៃការចូលរួមក្នុងដំណើរការ ក៏ដូចជាការធ្វើការជាមួយនឹងសហគមន៍ដែលមានការចូលរួមបោះឆ្នោតទាប– ខ្ញុំគិតថា អ្វីជាអាទិភាពសម្រាប់យើង នៅពេលយើងពិនិត្យទៅលើវិធានការស្តីពីលំនៅដ្ឋាន ដើម្បីផ្តោតទៅលើតំបន់ទាំងឡាយណាដែលច្រើនតែបោះឆ្នោតជំទាស់ទៅនឹងមណ្ឌលដែលមានជាងហើយជំទាស់ទៅនឹងការអភិវឌ្ឍលំនៅដ្ឋាន ។ ដូច្នេះ យើងត្រូវតែគាំទ្រដល់សហគមន៍ទាំងនេះ ហើយត្រូវប្រាកដថាសហគមន៍ទាំងនេះមានលទ្ធភាពងាយស្រួលក្នុងការបោះឆ្នោត ។ ខ្ញុំមិនដឹងថាអ្នកអាចកៀរគរដល់អង្គការមួយចំនួនដូចជាស្ថិតនៅ East San Jose ដោយធ្វើដំណើរតាមផ្លូវ Monterey Road ។ ខ្ញុំចង់លើក

ទឹកចិត្តអ្នកឲ្យទាក់ទងទៅពួកគេ អង្គការទាំងនោះមានដូចជា Alum Rock Organization ឬ Mayfair ហើយសាកមើលក្រែងលោអ្នកបោះឆ្នោតមានឆន្ទៈធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនោះ ។ ជាមួយគ្នានេះផងដែរ ស្វែងយល់ពីកន្លែងដែលគេនឹងចង់ទៅ ។ សមាជិក Neighborhood Association នឹងអាចផ្តល់ព័ត៌មានពីទីកន្លែង និងចម្ងាយដែលគេមានឆន្ទៈធ្វើដំណើរទៅបោះឆ្នោតបាន ។ យើងរីករាយ និងមានឆន្ទៈជួយចាប់ផ្តើម ឬរៀបចំបទសន្ទនានិងព្រឹត្តិការណ៍ទាំងនេះ ហើយអញ្ជើញ ROV ឲ្យចូលរួម ។

9. អ្នកចូលរួម៖ យើងមានអង្គការសម្ព័ន្ធភាពមានឈ្មោះថា The Nonprofit Housing Association of Northern California ដោយមានកម្មវិធីគំរូមានឈ្មោះថា "ការភ្ជាប់ទំនាក់ទំនងពលរដ្ឋ" ដែលបណ្តុះបណ្តាលអ្នកបង្ហាត់ឲ្យធ្វើការជាមួយនឹងអ្នកអភិវឌ្ឍដល់ទីតាំងទាក់ទងនឹងការអប់រំការចុះឈ្មោះអ្នកបោះឆ្នោតនៅតាមទីតាំងអភិវឌ្ឍ ។ បើទោះជាយើងមិនអាចមានមណ្ឌលបោះឆ្នោតនៅក្នុងតំបន់អភិវឌ្ឍជាក់លាក់ណាមួយក៏ដោយ ក៏យើងអាចមាន ROV មកធ្វើបទបង្ហាញ/កម្មវិធីផ្តល់ព័ត៌មានសម្រាប់ពលរដ្ឋក្នុងមូលដ្ឋានដើម្បីអប់រំពួកគេឲ្យយល់ដឹងពីការផ្លាស់ប្តូរទាំងអស់ដែលកើតមានឡើង ។ មានអ្នកបោះឆ្នោតជាច្រើនពេញចិត្តទទួលការបណ្តុះបណ្តាលដោយអ្នកដែលមិនពាក់ព័ន្ធនឹងគណបក្ស ជាជាងមកពីបេក្ខជនស្វែងរកការបោះឆ្នោត ។ យើងក៏រីករាយសម្របសម្រួលព្រឹត្តិការណ៍ប្រភេទនេះជាមួយនឹង ROV ផងដែរ ។
    a. បុគ្គលិក ROV៖ ពិតមែនហើយ តើអ្នកចាប់អារម្មណ៍ចំពោះសម្ព័ន្ធអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោតទេ ? យើងអាចចេញទៅជួបនឹងអង្គការរបស់អ្នកដើម្បីអប់រំដល់សាធារណជន ។ យើងមានឱកាសសម្រាប់ការកៀរគរពលរដ្ឋឲ្យចូលរួម "ការបណ្តុះបណ្តាលអ្នកបង្ហាត់" ។ យើងអាចទាក់ទងជាមួយនឹងអ្នកអភិវឌ្ឍទាំងឡាយ ហើយអញ្ជើញ ROV ឲ្យមកធ្វើបទបង្ហាញ ។

10. អ្នកចូលរួម៖ Silicon Valley Counsel of Nonprofits គឺជាអង្គការបង្កើតឲ្យមានសេវាកម្មជាច្រើន ។ ខ្ញុំបានលើកទឹកចិត្តដល់ ROV ឲ្យធ្វើការជាមួយ Silicon Valley Counsel of Nonprofits ដោយសារតែទំនាក់ទំនងដ៏ទូលំទូលាយរបស់គេក្នុងសហគមន៍ និងទាញយកផលប្រយោជន៍នៃក្របខណ្ឌផ្តល់សេវាកម្ម ។

## V. លទ្ធភាពទទួលបានផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*ធាតុចូលជាសាធារណៈ/សំណួរ៖*

1. បុគ្គលិក ROV៖ កន្លងមកយើងបានកំណត់គោលដៅចំពោះសហគមន៍ភាសាដោយផ្អែកទៅតាមមណ្ឌល និងជម្រើសផ្នែកភាសាត្រូវបានកំណត់ឡើងដោយអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ។ ក្នុងករណីដែលអាចធ្វើបាន គោលបំណងរបស់ VCA គឺដើម្បីផ្តល់ជំនួយផ្នែកភាសាសម្រាប់មួយក្នុងចំណោមភាសាដែលត្រូវបានគាំទ្រទាំងប្រាំបីនៅគ្រប់មណ្ឌលបោះឆ្នោត ។ តើមានមតិត្រឡប់ទាក់ទងនឹងជំនួយផ្នែកភាសា ឬសហគមន៍ភាសា ដែលគួរដឹងដែរឬទេ?
    a. អ្នកចូលរួម៖ តើនឹងមានយ៉ាងតិចបំផុតមួយភាសានៅតាមគ្រប់មណ្ឌលបោះឆ្នោតទេ? ដូចជាមានបុគ្គលិកនិយាយភាសាវៀតណាមចំនួន 120 នាក់ ដោយផ្តល់ម្នាក់ក្នុងមួយមណ្ឌលបោះឆ្នោតទេ?
    b. បុគ្គលិក ROV៖ យ៉ាងតិចបំផុត យើងចង់ឲ្យមានសមាជិកបុគ្គលិកម្នាក់មួយភាសានៅតាមគ្រប់មណ្ឌលបោះឆ្នោត ។ ផលវិបាកនោះគឺការជ្រើសរើសបុគ្គលិកដែលទំនេរមកធ្វើការសម្រាប់រយៈពេលពី 4 ទៅ 11 ថ្ងៃ ព្រមទាំងត្រូវឲ្យមានវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពផ្នែកភាសា ។ យើងចាំបាច់ត្រូវជ្រើសរើស

ឲ្យបានច្រើនជាងអប្បរមាក្នុងករណីមានបញ្ហាកាលវិភាគជាន់គ្នា ឬការបដិសេធផងនោះ ។ វាក៏ពិបាករកជួលសម្រាប់ភាសាដែលមានប្រើនៅតាមសហគមន៍តូចៗនៅក្នុងខោនធី Santa Clara ។ បុគ្គលិកខ្លះអាចនឹងមិនធ្វើការបានគ្រប់ទាំង 4 ឬ 11 ថ្ងៃ ដូច្នេះតាមលក្ខណៈជាក់ស្តែង យើងនឹងជួលច្រើនជាងលក្ខខណ្ឌតម្រូវកម្រិតអតិបរមា ។ បុគ្គលិកដែលត្រូវបានជួល នឹងទទួលបានការបណ្តុះបណ្តាលដូចគ្នា មានន័យថានឹងគ្មានអ្នកបកប្រែ ប៉ុន្តែមានសមាជិកបុគ្គលិកនិយាយពីរភាសា ។

c. អ្នកចូលរួម៖ មានសេវាកម្មដែលមិនមានតម្លៃថ្លៃ ដែលអ្នកអាចទូរសព្ទទៅដោយប្រើទូរសព្ទដៃដែលអ្នកអាចជ្រើសរើសយកភាសានិងទូរសព្ទចេញ ។

d. បុគ្គលិក ROV៖ យើងពិតជាមានសេវាបកប្រែតាមទូរសព្ទនៅនឹងកន្លែងត្រៀមរួចរាល់ដើម្បីទូរសព្ទចេញ ប្រសិនបើយើងមិនអាចផ្តល់ការគាំពារផ្នែកភាសាដោយបុគ្គលផ្ទាល់បានទេនោះ ។

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា។

1. បុគ្គលិក ROV៖ នឹងផ្សព្វផ្សាយពាណិជ្ជកម្មពីលទ្ធភាពទទួលបាននៃច្បាប់ VCA និងមណ្ឌលបោះឆ្នោត ។ ឧបករណ៍ដែលអាចប្រើបានសម្រាប់ការបោះឆ្នោតដោយឯករាជ្យនិងសម្ងាត់ នឹងមានដាក់ឲ្យប្រើប្រាស់នៅតាមមណ្ឌលបោះឆ្នោតនីមួយៗផងដែរ ។ តើមានធាតុចូលទាក់ទងនឹងលទ្ធភាពដែលអាចទទួលបានទាក់ទងពិការភាពទេ?

   a. អ្នកចូលរួម៖ មានពីរចំណុច មានលិខិតគតិយុទ្ធនិងការអនុលោមទៅតាមច្បាប់ ADA ដូចជាថាតើច្រកទ្វារចូលចាំបាច់ត្រូវធំប៉ុណ្ណា ។ ក៏មានផងដែរនូវរបៀបដែលច្បាប់ ADA ត្រូវបានអនុម័តជាស្មារតី ដែលមានលក្ខណៈចង្អៀតបន្តិច ប៉ុន្តែវាជាកាយវិការបញ្ជាក់ពីចិត្តសប្បុរសរបស់មនុស្ស និងបានត្រៀមរួចរាល់សម្រាប់ពិការភាពផ្សេងៗគ្នាជាច្រើន ។ នៅពេលបុគ្គលមកដល់ បុគ្គលិកគួរតែត្រូវប្រាកដថាអ្វីដែលគេត្រូវការគឺមាន ។ នៅក្នុងកិច្ចប្រជុំកន្លងមក មានការលើកឡើងថាគួរតែមានអ្នកស្វាគមន៍អ្នកបោះឆ្នោត ហើយពួកគេចាំបាច់ត្រូវត្រៀមលក្ខណៈឲ្យបានរួចរាល់ដើម្បីជួយដល់ពលរដ្ឋដែលថ្លង់ ឬស្តាប់មិនសូវឮ ឬគិតទុកក្រែងលោមានអ្នកពិការភ្នែក ។ សាច់ញាតិរបស់ខ្ញុំចំណាយពេលរាប់ខែក្នុងការត្រៀមខ្លួនសម្រាប់ការបោះឆ្នោត ។ មិត្តភក្តិរបស់គាត់ទូរសព្ទមកចង់សុំជំនួយពីគាត់ ។ ការគិតទុកជាមុនថានឹងមានអ្នកបោះឆ្នោតគ្រប់ប្រភេទទាំងអស់គឺជាគន្លឹះ ។ រៀងរាល់ឆ្នាំនៅក្នុងខែកក្កដា ជាសប្តាហ៍ចុះឈ្មោះអ្នកបោះឆ្នោតមានពិការភាព (NDVRW) ប្រហែលជាអ្នកគួរតែទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាក្រុងផ្សេងទៀត និងផ្តល់នូវមតិយោបល់ជាសាធារណៈ និងលើកកម្ពស់ការយល់ដឹង ។ មានមនុស្សជាច្រើនមានអារម្មណ៍ថាតម្រូវការបោះឆ្នោតរបស់គេនឹងមិនត្រូវបានឆ្លើយតប 35 លាន ឬ 1 ក្នុងចំណោម 6 នាក់មានប្រភេទ ឬទម្រង់ខ្លះនៃពិការភាព ។ ជាឧទាហរណ៍ តើអ្នកជួយមនុស្សដែលមានជំងឺខ្សោយបញ្ញាយ៉ាងដូចម្តេច? គ្រាន់តែជាអ្វីត្រូវទុកចិត្ត ។

2. អ្នកចូលរួម៖ ខ្ញុំជឿថាមានអង្គការជាច្រើនដែលធ្វើការជាមួយអ្នកនិយាយតែមួយភាសា ហើយមានបំណងផ្តល់មតិត្រឡប់ស្តីពីលទ្ធភាពដែលអាចទទួលបាន ។ ដូចជាបទពិសោធន៍នៅក្នុងការបោះឆ្នោតរបស់គេពីមុនមកយ៉ាងដូចម្តេច ហើយតើការផ្លាស់ប្តូរដែលមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះពួកគេនាពេលកន្លងមក ។ ROV អាចមានសក្តានុពលប្រើប្រាស់នូវមតិត្រឡប់មួយចំនួននោះ ។ ខ្ញុំតែងតែកត់សម្គាល់ថាបុគ្គលិកដែលមានសមត្ថភាពប្រើភាសាខុសៗគ្នានៅតាមការិយាល័យបោះឆ្នោតរបស់អ្នក ដែលជារឿង

អស្ចារ្យ ។ បញ្ហាចោទនោះគឺរក្សាឲ្យនៅថេរជាមួយនឹងចំនួនថ្ងៃដែលមណ្ឌលបោះឆ្នោតត្រូវបានពង្រីកឲ្យបើកទ្វារនោះ ។ វានឹងពិបាកសម្របសម្រួលនិងបង្កើតកាលវិភាគសម្រាប់អ្នកបោះឆ្នោត ។

a. បុគ្គលិក ROV៖ យើងពិតជាបានដឹងពីបញ្ហាចោទនានាដែលត្រូវបានលើកឡើង និងបានព្យាយាមដើម្បីទទួលបានសូហ្វត៍វែរនិងឧបករណ៍រៀបចំផ្សេងទៀត ដើម្បីជួយក្នុងការសម្របសម្រួលការជួលនិងរៀបចំកាលវិភាគបុគ្គលិកមណ្ឌលបោះឆ្នោត ។ ក្រុមការងារផ្សព្វផ្សាយរបស់យើងបាននិងកំពុងទំនាក់ទំនងទៅកាន់អង្គការនានា និងបើទោះបីជាយើងមិនទាន់ទទួលបានការឆ្លើយតបច្រើនក៏ដោយ ក៏យើងនិងបន្តផ្តួចផ្តើមទំនាក់ទំនងជាមួយនឹងសហគមន៍ផ្សេងៗទៀតដែរ ។ យើងក៏មានតំណាងមកពី Disability Rights of California ដែលស្ថិតនៅក្នុងគណៈកម្មាធិការប្រឹក្សាដើម្បីទទួលបានការបោះឆ្នោត (VAAC) ផងដែរ ក៏ដូចជាតំណាងមកពី Silicon Valley Independent Living Center ដែលមិនអាចមកចូលរួមបាននៅយប់នេះ ។

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយ ដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA។

1. បុគ្គលិក ROV៖ បានពិភាក្សាពីដើមមកអំពីការអប់រំសាធារណជនពីកម្មវិធីទទួលបានការចូលរួមក្នុងការបោះឆ្នោត មានដូចជា RAVBM និងការអប់រំសាធារណជនអំពីការផ្លាស់ប្តូរគំរូបោះឆ្នោតតាមច្បាប់ VCA ។ យើងនឹងបង្កើតឲ្យមានផងដែរ នូវសម្ព័ន្ធអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ដែលនឹងជួយអប់រំដល់អង្គការសហគមន៍តាមមូលដ្ឋាន (CBOs) ក៏ដូចជាសមាជិកសាធារជនផងដែរ ។ យើងនឹងធ្វើកម្មវិធី ”បណ្តុះបណ្តាល អ្នកបណ្តុះបណ្តាលបង្គោ” ដើម្បីយើងអាចបង្រៀនសមាជិកសាធារណជន ឬ CBOs អំពីរបៀបធ្វើបទបង្ហាញការអប់រំដល់មិត្តរបស់គេអំពី VCA ។ យើងក៏នឹងកំណត់គោលដៅទៅលើប្រភេទផ្សេងគ្នានៃការផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយ រាប់ចាប់តាំងពីវិទ្យុរហូតដល់ទូរទស្សន៍និងការសែត ។ តើអ្នកដឹងពីព្រឹត្តិការណ៍ ឬទីកន្លែងណាដែលចាប់អារម្មណ៍ឲ្យ ROV មកនិងអប់រំអំពីការបោះឆ្នោតទេ? តើមានស្ថានីយ៍ទូរទស្សន៍ណាខ្លះ និងឱកាសផ្សព្វផ្សាយពាណិជ្ជកម្មដែលអ្នកដឹងទេ?
   a. អ្នកចូលរួម៖ គឺ Abilities Expo ។ វាត្រូវណែនាំថាកុំឲ្យទៅវិញ ត្បិតវាមានលក្ខណៈពាណិជ្ជកម្មពេក ។
   b. អ្នកចូលរួម៖ វិទ្យុប្រសើរបំផុតសម្រាប់មនុស្សដែលមិនអាចមើលឃើញ ។
   c. បុគ្គលិក ROV៖ នោះពិតជាសំណូមពរដ៏ល្អ ។ យើងក៏ចង់បានមតិត្រឡប់ដែរ ប្រសិនបើអ្នកមានព័ត៌មានទំនាក់ទំនងណាដែលយើងអាចចែករំលែកនិម្មិតសញ្ញានិងឯកសារព័ត៌មានផ្សេងៗមួយចំនួនដើម្បីផ្តល់ដល់មិត្ត ឬអង្គការរបស់គេ ។
   d. អ្នកចូលរួម៖ តើអ្នកអាចផ្តល់ព័ត៌មានទៅដល់អ្នកបេក្ខជនខ្លួនគេផ្ទាល់បានទេ?
   e. បុគ្គលិក ROV៖ បេក្ខជនទទួលបានឯកសារព័ត៌មានសម្រាប់បេក្ខជន ដែលណែនាំពីរបៀបធ្វើយុទ្ធនាការនិងពីអ្វីដែល ROV នឹងត្រូវការពីបេក្ខជនទាំងនោះរួចហើយ ។ នៅក្នុងឆ្នាំនេះ ឯកសារណែនាំនឹងត្រូវដាក់បញ្ចូលនូវព័ត៌មានស្តីអំពីការឆ្ពោះទៅកាន់គំរូបោះឆ្នោតតាមច្បាប់ VCA ក៏ដូចជាការបង្ហាញពីសារៈសំខាន់នៃការអប់រំដល់អ្នកបោះឆ្នោតរបស់យើងពីការផ្លាស់ប្តូរដែលមាន ។ យើងសង្ឃឹមថាបេក្ខជននឹងចង់ជួយផ្សព្វផ្សាយយើងដោយហេតុថាពួកគេជាអ្នកទទួលរងនូវឥទ្ធិពលដោយផ្ទាល់ ។

f. អ្នកចូលរួម៖ ត្រូវឲ្យប្រាកដថាបេក្ខជនផ្តល់នូវព័ត៌មានត្រឹមត្រូវទៅដល់អ្នកបោះឆ្នោត ។ ចំពោះការផ្សព្វផ្សាយដល់អ្នកចេះតែមួយភាសាវិញ ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនមានផ្នែកព័ត៌មានដែលអ្នកអាចនិយាយអំពីអន្តោប្រវេសន៍ ដូចជាប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ ទាក់ទងទៅនឹងរឿងអន្តោប្រវេសន៍ជាដើម ។

g. អ្នកចូលរួម៖ យើងដឹងថាមាន VAAC ថ្នាក់រដ្ឋ ហើយយើងក៏បានរកឃើញអំពី VAAC ROV ផងដែរតាមរយៈ VAAC រដ្ឋនោះ ។ សាច់ញាតិរបស់ខ្ញុំមានគំនិតទៅកាន់ខោនធី និងនិយាយជាមួយគណៈកម្មាធិការ VAAC ហើយគាត់នឹងរាយការណ៍ត្រឡប់ទៅកាន់ ROV វិញ ។ មនុស្សត្រូវតែដឹងពីការផ្លាស់ប្តូរជាមុន ហើយបន្ទាប់មកត្រូវដឹងពីតម្រូវការរបស់បុគ្គលម្នាក់ៗនៃអ្នកបោះឆ្នោតផ្សេងៗគ្នាទាំងឡាយ ។

2. អ្នកចូលរួម៖ តើមានរដ្ឋផ្សេងនៅក្នុងប្រទេសបានធ្វើបែបនេះក្រៅពីរដ្ឋ California ទេ?

   a. បុគ្គលិក ROV៖ រដ្ឋ Colorado បានផ្តួចផ្តើមរួចមកហើយការបោះឆ្នោតដែលសន្លឹកឆ្នោតត្រូវបានផ្ញើតាមប្រៃសណីយ៍នោះ ។

   b. អ្នកចូលរួម៖ តើយើងអាចសាកសួរទៅកាន់រដ្ឋដទៃដើម្បីឲ្យដឹងពីអ្វីដែលដំណើរការបាន និងអ្វីដែលដំណើរការមិនបានបានទេ?

   c. បុគ្គលិក ROV៖ ប្រាកដណាស់ យើងអាចទាក់ទងទៅកាន់ពួកគេបាន ។ យើងក៏មានទំនាក់ទំនងជាប់គ្នាមិនដាច់ជាមួយនឹងការិយាល័យរដ្ឋលេខាធិការ ហើយមានការទំនាក់ទំនងតាមទូរសព្ទប្រចាំខែដែលមានខោនធីទាំងអស់ចូលរួម ដែលជាអ្នកត្រូវ ឬរៀបនឹងអនុវត្តច្បាប់ VCA ។ ការហៅតាមទូរសព្ទនេះគឺសម្រាប់សន្ទនាគ្នាពីរបៀបដែលខោនធីផ្សេងៗគ្នាចាប់ផ្តើមអនុវត្តនូវច្បាប់ VCA របស់គេ ពីអ្វីដែលដំណើរការបាន និងអ្វីដែលដំណើរការមិនបាន ហើយនិងសំណួមពរនានាឆ្ពោះទៅមុខ ។

   d. អ្នកចូលរួម៖ យើងដឹងថាមាន VAAC ថ្នាក់រដ្ឋ ហើយយើងក៏បានរកឃើញអំពី VAAC ROV ផងដែរតាមរយៈ VAAC រដ្ឋនោះ ។ សាច់ញាតិរបស់ខ្ញុំមានគំនិតទៅកាន់ខោនធីដទៃ និងនិយាយជាមួយគណៈកម្មាធិការ VAAC ហើយគាត់នឹងរាយការណ៍ត្រឡប់ទៅកាន់ ROV វិញ ។ មនុស្សត្រូវតែដឹងពីការផ្លាស់ប្តូរជាមុន ហើយបន្ទាប់មកត្រូវដឹងពីតម្រូវការរបស់បុគ្គលម្នាក់ៗនៃអ្នកបោះឆ្នោតផ្សេងៗគ្នាទាំងឡាយ ។

   e. បុគ្គលិក ROV៖ យើងប្រាកដជាអាចធ្វើការងារនោះបាន ស្តាប់ទៅប្រសើរណាស់ ។

3. តើមានសារអ្វីដែលយើងគួរផ្តោតការយកចិត្តទុកដាក់ទេ ដូចជាពេលយើងផ្ញើចេញនូវសេចក្តីជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយសង្គមជាដើម?

   a. អ្នកចូលរួម៖ មនុស្សគួរតែដឹងបានដោយងាយពីការផ្លាស់ប្តូរដែលចូលមកដល់ ។ នេះគឺជាសារទីមួយដែលយើងគួរតែបញ្ជូនចេញ ពីព្រោះថាមនុស្សចាំបាច់ត្រូវតែដឹងថាទាំងអស់នេះគឺថ្មី ។ ឲ្យពួកគេដឹងពី៖ “នេះគឺជាអ្វីសម្រាប់អ្នក ហើយប្រសិនបើអ្នកមានពិការភាពនោះ យើងត្រៀមរួចរាល់សម្រាប់អ្នកហើយ!” ។

   b. អ្នកចូលរួម៖ និយាយអំពីការផ្សព្វផ្សាយវិញ មានប៉ុស្តិ៍វិទ្យុជាច្រើន – ជាពិសេសនោះវិទ្យុនិយាយអេស្ប៉ាញ – មានផ្នែកព័ត៌មាននិយាយពីការផ្លាស់ប្តូរនៅក្នុងសហគមន៍ ។ អ្នកខ្លះអាចទៅកាន់ UNIVISION ឬ Telemundo និងចូលរួមផ្នែកផ្តល់ព័ត៌មានជាមួយពួកគេ ។ ក៏មានអង្គការមួយដែលមានឈ្មោះថា Association of Latino Election Officials ដែលធ្វើការជាមួយនឹងជាមួយនឹងអង្គការមិនរកកម្រៃក្នុងមូលដ្ឋានក្នុងរដ្ឋផ្ទាល់ ការងារទំនាក់ទំនងជាមួយអ្នកបោះឆ្នោត និងការងារជំរឿន ។ ពួកគេមានព័ត៌មានជាច្រើនភាសាដែលជាពិសេសចំពោះការរៀបចំសារនិងការកំណត់សារ ដែលអាចនឹងនឹងផ្សព្វផ្សាយសារនៅកម្រិតមូលដ្ឋានបាន ។ ផ្នែកព័ត៌មាន, វិទ្យុ, TV, ការផ្សាយពាណិជ្ជកម្ម, OP ED, លិខិតជូនបណ្ណាធិការព័ត៌មានអ្នកនិពន្ធ ។ល។ ស្តីអំពីការផ្លាស់ប្តូរទាំងឡាយដែលនឹងចូលមកដល់ដោយសារតែច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតនោះ ។ កំណត់គណៈកម្មាធិការជំនួសកិច្ចដែលអាចបញ្ជូនសារបន្តក្នុងនាម ROV ។ សហគមន៍និយាយតែមួយភាសាមិនមែនជនស្បែកសជាធម្មតា

មិនមានទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលទេ ។ ពួកគេមានទំនាក់ទំនងច្រើនជាមួយនឹងមេសហគមន៍មិនរកកម្រៃ ហើយមនុស្សច្រើនមានឆន្ទៈស្ដាប់វាជាងការសម្រុកផ្សព្វផ្សាយបែបពាណិជ្ជកម្មតាម VTA ឬ តាម TV/វិទ្យុ ។ កញ្ចប់ព័ត៌មានទាំងនោះនឹងផ្ដល់ព័ត៌មានបានទៅដល់ប្រជាជន ។ សារនោះចាំបាច់ត្រូវផ្សាយសារចុះសារឡើងឲ្យបានញឹកញាប់ ។ យុទ្ធនាការជាច្រើនធ្វើឡើងក្រោមរូបភាពដែលអ្នកត្រូវតែផ្សាយសារចុះសារឡើងឲ្យបានប្រាំពីរដង ប្រហែលជា ROV អាចនឹងយកគំរូតាមនៅមុនពេលការបោះឆ្នោតជិតចូលមកដល់ ។ ការចាប់ផ្ដើមឲ្យបានពីដើមទីពិតផ្ដល់នូវអត្ថប្រយោជន៍ ។ ថ្ងៃឈប់សម្រាកក៏នឹងជាបញ្ហាចោទដែរ ។ ការប្រាស្រ័យទាក់ទងទៅកាន់អ្នកបោះឆ្នោត និងការចាប់ផ្ដើមដំណើរការនេះឲ្យបានពីដើមទី នឹងជួយដល់អ្នកគ្រប់ៗគ្នា ។ បន្ថែមលើនេះ នៅពេលថ្ងៃចុះឈ្មោះអ្នកបោះឆ្នោតថ្នាក់ជាតិចូលមកដល់នៅថ្ងៃទី 24 ខែកញ្ញា ដែលជាឱកាសទាញបញ្ចូលនូវក្រុមមនុស្សពេញវ័យដ៏ច្រើនកុះករដែលជាអ្នកបោះឆ្នោតដ៏មានសក្ដានុពលនោះ ។

c. អ្នកចូលរួម៖ សប្ដាហ៍ចុះឈ្មោះអ្នកបោះឆ្នោតដែលមានពិការភាពថ្នាក់ជាតិពីថ្ងៃពី 15 ដល់ថ្ងៃទី 19 ខែកក្កដា ដែលមិនមានពេលច្រើន ប៉ុន្តែវាជាអ្វីដែលត្រូវពិចារណា ។ ខ្ញុំនឹងធ្វើជាអ្នកស្ម័គ្រចិត្តទាក់ទងសាកល្បងមើលក្រែងមានអ្វីនៅក្នុងកញ្ចប់ឧបករណ៍ដែលមានប្រយោជន៍ដល់យើង ។
d. បុគ្គលិក ROV៖ ពីខាងដើមបានលើកឡើងពី Mayfair Community Center ដែលយើងនឹងមានកិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីផែនការរដ្ឋបាលបោះឆ្នោតនៅទៅនោះនៅថ្ងៃទី 24 ខែមិថុនា ។
e. អ្នកចូលរួម៖ ខ្ញុំចង់លើកទឹកចិត្តឲ្យបន្តកៀរគរប្រភេទអង្គការទាំងនោះ ដូចជាអង្គការ Guadalupe, អង្គការ Neighborhood Association ហើយក៏អាចកៀរគរដល់ការិយាល័យរបស់ Councilwoman Magdalena Carrasco ព្រោះអីខ្ញុំជឿថាគាត់មានឆន្ទៈចេញមកនិយាយទៅកាន់ប្រជាពលរដ្ឋ ។ ជាមួយគ្នានេះដែរ សូមនិយាយទៅកាន់ PTAs ក្នុងមូលដ្ឋាន ដើម្បីជួយចាប់ផ្ដើមផ្សព្វផ្សាយសារ និងធ្វើការឆ្ពោះទៅបង្កើនវត្តមានចូលរួមឲ្យបានខ្ពស់ ។

# មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara

# ផែនការរដ្ឋបាលបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់អ្នកនិយាយភាសាវៀតណាម

Tully San Jose Branch Library

880 Tully Rd. San Jose, CA 95111

បន្ទប់សហគមន៍

ថ្ងៃចន្ទទី 17 ខែមិថុនា ឆ្នាំ 2019

6:30 ល្ងាច ដល់ 8:00 ល្ងាច

### វត្តមានអ្នកចូលរួម៖

អ្នកចូលរួមពីរនាក់ជាសាធារណជនមកពីសហគមន៍វៀតណាម

### វត្តមានបុគ្គលិកចូលរួម៖

Shannon Bushey, Vanessa Hamm, Magdalena Sta Maria, Priscilla Favela, Andrea Solorio, Shelby Galaviz, Linh Nguyen, Michelle Tran, Paulo Chang, Michael Borja, Bob Nguyen, Alfred Gonzales, April Bracamonte, Adrian Garcia, Martin Ayala, Janora Davis, Christina Rivas-Louie

### ចំណុចសកម្មភាព៖

- ពិនិត្យទៅលើសំណូមពររបស់អ្នកចូលរួមសម្រាប់ទីតាំងមណ្ឌលបោះឆ្នោត ។

I. **សេចក្តីណែនាំ**

*ការស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់គេតាមហិបទម្លាក់សន្លឹកឆ្នោតផ្លូវការ ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីសូមបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*ការធ្វើបទបង្ហាញរបស់ ROV ស្តីពី VCA* ត្រូវបានធ្វើឡើង ។

*ធាតុចូលជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ បានបង្ហាញនូវការមិនពេញចិត្តចំពោះការបោះឆ្នោតនាពេលកន្លងមក ។ គាត់និយាយថា សន្លឹកឆ្នោតរបស់គាត់មិនសំខាន់ចំពោះការបោះឆ្នោត ហើយមិនមានឥទ្ធិពលអ្វីទៅលើការបោះឆ្នោតក្នុងឆ្នាំ 2016 សោះ ។ គាត់បានសួរថាតើសន្លឹកឆ្នោតរបស់គាត់មានសារសំខាន់នៅក្នុងការបោះឆ្នោត ប្រធានាធិបតីជាប់ឆ្នោតបន្ទាប់នេះទេ?
    a. បុគ្គលិក ROV៖ បានពន្យល់ថា គ្រប់សន្លឹកឆ្នោតសុទ្ធតែមានសារសំខាន់ ហើយប្រសិនបើគ្រប់គ្នាបានចេញមកបោះឆ្នោតនោះ វាននឹងធ្វើឲ្យមានភាពខុសប្លែកខ្លាំងនៅក្នុងការបោះឆ្នោត ។

## III. គោលដៅនៃផែនការរដ្ឋបាលបោះឆ្នោត

ផែនការរដ្ឋបាលបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តន៍ការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហគមន៍ ។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

*ការធ្វើបទបង្ហាញរបស់ ROV ៖*

> បុគ្គលិក ROV៖ បានសួរថាតើអ្នកចូលរួមមានអនុសាសន៍ ឬ សំណួរអ្វីស្តីពីការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម មណ្ឌលបោះឆ្នោត ឬទីតាំងហិបទម្លាក់សន្លឹកឆ្នោតទេ? តើវាមានលក្ខណៈងាយស្រួលទេសម្រាប់ពលរដ្ឋដែលអាចទម្លាក់សន្លឹកឆ្នោតរបស់គេបានបើទោះបីជានៅចំថ្ងៃសៅរ៍ក៏ដោយនោះ?

*ធាតុចូលជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ អ្វីៗគ្រប់យ៉ាងគឺល្អសម្រាប់ពួកគេ ។ វាគ្មានបញ្ហាអ្វី ចំពោះពួកគេទេ គេអាចទៅកាន់កន្លែងណាក៏បានតាមរថយន្តក្រុង ឬបើកបរដោយខ្លួនឯងនោះ ។
    a. បុគ្គលិក ROV៖ បានពន្យល់និងស្នើសុំធាតុចូលទាក់ទងនឹងមណ្ឌលបោះឆ្នោត ។ អ្នកចូលរួមម្នាក់បានណែនាំពីឃ្លាំងផ្ទុកទំនិញរបស់ Do Van Tron ដែលជាបុគ្គលមានឈ្មោះបោះសម្លេងតាមស្ថានីយ៍វិទ្យុវៀតណាមក្នុងមូលដ្ឋាន - Vien Thao Radio ។

V. **លទ្ធភាពទទួលបានផ្នែកភាសា**

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*ធាតុចូលជាសាធារណៈ/សំណូរៈ*

1. បុគ្គលិក ROV ៖ បានសួរពីការយល់ឃើញរបស់អ្នកចូលរួមស្តីអំពីលទ្ធភាពទទួលបានផ្នែកភាសា ។
   a. អ្នកចូលរួម៖ បានឆ្លើយតបថាគាត់អាចយល់ភាសាអង់គ្លេសបានក្នុងការសរសេរនិងស្តាប់ ប៉ុន្តែគាត់និយាយមិនបានល្អទេ ។ គាត់អាចនឹងត្រូវការជំនួយការខាងភាសា ។

VI. **លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត**

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*ធាតុចូលជាសាធារណៈ/សំណូរៈ (គ្មាន)*

VII. **ឱកាសផ្សព្វផ្សាយ**

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*ធាតុចូលជាសាធារណៈ/សំណូរៈ*

1. អ្នកចូលរួម៖ បាបានសួរយើងថា ប្រសិនបើមានថវិកា តើយើងអាចចុះទៅដល់សហគមន៍របស់គេដើម្បីធ្វើបទបង្ហាញពី VCA បានទេ?
   a. បុគ្គលិក ROV៖ បានឆ្លើយតបថាយើងអាចទៅកាន់ទីណាក៏បានដែរ ព្រះវិហារ (សាសនាគ្រីស្ទ) វត្តអារាម សាលារៀន ។ល។ ដើម្បីធ្វើបទបង្ហាញជាភាសាវៀតណាមបាន ។
   b. បុគ្គលិក ROV៖ បានសុំឲ្យអ្នកចូលរួមមកចូលរួម និងធ្វើជាអ្នកបកប្រែភាសាវៀតណាមសម្រាប់កិច្ចប្រជុំបន្តបន្ទាប់ ។
   c. អ្នកចូលរួម៖ បាននិយាយថាគាត់រស់នៅឯ Campbell មិនមែននៅ San Jose ទេ ។
   d. បុគ្គលិក ROV៖ បានពន្យល់ថាគាត់អាចមកពីណាក៏បានដែរ ហើយយើងសូមធ្វើការកោតសរសើរចំពោះវត្តមានចូលរួមរបស់គាត់ ។

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara

# ផែនការរដ្ឋបាលបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ជាមួយពលរដ្ឋនិយាយភាសាខ្មែរ

មជ្ឈមណ្ឌលរដ្ឋាភិបាលខោនធី

70 W. Hedding St. San Jose, CA 95110

បន្ទប់ 157

ថ្ងៃអង្គារ៍ទី 18 ខែមិថុនា ឆ្នាំ 2019

ម៉ោង 5:30 ដល់ម៉ោង 7:00 ល្ងាច

### វត្តមានអ្នកចូលរួម៖

អ្នកចូលរួមម្នាក់ជាសាធារណជនមកពីសហាគមន៍ខ្មែរ

### វត្តមានបុគ្គលិកចូលរួម៖

Shannon Bushey, Michael Borja, Vanessa Hamm, Magdalena Sta Maria, Shelby Galaviz, Andrea Solorio, Priscilla Favela, Linh Nguyen, Michelle Tran, Liz Oviedo, Adrian Garcia, Martin Ayala, Bob Nguyen, Paulo Chang, Rachel Jung, April Bracamonte, Janora Davis, Patricia Lopez, Alfred Gonzales

### ចំណុចសកម្មភាព៖

- ពិនិត្យទៅលើសំសំណូមពររបស់អ្នកចូលរួមទាក់ទងទៅនឹងការកៀរគរសហាគមន៍ខ្មែរ៖ តាមវត្តអារាម តាមសង្កាត់ជាក់លាក់ និងនៅតាមកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ។

I. **សេចក្តីណែនាំ**

*ការស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់គេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីសុំបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

## III. គោលដៅនៃផែនការរដ្ឋបាលបោះឆ្នោត

ផែនការរដ្ឋបាលបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តន៍ការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហាគមន៍ ។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

*ធាតុចូលជាសាធារណៈ/សំណូរ៖*

អ្នកចូលរួម៖ បានសំណូមពរឲ្យដាក់មណ្ឌលបោះឆ្នោតនៅតាមវត្តអារាម ដើម្បីបង្កើនការចូលរួមបោះឆ្នោតនៅតាមសហាគមន៍ខ្មែរ ។

## V. លទ្ធភាពទទួលបានផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍ នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហាគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*ធាតុចូលជាសាធារណៈ/សំណូរ៖*

1. អ្នកចូលរួម៖ ការបកប្រែនៅលើបណ្ណព័ត៌មានលក្ខណៈត្រង់ៗពេក ហើយមិនបានបញ្ជូនសារដែលចង់ផ្តល់បានត្រឹមត្រូវ ។
    a. បុគ្គលិក ROV ៖ យើងនឹងជួលអ្នកជំនាញបោះឆ្នោតដែលចេះនិយាយពីរភាសាជាភាសាខ្មែរ ។

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*ធាតុចូលជាសាធារណៈ/សំណូរ៖*

អ្នកចូលរួម៖ សំណូមពរធ្វើការផ្សព្វផ្សាយនៅក្នុងសហគមន៍ខ្មែរដោយចូលជួបតាមខ្នងផ្ទះនៅក្នុងសង្កាត់ ដើម្បីរកឲ្យឃើញពលរដ្ឋវ័យចាស់ជរានៅក្នុងសហគមន៍ ដឹកជញ្ជូនពួកគេ ដឹកពួកគេទៅចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ និងដឹកជញ្ជូនពួកគេទៅកាន់មណ្ឌលបោះឆ្នោត ។

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*ធាតុចូលជាសាធារណៈ/សំណូរ៖*

អ្នកចូលរួម៖ បានសំណូមពរឲ្យមានការផ្សព្វផ្សាយធ្វើឡើងនៅតាមសហគមន៍ខ្មែរ បើមិនអញ្ជើងទេពួកគេនឹងមិនចូលរួមទេ ។ បានសំណូមពរឲ្យមានការផ្សព្វផ្សាយនៅតាមវត្តអារាម និងសង្កាត់ដែលមានចំនួនប្រជាជនច្រើននៅ East San Jose ជាពិសេសសង្កាត់ក្បែរៗ Poco Way, Rockspring, និង Santee ។ ក៏បានសំណូមពរដល់ ROV ឲ្យធ្វើការផ្សព្វផ្សាយជាសាធារណៈនៅឯកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ។

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

# ផែនការរដ្ឋបាលបោះឆ្នោត (EAP)

## កំណត់ហេតុកិច្ចប្រជុំពិគ្រោះយោបល់ជាភាសាតាកាឡុក

បណ្ណាល័យ Milpitas

160 N. Main St., Milpitas, CA 95035

សាលប្រជុំ

ថ្ងៃសុក្រ ទី21 ខែមិថុនា ឆ្នាំ 2019

ម៉ោង 4:30 ដល់ម៉ោង 6:00 ល្ងាច

**វត្តមានអ្នកចូលរួម៖**

សមាជិកប្រាំបីរូបពីសាធារណជនដែលមកពីសហគមន៍នៃភាសាតាកាឡុក៖

**វត្តមានបុគ្គលិកចូលរួម៖**

Shannon Bushey, Rachel Jung, Aaron Wong, Vanessa Hamm, Christina Rivas-Louie, Andrea Solorio, Shelby Galaviz, Priscilla Favela, Linh Nguyen, Allen Ocampo, Paulo Chang, Eric Kurhi, Alfred Gonzalez, Janora Davis

**ចំណុចសមកម្មភាព៖**

- ពិនិត្យតាមដានអ្នកចូលរួមពាក់ព័ន្ធនឹងឱកាសផ្សព្វផ្សាយ ដូចជាការប្រារព្ធពិធីបេតិកភណ្ឌវប្បធម៌ហ្វីលីពីន និងពិធីទិវាឯករាជ្យប្រទេសហ្វីលីពីន នៅក្នុងទីក្រុង Milpitas ។
- ពិនិត្យតាមដានជាមួយអ្នកចូលរួមពាក់ព័ន្ធនឹងអង្គការមិនរកប្រាក់កម្រៃរបស់ហ្វីលីពីនផ្សេងៗដែលអាចធ្វើការផ្សព្វផ្សាយតាមរយៈគេហទំព័រ ការផ្ញើទីផ្សារតាមអ៊ីម៉ែល ឬបណ្ដាញសង្គមផ្ទាល់ខ្លួនរបស់ពួកគេ ។
- បន្ថែមទំនាក់ទំនងពីប័ណ្ណអត្ថប្រយោជន៍ដែលបានផ្ដល់ជូនទៅលើតារាងបែងចែកដែលត្រូវផ្ញើតាមអ៊ីម៉ែលពាក់ព័ន្ធទៅនឹងសម្ព័ន្ធអប់រំ និងផ្សព្វផ្សាយអ្នកបោះឆ្នោត ។
- ផ្ដល់ឯកសារឌីជីថលថតចម្លងនៃខិត្តប័ណ្ណផ្សព្វផ្សាយទៅដល់អ្នកចូលរួម ដើម្បីឲ្យពួកគេអាចបង្ហោះផ្សាយទៅលើបណ្ដាញសង្គមរបស់ពួកគេផងដែរ ។
- បន្ថែមរាល់ឯកសារផ្សព្វផ្សាយឌីជីថលទាំងអស់ទៅលើគេហទំព័រសម្រាប់សហគមន៍/អង្គការនានាដើម្បីស្វែងរក និងទាញយកឯកសារសម្រាប់ការអប់រំអ្នកបោះឆ្នោត ។

**ខ្លឹមសាររបៀបវារៈ**

I. **ការណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ ការទម្លាក់សន្លឹកឆ្នោត

របស់គេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីធ្វើការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*បទបង្ហាញរបស់ ROV៖*

1. បទបង្ហាញស្តីពី VCA ត្រូវបានផ្តល់ជូន ។
2. បុគ្គលិក ROV បានពន្យល់ VCA និងកាលវិភាគ EAP និងគោលដៅនានា ដោយបានសង្កត់ធ្ងន់លើការប្រមូលយកមតិចូលរួម ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ បានសួរថា  តើការបោះឆ្នោតខែមីនាធ្វើឡើងនៅពេលណា?
   a. បុគ្គលិក ROV៖ ថ្ងៃទី3ខែមីនា ។ គ្មានការបោះឆ្នោតខែមិថុនាតទៅទៀតទេនៅពេលនេះ ។
2. អ្នកចូលរួម៖ អ្នកនឹងផ្ញើសន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ទៅដល់មនុស្សគ្រប់គ្នា ។ តើប្រជាពលរដ្ឋអាចចូលទៅកាន់កន្លែងបោះឆ្នោតដើម្បីធ្វើការបោះឆ្នោត និងមានការចាក់ផ្សាយតាមទូរទស្សន៍ដែរឬទេ?
   a. បុគ្គលិក ROV៖ ប្រជាពលរដ្ឋអាចទៅកាន់មណ្ឌលបោះឆ្នោត និងធ្វើការបោះឆ្នោតបាន ។ មិនចាំបាច់ទៅកាន់កន្លែងបោះឆ្នោតដែលបានកំណត់ដូចកាលពីមុនទៀតនោះទេ នៅពេលនេះអ្នកបោះឆ្នោតអាចទៅកាន់មណ្ឌលបោះឆ្នោតណាមួយ និងធ្វើការបោះឆ្នោតបាន ។ នឹងមានប្រព័ន្ធបោះឆ្នោតថ្មីមួយ ដែលមានបញ្ជីឈ្មោះបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក ឬថេបឡេត ជំនួសឲ្យបញ្ជីឈ្មោះជាក្រដាស ។ ថេបឡេតទាំងនេះ នឹងយកទៅប្រើប្រាស់ដើម្បីស្វែងរកអ្នកបោះឆ្នោត និងពិនិត្យមើលថាតើសន្លឹកឆ្នោតតាមសំបុត្រប្រៃសនីយ៍បានប្រគល់ត្រឡប់មកវិញឬអត់ ។ យើងអាចចាត់ទុកជាមោឃៈនូវសន្លឹកឆ្នោតចាស់ៗ និងប្រគល់សន្លឹកឆ្នោតថ្មីជាភាសាណាមួយក្នុងចំណោមភាសាទាំងប្រាំបួនដោយប្រើប្រាស់ម៉ាស៊ីនព្រីនសន្លឹកឆ្នោតថ្មីតាមការចង់បាន ។
3. អ្នកចូលរួម៖ តើ SOS មានកាលបរិច្ឆេទកំណត់សម្រាប់ឯកសារពង្រាងចុងក្រោយនេះដែរឬទេ? តើមានកាលៈទេសៈណាមួយដែលឯកសារនេះ នឹងនៅមិនទាន់សម្រេចបញ្ចប់នៅត្រឹមខែកុម្ភៈនេះដែរឬទេ?
   a. បុគ្គលិក ROV៖ ការផ្លាស់ប្តូរកាលបរិច្ឆេទបោះឆ្នោតពីខែមិថុនាដល់ខែមីនា មិនបានផ្លាស់ប្តូរកាលបរិច្ឆេទកំណត់ថា  តើពេលណាអ្វីៗគ្រប់យ៉ាងត្រូវដល់ពេលកំណត់នោះទេ? គោលដៅរបស់យើងគឺត្រូវទទួលបានឯកសារពង្រាងដែលបានឯកភាពពេញលេញនៅត្រឹមដំណាច់ឆ្នាំនេះ  ។
4. អ្នកចូលរួម៖ ខោនធី Santa Clara (SCC) ជាប្រវត្តិសាស្ត្រតែងស្ថិតនៅក្នុងបណ្តាខោនធីចុងក្រោយដែលត្រូវរាយការណ៍អំពីលទ្ធផលរបស់ពួកគេ ។ ជាមួយនឹងការផ្លាស់ប្តូរទាំងអស់ដែលត្រូវអនុវត្ត តើ ROV មានបុគ្គលិកគ្រប់គ្រាន់ដែរឬទេ? ជាមួយនឹងសម្ភារៈបរិក្ខារថ្មីៗ តើមានចំនួនពេលវេលាសមស្របសម្រាប់ការធ្វើតេស្តសាកល្បងដែរឬទេ? តើ ROV ត្រូវបានរៀបចំឡើងដើម្បីឲ្យប្រាកដថា SCC មិនមែនជាខោនធីចុងក្រោយដែលត្រូវរាយការណ៍អំពីលទ្ធផលនោះទេ? ជាពិសេសជាមួយនឹងសម្ភារៈបរិក្ខារថ្មីៗ ចាំបាច់ត្រូវការពេលវេលាច្រើនសម្រាប់ការផ្លាស់ប្តូរទាំងនេះ ។
   a. បុគ្គលិក ROV៖ យើងគឺជាស្ថាប័នចុងក្រោយ  ដោយសារតែប្រព័ន្ធរាប់សំឡេងឆ្នោតមណ្ឌលកណ្តាលរបស់យើង; អ្នកដែលមកបោះឆ្នោតមុនគេ ត្រូវបានរាប់នៅមណ្ឌលបោះឆ្នោតនោះ ។ ខោនធីមួយចំនួនធ្វើការរាប់សន្លឹកឆ្នោតនៅមណ្ឌលបោះឆ្នោត ជាកន្លែងដែលពួកគេរាប់ចំនួនសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ។ ដុំផ្ទុកទិន្នន័យលទ្ធផល នឹងត្រូវបញ្ជូនត្រឡប់ទៅកាន់ការិយាល័យកណ្តាលដើម្បីធ្វើការផ្ទេរទិន្នន័យ  ។ ការរាប់សន្លឹកឆ្នោតមណ្ឌលកណ្តាល មានន័យថារាល់សន្លឹកឆ្នោតទាំងអស់ត្រូវទៅកាន់កន្លែងមណ្ឌលកណ្តាលដើម្បីធ្វើការរាប់ចំនួន ។ គណៈកម្មការគ្រប់គ្រងខោនធី Santa Clara បានជ្រាបថាយើងតែងស្ថិតនៅក្នុងចំណោមខោនធីចុងក្រោយដែលត្រូវរាយការណ៍អំពីលទ្ធផលរបស់ពួកយើងថាតើយើងត្រូវបន្តស្ថិតនៅជាមួយប្រព័ន្ធរាប់សំឡេងឆ្នោតមណ្ឌលកណ្តាលទៀតឬយ៉ាងណា ។
   b. បុគ្គលិក ROV៖ ROV ចំណាយពេលច្រើន និងខិតខំប្រឹងប្រែងដើម្បីធានាថាសន្លឹកឆ្នោតត្រូវបានធ្វើការរាប់ចំនួនឲ្យបានឆាប់តាមដែលអាចធ្វើបាន ។ យើងមានម៉ាស៊ីនរាប់សន្លឹកឆ្នោតចំនួន 18 គ្រឿងដែល

ការរាប់ចំនួនបន្តរហូតដល់រយៈពេល 24 ម៉ោងក្នុងមួយថ្ងៃ ។ ការបោះឆ្នោតចុងក្រោយមានប័ណ្ណសន្លឹកឆ្នោតដែលត្រូវរាប់ចំនួន ដែលបង្កើននូវចំនួនពេលវេលាត្រូវការចាំបាច់ដើម្បីរាប់ចំនួន ។

c. បុគ្គលិក ROV៖ យើងនឹងទទួលបានប្រព័ន្ធបោះឆ្នោតថ្មីមួយ ដែលនឹងមានការរាប់ចំនួននៅតាមមណ្ឌលបោះឆ្នោត ដូច្នេះវាអាចជួយយើងផ្តល់នូវលទ្ធផលបោះឆ្នោតនៅពេលយប់ បោះឆ្នោតបានយ៉ាងឆាប់រហ័សជាងមុន ។ អ្នកបោះឆ្នោត នឹងធ្វើការស្កេនសន្លឹកឆ្នោតរបស់ពួកគេនៅក្នុងមណ្ឌលបោះឆ្នោត ធ្វើការបោះឆ្នោត ហើយសំឡេងឆ្នោតរបស់គេនឹងត្រូវរៀបជាតារាងនៅក្នុងមណ្ឌលបោះឆ្នោត ។ នៅយប់បោះឆ្នោត លទ្ធផលពីមណ្ឌលបោះឆ្នោតនឹងត្រូវប្រមូលទុកទៅក្នុងការិយាល័យកណ្តាល ហើយសន្លឹកឆ្នោតនឹងមិនចាំបាច់ធ្វើការរាប់ចំនួនតទៅទៀតនោះទេ នៅទីតាំងមណ្ឌលកណ្តាលនៅយប់បោះឆ្នោតដោយផ្ទាល់ ។

5. អ្នកចូលរួម៖ តើអ្នកគិតថាប្រជាពលរដ្ឋនឹងមានពេលវេលាគ្រប់គ្រាន់ដើម្បីយល់ដឹងរាល់ការផ្លាស់ប្តូរទាំងអស់ រួមទាំងប្រព័ន្ធបោះឆ្នោតថ្មីដែរឬទេ?
    a. បុគ្គលិក ROV៖ ពិតមែនហើយ ។ នឹងមានបុគ្គលិកនៅមណ្ឌលបោះឆ្នោតនៅពេលពួកគេ មកផ្តល់ជំនួយដល់អ្នកបោះឆ្នោតឲ្យប្រើប្រាស់ប្រព័ន្ធនេះយ៉ាងត្រឹមត្រូវ ។ ប្រព័ន្ធបោះឆ្នោតថ្មីមិនទាន់ដាក់ឲ្យប្រើប្រាស់នៅឡើយទេ ប៉ុន្តែគេរំពឹងថាត្រូវរៀបចំកិច្ចសន្យាឲ្យបានរួចរាល់សម្រាប់គណៈកម្មការគ្រប់គ្រងឲ្យចុះហត្ថលេខានៅខែសីហា ។ បន្ទាប់ពីនោះមក សម្ភារៈបរិក្ខារទាំងនោះត្រូវចាប់ផ្តើមយកមកធ្វើតេស្តសាកល្បងទទួលយក ។
    b. បុគ្គលិក ROV៖ យើងបាននិងកំពុងធ្វើការងារលើបញ្ហានេះអស់ពេលមួយរយៈហើយនៅពេលនេះ ។ យើងបានចាប់ផ្តើមធ្វើផែនការកាលពីដើមឆ្នាំនេះ ហើយបានរង់ចាំតែការអនុម័តចុងក្រោយតែប៉ុណ្ណោះពីគណៈកម្មការគ្រប់គ្រង មុនពេលបន្តអនុវត្ត ។ ការអនុម័តត្រូវបានធ្វើឡើងនៅថ្ងៃទី9ខែមេសា ។ យើងកំពុងធ្វើលទ្ធកម្មលើបទពិសោធន៍បោះឆ្នោតថ្មីមួយ ។ ជាមួយនឹងការផ្លាស់ប្តូរទាំងនេះ វានឹងមិនមានលក្ខណៈល្អឥតខ្ចោះនោះទេ ប៉ុន្តែយើងព្យាយាមកាត់បន្ថយជាអតិបរមានូវភាពរអាក់រអួលនៅក្នុងការអនុវត្តនេះ ។
6. អ្នកចូលរួម៖ តើមានខោនធីផ្សេងទៀតចំនួនប៉ុន្មាន ដែលបាននិងកំពុងប្រើប្រាស់ការដំឡើងកម្មវិធីដូចគ្នានេះ?
    a. បុគ្គលិក ROV៖ ជាងពាក់កណ្តាលនៃខោនធីដែលមានប្រព័ន្ធបោះឆ្នោតថ្មី និងខោនធីចំនួនប្រាំទៀតដែលបានផ្លាស់ប្តូរទៅរក VCA នៅក្នុងឆ្នាំ2018 ។
7. អ្នកចូលរួម៖ តើភាពជោគជ័យរបស់ពួកគេមានកម្រិតណា?
    a. បុគ្គលិក ROV៖ វាមានភាពលំបាកក្នុងការកំណត់និយមន័យភាពជោគជ័យ ដោយសារចំនួនអ្នកចូលរួមបោះឆ្នោត គឺភាគច្រើនអាស្រ័យទៅលើការប្រកួតប្រជែងនៅលើសន្លឹកឆ្នោត ។
8. អ្នកចូលរួម៖ តើអ្នកមានស្ថិតិ ទិន្នន័យប្រជាសាស្ត្រដើម្បីកត់ត្រាតាមដានពីភាពជោគជ័យរបស់ VCA ដែរឬទេ? ប្រសិនបើអ្នកមានស្ថិតិពីការបោះឆ្នោតពីមុនមក នោះអាចប្រើប្រាស់ដើម្បីកំណត់ពីភាពជោគជ័យរបស់ VCA បាន ។
    a. បុគ្គលិក ROV៖ យើងមានស្ថិតិ ប៉ុន្តែយើងមានការកំណត់ថាតើព័ត៌មានរបស់អ្នកបោះឆ្នោតអ្វីខ្លះដែលបានមកពីទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត ។
    b. បុគ្គលិក ROV៖ មានស្ថិតិអ្នកចូលរួមបោះឆ្នោតពីរបាយការណ៍លទ្ធផលឆ្នោតដែលផ្តល់ជូនដោយមណ្ឌលបោះឆ្នោត និងទីក្រុង ។
9. អ្នកចូលរួម៖ ស្នើសុំប្រើប្រាស់ស្ថិតិដើម្បីប្រើប្រាស់ជាមូលដ្ឋាន ដូចជាសម្រាប់កញ្ចប់ថវិកាជាដើម ។
    a. បុគ្គលិក ROV៖ យើងមានរបាយការណ៍ក្រោយការបោះឆ្នោតដែលរៀបរាប់អំពីស្ថិតិភាសា ។
10. អ្នកចូលរួម៖ តើអ្នកអាចស្វែងរករបាយការណ៍ក្រោយការបោះឆ្នោតនៅកន្លែងណា? ខ្ញុំគ្រាន់តែអាចស្វែងរករបាយការណ៍មណ្ឌលបោះឆ្នោតតែប៉ុណ្ណោះ ។
    a. បុគ្គលិក ROV៖ វាគឺស្ថិតនៅលើគេហទំព័ររបស់យើង នៅក្រោមរបាយការណ៍ និងស្ថិតិ ។ របាយការណ៍ក្រោយការបោះឆ្នោត គឺជារបាយការណ៍បំពេញបន្ថែមដែលយើងបង្កើតឡើងផ្អែកលើអ្វីដែលបានកើតឡើងនៅក្នុងការបោះឆ្នោតពីមុនមក ។ របាយការណ៍ក្រោយការបោះឆ្នោតខែវិច្ឆិកាមិនទាន់បានបិទផ្សាយនៅឡើយ ប៉ុន្តែការបោះឆ្នោតខែមិថុនាគឺមានបិទផ្សាយលើគេហទំព័រនេះ ។

b. បុគ្គលិក ROV៖ របាយការណ៍ខែវិច្ឆិកានឹងផ្សព្វផ្សាយក្នុងពេលឆាប់ៗនេះ ។ របាយការណ៍ក្រោយការបោះឆ្នោត គឺជារបាយការណ៍ល្អបំផុតដែលពន្យល់អំពីបច្ចេកសព្ទជាច្រើនដូចជា "តើមណ្ឌលបោះឆ្នោតជាអ្វី?" ឬ "តើការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ជាអ្វី?" វាមានស្ថិតិ ហើយស្ថិតិទាំងអស់នោះ គឺជាតួលេខដែលយើងអាចប្រើប្រាស់សម្រាប់ធ្វើការប្រៀបធៀបនៅពេលអនាគត ។

c. អ្នកចូលរួម៖ ទទួលបានស្ថិតិជាមុន គឺជាមូលដ្ឋានដ៏ល្អនៅក្នុងការកំណត់ការកែលម្អ និងបន្តកិច្ចដំណើរការ ។

d. បុគ្គលិក ROV៖ យើងចាំបាច់ត្រូវចងចាំថាការចូលរួមបោះឆ្នោត គឺពឹងផ្អែកខ្លាំងទៅលើការប្រកួតប្រជែងនៅលើសន្លឹកឆ្នោត ។

11. អ្នកចូលរួម៖ តើអ្នកមានទំនាក់ទំនងជាមួយខោនធីទាំងប្រាំនេះដែរឬទេ?

 a. បុគ្គលិក៖ យើងបាននិងកំពុងពិភាក្សាជាមួយខោនធីផ្សេងទៀតអស់រយៈពេលមួយឆ្នាំមកហើយ ។ បុគ្គលិកបានជួបជុំគ្នា និងបានពិភាក្សាជាមួយបុគ្គលិកបោះឆ្នោតនៅក្នុងខោនធី Sacramento ខោនធី San Mateo និងខោនធី Napa ។ យើងរក្សាទំនាក់ទំនងជាបន្តជាមួយរដ្ឋ ដោយធ្វើការហៅទូរសព្ទរយៈពេលបីម៉ោង ម្តងក្នុងមួយខែ ដោយព្យាយាមធ្វើការស្វែងយល់អំពីអ្វីគ្រប់យ៉ាងដែលអាចធ្វើបាន ។ យើងបានស្វែងយល់ថាយើងចាំបាច់ត្រូវស្តាប់ដំណឹងពីសហគមន៍របស់យើង ហើយនោះជាមូលហេតុដែលយើងមានវត្តមាននៅទីក្រុង Milpitas នៅពេលនេះ ។

12. អ្នកចូលរួម៖ ក្នុងចំណោមខោនធីជាច្រើននៅក្នុងរដ្ឋ California តើមានខោនធីចំនួនប៉ុន្មានប្រើប្រាស់ប្រព័ន្ធរាប់សន្លឹកឆ្នោតតាមមណ្ឌលបោះឆ្នោត ហើយតើមានខោនធីចំនួនប៉ុន្មានប្រើប្រាស់ប្រព័ន្ធរបស់សន្លឹកឆ្នោតមណ្ឌលកណ្តាល?

 a. បុគ្គលិក ROV៖ ខោនធីចំនួន 13 នឹងធ្វើ VCA នៅត្រឹមឆ្នាំ2020 ដែលមានចំនួនស្មើនឹង 50% នៃប្រជាជនបោះឆ្នោតរបស់រដ្ឋ ។ ជាមួយនឹងប្រព័ន្ធបោះឆ្នោតថ្មី លទ្ធផលយប់បោះឆ្នោតនឹងមានភាពឆាប់រហ័ស ប៉ុន្តែរយៈពេលត្រួតពិនិត្យសន្លឹកឆ្នោត នឹងត្រូវចំណាយពេលដូចគ្នា។ នីតិវិធីរាប់សន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ នឹងបន្តអនុវត្តដដែល ដូច្នេះពេលវេលាអនុវត្តនីតិវិធីនឹងមិនមានការប្រែប្រួលនោះទេ ។ វាគឺជានីតិវិធីរាប់ដោយដៃ ដែលមានជាប់ពាក់ព័ន្ធនឹងការបើកស្រោមសំបុត្រ និងតម្រៀបសន្លឹកឆ្នោតមុនពេលរាប់ចំនួន ។

 b. បុគ្គលិក ROV៖ ផ្អែកលើព័ត៌មានបានមកពីរដ្ឋមន្ត្រីក្រសួងការបរទេស ខោនធីចំនួន 27 ក្នុងចំណោមខោនធីចំនួន 58 ស្មើនឹងប្រមាណ 47% បានប្រើប្រាស់ប្រព័ន្ធរៀបតាមតារាងនៅមណ្ឌលកណ្តាល ។

13. អ្នកចូលរួម៖ ទោះបីជាមានប្រព័ន្ធថ្មី និងមធ្យោបាយថ្មីសម្រាប់ការអនុវត្តយ៉ាងណាក៏ដោយ តើនីតិវិធីដោយដៃនៅតែបន្តមានវត្តមានដែរឬទេ?

 a. បុគ្គលិក ROV៖ ពិតជាមាន ។ ពាក់ព័ន្ធនឹងល្បឿននៃការរាយការណ៍នៅយប់បោះឆ្នោត យើងមានភាពយឺតយ៉ាវជាងមុន ដោយសារតែប្រព័ន្ធបោះឆ្នោតរបស់យើង ប៉ុន្តែនៅខែវិច្ឆិកា ឆ្នាំ2018 យើងមានកម្រិតល្បឿននៃការរាប់សន្លឹកឆ្នោតឆាប់រហ័សជាងមុន ដែលនាំឆ្ពោះទៅរក E+30 ឬបញ្ចប់រយៈពេលត្រួតពិនិត្យសន្លឹកឆ្នោត ។

 b. បុគ្គលិក ROV៖ ប្រព័ន្ធបោះឆ្នោតថ្មីនឹងផ្តល់នូវភាពងាយស្រួលជាងមុនសម្រាប់អ្នកបោះឆ្នោត ហើយតាមរយៈ VCA ប្រជាពលរដ្ឋប្រហែលជាមានចំនួនច្រើនជាងមុន នឹងធ្វើការបោះឆ្នោតដោយសារតែមនុស្សគ្រប់គ្នានឹងផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ ហើយនឹងលែងមានកន្លែងបោះឆ្នោត "ខុសទីតាំង" សម្រាប់ប្រជាពលរដ្ឋត្រូវទៅបោះឆ្នោតតទៅទៀត ។ម្យ៉ាងទៀត ជំនួសឲ្យមណ្ឌលបោះឆ្នោតដែលបានកំណត់គោលដៅ ជាមួយនឹងការគាំទ្រផ្នែកភាសាកាតាឡុក គោលដៅនេះគឺត្រូវឲ្យមណ្ឌលបោះឆ្នោតគ្រប់ទីតាំងទាំងអស់មានការគាំទ្រផ្នែកភាសាកាតាឡុក ។ ដូច្នេះនឹងមានការគាំទ្រផ្នែកភាសា ច្រើនជាងមុននៅគ្រប់មណ្ឌលទាំងអស់ គ្មានកន្លែងបោះឆ្នោតខុសទីតាំងឡើយ មានអត្ថប្រយោជន៍ច្រើននៅខាងភាគីអ្នកបោះឆ្នោត ។

c. បុគ្គលិក ROV៖ ទាំងអស់នេះនឹងត្រូវចំណាយប្រាក់ច្រើន ប៉ុន្តែយើងកំពុងព្យាយាមសន្សំសំចៃតាមលទ្ធភាពដែលយើងអាចធ្វើបាន។ យើងកំពុងធ្វើការជួល ជំនួសឲ្យការទិញសម្ភារៈបរិក្ខារថ្មីៗ ហើយយើងនឹងទទួលបានប្រាក់ $5.5 លានដើម្បីជួយធ្វើការទូទាត់សម្រាប់ប្រព័ន្ធនេះ ។

14. អ្នកចូលរួម៖ តើយើងកំពុងធ្វើអ្វីខ្លះ សម្រាប់អន្តរាគមន៍បរទេស?

a. បុគ្គលិក ROV៖ យើងកំពុងធ្វើការងារជាមួយក្រសួងសន្តិសុខមាតុភូមិ ក៏ដូចជាទីភ្នាក់ងារសហព័ន្ធ រដ្ឋ និងខោនធី ដើម្បីឲ្យប្រាកដថាការបោះឆ្នោតនេះមានសុវត្ថិភាព ។ យើងអនុវត្តការធ្វើតេស្តសាកល្បងលើការជ្រាតចូលតាមប្រព័ន្ធអ៊ីនធឺណែត បច្ចេកវិទ្យាស៊ើបព័ត៌មានសម្ងាត់ថ្មីដែលបានដំឡើង ។ល។ ជំនួយគាំទ្រផ្នែក IT របស់យើង គឺជាជំនួយគាំទ្រដ៏ល្អបំផុត ។ យើងមិនធ្លាប់មានបញ្ហាណាមួយជាមួយនឹងខោនធីរបស់យើងឡើយ ។ លទ្ធផលរបស់យើងមិនអាចមានការប្រែប្រួលដោយអ្នកខាងក្រៅបានឡើយ ដោយសារតែម៉ាស៊ីនបែងចែកសន្លឹកឆ្នោតរបស់យើងមិនបានតភ្ជាប់ជាមួយបណ្តាញអ៊ីនធឺណែតឡើយ ។ យើងទទួលបានលទ្ធផលរបស់យើងពីវា ហើយនោះជាអ្វី ដែលយើងយកទៅកាន់កុំព្យូទ័រដើម្បីធ្វើការផ្ទេរទិន្នន័យ ។

15. អ្នកចូលរួម៖ ចុះចំណែកការហេកចូលតាមប្រព័ន្ធអ៊ីនធឺណែតវិញ?

a. បុគ្គលិក ROV៖ យើងមានការធ្វើតេស្តសាកល្បងការជ្រាតចូលតាមប្រព័ន្ធអ៊ីនធឺណែត ហើយគ្មាននរណាម្នាក់អាចជ្រាតចូលបានឡើយ ។ យើងផ្តល់នូវការបណ្តុះបណ្តាលលើការស៊ើបយកព័ត៌មានសម្ងាត់ទៅដល់បុគ្គលិកផងដែរ ហើយផ្តល់នូវការព្រមានផ្នែកសុវត្ថិភាពជូនដល់គ្រប់ជាន់ថ្នាក់ទាំងអស់ ។

16. អ្នកចូលរួម៖ នៅពេលណាទើបអ្នកទទួលបានសន្លឹកឆ្នោតបណ្តោះអាសន្ន?

a. បុគ្គលិក ROV៖ តាមរយៈ VCA សន្លឹកឆ្នោតបណ្តោះអាសន្ននឹងមានផ្តល់ជូនមនុស្សគ្រប់គ្នាដែលចង់ប្រើប្រាស់សិទ្ធិក្នុងការបោះឆ្នោត ប៉ុន្តែយើងមិនអាចផ្ទៀងផ្ទាត់ការចុះឈ្មោះរបស់ពួកគេបានទេ (ឧ.ទា. នៅក្រៅខោនធី នៅក្រៅរដ្ឋ ។ល។)

b. បុគ្គលិក ROV៖ ការចុះឈ្មោះអ្នកបោះឆ្នោតដោយមានលក្ខខណ្ឌ គឺសម្រាប់អ្នកបោះឆ្នោតដែលមានបំណងចុះឈ្មោះនៅថ្ងៃនោះ ហើយធ្វើការបោះឆ្នោតតែម្តង ។

c. បុគ្គលិក ROV៖ សន្លឹកឆ្នោតទាំងនេះនឹងត្រូវចាត់នីតិវិធីជាបន្តក្រោយការបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

d. បុគ្គលិក ROV៖ យើងរំពឹងថានឹងទទួលបានសន្លឹកឆ្នោតបណ្តោះអាសន្នក្នុងចំនួនតិចតួចបំផុតតាមរយៈ VCA ។ មុនពេល VCA សន្លឹកឆ្នោតបណ្តោះអាសន្នត្រូវបានផ្តល់ជូនប្រជាពលរដ្ឋដែលបានបោះឆ្នោតក្រៅមណ្ឌលបោះឆ្នោតដែលបានកំណត់របស់ពួកគេ ។ ឧទាហរណ៍ ប្រសិនបើអ្នកបោះឆ្នោតណាម្នាក់នៅទីនេះ (ទីក្រុង Milpitas) ប៉ុន្តែពួកគេបានធ្វើការងារនៅក្នុងទីក្រុង Palo Alto ។ ប្រសិនបើពួកគេមិនមានឱកាសត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ហើយធ្វើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលបានកំណត់ ពួកគេនៅតែបន្តមានសិទ្ធិធ្វើការបោះឆ្នោត ហើយអាចធ្វើការបោះឆ្នោតនៅក្នុងទីក្រុង Palo Alto បាន ។ នោះជាពេលដែលពួកគេអាចធ្វើការបោះឆ្នោតបណ្តោះអាសន្នបាន ។ ប៉ុន្តែតាមរយៈ VCA និងលទ្ធភាពដែលអ្នកអាចធ្វើការបោះឆ្នោតបាននៅគ្រប់ទីកន្លែងនៅក្នុងខោនធី ករណីអ្នករស់នៅក្នុងទីក្រុង Palo Alto នោះអ្នកមានសេរីភាពធ្វើទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតនៅក្នុងឬក្បែរទីក្រុង Palo Alto ហើយអ្នកអាចធ្វើការបោះឆ្នោតទៅលើសន្លឹកឆ្នោតណាមួយដែលមានការប្រកួតប្រជែងជាក់លាក់នៅក្នុងទីក្រុង Milpitas បាន ។ នេះនឹងកាត់បន្ថយគួរឲ្យកត់សម្គាល់នូវចំនួនអ្នកបោះឆ្នោតបណ្តោះអាសន្ន ។

e. បុគ្គលិក ROV៖ CVR គឺជាជម្រើសដ៏ល្អបំផុតផ្សេងទៀត ករណីដែលអ្នកមិនមានឱកាសក្នុងការចុះឈ្មោះមុនពេលកាលបរិច្ឆេទកំណត់ទេ អ្នកអាចចូលទៅកាន់មណ្ឌលបោះឆ្នោតណាមួយ រួចបំពេញពាក្យសុំចុះឈ្មោះ ទទួលបានសន្លឹកឆ្នោត បោះឆ្នោតលើសន្លឹកឆ្នោតនោះ ភ្ជាប់នៅក្នុងស្រោមសំបុត្រ ហើយធ្វើការបោះឆ្នោត ។ នៅពេលស្រោមសំបុត្រទៅដល់ការិយាល័យរបស់យើង យើងធ្វើការផ្ទៀងផ្ទាត់នូវសិទ្ធិរបស់បុគ្គលក្នុងការបោះឆ្នោត ហើយប្រសិនបើពួកគេអាចបោះឆ្នោតបាន ពេលនោះយើងនឹងរាប់សន្លឹកឆ្នោតរបស់ពួកគេ ។

f. បុគ្គលិក ROV៖ នៅមុន VCA អ្នកទាំងឡាយដែលមិនអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតតាមលំនៅដ្ឋានរបស់ពួកគេ ពួកគេទាំងអស់នោះត្រូវតែធ្វើការបោះឆ្នោតបណ្ដោះអាសន្ន ។
g. បុគ្គលិក ROV៖ ការបោះឆ្នោតចុងក្រោយ យើងបានទទួលសន្លឹកឆ្នោតបណ្ដោះអាសន្នប្រហែល 35,000 សន្លឹក ហើយយើងរំពឹងទុកថានឹងមានកាត់បន្ថយចំនួន 90% តាមរយៈ VCA ។

17. អ្នកចូលរួម៖ មណ្ឌលបោះឆ្នោតបើកដំណើរការរយៈពេល 10 មុនការបោះឆ្នោត មែនដែរឬទេ?
   a. បុគ្គលិក ROV៖ មានលក្ខខណ្ឌតម្រូវដោយច្បាប់នៅក្នុងការបើកដំណើរការមណ្ឌលបោះឆ្នោតរយៈពេល 10 ថ្ងៃនៅមុនការបោះឆ្នោត សូមហៅមណ្ឌលទាំងនោះថាជាមណ្ឌលបោះឆ្នោតរយៈពេល 11 ថ្ងៃ ។ គប្បីត្រូវមានមណ្ឌលមួយបើកដំណើរការសម្រាប់អ្នកបោះឆ្នោត 50,000 នាក់ ។ ដូច្នេះត្រូវមានមណ្ឌលបោះឆ្នោតរយៈពេល 11 ថ្ងៃចំនួនពី 20 ទៅ 25 មណ្ឌល ។
   b. បុគ្គលិក ROV៖ យើងក៏មានមណ្ឌលបោះឆ្នោតរយៈពេល 4 ថ្ងៃដែលចាំបាច់ត្រូវបើកដំណើរការរយៈពេល 3 ថ្ងៃមុនការបោះឆ្នោត ។ ចាំបាច់ត្រូវមានមណ្ឌលមួយបើកដំណើរការសម្រាប់អ្នកបោះឆ្នោះចំនួន 10,000 នាក់ មានន័យថាត្រូវមានមណ្ឌលបោះឆ្នោតប្រហែលច្រើនជាង 100 មណ្ឌល ។

18. អ្នកចូលរួម៖ សម្រាប់ការបោះឆ្នោតបឋមនៅខែមីនា តើមានអ្វីកើតឡើងបើខ្ញុំមានបំណងជ្រើសរើសគណៈបក្សនយោបាយណាមួនៅពេលខ្ញុំបោះឆ្នោតនោះ? តើខ្ញុំចាំបាច់ត្រូវទៅកាន់មណ្ឌលបោះឆ្នោតដែរឬទេ? តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍បានដែរឬទេ?
   a. បុគ្គលិក ROV៖ អ្នកអាចផ្លាស់ប្ដូរការចុះឈ្មោះរបស់អ្នក ហើយត្រូវធ្វើការបោះឆ្នោតឆ្លងគណៈបក្ស ។ រយៈពេលប្រហែល 135 ថ្ងៃមុនពេលបោះឆ្នោត គណៈបក្សនីមួយៗនឹងប្រាប់យើងថាតើនរណាដែលពួកគេអនុញ្ញាតឲ្យមានការឆ្លងគណៈបក្ស និងត្រូវធ្វើការបោះឆ្នោត ។ ការបោះឆ្នោតបឋមចុងក្រោយ គណៈបក្សនានាដែលបានអនុញ្ញាតមានការឆ្លងគណៈបក្ស ដូចជាគណៈបក្សប្រជាធិបតេយ្យ គណៈបក្សអាមេរិកាំងឯករាជ្យ និងគណៈបក្សអ្នកសេរីនិយម ។
   b. បុគ្គលិក ROV៖ ប្រសិនបើអ្នកមិនមានបក្សសម្ព័ន្ធទេ អ្នកនឹងទទួលបានសន្លឹកឆ្នោតមិនជាប់បក្សសម្ព័ន្ធ ។ បន្ទាប់មក អ្នកបោះឆ្នោតអាចធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោត ប្រគល់សន្លឹកឆ្នោតមិនជាប់បក្សសម្ព័ន្ធ និងស្នើសុំសន្លឹកឆ្នោតពីគណៈបក្សដែលអនុញ្ញាតឲ្យមានការបោះឆ្នោតឆ្លងគណៈបក្ស ។
   c. អ្នកចូលរួម៖ តើអ្នកអាចស្នើសុំសន្លឹកឆ្នោតឆ្លងគណៈបក្សនៅមណ្ឌលបោះឆ្នោតបានដែរឬទេ?
   d. បុគ្គលិក ROV៖ ប្រសិនបើអ្នកជាអ្នកបោះឆ្នោតមិនជាប់បក្សសម្ព័ន្ធ ការផ្ញើសំបុត្រប្រៃសណីយ៍នឹងត្រូវបញ្ជូនដើម្បីសួរថាតើអ្នកមានបំណងធ្វើការបោះឆ្នោតឆ្លងគណៈបក្សដែរឬទេ ។ នៅក្នុងការផ្ញើសំបុត្រប្រៃសណីយ៍នេះ ប្រសិនបើអ្នកបង្ហាញថាអ្នកមានបំណងចង់ធ្វើការបោះឆ្នោតឆ្លងគណៈបក្ស សន្លឹកឆ្នោតមួយសន្លឹកសម្រាប់គណៈបក្សដែលបានស្នើសុំ នឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ជូនអ្នក ។
   e. បុគ្គលិក ROV៖ យើងមានអ្នកបោះឆ្នោតមិនជាប់បក្សសម្ព័ន្ធចំនួន 300,000 នាក់នៅក្នុងខោនធីរបស់យើង ។ ប្រហែល E-135 ឬរយៈពេល 135 ថ្ងៃមុនពេលបោះឆ្នោត គឺនៅពេលដែលរដ្ឋមន្ត្រីក្រសួងការបរទេសអនុញ្ញាតឲ្យពួកយើងដឹងថា តើគណៈបក្សមួយណាដែលអនុញ្ញាតឲ្យមានការបោះឆ្នោតឆ្លងគណៈបក្ស ។ នៅពេលដែលយើងរកឃើញ យើងមានរយៈពេលដ៏ខ្លីមួយក្នុងការបង្កើតសំបុត្រប្រៃសណីយ៍ ។ ជាធម្មតាវាត្រូវចំណាយពេលប្រមាណ 10 ថ្ងៃក្រោយការជូនដំណឹងពី SOS ដើម្បីបង្កើតឯកសារព្រាងដែលត្រូវបញ្ជូនទៅកាន់អ្នកទទួលបន្ទុកសម្រាប់ការព្រីននិងការផ្ញើជូនតាមប្រៃសណីយ៍ ។ សំបុត្រប្រៃសណីយ៍មានសរសេរអាសយដ្ឋានអ្នកបោះឆ្នោតដែលមិនមានជាប់បក្សសម្ព័ន្ធ ហើយផ្ដល់ដំណឹងដល់ពួកគេអំពីគណៈបក្សនានាដែលបើកទូលាយសម្រាប់ការបោះឆ្នោតឆ្លងគណៈបក្សនៅក្នុងការបោះឆ្នោតបឋមនេះ ។

19. អ្នកចូលរួម៖ អ្នកបានលើកឡើងថាខ្ញុំអាចផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ចូលមកបាន ប៉ុន្តែតើនឹងមានអ្វីកើតឡើងបើអ្នកផ្លាស់ប្ដូរចិត្តរបស់ខ្លួន និងមានបំណងចង់បោះឆ្នោតនៅមណ្ឌលបោះឆ្នោតដើម្បីផ្លាស់ប្ដូរសំឡេងឆ្នោតរបស់អ្នក? តើកត់ត្រាតាមដានការផ្លាស់ប្ដូរទាំងនេះដែរឬនៅ? ដូច្នេះអ្នកអាចទៅពិនិត្យមើលថាតើមាននរណាម្នាក់បានបោះឆ្នោតហើយឬនៅ? ចុះចំណែកការបោះឆ្នោតពីលើកវិញ?

a. បុគ្គលិក ROV៖ យើងនឹងចាំបាច់ត្រូវចូលទៅប្រើប្រាស់ប្រព័ន្ធព័ត៌មានការបោះឆ្នោតរបស់យើងនៅមណ្ឌលបោះឆ្នោត ដើម្បីឲ្យយើងអាចស្វែងរកអ្នកបោះឆ្នោត និងពិនិត្យមើលថាតើអ្នកបោះឆ្នោតនោះបានប្រគល់សន្លឹកឆ្នោតហើយឬនៅ ។ ប្រសិនបើពួកគេបានបោះឆ្នោតរួចហើយ យើងមិនអាចអនុញ្ញាតឲ្យអ្នកធ្វើការបោះឆ្នោតសន្លឹកឆ្នោតធម្មតានៅតាមមណ្ឌលបោះឆ្នោតបានឡើយ ។ ប្រសិនបើអ្នកបានបោះឆ្នោតរួចហើយ នោះសន្លឹកឆ្នោត VBM របស់អ្នកនឹងបញ្ជូនមកក្នុងសំបុត្រប្រៃសណីយ៍ ពេលនោះយើងនឹងស្វែងរកឈ្មោះអ្នកនៅក្នុងប្រព័ន្ធ ហើយមើលឃើញថាអ្នកបានបោះឆ្នោតរួចហើយនៅក្នុងមណ្ឌលបោះឆ្នោតនេះ ។ បន្ទាប់មក យើងនឹងមិនរាប់ចំនួនសន្លឹកឆ្នោតដែលទើបតែបញ្ចូលមកតាមរយៈសំបុត្រប្រៃសណីយ៍នោះទេ ។

b. បុគ្គលិក ROV៖ ជាគោលការណ៍ មួយណាមកដល់មុន ជ្រើសយកមុនគេ ។ ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកមកដល់ក្នុងសំបុត្រប្រៃសណីយ៍នេះ យើងនឹងពិនិត្យហត្ថលេខារបស់អ្នក ហើយប្រសិនបើវាត្រឹមត្រូវ ជាស្វ័យប្រវត្តិមានន័យថាអ្នកបានបោះឆ្នោតរួចរាល់ហើយ ។ បន្ទាប់មក បញ្ជីឈ្មោះបោះឆ្នោតអេឡិចត្រូនិកដែលប្រើប្រាស់នៅក្នុងមណ្ឌលបោះឆ្នោតនឹងមកដល់ក្នុងពេលវេលាជាក់ស្តែង ដូច្នេះប្រសិនបើអ្នកបានបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍រួចហើយ ហើយអ្នកបានសម្រេចចិត្តថាត្រូវបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតនេះ វានឹងបង្ហាញថាអ្នកបានបោះឆ្នោតរួចហើយ ។ ក្នុងស្ថានភាពនេះ ប្រសិនបើអ្នកនៅតែទទូចសុំធ្វើការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតទៀត អ្នកអាចនឹងទទួលបានសន្លឹកឆ្នោតបណ្តោះអាសន្ន ។

c. បុគ្គលិក ROV៖ មានស្ថានភាពផ្សេងទៀតដែលអ្នកនឹងត្រូវធ្វើការបោះឆ្នោតជាបណ្តោះអាសន្ន ។ ទោះបីជាបុគ្គលិកមណ្ឌលបោះឆ្នោតនិយាយថាប្រព័ន្ធរបស់យើងបង្ហាញថាអ្នកបានបោះឆ្នោតរួចហើយក៏ដោយ ប្រសិនបើអ្នកបដិសេធសិទ្ធិក្នុងការបោះឆ្នោត អ្នកអាចធ្វើការបោះឆ្នោតនៅលើសន្លឹកឆ្នោតបណ្តោះអាសន្នបាន ។ ក្នុងការិយាល័យរបស់ ROV យើងនឹងពិនិត្យមើលស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នក ដោយសារតែយើងពិនិត្យគ្រប់ស្រោមសំបុត្រ CVR និងសន្លឹកឆ្នោតបណ្តោះអាសន្នទាំងអស់ ហើយប្រសិនបើយើងកំណត់ថាអ្នកបានប្រគល់សន្លឹកឆ្នោតរបស់អ្នករួចហើយ យើងនឹងមិនរាប់ចំនួនសន្លឹកឆ្នោតបណ្តោះអាសន្ននោះទេ ។

d. អ្នកចូលរួម៖ តើខ្ញុំអាចបញ្ជាក់ប្រាប់ថាសន្លឹកឆ្នោតបណ្តោះអាសន្នរបស់ខ្ញុំត្រូវបានរាប់ចំនួនបានដែរឬអត់?

e. បុគ្គលិក ROV៖ មានប្រព័ន្ធអនឡាញមួយដែលអ្នកអាចស្វែងរកលេខស្រោមសំបុត្របណ្តោះអាសន្នរបស់អ្នក និងបញ្ជាក់ប្រាប់ថាវាត្រូវបានរាប់ចំនួនឬអត់ ។

f. អ្នកចូលរួម៖ ដូច្នេះ តើត្រូវរាប់សន្លឹកឆ្នោតចុងក្រោយបំផុតដែលបានមកដល់មែនដែរឬទេ?

g. បុគ្គលិក ROV៖ ទេ ត្រូវរាប់សន្លឹកមួយណាដែលមកដល់មុនគេ ។

h. អ្នកចូលរួម៖ តើមានអ្វីកើតឡើង បើអ្នកផ្លាស់ប្តូរចិត្ត? អ្នកត្រូវបន្តជ្រើសរើសយកជម្រើសដំបូងរបស់អ្នក?

i. បុគ្គលិក ROV៖ ពិតជាមាន ។ យើងមិនអាចធ្វើអ្វីបាននោះទេ ប្រសិនបើសន្លឹកឆ្នោតនោះត្រូវបានគេរាប់រួចរាល់ហើយ។

j. អ្នកចូលរួម៖ វាគឺជាជម្រើសដ៏សំខាន់មួយ ។ ប៉ុន្តែខ្ញុំយល់ពីបញ្ហានេះ ។

20. អ្នកចូលរួម៖ មុនពេលអ្នកអនុញ្ញាតឲ្យមណ្ឌលបោះឆ្នោត និងអ្នកស្ម័គ្រចិត្តចូលមកកាន់កាប់ពួកវា ។ តាមរយៈមណ្ឌលបោះឆ្នោតទាំងនេះ តើមានបុគ្គលិកធ្វើការងារពេញម៉ោងដែរឬទេ?

a. បុគ្គលិក ROV៖ ROV នឹងជួលបុគ្គលិករបស់ខោនធីសម្រាប់ការផ្តល់ជំនួយបន្ថែម និងបុគ្គលិកស្ម័គ្រចិត្តដែលទទួលបានប្រាក់កម្រៃមកធ្វើការងាររួមគ្នា ។ យើងកំពុងព្យាយាមជាបន្តដើម្បីដោះស្រាយបញ្ហានេះ ។ សម្រាប់ជំនួយបន្ថែម គប្បីត្រូវចំណាយពេលធ្វើការងាររយៈពេល 3 សប្តាហ៍ រួមទាំងការបណ្តុះបណ្តាលផងដែរ សម្រាប់បុគ្គលិកមណ្ឌលបោះឆ្នោត ។ បុគ្គលិកជំនួយបន្ថែម ត្រូវតែឆ្លងកាត់នីតិវិធីចូលបម្រើការងាររបស់ខោនធី ហើយយើងជួយគាំទ្រដល់បញ្ហានេះ ។ អ្នកស្ម័គ្រចិត្តដែលទទួលបានប្រាក់កម្រៃ អាចនឹងជួយគ្រាំទ្របន្ថែមទៀតដល់មណ្ឌលបោះឆ្នោតរយៈពេល 4 ថ្ងៃ ដោយសារតែបទពិសោធន៍របស់ខោនធីផ្សេងទៀតឃើញថាសប្តាហ៍ទីមួយមិនមានភាពមមាញឹកខ្លាំងនោះទេ ។ ដូច្នេះ

យើងមិនត្រូវការបុគ្គលិកច្រើននោះទេនៅសប្ដាហ៍ទីមួយ ។ នៅពេលមានភាពមមាញឹកខ្លាំង យើងនឹងដាក់បញ្ចូលបុគ្គលិកស្ម័គ្រចិត្តដែលទទួលបានប្រាក់កម្រៃដើម្បីជួយធ្វើការងារ ។

b. អ្នកចូលរួម៖ ដូច្នេះតើបុគ្គលិកដែលធ្វើការងារមុនពេលបោះឆ្នោត នឹងទទួលបានព័ត៌មានអំពីឱកាសទាំងនេះដែរឬទេ?

c. បុគ្គលិក ROV៖ បាទ/ចាស យើងកំពុងធ្វើការលើលិខិតមួយច្បាប់នៅពេលនេះដើម្បីផ្ញើជូនដល់បុគ្គលិកដែលបានធ្វើការងារជាអ្នកស្ម័គ្រចិត្តពីមុនមក ។ លិខិតនេះនឹងរៀបរាប់អំពីការផ្លាស់ប្ដូរថ្មីៗ និងសួរថាតើពួកគេមានចំណាប់អារម្មណ៍ក្នុងការធ្វើជាបុគ្គលិកស្ម័គ្រចិត្តមានប្រាក់កម្រៃ ឬជាបុគ្គលិកជំនួយបន្ថែមដែរឬទេ ។

d. បុគ្គលិក ROV៖ យើងសូមអញ្ជើញមន្ត្រីបោះឆ្នោតពីមុនដែលធ្លាប់បានជួយការងារពីមុនមក ដើម្បីពិនិត្យមើលថាតើពួកគេនៅតែមានលទ្ធភាពជួយដល់មណ្ឌលបោះឆ្នោតទៀតដែរឬទេ ។ គួរកត់សម្គាល់ផងដែរថា បច្ចេកវិទ្យាថ្មីដែលនឹងយកមកប្រើប្រាស់នឹងមានការលំបាកសម្រាប់បុគ្គលិកស្ម័គ្រចិត្ត និងបុគ្គលិករបស់ ROV ផងដែរ ។ ដូច្នេះ នឹងមានតម្រូវការក្នុងការបណ្ដុះបណ្ដាល និងបុគ្គលិកគ្រប់គ្រាន់នៅមណ្ឌលបោះឆ្នោត ដើម្បីឲ្យប្រាកដថាកិច្ចដំណើរការនៅមណ្ឌលបោះឆ្នោតនឹងប្រព្រឹត្តទៅដោយរលូន បើទោះបីជាមានបច្ចេកវិទ្យាថ្មីៗយ៉ាងណាក៏ដោយ ។

## III. គោលដៅនៃផែនការរដ្ឋបាលបោះឆ្នោត

ផែនការរដ្ឋបាលបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្ដូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហគមន៍ ។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្ដានុពលសម្រាប់មណ្ឌលបោះឆ្នោត និងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន និងមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្ដល់សេវាបានយ៉ាងសមរម្យដល់អ្នកបោះឆ្នោតនៅក្នុងខោនធី Santa Clara ។

*ការឆ្លើយតបរបស់ ROV៖*

1. បុគ្គលិក ROV៖ បានឆ្លើយតបទៅបង្ហាញពីផែនទីនៅលើជញ្ជាំង –ផែនទីមួយបង្ហាញពីព្រំប្រទល់មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 11 ថ្ងៃ និងផែនទីផ្សេងទៀតបង្ហាញពីព្រំប្រទល់មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃ ។ អ្នកនឹងកត់សម្គាល់ទៅតំបន់ធំៗមួយចំនួនក្នុងខោនធី ភាគខាងត្បូង ដែលមានចំនួនប្រជាជនរស់នៅរាយប៉ាយច្រើនជាង និងដែលជាបរិវេណដែលត្រូវផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍រួចទៅហើយ ។ ពួកគេនឹងនៅតែផ្ដល់នូវកញ្ចប់បោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ប៉ុន្តែបច្ចុប្បន្ននេះពួកគេក៏អាចទៅបោះឆ្នោតតាមមណ្ឌលបោះឆ្នោតណាមួយក៏បានដែរ ។ ពីមុនមក ពលរដ្ឋក្នុងបរិវេណដែលសន្លឹកឆ្នោតត្រូវផ្ញើតាមប្រៃសណីយ៍ អាចបោះឆ្នោតបានតែតាមតែសំបុត្រ ឬនៅតាមការិយាល័យ ROV តែប៉ុណ្ណោះ ។ បច្ចុប្បន្ននេះ ពួកគេនឹងមានជម្រើសបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បានផងដែរ ។
2. បុគ្គលិក ROV៖ ប្រសិនបើអ្នកដឹងពីទីតាំងណាដែលធ្លាប់ជាមណ្ឌលបោះឆ្នោតនោះ អ្នកអាចផ្ដល់នូវមតិត្រឡប់និងសំណូមពរនានាដោយប្រើទម្រង់មតិត្រឡប់ អ៊ីម៉ែល ឬតាមគេហទំព័របាន ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ ពាក់ព័ន្ធនឹងទីតាំង មណ្ឌលបោះឆ្នោតវិញ តើវាមានលក្ខណៈជាបណ្ដោះអាសន្នមែនទេ?
   a. បុគ្គលិក ROV៖ ពិតមែនហើយ ពួកវាមានលក្ខណៈបណ្ដោះអាសន្នទាំងអស់ ។ យើងព្យាយាមស្វែងរកកន្លែងណាមួយ – មណ្ឌលពាណិជ្ជកម្ម អគាររដ្ឋាភិបាល ក្រុង សាលារៀន សមាគមផ្ទាល់ខ្លួនរបស់អ្នក ក្រុមសហគមន៍ផ្ទាល់ខ្លួនអ្នក ព្រះវិហារ (សាសនាគ្រីស្ទ) – ប្រសិនបើពួកគេមានឆន្ទៈផ្ដល់វាឲ្យយើងបាន 13 ថ្ងៃ ឬ 6 ថ្ងៃនោះ យើងនឹងយកវា (ថ្ងៃបន្ថែមទៀតដែលត្រូវការសម្រាប់ការបញ្ជូនមកដល់និងការទទួលយកនូវគ្រឿងបរិក្ខារបោះឆ្នោត) ជាពិសេសប្រសិនបើវាត្រូវបានផ្ដល់ដោយមិនគិតថ្លៃនោះ ។ ដូច្នេះហើយ បច្ចុប្បន្ននេះយើងស្វែងរកទីតាំងទាំង

នោះ ។ យើងពិតជាមានសន្និធិរបស់ការិយាល័យបោះឆ្នោតច្រើនមែន ដែលត្រូវបានប្រើប្រាស់នាពេលកន្លងមកនេះ ។ មានការិយាល័យបោះឆ្នោតប្រហែលជា 850 ការិយាល័យកាលពីបោះឆ្នោតលើកចុងក្រោយនេះ មានន័យថាយើងត្រូវទំនាក់ទំនងទៅកាន់ប្រហែលជា 1000 ការិយាល័យបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយការិយាល័យបោះឆ្នោតទាំងនេះមានលក្ខណៈតូចចង្អៀតជាប្រវត្តិសាស្ត្រទៅហើយ វាដូចជា ហ្គារាសចតរថយន្តឬបន្ទប់តូចមួយ ។ សម្រាប់មណ្ឌលបោះឆ្នោតមួយ ទីតាំងត្រូវតែធំទូលាយជាង (ទំហំត្រូវបានកំណត់នៅក្នុងប័ណ្ណព័ត៌មានស្តីពីការជ្រើសរើសមណ្ឌលបោះឆ្នោត) ។ យើងត្រូវការកន្លែងដោយសារតែប្រព័ន្ធថ្មី ។ យើងចង់ឲ្យពលរដ្ឋមានអារម្មណ៍ថាមានផាសុខភាព និងកុំឲ្យមានអារម្មណ៍បញ្ចៀតគ្នា ។ យើងចង់ធ្វើឲ្យពលរដ្ឋអាចចូលមកហើយមើលឃើញថាអ្វីៗ គឺស្ថិតក្រោមការគ្រប់គ្រងបានទាំងអស់ ។ នេះគឺផ្លូវដែលគេត្រូវអនុវត្ត តាមនៅពេលពួកគេមកកាន់មណ្ឌលបោះឆ្នោត៖

i. ចុះឈ្មោះ
ii. ទទួលយកសន្លឹកឆ្នោត
iii. ដើរទៅកាន់ស្តង់បោះឆ្នោតដើម្បីគូសសន្លឹកឆ្នោត
iv. ទម្លាក់សន្លឹកឆ្នោត

ដូច្នេះ បច្ចុប្បន្ននេះយើងកំពុងស្វែងរកកន្លែងធំជាងមុន ដូចជាព្រះវិហារ ដើម្បីដាក់ជណ្តើរ និងផ្ទៃបន្ទប់ត្រូវការចាំបាច់ឲ្យបោះឆ្នោតបានដោយផាសុខភាព ។

b. បុគ្គលិក ROV៖ ដូច្នេះយើងមកចូលរួមក្នុងកិច្ចប្រជុំទាំងនេះដោយសូមអំពាវនាវដល់អ្នកដែលស្គាល់បុគ្គលណាមួយ សមាគម ឬអង្គការ ដែលមានបន្ទប់ប្រជុំមានទំហំធំល្មម ហើយដែលមានសក្តានុពលអាចប្រើប្រាស់បានជា មណ្ឌលបោះឆ្នោតនោះ សូមអ៊ីម៉ែលមកពួកយើងតាម voterschoice@rov.sccgov.org ។ យើងនឹងបញ្ជូនអ្នកឯកទេសយើងម្នាក់ឲ្យទៅពិនិត្យទីតាំង ថាតើវាត្រូវទៅតាមលក្ខខណ្ឌតម្រូវពីភាពដែលអាចប្រើប្រាស់បានដែរឬទេ ស្ថិតនៅជិតកន្លែងដែលមានចរាចរណ៍ខ្លាំងទេ ស្ថិតនៅជិតនឹងមធ្យោបាយធ្វើដំណើរសាធារណៈទេ ស្ថិតនៅក្បែរផ្លូវទេ ហើយអ្វីដែលពិសេសបំផុតនោះគឺថា តើវាមានចំណតរថយន្តសម្រាប់គ្រប់គ្នាដែរឬទេ ។ អ្វីៗទាំងអស់នេះយើងត្រូវតែពិចារណា៖

c. បុគ្គលិក ROV៖ បញ្ហាចោទមួយទៀតនៅក្នុងការទទួលបាននូវទីតាំងទាំងនេះ គឺចំនួនថ្ងៃដែលកន្លែងនោះទំនេរ/បើកឲ្យប្រើបាន ។ ឧទាហរណ៍៖ យើងពីមុនមកអាចយកព្រះវិហារធ្វើជាទីតាំងនៃការិយាល័យបោះឆ្នោតនៅថ្ងៃអង្គារ៍បាន ។ បច្ចុប្បន្ននេះ យើងត្រូវការវាឲ្យទំនេរប្រើបានជាមណ្ឌលបោះឆ្នោតរហូតដល់ទៅជាង 1-2 ចុងសប្តាហ៍ ហើយចុងសប្តាហ៍ជាធម្មតាជាថ្ងៃប្រជុំក្រុមជំនុំ ថ្ងៃបួងសួង រៀបអាពាហ៍ពិពាហ៍ ប្រសិទ្ធិគ្រឹស្តសាសនា អ្វីៗទាំងអស់នោះដែលសហគមន៍ពឹងពាក់លើនោះគឺព្រះវិហារនេះឯង ។ ទីតាំងសហគមន៍ផ្សេងទៀតក៏អាចជាប់កម្មវិធីផ្សេងក្នុងកំពុងសប្តាហ៍ដែលមណ្ឌលបោះឆ្នោតបោះឆ្នោតត្រូវចាប់ផ្តើមបើកដំណើរការដែរ ។ វាកាន់តែលំបាកជាងនេះទៅទៀតនោះ គឺការស្វែងរកទីតាំងដែលមានទំហំធំ ដែលទំនេរច្រើនថ្ងៃទៅតាមយើងត្រូវការ ។

d. បុគ្គលិក ROV៖ យើងក៏សាកសួរដល់សហគមន៍ផងដែរ ថាតើគេមានឆន្ទៈទទួលធ្វើជា មណ្ឌលបោះឆ្នោតដែរឬទេ ។ ប្រសិនបើអ្នកដឹងកន្លែងណាមួយដែលអាចជាទីតាំងស្ថិតក្រោមការទទួលខុសត្រូវរបស់សហគមន៍ ដែលទីតាំងនោះអាចសុំចុះឈ្មោះធ្វើជាមណ្ឌលបោះឆ្នោតបាននោះ ។ ពួកគេនឹងត្រូវផ្តល់នូវការបណ្តុះបណ្តាលហើយរាល់ចំណូលទាំងអស់ដែលគេអាចទទួលបានពីការធ្វើមណ្ឌលបោះឆ្នោតនោះ ពួកគេអាចរក្សាទុកដោយខ្លួនគេបាន ឬក៏អាចបរិច្ចាគត្រឡប់ទៅកាន់សហគមន៍វិញក៏បានដែរ ។ នេះគឺជាអត្ថប្រយោជន៍នៃកិច្ចប្រជុំជាមួយអ្នក ដែលជាសហគមន៍ ដូច្នេះហើយយើងអាចស្នើសុំជំនួយពីនាក់មិនត្រឹមតែការស្វែងរកទីតាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការស្វែងរកមនុស្សដែលអាចធ្វើជាបុគ្គលិកបម្រើការនៅតាមមណ្ឌលបោះឆ្នោតទៀតផង ។

e. បុគ្គលិក ROV៖ ហើយសូមចាំថា យើងមិនគ្រាន់តែកក់មណ្ឌលបោះឆ្នោតសម្រាប់ខែមិនា 2020 ទេ ប៉ុន្តែក៏សម្រាប់ខែវិច្ឆិកា 2020 ផងដែរ ។ យើងចង់រក្សាទុកមណ្ឌលបោះឆ្នោតឲ្យនៅដដែលបានច្រើនតាមដែលអាចធ្វើទៅបានដូចគ្នានេះដែរ យើងប្រឹងប្រែងរក្សាការិយាល័យបោះឆ្នោតឲ្យនៅដដែលផងដែរ ។ ដូច្នេះប្រសិនបើទីតាំងមណ្ឌលបោះឆ្នោតរបស់អ្នកវាបែរទៅជាខុសពីគ្នារវាងការបោះឆ្នោតក្នុងខែមិនានិងខែវិច្ឆិកា 2020 នោះ វាទំនងជាដោយសារតែទីតាំងនោះទំនេរសម្រាប់តែការបោះឆ្នោតមួយតែប៉ុណ្ណោះ ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ មតិត្រឡប់បានពីពលរដ្ឋហ្វីលីពីនក្នុង Milpitas – មានភាសាជាច្រើនត្រូវបាននិយាយនៅក្នុងប្រទេសហ្វីលីពីន ។ ពលរដ្ឋហ្វីលីពីនមួយចំនួនដែលមិននិយាយ តាកាឡុក នោះត្រូវបានធ្វើឲ្យឃ្លើសចិត្ត ។ ពួកគេមិនបង្ហាញដោយភាសា តាកាឡុក នោះទេ ។ វាគួរតែធ្វើឡើងទៅតាមការពេញចិត្តប្តូរពីភាសា តាកាឡុកមកជាហ្វីលីពីណូវិញនោះ ។
    a. បុគ្គលិក ROV៖ ថ្មីៗនេះមានភាសាដែលត្រូវបានកំណត់ចំនួនប្រាំ ហើយតាកាឡុក គឺជាភាសាមួយនៃភាសាដែលត្រូវបានកំណត់ ។
    b. អ្នកចូលរួម៖ តាកាឡុកមិនមែនជាភាសាទេ វាជាគ្រាមភាសា ។
    c. អ្នកចូលរួម៖ វាមិនមែនជាភាសាដោយខ្លួនវាទេ វាជាព័ត៌មានតែប៉ុណ្ណោះ ។
    d. បុគ្គលិក ROV៖ មានភាសាសហព័ន្ធចំនួនប្រាំ៖ អង់គ្លេស, អេស្ប៉ាញ, វៀតណាម និងតាកាឡុក ។ សម្រាប់ភាសាដែលកំណត់ដោយរដ្ឋនោះ គេត្រូវតែផ្អែកទៅលើការធ្វើជំរឿន និងការស្ទង់មតិដទៃផ្សេងទៀតដែលរដ្ឋបានធ្វើ ។ ពីដើមមក ភាសាកំណត់ដោយរដ្ឋមានបួន៖ កូរ៉េ, ខ្មែរ, ហិណ្ឌី និងជប៉ុន ។ ពេលនោះវាត្រូវបានកាត់បន្ថយមកត្រឹមពីរ៖ កូរ៉េ និង ខ្មែរ ។ ទោះជាយ៉ាងណាក៏ដោយ ROV បន្តផ្តល់ការគាំទ្រសម្រាប់ហិណ្ឌី និងជប៉ុន ។ ជាមួយនឹង VCA យើងនឹងផ្តល់ការគាំទ្រសម្រាប់ភាសាទាំងប្រាំបួននេះ ។ យើងចង់ឲ្យមានគ្រាមភាសាទាំងអស់ ប៉ុន្តែវាមិនអាចធ្វើបានទេ ។
    e. អ្នកចូលរួម៖ ជាផ្លូវការ ហ្វីលីពីណូគឺជាភាសា បើទោះបីជាមនុស្សបានសុំទៅនឹងការហៅវាថា តាកាឡុកក៏ដោយ ដោយផ្អែកថាវាជាគ្រាភាសា ។
    f. អ្នកចូលរួម៖ អ្នកនិយាយថាវាជាភាសាដែលត្រូវបានកំណត់ ។ តើយើងផ្លាស់ប្តូរវានេះដោយរបៀបណា? តើយើងត្រូវនិយាយទៅកាន់នរណា?
    g. បុគ្គលិក ROV៖ អ្នកនឹងចាំបាច់ត្រូវនិយាយទៅកាន់ថ្នាក់រដ្ឋ ឬសហព័ន្ធ ។
    h. បុគ្គលិក ROV៖ អ្នកអាចប្រើជម្រើស "ផ្សេងៗ" នៅលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោត ដើម្បីបង្ហាញពីភាសាជាក់ស្តែងដែលពួកគេនិយាយា ។ នៅពេល ROV ដំណើរការប័ណ្ណនោះ ពួកគេនឹងកត់សម្គាល់នូវភាសានោះហើយ ។ ស្ថិតិនឹងរាប់បញ្ចូលព័ត៌មាននេះ ប៉ុន្តែ ROV ពឹងផ្អែកទៅលើអ្នកបោះឆ្នោតដើម្បីផ្តល់ព័ត៌មាននេះ ។ អ្វីៗគ្រប់យ៉ាងគឺត្រូវបានរាយការណ៍ដោយខ្លួនឯង ។ ប្រសិនបើគ្មានភាសាត្រូវបានជ្រើសរើស ឬបង្ហាញនៅលើប័ណ្ណចុះឈ្មោះ ដោយស្វ័យប្រវត្តិទេនោះ ភាសាដែលពេញចិត្តដោយអ្នកបោះឆ្នោតនឹងត្រូវកំណត់ជាភាសាអង់គ្លេស ។ សូមពិចារណារឿងនេះនៅពេលនិយាយពីស្ថិតិ និងដឹងថាមានជម្រើសផ្សេងទៀតដើម្បីបង្ហាញពីគ្រាមភាសាដែលពេញចិត្ត ។
    i. អ្នកចូលរួម៖ តើអ្នកចាប់យកព័ត៌មាននេះទេ?
    j. បុគ្គលិក ROV៖ យើងចាប់យក ។ នៅពេលប័ណ្ណត្រូវបានដំណើរការ ហើយជម្រើស "ផ្សេងៗ" ត្រូវបានជ្រើសរើសនោះ ភាសាត្រូវបានកំណត់ដើម្បីបន្តការចុះឈ្មោះតទៅទៀត ។
    k. អ្នកចូលរួម៖ បញ្ហានេះជាបញ្ហាដាច់ដោយឡែកតែចំពោះភាសាហ្វីលីពីណូទេ ដូច្នេះវាមិនអីទេ ។ យើងនឹងគ្រាន់តែលើកវាឡើងចំពោះមុខតំណាងរាស្ត្រយើងតែប៉ុណ្ណោះ ។
    l. អ្នកចូលរួម៖ ហេតុអ្វី "ចិន" ត្រូវបានកំណត់ ហើយ "ម៉ែនដារីន" មិនត្រូវបានកំណត់ទៅវិញ? ហេតុអ្វីបានជាវាមិនអាចកំណត់ "ហ្វីលីពីណូ" ជំនួសឲ្យ "តាកាឡុក" បាន?
    m. បុគ្គលិក ROV៖ នៅក្នុងប្រអប់ជម្រើស "ផ្សេងៗ" អ្នកអាចសរសេរ តាកាឡុក បាន ។

n. បុគ្គលិក ROV៖ អ្វីៗគ្រប់យ៉ាងត្រូវបានធ្វើឡើងដោយក្រុមបោះឆ្នោត និងអ្វីៗសុទ្ធតែត្រូវបានកំណត់ទាំងអស់ ។ ប្រហែលជានេះអាចលើកឡើងចំពោះមុខតំណាងរាស្ត្ររបស់អ្នកបាន ហើយពួកគេអាចធ្វើការផ្លាស់ប្តូរពីរបៀបកំណត់របស់ពួកគេ ។

2. បុគ្គលិក ROV៖ យើងមានព័ត៌មាន VCA ជាភាសា តាកាឡុក នៅលើគេហទំព័ររបស់យើងផងដែរ ។ ប្រសិនបើអ្នកចូលទៅកាន់ទំព័រដើមរបស់គេហទំព័រជម្រើសរបស់អ្នកបោះឆ្នោតនោះ មានតំណភ្ជាប់មួយសម្រាប់ភាសាតាកាឡុក ។ យើងកំពុងស្ថិតក្នុងដំណើរការនៃការបកប្រែគ្រប់ទំព័រទាំងអស់ ប៉ុន្តែមានខ្លឹមសារមួយចំនួនជាភាសាតាកាឡុករួចហើយនៅលើគេហទំព័រ ។

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*ធាតុចូលពីសាធារណៈមតិ/សំណួរ៖* (គ្មាន)

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*បទបង្ហាញរបស់ ROV៖*

បុគ្គលិក ROV៖ យើងកំពុងស្វែងរកសំណូមពរនានាសម្រាប់ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយ ។ យើងចង់ធ្វើផែនការផ្សព្វផ្សាយទ្រង់ទ្រាយធំមួយ ហើយយើងនឹងបង្កើនថវិកាឲ្យបានច្រើនខ្លាំងសម្រាប់ការងារនេះ ។ ថ្មីៗនេះយើងកំពុងតែផ្សព្វផ្សាយតាម Facebook, Twitter, NextDoor, សេចក្តីប្រកាសព័ត៌មាន, Instagram ហើយយើងបានចាប់ផ្តើមបង្កើតជាវីដេអូសម្រាប់ការផ្សព្វផ្សាយ ។ យើងនៅតែកំពុងបង្កើតផែនការផ្សព្វផ្សាយនេះនៅឡើយ ដែលនឹងជាផ្នែកមួយនៃផែនការរដ្ឋបាលបោះឆ្នោត ។ ដូច្នេះ យើងសង្ឃឹមថាអ្នកអាចជួយផ្តល់ដល់យើងនូវសំណូមពរនានាសម្រាប់ការផ្សព្វផ្សាយតាមការសែត និងស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ជាក់លាក់ទាំងឡាយ ដែលនឹងមានប្រសិទ្ធិភាពដល់សហគមន៍និយាយភាសាហ្វីលីពីណូ ។ បើទោះបីជាសំណូមពរនោះលើកឡើងពីការមិនគួរប្រើស្ថានីយ៍ ឬកាសែតណាមួយក៏ដោយ ក៏យើងសូមស្វាគមន៍ដែរ ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ ពាក់នឹងការព្រួយបារម្ភអំពីអ្នកបោះឆ្នោតនៅក្នុង Milpitas ។ មានពលរដ្ឋហ្វីលីពីនតែ 18% បានបោះឆ្នោតនាពេលចុងក្រោយនេះ ដូច្នេះយើងព្រួយបារម្ភអំពីភ្ជាប់ទៅនឹងចំនួនប្រជាជនបោះឆ្នោតដើម្បីកេញចំណេញទេ ។
   a. អ្នកចូលរួម៖ សម្រាប់ការបោះឆ្នោតខែវិច្ឆិកា 2020 សូមផ្តល់អនុសាសន៍ឲ្យទាក់ទងទៅកាន់ Milpitas សម្រាប់បុណ្យអបអរសារទទិវាឯករាជ្យរបស់ហ្វីលីពីន (មិថុនា) ដើម្បីឲ្យ ROV អាចមានស្តង់នៅទីនោះ ។
   b. ការចូលរួម៖ ពិនិត្យទៅលើ ការប្រារព្ធពិធីបេតិកភណ្ឌវប្បធម៌ហ្វីលីពីននៅក្នុង Milpitas ដែលនឹងចំថ្ងៃសុក្រចុងក្រោយនៃខែតុលា – 25 តុលា ។ នេះគឺស្ថិតនៅក្នុងដំណាក់កាលធ្វើផែនការនៅឡើយ យើងនៅបន្តធ្វើវាប៉ុន្តែខ្ញុំអាចធ្វើវាតាមអ៊ីម៉ែលទៅឲ្យអ្នកណាក៏ដោយដែលត្រូវការវាតាមអ៊ីម៉េល ហើយយើងចង់ឲ្យ ROV មានវត្តមាននៅក្នុងព្រឹត្តិការណ៍របស់ហ្វីលីពីន ។
   c. បុគ្គលិក ROV៖ សម្រាប់មតិត្រឡប់ ឬការទំនាក់ទំនងពាក់ព័ន្ធនឹងការផ្សព្វផ្សាយ ឬការធ្វើផែនការរដ្ឋបាលបោះឆ្នោត សូមអ៊ីម៉ែលទៅកាន់ voterschoice@rov.sccgov.org ។

2. អ្នកចូលរួម៖ សូមដាក់តំណភ្ជាប់ដែលដំណើរការនៅលើគេហទំព័ររបស់ សភាហ្វីលីពីន-អាមេរិក អង្គការហ្វីលីពីន មិនរកកម្រៃផ្សេងទៀត ឬ តាម Facebook ។ អ្នកក៏អាចដាក់និមិត្តសញ្ញានៅលើគេហទំព័រដែលនឹងនាំពួកគេទៅកាន់ទំព័រផ្សេងទៀត ។ ផ្សាយតាមទំព័រ Facebook និងអង្គការនានាអាចធ្វើការផ្សព្វផ្សាយតាមអ៊ីម៉ែលបាន ។
    a. បុគ្គលិក ROV៖ ទាំងអស់នេះពិតជាអស្ចារ្យខ្លាំងណាស់ ។ ជាមួយនឹងសហគមន៍ទាំងនេះ តើវាទាំងអស់ហ្នឹងធ្វើបានតែការផ្សព្វផ្សាយតាមអ៊ីម៉ែល ឬ លើគេហទំព័រមែនទេ ឬ តើមានកិច្ចប្រជុំតាមសហគមន៍ជាមួយអ្នកក្នុងមូលដ្ឋានខ្លះទេ ប្រចាំសប្តាហ៍ ឬ ប្រចាំខែ ដែលយើងប្រហែលជាអាចទៅចូលរួមបានទេ? ក្រៅពីការផ្សាយពាណិជ្ជកម្ម យើងចង់បង្រៀនដល់អ្នកនិងអង្គការរបស់អ្នកផងដែរពីវិធីអប់រំសហគមន៍របស់អ្នក ។ អ្នកអាចចែកចាយព័ត៌មានក្នុងកំពុងពេលកិច្ចប្រជុំជាទៀតទាត់របស់អ្នកបាន ប្រសិនបើមាន ។
    b. បុគ្គលិក ROV៖ យើងក៏សូមស្វាគមន៍ចំពោះការភ្ជាប់ទំនាក់ទំនងទៅកាន់អ្នកដែលមានឥទ្ធិពលទាំងឡាយនៅក្នុងអង្គការរបស់អ្នក ដូច្នេះគេអាចត្រូវបានសួរនាំដើម្បីចែកចាយបន្ថែម និងកៀរគរសហគមន៍ ។
    c. បុគ្គលិក ROV៖ យើងបានប័ណ្ណចំណាប់អារម្មណ៍ ដែលអ្នកអាចទុកព័ត៌មានទំនាក់ទំនងឲ្យយើង ហើយយើងអាចបញ្ចូលអ្នកទៅក្នុងបញ្ជីចែកចាយរបស់យើង ។ យើងអាចផ្ញើអ៊ីម៉ែលអំពីសម្ព័ន្ធភាពដើម្បីការអប់រំ និងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ដែលកំពុងត្រូវបានអភិវឌ្ឍឡើង ហើយនឹងចាប់ផ្តើមនៅដើមខែសីហា ។ សូមបញ្ជូនបន្តនូវអ៊ីម៉ែលទាំងនោះទៅកាន់អ្នកផ្សេងនៅក្នុងអង្គការរបស់អ្នក ។ យើងត្រូវការជំនួយក្នុងការពង្រីកផ្សព្វផ្សាយ ។
3. អ្នកចូលរួម៖ ពេញចិត្តច្បាប់ VCA គិតថាវានឹងទៅដល់អ្នកបោះឆ្នោតច្រើនជាងមុន ហើយមានភាពប្រសើរឡើងច្រើនចំពោះដំណើរការបោះឆ្នោត ។ ឆ្នាំ 2020 ឥឡូវនេះនឹងជាប័ណ្ណរាយការណ៍ថ្មីសម្រាប់ ROV ។ ជាមួយនឹងថវិការកើនឡើង ROV ត្រូវការគោលបំណងដើម្បីបង្កើនការចេញមករបស់អ្នកបោះឆ្នោត ។ វាត្រឹមត្រូវណាស់ដែលត្រូវចុះទៅតាមសហគមន៍ដើម្បីទំនាក់ទំនងដោយផ្ទាល់មួយៗតែម្តង ។
4. បុគ្គលិក ROV៖ យើងក៏កំពុងស្វែងរកគំនិតនានាសម្រាប់សំណូមពរយុទ្ធនាការផ្សព្វផ្សាយ ។ នេះជាយុទ្ធនាការធំជាងខ្លាំងជាងយើងធ្លាប់ធ្វើពីមុនមក យើងពិតជាស្វែងរកទីតាំងដើម្បីស្វែងយល់ទាក់ទងទៅនឹងការផ្សាយពាណិជ្ជកម្ម ។
    a. អ្នកចូលរួម៖ សុំកុំប្រើកាសែត Philippine News ។ វាមិនមានប្រសិទ្ធភាពទេ ហើយថ្លៃខ្លាំងពេក ។
    b. បុគ្គលិក ROV៖ តើមានជម្រើសផ្សេងទេ? តើយើងគួរតែមើលទៅលើអ្វីវិញ?
    c. អ្នកចូលរួម៖ មើលទៅតាមអង្គភាពផ្សេង និងស្វែងរកអ្នកដែលមានឥទ្ធិពលទាំងឡាយ ។ សាកល្បងជាមួយ Milpitas Lions Club ឬទាក់ទងមកខ្ញុំ ខ្ញុំសកម្មនៅក្នុងសហគមន៍ ។
    d. អ្នកចូលរួម៖ មិនមែនគ្រប់គ្នាមើល ប៉ុស្តិ៍ហ្វីលីពីន (TFC) ទេ ប៉ុន្តែខ្ញុំនឹងមិនចង់បញ្ចុះតម្លៃវានោះទេ ។ ពលរដ្ឋហ្វីលីពីនវ័យចាស់មួយចំនួនមើលប៉ុស្តិ៍ជនជាតិដើម ។
    e. អ្នកចូលរួម៖ តើអ្នកមានប័ណ្ណព័ត៌មានជាឌីជីថលដែលមានព័ត៌មានដែលចង់ផ្សព្វផ្សាយទេ? ខ្ញុំអាចចុះផ្សាយវានៅលើទំព័រ Facebook របស់ខ្ញុំបាន ។
    f. បុគ្គលិក ROV៖ យើងអាចផ្ញើឲ្យអ្នកជាឌីជីថលនោះបាន ។ សូមមើលនៅលើទំព័រ Facebook របស់ ROV និងគេហទំព័ររបស់ ROV ផងដែរ សម្រាប់ឯកសារនិងព័ត៌មានបន្ថែម ។
    g. អ្នកចូលរួម៖ សំណូមពរសម្រាប់ប័ណ្ណព័ត៌មាន VCA ដោយបន្ថែមយោងទៅលើច្បាប់ VCA នៅក្នុងជួរ "សូមជ្រើសរើសរបៀបអ្នកបោះឆ្នោត" ដើម្បីផ្តល់នូវបរិបទ ។ ជួរត្រូវបានសំណូមពរគឺ "សូមជ្រើសរើសការបោះឆ្នោតជាមួយ VCA" ឬ អ្វីម្យ៉ាងស្រដៀងនេះ ។ ប័ណ្ណព័ត៌មានបច្ចុប្បន្ននេះមិនមាននិយាយអ្វីទាល់តែសោះពីច្បាប់ VCA ។
    h. បុគ្គលិក ROV៖ យើងកំពុងស្ថិតក្នុងដំណើរការធ្វើពិធភាពនិងធ្វើឲ្យប្រសើរឡើងវិញនូវខ្លឹមសាររបស់យើង ។ យើងនឹងកត់ត្រាទុកនូវសំណូមពររបស់អ្នកសម្រាប់ឯកសារផ្សព្វផ្សាយរបស់យើងនាពេលអនាគត ។
    i. បុគ្គលិក ROV៖ យើងនឹងធ្វើការផ្ញើអ៊ីម៉ែលដោយផ្ទាល់ចំនួនពីរ ដែលនឹងត្រូវផ្ញើទៅកាន់អ្នកបោះឆ្នោតម្នាក់ៗ ហើយនឹងផ្តល់នូវព័ត៌មានបន្ថែមពី VCA ។
    j. អ្នកចូលរួម៖ គួរមានការពិភាក្សាជាក្រុមសម្រាប់ការបង្កើតឯកសារទាំងនេះ ។

k. បុគ្គលិក ROV៖ មានក្រុមពិភាក្សាមួយសម្រាប់ការបង្កើតនូវឯកសារអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ហើយដែលជា VEOC ដែលយើងកំពុងតែបានពិភាក្សាគ្នានេះ ។ យើងអាចនិយាយជាមួយអ្នកបាននៅក្រោយកិច្ចប្រជុំអំពីរឿងនោះ និងសំណូមពរនានារបស់យើង ។

5. អ្នកចូលរួម៖ អង្គការមិនរកកម្រៃហ្វីលីពីន មានព្រឹត្តិការណ៍ជាច្រើន ហើយព្រឹត្តិការណ៍ទាំងនោះជាកន្លែងល្អត្រូវចូលរួម ។
    a. បុគ្គលិក ROV៖ សូមបំពេញប័ណ្ណចំណាប់អារម្មណ៍ ហើយសូមគូស VEOC ដូច្នេះយើងអាចទាក់ទងទៅអ្នកបាន និងបង្ហាញអ្នកពីរបៀបអប់រំដល់សហគមន៍របស់អ្នក ។ អ្វីដែលអ្នកទើបតែសួរមាននៅក្រោម VEOC ។ យើងអាចភ្ជាប់ទំនាក់ទំនងជាមួយអ្នក និងអង្គការផ្សេងទៀត ដែលអាចរៀបចំកម្មវិធីឲ្យយើង ឬរៀបចំព្រឹត្តិការណ៍ជាមួយយើងបាន ។

6. បុគ្គលិក ROV៖ នៅលើប័ណ្ណចំណាប់អារម្មណ៍ក៏មានគណៈកម្មាធិការប្រឹក្សាលទ្ធភាពទទួលបានជំនួយផ្នែកភាសាផងដែរ ដែលជួបជុំគ្នាប្រចាំខែសម្រាប់ពេលបច្ចុប្បន្នដើម្បីផ្តល់ឲ្យយើងនូវដំបូន្មាន និងមតិត្រឡប់ស្តីពីភាសាផ្សេងៗគ្នាដូចជាហ្វីលីពីណូជាដើម ។ យើងថ្មីៗនេះមិនមានសមាជិកជាអ្នកនិយាយហ្វីលីពីណូ/កាតាឡុកទេ ។
    a. អ្នកចូលរួម៖ ខ្ញុំអាចជាសមាជិកបាន ។
    b. បុគ្គលិក ROV៖ នេះពិតជាប្រសើរខ្លាំងណាស់ សូមអរគុណច្រើន ។ ហើយអាចមកចូលរួមបានលើសពីម្នាក់! ដូច្នេះសូមគូសប្រអប់គណៈកម្មាធិការប្រឹក្សាលទ្ធភាពទទួលបានជំនួយផ្នែកភាសានៅលើប័ណ្ណចំណាប់របស់អ្នក ដូច្នេះអ្នកអាចត្រូវបានបញ្ចូលទៅក្នុងបញ្ជីបាន ។ នេះគឺដាច់ដោយឡែកពីប្រអប់ត្រូវគូសសម្រាប់ការផ្សព្វផ្សាយ (VEOC) ។
    c. បុគ្គលិក ROV៖ មានតែកិច្ចប្រជុំមួយចំនួនតូចប៉ុណ្ណោះ ដែលបានធ្វើឡើងរហូតមកដល់ពេលនេះ ប៉ុន្តែយើងអាចផ្ញើឲ្យអ្នកតាមអ៊ីម៉ែលអំពីកិច្ចប្រជុំដែលនឹងចូលមកដល់ ។ ព័ត៌មានអំពីគណៈកម្មាធិការក៏ត្រូវមាននៅលើគេហទំព័ររបស់ ROV ផងដែរ ។

7. អ្នកចូលរួម៖ តាងនាមឲ្យពលរដ្ឋនៅ Milpitas ជាពិសេសអ្នកបោះឆ្នោតជាអ្នកនិយាយភាសាហ្វីលីពីណូនោះ យើងសូមថ្លែងអំណរគុណដល់អ្នកដែលបានមកចូលរួមជាមួយយើងនៅទីនេះ ។ យើងគួរតែនាំមនុស្សមកចូលរួមបានច្រើនជាងនេះប្រសិនបើយើងបានដឹងអំពីកិច្ចប្រជុំនេះបានមុននោះ ។
    a. បុគ្គលិក ROV៖ នឹងមានឱកាសច្រើនទៀតដើម្បីជួបជុំនិងផ្តល់នូវមតិត្រឡប់ឲ្យគ្នាទៅវិញទៅមក ។ សូមមើលនៅលើគេហទំព័ររបស់អ្នក ហើយរងចាំមើលអ៊ីម៉ែលពីយើងផ្ញើជូនអ្នក ។ កិច្ចប្រជុំពីផែនការរដ្ឋបាលបោះឆ្នោតបន្ទាប់មកដល់មាននៅក្នុងឯកសារដែលបានចែកជូនដល់អ្នក ។
    b. បុគ្គលិក ROV៖ យើងក៏អាចទៅចូលរួមកិច្ចប្រជុំរបស់អង្គការនិងសហគមន៍របស់អ្នកបាន ហើយធ្វើបទបង្ហាញពីច្បាប់ VCA ។ អ្នកថែមទាំងអាចបញ្ចូលយើងចូលក្នុងប្រតិទិនរបស់អ្នកក្នុងខែមករា ឬ ខែកុម្ភៈបានផងដែរ ។ មានមនុស្សច្រើនជាមុននឹងចាប់អារម្មណ៍នៅក្នុងការបោះឆ្នោតនៅពេលនោះ ។
    c. អ្នកចូលរួម៖ អង្គការមួយចំនួនមានកម្មវិធីជួបជុំធំៗ ដែលអ្នកក៏អាចចូលរួមបានផងដែរ ។

8. អ្នកចូលរួម៖ តើមានក្រុមវ័យជាក់លាក់ដែលអ្នកកំណត់គោលដៅទេ? ប្រជាសាសន៍ដែលនាពេលបច្ចុប្បន្ននេះនឹងមិនទៅការិយាល័យបោះឆ្នោត ឬមិនចាប់អារម្មណ៍ទេឬ? ជាជំនាន់សហស្សវត្សថ្មីមែនទេ?
    a. បុគ្គលិក ROV៖ យើងពិតជាកំពុងកំណត់គោលដៅចំពោះយុវជនជំនាន់ថ្មី ដូច្នេះហើយ យើងនឹងធ្វើការផ្សព្វផ្សាយច្រើននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្តល់ព័ត៌មាន ។ ទោះជាយ៉ាងណាក៏ដោយជាទូទៅ វាមិនមែនបញ្ហានៅលើវ័យនោះទេ ប៉ុន្តែយើងចង់ឲ្យប្រាកដថាសហគមន៍ផ្ទាល់ដឹងអំពី VCA ។ យើងក៏ចង់ធ្វើឲ្យបានច្រើនជាមួយនឹងវិទ្យាល័យ ឬការអប់រំនិស្សិត ហើយក្តីសង្ឃឹមគឺថាពួកគេជួយផ្សព្វផ្សាយព័ត៌មានបន្តទៅកាន់សមាជិកចាស់ៗរបស់គេនៅតាមគ្រួសារគេ ។ គោលបំណងធំនោះគឺដើម្បីទាក់ទងទៅគ្រប់ៗគ្នាទាំងអស់ ដោយមិនរើសអើងប្រជាសាសន៍ឡើយ ។
    b. បុគ្គលិក ROV៖ មតិត្រឡប់បានពីខោនធីផ្សេង ដែលបានអនុវត្ត VCA បានបង្ហាញថា ការឆ្លើយតបមានភាពប្រសើរឡើងចាប់ពីការបោះឆ្នោតលើកទីមួយទៅលើកទីពីរ ។ វាជាដំណើរការកំពុងរីកចំរើន ហើយកើនឡើងដោយខ្លួនវា ។ យើងនឹងបន្តធ្វើការអប់រំដល់សហគម៍ម្តងហើយម្តងទៀតរហូតទាល់តែគ្រប់គ្នា

មានភាពងាយស្រួលជាមួយនឹងប្រព័ន្ធថ្មីនេះ ។ នេះក៏ជាមូលហេតុដែលយើងត្រូវការធាតុចូលនិងជំនួយពីអ្នកដើម្បីភ្ជាប់ទំនាក់ទំនងជាមួយនឹងសហគមន៍ផ្សេងៗគ្នា ។

c. បុគ្គលិក ROV៖ យើងក៏កំពុងប្រមែប្រមូលនូវគំនិតច្នៃប្រឌិត ថ្មី និងមកពីខាងក្រៅ ដើម្បីកៀរគរដល់ មិនត្រឹមតែអ្នកបោះឆ្នោតវ័យក្មេងទេ តែថែមទាំងទៅដល់អ្នកបោះឆ្នោតថ្មីដែលជាអ្នកថ្មី លើកទីមួយ ឬ ជាជនអន្តោប្រវេសន៍ ។ ដូច្នេះ សូមធ្វើការចែករំលែកដល់យើងនូវគំនិតថ្មីៗរបស់អ្នក ។ សូមអ៊ីម៉ែលមកយើងពេលណាក៏បានតាម voterschoice@rov.sccgov.org ។

9. អ្នកចូលរួម៖ មធ្យោបាយមួយទៀតគឺដើម្បីភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកផលិតកម្មវិធី និងផ្តល់ដល់ពួកគេឲ្យបានច្រើននូវប័ណ្ណព័ត៌មានរបស់អ្នកដើម្បីចែកចាយនៅតាមតុចុះឈ្មោះរបស់ការប្រគំតន្ត្រី ឬព្រឹត្តិការណ៍ទាំងឡាយដែលពួកគេផលិតឡើង ។

a. បុគ្គលិក ROV៖ ប្រសិនបើមានព្រឹត្តិការណ៍ ហើយគេអនុញ្ញាតដល់យើង យើងអាចដាក់ស្តង់មួយក៏បាដែរ ។ ទោះជាយ៉ាងណាក៏ដោយ យើងពិតជាត្រូវដឹងជាមុនដើម្បីយើងអាចធ្វើផែនការឲ្យបានសមស្រប ។

b. អ្នកចូលរួម៖ យើងអាចគ្រាន់តែរក្សាការបញ្ជូនបន្តនូវព្រឹត្តិការណ៍បន្ទាប់ដែលយើងត្រូវបានគេអញ្ជើញឲ្យចូលរួមនោះ ។

c. បុគ្គលិក ROV៖ វាក៏ជាការល្អដែលត្រូវដឹងពីប្រជាសាសន៍សម្រាប់ព្រឹត្តិការណ៍នីមួយៗ ដូច្នេះយើងអាចប្រាកដយើងក្តោបបានគ្រប់ប្រជាសាសន៍ទាំងអស់ ហើយមិនគ្រាន់តែក្តោបទៅលើតែមួយចំនួនតូចនោះនៃពួកគេនោះទេ ។

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្រ្តីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

# គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP)

# របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់សហគមន៍ភាសាអេស្ប៉ាញ

មជ្ឈមណ្ឌលសហគមន៍ Mayfair

2039 Kammerer Ave. San Jose, CA. 95116

បន្ទប់ Lincoln

ថ្ងៃច័ន្ទ ទី24 ខែមិថុនា ឆ្នាំ 2019

ម៉ោង 4:00 ដល់ម៉ោង 5:30 ល្ងាច

**វត្តមានអ្នកចូលរួម៖**

អ្នកសម្របសម្រួលការផ្សព្វផ្សាយសហគមន៍នៃទីក្រុង San Jose តំណាងការិយាល័យទំនាក់ទំនងជនអន្តោប្រវេសន៍នៃខោនធី Santa Clara ការិយាល័យ និងសមាជិកសាធារណជនប្រាំពីររូបមកពីសហគមន៍ភាសាអេស្ប៉ាញ

**វត្តមានបុគ្គលិកចូលរួម៖**

Shannon Bushey, Vanessa Hamm, Magdalena Sta Maria, Priscilla Favela, Shelby Galaviz, Andrea Solorio, Allen Ocampo, Paulo Chang, Patricia Lopez, Dan Fiorenza, Bob Nguyen, Martin Ayala, Kelly Phan, Eric Kurhi, Chipo Mulenga, April Bracamonte, Janora Davis, Michael Borja, Jose Posadas, Liz Oviedo, Anazay Rivera

**ចំណុចសកម្មភាព៖**

- ផ្តល់ប័ណ្ណព័ត៌មានអំពីច្បាប់ជម្រើសអ្នកបោះឆ្នោត (VCA) ជាភាសាអេស្ប៉ាញ
- ផ្ញើប័ណ្ណព័ត៌មាន VCA ឌីជីថលសម្រាប់ការបោះពុម្ពផ្សាយអនឡាញ
- ពិនិត្យមើលក្នុងការផ្តល់កិច្ចប្រជុំភាសាតែមួយបន្ថែមសម្រាប់សហគមន៍និយាយភាសាអេស្ប៉ាញ

I. **សេចក្តីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

*ធាតុចូលពីសាធារណមតិ/សំណួរ៖*

1. អ្នកចូល រួម៖ តើមានការបណ្តុះបណ្តាលផ្សេង ឬផ្នែកនៃការបណ្តុះបណ្តាល ដែលធ្វើឡើងនៅក្នុងអគារខោនធី Santa Clara គឺក្នុងការិយាល័យមន្រ្តីគ្រប់គ្រងបញ្ជីបោះឆ្នោតទេ?
   a. បុគ្គលិក ROV៖ ការិយាល័យបោះឆ្នោតកាលពីដើមនោះបានបង្ហាញថា អ្នកត្រូវទៅបោះឆ្នោតនៅឯការិយាល័យបោះឆ្នោតដែលស្ថិតនៅជិតផ្ទះរបស់អ្នកបំផុត ។ ជាមួយនឹងគំរូថ្មីនេះ អ្នកបោះឆ្នោតទាំងអស់ទទួលបានសន្លឹកឆ្នោតតាមសំបុត្រ ។ ជំនួសឲ្យការិយាល័យបោះឆ្នោត ឥឡូវនេះមានមណ្ឌលបោះឆ្នោត ហើយមណ្ឌលទាំងនោះនឹងបើកស្វាគមន៍ទៅជនគ្រប់រូប មិនប្រកាន់ថាមណ្ឌលគេមួយណាទេ ។ យើងសង្ឃឹមថា នេះនឹងកាន់តែងាយស្រួលដល់អ្នកបោះឆ្នោតទាំងអស់ដោយគ្រាន់តែទម្លាក់សន្លឹកឆ្នោតរបស់គេ និងបោះឆ្នោតនៅតាមមណ្ឌលទាំងនោះ ។
2. អ្នកចូលរួម៖ នៅពេលអ្នកបោះបោះតាមសំបុត្របានចូលដល់ការិយាល័យបោះឆ្នោតរបស់គេ ដោយមិនបោះបង់សន្លឹកឆ្នោតផ្ញើមកតាមសំបុត្ររបស់គេនោះ គេត្រូវបោះឆ្នោតមានលក្ខខណ្ឌ ហើយមិនមានអ្នកបោះឆ្នោតច្រើនចូលចិត្តបោះឆ្នោតមានលក្ខខណ្ឌនោះទេ ។
   a. បុគ្គលិក ROV៖ ប្រហែលជា 90% នៃអ្នកបោះឆ្នោតមានលក្ខខណ្ឌនឹងត្រូវកាត់បន្ថយ ហើយជាមួយនឹងថាប្លេតអាឡិចត្រូនិកនោះ វានឹងកាន់តែងាយស្រួលចូលទៅមើលស្ថានភាពរបស់អ្នកបោះឆ្នោតទៅទៀត ហើយនឹងដឹងថាតើគាត់បានបោះ

ឆ្នោតហើយ ឬនៅតែត្រូវការបោះ ។ ការបោះឆ្នោតមានលក្ខខណ្ឌជាអ្វីដែលថ្មីក្នុងរយៈពេលពីឆ្នាំកន្លងមកនេះ ដែលធ្វើឲ្យវាស្រួលចូលទៅចុះឈ្មោះ និងបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ។

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់គេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ តើខ្លឹមសារច្បាប់ជម្រើសអ្នកបោះឆ្នោតដើម្បីបង្កើនការចេញមកបោះឆ្នោតរបស់អ្នកបោះឆ្នោត ឬដើម្បីឲ្យការបោះឆ្នោតកាន់តែលឿនជាងមុន និងស្អាតស្អំជាងមុន?
   a. បុគ្គលិក ROV៖ គោលបំណងចំបងគឺ ដើម្បីផ្តល់នូវភាពងាយស្រួលដល់អ្នកបោះឆ្នោត ដោយផ្ញើសន្លឹកឆ្នោតទៅមនុស្សគ្រប់គ្នាតាមសំបុត្រ ធ្វើវាឲ្យងាយស្រួលបោះនៅតាមទីតាំងមណ្ឌលបោះឆ្នោត ហើយយើងសង្ឃឹមថាចំនួនអ្នកចេញមកបោះឆ្នោតនឹងកើនឡើងជាមួយនឹងច្បាប់នេះ ។ គោលបំណងធំគឺ ផ្សព្វផ្សាយឲ្យទៅដល់សហគមន៍ដែលពុំមានតំណាងគ្រប់គ្រាន់ និងជួយដល់អ្នកដែលជាធម្មតាមិនបោះឆ្នោតឲ្យចេញមកហើយបោះឆ្នោត ។ យើងមិនអាចគ្រប់គ្រងបានថាមានមនុស្សប៉ុន្មាននាក់នឹងចេញមកបោះឆ្នោតទេ ប៉ុន្តែជួនកាលអ្វីដែលមាននៅលើសន្លឹកឆ្នោតគឺជាអ្វីដែលអូសទាញមនុស្សជាច្រើនឲ្យបោះឆ្នោត ។ យើងមានទិន្នន័យនាពេលកន្លងមក ហើយសង្ឃឹមនឹងឃើញនិន្នាការទាន់ពេល ប៉ុន្តែវាពិបាកវាស់វែងឲ្យដឹងថាមានមនុស្សប៉ុន្មាននាក់ បានចេញមកបោះឆ្នោតដោយសារតែច្បាប់ជម្រើសអ្នកបោះឆ្នោតនេះ ។ វាពិបាកគ្រប់គ្រងនូវអ្វីដែលអូសទាញអ្នករាល់គ្នាឲ្យទៅបោះឆ្នោត ប៉ុន្តែអ្វីដែលសំខាន់គឺភាពងាយស្រួលសម្រាប់អ្នកបោះឆ្នោត សង្ឃឹមថាវាធ្វើឲ្យចំនួនអ្នកចេញមកបោះឆ្នោតកើនឡើង ។
2. អ្នកចូលរួម៖ តើយើងមានឃើញអ្នកបោះឆ្នោតចេញមកបោះឆ្នោតកើនឡើងនៅក្នុងរដ្ឋដែលបានធ្វើរួចហើយនូវការបោះឆ្នោតទាំងអស់តាមសំបុត្រទេ?
   a. បុគ្គលិក ROV៖ ខ្ញុំផ្ទាល់មិនបានសិក្សាពីរដ្ឋផ្សេងទេ តែទោះជាយ៉ាងណាក៏ដោយ ការយល់ឃើញរបស់ខ្ញុំនៅរដ្ឋ Oregon នោះគឺថាពួកគេបោះឆ្នោតតាមសំបុត្រ ប៉ុន្តែពួកគេមិនមានមណ្ឌលបោះឆ្នោតទៀតទេ ពួកគេបានទៅបោះឆ្នោតតែតាមសំបុត្រប៉ុណ្ណោះ ។ រដ្ឋ Colorado មានគំរូនេះ ខ្ញុំមិនមានភាគរយនេះជាប់មកជាមួយទេ ។
3. អ្នកចូលរួម៖ តើខ្ញុំនឹងអាចបានដឹងអំពីច្បាប់ជម្រើសអ្នកបោះឆ្នោតតាមរបៀបណា ប្រសិនបើខ្ញុំមិនត្រូវបានគេជូនដំណឹងពីវាទេនោះ?
   a. បុគ្គលិក ROV៖ ពុំមានចែងនៅក្នុងច្បាប់ដែលតម្រូវឲ្យមានសេចក្តីជូនដំណឹងទៅដល់អ្នកបោះឆ្នោតអំពីច្បាប់ជម្រើសអ្នកបោះឆ្នោតកំពុងត្រូវបានអនុម័តដោយគណៈកម្មការអ្នកគ្រប់គ្រងទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយយើងនឹងជូនដំណឹងដល់អ្នកបោះឆ្នោតអំពី VCA ។
4. អ្នកចូលរួម៖ តើច្បាប់ជម្រើសអ្នកបោះឆ្នោតជាច្បាប់ខោនធីឬច្បាប់រដ្ឋ?
   a. បុគ្គលិក ROV៖ វាជាច្បាប់រដ្ឋ ដែលអនុញ្ញាតឲ្យខោនធីប្តូរទៅកាន់គំរូមណ្ឌលបោះឆ្នោតវិញ ។ នេះជាផ្នែកនៃអ្វីដែលយើងកំពុងធ្វើ ប្រមូលទាញយកធាតុចូល និងមតិត្រឡប់សម្រាប់ពង្រាងគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP) របស់យើង ហើយបន្ទាប់មកបង្កើតពង្រាងជាប្រាំបីភាសាបន្ថែមទៅលើភាសាអង់គ្លេស ។
5. អ្នកចូលរួម៖ តើអ្នកពិនិត្យមើលបញ្ជីឈ្មោះអ្នកបោះឆ្នោតញឹកញាប់ប៉ុណ្ណា?
   a. បុគ្គលិក ROV៖ យើងទទួលប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោត ដែលពលរដ្ឋបានចុះហត្ថលេខាក្រោមទោសបញ្ញត្តិនៃសក្ខីភាពទុច្ចរិតថាគេរស់នៅតាមអាសយដ្ឋាននេះ ព័ត៌មានថ្មី ។ល។ យើងធ្វើបច្ចុប្បន្នភាពច្រើនដង ហើយទទួលបានការផ្លាស់ប្តូរអាសយដ្ឋានពីទីកន្លែងជាច្រើនដូចជាការិយាល័យប្រៃសណីយ៍ ក្រសួងយានយន្ត (DMV) រដ្ឋលេខាធិការ ។ល។ ឥឡូវនេះយើងក្លាយជាផ្នែកមួយនៃមូលដ្ឋានទិន្នន័យទូទាំងរដ្ឋ ហើយទាញយកនូវកំណត់ត្រាអ្នកបោះឆ្នោតជាច្រើន ។
6. អ្នកចូលរួម៖ ប័ណ្ណ VCA នេះនិយាយអំពីការគ្រប់គ្រងភ័ស្តុភារហើយវាប្រាប់ខ្ញុំច្រើន ប៉ុន្តែអ្វីដែលងាយជាងនេះបន្តិចនោះ គឺអ្វីដែលមិនមែនគ្រាន់តែការគ្រប់គ្រងភ័ស្តុភារនៃការបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថាវាប្រាប់ខ្ញុំទាំងអស់ពីរបៀបងាយៗទាំងឡាយដែលវាត្រូវបោះឆ្នោត ។ នេះប្រាប់ខ្ញុំពីរបៀបដែលបោះឆ្នោត ប៉ុន្តែវាមិនប្រាប់ខ្ញុំថាវាងាយស្រួលជាងដើម្បីបោះឆ្នោតនោះទេ ។
7. អ្នកចូលរួម៖ យើងកំពុងផ្លាស់ប្តូរទៅកាន់ប្រព័ន្ធបោះឆ្នោតថ្មី ហើយយើងនឹងមានប្រព័ន្ធបោះឆ្នោតថ្មីដែលខ្ញុំអាចទៅកាន់និងបោះនៅទីតាំងណាមួយក៏បានក្នុងចំណោម ទីតាំងទាំង 140 ។ ក្នុងពេលជាមួយគ្នានេះដែរ យើងមានការស៊ើបអង្កេតពាក់ព័ន្ធនឹងរុស្ស៊ីអំពីថា តើអ្នកមិនជឿទុកចិត្តប្រព័ន្ធអេឡិចត្រូនិកយ៉ាងដូចម្តេច តើអ្នកនឹងដោះស្រាយបញ្ហានោះតាមរបៀបណា?

a. បុគ្គលិក ROV៖ យើងមានសន្តិសុខច្រើន ហើយយើងធ្វើតក្កវិទ្យានិងតេស្តពីភាពត្រឹមត្រូវនៅពេលមុននិងក្រោយការបោះឆ្នោតនិងការធ្វើសវនកម្ម ។ ប្រសិនបើអ្នកដើរចូលមក ហើយប្រើបច្ចេកវិទ្យាអេឡិចត្រូនិកដែលមាននៅទីនោះ វានឹងព្រីនចេញក្រដាសសន្លឹកឆ្នោត ដូច្នេះម៉ាស៊ីនបោះឆ្នោតថ្មីនេះដែលគេនឹងប្រើសម្រាប់បោះឆ្នោតនោះ ហៅថា ឧបករណ៍គូសសន្លឹកឆ្នោត កន្លែងដែលបិទបាំងនូវអ្វីដែលគេចង់បោះ វានឹងព្រីនវាចេញហើយគេនឹងផ្ទៀងផ្ទាត់វា ហើយទោះបីយ៉ាងណាក៏ដោយ ខ្ញុំនឹងមានក្រដាសដែលទីបំផុតនឹងទៅដល់ការិយាល័យរបស់ខ្ញុំ ហើយនឹងត្រូវរក្សាទុកសម្រាប់រយៈពេល 22 ខែក្រោយការបោះឆ្នោត ។

8. អ្នកចូលរួម៖ ប្រសិនបើខ្ញុំបោះឆ្នោតតាមអេឡិចត្រូនិកនោះ អ្នកនឹងមានក្រដាសន្លឹកឆ្នោតមួយសន្លឹកមែនទេ?
   a. បុគ្គលិក ROV៖ ពិតមែនហើយ ។ អ្នកនឹងចុចវាតាមអេឡិចត្រូនិកក្នុងនាមជាអ្នកបោះឆ្នោត ។ វានឹងព្រីនចេញក្រដាសមួយសន្លឹក ហើយពេលនោះអ្នកនឹងយកវាចេញ ហើយបញ្ចូលក្នុងម៉ាស៊ីន វានឹងបោះឆ្នោតឲ្យអ្នក ។ ការរៀបសន្លឹកឆ្នោតនឹងត្រូវធ្វើឡើងចប់សព្វគ្រប់ភ្លាមនៅតាមមណ្ឌល ។ នៅយប់ថ្ងៃបោះឆ្នោត លទ្ធផលឥឡូវនេះនឹងត្រូវពន្លឿន ដែលក្នុងនាមជាបេក្ខជន ខ្ញុំជឿជាក់ថាអ្នកនឹងស្ញើចសរសើរវាមិនខានឡើយ ។

9. អ្នកចូលរួម៖ ចុះប្រសិនបើក្នុងករណីខ្ញុំគ្រាន់តែចង់បោះឆ្នោតនៅលើអ្វីទាំងប្រាំ តើខ្ញុំនឹងនៅតែត្រូវបោះឆ្នោតទាំងប្រាំនោះមែនទេ?
   a. បុគ្គលិក ROV៖ ពិតមែនហើយ គឺពិតជាដូចកាលពីមុនអញ្ចឹង ។
   b. បុគ្គលិក ROV៖ អ្វីដែលជាការរំពឹកដ៏ល្អនោះគឺថា ជាច្រើនដងមនុស្សនៅតែមិនចាំចំពោះការត្រឡប់ក្រដាស ពីព្រោះប្រសិនបើគេទទួលបានប័ណ្ណបី ជាឧទាហរណ៍ ហើយគេគ្រាន់តែបោះដោយប្រើផ្នែកខាងមុខដោយមិនត្រឡប់ក្រដាសសន្លឹកឆ្នោតរបស់គេនោះ ម៉ាស៊ីនបោះឆ្នោតថ្មីនឹងប្រាប់អ្នកបោះឆ្នោតថាគេបានខកខានក្នុងការប្រកួតមួយចំនួនហើយ និងផ្តល់ឱកាសឲ្យគេត្រឡប់ទៅក្រោមហើយបោះឆ្នោតនោះឡើងវិញ ប្រសិនបើគេចង់ធ្វើវានោះ ។

10. អ្នកចូលរួម៖ ហេតុអ្វីបានជាការបោះឆ្នោតធ្វើឡើងនៅខែមិនា ឆ្នាំ 2020 ហើយមិនធ្វើឡើងនៅខែមិថុនា? ហេតុអ្វីបានជាកាលបរិច្ឆេទត្រូវបានផ្លាស់ប្តូរ? អ្វីទៅជាមូលហេតុដែលការបោះឆ្នោតត្រូវបានផ្លាស់ប្តូរ?
   a. បុគ្គលិក ROV៖ វាគឺអ្នកធ្វើច្បាប់ទេដែលជាអ្នកប្តូរច្បាប់នៅក្នុងក្រមបោះឆ្នោតទៅខែមិនាសម្រាប់ការបោះឆ្នោតបឋមសម្រាប់បេក្ខជនប្រធានាធិបតី ។ ខ្ញុំជឿថាកាលពីក្នុងឆ្នាំ 1996 ពួកគេព្យាយាមនោះ គេបានប្តូរវាទៅខែមិនាមួយឆ្នាំ បន្ទាប់មកប្តូរត្រឡប់ទៅខែមិថុនា ដូច្នេះនេះជាលើកទីមួយនៅក្នុងខណៈដែលយើងនឹងត្រឡប់ទៅខែមិនា ។ ឥឡូវនេះវាត្រូវត្រៀមដើម្បីខែមិនាសម្រាប់ការបោះឆ្នោតបឋមទាំងអស់លើកលែងតែគេប្តូរចោលម្តងទៀត ដែលពួកគេបានអនុវត្តពីមុនមក ។

11. អ្នកចូលរួម៖ តើការបោះឆ្នោតសាកលនៅតែនឹងធ្វើឡើងនៅខែវិច្ឆិកា?
   a. បុគ្គលិក ROV៖ ពិតមែនហើយ ដូចជានិច្ចដែលនឹងស្ថិតនៅដដែល ។

12. បុគ្គលិក ROV៖ ច្បាប់ VCA ភាគច្រើនយោងទៅដល់ជម្រើសរបស់អ្នកបោះឆ្នោតនីមួយៗនៅក្នុងខោនពីព្រោះកាលពីមុន សំខាន់អ្នកមានជម្រើសពីរបៀបបោះឆ្នោត៖ បោះឆ្នោតនៅថ្ងៃបោះឆ្នោត បោះឆ្នោត 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ឬ បោះឆ្នោតតាមសំបុត្រ ។ ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត អ្វីដែលវាធ្វើនៅពេលនេះ គឺពន្យាថ្ងៃបោះឆ្នោតអ្នកពីមួយថ្ងៃទៅ 11 ថ្ងៃ ។ វាពិតជាផ្តល់នូវជម្រើសកាន់តែច្រើនសម្រាប់អ្នកបោះឆ្នោត ហើយឥឡូវនេះគ្រប់គ្នាក្លាយជាអ្នកបោះឆ្នោតតាមសំបុត្រដោយស្វ័យប្រវត្តិ និងអាចបោះឆ្នោតពីផ្ទះមកបាន ។ អ្នកបោះឆ្នោតនៅតែមានជម្រើសបើកឡានមកកាន់ទីតាំងហិបទម្លាក់សន្លឹកឆ្នោត ដែលគេដឹងរួចជាស្រេចដើម្បីទម្លាក់សន្លឹកឆ្នោតរបស់គេ ឬ នៅថ្ងៃបោះឆ្នោតមកកាន់ទីតាំងមណ្ឌលបោះឆ្នោតដើម្បីទម្លាក់សន្លឹកឆ្នោតរបស់គេ ឬ បោះដោយផ្ទាល់តែម្តងនៅតាមមណ្ឌលបោះឆ្នោតតែម្តងក៏បានដែរ ។ អ្វីដែលប្រសើរបំផុតសម្រាប់អ្នកបោះឆ្នោតដែលមានកាលបរិច្ឆេទកំណត់ដើម្បីចុះឈ្មោះនោះ គេអាចមកកាន់មណ្ឌលបោះឆ្នោតដោយផ្ទាល់ក្នុងរយៈពេល 11 ថ្ងៃ ចុះឈ្មោះនៅថ្ងៃនោះ ចុះហត្ថលេខាលើលិខិតបញ្ជាក់ ទាញយកសន្លឹកឆ្នោតពិតប្រាកដនិងស្រោមសំបុត្រចេញមក ហើយដំណើរការវាតែម្តងចាប់ ។ ពេលនោះការិយាល័យយើងនឹងទទួលវាបាន និងបញ្ជាក់ឲ្យប្រាកដថាបុគ្គលពិតជាមានសិទ្ធិបោះឆ្នោតបានមែន ដូច្នេះហើយនោះគឺជាបទបង្ហាញ CVR ដែលនិយាយពីចំណុចនេះ ។ អ្វីដែលច្បាប់ VCA មាន គឺពិតជាជម្រើសដែលអ្នកបោះឆ្នោតនឹងមាននាពេលនេះ ។ នោះគឺទីកន្លែងដែលអ្នកទាំងអស់គ្នាចូលមក និងចូលរួមហើយប្រាប់យើងថាតើយើងអាចជួយសហគមន៍របស់អ្នកបានយ៉ាងដូចម្តេច? យើងចង់ឲ្យអ្នកគ្រប់គ្នាបានដឹងពីចំណុចនេះ ហើយវានឹងជាការផ្លាស់ប្តូរដ៏ធំសម្បើមមួយ មិនត្រឹមតែសម្រាប់ការបោះឆ្នោតខែមិនាទេ តែក៏សម្រាប់ការបោះឆ្នោតច្រើនទៅមុខដែរ ។ វាជាការផ្លាស់ប្តូរមួយប្រកបដោយវិជ្ជមាន ។ យើងចង់ធ្វើវាឲ្យបានត្រឹមត្រូវ ។ យើងកំពុងព្យាយាមរៀបចំកិច្ចប្រជុំទាំងនេះ យើងកំពុងតែព្យាយាមទំនាក់ទំនងទៅកាន់អ្នករាល់គ្នា ហើយយើងត្រូវការជំនួយពីអ្នកទាំងអស់គ្នាជាចាំបាច់ ។

13. អ្នកចូលរួម៖ គំនិតនាពេលនេះគឺថា 100% នៃអ្នកបោះឆ្នោតនឹងទទួលបានសន្លឹកឆ្នោតរបស់គេនៅតាមផ្ទះ ។ នោះកាត់បន្ថយចំនួនមនុស្សដែលនឹងស្វះស្វែងរកកន្លែងរបស់គេដើម្បីបោះឆ្នោត ។
    a. បុគ្គលិក ROV៖ ត្រឹមត្រូវហើយ ដោយពេលវេលាចេះតែទៅមុខ វានឹងកាត់បន្ថយវាបានច្រើនជាងមុន ។ យើងជួបការផ្លាស់ប្តូរជាច្រើន ហើយសង្ឃឹមថាវានឹងកាត់បន្ថយបានពី 20% នៃអ្នកបោះឆ្នោតដែលបោះនៅតាមមណ្ឌលបោះឆ្នោតមកនៅត្រឹម 10% ដូច្នេះនៅក្នុងការបោះឆ្នោតម្តងៗ វាអាចថាវាថយចុះបន្តិចម្តងៗ ។ យើងទទួលបានសារពីពលរដ្ឋគ្រប់មជ្ឈដ្ឋានទាំងអស់ដែលបានបោះឆ្នោតពីមុនមក ហើយមិនមែនត្រឹមតែថ្ងៃបោះឆ្នោតទេ ដែលនោះជាកន្លែងដែលពលរដ្ឋនឹងជួបការតម្រង់ជួរដ៏វែងដោយសារតែ ពលរដ្ឋមិនបានដឹង ឬដោយសារតែពួកខ្ជិលខ្ជា ដូច្នេះខ្ញុំគិតថាយូរៗទៅ នឹងមានជួរតិចទៅៗនៅថ្ងៃបោះឆ្នោត ។ ប៉ុន្តែការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌ (CVR) គឺពិតជាអ្វីដែលនឹងបង្កឲ្យមានជួរកាន់តែច្រើនជាងមុននៅថ្ងៃបោះឆ្នោត ព្រោះថាមនុស្សចុះឈ្មោះហើយបោះឆ្នោតទៀត ។ យើងនឹងធ្វើឲ្យជួរប្រញាប់ និងជួរ CVR សង្ឃឹមថាធ្វើឲ្យវាលឿនជាងមុនសម្រាប់ពលរដ្ឋ ព្រោះថានៅក្នុងខែវិច្ឆិការ ឆ្នាំ 2018 មានពលរដ្ឋមកកាន់ការិយាល័យយើងរង់ចាំរហូតដល់ទៅបីម៉ោងក្នុងជួរ ហើយយើងស្ថិតនៅទីនោះជួយដល់ពួកគេ ។
14. បុគ្គលិក ROV៖ អ្នកគ្រប់គ្នាក្នុងខោនធីនឹងចង់មានរយៈពេលពីរចុងសប្តាហ៍ បន្ថែមថ្ងៃធ្វើការ ដើម្បីបោះឆ្នោត ដែលនោះគឺដប់ថ្ងៃមុនថ្ងៃបោះឆ្នោត បន្ថែមថ្ងៃបោះឆ្នោតមួយថ្ងៃទៀត ធ្វើចំនួនសរុបមាន 11 ថ្ងៃ ។ នេះគឺជាមូលហេតុដែលយើងធ្វើការផ្សព្វផ្សាយនេះដើម្បីឲ្យប្រាកដថាអ្នកគ្រប់គ្នាយល់ថាមានជម្រើសជាច្រើនសម្រាប់គេគ្រប់គ្នាដើម្បីបោះឆ្នោត ហើយព្យាយាមបោះឆ្នោតមុនកាលកំណត់ ។

## III. គោលបំណងនៃគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត

គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហគមន៍ ។

## IV. ការជ្រើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ ប្រសិនបើនិយាយថាពលរដ្ឋគ្រប់គ្នានឹងអាចបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាននោះ តើការបោះឆ្នោតនឹងមានលក្ខណៈយ៉ាងដូចម្តេចទៅ? ការបោះឆ្នោតបណ្តោះអាសន្ន?
    a. បុគ្គលិក ROV៖ ទេមិនមែនទេ គ្រប់មណ្ឌលបោះឆ្នោតនឹងមានបញ្ជីឈ្មោះអ្នកបោះឆ្នោតជាអេឡិចត្រូនិក ហើយជាមួយនឹងបញ្ជីនេះ យើងនឹងអាចរកឈ្មោះបុគ្គលណាក៏ឃើញដែរ ។ ឧទាហរណ៍ ប្រសិនបើអ្នករស់នៅក្នុង San Jose ហើយធ្វើការនៅឯ Palo Alto អ្នកអាចទៅកាន់មណ្ឌលបោះឆ្នោតនៅ Palo Alto បានហើយបោះឆ្នោតនៅទីនោះ ។ អ្នកនឹងមិនត្រូវបោះឆ្នោតបណ្តោះអាសន្នទេ គេនឹងផ្តល់ដល់អ្នកនូវសន្លឹកឆ្នោតផ្លូវការដែលត្រូវទៅតាមសង្កាត់របស់អ្នក ។
    b. អ្នកចូលរួម៖ តើវានឹងគូសជាស្វ័យប្រវត្តិនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតអេឡិចត្រូនិកមែនទេ?
        i. បុគ្គលិក ROV៖ បញ្ជីឈ្មោះនឹងចូលបានទៅកាន់កំណត់ត្រាចុះឈ្មោះរបស់អ្នកបោះឆ្នោតទាំងអស់ដែលបានចុះរួច ។ ប្រសិនបើអ្នក ឬនរណាម្នាក់ភ្លេចចុះឈ្មោះបោះឆ្នោតនោះ គេអាចទៅថ្ងៃជាមួយគ្នាបាន ហើយចុះឈ្មោះបោះឆ្នោតតែម្តង ក្នុងករណីនោះ នឹងត្រូវបោះឆ្នោតដោយមានលក្ខខណ្ឌ ។
2. អ្នកចូលរួម៖ ការបណ្តុះបណ្តាលដល់មន្ត្រីបោះឆ្នោតនឹងមានជាភាសាអេស្ប៉ាញទេ?
    a. បុគ្គលិក ROV៖ ពុំមានទេ វានឹងមានជាភាសាអង់គ្លេស ។ មន្ត្រីបោះឆ្នោតគ្រប់រូបតម្រូវឲ្យនិយាយភាសាអង់គ្លេស ប្រសិនបើគេអាចនិយាយភាសាផ្សេងទៀតបានដោយសារតែមាននរណារម្នាក់ធ្វើការនៅក្នុងមណ្ឌលបោះឆ្នោតនោះ គេនៅទៅទីនោះមិនត្រឹមតែដើម្បីជួយបកប្រែទេ ប៉ុន្តែថែមទាំងជួយរាល់អ្វីៗផ្សេងទៀតដែរ ។
3. អ្នកចូលរួម៖ ពីមុនយើងមានការបោះឆ្នោតមុនកាលកំណត់ ដែលអ្នកអាចទៅបោះឆ្នោតនៅការិយាល័យចុះឈ្មោះដូចជាមួយខែមុន ឬបីសប្តាហ៍មុន តើនោះនៅតែបន្តទៀតទេ?
    a. បុគ្គលិក ROV៖ នៅតែបន្ត
4. អ្នកចូលរួម៖ ខ្ញុំគិតថាវាជាការល្អប្រសិនបើមានប័ណ្ណព័ត៌មាននិយាយ "ទាំងនេះជារបៀបងាយៗដើម្បីបោះឆ្នោត" និយាយពីរបៀបបោះឆ្នោតមុនបានដោយមានមណ្ឌលបោះឆ្នោតជាច្រើនដែលអ្នកអាចទម្លាក់សន្លឹកឆ្នោតរបស់អ្នកបាន ។ ប័ណ្ណព័ត៌មានមិនត្រូវមានលក្ខណបច្ចេកទេសពេកទេរៀបរាប់ពីដំផ្លាស់ប្តូរ ប៉ុន្តែវាជាការផ្លាស់ប្តូរដើម្បីភាពងាយស្រួលទៅវិញទេ ។ អ្វីដែលខ្ញុំអាចអានបានត្រឹមតែ 30 នាទីឬក៏តិចជាងនេះ ដោយហេតុថាគ្មាននរណាម្នាក់នឹងអានច្រើនជាងនេះទេ ។

5. អ្នកចូលរួម៖ តើនឹងមានមន្ត្រីបោះឆ្នោតប៉ុន្មាននាក់ នៅតាមមណ្ឌលបោះឆ្នោត?
   a. បុគ្គលិក ROV៖ វានឹងអាស្រ័យទៅតាមថ្ងៃនៅក្នុងរយៈពេល 11 ថ្ងៃវាបើកដំណើរការ ដោយហេតុថាថ្ងៃខ្លះអាចមានលក្ខណៈមមាញឹកជាងថ្ងៃផ្សេងទៀត ដូចជាថ្ងៃសៅរ៍មុនថ្ងៃបោះឆ្នោតជាដើម ។
   b. អ្នកចូលរួម៖ តើមានកាលវិភាគហើយឬនៅ?
   c. បុគ្គលិក ROV៖ យើងកំពុងតែរៀបចំវា ព្រមជាមួយនឹងឯកសារផ្សព្វផ្សាយផ្សេងទៀត ដោយហេតុថាយើងត្រូវការអ្នកជួយស្វាគមន៍ដើម្បីស្វាគមន៍និងជួយដល់អ្នកបោះឆ្នោត ។
   d. អ្នកចូលរួម៖ ចំណែកឯម៉ោងការងារវិញយ៉ាងម៉េចដែរ?
   e. បុគ្គលិក ROV៖ វានឹងបើកដំណើរការយ៉ាងតិចបំផុតក៏ប្រាំបីម៉ោងក្នុងមួយថ្ងៃ ប៉ុន្តែម៉ោងធ្វើការនឹងប្រែប្រួលផ្សេងៗគ្នា ។ យើងព្យាយាមឲ្យវាមានម៉ោងដូចគ្នាដើម្បីឲ្យមានពេលយប់ ពេលព្រឹក និងពេលចុងសប្តាហ៍ ។ អ្វីៗវាអាស្រ័យលើថាតើមានមណ្ឌលបោះឆ្នោតប៉ុន្មាន ដែលទំនេរសម្រាប់រយៈពេលច្រើនថ្ងៃនោះ តើគេអនុញ្ញាតឲ្យយើងប្រើបានប៉ុន្មានថ្ងៃ និងតើយើងមានពេលប៉ុន្មានម៉ោង នៅទីនោះដើម្បីរៀបចំការបោះឆ្នោត ។
6. អ្នកចូលរួម៖ ដោយហេតុថាហិបទម្លាក់សន្លឹកឆ្នោតបើក 24 ម៉ោងនោះ ជាគំនិតល្អត្រូវដាក់វានៅខាងក្រៅ *ភ្ជិបហាត់ប្រាណដែលបើកដំណើរការ 24 ម៉ោង* ។
7. អ្នកចូលរួម៖ តើផែនទីទាំងនេះសម្រាប់ធ្វើអ្វី?
   a. បុគ្គលិក ROV៖ ផែនទីដែលមានព្រំប្រទល់ពណ៌ស្វាយជាមណ្ឌលបោះឆ្នោតមានរយៈពេលដំណើរការ 11 ថ្ងៃ ។ យើងមានពីរដំណាក់កាល៖ មណ្ឌល 11 ថ្ងៃ និងមណ្ឌល 4 ថ្ងៃ ។ ដប់ថ្ងៃមុនថ្ងៃបោះឆ្នោត យើងនឹងតម្រូវឲ្យមានមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 50,000 នាក់ ។ នៅពេលយើងឈានចូលដល់បួនថ្ងៃ ថ្ងៃសៅរ៍មុនការបោះឆ្នោតនោះ អ្នកអាចឃើញថាវាមានលក្ខណៈតិចតួចជាង បំបែកវាឲ្យតូចមកនៅត្រឹម 125 ទីតាំងដោយផ្អែកទៅលើការចុះឈ្មោះបោះឆ្នោត ។
8. អ្នកចូលរួម៖ (យោងទៅលើឯកសារផ្តល់ជូន) នៅទីនេះអ្នកមានសំណួរអំពីមណ្ឌលចល័តមែនទេ?
   បុគ្គលិក ROV៖ វាមានលក្ខខណ្ឌតម្រូវចំនួន 14 សម្រាប់យើងត្រូវពិចារណា ។ ទាំងនោះជាលក្ខខណ្ឌតម្រូវទាំង 14 តាមលំដាប់លំដោយ ដើម្បីឲ្យដឹងពីអ្វីដែលសំខាន់បំផុតសម្រាប់អ្នក ។ មួយចំនួននៃខោនធីផ្សេងទៀតដែលមានទីតាំងដីធំទូលាយនោះចាំបាច់ឲ្យមណ្ឌលបោះឆ្នោតរៀបចំឡើងនៅក្នុងទីតាំងទាំងនោះ ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ តើអ្នកនឹងបង្កើតជាវីដេអូដែលអាចជួយចែករំលែកបានជាច្រើនភាសាទេ?
   a. បុគ្គលិក ROV៖ មាន វីដេអូទាំងនោះនឹងរួចរាល់ក្នុងពេលឆាប់ៗ ។ មកដល់នឹងពេលនេះ យើងមានបង្កើតវីដេអូរួចរាល់មួយយើង ប៉ុន្តែយើងនឹងបង្កើតវីដេអូនិងឯកសារផ្សព្វផ្សាយជាច្រើនបន្ថែមទៀត ។ យើងគ្រាន់ទេចង់ឲ្យប័ណ្ណចំណាប់អារម្មណ៍បកប្រែជាភាសាទាំងអស់ ដូច្នេះត្រឹមត្រូវយើងនឹងមានវាជាភាសាផ្សេងៗគ្នាដូចគ្នាទៅនឹងការរៀបចំកិច្ចប្រជុំអញ្ចឹងដែរ ។
2. អ្នកចូលរួម៖ តើវានឹងមានកិច្ចប្រជុំដែលនឹងធ្វើឡើងនិយាយតែភាសាអេស្ប៉ាញទេ ដោយហេតុថានេះកិច្ចប្រជុំពីរភាសានោះ? ប្រសិនបើខ្ញុំមិនមែនជាអ្នកនិយាយភាសាអង់គ្លេស ឬ និយាយតែភាសាអេស្ប៉ាញនោះ វានឹងពិតជាពិបាកចូលរួមនៅពេលដែលមិនមានឧបករណ៍បកប្រែនៅទីនោះ ។
   a. បុគ្គលិក ROV៖ យើងពិតជាមានបុគ្គលិកនៅក្នុងកិច្ចប្រជុំទីនេះដែលចេះនិយាយភាសាអេស្ប៉ាញដើម្បីបកប្រែប្រសិនបើមាននរណាម្នាក់មានតម្រូវការវានោះ ។ មិនមានកិច្ចប្រជុំ EAP ដែលរៀបចំឡើងនិយាយតែភាសាអេស្ប៉ាញនោះទេ ។ ជាចុងក្រោយយើងនឹងមានសិក្ខាសាលាស្តីពីភាសានីមួយៗ ដើម្បីធ្វើបទបង្ហាញពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតដើម្បីផ្តល់ជាព័ត៌មានដល់អ្នកចូលរួមជាភាសាអេស្ប៉ាញ-អង់គ្លេស ។
3. អ្នកចូលរួម៖ ការព្រួយបារម្ភរបស់ខ្ញុំនោះគឺ ថាមិនមានកិច្ចប្រជុំធ្វើឡើងនិយាយតែភាសាអេស្ប៉ាញមួយ។ ខ្ញុំគិតថាយើងចាំបាច់ត្រូវតែមានធាតុចូលដែលប្រសិនបើអ្នកជាអ្នកនិយាយភាសាអេស្ប៉ាញដែលត្រូវការព័ត៌មាននេះជាភាសាអេស្ប៉ាញ

ដោយមានថប់អារម្មណ៍នៅក្នុងសហគមន៍ជាមួយនឹងស្ថានភាពគ្រួសារចំរុះ ដោយសារពលរដ្ឋអាមេរិក មិនមានឯកសារត្រឹមត្រូវ ហើយយុទ្ធនាការបោះឆ្នោតនេះ ដែលមិនមានការផ្តោតការយកចិត្តទុកដាក់ដល់សហគមន៍និយាយភាសាអេស្ប៉ាញដែលកំពុងតែប្រឈមជាមួយនឹងជំងឺថប់អារម្មណ៍នេះ 24/7 ។

   a. បុគ្គលិក ROV៖ យើងកំពុងតែព្យាយាមដើម្បីឲ្យទទួលបានធាតុចូលសម្រាប់ផែនការ ដូច្នេះទីបំផុតទៅនៅពេលរៀបចំផែនការនោះ នឹងមានការផ្សព្វផ្សាយចេញមកច្រើនទៅដល់សហគមន៍ ។

4. អ្នកចូលរួម៖ ខ្ញុំគិតថានេះជាការផ្លាស់ប្តូរថ្មីដ៏អស្ចារ្យមួយ ហើយវានឹងធ្វើឲ្យការបោះឆ្នោតកាន់តែងាយស្រួលជាងមុន ប៉ុន្តែវាជាអ្វីដែលថ្មី ។ ប្រព័ន្ធនេះជាអ្វីមួយដែលថ្មីជាមួយនឹងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មី ជំរឿន ។ល។ និងដោយថាវាអាចនឹងងាយស្រួលជាងមុននោះ វានៅតែជាអ្វីមួយដែលថ្មី ហើយដោយសារតែវាមិនត្រូវបានចេញផ្សាយជាអ្វីតែមួយដែលថ្មីនោះ វាជាអ្វីមួយបន្ថែមត្រូវដឹងក្នុងពេលជាមួយគ្នា ។ ថ្វីបើនេះអាអ្វីដែលថ្មី ហើយគួរឲ្យរំភើបក៏ពិតមែន បញ្ហាប្រឈមគឺជាបរិបទ។

   a. បុគ្គលិក ROV៖ យើងនឹងធ្វើការផ្សព្វផ្សាយ ហើយផ្នែកមួយនៃការផ្សព្វផ្សាយនោះគឺថានរណាម្នាក់ ឬក្រុមណាមួយ ដែលទាក់ទងមកយើងហើយប្រាប់ថា "មកប្រជុំនៅសហគមន៍អេស្ប៉ាញយើង" យើងនឹងបញ្ជូនអ្នកនិយាយភាសាអេស្ប៉ាញទៅធ្វើបទបង្ហាញពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត ។

5. អ្នកចូលរួម៖ ខ្ញុំមានអារម្មណ៍កក់ក្តៅនិយាយជាភាសាកំណើតរបស់ខ្ញុំជាង ក៏ដូចជាការទទួលយកនិងយល់ពីឯកសារផ្សព្វផ្សាយព្រោះវាច្បាស់ខ្លាំងជាងច្រើនណាស់ ។

6. អ្នកចូលរួម៖ ការយល់មានលក្ខណៈជ្រាលជ្រៅជាង ហើយវាសំខាន់គឺត្រូវយល់ពីព័ត៌មានសំខាន់ៗដែលត្រូវបានផ្តល់ដល់យើង ។ វាក៏សំខាន់ដែលគួរតែមានកិច្ចប្រជុំដែលធ្វើឡើងនិយាយជាភាសាអេស្ប៉ាញសុទ្ធនោះ ព្រោះថាខ្ញុំដឹងថាមានកិច្ចប្រជុំជាច្រើនបានរៀបចំឡើងសម្រាប់តែវៀតណាម ចិន និងដូចគ្នានេះគួរតែមានសម្រាប់សហគមន៍អេស្ប៉ាញដែរ ។

7. អ្នកចូលរួម៖ យើងជាជនជាតិដើមកំណើតអេស្ប៉ាញចូលចិត្តភាពច្បាស់លាស់ជាមួយនឹងអ្វីដែលកំពុងស្វែងយល់ ។

   a. បុគ្គលិក ROV៖ យើងត្រៀមរួចជាស្រេចទៅកាន់អង្គការណាមួយ ឬក្រុមណាមួយដែលចង់ឲ្យយើងធ្វើបទបង្ហាញ ។

8. អ្នកចូលរួម៖ ខ្ញុំបានឃើញការបោះឆ្នោតតាំងពីខ្ញុំមានអាយុ 18 ឆ្នាំមកម្លេះ ។ នេះនឹងច្រើនលើសលប់ពេកសម្រាប់សហគមន៍ជនអន្តោប្រវេសន៍របស់យើង ។ អ្នកខ្លះអាចនិយាយថានេះវាជាពេលវេលារបស់គេដើម្បីទទួលបានភាពជាពលរដ្ឋ ក្រោយពីពលរដ្ឋរស់នៅទីនេះច្រើជំនាន់មកហើយនោះ ដូច្នេះសម្រាប់អ្នកដែលធ្វើយុទ្ធនាការនិងជ្រើសរើសបេក្ខជនដែលមើលទៅមានលក្ខណៈដូចជាសហគមន៍ ដូចខ្លួនខ្ញុំផ្ទាល់នោះ វាពិបាកទាក់ទាញមនុស្សម្នាក់ដែលបានបោះឆ្នោតអស់រយៈពេល 25 ហើយនោះ ឲ្យចេញទៅបោះឆ្នោតបានណាស់ ។ គំនិតជារួមនោះគឺថា អ្នកបោះឆ្នោតមានរយៈពេល 11 ថ្ងៃដើម្បីបោះឆ្នោត ហើយមិនមានទីតាំងការិយាល័យបោះឆ្នោតនៅកន្លែងណាមួយទៀតឡើយ ខ្ញុំអាចធានាថាចំណុចទីមួយដែលពលរដ្ឋលើកឡើងនោះគឺថាគេនឹងបោះឆ្នោតនៅតាមសង្កាត់ក្នុងមូលដ្ឋានរបស់គេ នៅពេលឥឡូវវាលែងមានទៀតហើយ ។ ខ្ញុំយល់ពីគំនិត ហើយវាពិតជាងាយស្រួលជាងមុនមែន ប៉ុន្តែមិនមែនសម្រាប់សហគមន៍ជនអន្តោប្រវេសន៍ដែលនិយាយតែមួយភាសារបស់យើងទេ ។ ខ្ញុំរីករាយដែលវាកំពុងអនុវត្ត ហើយយើងមានមេដឹងនាំដ៏អស្ចារ្យ ហើយអ្នកផ្សេងទៀតដែលនឹងជម្រុញឲ្យយើងចូលសាលា ចូលមណ្ឌលសហគមន៍ ប៉ុន្តែវាច្រើនលើសលប់ខ្លាំងណាស់ ។ Mayfair មានមណ្ឌលពលរដ្ឋវ័យចាស់ជរាដ៏អស្ចារ្យមួយ ហើយវាជាឱកាសដ៏ប្រពៃដែលចូលទៅនិយាយជាមួយជនចាស់ជរាទីនេះ ដោយហេតុថាភាគច្រើននៃពួកគេនិយាយតែភាសាអេស្ប៉ាញទេ ។ គេនិយាយថាគ្រប់ការបោះឆ្នោតទាំងអស់ជាពេលវេលាមានសារៈសំខាន់បំផុតក្នុងជីវិតរបស់យើង ប៉ុន្តែយើងមានបេក្ខជនជាច្រើនឈរឈ្មោះ ហើយពលរដ្ឋដើមដំណើតពីអាមេរិកឡាទីនចង់ជ្រើសរើសបេក្ខជនដែលល្អ ។ ខ្ញុំយល់ថាវានឹងជាការច្របូកច្របល់ ហើយអង្គការដូចជា SIREN (បណ្តាញសេវា សិទ្ធិជនអន្តោប្រវេសន៍ និងការអប់រំ) LUNA (ការរួបរួមពលរដ្ឋដើមកំណើតអាមេរិកឡាទីនដើម្បីទឹកដីអាមេរិកថ្មី) និងសហជីពទាំងអស់ដែលជួបការលំបាកទាក់ទាញសមាជិករបស់គេឲ្យទៅបោះឆ្នោត វានឹងជាពេលវេលាដ៏លំបាកមួយ ។ ខ្ញុំសង្ឃឹមថាអ្វីៗនឹងប្រសើរបំផុត ព្រោះថាយើងពិតជាមានអង្គការធំៗជាច្រើននៅទីនោះជួយដល់សហគមន៍ជនអន្តោប្រវេសន៍របស់យើង ប៉ុន្តែវាច្រើនពេក គួរឲ្យខ្លាចនិងប្រឈមខ្លាំង ប៉ុន្តែជាការប្រឈមមួយដ៏ល្អ និងជាពេលវេលាមួយដ៏ល្អដើម្បីអប់រំដល់ពលរដ្ឋរបស់យើង ។

   a. បុគ្គលិក ROV៖ មានកិច្ចប្រជុំមួយបានធ្វើឡើងពីរបីសប្តាហ៍កន្លងមកនេះ ដោយមានគណៈកម្មការអប់រំ និងយើងបានចាប់ផ្តើមពិភាក្សារឿងនោះជាមួយពួកគេ សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រីក៏ជាគម្រោងដាច់ដោយឡែកមួយដើម្បីកៀរគរពលរដ្ឋវ័យកណ្តាលអំពីការចុះឈ្មោះនៅតាមវិទ្យាល័យនានាក្នុងខោនធី ។ យើងបានសួរក្រែងលោយើងអាចបន្ថែមចូលទៅស្លែដ៍ស្តីពីច្បាប់ជម្រើសរបស់អ្នកបោះឆ្នោតសម្រាប់ពលរដ្ឋវ័យកណ្តាលទាំងនោះ ។ យើងកំពុងរង់ចាំការកំណត់កាលបរិច្ឆេទកិច្ចប្រជុំ ដោយហេតុថាយើងដឹងថាគេមានក្រុមប្រព័ន្ធផ្សព្វផ្សាយដ៏អស្ចារ្យជាមួយនឹងផ្នែកកិច្ចការសាធារណៈ និងនិតិកម្មរបស់យើង ដូច្នេះយើងអាចមានកិច្ចប្រជុំមួយដើម្បីជួយបញ្ជូនព័ត៌មានទៅតាមរយៈសាលារបស់គេ ។

9. អ្នកចូលរួម៖ ខ្ញុំគិតថាវាសំខាន់ណាស់ត្រូវមានក្រុមពិភាក្សាមួយដែលនិយាយពីអ្វីដែលយើងមើលឃើញថាជាបញ្ហាប្រឈមជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតនោះ ។ យើងរំភើបខ្លាំងណាស់អំពីអ្វីដែលថ្មីនេះ ហើយនិយាយពីវា ប៉ុន្តែ

គ្មាននរណាម្នាក់សួរថា "តើអ្វីជាបញ្ហាប្រឈមជាមួយនឹងអ្វីដែលថ្មីនេះទាល់តែសោះ?" ខ្ញុំគិតថាវាមានសារៈសំខាន់ត្រូវមានក្រុមពិភាក្សាមួយជាមួយនឹងអ្នកដែលជាអ្នកតែងតែចេញទៅបោះឆ្នោតនៅសហគមន៍ពលរដ្ឋដើមកំណើតអាមេរិកឡាទីននេះ ហើយសួរ "តើអ្វីទៅជាឧបសគ្គចំពោះការធ្វើផែនការ?" ដោយសារតែខ្ញុំគិតថាយើងមានចំណេះដឹងច្រើនពីសហគមន៍របស់យើង ហើយជំនួសឲ្យការគ្រាន់តែផ្តល់ព័ត៌មានចេញទៅនោះ យើងគួរតែចំណាយពេលសួរពីអ្វីដែលជាបញ្ហាប្រឈម និងរបៀបដែលយើងដោះស្រាយបញ្ហាប្រឈមទាំងនោះ ។

   a. បុគ្គលិក ROV៖ កន្លែងដែលជាឱកាសមួយផ្សេងទៀតនោះគឺគណៈកម្មាធិការប្រឹក្សាស្តីពីលទ្ធភាពទទួលបានផ្នែកភាសា (LAAC) ដែលយើងបានបង្កើតឡើង ហើយដែលបច្ចុប្បន្ននេះយើងនៅតែកំពុងស្វែងរកសមាជិកដែលចូលរួមនៅតាមសហគមន៍នីមួយៗ ។ បច្ចុប្បន្ននេះ យើងមិនមានតំណាងភាសាអេស្ប៉ាញនៅឡើយទេ ។ គណៈកម្មាធិការនេះទើបតែបានចាប់ផ្តើមជួបគ្នាបានពីរដង ហើយយើងនឹងមានកិច្ចប្រជុំប្រចាំខែ ។ យើងកំពុងព្យាយាមជ្រើសរើសសមាជិក ។ យើងទើបតែអាចជ្រើសរើសបានសមាជិកនិយាយភាសាកាតាឡុកម្នាក់ចេញពីកិច្ចប្រជុំសហគមន៍កាតាឡុករបស់យើង ។ ការផ្តោតការយកចិត្តទុកដាក់របស់គណៈកម្មាធិការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC) គឺធ្វើយ៉ាងណាឲ្យបញ្ហាទទួលបានផ្នែកភាសាឲ្យបានដឹងទៅដល់សហគមន៍របស់យើង ។ ការងារមួយទៀតដែលយើងកំពុងតែធ្វើនោះគឺទាក់ទងទៅនឹងការធ្វើបទបង្ហាញនានានោះគឺ សម្ព័ន្ធអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ។ យើងបានបង្កើតគណៈកម្មការមួយសម្រាប់សហគមន៍ជនចាស់ជរានិងជនមានពិការភាព ហើយគណៈម្មការភាសា ប៉ុន្តែយើងចង់ធ្វើការបណ្តុះបណ្តាលឲ្យបានច្រើន ដូច្នេះហើយនោះជាមូលហេតុដែលយើងមានសម្ព័ន្ធភាពគណៈកម្មការ VEOC ដែលអាចបណ្តុះបណ្តាលគ្រូបង្គោលដោយផ្ទាល់ និងធ្វើបទបង្ហាញនានាបាន ដូច្នេះហើយនោះក៏ជាឱកាសផងដែរ ។

10. បុគ្គលិក ROV៖ ឧទាហរណ៍កាលពីដើម យើងមានសង្កាត់បោះឆ្នោតដល់ទៅ 800 តែមានសង្កាត់តែ 400 ប៉ុណ្ណោះដែលកំណត់គោលដៅសម្រាប់សហគមន៍អេស្ប៉ាញ នេះមានន័យថាមានតែប្រាំនៃសង្កាត់ប៉ុណ្ណោះដែលមានបុគ្គលិកនិយាយតែភាសាអេស្ប៉ាញ ។ ជាមួយនឹងច្បាប់ VCA គោលបំណងរបស់យើងគឺមណ្ឌលបោះឆ្នោតនឹងមានបុគ្គលិកនិយាយពីរភាសាដែលនឹងអាចជួយដល់អ្នកបោះឆ្នោតបាន ។
11. អ្នកចូលរួម៖ វាសំខាន់ណាស់ត្រូវធ្វើវាកាន់តែងាយស្រួលបោះឆ្នោត ប៉ុន្តែពេលខ្លះវាពិបាកសម្រាប់សហគមន៍របស់យើងដើម្បីអនុវត្តទៅតាមការផ្លាស់ប្តូរនានា ដូចជាការបន្ថែមឲ្យមានភាពកក់ក្តៅដែលការបោះឆ្នោតរបស់គេនឹងត្រូវរាប់ របៀបបំពេញសន្លឹកឆ្នោត និងលក្ខណៈងាយស្រួលដឹងថាទៅបោះឆ្នោតនៅកន្លែងណា ។ បច្ចេកវិទ្យាថ្មីអស់ទាំងនេះ និងច្បាប់ថ្មីនេះ អាចនឹងធ្វើឲ្យពួកគេលើកដៃចុះចាញ់ហើយបោះបង់ចោលក៏ថាបាន ។

   a. បុគ្គលិក ROV៖ 75-80% នៃពលរដ្ឋ គ្មានអ្វីផ្លាស់ប្តូរទាល់តែសោះនៅក្នុងការបោះឆ្នោតរបស់គេ ប៉ុន្តែសម្រាប់ 20-25% នៃអ្នកបោះឆ្នោតផ្សេងទៀត វានឹងមានការផ្លាស់ប្តូរ ។

12. បុគ្គលិក ROV៖ នៅលើគេហទំព័ររបស់យើង ឯកសារផ្សព្វផ្សាយទាំងអស់នឹងត្រូវបកប្រែជាភាសាអេស្ប៉ាញ ។ យើងនឹងមានព័ត៌មាននៅក្នុងសេចក្តីណែនាំដែលមានផ្ទុកព័ត៌មានស្តីពីការបោះឆ្នោត ហើយនឹងផ្ញើវាទៅអ្នកបោះឆ្នោតទាំងអស់ ដែលបានស្នើសុំចង់បានវាតាមប្រៃសណីយ៍ ។ យើងកំពុងធ្វើបច្ចុប្បន្នភាពនៅលើគេហទំព័ររបស់យើង ប៉ុន្តែយើងពិតជាមានព័ត៌មានស្តីពីច្បាប់ថ្មីនេះនៅលើគេហទំព័ររបស់យើងជាភាសាអេស្ប៉ាញ ។ យើងនៅបាត់ពីរបីទំព័រនៅលើគេហទំព័ររបស់យើង ដោយសារតែយើងបង្ហោះគេហទំព័រយើងជាភាសាអង់គ្លេស ប៉ុន្តែមកដល់ពេលនេះ យើងមានបួនទំព័រហើយនៅលើគេហទំព័ររបស់យើងជាភាសាអេស្ប៉ាញ ។
13. អ្នកចូលរួម៖ ជាមូលដ្ឋាននោះ អ្នកត្រូវតែនិយាយជាភាសាអង់គ្លេស ហើយភាសាទីពីរអាស្រ័យទៅលើការជ្រើសរើសរបស់អ្នក មិនមែនមានតែភាសាអេស្ប៉ាញមួយប៉ុណ្ណោះទេ៖ មានវៀតណាម ចិន អេស្ប៉ាញ តាកាឡុក ប៉ុន្តែភាសាជាមូលដ្ឋានសម្រាប់មន្ត្រីបោះឆ្នោតនោះគឺ អង់គ្លេស ។

   a. បុគ្គលិក ROV៖ យើងពង្រីកភាសាហើយនឹងមានភាសាសរុបចំនួនប្រាំបួនសម្រាប់សន្លឹកឆ្នោតរបស់យើង ។ យើងនឹងបន្ថែមភាសាបួន៖ ហ៊ីនឌូ កូរ៉េ, និងខ្មែរ ដូច្នេះយើងនឹងមានទាំងប្រាំបួនភាសានៅក្នុងសន្លឹកឆ្នោតរបស់យើង ។

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*មតិចូលរួមជាសាធារណៈ:/សំណួរ៖*

1. (គ្មាន)

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ សាលាភាគច្រើនមានសិក្ខាសាលាស្តីពី "មាតាបិតាសាកលវិទ្យាល័យ" ឬ "គ្រួសារសាកលវិទ្យាល័យ" ដែលមួយថ្ងៃនោះមានការចូលរួមពីគ្រប់មណ្ឌលសិក្សាធិការ ហើយប្រសិនបើមាននរណាម្នាក់ធ្វើបទបង្ហាញពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត ជាភាសាអង់គ្លេស អេស្ប៉ាញ វៀតណាម ចិន ឬនៅកន្លែងណាក៏ដោយ អ្នកអាចជួបជាមួយនឹងមនុស្សជាច្រើនដោយសារតែគេកំពុងចូលរួមជាស្រេចក្នុងព្រឹត្តិការណ៍នេះ ។ នេះនឹងជួយភ្ជាប់បានច្រើនទៅមនុស្សជាច្រើយ៉ាងឆាប់រហ័ស ។ យើងទទួលបានមនុស្សរហូតដល់ទៅ 200 នាក់ក្នុងរយៈពេល 3 ម៉ោង ហើយអ្នកអាចមានឱកាសណែនាំពីច្បាប់នេះទៅដល់មនុស្សថ្មីក្នុងរយៈពេលពីរបីនាទី ។
2. បុគ្គលិក ROV៖ ឯកសារផ្សព្វផ្សាយទាំងឡាយ ហើយឯកសារផ្តល់ជូននានា យើងនឹងធ្វើជាភាសាផ្សេងៗគ្នា យើងអាចផ្តល់ដល់អ្នកទាំងអស់គ្នាជាអេឡិចត្រូនិកដែលងាយស្រួលផ្តល់ ។ អ្វីៗទាំងអស់វាត្រូវតែជាកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ ដូច្នេះយើងទាំងអស់គ្នាធ្វើការផ្តោតទៅច្បាប់ VCA ជាមួយគ្នា ប៉ុន្តែយើងពិតជាត្រូវការដៃគូសហគមន៍របស់យើងឲ្យជួយ ។
3. បុគ្គលិក ROV៖ យើងយល់ថាការព្រួយបារម្ភអំពីការទំនាក់ទំនងទៅកាន់សហគមន៍ទាំងអស់ និងភាពលំបាកលំបិននៃការទំនាក់ទំនងទៅកាន់អ្នកនិយាយភាសាកំណើត នៃភាសាជាក់លាក់ឲ្យចេញមកបោះឆ្នោតនៅថ្ងៃនោះ ។ យើងព្យាយាមធ្វើការផ្សព្វផ្សាយទៅគ្រប់សហគមន៍ មិនត្រឹមតែសហគមន៍ជាក់លាក់មួយនោះទេ ហើយសហគមន៍ណាដែលចង់ធ្វើការជាមួយយើង ។ យើងមានប័ណ្ណចំណាប់អារម្មណ៍ ដែលអ្នកអាចបំពេញ និងបង្ហាញពីការព្រួយបារម្ភ និងចង់បានដើម្បីឲ្យមានអារម្មណ៍កក់ក្តៅនៅក្នុងការរៀនពីដំណើរការជាភាសាកំណើតរបស់អ្នកនោះ ។ យើងព្យាយាមជួយធ្វើវាឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ។ យើងនឹងផ្តល់កម្មវិធីសម្ព័ន្ធភាពដើម្បីការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ហើយយើងនឹងធ្វើការងារនេះជាភាសាផ្សេងៗគ្នា ហើយនេះគឺជាមូលហេតុដែលយើងមានកិច្ចប្រជុំទាំងនេះ សូមប្រាប់យើងពីអារម្មណ៍យល់ឃើញ និងបន្ទាប់មកផ្តល់ដល់យើងនូវព្រឹត្តិការណ៍ ឬសិក្ខាសាលាដែលអ្នកអាចដឹងសម្រាប់ការងារផ្សព្វផ្សាយ ។ នៅពេលយើងបានដឹងពីការព្រួយបារម្ភផ្សេងៗគ្នាទាំងនេះហើយ នោះយើងអាចធ្វើការជាមួយនិងជួយដល់សហគមន៍ផ្សេងគ្នាទាំងនេះ ។ យើងមានបុគ្គលិកដែលចេះនិយាយពីរភាសានៅក្នុងការិយាល័យយើង ដែលជួយដល់ការងារផ្សព្វផ្សាយ ។ នេះមិនមែនជាវេទិកាតែមួយទេ ដែលយើងត្រូវព្យាយាមនិងទទួលគ្រប់ភាសាទាំងអស់នៅក្នុងសហគមន៍ទាំងអស់នោះ យើងក៏មានគណៈកម្មាធិការប្រឹក្សាដើម្បីលទ្ធភាពទទួលបានជំនួយផ្នែកភាសា ។ ទាំងនេះជាកិច្ចប្រជុំដែលយើងត្រូវការអ្នកទាំងអស់គ្នាចូលរួមនិងជួបជារៀងរាល់ខែ ហើយយើងនៅតែមិនទាន់មាននរណាម្នាក់ពីសហគមន៍និយាយភាសាអេស្ប៉ាញបង្ហាញខ្លួននៅឡើយដែរ ។ ការព្រួយបារម្ភទាំងអស់នេះដែលអ្នកមាន ពាំនាំមកកាន់គណៈកម្មការនេះ និងបង្ហាញពីតម្រូវការដែលអ្នកឃើញនៅក្នុងសហគមន៍របស់អ្នកផ្ទាល់ ។ យើងអាចដឹងច្រើនបានតែដោយសារការទំនាក់ទំនងដែលយើងមាន ដូច្នេះដើម្បីឲ្យកាន់តែមានប្រសិទ្ធិភាពនិងទទួលបានលទ្ធផលច្រើនចេញពីកិច្ចប្រជុំនេះនោះ គឺប្រសិនបើមាននរណាម្នាក់ក្នុងចំណោមអ្នកអាចមកចូលរួមកិច្ចប្រជុំទាំងនេះបាន ។ យើងក៏មានកិច្ចប្រជុំមួយទៀតហៅថា គណៈកម្មាធិការប្រឹក្សាដើម្បីលទ្ធភាពបោះឆ្នោត។ នេះគឺដើម្បីជួយអ្នកដែលមានពិការភាពដោយត្រូវប្រាកដថាពួកគេអាចរកបានវិធីបោះឆ្នោតមួយដ៏ត្រឹមត្រូវបាន ។ គណៈកម្មាធិការទាំងអស់ដែលយើងមាន នរណាម្នាក់ក៏សូមស្វាគមន៍ចូលរួមដែរ ។ បើទោះបីជានេះជាកិច្ចប្រជុំសហគមន៍និយាយភាសាអេស្ប៉ាញក៏ពិតមែន នរណាក៏ស្វាគមន៍ចូលរួមដែរ ។ បើទោះជាកិច្ចប្រជុំនិយាយថាវាជាកិច្ចប្រជុំធំក៏ដោយ ក៏វាមិនមែនមានន័យថាវាសម្រាប់តែអ្នកបោះឆ្នោតនិយាយភាសាអង់គ្លេសទេ វាបើកទូលាយដល់អ្នកគ្រប់គ្នា ដូច្នេះអ្នកគ្រប់គ្នាក៏អាចចូលមកបានដែរ ។ កិច្ចប្រជុំចុងក្រោយ ដែលជាកិច្ចប្រជុំសំខាន់បំផុតនោះ ដែលក្រែងលោអ្នកទាំងអស់គ្នាចង់ចូលរួមនោះ វាគឺ (VEOC) សម្ព័ន្ធភាពដើម្បីការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ។ នេះគឺជាវេទិកាដែលយើងស្តាប់អ្នកទាំងអស់គ្នា យើងក៏មានគម្រោង ហើយអ្វីៗដែលបានបង្ហាញនោះ គឺយើងមានទាំងអស់ ហើយយើងនឹងបកប្រែវា ។ ប្រសិនបើអ្នកប្រាប់យើងថាអ្នកត្រូវការឲ្យមានថ្នាក់មួយដែលឪពុកម្តាយចូលរួមនោះ ហើយចង់ចូលរួមនិងរៀនពីប្រព័ន្ធថ្មីនោះ អ្នកត្រូវតែប្រាប់យើងឲ្យបានដឹង ។ ប្រសិនបើថ្នាក់នោះសុទ្ធតែអ្នកនិយាយភាសាអេស្ប៉ាញនោះ យើងនឹងរៀបចំឲ្យប្រាកដថាសមាជិកម្នាក់នៃពួកយើងដែលចេះពីរភាសាអាចចូលរួមនិងធ្វើការជាមួយអ្នក ។ យើងនឹងនាំយកមកជាមួយនូវឯកសារផ្សព្វផ្សាយទាំងអស់របស់យើង បង្ហាញវាទៅអ្នក ហើយបន្ទាប់មកអ្នកអាចយកវាទៅហើយបង្ហាញដល់សហគមន៍របស់អ្នកផ្ទាល់ ។

4. អ្នកចូលរួម៖ ខ្ញុំភើបជាខ្លាំងអំពីការផ្លាស់ប្តូរ ខ្ញុំគ្រាន់តែមានអារម្មណ៍ថាវាជាការផ្លាស់ប្តូរច្រើន ដែលទាំងអស់ប្តូរក្នុងពេលតែមួយ ហើយដោយពលរដ្ឋមានជំងឺថប់អារម្មណ៍ស្រាប់នោះ សូម្បីតែការផ្លាស់ប្តូរដ៏តូចមួយនោះក៏បន្ថែមទម្ងន់ដល់វាដែរ ។ ខ្ញុំក៏គិតថាកម្រិតភាពកក់ក្តៅនៃភាសាសាក៏នឹងមានការប៉ះពាល់ដ៏ធំផងដែរ ពីព្រោះនៅពេលនេះខ្ញុំមានអារម្មណ៍ថាខ្ញុំដូចជាអ្នកខាងក្រៅទៅវិញ ។ ដូច្នេះ ប្រសិនបើនរណាម្នាក់មិនគួរសមដក់ខ្ញុំ ឬមិនឯមិនផ្តល់ដល់ខ្ញុំនូវឯកសារផ្សព្វផ្សាយរបស់ខ្ញុំជាភាសាអេស្ប៉ាញ ឬវៀតណាមទេនោះ ខ្ញុំអាចនឹងមានអារម្មណ៍ពិតជាមិនស្និទ្ធស្នាលនេះនាពេលនេះ ក៏ព្រោះតែមានជំងឺថប់អារម្មណ៍ច្រើនណាស់នៅក្នុងសហគមន៍ ។ ខ្ញុំគិតថានេះជាផ្នែកមួយនៃការងារដែលយើងចាំបាច់ត្រូវធ្វើ ដែលត្រូវអប់រំដល់ពលរដ្ឋដែលនឹងមកកាន់ទីតាំងនានា ដោយសារតែទាំងអស់នេះសុទ្ធតែអាចមានឥទ្ធិពលលើ ។
    a. បុគ្គលិក ROV៖ នេះគឺជាមូលហេតុដែលយើងកំពុងព្យាយាមផ្សព្វផ្សាយនាពេលនេះ ហើយមិនមែនពីរខែមុនថ្ងៃបោះឆ្នោតនោះទេ។ ដូច្នេះការងារទាំងអស់នេះដែលយើងធ្វើជាមួយកិច្ចប្រជុំទាំងឡាយដែលកំពុងធ្វើឡើងនាពេលនេះ យើងអាចនឹងធ្វើខ្លះនៅក្នុងខែស្លឹកឈើជ្រុះ ដើម្បីចាប់ផ្តើមអ្វីៗគ្រប់យ៉ាង ។
5. អ្នកចូលរួម៖ ខ្ញុំជឿថាភាពមិនប្រែប្រួលនៃសារគឺមានសារៈសំខាន់ណាស់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយជាភាសាអេស្ប៉ាញរបស់យើង ។ ទីតាំងសហគមន៍និយាយភាសាអេស្ប៉ាញបានចាប់ផ្តើមពី 30 មកដូចជាដប់ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ។ ដូច្នេះវាមានការកាត់បន្ថយធំណាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយភាសាអេស្ប៉ាញនោះ ។ វិទ្យុគឺជាប្រព័ន្ធផ្សព្វផ្សាយដ៏ល្អដោយហេតុថាមានមនុស្សច្រើនស្តាប់វិទ្យុនៅពេលគេកំពុងធ្វើការ ។
6. អ្នកចូលរួម៖ ខ្ញុំស្គាល់អ្នកគ្រប់គ្រងស្ថានីយ៍វិទ្យុអេស្ប៉ាញ *La Kaliente* ហើយខ្ញុំនឹងសួរពួកគេមើល ។
7. អ្នកចូលរួម៖ វិនិយោគទៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយហេតុថាគ្មាននរណាម្នាក់មើលទូរទស្សន៍ទៀតទេ ។
8. បុគ្គលិក ROV៖ ប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលល្បី ឬមានគេស្គាល់ច្រើននៅសហគមន៍ ដែលមានអ្នកដើរតាមច្រើន សូមប្រាប់ដល់យើងដើម្បីយើងអាចទាក់ទងទៅពួកគេ ហើយនោះជាអ្វីដែលយើងត្រូវការ គឺភាពជាដៃគូ ។ យើងនឹងមានកិច្ចប្រជុំចាប់ផ្តើមកម្មវិធីមួយនៅដើមខែសីហា ហើយនៅកិច្ចប្រជុំនេះយើងចង់ឲ្យអ្នកចូលរួមដើម្បីប្រាប់យើងពីធាតុចូលនិងការព្រួយបារម្ភទាំងអស់របស់អ្នក ។

## VIII. ប្រធានបទបន្ទាប់បន្សំ/សំណួរ៖

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ ការព្រួយបារម្ភរបស់ខ្ញុំគឺអំពីសុចរិតភាពការបោះឆ្នោត ។ នៅឆ្នាំ 2016 មានបុរសម្នាក់ដែលមកបោះឆ្នោតនៅសង្កាត់របស់យើង ប៉ុន្តែគាត់មិនរស់នៅទីនេះទេ គាត់រស់នៅឯ Las Vegas។ គាត់បានបោះឆ្នោតនៅ Las Vegas រួចហើយ ហើយនៅតែអាចមកបោះឆ្នោតនៅទីនេះបាន ។
    a. បុគ្គលិក ROV៖ យើងអាចចាប់បញ្ជូនទៅកាន់មេធាវីមណ្ឌលដែលនឹងស៊ើបអង្កេតបានប្រសិនបើប្រជាជនជឿថាគេមិនរស់នៅទីនេះ ។
2. បុគ្គលិក ROV៖ នៅយើងស្វែងរកទីតាំងអាចប្រើបាននោះ ខ្ញុំបានសុំពួកគេក្រែងខ្ញុំអាចត្រឡប់ទៅធ្វើបទបង្ហាញវិញបាន ។ យើងពិតជាចង់នាំមកជាមួយនូវបច្ចេកវិទ្យាថ្មីនេះមកដល់សាធារណជន និងក្រុមសហគមន៍ផ្សេងៗគ្នា ហើយអញ្ជើញពួកគេមកឃើញបច្ចេកវិទ្យាថ្មី និងសួរពួកយើងនូវសំណួរសន្តិសុខទាំងនោះ ដើម្បីឲ្យពួកគេគាន់តែមានភាពកក់ក្តៅអំពីវា ។ នេះជាអ្វីដែលយើងមិនធ្លាប់ធ្វើពីមុនមក។ ដូច្នេះនេះជាអ្វីមួយថ្មីដែលយើងកំពុងសាកល្បង ។
3. អ្នកចូលរួម៖ ត្រឡប់ទៅកាន់សុចរិតភាពបោះឆ្នោតវិញ ដោយមានការលួចចូលក្នុងប្រព័ន្ធអនឡាញដូចជាចិន និងរុស្ស៊ី ហើយអ្នកទាំងនោះ តើពួកគេលែងជាមួយប្រព័ន្ធរបស់ទេ?
    a. បុគ្គលិក ROV៖ យើងមិនធ្លាប់មានបញ្ហាណាមួយនឹងសន្តិសុខឡើយ ។ យើងធ្វើការជាមួយនឹងក្រសួងសន្តិសុខមាតុភូមិ ប្រធានការិយាល័យសន្តិសុខព័ត៌មានខោនធី ប្រធានការិយាល័យព័ត៌មានបុគ្គលខោនធី ការិយាល័យរដ្ឋលេខាធិការ ដូច្នេះយើងធ្វើការជាមួយនឹងកម្រិតសហព័ន្ធ រដ្ឋ និងកម្រិតមូលដ្ឋាន ។ យើងតេស្តពីការលួចជ្រៀតចូល ការបណ្តុះបណ្តាលពីការបោកបញ្ឆោតតាមអនឡាញ និងយើងទើបតែបានអនុវត្តបច្ចេកវិទ្យាទប់ស្កាត់ការបោកបញ្ឆោតថ្មី ដូច្នេះមានរឿងជាច្រើនដែលយើងកំពុងតែធ្វើ ។ ប្រព័ន្ធរៀបជាតារាងបញ្ជីមិនត្រូវបានភ្ជាប់ទៅនឹងអ៊ីនធឺណិតទេ ។ យើងយកលទ្ធផលនានាចេញពីកុំព្យូទ័រនោះ ដែលត្រូវបានធ្វើតេ ហើយពិនិត្យមើលយ៉ាងលម្អិតពីការធ្វើតេស្ត ដើម្បីឲ្យប្រាកដថាវារាប់បានត្រឹមត្រូវមុននឹងយើងចាប់ផ្តើមរាប់និងចាប់ផ្តើមរាប់តាមក្រោយភ្លាមៗ ហើយបានយកលទ្ធផលទៅកាន់ប្រព័ន្ធដែលភ្ជាប់ទៅនឹងអ៊ីនធឺណិតដើម្បីគ្រាន់តែបង្ហោះវានៅទីនោះប៉ុណ្ណោះ ។

4. អ្នកចូលរួម៖ ខ្ញុំបានឮថាដរាបណាគេឆ្លងផុតព្រំដែន NGO អាចយកគេទៅកាន់ការិយាល័យខោនធី ហើយផ្តល់ឲ្យពួកគេកញ្ចប់ទាំងមូលមួយ ដែលមានទាំងប័ណ្ណអ្នកចុះឈ្មោះបោះឆ្នោតផងដែរ មែនទេ? ។
    a. បុគ្គលិក ROV៖ ខ្ញុំមិនដឹងថា NGO ជានរណាទេ? នៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត នៅពេលគេចុះឈ្មោះ គេត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលេខសន្តិសុខសង្គម បួនលេខចុងក្រោយនៃលេខសន្តិសុខសង្គមរបស់គេ ឬលេខប័ណ្ណបើកបររបស់គេ ។
5. អ្នកចូលរួម៖ នៅទីនេះក្នុង California និងនៅ New York តើវាអាចទៅរួចទេដែលមនុស្សមិនដឹងថាអ្នកជាពលរដ្ឋនៅទីនេះ ហើយអាចដាក់ពាក្យសុំប័ណ្ណបើកបរ និងពួកគេបានដាក់ពាក្យសុំបោះឆ្នោត តើនេះជាអ្វីដែលធ្វើទៅបានទេ?
    a. បុគ្គលិក ROV៖ ទេ អ្នកដាច់ខាតត្រូវតែជាពលរដ្ឋដើម្បីអ្នកអាចបោះឆ្នោតបាន ។ មានមនុស្សម្នាក់ដែលពិនិត្យទៅលើគ្រប់ផ្នែកនៃព័ត៌មានទាំងអស់ដែលអ្នកបានបំពេញដើម្បីឲ្យប្រាកដថាត្រឹមត្រូវ ។ បើទោះបីជាអ្នកមិនមែនជាពលរដ្ឋក៏ដោយ យើងរក្សាលិខិតបញ្ជាក់នោះនៅក្នុងសំណុំឯកសារជាភស្តុតាងដែលនៅពេលអ្នកចូលមកហើយនិយាយថា "ខ្ញុំបានព្យាយាមបានទៅការិយាល័យបោះឆ្នោត និងបោះឆ្នោត" នៅពេលអ្នកមិនមែនជាពលរដ្ឋនោះ ។ តាមច្បាប់ព័ត៌មានទាំងអស់ត្រូវបានរក្សាទុកក្នុងសំណុំឯកសារសម្រាប់រយៈពេលជាចំនួនឆ្នាំជាក់លាក់ ហើយដែលជួនកាលយើងរក្សាទុកសម្រាប់ពីរឆ្នាំឬច្រើនជាងក៏មាន ។
    b. អ្នកចូលរួម៖ ហើយក្នុងនាមជាជនអន្តោប្រវេសន៍ ការបោះឆ្នោតនៅពេលអ្នកមិនទាន់ជាពលរដ្ឋនោះគឺជាបទឧក្រិដ្ឋដែលកាន់តែធ្ងន់ធ្ងរដែលអាចធ្វើឲ្យអ្នកអាចត្រូវបានគេបណ្តេញចេញបាន ។ វាមិនមែនជាអ្វីមួយដែលអ្នកអាចរួចខ្លួនបានទេនោះ ។
6. អ្នកចូលរួម៖ នៅក្នុងខិត្តប័ណ្ណដែលអ្នកបានផ្ញើចេញនោះ តើមានរយៈពេលយូរប៉ុណ្ណាមុនការបោះឆ្នោតដែលអ្នកនឹងផ្ញើវាចេញ?
    a. បុគ្គលិក ROV៖ ច្បាប់អនុញ្ញាតឲ្យយើងផ្ញើចេញនូវខិត្តប័ណ្ណទាំងនោះលឿនបំផុតត្រឹម 40 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ យើងព្យាយាមផ្ញើវាចេញឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ វាចំណាយពេលពីរបីសប្តាហ៍ដើម្បីផ្ញើវាចេញ ពីព្រោះវាមកទាំងឡានៗរាល់ថ្ងៃ ហើយយើងត្រូវតែព្រើនបញ្ចូលនូវអសយដ្ឋាន ។ យើងផ្ញើវាទាំងនោះចេញចន្លោះ 40 និងដប់ថ្ងៃ អាស្រ័យលើការបោះឆ្នោតតូចឬធំ ដែលវាមួយចំនួននោះអាចត្រូវផ្ញើចេញមុនដោយសារតែមិនសូវមានអ្វីត្រូវរៀបចំ ។ ចំណែកឯការបោះឆ្នោតធំវិញ ខិត្តប័ណ្ណ 100 ទំព័រដែលអាចចំណាយពេលយូរដើម្បីផលិត នឹងត្រូវផ្ញើចេញពេលក្រោយ ។
7. អ្នកចូលរួម៖ តើខិត្តប័ណ្ណរដ្ឋបញ្ជូនចេញមុន ឬ ក្រោយខិត្តប័ណ្ណរបស់អ្នក?
    a. បុគ្គលិក ROV៖ វាត្រូវបានបញ្ជូនចេញមុន ។ រដ្ឋផ្ញើចេញតែខិត្តប័ណ្ណមួយសម្រាប់មួយគ្រួសារ ហើយបន្ទាប់មកសម្រាប់យើង បើទោះជាមាននរណារម្នាក់ជ្រើសរើសយកភាសាអេស្ប៉ាញក៏ដោយ យើងផ្ញើចេញភាសាអង់គ្លេសទៅគ្រប់គ្នាទាំងអស់។ ដូច្នេះយើងផ្ញើជាងមួយលានខិត្តប័ណ្ណមុន ហើយបន្ទាប់មកយើងផ្ញើចេញទៅតាមភាសា ។ អ្នកនឹងដំបូងទទួលបានខិត្តប័ណ្ណជាភាសាអង់គ្លេស ហើយបន្ទាប់មកទើបភាសាអ្នកត្រូវការ ។

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

## គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់អ្នកនិយាយភាសាចិន

មជ្ឈមណ្ឌលសហគមន៍ Quinlan

10185 N. Stelling Rd, Cupertino, CA

បន្ទប់សង្គម

ថ្ងៃអង្គារ ទី 25 ខែមិថុនា ឆ្នាំ 2019

ម៉ោង 5:30 ដល់ម៉ោង 7:00 យប់

**វត្តមានអ្នកចូលរួម ៖**

អភិបាលក្រុងរង Cupertino, តំណាងមកពីមជ្ឈមណ្ឌលបោះឆ្នោតតៃវ៉ាន់, តំណាងមកពី ROV ខោនធី Alameda, និងសមាជិកសាធារណៈ

**វត្តមានបុគ្គលិកចូលរួម ៖**

Shannon Bushey, Vanessa Hamm, Andrea Solorio, Shelby Galaviz, Michael Borja, Magdalena Sta Maria, Priscilla Favela, Janora Davis, Patricia Lopez, Allen Ocampo, Linh Nguyen, Michelle Tran, Adrian Garcia, Paulo Chang, Alfred Gonzales, Eric Kurhi, Rachel Jung, Liz Oviedo, Chipo Mulenga, George Hiu, Mike Davis, Martin Ayala, Smita Shah, Lorenzo Castaneda, Diane Castaneda, Ruth Luo, Chenxi Ye

I. **សេចក្តីណែនាំ**

*កិច្ចស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅអំពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA), អ្នកបោះឆ្នោតនឹងអាចជ្រើសរើសពីរបៀបពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ទម្លាក់សន្លឹកឆ្នោតរបស់គេតាមប្រអប់ដាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*បទបង្ហាញស្តីពី VCA ត្រូវបានផ្តល់ជូន ។*

## III. គោលដៅនៃគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងការចូលរួមពីសហគមន៍ ។

*បទបង្ហាញរបស់ ROV ៖*

1. បុគ្គលិក ROV ៖ មណ្ឌលបោះឆ្នោត និងការពន្យល់អំពីលក្ខណៈវិនិច្ឆ័យទាំង 14 ។ បុគ្គលិកប្រើបន្ទប់សង្គមនៅក្នុងមជ្ឈមណ្ឌលសហគមន៍ Cupertino ដែលជាគំរូមួយនៃមណ្ឌលបោះឆ្នោតកំពុងមានភាពតូចចង្អៀត ។ បុគ្គលិកទទួលបន្ទុកក្នុងការកំណត់អត្តសញ្ញាណមណ្ឌលបោះឆ្នោតត្រូវបានណែនាំហើយអ្នកចូលរួមត្រូវបានជូនដំណឹងដល់បុគ្គលិកទាំងនេះ និងព័ត៌មានទំនាក់ទំនងក៏ត្រូវបានចុះបញ្ជីនៅលើប័ណ្ណផ្សព្វផ្សាយព័ត៌មាននៃមណ្ឌលបោះឆ្នោតក្នុងករណីដែលអ្នកណាម្នាក់មានគំនិតសម្រាប់ទីតាំងបោះឆ្នោត ។ បញ្ហាប្រឈមគឺមិនត្រឹមតែស្វែងរកកន្លែងប៉ុណ្ណោះទេ ប៉ុន្តែជាទីតាំងដែលអាចផ្តល់ចំនួនថ្ងៃជាក់លាក់បានផងដែរ ។
2. បុគ្គលិក ROV ៖ និយាយអំពីការកំណត់ផែនទី GIS ដើម្បីផ្តល់ការយល់ដឹងពីទស្សនៈទិន្នន័យ ។ ផែនទីបានពន្យល់ទាក់ទងនឹងមណ្ឌលបោះឆ្នោតរយៈពេល 11 ថ្ងៃ និងណែនាំលក្ខណៈវិនិច្ឆ័យទាំង 14 របស់មណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត ។ ឧទាហរណ៍មួយចំនួននៃលក្ខណៈវិនិច្ឆ័យគឺផ្អែកលើសហគមន៍ភាសា ។ ការកំណត់ផែនទី GIS កំពុងធ្វើការលើគុណភាពនៃទិន្នន័យ និងត្រូវការការចូលរួម ។
3. បុគ្គលិក ROV ៖ ប្រសិនបើគំនិតណាមួយសម្រាប់មណ្ឌលបោះឆ្នោត ឬសំណូមពរទាក់ទងនឹង EAP កើតឡើងបន្ទាប់ពីកិច្ចប្រជុំនេះ នោះសាធារណជនអាចចូលមើលទម្រង់មតិត្រឡប់នានានៅលើគេហទំព័រជម្រើសរបស់អ្នកបោះឆ្នោត ៖ sccgov.org/voterschoice ។ អាចផ្ញើទម្រង់ទាំងនេះតាមសំបុត្រ ឬអ៊ីមែលទៅ ROV តាមរយៈ voterschoice@rov.sccgov.org ។

*មតិចូលរួម/សំណួរពីសាធារណជន ៖*

1. បុគ្គលិក ROV ៖ យើងកំពុងស្វែងរកមតិត្រឡប់សម្រាប់ EAP ជាពិសេសពីសហគមន៍ចិន ប៉ុន្តែយើងបើកចំហចំពោះមតិយោបល់ណាមួយសម្រាប់ការអភិវឌ្ឍសេចក្តីព្រាង EAP នេះ ។ តើយើងគួរធ្វើយ៉ាងណាក្នុងការផ្សព្វផ្សាយ រកមើលទីតាំងមណ្ឌលបោះឆ្នោត ហើយតើយើងគួរដាក់ប្រអប់ដាក់សន្លឹកឆ្នោតក្នុងសហគមន៍នៅកន្លែងណា ?
2. អ្នកចូលរួម ៖ 12 ឬ 14 ថ្ងៃសម្រាប់មណ្ឌលបោះឆ្នោត តើថ្ងៃទាំងនោះបន្តជាប់ៗគ្នាជានិច្ចមែនទេ ? ព្រះវិហារខ្លះអាចជាជម្រើសល្អ ។ ព្រះវិហារខ្លះមានកន្លែងធំៗដែលអាចដាក់សម្ភារៈប្រើប្រាស់បាន ។
    a. បុគ្គលិក ROV ៖ មែនហើយ មណ្ឌលទាំងនោះដំណើរការបន្តជាប់ៗគ្នា ។ ព្រះវិហារគឺជាទីតាំងដ៏ល្អដែលអ្នកបោះឆ្នោតអាចស្គាល់ ទោះយ៉ាងណាក៏ដោយព្រះវិហារទាំងនោះមិនអាចដំណើរការបានគ្រប់ចំនួនថ្ងៃទាំងអស់នោះទេ ដោយសារតែមានសេវាកម្មផ្សេងទៀតដែលពួកគេត្រូវធ្វើ ។ កាលពីមុន ការប្រើទីតាំងនៅក្នុងព្រះវិហារមានភាពងាយស្រួល

ពីព្រោះថ្ងៃអង្គារ (ថ្ងៃបោះឆ្នោតធម្មតា) មិនបានប៉ះពាល់ជាមួយកាលវិភាគរបស់ព្រះវិហារឡើយ ។ ឥឡូវនេះពួកគេអាចនឹងផ្តល់ជូនតែថ្ងៃធ្វើការ ROV ប៉ុណ្ណោះ ប៉ុន្តែមិនមែនថ្ងៃចុងសប្តាហ៍ទេ ដោយសារតែសេវាកម្មព្រះវិហារ និងសកម្មភាពព្រះវិហារផ្សេងទៀត ។ យើងក៏ត្រូវរាប់បញ្ចូលពេលវេលាដើម្បីរៀបចំ និងបែងចែកសម្ភារៈដែលមានន័យថាត្រូវបន្ថែមមួយឬពីរថ្ងៃទៀត ។ ទាក់ទិននឹងបញ្ហានេះក៏ស្នើឲ្យមានមណ្ឌលបោះឆ្នោតដែលមានសុវត្ថិភាពប្រកបដោយប្រសិទ្ធភាពសម្រាប់សន្លឹកឆ្នោត និងឧបករណ៍បោះឆ្នោតផងដែរ ។

3. អ្នកចូលរួម ៖ តើអ្នកនិយាយអំពីពេលដែលអ្នកបោះឆ្នោតបានបោះឆ្នោតរួចហើយ ហើយសន្លឹកឆ្នោតទាំងនេះនឹងស្ថិតនៅទីតាំងតែមួយ មែនទេ ?
    a. បុគ្គលិក ROV ៖ សន្លឹកឆ្នោតនឹងត្រូវបានចាក់សោ និងបិទជិតដោយសុវត្ថិភាពនៅក្នុងមណ្ឌលបោះឆ្នោតរៀងរាល់យប់ ។ ដូច្នេះយើងត្រូវការទីតាំងដែលមានសុវត្ថិភាពបំផុតតាមដែលអាចធ្វើទៅបាន ។ តើមានសំណួរផ្សេងទៀតអំពីមណ្ឌលបោះឆ្នោតទេ ? វាមិនចាំបាច់ទាល់តែនៅ Cupertino ទេវាអាចនៅគ្រប់ទីកន្លែងក្នុងខោនធី ។ សូមផ្ញើអ៊ីមែលមកយើងតាមរយៈ voterschoice@rov.sccgov.org ។

4. បុគ្គលិក ROV ៖ ថ្ងៃនេះយើងបាននាំយកខិត្តប័ណ្ណ "ជ្រើសរើសវិធីដែលអ្នកបោះឆ្នោត" មកជូនអ្នក ។ ខិតប័ណ្ណនេះជាសេចក្តីសង្ខេបអំពី VCA និងវិធីសាស្ត្រថ្មីនៃការបោះឆ្នោតសម្រាប់ខោនធី ។ សម្រាប់ព័ត៌មានបន្ថែម សាធារណជនក៏អាចចូលប្រើថេបអំពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតនៅលើគេហទំព័រ ៖ www.sccvote.org/voterschoice ។
    a. បុគ្គលិក ROV ៖ ROV ក៏បានផ្តល់ "ប័ណ្ណអត្ថប្រយោជន៍" ដោយអញ្ជើញសាធារណជនឲ្យចូលរួមនៅក្នុងគណៈកម្មាធិការទីប្រឹក្សាលទ្ធភាពទទួលបានភាសា (LAAC), គណកម្មការប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC) និងសម្ព័ន្ធផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត (VEOC) ។ យើងកំពុងមានការប្រជុំ LAAC ហើយយើងត្រូវការសហគមន៍ដែលមានភាសាផ្សេងៗគ្នាដើម្បីចូលរួម ។ VAAC គឺសម្រាប់ការចូលរួមចំពោះលទ្ធភាពដែលអាចចេញចូលបានសម្រាប់មនុស្សគ្រប់គ្នាដើម្បីអាចបោះឆ្នោតបាន រួមទាំងជនពិការ ឬជនដែលមានតម្រូវការពិសេស ។ VEOC បានផ្តោតការយកចិត្តទុកដាក់លើការផ្សព្វផ្សាយ និងការអប់រំរបស់សហគមន៍ទៅលើប្រព័ន្ធបោះឆ្នោតថ្មី ។ តាមរយៈ VEOC នឹងផ្តល់ការបណ្តុះបណ្តាល និង "ថវិកា" ដល់អ្នកដើម្បីអាចជួយអប់រំសហគមន៍របស់អ្នក ។ យើងត្រូវការមនុស្សជាច្រើនទៀតដើម្បីបង្ហាញ និងចូលរួមក្នុងគណៈកម្មាធិការរបស់យើង ។ អ្នកចូលរួមម្នាក់របស់យើងបានផ្តល់ឲ្យយើងនូវមណ្ឌលបោះឆ្នោតមួយរួចហើយ ។ យើងក៏ត្រូវការបុគ្គលិក និងអ្នកស្ម័គ្រចិត្តថ្មីដើម្បីជួយយើងក្នុងផ្នែកភាសានៅមណ្ឌលបោះឆ្នោត ។

5. បុគ្គលិក ROV ៖ ROV នឹងត្រូវការមន្ត្រីបោះឆ្នោតថ្មី និងបុគ្គលិកសម្រាប់មណ្ឌលបោះឆ្នោត ។ យើងនៅតែផ្តល់ជូនប្រាក់ឧបត្ថម្ភដល់អ្នកស្ម័គ្រចិត្តដូចដែលយើងធ្លាប់មានកាលពីមុន ប៉ុន្តែឥឡូវនេះយើងកំពុងជួលជំនួយបន្ថែមក្នុងនាមជាបុគ្គលិកខោនធីដល់បុគ្គលិកការិយាល័យបោះឆ្នោតឲ្យបានគ្រប់គ្រាន់ ។ យើងនឹងចាប់ផ្តើមហៅទូរស័ព្ទនៅខែកញ្ញាដើម្បីសម្ភាស និងជួល

សូមមើលគេហទំព័រខោនធី និងស្វែងរក "បុគ្គលិកបោះឆ្នោត" តាមរយៈ http://www.sccgov.org/jobs ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកអាចស្គាល់ ចាប់អារម្មណ៍ចង់ដាក់ពាក្យចូលរួម ។

6. បុគ្គលិក ROV ៖ ចុះប្រសិនបើខ្ញុំជាអ្នកបោះឆ្នោតតាមការផ្ញើសំបុត្រ (VBM) ? តើមនុស្សគ្រប់គ្នានឹងទទួលបានសន្លឹកឆ្នោតផ្ញើតាមសំបុត្រដែរឬទេ ? តើខ្ញុំអាចចូល និងបោះឆ្នោតនៅមណ្ឌលបោះឆ្នោតបានទេ ប្រសិនបើគ្រប់គ្នាជាអ្នកបោះឆ្នោត VBM ?
    a. បុគ្គលិក ROV ៖ ពិតជាបាន ! ជាមួយ VCA អ្នកបោះឆ្នោតគ្រប់រូបនឹងទទួលបានសន្លឹកឆ្នោតក្នុងសំបុត្រដោយមិនចាំបាច់ចុះឈ្មោះក្នុងនាមជាអ្នកបោះឆ្នោតតាមសំបុត្រទេ ។ ភាពខុសគ្នាមួយទៀតនៃតំបន់/កន្លែងបោះឆ្នោតបើប្រៀបធៀបទៅនឹងមណ្ឌលបោះឆ្នោត VCA គឺថា ឥឡូវនេះយើងនឹងមានសន្លឹកឆ្នោតនៅលើម៉ាស៊ីនបោះពុម្ពសន្លឹកឆ្នោតតាមតម្រូវការ (BOD) ។ យើងនឹងអាចបោះពុម្ពសន្លឹកឆ្នោតដោយផ្អែកលើការចុះឈ្មោះរបស់អ្នក នៅឯមណ្ឌលបោះឆ្នោតណាមួយដែលអ្នកជ្រើសរើសទៅចូលរួម ព្រោះអ្នកលែងតម្រូវឲ្យរាយការណ៍ទៅការិយាល័យបោះឆ្នោតជាក់លាក់តែមួយទៀតហើយ ។ ជាមួយនឹងការអនុវត្ត VCA ចំនួនសន្លឹកឆ្នោតបណ្ដោះអាសន្នដែលត្រូវការនឹងថយចុះខ្លាំង ។ ឧទាហរណ៍ ប្រសិនបើខ្ញុំទៅបោះឆ្នោតនៅខោនធី Santa Clara ហើយខ្ញុំបានចុះឈ្មោះនៅ San Francisco នោះគឺជាពេលវេលាដើម្បីប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន ។ សេវាកម្មដូចគ្នានឹងការិយាល័យ ROV នៅ Berger Drive ផ្ដល់ជូនឥឡូវនេះនឹងមាននៅក្នុងមណ្ឌលបោះឆ្នោតចំនួន 120+ កន្លែង ។ យ៉ាងណាក្ដី ឥឡូវនេះបុគ្គលិកមណ្ឌលបោះឆ្នោតរបស់យើងនឹងត្រូវការបណ្ដុះបណ្ដាលជាមួយឧបករណ៍ថ្មី ។ ឧទាហរណ៍នៃ CVR (ការចុះឈ្មោះអ្នកបោះឆ្នោតតាមលក្ខខណ្ឌ) បុគ្គលិកនឹងចុះឈ្មោះបុគ្គលនោះ ប្រគល់លិខិតបញ្ជាក់ឲ្យពួកគេដើម្បីបំពេញ ហើយដាក់វានៅក្នុងស្រោមសំបុត្រដើម្បីផ្ទៀងផ្ទាត់នៅពេលក្រោយ ប្រសិនបើពួកគេអាច ឬមិនអាចបោះឆ្នោតនៅខោនធីរបស់យើង ។ សូមមើល VEOC របស់យើង (គណកម្មការផ្សព្វផ្សាយការអប់រំអ្នកបោះឆ្នោត) សម្រាប់ព័ត៌មានបន្ថែម ។

7. អ្នកចូលរួម ៖ តើត្រូវការរយៈពេលប៉ុន្មានដើម្បីបណ្ដុះបណ្ដាលបុគ្គលិកមណ្ឌលបោះឆ្នោត និងអ្នកស្ម័គ្រចិត្ត ?
    a. បុគ្គលិក ROV ៖ យើងនឹងមានបុគ្គលិកនៅមណ្ឌលបោះឆ្នោតច្រើនជាងនៅកន្លែងបោះឆ្នោត ។ យើងនឹងមានអ្នករៀបចំជួរ ហើយយើងនឹងបណ្ដុះបណ្ដាលបុគ្គលិករហូតដល់ទៅបួនទៅប្រាំថ្ងៃមុនពេលបើកមជ្ឈមណ្ឌលបោះឆ្នោត ជំនួសឲ្យការបណ្ដុះបណ្ដាលអ្នកស្ម័គ្រចិត្តចំនួនមួយថ្ងៃដែលធ្លាប់ទទួលបាន ។
    b. អ្នកចូលរួម ៖ ដំណើរការមិនដូចគ្នាទេ ?
    c. បុគ្គលិក ROV ៖ ស្រដៀងគ្នា ប៉ុន្តែបរិយាកាសនឹងមិនដូចគ្នាទេ ។ ប្រព័ន្ធបោះឆ្នោតគឺខុសគ្នាឆ្ងាយណាស់ ។ អ្វីៗទាំងអស់នឹងមាននៅក្នុងសន្លឹកឆ្នោតអេឡិចត្រូនិក ។ យើងនឹងបណ្ដុះបណ្ដាលសម្រាប់សេវាកម្មអតិថិជន និងការបណ្ដុះបណ្ដាលដែលមិនស្ទីកទម្រន់ ។

មានម៉ាស៊ីនបោះឆ្នោតថ្មីៗក៏ដូចជាសេវាកម្មថ្មីៗដែលបានផ្តល់ជូននៅមណ្ឌលបោះឆ្នោត ដែលពីមុនត្រូវបានផ្តល់ជូនតែនៅការិយាល័យ ROV ប៉ុណ្ណោះ ។ ដំណើរការត្រូវបាន ធ្វើបច្ចុប្បន្នភាព និងមានន័យថាសម្រាប់ការពង្រឹងសេវាកម្ម ដូច្នេះយើងចង់ធ្វើអ្វីដែល ត្រឹមត្រូវចាប់តាំងពីដំបូង ។ នេះជាសហគមន៍របស់អ្នក យើងទាំងអស់គ្នាចង់ធ្វើ ឲ្យបានត្រឹមត្រូវ ។

8. អ្នកចូលរួម ៖ តើមានប៉ុន្មានម៉ោង និងប៉ុន្មានថ្ងៃ ?
    a. បុគ្គលិក ROV ៖ មាន 8 ម៉ោងក្នុងមួយថ្ងៃ ប្រែប្រួលពី 11 ថ្ងៃ និង 4 ថ្ងៃ ។ យើងនឹងបើក ប្រាក់ខែឲ្យបុគ្គលិកសម្រាប់ម៉ោងធ្វើការ និងការបណ្តុះបណ្តាល ។
9. អ្នកចូលរួម ៖ តើមណ្ឌលបោះឆ្នោតដែលល្អបំផុតមានទំហំប៉ុនណា ?
    a. បុគ្គលិក ROV ៖ បីដងនៃទំហំ "បន្ទប់ធំ" ដែលយើងធ្លាប់ប្រើ ។ អាចយ៉ាងហោចណាស់ 40′x40′ ប៉ុន្តែយើងចង់បាន 60′x60′ ។
10. អ្នកចូលរួម ៖ តើអ្នកបាននិយាយជាមួយក្រុមហ៊ុនធំៗដូចជា Google ទេ ?
    a. បុគ្គលិក ROV ៖ នៅពេលដែលខ្ញុំនិយាយទៅកាន់ក្រុមហ៊ុនធំៗ ទ្វារចាំបាច់ត្រូវបើកចំហ ដល់សាធារណជនទាំងអស់រួមទាំងចំណតរថយន្តផងដែរ ។ ពួកគេក៏ត្រូវបើកសម្រាប់ថ្ងៃ និងម៉ោងដែលត្រូវការ ។
    b. អ្នកចូលរួម ៖ ពួកគេនឹងមានការយកចិត្តទុកដាក់អំពីសុវត្ថិភាព ។
    c. អ្នកចូលរួម ៖ ប្រសិនបើអ្នកនាំយកប្រព័ន្ធ ឬម៉ាស៊ីនបម្រើនៅក្នុងទីតាំងរបស់ពួកគេ អាចនឹងមានបញ្ហាសន្តិសុខកើតឡើង ។
    d. បុគ្គលិក ROV ៖ អ្នកនិយាយត្រូវហើយ យើងមានដំណើរការសន្តិសុខជាច្រើននៅនឹង កន្លែងពីព្រោះយើងតែងតែមានការព្រួយបារម្ភអំពីសុវត្ថិភាព មិនថាទីតាំងដែលយើង កំពុងពិចារណាសម្រាប់មជ្ឈមណ្ឌលបោះឆ្នោតនោះទេ ។ ប្រព័ន្ធដែលយើងកំពុងទិញ កំពុងត្រូវបានប្រើប្រាស់ដោយខោនធីផ្សេងទៀតផងដែរ ។ ប្រព័ន្ធដែលយើងប្រើមាន សុវត្ថិភាព បានបញ្ជាក់ និងបានសាកល្បងរួច ។ គ្រឿងបរិក្ខារចាំបាច់ត្រូវតែមានការ បញ្ជាក់ពីរដ្ឋលេខាធិការផងដែរ ។
11. អ្នកចូលរួម ៖ មូលហេតុដែលខ្ញុំមកទីនេះ ខ្ញុំនឹងធ្វើបទបង្ហាញស្តីពីសហគមន៍បោះឆ្នោតទូទៅ និងក្រុមបោះឆ្នោតជនជាតិភាគតិចផ្សេងៗគ្នាស្តីពីសុវត្ថិភាពនៃសន្លឹកឆ្នោតបណ្តោះអាសន្ន ។ នៅពេលដែលខ្ញុំផ្តល់បទបង្ហាញ ហើយពួកគេស្វែងយល់អំពីប្រព័ន្ធបោះឆ្នោតថ្មី ខ្ញុំហ៊ានភ្នាល់ថា ពួកគេនឹងយល់បានច្រើន ។
    a. បុគ្គលិក ROV ៖ យើងចង់ស្វែងយល់បន្ថែមអំពីបទបង្ហាញរបស់អ្នក ប៉ុន្តែយើងនឹងនិយាយ បន្ថែមទៀតអំពីរឿងនេះបន្ទាប់ពីកិច្ចប្រជុំ ។

12. អ្នកចូលរួម ៖ តើយើងនឹងនៅតែមានសន្លឹកឆ្នោតមែនទេ ?
    a. បុគ្គលិក ROV ៖ មែនហើយ យើងនៅតែមានសន្លឹកឆ្នោត ។ អ្នកនឹងទទួលបានសន្លឹកឆ្នោតជាក្រដាសនៅក្នុងសំបុត្រ ហើយប្រសិនបើអ្នកជ្រើសរើសមកមណ្ឌលបោះឆ្នោត យើងអាចបោះពុម្ពសន្លឹកឆ្នោតសម្រាប់អ្នកនៅនឹងកន្លែងបាន ។
13. អ្នកចូលរួម ៖ ទាក់ទងនឹង CVR តើអ្នកបញ្ជាក់ដូចម្ដេចអំពីមនុស្សម្នាក់ដែលទើបតែផ្លាស់ទីលំនៅ ? តើអ្នកបញ្ជាក់ថាពួកគេបានផ្លាស់ទីលំនៅដូចម្ដេច ? ពួកគេអាចនឹងផ្លាស់ទីលំនៅនៅថ្ងៃបន្ទាប់ម្ដងទៀត ។
    a. បុគ្គលិក ROV ៖ ពួកគេត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ក្រោមការពិន័យ និងការបំពានសម្បថ ហើយក្នុងករណីមានកំហុសណាមួយ យើងនឹងបញ្ជូនព័ត៌មានរបស់ពួកគេទៅកាន់មេធាវីមណ្ឌលដែលនឹងចាត់វិធានការបន្ថែមប្រសិនបើចាំបាច់ ។ ប៉ុន្តែថាតើយើងត្រូវធ្វើដូចម្ដេចដើម្បីប្រាកដថាសន្លឹកឆ្នោត CVR ត្រូវបានរាប់បញ្ចូល ? ផ្នែកចុះឈ្មោះរបស់យើងប្រឹងប្រែងធ្វើការដើម្បីផ្លាស់ប្ដូរអាសយដ្ឋានទាំងនេះ និងស្ថានភាពស្រដៀងគ្នាផ្សេងៗ ។ ប្រសិនបើមាននរណាម្នាក់និយាយថានេះមិនអាចបញ្ជូនបានទេ យើងយកព័ត៌មានទាំងអស់ ហើយយើងនឹងបញ្ជូនអ្នកផ្ញើសំបុត្រម្នាក់ដើម្បីបញ្ជាក់ពីការស្នាក់នៅ ។ យើងដោះស្រាយព័ត៌មានជាមួយប្រព័ន្ធ VoteCal ដែលឥឡូវមាននៅទូទាំងរដ្ឋហើយពួកគេនឹងជូនដំណឹងដល់យើង ។ មានកំណត់ត្រាអ្នកបោះឆ្នោតចំនួន 908,000 ដែលយើងកំពុងដំណើរការរាល់ថ្ងៃ ។ ចាប់តាំងពីកំណត់ត្រាសម្រាប់អ្នកបោះឆ្នោតគឺស្ថិតនៅក្នុងប្រព័ន្ធកណ្ដាល វាមិនអាចទៅរួចទេក្នុងការបោះឆ្នោតច្រើនជាងម្ដងក្នុងរដ្ឋ California ។
    b. អ្នកចូលរួម ៖ តើវគ្គបណ្ដុះបណ្ដាលនឹងផ្ដោតលើបញ្ហាទាំងអស់នេះ ដែរឬទេ ?
    c. បុគ្គលិក ROV ៖ យើងនឹងផ្ដល់ឲ្យអ្នកនូវព័ត៌មានទូទៅទាំងអស់ ហើយប្រសិនបើមានស្ថានភាពស្មុគស្មាញបន្ថែមទៀត អ្នកដឹកនាំនឹងជួយនៅក្នុងមណ្ឌលបោះឆ្នោត ។
14. អ្នកចូលរួម ៖ ប្រសិនបើអ្នកផ្លាស់ទៅមហាវិទ្យាល័យ តើអ្នកនិយាយថាអ្នករស់នៅកន្លែងណា ?
    a. បុគ្គលិក ROV ៖ អ្នកជ្រើសរើសអាសយដ្ឋានមួយដោយផ្អែកលើស្ថានភាពបុគ្គល ។
    b. អ្នកចូលរួម ៖ តើខ្ញុំអាចចុះឈ្មោះនៅ San Diego បានទេ ?
    c. បុគ្គលិក ROV ៖ អ្នកអាចកំណត់អាសយដ្ឋានផ្ញើសំបុត្ររបស់អ្នកឲ្យនៅ San Diego ហើយនៅតែបោះឆ្នោតសម្រាប់ការបោះឆ្នោតនៅខោនធី Santa Clara ខណៈពេលនៅសាលារៀន ។ ប្រសិនបើអ្នកជ្រើសរើសចុះឈ្មោះនៅ San Diego អ្នកនឹងលែងចុះឈ្មោះ និងមានសិទ្ធិបោះឆ្នោតនៅខោនធី Santa Clara ទៀតហើយ ។
    d. បុគ្គលិក ROV ៖ យើងស្ថិតនៅលើមូលដ្ឋានទិន្នន័យទូទាំងរដ្ឋ យើងអាចប្រាប់បាន ថាតើអ្នកបានបោះឆ្នោតក្នុងខោនធីផ្សេងៗគ្នា ហើយយើងនឹងដឹង ថាតើអ្នកបានរាប់ឬអត់ ។ អ្នកកំពុងចុះហត្ថលេខាក្រោមការពិន័យ និងការបំពានសម្បថ ។

15. អ្នកចូលរួម ៖ ដោយសារយើងកំពុងដាក់បញ្ចូលទៅក្នុងមណ្ឌលបោះឆ្នោតធំៗ តើនឹងមានការបម្រុងទុកទេ ?
    a. បុគ្គលិក ROV ៖ អ្នកមើលអ្នកបោះឆ្នោតក្នុងម្នាក់ៗ ។ យើងកំពុងព្យាយាមផ្តល់ការគ្របដណ្តប់សម្រាប់អ្នកគ្រប់គ្នានៅក្នុងតំបន់ ហើយយើងនឹងពិនិត្យមើលព័ត៌មានជំរឿន និងពិនិត្យមើលតំបន់ដែលយើងបានគ្របដណ្តប់អ្នកបោះឆ្នោតកាលពីពេលមុន ។ យើងកំពុងពិនិត្យមើលបរិមាណ ហើយនឹងផ្តែកទៅលើលក្ខណៈវិនិច្ឆ័យ ។
16. អ្នកចូលរួម ៖ តើមានចម្ងាយឆ្ងាយបំផុតប៉ុន្មានដែលមនុស្សម្នាក់នឹងត្រូវធ្វើដំណើរ ? សម្រាប់ម៉ូដែលចាស់មានកន្លែងនៅជិតផ្ទះ ។
    a. បុគ្គលិក ROV ៖ យើងត្រូវរកមើលកន្លែងណាដែលងាយស្រួលសម្រាប់ប្រជាសាស្ត្រទាំងអស់ ។ វាជាអ្វីដែលយើងកំពុងធ្វើការ និងជាមូលហេតុដែលយើងកំពុងមានការប្រជុំជាមួយអ្នកទាំងអស់គ្នា ។ នៅឆ្នាំ 2018 អ្នកមកបោះឆ្នោតភាគច្រើនគឺនៅថ្ងៃបោះឆ្នោត ។ ឥឡូវមានច្រើនថ្ងៃ មនុស្សអាចពន្យារពេលហើយមកបោះឆ្នោតនៅថ្ងៃបញ្ចប់ ។ អ្នកលែងមានជម្រើសតែមួយដើម្បីបោះឆ្នោតទៀតហើយ ប៉ុន្តែប្រសិនបើមិនមានមណ្ឌលបោះឆ្នោតដែលនៅជិតផ្ទះរបស់អ្នកទេ អ្នកអាចទៅបោះឆ្នោតនៅជិតកន្លែងធ្វើការរបស់អ្នកបាន ។ អ្នកលែងមានការដាក់កម្រិតទៀតហើយ ។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងប្រអប់ដាក់សន្លឹកឆ្នោត

ROV នឹងប្រមូលមតិយោបល់ចូលរួមពីសាធារណជនដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោត និងកន្លែងដើម្បីដាក់ប្រអប់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោត ចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាធំទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

*មតិចូលរួម/សំណួរពីសាធារណជន ៖*

1. អ្នកចូលរួម ៖ ចុះចំពោះប្រអប់ដាក់សន្លឹកឆ្នោត? 100% ទទួលបានសន្លឹកឆ្នោតតាមសំបុត្រមែនទេ ? គោលដៅគឺត្រូវមានសំបុត្រសន្លឹកឆ្នោត 100% មែនទេ ? យើងកំពុងដោះស្រាយសម្រាប់អ្នកដែលចង់មានបទពិសោធន៍បោះឆ្នោត ។ ប្រសិនបើការងាររបស់យើងគឺផ្តល់អាហារដល់អ្នកដែលចង់បាន ។
    a. អ្នកចូលរួម ៖ មួយថ្ងៃយើងមានតែអ្នកបោះឆ្នោត 25 នាក់នៅកន្លែងបោះឆ្នោត ។
    b. បុគ្គលិក ROV ៖ សម្រាប់អ្នកបោះឆ្នោត 75% គ្មានអ្វីនឹងផ្លាស់ប្តូរទេ ។ យើងត្រូវត្រៀមសម្រាប់ប្រជាជនដែលមិនចង់ផ្ញើសំបុត្រសន្លឹកឆ្នោតរបស់ពួកគេ ប៉ុន្តែអ្នកដែលចង់បានបទពិសោធន៍បោះឆ្នោត ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលការចូលរួមពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមាន

បញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*មតិចូលរួម/សំណួរពីសាធារណជន ៖ (មិនមាន)*

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលការចូលរួមពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*មតិចូលរួម/សំណួរពីសាធារណជន ៖ (មិនមាន)*

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលការចូលរួមពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយ ដើម្បីឲ្យ បានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖*

1. បុគ្គលិក ROV ៖ យើងកំពុងព្យាយាមប្រមូលព័ត៌មានអំពីទីកន្លែងដែលអាចធ្វើទៅបានដែលយើងមិនទាន់បានរកឃើញទាក់ទងនឹងការផ្សាយពាណិជ្ជកម្មប្រព័ន្ធផ្សព្វផ្សាយសង្គម និងការផ្សព្វផ្សាយផ្សេងៗ ។ តើយើងអាចផ្សព្វផ្សាយដល់សហគមន៍ជាក់លាក់ដោយរបៀបណា ? អ្នកនៅជិតគ្នាគឺជាឧបករណ៍ផ្សព្វផ្សាយដ៏អស្ចារ្យមួយ ។ យើងកំពុងស្វែងរកគំនិតមកពីសហគមន៍ ។
   a. អ្នកចូលរួម ៖ សម្រាប់ជនជាតិចិនយើងប្រើ WeChat និង WhatsApp ។ និងវិទ្យុចិនផងដែរ ។
3. បុគ្គលិក ROV ៖ មានការបោះពុម្ពផ្សាយណាមួយទេ ?
   a. អ្នកចូលរួម: Tsingtao ភាគច្រើនគឺសម្រាប់មនុស្សចាស់ ។
   b. អ្នកចូលរួម ៖ បង្កើតរូបភាព ឬបង្ហោះដែលសាធារណជនអាចបង្ហោះចូលទំព័រ Facebook ផ្ទាល់ខ្លួនរបស់ពួកគេបាន ។
4. អ្នកចូលរួម ៖ សម្រាប់មនុស្សវ័យក្មេងប្រហែលជាអ្នកអាចមានការប្រកួតប្រជែងរចនាខិតប័ណ្ណដើម្បីផ្តល់ការយល់ដឹងបន្ថែម ។ តាមវិទ្យាល័យអាចប្រើឃ្លីបវីដេអូ ។
   a. អ្នកចូលរួម ៖ សិស្សនៅវិទ្យាល័យអាចនិយាយអំពីគម្រោងនានាទៅកាន់ឪពុកម្តាយរបស់ពួកគេតាមរយៈផ្សព្វផ្សាយការយល់ដឹង ។
   b. អ្នកចូលរួម ៖ ធ្វើការជាមួយសិស្សសាលាមួយចំនួនហើយអ្នកអាចបង្ហោះការរចនារបស់ពួកគេ ។
   c. បុគ្គលិក ROV ៖ យើងប្រហែលជាអាចមានរង្វាន់តបស្នងចំពោះការ "បង្ហោះឡើងវិញ" ។ បង្ហោះឡើងវិញហើយយើងនឹងផ្ញើរង្វាន់ជូនអ្នក ។

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara

# **ផែនការរដ្ឋបាលបោះឆ្នោត (EAP)**

## **របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍កូរ៉េ**

ការិយាល័យចុះបញ្ជីបោះឆ្នោតខោនធី Santa Clara
1555 Berger Dr., Bldg 2, San Jose, CA 95112
សាលប្រជុំ
ថ្ងៃព្រហស្បត្តិ៍ ទី27 ខែមិថុនា ឆ្នាំ2019
ម៉ោង 2:00 ដល់ម៉ោង 3:30 រសៀល

**វត្តមានអ្នកចូលរួម៖**

មានសមាជិកប្រាំពីររូបជាសាធារណជនមកពីសហគមន៍កូរ៉េ ។

**វត្តមានបុគ្គលិកចូលរួម៖**

Shannon Bushey, Vanessa Hamm, Andrea Solorio, Michael Borja, Magdalena Sta Maria, Shelby Galaviz, Priscilla Favela, Janora Davis, Patricia Lopez, Allen Ocampo, Linh Nguyen, Michelle Tran, Adrian Garcia, Paulo Chang, Alfred Gonzales, Eric Kurhi, Rachel Jung, Liz Oviedo, Chipo Mulenga, George Hiu, Mike Davis, Martin Ayala, Smita Shah, Lorenzo Castaneda, Diane Castaneda, Bob Nguyen, Aaron Wong

**ចំណុចសកម្មភាព៖**

- សាកសួរអ្នកចូលរួមទាក់ទងនឹងការបន្ថែមហិបទម្លាក់សន្លឹកឆ្នោតនៅតាមមណ្ឌលសេវាសហគមន៍អាមេរិកាំងកូរ៉េ ។
- សាកសួរអ្នកចូលរួមទាក់ទងនឹងការប្រើប្រាស់ព្រះវិហារធំៗ ដែលមានសក្តានុពលជាទីតាំងមណ្ឌលបោះឆ្នោត ។
- សាកសួរអ្នកចូលរួមទាក់ទងនឹងចំណាប់អារម្មណ៍របស់ពួកគេក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ។
- សាកសួរអ្នកចូលរួមទាក់ទងនឹងឱកាសផ្សព្វផ្សាយផ្សេងៗតាមប្រព័ន្ធផ្សព្វផ្សាយកូរ៉េ ។
- ផ្តល់ឯកសារឌីជីថលថតចម្លងនៃខិតប័ណ្ណផ្សព្វផ្សាយទៅដល់អ្នកចូលរួម ដើម្បីឲ្យពួកគេអាចបង្ហោះផ្សាយនៅលើបណ្តាញសង្គមរបស់ពួកគេផងដែរ ។
- បន្ថែមរាល់ឯកសារផ្សព្វផ្សាយឌីជីថលទាំងអស់ទៅលើគេហទំព័រសម្រាប់សហគមន៍/អង្គការនានា ដើម្បីស្វែងរកនិងទាញយកឯកសារសម្រាប់ការអប់រំអ្នកបោះឆ្នោត ។

**របៀបវារៈ៖**

I. **សេចក្តីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

## II. ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ទម្លាក់សន្លឹកឆ្នោតរបស់គេនៅតាមហិបទម្លាក់សន្លឹកឆ្នោត ឬ មានរយៈពេល 11 ថ្ងៃ ដើម្បីបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*បទបង្ហាញរបស់ ROV៖*

1. Shannon Bushey ធ្វើបទបង្ហាញពីទិដ្ឋភាពទូទៅអំពីច្បាប់ VCA ។
2. បទបង្ហាញនៃទិដ្ឋភាពទូទៅនៃច្បាប់ VCA ត្រូវបានធ្វើឡើងជាភាសាកូរ៉េ ។
3. បុគ្គលិក ROV៖ តើអ្នកគ្រប់គ្នាបានដឹងពីកិច្ចប្រជុំថ្ងៃនេះតាមរបៀបណា?
   a. អ្នកចូលរួម៖ តាមអ៊ីម៉ែល និង Facebook ។

## III. គោលបំណងនៃផែនការរដ្ឋបាលបោះឆ្នោត

ផែនការរដ្ឋបាលបោះឆ្នោត (EAP) ដាក់ចេញនូវរបៀបដែលការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្តូរនានាទាក់ទងនឹងច្បាប់ VCA ហើយនឹងអភិវឌ្ឍរួមគ្នាជាមួយនឹងធាតុចូលបានពីសហគមន៍ ។

*បទបង្ហាញរបស់ ROV៖*

បុគ្គលិក ROV៖ យើងនឹងអភិវឌ្ឍនូវពង្រាង EAP ហើយនឹងរៀបចំសវនាការសាធារណៈនៅថ្ងៃទី30 ខែសីហា ដើម្បីផ្តល់និងស្តាប់មតិត្រឡប់ ។ ពង្រាងនេះនឹងបង្ហោះផ្សាយមុនពេល ឲ្យបានយូរនៅលើគេហទំព័ររបស់យើង ដោយធ្វើបែបនេះ អ្នកបោះឆ្នោតអាចមើលពង្រាងនេះបានមុនពេលគេមកចូលរួមសវនាការ ឬផ្តល់ដល់យើងនូវមតិត្រឡប់តាមរយៈគេហទំព័រ ឬអ៊ីម៉ែល ។ អ្វីដែលយើងនឹងធ្វើបច្ចុប្បន្ននេះ គឺទទួលយកធាតុចូលពីសហគមន៍យើងនឹងរៀបចំកិច្ចប្រជុំចំនួន 12 នៅតាមតំបន់ផ្សេងៗគ្នានៃខោនធី ដោយធ្វើឡើងជាភាសាផ្សេងៗគ្នា ដើម្បីជួយដល់យើងឲ្យយើងជួយដល់អ្នកបោះឆ្នោតនៅក្នុងខោនធី Santa Clara ។ យើងស្វែងរកធាតុចូលស្តីពីទីតាំងមណ្ឌលបោះឆ្នោតនៅក្នុងសហគមន៍កូរ៉េ ។ តើមានទីតាំងណាដែលមានមនុស្សច្រើននឹងទៅបោះឆ្នោតទេ? យើងស្វែងរកសំណូមពររបស់អ្នក ហើយអ្នកអាចផ្តល់ដល់យើងនៅទីនេះថ្ងៃនេះ សូមសរសេរវាចុះ ឬអ៊ីម៉ែលមកយើងក៏បាន ។ យើងស្វែងរកមើលដូចជាប្រព័ន្ធផ្សព្វផ្សាយកូរ៉េដែលយើងអាចធ្វើការផ្សព្វផ្សាយបាន ។ យើងក៏ស្វែងរកដែរ នូវអនុសាសន៍ទាំងឡាយអំពីមណ្ឌលពលរដ្ឋវ័យចាស់ជរាសម្រាប់សហគមន៍ជនចាស់ជរានិងពិការភាពរបស់យើង ។ ទាំងនេះគឺជាឧទាហរណ៍ខ្លះៗនៃធាតុចូលដែលយើងស្វែងរកថ្ងៃនេះ ។ សម្រាប់ព័ត៌មានបន្ថែមស្តីពី EAP សូមចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការ ។

## IV. ការជ្រើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara។

*បទបង្ហាញរបស់ ROV៖*

1. បុគ្គលិក ROV៖ បច្ចុប្បន្ននេះយើងកំពុងស្វែងរកមណ្ឌលបោះឆ្នោតសម្រាប់ 120-125 មណ្ឌល ដែលនឹងធំជាងមុន ហើយមានសមត្ថភាពធ្វើបានច្រើនជាងការិយាល័យបោះឆ្នោតដែលយើងធ្លាប់ប្រើ ។ កាលពីមុនមក ការិយាល័យបោះឆ្នោតអាចដាក់មនុស្សបានពី 4-5 នាក់ ហើយជាទូទៅគឺមានលក្ខណៈតូចចង្អៀត ។ បច្ចុប្បន្ននេះ បន្ទប់អាចមានទំហំ 40x40 ឬ 60x60 ដោយមានបុគ្គលិកបម្រើការចាប់ពី 8-15 នាក់ ហើយនឹងអាចធ្វើបានច្រើនជាងការិយាល័យបោះឆ្នោត ។ វានឹងមានលក្ខណៈដូចគ្នាទៅនឹងមណ្ឌលសេវាកម្ម ។ តាមពិតទៅនោះ មណ្ឌលទាំងនោះនឹងត្រូវបើកដំណើរការពីដើមទី ហើយសម្រាប់រយៈពេលជាច្រើនថ្ងៃក្នុងពេលម្តងៗ អាច 11 ថ្ងៃ ឬ 4 ថ្ងៃ នេះមានន័យថាទីតាំងទាំងឡាយនឹងពិបាកទទួលយកបានដោយសារតែភាពទំនេរនិងថ្លៃចំណាយ ។

2. បុគ្គលិក ROV៖ យើងបញ្ចប់បាន 60-70% ហើយ ទាក់ទងនឹងការស្វែងរកទីតាំងមណ្ឌលបោះឆ្នោត និងការប្រើប្រាស់បញ្ជីលក្ខខណ្ឌតម្រូវ 14 ចំណុចដែលបង្ហាញពីលក្ខណៈសមស្របបំផុតសម្រាប់មណ្ឌលបោះឆ្នោត ។
3. បុគ្គលិក ROV៖ ប្រសិនបើអ្នកមានមតិយោបល់ទាក់ទងនឹងទីតាំងនោះ សូមទាក់ទងទៅកាន់ voterschoice@rov.sccgov.org
4. បុគ្គលិក ROV៖ នៅក្នុងឆ្នាំ 2018 ប្រហែលជា 75% នៃអ្នកបោះឆ្នោតនៅក្នុងខោនធី Santa Clara បានធ្វើការបោះឆ្នោតតាមប្រៃសណីយ៍ (VBM) ហើយបច្ចុប្បន្ននេះ 100% នៃអ្នកបោះឆ្នោតនឹងត្រូវបោះតាម VBM ។ យើងនឹងបង្កើនចំនួនហិបទម្លាក់សន្លឹកឆ្នោតដើម្បីឲ្យអាចទទួលបានទៅតាមចំនួនកើនឡើងនៃអ្នកបោះឆ្នោតតាម VBM ។ នៅក្នុងឆ្នាំ 2018 យើងមានហិបទម្លាក់សន្លឹកឆ្នោតចំនួន 55 កន្លែង ប៉ុន្តែឥឡូវនេះលក្ខខណ្ឌតម្រូវគឺមួយហិបទម្លាក់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតចំនួន 15k សរុបរួមទៅមានហិបទម្លាក់សន្លឹកឆ្នោតទាំងអស់ចំនួន 78 ។
5. បុគ្គលិក ROV៖ ជាមួយនឹងការផ្លាស់ប្តូរទាំងឡាយនៃការិយាល័យបោះឆ្នោត យើងនឹងមានបុគ្គលិកពីរនាក់ផ្សេងគ្នា គឺអ្នកស្ម័គ្រចិត្តនិងបុគ្គលិកជំនួយបន្ថែម ។ យើងនឹងជួលបុគ្គលិកជំនួយបន្ថែមដែលនឹងធ្វើការសម្រាប់ខោនធីដោយផ្ទាល់ ។ អ្វីៗនឹងត្រូវអនុវត្តតាមរយៈភ្នាក់ងារសេវាការងារ (ESA) ។ យើងនឹងត្រូវការមុខតំណែងផ្នែកដឹកនាំ និងស្មៀន (ចំនួនសរុបប្រហែល 1,800 នាក់ជាស្មៀននិង 250 នាក់ជាអ្នកដឹកនាំ) ដែលនឹងត្រូវដាក់ពាក្យតាមរយៈគេហទំព័រ https://www.governmentjobs.com/careers/santaclara ។ យើងនឹងជួលបុគ្គលិកដែលនឹងទទួលបានប្រាក់ឧបត្ថម្ភចាប់តាំងពីសិស្សវិទ្យាល័យរហូតដល់មនុស្សពេញវ័យ។ យើងនឹងរៀបចំដូចគ្នាទៅនឹងអ្វីដែលយើងបានធ្វើសម្រាប់អ្នកស្ម័គ្រចិត្តដែរ ។ យើងនឹងផ្ញើលិខិតទៅកាន់អ្នកដែលធ្លាប់បម្រើការ/អ្នកស្ម័គ្រចិត្តពីមុនមក ហើយយើងនឹងត្រូវការជំនួយពីសហគមន៍របស់យើង ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ មានគូរ៉េជាច្រើនទៅកាន់ផ្សារកូរ៉េ តើមានលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ហិបទម្លាក់សន្លឹកឆ្នោតទេ?
    a. បុគ្គលិក ROV៖ លក្ខខណ្ឌតម្រូវសម្រាប់ការដាក់ហិបទម្លាក់សន្លឹកឆ្នោតមាន (1) មួយទីតាំងត្រូវមានអ្នកបោះឆ្នោត 15K ប៉ុន្តែយើងក៏មានភាពបត់បែនដែរ ដើម្បីបន្ថែមហិបទម្លាក់សន្លឹកឆ្នោតឲ្យបានច្រើន ដើម្បីអាចទទួលបានប្រសើរជាងមុនសម្រាប់សហគមន៍ ។ យើងមានហិបទម្លាក់សន្លឹកឆ្នោតនៅខាងក្រៅនិងខាងក្នុងដែលមានសន្តិសុខ ដោយយើងគ្រាន់តែត្រូវការឲ្យមានការអនុញ្ញាតពីម្ចាស់ទីតាំងតែប៉ុណ្ណោះ ។
    b. បុគ្គលិក ROV៖ ម្ចាស់ទីតាំងនិង/ឬម្ចាស់អចលនទ្រព្យនឹងត្រូវអនុញ្ញាតដល់យើងឲ្យរៀបចំសន្តិសុខដោយប្រើច្រវ៉ាក់ ដោយហិបទាំងនោះមិនចាំបាច់ត្រូវរឹតឡោស៊ីទេ ។
2. អ្នកចូលរួម៖ ខ្ញុំអាចសាកសួរដល់ក្រុងអំពីការដាក់ហិបទម្លាក់សន្លឹកឆ្នោតនៅឯមណ្ឌលរបស់ខ្ញុំ ។ យើងមានមនុស្សប្រហែលជា 70 ទៅ 80 នាក់ចូលមកមណ្ឌលរបស់យើងជារៀងរាល់ថ្ងៃ ហើយនៅពេលយើងមានព្រឹត្តិការណ៍អ្វីមួយនោះមានមនុស្សច្រើនជាង 300 នាក់មកចូលរួម ។ ហិបទម្លាក់សន្លឹកឆ្នោតនឹងអាចធ្វើទៅបានសម្រាប់មណ្ឌលកូរ៉េរបស់យើង។ ចំណែកឯការដាក់ហិបទម្លាក់សន្លឹកឆ្នោតនៅតាមព្រះវិហារធំៗវិញយ៉ាងម៉េចដែរ? មានព្រះវិហារធំៗមួយចំនួន ហើយព្រះវិហារទាំងនោះមានអចលនទ្រព្យ និងមានសមាជិកពីរពាន់នាក់ ។
    a. បុគ្គលិក ROV៖ យើងអាចចុះទៅមើលព្រះវិហារទាំងនោះ ថាតើគេអាចអនុញ្ញាតឲ្យយើងបានប៉ុន្មានថ្ងៃ ដោយសារតែព្រះវិហារមួយចំនួននឹងមិនអនុញ្ញាតឲ្យយើងប្រើនៅថ្ងៃអាទិត្យទេ ។
    b. អ្នកចូលរួម៖ ប្រហែលជាព្រះវិហារត្រូវកំណត់តំបន់ដាក់លាក់សម្រាប់មណ្ឌលបោះឆ្នោត ។ មានអចលនទ្រព្យមួយដែលយើងជាម្ចាស់កម្មសិទ្ធិស្ថិតនៅតាមផ្លូវ 136 Burton Avenue ប៉ុន្តែលក្ខខណ្ឌតម្រូវមិនត្រូវឡើយ ដោយសារតែវាជាកន្លែងតូចចង្អៀត ប៉ុន្តែយើងអាចដាក់ហិបទម្លាក់សន្លឹកឆ្នោតបាន ។ មណ្ឌលសហគមន៍ Sherman Oaks ក៏ជាកន្លែងដែលអាចប្រើបានដែរ យើងត្រូវការតែការយល់ព្រមពីក្រុងតែប៉ុណ្ណោះ ។

3. អ្នកចូលរួម៖ ហិបទម្លាក់សន្លឹកឆ្នោតមានន័យថាមិនមាននរណាម្នាក់នៅយាមហិបនោះមែនទេ?
    a. បុគ្គលិក ROV៖ ពិតមែនហើយ ។ ហិបទម្លាក់សន្លឹកឆ្នោត 24 ម៉ោងរបស់យើងស្ថិតនៅខាងក្រៅទេ ។ ហិបទម្លាក់សន្លឹកឆ្នោតត្រូវបានរចនាឡើងដូចគ្នាទៅនឹងហិបទាំងនោះនៅតាមការិយាល័យប្រៃសណីយ៍អញ្ចឹងដែរ ។ ហិបទាំងនោះធ្វើពីដែក ធ្ងន់ខ្លាំង ហើយយើងតម្រូវឲ្យចាក់ច្រវ៉ាក់វា ។
    b. អ្នកចូលរួម៖ តើមាននរណាម្នាក់មកទទួលយកវាទេ?
    c. បុគ្គលិក ROV៖ ពិតជាមាន យើងមានកាលវិភាគសម្រាប់មកទទួលវា ។ ថ្ងៃមកទទួលវានឹងត្រូវបិទភ្ជាប់ទៅនឹងហិបទម្លាក់សន្លឹកឆ្នោត ហើយនៅពេលការបោះឆ្នោតមកដល់ ការមកទទួលយកនឹងធ្វើឡើងកាន់តែញឹកញាប់ ។ ចាប់ពីពេលឥឡូវនេះទៅ យើងបានទាក់ទងទៅកាន់បណ្ណាល័យភាគច្រើន សាលារៀន សាលាក្រុង សាកលវិទ្យាល័យ ស្ថានីយ៍អគ្គិភ័យ និងផ្សារទំនើបពីរ សម្រាប់ដាក់ហិបទម្លាក់សន្លឹកឆ្នោត ។ សម្រាប់ទីតាំងដាក់ខាងក្នុងវិញ យើងនឹងត្រូវដឹងម៉ោងធ្វើការ ហើយនៅថ្ងៃបោះឆ្នោតយើងនឹងត្រូវស្ថិតនៅទីនោះនៅមុនពេលការិយាល័យបិទ ។
4. អ្នកចូលរួម៖ ប្រសិនបើការិយាល័យបិទនៅម៉ោង 5:00 តើយើងអាចអនុញ្ញាតឲ្យនរណាម្នាក់មកពីបុគ្គលិកការិយាល័យស្ថិតនៅយឺត នៅយប់ថ្ងៃបោះឆ្នោតបានទេ?
    a. បុគ្គលិក ROV៖ នៅយប់ថ្ងៃបោះឆ្នោត? យើងមានអ្នកដឹកនាំអីវ៉ាន់នៅយប់ថ្ងៃបោះឆ្នោត ហើយត្រូវដឹងម៉ោងបិទរបស់កន្លែងអចលនទ្រព្យនីមួយៗ ។ អ្នកដឹកនាំអីវ៉ាន់ចាំបាច់ត្រូវតែអាចទទួលបានសន្លឹកឆ្នោត និងរុំបិទហិបទម្លាក់សន្លឹកឆ្នោត ។

## II. លទ្ធភាពទទួលបានផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ឧទាហរណ៍ទាំងឡាយរួមមានសំណូមពរនានាសម្រាប់សហគមន៍ភាសាដែលមិនទទួលបានសេវាជិតដល់ និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលចេះពីរភាសា ។

*បទបង្ហាញរបស់ ROV៖*

បុគ្គលិក ROV៖ ភាសាកូរ៉េ ជាភាសាមួយកំណត់ដោយរដ្ឋ ។ ជាមួយនឹងច្បាប់ VCA យើងនឹងផលិតសន្លឹកឆ្នោតផ្លូវការជាភាសាទាំងប្រាំបួន ហើយអ្នកបោះឆ្នោតអាចស្នើសុំសន្លឹកឆ្នោតជាភាសាកូរ៉េនៅតាមមណ្ឌលបោះឆ្នោតបាន ។

a. បុគ្គលិក ROV៖ សន្លឹកឆ្នោតឥឡូវនេះមានជាពីរភាសាដែលអ្នកអាចស្នើសុំសន្លឹកឆ្នោតជាភាសាកូរ៉េ/អង់គ្លេស អេស្ប៉ាញ/អង់គ្លេស ។ល។ អ្នកអាចស្នើសុំភាសាដោយបំពេញទម្រង់ចុះឈ្មោះបោះឆ្នោត ។
b. បុគ្គលិក ROV៖ ដើម្បីបញ្ជាក់ សន្លឹកឆ្នោតផ្លូវការនឹងត្រូវបកប្រែ ប៉ុន្តែមិនមែនជាសេចក្តីណែនាំដែលមានផ្ទុកព័ត៌មានស្តីពីការបោះឆ្នោតខោនធី (CVIG) ។

## III. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV ប្រមូលធាតុចូលដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់នូវលទ្ធភាពឲ្យបោះបានសម្រាប់អ្នកបោះឆ្នោតចាស់ជរា និងអ្នកបោះឆ្នោតដែលមានពិការភាព អាចយល់បានពីដំណើរការបោះឆ្នោត និងការទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*បទបង្ហាញរបស់ ROV៖*

1. បុគ្គលិក ROV៖ យើងកំពុងស្វែងរកទីតាំងនិងជំនួយសម្រាប់សហគមន៍ចាស់ជរា និងជនមានពិការភាព ។ យើងកំពុងស្វែងរកស្លាកសញ្ញា ផ្លូវជម្រាល និងឧបករណ៍សំរាប់គូសសញ្ញា ដែលនឹងជួយឲ្យទទួលបានលទ្ធភាពក្នុងការបោះឆ្នោត ។ ប្រសិនបើនរណាម្នាក់មិនអាចចាកចេញពីផ្ទះគេបាន កំពុងស្ថិតនៅក្រៅប្រទេស ឬមកពីយោធា យើងនឹងផ្តល់ឲ្យនូវការបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) ហើយនឹងមានព័ត៌មាននៅលើគេហទំព័រស្តីពីវា ប៉ុន្តែជាពិសេសនោះនរណា

ម្នាក់ស្ថិតនៅផ្ទះអាចចូលអនឡាញ ឆ្លើយពីរសំណួរ ហើយទាញយកប្រភេទសន្លឹកឆ្នោតទៅតាមកន្លែងរស់នៅរបស់គេ និងអ្វីដែលជាទម្រង់ដែលគេអាចបោះឆ្នោតបាន ។ អ្នកទាញយកសន្លឹកឆ្នោត គូសវា ព្រីនវាចេញ ហើយផ្ញើវាមកយើង ។ ប្រសិនបើអ្នកអាចគិតដល់អ្វីមួយសម្រាប់ជួយដល់អ្នកពិការបាន យើងរង់ចាំទទួលស្តាប់ដោយរីករាយ ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ នៅឯអង្គការរបស់យើង យើងបានធ្វើការអប់រំអ្នកបោះឆ្នោតច្រើនណាស់ ។ នៅពេលមានការបោះឆ្នោតធ្វើឡើង យើងគឺជាមណ្ឌលកណ្តាលដ៏សំខាន់ ។
2. អ្នកចូលរួម៖ នៅពេលជ្រើសរើសបុគ្គលិកបោះឆ្នោត យើងមានតំណភ្ជាប់ដោយផ្ទាល់ ឬតំណភ្ជាប់ខ្លីជាងគេទៅកាន់ការដាក់ពាក្យសុំការងារ ។
    a. បុគ្គលិក៖ យើងសង្ឃឹមថានៅពេលយើងផ្ញើសេចក្តីជូនដំណឹងចេញទៅ យើងអាចបញ្ចូលតំណភ្ជាប់មួយសម្រាប់អ្នកទាំងឡាយ ប៉ុន្តែវាជាគេហទំព័ររបស់ ESA ដូច្នេះយើងនឹងមិនអាចប្តូរតំណភ្ជាប់នោះបានឡើយ ។
    b. បុគ្គលិក ROV៖ មើលនៅលើគេហទំព័រ sccjobs.org ចូលត្រង់ទៅកាន់ផ្នែកនោះ ហើយវាយពាក្យថា “ការបោះឆ្នោត” ។
3. បុគ្គលិក ROV៖ យើងរៀបចំសិក្ខាសាលាដាច់ដោយឡែកជាច្រើនជាមួយនឹងសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី មណ្ឌលជនពិការ ភ្នែកVista និងអង្គការតាមសហគមន៍ខ្នាតតូចឯកជនផ្សេងៗជាច្រើនទៀត ។ សង្ឃឹមថាយើងអាចសហការជាមួយអង្គការរបស់អ្នក គឺអង្គការ Simple Steps ធ្វើដូច្នេះយើងអាចភ្ជាប់ទំនាក់ទំនងទៅកាន់ក្រុមជនជាតិភាគតិចផ្សេងទៀតដើម្បីរៀបចំសិក្ខាសាលា ។ សូមបញ្ជូនបន្តទៅកាន់អង្គការទាំងឡាយផ្សេងទៀត ហើយខ្ញុំនឹងអាចទាក់ទងទៅកាន់ពួកគេបាន ។
4. បុគ្គលិក ROV៖ តើមានសំណួរអីផ្សេងទៀតទេ?
    a. អ្នកចូលរួម៖ ក្នុងនាមជាពលរដ្ឋ យើងសូមធ្វើការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខោនធី ដើម្បីកៀរគរដល់ក្រុមភាគតិចនានា ហើយយើងរំភើបណាស់ចំពោះការផ្លាស់ប្តូរទាំងឡាយ ។ ខ្ញុំសង្ឃឹមថារួមគ្នាជាសហគមន៍តែមួយយើងអាចបង្កើនចំនួនអ្នកបោះឆ្នោតបាន ។
    b. បុគ្គលិក ROV៖ សូមអរគុណ យើងទាំងអស់គ្នាមានគោលបំណងដូចគ្នា ដើម្បីបង្កើនការចូលរួមរបស់អ្នកបោះឆ្នោត ។ ត្រឹមពាក់កណ្តាលខែសីហា ក្នុងរយៈពេល 14 ថ្ងៃមុនការបោះឆ្នោត យើងនឹងត្រូវចេញផ្សាយ EAP គ្រប់ភាសាទាំងអស់ ដោយភាសាអង់គ្លេសនឹងត្រូវបង្ហោះផ្សាយមុនគេ ពោលគឺមុនពាក់កណ្តាលខែសីហា ដោយហេតុថាអ្នកបកប្រែនឹងត្រូវធ្វើការងារលើភាសាផ្សេងទៀត ។ ឯកសារបកប្រែទាំងឡាយនឹងត្រូវបង្ហោះផ្សាយនៅមុំរយៈពេល 14 ថ្ងៃមុនថ្ងៃទី 30 ខែសីហា ។

## II. ឱកាសផ្សព្វផ្សាយ

ROV កំពុងតែស្វែងរកនូវធាតុចូលពីសាធារណជន ដើម្បីកំណត់ទៅលើទីតាំងនិងវិធីសាស្ត្រផ្សេងគ្នានៃការផ្សព្វផ្សាយដើម្បីឲ្យប្រសើបំផុតទៅដល់អ្នកបោះឆ្នោតក្នុងខោនធី ហើយអប់រំពួកគេពីការផ្លាស់ប្តូរនានាក្នុងការបោះឆ្នោតដែលនឹងកើតឡើងជាមួយនឹងច្បាប់ VCA ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. បុគ្គលិក ROV៖ តើអ្នកមានសំណូមពរពីរបៀបដែលយើងអាចធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មបានទេ?
    a. អ្នកចូលរួម៖ មានគេហទំព័រធំមួយដែលពលរដ្ឋកូរ៉េភាគច្រើនប្រើ ហើយមានផ្នែកមួយហៅថា “ជួយទៅតាមចង់” ។ មានគេហទំព័រពេញនិយមមួយដែរ ដែលចេញផ្សាយពាណិជ្ជកម្មប្រចាំសប្តាហ៍ ប្រហែលជាអ្នកអាចផ្សព្វផ្សាយតាមរយៈគេហទំព័រនេះបាន ។ នាយកដ្ឋានផ្សព្វផ្សាយរបស់យើងមានប្រភពទាំងអស់ ដូចជាស្ថានីយ៍វិទ្យុជាដើម ។ ប្រសិនបើអ្នកចង់បាន ខ្ញុំក៏អាចផ្តល់វាឲ្យបានដែរ ។
    b. អ្នកចូលរួម៖ មានអង្គការមិនរកកម្រៃមួយ ហៅថា Simple Steps ដែលអាចជួយស្ត្រីកូរ៉េក្នុងការស្វែងរកការងារនៅ Bay Area ។ ខ្ញុំបានចូលរួមសិក្ខាសាលារបស់គេ ហើយខ្ញុំជឿថាវាគួរតែជាកន្លែងដ៏ល្អសម្រាប់ធ្វើការផ្សព្វផ្សាយ ។

c. អ្នកចូលរួម៖ ពលរដ្ឋដើមកំណើតកូរ៉េភាគច្រើនរស់នៅទីនោះ ប្រហែលជា 90% មើលគេហទំព័រ SFKorean.com ។ យុវជនជំនាន់ក្រោយប្រើ MissyUSA.com វាស្រដៀងគ្នាទៅនឹង Facebook ដែរ ។ Facebook ក៏ជាការភ្ជាប់ទំនាក់ទំនងដ៏ល្អសម្រាប់សហគមន៍កូរ៉េដែរ ។
d. អ្នកចូលរួម៖ កាសែតជាជម្រើសសម្រាប់មនុស្សចាស់ ដោយសារតែមនុស្សភាគច្រើនចូលចិត្តចូលអនឡាញ ឬប្រើទូរសព្ទរបស់គេ ។ ខ្ញុំគិតថា SFKorean.com គឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ការផ្សព្វផ្សាយ ។
e. អ្នកចូលរួម៖ យើងនឹងធ្វើតារាងបញ្ជីមួយ ។
f. អ្នកចូលរួម៖ យើងក៏មានព្រឹត្តិប័ត្រប្រចាំខែរបស់យើងដែរ ហើយព្រីនចេញ និងបង្ហោះផ្សាយប្រមាណ 1,200 ក្នុងមួយខែ ។

2. បុគ្គលិក ROV៖ យើងសង្ឃឹមថានឹងរៀបចំទិន្នន័យរួមគ្នាសម្រាប់សហគមន៍ប្រើប្រាស់ ។ យើងក៏ធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គមដែរ ។ សូមចូលទៅមើលគេហទំព័រ http://www.sccvote.org/voterschoice សម្រាប់ព័ត៌មានបន្ថែមអំពីគណៈកម្មាធិការទទួលបានការប្រឹក្សាផ្នែកភាសា (LAAC), គណៈកម្មាធិការប្រឹក្សាដើម្បីលទ្ធភាពអ្នកបោះឆ្នោតអាចចូលរួមបាន (VAAC) និង EAP ។ តើមានប្រព័ន្ធផ្សព្វផ្សាយណាផ្សេងទៀតសម្រាប់ធ្វើការផ្សព្វផ្សាយទៀតទេ?
    a. អ្នកចូលរួម៖ យើងនឹងធ្វើតារាងបញ្ជីសង្ខេបមួយសម្រាប់ ROV ។
3. អ្នកចូលរួម៖ និយាយពីប្រព័ន្ធផ្សព្វផ្សាយនោះ យើងធ្វើច្រើនទៅលើសេចក្តីប្រកាសព័ត៌មានតាមវិទ្យុ TV និងតាមអនឡាញ ។ យើងអាចទទួលបានខ្លឹមសារដើម្បីបង្ហោះផ្សាយ អ្វីៗដែលយើងបានមកពីខាងខោនធី យើងអាចធ្វើការរួមគ្នាបាន ។
    a. បុគ្គលិក ROV៖ យើងពេញចិត្តរៀបចំខ្លឹមសាររួមគ្នា ។ ជាមួយគ្នានេះដែរ តើយើងអាចសុំឲ្យនរណាម្នាក់មកពី ROV ចូលរួមព្រឹត្តិការណ៍មួយ ដូចនឹងអ្វីដែលអ្នកបានលើកឡើងពីមុនដោយមនុស្សចូលរួម 300 នាក់ ប្រសិនបើយើងអាចមាននរណាម្នាក់មកចូលរួមនិងធ្វើបទបង្ហាញបានទេ? បន្ថែមលើនេះដែរ វាប្រហែលជាល្អដែរ ដោយធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ប្រសិនបើមាននរណាម្នាក់នៅក្នុងអង្គការដែលអាចបង្រៀនធ្វើការងារនេះ ។
    b. អ្នកចូលរួម៖ មែនហើយ យើងចាប់អារម្មណ៍ការបណ្តុះបណ្តាលនោះ ។
    c. បុគ្គលិក ROV៖ និយាយពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល សម្ព័ន្ធភាពសម្រាប់ការអប់រំផ្សព្វផ្សាយអ្នកបោះឆ្នោត (VEOC) នឹងរៀបចំព្រឹត្តិការណ៍មួយសម្រាប់សមាជិក VEOC ដែលយើងនឹងបំពាក់ដល់ពួកគេជាមួយឧបករណ៍ពិសេសៗ និងបណ្តុះបណ្តាលពួកគេពីរបៀបធ្វើបទបង្ហាញ និងចែករំលែកជាមួយពួកគេនូវធនធានទាំងអស់ដែលយើងមាន ។ ព្រឹត្តិការណ៍នេះនឹងធ្វើឡើងនៅពេលមួយនាដើមខែសីហា ហើយវានឹងមានលក្ខណៈសាមញ្ញមិនផ្លូវការឡើយ ។ យើងនឹងអញ្ជើញអង្គការជាង 60 ផ្សេងៗគ្នាមកចូលរួម ហើយយើងនឹងសហការរៀបចំព្រឹត្តិការណ៍នេះជាមួយនឹង Silicon Valley at Home ។
    d. អ្នកចូលរួម៖ តើអ្នកនឹងមានផែនការកំណត់គោលដៅចំពោះក្រុមជនជាតិភាគតិចនីមួយៗទេ?
    e. បុគ្គលិក ROV៖ ពិតមែនហើយ យើងនឹងមាន ។
    f. អ្នកចូលរួម៖ ប្រសិនបើខ្ញុំអាចបន្ថែមបាន ស្ត្រីទាំងពីររូបនេះធ្លាប់បានធ្វើការនៅតាម ការិយាល័យបោះឆ្នោតពីមុនមក ហើយចាប់អារម្មណ៍នឹងជួយ ។ ពួកគេជាបុគ្គលិកសង្គមកិច្ចខោនធីចូលនិវត្តន៍ ហើយជាសមាជិកក្រុមប្រឹក្សានៃសេវាសហគមន៍ ។

មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

# គម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់សហគមន៍ហ៊ីនឌី

មជ្ឈមណ្ឌលសហគមន៍ឥណ្ឌា
525 Los Coches St., Milpitas, CA
បន្ទប់សង្គម
ថ្ងៃចន្ទទី8 ខែកក្កដា ឆ្នាំ2019
ម៉ោង 7:30 ល្ងាចដល់ម៉ោង 9:00 ល្ងាច

**វត្តមានអ្នកចូលរួម៖**

មានសមាជិកសាធារណជនចំនួនប្រាំមួយនាក់ចូលរួម

**វត្តមានបុគ្គលិកចូលរួម៖**

Shannon Bushey, Vanessa Hamm, Andrea Solorio, Michael Borja, Magdalena Sta Maria, Priscilla Favela, Janora Davis, Christina Rivas-Louie, Allen Ocampo, Linh Nguyen, Michelle Tran, Mike Davis, Ravi Dhillon, Alfred Gonzales, Eric Kurhi, Rachel Jung, Mike Davis, Smita Shah, Lorenzo Castaneda, Shelby Galaviz, Aaron Wong

**ចំណុចសកម្មភាព៖**

- ពិនិត្យទៅលើទីតាំងមណ្ឌលបោះឆ្នោតដែលបានស្នើឡើង (ឧទា. ព្រះវិហារ ផ្ទះចល័ត ។ល។)
- ពិនិត្យទៅលើទស្សនាវដ្ដីនិងស្ថានីយ៍វិទ្យុដែលបានស្នើឡើង

I. **សេចក្ដីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់គេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីស្នើសុំបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*បទបង្ហាញពីទិដ្ឋភាពទូទៅរបស់ច្បាប់ VCA ជាហ៊ីនឌីនិងអង់គ្លេសត្រូវបានធ្វើឡើង ។*

1. អ្នកចូលរួម៖ តើច្បាប់ជម្រើសអ្នកបោះឆ្នោត (VCA) ជាច្បាប់ខោនធី Santa Clara ឬច្បាប់រដ្ឋ California?
    a. បុគ្គលិក ROV៖ វាត្រូវបានផ្ដល់នៅក្នុងក្រមបោះឆ្នោត California និងវាជាជម្រើសសម្រាប់ខោនធីទាំងឡាយដើម្បីប្ដូរទៅកាន់ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត ។ នៅក្នុងរដ្ឋរបស់យើង អ្នកនឹងឃើញខោនធីទាំងឡាយប្រើពាក្យ ការិយាល័យបោះឆ្នោត ហើយអ្នកនឹងមានខោនធីប្រើពាក្យមណ្ឌលបោះឆ្នោត ។ មានខោនធីប្រាំដែលបានអនុវត្តន៍មណ្ឌលបោះឆ្នោតនៅក្នុងឆ្នាំ 2018 និងប្រាំបួនខោនធីផ្សេងទៀតបានចូលរួមអនុវត្តន៍សម្រាប់ឆ្នាំ 2020 ធ្វើឲ្យចំនួនខោនធីឡើងដល់ 14 បច្ចុប្បន្ននេះនៅក្នុង California កំពុងចូលរួមអនុវត្តន៍ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត ។
    b. អ្នកចូលរួម៖ តើអ្នកផ្សេងនៅទូទាំងប្រទេសយល់ឃើញយ៉ាងម៉េចដែរ?
    c. បុគ្គលិក ROV៖ រដ្ឋផ្សេងគ្នាមានច្បាប់ផ្សេងគ្នា ដូច្នេះម្នាក់ៗអនុវត្តន៍ទៅតាមក្រមបោះឆ្នោតរបស់គេរៀងៗខ្លួន ។
2. អ្នកចូលរួម៖ ខ្ញុំកត់សម្គាល់ឃើញថា មានកំហុសខ្លះនៅក្នុងឯកសារច្បាប់ VCA បកប្រែជាភាសាហ៊ីនឌី ហើយខ្ញុំពេញចិត្តជួយឲ្យអស់ពីដៃពីជើងក្នុងរឿងនេះ ។
    a. បុគ្គលិក ROV៖ នោះពិតជាប្រសើរខ្លាំងណាស់ សូមអរគុណ ។ ប្រហែលអ្នកអាចជួយយើងពិនិត្យឡើងវិញនូវពង្រាងផែនការរបស់យើង នៅពេលយើងធ្វើជាភាសាហ៊ីនឌី។ យើងមានអ្នកដែលអាចទាក់ទងបានដែលមានបញ្ជាក់ដោយរដ្ឋដែលជួយបកប្រែ ប៉ុន្តែយើងដឹងថាពេលខ្លះវាមិនមែនតែងតែបកប្រែដូចគ្នាជានិច្ចនោះទេ ប៉ុន្តែយើងសូមកោតសរសើរចំពោះមតិត្រឡប់របស់អ្នក ។

3. អ្នកចូលរួម៖ តើថ្ងៃបោះឆ្នោតចុងក្រោយថ្ងៃណា? ថ្ងៃទី3 ខែមីនា?
    a. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ។ សន្លឹកឆ្នោតបោះតាមសំបុត្រត្រូវតែវាយត្រាដោយប្រៃសណីយ៍នៅថ្ងៃនោះ និងបានទទួលដោយការិយាល័យយើងក្នុងរយៈពេលបីថ្ងៃ ។
4. អ្នកចូលរួម៖ នេះជាសេណារីយ៉ូ៖ អ្នកនឹងផ្ញើសន្លឹកឆ្នោតផ្លូវការមករយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ហើយខ្ញុំគ្រាន់តែរក្សាទុកសន្លឹកឆ្នោតរបស់ខ្ញុំឲ្យរួចរាល់ ហើយខ្ញុំដឹងថាខ្ញុំមានរយៈពេល 29 ថ្ងៃបន្ថែមទៀត ប៉ុន្តែអ្នកពិតជារវល់ខ្លាំងហើយក៏ភ្លេចទៅ ក្នុងករណីនេះតើមានអ្វីជាការរំឭកដល់ខ្ញុំ ឬអ្នកបោះឆ្នោតដទៃទៀតឲ្យផ្ញើសន្លឹកឆ្នោតរបស់គេចេញទេ?
    a. បុគ្គលិក ROV៖ យើងនឹងធ្វើការផ្សព្វផ្សាយតាមរយៈឯកសារបោះពុម្ព និងតាមវិទ្យុ សេចក្ដីប្រកាសអំពីសេវាសាធារណៈ និងការផ្សព្វផ្សាយពាណិជ្ជកម្ម ដូច្នេះយើងអាចប្រាប់ទៅដល់អ្នកបោះឆ្នោតទាំងអស់ឲ្យបានដឹងពីការផ្លាស់ប្ដូរនានានៅក្នុងគំរូបោះឆ្នោតរបស់ខោនធី និងរំឭកពួកគេឲ្យទៅបោះឆ្នោត ។ បុគ្គលិកជំនាញទំនាក់ទំនងសាធារណៈរបស់យើងធ្វើយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការផ្សព្វផ្សាយនៅតាមវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗដូចជា *Facebook*, *Twitter* និង *Nextdoor* ហើយយើងនឹងបង្កើនការផ្សព្វផ្សាយវាឲ្យខ្លាំងក្លា ។

## III. គោលបំណងនៃគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត

គម្រោងរដ្ឋបាលបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តន៍ការផ្លាស់ប្ដូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហគមន៍។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្ដានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្ដល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara។

*មតិចូលរួមជាសាធារណៈ/សំណួរ ៖*

1. អ្នកចូលរួម៖ នឹងមានប្រមាណ 120 មណ្ឌលបោះឆ្នោតនៅទូទាំងខោនធី Santa Clara? តើមានការប្រៀបធៀបរវាងចំនួនស្តង់បោះឆ្នោតទៅនឹងមណ្ឌលបោះឆ្នោតទេ?
    a. បុគ្គលិក ROV៖ នៅក្នុងខែវិច្ឆិកា ឆ្នាំ2018 មានការិយាល័យបោះឆ្នោតប្រមាណជា 850 កន្លែង ។ វាអាចនឹងឆ្ងាយជាងមុនសម្រាប់អ្នកទាំងនោះដែលត្រូវបើកបរទៅកាន់មណ្ឌលបោះឆ្នោត ប៉ុន្តែអត្ថប្រយោជន៍វាតិចជាងការចំណាយទៅលើការបើកបរ ។ នោះគឺជាផ្នែកអវិជ្ជមាន ដោយគេត្រូវបើកឆ្ងាយជាងមុន ប៉ុន្តែប្រហែលវានឹងមិនឆ្ងាយសម្រាប់ពួកគេក្នុងរយៈពេល 10 ថ្ងៃនោះទេ អាស្រ័យលើអ្វីដែលគេនឹងធ្វើ ។

2. អ្នកចូលរួម៖ តើនឹងមានមណ្ឌលបោះឆ្នោតណាមួយនៅតាមទីតាំងដូចជាបណ្ណាល័យសាធារណៈ និងកន្លែងទម្លាក់សន្លឹកឆ្នោតមែនទេ?
    a. បុគ្គលិក ROV ៖ ពិតជាមាន ។ មានលក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយចំនួនដូចជាទំហំ កន្លែងត្រូវចាក់សោរ ចំនួនថ្ងៃជាក់លាក់ និងមានច្រើនទៀត ដែលត្រូវពន្យល់នៅក្នុងប័ណ្ណព័ត៌មានស្តីពី "តម្រូវការមណ្ឌលបោះឆ្នោត" ។ ទាំងនេះជាលក្ខខណ្ឌតម្រូវមួយចំនួននៃលក្ខខណ្ឌតម្រូវជាច្រើន ដែលយើងកំពុងពិនិត្យមើល និងកំពុងតែសួរទៅកាន់បណ្ណាល័យ សាលារៀន ព្រះវិហារ កន្លែងផ្សេងៗទៀត ដែលយើងបានប្រើប្រាស់ពីមុនមក ហើយនិងកន្លែងថ្មីនានាពីព្រោះថាយើងពិតជាត្រូវការបន្ទប់មានទំហំធំជាងមុនដើម្បីធ្វើជាមណ្ឌលបោះឆ្នោតជាមួយនឹងគ្រឿងបរិក្ខារបោះឆ្នោតថ្មី ។ ដោយថាពេលនេះយើងត្រូវទុកគ្រឿងបរិក្ខារនៅទីនោះ ហើយចាក់សោរវា និងធានាសន្តិសុខវាជារៀងរាល់យប់នោះ យើងមានលក្ខខណ្ឌតម្រូវមួយចំនួនបន្ថែមទៀតសម្រាប់មណ្ឌលបោះឆ្នោតរបស់យើងជាងការិយាល័យបោះឆ្នោតពីមុន ។
3. អ្នកចូលរួម៖ តើកន្លែងដូចជាមជ្ឈមណ្ឌលសហគមន៍ឥណ្ឌាមួយនេះយ៉ាងម៉េចដែរ?
    a. បុគ្គលិក ROV ៖ បាន យើងទទួលបានសេចក្ដីបញ្ជាក់ហើយ និងត្រូវពិនិត្យបន្ទប់ដើម្បីឲ្យដឹងថាតើវាត្រូវទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ប្រើជាមណ្ឌលបោះឆ្នោតដែរឬអត់ ។
    b. អ្នកចូលរួម៖ មានចរាចរច្រើននៅក្នុងតំបន់នេះ ។
    c. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ហើយតាមពិតទៅនោះគឺជាអ្វីដែលយើងចង់បាន ព្រោះថាបើអញ្ចឹងមែនអ្នកអាចបោះឆ្នោតបាននៅពេលអ្នកចេញមកទីនេះមកលែងមជ្ឈមណ្ឌលសហគមន៍ ។ ទាំងនោះគឺពិតជាទីតាំងដែលយើងស្វែងរក ហើយប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលមានទំនាក់ទំនងជាមួយនឹងកន្លែងណាមួយនោះ សូមប្រាប់ដល់យើង ។ ពេលខ្លះប្រសិនបើយើងទូរសព្ទមក យើងបានជួបតែជាមួយនឹងអ្នកទទួលភ្ញៀវ ឬនរណាម្នាក់ឆ្លើយសំណួរ ដែលប្រហែលជាមិនដឹងពីសារសំខាន់នៃអ្វីដែលយើងកំពុងតែសួរទេ ដូច្នេះហើយពេលខ្លះប្រសិនបើមាននរណាម្នាក់ស្គាល់នរណាម្នាក់ទៀតសម្រាប់ទីតាំងនោះ វាពិតជាជួយខ្លាំងណាស់ ។
4. អ្នកចូលរួម៖ ខ្ញុំចូលចិត្តពីរបៀបដែលអ្នកចុះឈ្មោះអាចចុះឈ្មោះបាននៅនាទីចុងក្រោយ ពីព្រោះមានមនុស្សច្រើនណាស់ខកខានមិនបានចុះឈ្មោះនោះ ដូច្នេះហើយនេះជាចំណុចល្អ ។
    a. បុគ្គលិក ROV ៖ ពិតមែនហើយ វាជាអត្ថប្រយោជន៍ ។ បច្ចុប្បន្ននេះ ពួកគេអាចទៅកាន់មណ្ឌលបោះឆ្នោតមួយដើម្បីចុះឈ្មោះនិងបោះនៅក្នុងថ្ងៃតែមួយ ។

5. អ្នកចូលរួម៖ នៅពេលអ្នកនិយាយថាមានមនុស្សដល់ទៅ 75% នឹងទៅបោះឆ្នោតតាមសំបុត្រនោះ តើអ្នកនៅតែត្រូវផ្ញើទៅកាន់មនុស្សទាំងអស់ 100% ឬ?
   a. បុគ្គលិក ROV ៖ ពិតមែនហើយ យើងនឹងផ្ញើវាទៅកាន់មនុស្សគ្រប់គ្នាពីព្រោះឥឡូវនេះអ្នកបោះឆ្នោតទាំងអស់នឹងក្លាយជាអ្នកបោះឆ្នោតតាមសំបុត្រ ។
6. អ្នកចូលរួម៖ តើអ្វីទៅជាគោលបំណងនៃការកាត់បន្ថយពី 800 មកនៅត្រឹម 120 ទីតាំងនោះ? រវៀង 1 និង 11 ថ្ងៃ តើវាមានប្រសិទ្ធិភាពលើការចំណាយប៉ុណ្ណាដល់ខោនធីនោះ? តើវាចាំបាច់ប៉ុណ្ណាចំពោះការធ្វើនេះ ពីព្រោះថាប្រសិនបើខ្ញុំនឹងទៅធ្វើការ ខ្ញុំនឹងធ្វើការតែមួយថ្ងៃមិនមែនសាមសិបថ្ងៃទេ ដូច្នេះដោយការពន្យាពេលទៅដល់រហូត 11 ថ្ងៃ តើវាមានប្រសិទ្ធិភាពលើការចំណាយប៉ុណ្ណា?
   a. បុគ្គលិក ROV៖ វានឹងចំណាយច្រើនជាងមុនសម្រាប់ខោនធី ។ យើងមិនដែលនិយាយថានេះនឹងកាត់បន្ថយចំណាយអ្វីឡើយសម្រាប់ការបោះឆ្នោតនោះ ។ អ្វីដែលសំខាន់នោះគឺភាពងាយស្រួលសម្រាប់អ្នកបោះឆ្នោត ដើម្បីផ្តល់ឱកាសនិងឱកាសជាច្រើនបន្ថែមទៀតដល់អ្នកទៅបោះឆ្នោត ជំនួយផ្នែកភាសាជាច្រើនបន្ថែមទៀតនៅតាមមណ្ឌលបោះឆ្នោត ។ ដូច្នេះជំនួសឲ្យមានតែមួយថ្ងៃដើម្បីបោះឆ្នោតនោះ មានអ្នកមួយចំនួនដែលអាចនឹងទៅមិនបាននៅថ្ងៃជាក់លាក់ណាមួយនៃសប្តាហ៍នោះ ដូច្នេះហើយការពន្យាពេលច្រើនថ្ងៃបន្ថែមមានន័យថាមានឱកាសច្រើនជាងមុនសម្រាប់អ្នកចេញទៅបោះឆ្នោតនៅពេលដែលគេមិនធ្វើការ ឬបោះភ្លាមៗដោយមិនបង្អង់ឡើយ សូម្បីតែចុងសប្តាហ៍ក៏បានដែរ ។ វានឹងត្រូវចំណាយច្រើនលានដុល្លារបន្ថែមទៀតដើម្បីរៀបចំការបោះឆ្នោតប្រភេទនេះ ។
   b. អ្នកចូលរួម៖ ទៅឆ្ងាយជាងអ្វីដែលខ្ញុំត្រូវបើកអាចជាអ្វីមួយមិនជាងាយប៉ុន្មានទេ ឬខ្ញុំអាចនឹងមិនបានទៅមណ្ឌលបោះឆ្នោត ប្រៀបធៀបទៅនឹងបើមានវាស្ថិតនៅក្នុងសង្កាត់ ដូច្នេះហើយវាអាចនឹងប៉ះពាល់ធ្វើឲ្យមានអ្នកបោះឆ្នោតទៅចុះឈ្មោះតិច ។
   c. បុគ្គលិក ROV៖ វាប្រហែលជាអាចទៅរួច ខ្ញុំមិនប្រាកដថាចំនួនអ្នកបោះឆ្នោតដែលអាចនឹងមិនចង់បើកបរបន្ថែមពីរបីម៉ៃល៍ថែមទៀតដើម្បីទៅកាន់មណ្ឌលបោះឆ្នោតដែលនៅជិតពួកគេបំផុតនោះទេ ។ យើងពិតជាសង្ឃឹមថា ដោយមានមណ្ឌលបោះឆ្នោតបើកដំណើរការច្រើនថ្ងៃនោះ នៅទីណាមួយក្នុងរយៈពេល 10 ថ្ងៃបែបនេះ ពួកគេនឹងមានឱកាសចេញទៅកាន់មួយក្នុងចំណោមមណ្ឌលបោះឆ្នោតរបស់យើង ។ ជំនួសឲ្យមានតែមួយថ្ងៃ ពួកគេមានជម្រើសច្រើន និងជម្រើសទៅច្រើន ។ យើងសង្ឃឹមថាវានឹងមានផលវិជ្ជមានច្រើនជាងមុនដល់អ្នកបោះឆ្នោតដែលជ្រើសរើសមិនចេញទៅនោះ ។
7. អ្នកចូលរួម៖ នៅកន្លែងធ្វើការ សម្រាប់រយៈពេលមួយថ្ងៃគេអាចចំណាយពេលពីរម៉ោងដើម្បីទៅបោះឆ្នោត ប៉ុន្តែខ្ញុំមិនគិតថាគេនឹងចំណាយថ្ងៃណាមួយសម្រាប់រយៈពេលដប់ថ្ងៃដើម្បីចេញទៅបោះឆ្នោតនោះទេ ។
   a. បុគ្គលិក ROV៖ យ៉ាងហោចណាស់ក៏គេទុកឲ្យពេលមួយថ្ងៃ ហើយយើងនឹងបើកនៅថ្ងៃបោះឆ្នោតប្រសិនបើពួកគេមកមិនបានក្នុងរយៈពេលប្រាំបួនថ្ងៃផ្សេងទៀតនោះ ។
   b. បុគ្គលិក ROV៖ យើងមានមណ្ឌលបោះឆ្នោតបើកដំណើរការមុនពេលបោះឆ្នោត យើងនឹងចាប់ផ្តើមមុនខោនធីផ្សេងទៀតបន្តិចដែលអនុវត្តន៍ដើម្បីឲ្យប្រាកដថាមនុស្សមានពេលច្រើនជាងមួយថ្ងៃដើម្បីបោះឆ្នោត ។ ធ្វើការពិចារណាទៅដល់កាលៈទេសៈសម្រាប់អ្នកបោះឆ្នោតនិងប្រជាសាសន៍ផ្សេងៗគ្នានោះ និងព្រមទាំងលក្ខណៈនៃខោនធីរបស់យើងដោយមានប្រជាជនច្រើនខ្លាំងធ្វើដំណើរដោយថ្មើរជើងមកធ្វើការនោះ ហើយមនុស្សបើកបរមកពីគ្រប់ទីក្រុងឆ្ងាយៗនោះ វាសមនឹងមានទីតាំងច្រើនជាងមួយដើម្បីបោះឆ្នោតដោយផ្ទាល់ ប្រសិនបើពួកគេជ្រើសរើសបោះឆ្នោតដោយផ្ទាល់នោះ ប៉ុន្តែពួកគេនឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រដោយស្វ័យប្រវត្តិតែម្តង ។
8. អ្នកចូលរួម៖ ប្រសិនបើប្រៀបធៀបការបោះឆ្នោតដោយសំបុត្រដែលមានដល់ទៅ 75% នោះ អញ្ចឹងអ្នកមិនចាំបាច់ត្រូវមានរហូតដល់ទៅដប់ថ្ងៃទេ ពីព្រោះប្រសិនបើមានមនុស្សច្រើនជាងមុនទៅបោះឆ្នោតតាមសំបុត្រនោះ អ្នកអាចនឹងមានចំនួនថ្ងៃតិចជាង និងចំនួនទីតាំងតិចជាង 120 កន្លែង ។
   a. ខ្ញុំគិតថាយូរៗទៅមនុស្សនឹងទៅបោះឆ្នោតដោយសំបុត្រ ប៉ុន្តែយើងមិនមានជម្រើសនៅក្នុងចំនួនថ្ងៃទេ ។ ច្បាប់កំណត់ចំនួនថ្ងៃជាក់លាក់ យ៉ាងតិចបំផុតត្រឹមប្រាំបីម៉ោងក្នុងមួយថ្ងៃ ដូច្នេះខ្ញុំមិនមានឆន្ទានុសិទ្ធិណាមួយនៅពេលនេះចំពោះច្បាប់ឡើយ ។ ខ្ញុំសង្ឃឹមថាប្រហែលជាក្រោយពីការបោះឆ្នោតបានពីរបីជុំរួចមក នោះអង្គនីតិបញ្ញត្តិរបស់រដ្ឋនឹងយកទិន្នន័យពីគ្រប់ខោនធីទាំងអស់ដែលកំពុងអនុវត្តន៍ច្បាប់នេះ និងយល់ឃើញដូចដែលយើងបានព្យាករណ៍ថាអ្នកបោះឆ្នោតទៅកាន់មណ្ឌលបោះឆ្នោតនឹងថយចុះ យើងសង្ឃឹមថាតាមរយៈការបង្ហាញនូវទិន្នន័យនេះដល់ពួកគេនោះ ពួកគេនឹងផ្លាស់ប្តូរអ្វីមួយ ។ គេប្តូរចំនួនថ្ងៃ ឬលក្ខខណ្ឌតម្រូវនៃមណ្ឌលបោះឆ្នោតក៏បានដែរ ប៉ុន្តែឲ្យតែប្តូរអ្វីមួយទៅតាមការបង្ហាញរបស់ទិន្នន័យ ។
9. អ្នកចូលរួម៖ ព្រះវិហារស្ថិតនៅគ្រប់តំបន់ មានមួយចំនួននៅក្នុង Milpitas និងមួយចំនួននៅ Sunnyvale ។ សម្រាប់ឥណ្ឌា យ៉ាងហោចណាស់ ការមកកាន់ព្រះវិហារមួយសប្តាហ៍ ឬមួយខែម្តងដែរ ដូចនេះហើយវាអាចនិយាយបានថាព្រះវិហារនោះឯងដែលអាចជួយដើរតួជាមណ្ឌលបោះឆ្នោតបាន ដោយសារតែជាទូទៅវាមានទំហំធំ ។
10. អ្នកចូលរួម៖ ជម្រើសមួយទៀតដែលអាចធ្វើទៅរួចដែរនោះគឺរៀបចំមណ្ឌលបោះឆ្នោតនៅជិតៗ ឬ នៅក្នុងការិយាល័យវាដោយផ្ទាល់តែម្តងដូចជា *Apple*, *Google* ឬ *Facebook* នោះ ។ វាងាយស្រួលជាងមុនសម្រាប់ពួកគេដោយគ្រាន់តែទៅនិងបោះឆ្នោត ។
   a. បុគ្គលិក ROV៖ កន្លែងមួយចំនួនយើងប្រហែលជាបានពិនិត្យរួចហើយ ប៉ុន្តែនេះគឺជាមូលហេតុដែលយើងព្យាយាមស្តាប់គំនិតពីអ្នកទាំងអស់គ្នា បើទោះបីជាគំនិតខ្លះយើងកំពុងអនុវត្តន៍ និងខ្លះទៀតមិនទាន់ក៏ដោយ ។ យើងទទួលបានអនុសាសន៍ឲ្យប្រើផ្សារទំនើបមួយចំនួន ។

11. អ្នកចូលរួម៖ មានផ្ទះចល័តជាច្រើននៅជុំវិញខោនធីនេះ ហើយភាគច្រើននៃផ្ទះចល័តទាំងនោះដូចគ្នាទៅនឹងផ្ទះអញ្ជឹងដែរ ហើយតែងតែបើកធ្វើការជាមួយសហគមន៍ ។ អ្នកអាចទៅកាន់មជ្ឈមណ្ឌលសហគមន៍ផ្ទះចល័តផ្សេងៗគ្នាដែលអាចដាក់មនុស្សបានរាប់រយនាក់ ។

12. អ្នកចូលរួម៖ ដោយហេតុថាខ្ញុំបានធ្វើការក្នុងការបោះឆ្នោតពីរដងចុងក្រោយកន្លងមកនេះ អ្នកមានលក្ខខណ្ឌតម្រូវពិសេស និងលក្ខខណ្ឌសម្រាប់ការិយាល័យបោះឆ្នោតនោះ ដូច្នេះតើអ្នកនៅតែស្វែងរកលក្ខខណ្ឌតម្រូវដូចគ្នាទេនៅពេលធ្វើការស្វែងរកមណ្ឌលបោះឆ្នោតមួយដូចជាភាពដែលអាចចេញចូលបានជាដើមនោះ ។

    a. បុគ្គលិក ROV ៖ ពិតមែនហើយ ទីតាំងទាំងអស់នឹងត្រូវអាចចេញចូលបានដោយជនមានពិការភាព ហើយឥឡូវនេះយើងមានលក្ខខណ្ឌបន្ថែមទៀតដោយសារតែយើងត្រូវការឲ្យមានវាច្រើនវាមួយថ្ងៃ ដែលតម្រូវការរៀបចំមួយថ្ងៃឬពីរថ្ងៃមុន ។ យើងពិនិត្យវាយតម្លៃសម្រាប់ទីតាំង និងសាកសួរក្រុមហ៊ុន មហាវិទ្យាល័យ សាលារៀន និងព្រះវិហារ ។

13. អ្នកចូលរួម៖ ខ្ញុំអាចគិតទៅដល់កន្លែងល្អដែលជាផ្នែកនៃព្រះវិហារ ប៉ុន្តែមានការកំណត់មួយចំនួនដូចជាត្រូវតែដោះស្បែកជើងចេញជាដើម ។ ប្រហែលជាអាចដាក់ស្លាកសញ្ញានៅខាងក្រៅបង្ហាញប្រាប់ឲ្យដោះស្បែកជើងចេញ ។

    a. បុគ្គលិក ROV៖ សូមអរគុណ ប៉ុន្តែដោយសារតែវាគឺសម្រាប់សាធារណជនទាំងអស់នោះ ខ្ញុំមិនគិតថាយើងអាចប្រើទីតាំងនោះបានទេ ។

14. បុគ្គលិក ROV៖ ក្រុមប្រព័ន្ធផែនទី GIS ធ្វើការជាពិសេសក្នុងការបង្កើតព្រំប្រទល់និងធ្វើការវិភាគទិន្នន័យមួយចំនួនជាជំនួយជាមួយនឹងផ្នែកប្រតិបត្តិការតាមសង្កាត់ ដើម្បីជួយដល់ពួកគេកំណត់តំបន់ទាំងឡាយនៃខោនធីដែលត្រូវការប្រើជាមណ្ឌលបោះឆ្នោតនោះ ។ សម្រាប់មណ្ឌលបោះឆ្នោតទាំងនេះ ពោលគឺមណ្ឌលបោះឆ្នោតដែលដំណើរការរយៈពេល 11 ថ្ងៃត្រូវផ្តល់សេវាដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចប្រមាណជា 50k ។ យើងបានបែងចែកខោនធីជា 25 តំបន់ ដែលតំបន់នីមួយៗមានអ្នកបោះឆ្នោត 50k ។ ឧទាហរណ៍ Milpitas មានព្រំប្រទល់ផ្ទាល់ខ្លួនរបស់វាដោយហេតុថាវាជាតំបន់ធំ ហើយនឹងមានយ៉ាងហោចណាស់ក៏មណ្ឌលបោះឆ្នោតមួយដើម្បីបម្រើដល់ក្រុង Milpitas ដែលនឹងបើកដំណើរការរយៈពេល 11 ថ្ងៃមុនការបោះឆ្នោត ។ យើងក៏បានបង្កើតនូវការស្ទង់មតិដែលមានមួយចំនួននៃលក្ខខណ្ឌដែលកំណត់ឡើងដោយរដ្ឋ និងលក្ខខណ្ឌទាំងនេះមានបញ្ចូលដូចជា មធ្យោបាយធ្វើដំណើរសាធារណៈ ស្ថិតនៅមិនឆ្ងាយពីមជ្ឈមណ្ឌលដែលមានប្រជាជនខ្ពស់ នៅជិតសហគមន៍ដែលមានចំណូលតិច និងជាពិសេសសហគមន៍ដែលភាសាអង់គ្លេសមិនមែនជាភាសាទីមួយរបស់គេ ។ ស្វែងយល់ពីការស្ទង់មតិនេះមានសារសំខាន់ណាស់ចំពោះយើង ដោយហេតុថាវាបង្ហាញនូវអ្វីដែលសហគមន៍និងសាធារណជនមានអារម្មណ៍ថាមានសារសំខាន់ជាងនៅពេលព្យាយាមគិតរកកន្លែងមណ្ឌលបោះឆ្នោត ។ ឧទាហរណ៍ ប្រសិនបើមានទីតាំងពីរដែលមានតម្លៃនិងស្តង់ដាស្មើគ្នា ហើយត្រូវទៅតាមលក្ខខណ្ឌតម្រូវទាំងអស់ ហើយមួយនៃលក្ខខណ្ឌតម្រូវនោះគឺស្ថិតនៅជិតមជ្ឈមណ្ឌល VTA ហើយកន្លែងផ្សេងៗទៀតនៅឆ្ងាយបន្តិច ដោយប្រើការស្ទង់មតិនេះ ក៏ដូចជាព័ត៌មានយើងប្រមូលដើម្បីជួយដល់ក្រុមប្រតិបត្តិការសង្កាត់ ដើម្បីបង្រួមឲ្យនៅតិចនូវអ្វីដែលមណ្ឌលបោះឆ្នោតចង់បានជាងដូចជាភាពងាយស្រួលទាំងនេះដែលយើងផ្តល់ជូន ។

    a. បុគ្គលិក ROV៖ យើងនឹងមានមណ្ឌលបោះឆ្នោតប្រហែលជា 25 ដែលបើកដំណើរការសរុបចំនួន 11 ថ្ងៃ និងដែលនោះជាពេលដែលការបោះឆ្នោតមិនសូវមមាញឹក បើតាមការចេញមករបស់ពលរដ្ឋនោះ ។ ដូច្នេះហើយ មានតែមណ្ឌលបោះឆ្នោតមួយចំនួនតូចទេដែលបើកដំណើរការនាពេលចាប់ផ្តើម ហើយមិនមែនមណ្ឌលបោះឆ្នោតទាំង 125 បើកដំណើរការទាំងអស់ទេ ។ នៅពេលគេធ្វើច្បាប់ គេដឹងច្បាស់ថានៅសប្តាហ៍ទីមួយនឹងមិនសូវមមាញឹកទេ ហើយវានឹងកើនឡើងក្រោយពេលចាប់ផ្តើមដំណើរការ ។ នៅថ្ងៃសៅរ៍មុនថ្ងៃអង្គារ យើងបន្ថែមមណ្ឌលបោះឆ្នោត 100 ផ្សេងទៀត ធ្វើឲ្យចំនួនសរុបនៃមណ្ឌលបោះឆ្នោតឡើងដល់ 125 នៅត្រឹមថ្ងៃបោះឆ្នោត ។ គេផ្អែកលើបទពិសោធន៍នៅ Colorado ហើយដែលមិនមានការបោះឆ្នោតខ្ពស់នៅពេលចាប់ផ្តើម ដូច្នេះយើងមានលក្ខខណ្ឌតម្រូវជាច្រើនផ្សេងៗគ្នាដែលយើងអនុវត្តន៍តាម ។

    b. អ្នកចូលរួម៖ ដូច្នេះ មានមណ្ឌលបោះឆ្នោតចំនួន 25 ដំណើរការក្នុងរយៈពេល 11 ថ្ងៃ ហើយអ្នកនឹងបន្ថែមចំនួន 100 ទៀតទៅកាន់ទីបញ្ចប់ ។

    c. បុគ្គលិក ROV៖ សរុបទាំងអស់មាន 125 មណ្ឌលបោះឆ្នោត ដែលដំណើរការរយៈពេលបួនថ្ងៃ ។

15. បុគ្គលិក ROV៖ ប្រសិនបើអ្នកត្រូវបោះឆ្នោតតាមសំបុត្រនៅក្នុងការបោះឆ្នោតចុងក្រោយឆ្នាំ 2018 នោះ អ្នកជាផ្នែកមួយក្នុងចំណោមអ្នកបោះឆ្នោត 75% ដែលបានបោះតាមសំបុត្ររួចមកហើយ ។ ប្រសិនបើអ្នកមិនបានទេ អ្នកនឹងត្រូវបោះតាមសំបុត្រ ឬ អ្នកនឹងទទួលបានសន្លឹកឆ្នោតផ្លូវការបោះតាមសំបុត្រនៅក្នុងឆ្នាំ 2020 ។ អ្នកបោះតាមសំបុត្រក៏បាន ឬអត់ក៏បាន ។ យើងនឹងបោះតាមសំបុត្រ 100% ។ នៅក្នុងឆ្នាំ 2018 យើងមានទីតាំងទម្លាក់សន្លឹកឆ្នោតជាង 50+ និងប្តូរទៅបោះតាមសំបុត្រ យើងបានបង្កើនទីតាំងទម្លាក់សន្លឹកឆ្នោតរបស់យើងពី 50+ ទៅជិត 80 កន្លែង ។ គោលដៅរបស់យើងផ្អែកទៅលើផែនទីដែលត្រូវបានបង្ហាញពីមុនមក ។ វានឹងមានទីតាំងទម្លាក់សន្លឹកឆ្នោតមួយកន្លែងសម្រាប់អ្នកបោះឆ្នោត 15k ។ ក្រុមផែនទី GIS បានបង្កើតផែនទីទាំងនេះបង្ហាញពីទីតាំងទាំងនេះ ។ នឹងមានជម្រើសច្រើនជាងមុន ដែលម្នាក់ៗនឹងបោះឆ្នោតតាមសំបុត្រ ស្រោមសំបុត្រផ្ញើត្រឡប់វិញមិនគិតថ្លៃ នឹងមានជិតដល់ 80 ទីតាំងទម្លាក់សន្លឹកឆ្នោត ហើយអ្នកអាចទម្លាក់សន្លឹកឆ្នោតរបស់អ្នកបានផងដែរនៅតាមទីតាំងមណ្ឌលបោះឆ្នោតណាមួយក្នុងចំណោម 120 ទីតាំង ដោយហេតុថានឹងមានហិបទម្លាក់សន្លឹកឆ្នោតនៅទីនោះផងដែរ ។ អ្នកបោះឆ្នោតនឹងមានជម្រើសជាច្រើន ហើយអ្នកទទួលបានសន្លឹកឆ្នោតរបស់អ្នករយៈពេល 29 ថ្ងៃមុនការបោះឆ្នោត ។ ប្រសិនបើអ្នកមានគម្រោងចេញធ្វើដំណើរទៅក្រៅ គ្រាន់តែជូនដំណឹងដល់ការិយាល័យយើង ហើយយើងធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នក ។ ប្រសិនបើអ្នកមានគម្រោងធ្វើដំណើរកាន់តែយូរនោះ យើងនឹងត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មាននោះផងដែរ ។ គ្រាន់តែត្រូវប្រាកដថាអាសយដ្ឋានគេហដ្ឋានរបស់អ្នកនៅក្នុងខោនធី Santa Clara ហើយអាសយដ្ឋានផ្ញើសំបុត្ររបស់អ្នកនៅទីណាដែលអ្នកកំពុងស្ថិតនៅ ធ្វើដូច្នេះនៅរាល់ការបោះឆ្នោតអ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកនៅទីនោះ ។

a. អ្នកចូលរួម៖ តើហិបទម្លាក់សន្លឹកឆ្នោតនឹងមានវត្តមានគ្រប់ទាំងពី 11-14 ថ្ងៃមែនទេ?
b. បុគ្គលិក ROV៖ មាន 29 ថ្ងៃមុនថ្ងៃបោះឆ្នោតចូលមកដល់ យើងនឹងចាប់ផ្តើមប្រគល់ហិបទម្លាក់សន្លឹកឆ្នោត ។ ស្ថិតក្នុងពេលជាមួយគ្នានោះដែរ យើងនឹងទម្លាក់សន្លឹកឆ្នោតតាមសំបុត្ររបស់យើងនៅតាមការិយាល័យប្រៃសណីយ៍ ។ ប្រសិនបើយើងទម្លាក់វានៅតាមការិយាល័យប្រៃសណីយ៍នៅក្នុងរយៈពេល 29 ថ្ងៃនោះ វានឹងត្រូវប្រើពេលមួយរយៈដើម្បីចាប់ផ្តើមមកដល់ ដូច្នេះមកដល់ត្រឹមពេលនោះ ហិបទម្លាក់សន្លឹកឆ្នោតទាំងអស់នឹងត្រូវបានបញ្ជូនទៅដល់គោលដៅពិតប្រាកដរបស់វា ។ ទីតាំងមានបង្ហាញនៅលើគេហទំព័ររបស់យើង ហើយក៏នឹងមាននៅក្នុងខិត្តប័ណ្ណព័ត៌មានណែនាំស្តីពីការបោះឆ្នោតដែរ ។ សំណួរ ឬការព្រួយបារម្ភទាំងឡាយណាដែលអ្នកអាចមាន សូមចូលទៅកាន់គេហទំព័ររបស់យើង ហើយអ្នកនឹងរកបានព័ត៌មានជាច្រើននៅទីនោះ ។
c. អ្នកចូលរួម៖ ក្រដាសសន្លឹកឆ្នោតមិនស្តង់ដាសម្រាប់គ្រប់គ្នា វាអាស្រ័យលើថាតើអាសយដ្ឋានរបស់អ្នកនៅឯណា តើត្រឹមត្រូវទេ?
d. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ។ នៅពេលអ្នកចូលទៅកាន់គេហទំព័ររបស់យើង អ្នកត្រូវវាយបញ្ចូលនូវអាសយដ្ឋានរបស់អ្នក ថ្ងៃខែឆ្នាំកំណើត ហើយបន្ទាប់មកវានឹងទាញឡើងដោយស្វ័យប្រវត្តិនូវប្រភេទសន្លឹកឆ្នោតទៅតាមការកំណត់មកឲ្យអ្នក ។ អ្នកអាចមើលឃើញតែសន្លឹកឆ្នោតដែលត្រូវបានកំណត់ទៅតាមអាសយដ្ឋានលំនៅដ្ឋានរបស់អ្នកប៉ុណ្ណោះ ។
e. អ្នកចូលរួម៖ ឧបមាថាខ្ញុំកំពុងដើរផ្សារនៅកន្លែងណាមួយ ហើយមិនមានជាប់ជាមួយនូវសន្លឹកឆ្នោតរបស់ខ្ញុំ ប្រសិនបើខ្ញុំទៅកាន់មណ្ឌលបោះឆ្នោត តើគេមានសិទ្ធិព្រីនវាចេញឲ្យខ្ញុំនៅពេលនោះបានទេ ឬក៏មានសំណៅមួយសន្លឹកទៀតដូចគ្នានៅមណ្ឌលនោះទេ?
f. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ។ ឧទាហរណ៍ ប្រសិនបើអ្នករស់នៅ Milpitas ហើយអ្នកកំពុងដើរផ្សារនៅផ្សារទំនើប Stanford ហើយយើងមានទីតាំងមណ្ឌលបោះឆ្នោតនៅក្បែរផ្សារនោះ អ្នកអាចដើរចូលហើយគេនឹងមានបញ្ជីឈ្មោះអេឡិចត្រូនិកដែលមានគ្រប់ទិន្នន័យរបស់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចទាំងអស់នៅក្នុងខោនធី Santa Clara ។ គេនឹងរកឈ្មោះអ្នកនៅក្នុងបញ្ជីនោះ ហើយព្រីនសន្លឹកឆ្នោតឲ្យអ្នកដោយផ្អែកទៅលើប្រភេទសន្លឹកឆ្នោត ឬ ទៅតាមសង្កាត់ដែលអ្នកស្ថិតនៅ ដោយមូលហេតុនេះហើយទើបវាបើកទូលាយដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធីទាំងអស់ ។
g. អ្នកចូលរួម៖ តើវានឹងបញ្ឈប់ខ្ញុំពីការបោះឆ្នោតពីរដង ដូចជាខ្ញុំបោះឆ្នោតទៅតាមតម្រូវ និងបោះឆ្នោតដោយសន្លឹកឆ្នោតដែលខ្ញុំទទួលបានពីផ្សារទំនើបទេ? តើអ្វីដែលបញ្ឈប់ខ្ញុំមិនឲ្យបោះឆ្នោតបានពីរដងនោះ?
h. បុគ្គលិក ROV៖ ប្រព័ន្ធរបស់យើងមានមុខងារស្វ័យប្រវត្តិមួយដែលកំណត់ថានៅពេលយើងទទួលបានសន្លឹកឆ្នោតរបស់អ្នកភ្លាម អ្នកមិនអាចបោះឆ្នោតបានម្តងទៀតទេ ។ អ្នកអាចផ្ញើវាមកបាន ប៉ុន្តែយើងនឹងមិនរាប់វាទេប្រសិនបើអ្នកបានបោះឆ្នោតរួចហើយនោះ ។
i. អ្នកចូលរួម៖ ដូច្នេះហើយ ការបោះឆ្នោតនឹងដូចជាការបោះឆ្នោតបណ្តោះអាសន្នអញ្ចឹងដែរមែនទេ? នោះគឺជាអ្វីដែលខ្ញុំយល់បានពីការបោះឆ្នោតបណ្តោះអាសន្ននោះ ដែលខ្ញុំជាអ្នកបោះឆ្នោតតាមសំបុត្រ ហើយខ្ញុំទៅកាន់មណ្ឌលបោះឆ្នោត និងទៅបោះឆ្នោតដោយផ្ទាល់ នោះគឺដើម្បីបញ្ឈប់ការបោះឆ្នោតពីរដង ។
j. បុគ្គលិក ROV៖ កាលពីមុនមក ជាមួយនឹងការិយាល័យបោះឆ្នោត យើងមិនមានតារាងបញ្ជីដែលយើងអាចចូលមើលសំណុំឯកសាររបស់អ្នកបោះឆ្នោតបាននិងបង្ហាញថាតើអ្នកបោះឆ្នោតបានផ្ញើសន្លឹកឆ្នោតរបស់អ្នកហើយឬនៅនោះទេ។ ឥឡូវនេះនៅតាមមណ្ឌលបោះឆ្នោតដោយមានតារាងបញ្ជីថ្មី វានឹងប្រាប់អ្នកថាអ្នកបានបោះរួចហើយ ឬ ប្រសិនបើអ្នកទៅកាន់មណ្ឌលបោះឆ្នោតហើយពេលនោះអ្នកទៅផ្ទះ ហើយផ្ញើសន្លឹកឆ្នោតត្រឡប់មកយើង ពេលនោះវាចូលមកហើយយើងបញ្ចូលវាឲ្យឆ្លងកាត់ម៉ាស៊ីនដើម្បីផ្ទៀងផ្ទាត់វា ហើយវានឹងប្រាប់យើងថាអ្នកបានបោះឆ្នោតរួចហើយនៅឯមណ្ឌលបោះឆ្នោត ដូច្នេះហើយសន្លឹកឆ្នោតនឹងចាត់ទុកជាមិនបានការ ហើយមិនត្រូវបានបើកឡើយ ។
k. អ្នកចូលរួម៖ តើការបោះឆ្នោតតាមសំបុត្រនឹងនៅតែដូចគ្នាដដែលមែនទេ?
l. បុគ្គលិក ROV៖ ការបោះឆ្នោតតាមសំបុត្រមិនប្រែប្រួលឡើយ ។

16. អ្នកចូលរួម៖ ដូច្នេះ តើវាបដិសេធសន្លឹកឆ្នោតដោយស្វ័យប្រវត្តិមែនទេ?
a. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ។ អ្វីៗដែលយើងបានទទួល និងផ្ទៀងផ្ទាត់ហត្ថលេខាជាមួយនឹងហត្ថលេខាដែលចុះឈ្មោះ និងវាត្រូវគ្នា វានឹងជាសន្លឹកឆ្នោតបោះមានសុពលភាព ។ ប្រសិនបើយើងចេញសន្លឹកឆ្នោតឲ្យអ្នកពីរ ហើយសន្លឹកឆ្នោតទីពីរដែលអ្នកមិនចាំថាអ្នកបានផ្ញើវាមកយើងដោយចៃដន្យនោះ នៅពេលយើងទទួលបានវាភ្លាម ប្រព័ន្ធរបស់យើងត្រូវបានកំណត់ដោយស្វ័យប្រវត្តិថាអ្នកបានបោះម្តងរួចហើយ នោះសន្លឹកឆ្នោតបន្ទាប់នឹងចាត់ទុកជាមិនបានការឡើយ ។ ប្រព័ន្ធនឹងមិនអនុញ្ញាតឲ្យអ្នកបោះបានពីរដងនោះទេ ដូច្នេះហើយនោះគឺជារឿងល្អ ។
b. អ្នកចូលរួម៖ ប្រសិនបើនរណាម្នាក់ធ្វើឲ្យមានកំហុសចំពោះហត្ថលេខារបស់គេនៅលើសន្លឹកឆ្នោតទាំងពីរដែលអ្នកទទួលបាន តើវានឹងបដិសេធវាទេ?
c. បុគ្គលិក ROV៖ ប្រសិនបើហត្ថលេខារបស់អ្នកមិនត្រូវគ្នា ឬ អ្នកភ្លេចចុះហត្ថលេខានោះ ច្បាប់ផ្តល់ថាការិយាល័យយើងត្រូវផ្ញើឲ្យអ្នកនូវសេចក្តីថ្លែងពីសន្លឹកឆ្នោតដែលមិនបានចុះហត្ថលេខា ឬសេចក្តីថ្លែងផ្ទៀងផ្ទាត់ហត្ថលេខា មានន័យថាអ្នកអាចភ្លេចចុះហត្ថលេខាលើស្រោមសំបុត្រសន្លឹកឆ្នោត ឬហត្ថលេខារបស់អ្នកមិនត្រូវទៅនឹងមូលដ្ឋានទិន្នន័យរបស់យើង ។ យើងផ្ញើឲ្យអ្នកនូវលិខិតជូនដំណឹងដល់អ្នកបោះឆ្នោតដើម្បីកែកំហុសរបស់វា ។ នៅខាងលើនៃលិខិតនោះ យើងមាន 28 ថ្ងៃបន្ទាប់ការបោះឆ្នោតដើម្បីរង់ចាំលិខិតនោះត្រឡប់មកការិយាល័យយើងវិញ ដូច្នេះយើងអាចផ្តល់ដល់អ្នកបោះឆ្នោតនូវពេលវេលាគ្រប់គ្រាន់ ។

17. អ្នកចូលរួម៖ តើអ្នកអាចនិយាយពីម៉ាស៊ីនបោះឆ្នោតអេឡិចត្រូនិចបានទេ?

   a. បុគ្គលិក ROV៖ នៅតាមមណ្ឌលបោះឆ្នោត នឹងមានអេក្រង់តារាងបញ្ជីធំមួយដែលសន្លឹកឆ្នោតរបស់អ្នកនឹងចេញមក ហើយអ្នកនឹងប៉ះលើអេក្រង់នោះ និងធ្វើការជ្រើសរើស ហើយបន្ទាប់មកវាអាចព្រីនចេញក្រដាសសន្លឹកឆ្នោតបាន ។ បើមិនអញ្ចឹងទេ យើងអាចព្រីនសន្លឹកឆ្នោតរបស់អ្នកចេញមកបាននៅឯបញ្ជរហើយយកវាទៅកាន់ស្តង់របស់អ្នក ហើយគូសវាដោយដៃ ដូច្នេះបើទោះបីជាយ៉ាងណាក៏ដោយ វានឹងជាកំណត់ត្រាក្រដាសបោះឆ្នោតរបស់អ្នកគ្រប់ៗគ្នា ។ វាមិនដូចលើកមុនទេ ដែលអ្នកបោះឆ្នោតនៅលើអេក្រង់ប៉ះ ហើយទម្លាក់សន្លឹកឆ្នោតរបស់អ្នក ហើយមិនមានក្រដាសសន្លឹកឆ្នោតចេញមកទេពីព្រោះថាវាត្រូវបានរាប់នៅក្នុងម៉ាស៊ីននោះតែម្តង ដូច្នេះបច្ចុប្បន្ននេះរបៀបទាំងពីរអ្នកនឹងទទួលបានសន្លឹកឆ្នោតជាក្រដាស ។ អ្នកយកក្រដាសសន្លឹកឆ្នោតនោះទៅម៉ាស៊ីនរាប់ដែលរាប់សន្លឹកឆ្នោតរបស់អ្នកជាមួយនឹងសន្លឹកឆ្នោតទាំងអស់ និងទម្លាក់សន្លឹកឆ្នោតចូលទៅក្នុងធុងដែលមានសុវត្ថិភាព ។ កាលពីមុន សន្លឹកឆ្នោតទាំងអស់ត្រូវតែចូលមកការិយាល័យរបស់យើងដើម្បីរាប់វា ។ ដោយសារតែមូលហេតុនេះហើយ ទើបយើងតែងតែជាខោនធីមួយក្នុងចំណោមខោនធីដែលយឺតបំផុតក្នុងរដ្ឋនៅក្នុងយប់លទ្ធផលបោះឆ្នោត និងរាប់រហូតដល់ថ្ងៃបន្ទាប់ ។ បច្ចុប្បន្ននេះ អ្នកអាចយកតែសំបកត្រឡប់មកវិញ ឬអ្វីមួយជាអេឡិចត្រូនិកពីម៉ាស៊ីនរាប់នីមួយៗពីមណ្ឌលបោះឆ្នោតនីមួយៗនិងបញ្ចូលវាក្នុងប្រព័ន្ធជំនួសឲ្យស្កេនគ្រប់ក្រដាសសន្លឹកឆ្នោតទាំងអស់នៅការិយាល័យរបស់យើង ។ ធ្វើបែបនេះ វានឹងលឿនជាងនៅយប់លទ្ធផលបោះឆ្នោត ប៉ុន្តែនៅតែមានរយៈពេល 30 ថ្ងៃសម្រាប់ឲ្យយើងផ្ទៀងផ្ទាត់ការបោះឆ្នោតតាមសំបុត្រដដែល ។

18. អ្នកចូលរួម៖ នៅពេលអ្នករាប់មណ្ឌលបោះឆ្នោតទាំង 125 នេះ មានមនុស្សច្រើនជាងមុនបោះឆ្នោតតាមសំបុត្រ ហើយមានចំនួនខ្ពស់ ។ អ្នកបោះឆ្នោតដែលទៅបោះឆ្នោត ហើយទាមទារប្រើសិទ្ធិរបស់គេដើម្បីបោះឆ្នោតជាអ្នកបោះឆ្នោតដែលនឹងចូលមណ្ឌលបោះឆ្នោតមុនគេក្នុងកំឡុងពេលដប់ថ្ងៃ ។

   a. បុគ្គលិក ROV៖ ខ្ញុំគិតថាអ្នកបោះឆ្នោតភាគច្រើននឹងមានអារម្មណ៍បែបហ្នឹង ។

19. អ្នកចូលរួម ៖ សម្រាប់ទីតាំងមណ្ឌលបោះឆ្នោត តើអ្នកបានមើលនៅវិទ្យាល័យសហគមន៍ដូចជា De Anza ហើយឬនៅ?

   a. បុគ្គលិក ROV៖ យើងកំពុងសាកសួរពួកគេ ។ យើងទទួលបានការយល់ព្រមពី *សាកលវិទ្យាល័យរដ្ឋ San Jose* រួចហើយ ។ យើងកំពុងតែសម្លឹងឃើញ West Valley ផងដែរ ។

   b. អ្នកចូលរួម៖ សាលារៀនទាំងអស់ និងមហាវិទ្យាល័យគឺជាគំនិតល្អ ។ សាលារៀនមានក្លិបហាត់ប្រាណធំដែលអាចប្រើបាន ។ បញ្ហានោះគឺមណ្ឌលបោះឆ្នោតដំណើរការរយៈពេល 11 ថ្ងៃ អាចនឹងមិនធ្វើបានសម្រាប់ទីតាំងទាំងនេះ ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*ធាតុចូលពីសាធារណមតិ/សំណួរ៖ (គ្មាន)*

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលធាតុចូលពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា។

*មតិចូលរួមជាសាធារណៈ/សំណួរ ៖*

1. បុគ្គលិក ROV៖ យើងមានប្រព័ន្ធបោះឆ្នោតថ្មីនៅតាមមណ្ឌលបោះឆ្នោត ដោយឥឡូវនេះមានយ៉ាងតិចបីនោះ ប្រសិនបើមិនបានច្រើនជាងនេះទេនោះ តារាងបញ្ជីដែលអាចប្រើបានដែលជាកន្លែងអ្នកទាញសន្លឹកឆ្នោតចេញ គូសវានៅអេក្រង់ ហើយព្រីនវាចេញមកនូវអ្វីដែលអ្នកបានជ្រើសរើស ។ យើងក៏អាចព្រីនចេញនូវសន្លឹកឆ្នោតជាក្រដាសទៅតាមតម្រូវការនៃភាសា ឬតាមប្រភេទសន្លឹកឆ្នោតណាមួយ ហើយពេលនេះយើងដាក់វាចូលទៅក្នុងម៉ាស៊ីនរាប់ ដែលទាំងនោះក៏ជាអ្វីដែលថ្មីផងដែរ ។ ម៉ាស៊ីននឹងប្រាប់អ្នកបោះឆ្នោតប្រសិនបើគេភ្លេចបោះឆ្នោត ប្រសិនបើគេបោះក្រោមអាយុ ឬរំលងការប្រកួតប្រជែង ដូចនេះហើយអ្នកបោះឆ្នោតអាចត្រឡប់ទៅវិញ ប្រសិនបើពួកគេប្តូរចិត្ត ពោលគឺធ្វើវាឲ្យងាយស្រួលដល់អ្នកបោះឆ្នោត ។ ម៉ាស៊ីននឹងទម្លាក់សន្លឹកឆ្នោតរបស់គេចូលទៅក្នុងធុងសុវត្ថិភាពនៅខាងក្រោមជាកន្លែងដែលវានឹងរក្សាសម្រាប់ឲ្យយើងទៅយក ។ យើងមានព័ត៌មាននៅលើគេហទំព័រប្រសិនបើអ្នកមិនអាចចាកចេញពីផ្ទះបាន ហើយមិនអាចមកដោយផ្ទាល់បានទេនោះ មានប្រព័ន្ធមួយហៅថាប្រព័ន្ធបោះឆ្នោតតាមសំបុត្រពីចម្ងាយ ។

   a. អ្នកចូលរួម៖ ជាមួយនឹងការបញ្ជូនមកជាអេឡិចត្រូនិក តើមានមធ្យោបាយណាដែលនរណាម្នាក់អាចគ្រាន់ទៅហើយទាញយកសន្លឹកឆ្នោតទៅតាមតម្រូវការ ដូចជាអាចមកពីកំណត់ត្រារបស់ DMV (ក្រសួងយានយន្ត) ឬអ្វីមួយស្រដៀងគ្នានេះ ឬអ្នកនឹងត្រូវតែផ្ញើវាតាមអ៊ីម៉ែលទៅពួកគេ ។

b. បុគ្គលិក ROV៖ អ្នកបោះឆ្នោតត្រូវតែស្នើសុំវា ។ នេះមានតែនៅតាមការបោះឆ្នោតអេឡិចត្រូនិកទេ ហើយសម្រាប់យោធា អ្នកបោះឆ្នោតនៅក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព ។ ឧទាហរណ៍ ប្រសិនបើអ្នកជាយោធា អ្នកត្រូវតែស្ថិតនៅក្រៅខោនធីដើម្បីដាក់ពាក្យស្នើសុំវាបាន ប៉ុន្តែប្រសិនបើអ្នកស្ថិតនៅទីនេះក្នុងខោនធី Santa Clara នោះ វាមិនអាចធ្វើបានទេ ។ វាត្រូវភ្ជាប់ទៅនឹងកន្លែងដែលជាសំណៅនៃសន្លឹកឆ្នោតផ្លូវការរបស់អ្នក ។ នៅទីបញ្ចប់ អ្នកត្រូវព្រីនវាចេញដោយសារតែវាមិនរាប់អេឡិចត្រូនិកទេ ។ នៅពេលអ្នកព្រីនសន្លឹកឆ្នោតរបស់អ្នកចេញភ្លាម សូមផ្ញើវាត្រឡប់ទៅការិយាល័យចុះបញ្ជីបោះឆ្នោតវិញ ។ វាមិនដូចជាអ្នកបោះឆ្នោតតាមទូរសព្ទទេ វានៅតែត្រូវតែជាក្រដាស ។

## VII.ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. បុគ្គលិក ROV៖ ប្រសិនបើអ្នកចង់ឲ្យមានការរំឭកនោះ អ្នកអាចចុះឈ្មោះជាមួយនឹង*Twitter* ព័ត៌មានរបស់យើង *Facebook* ព័ត៌មានរបស់យើងនិង *Nextdoor* ។ យើងមានការងារដ៏ធំនឹងមកដល់ហើយយើងនឹងសម្រេចឲ្យបាននូវយុទ្ធនាការដ៏ខ្លាំងខ្លាមួយដើម្បីបញ្ចេញសារថាការបោះឆ្នោតនឹងមានការផ្លាស់ប្តូរ ។ យើងគិតថាវាដើម្បីភាពប្រសើរឡើង ហើយខ្ញុំគិតថាមនុស្សភាគច្រើនក៏នឹងយល់ដូច្នេះដែរ ប៉ុន្តែយើងនឹងធ្វើឲ្យវាកាន់តែបុរេសកម្មដើម្បីបញ្ចេញសារទៅមនុស្សនៅតាមវេទិការផ្សេងៗគ្នា ។ កាលពីពេលកន្លងមកយើងបានផ្សាយពាណិជ្ជកម្មនៅក្នុងកាសែត *India West* និង *India Post* ប៉ុន្តែយើងមិនដឹងថាពលរដ្ឋអានអ្វីនោះទេ ឬ ថាតើនេះជាការបោះពុម្ពផ្សាយក្នុងកម្រិតមូលដ្ឋាន ឬជាតិនោះទេ ដូច្នេះយើងនឹងស្វែងរកព័ត៌មានបន្ថែមទៀតអំពីអ្វីជាមធ្យោបាយប្រសើរបំផុតដើម្បីទៅឲ្យដល់ពលរដ្ឋដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះ ។
   a. អ្នកចូលរួម៖ មានទស្សនាវដ្ដីលំដាប់ជាតិមួយហៅថា India Current ហើយពលរដ្ឋទទួលវាបានតាមអ៊ីម៉ែលផងដែរ ។ ជាតម្មតាវាដាក់នៅតាមហាងទំនិញ ព្រះវិហារ និងកន្លែងផ្សេងៗទៀត ។ វាជាទស្សនាវដ្ដីមួយដែលពេញនិយមខ្លាំងណាស់ ។
   b. អ្នកចូលរួម៖ មានកាសែតក្នុងស្រុកជាច្រើនពី Sunnyvale និង Cupertino បោះពុម្ពផ្សាយពីស្តង់ពិព័ណសុខភាពពី ROV ហើយខ្ញុំពិតជាភ្ញាក់ផ្អើល និងខ្ញុំគិតថាអ្នកទាំងអស់គ្នាកំពុងធ្វើមានលទ្ធផលនិងលក្ខណៈស្និទ្ធស្នាលច្រើនជាងមុនសម្រាប់អ្នកប្រើប្រាស់ ។
   c. អ្នកចូលរួម៖ អ្នកទាំងអស់គ្នាគួរតែជាអ្នកយកចិត្តទុកដាក់លើបរិស្ថានច្រើនជាង ។
2. អ្នកចូលរួម៖ មានទស្សនាវដ្ដីមួយមានឈ្មោះថា *Siliconial* និកកម្មវិធី TV មានមូលដ្ឋាននៅ New York មានឈ្មោះថា *Namaste America* ។ វាមានកម្មវិធីនៅថ្ងៃសៅរ៍វេលាម៉ោង 9:00 មានមនុស្ស 80-90% ទស្សនាកម្មវិធីនេះ ។
   a. បុគ្គលិក ROV៖ តើ *Namaste America* មានគោលដៅផ្សាយពាណិជ្ជកម្ម ដូចជាចំពោះខោនធី Santa Clara ទេ?
   b. អ្នកចូលរួម៖ អ្នកអាចទាក់ទងពួកគេបាន ផ្ញើទៅពួកគេនូវទិន្នន័យដូចជាអ្វីដែលបានថតជាសម្លេង ឬ ជាវីដេអូ ហើយពួកគេនឹងកាត់តវា ។ ពួកគេជំនាញផ្នែកនេះខ្លាំងណាស់ ។
3. អ្នកចូលរួម៖ យើងបានធ្វើយុទ្ធនាការមន្ត្រីរៀបចំការបោះឆ្នោតជាមួយនឹង ROV ពីមុនមក ។ យើងបានផលិតជាករណីសិក្សាមួយនៃយុទ្ធនាការនៅក្នុងកញ្ចប់ផ្សព្វផ្សាយរបស់យើងដោយសារនោះជាយុទ្ធនាការទាក់ទាញការចូលរួមខ្ពស់បំផុតដែលយើងបានធ្វើ ។ នោះជាយុទ្ធនាការមួយដ៏ល្អខ្លាំងណាស់ ។
   a. បុគ្គលិក ROV៖ ពិតជាប្រសើរណាស់ដែលបានដឹង ។ យើងបានដាក់អ្នកចូលក្នុងបញ្ជីរួចហើយសម្រាប់យុទ្ធនាការឆ្នាំនេះ ។ យើងទន្ទឹងរងចាំធ្វើការជាមួយអ្នកម្តងទៀត ។
   b. អ្នកចូលរួម៖ ឥឡូវនេះយើងទាំងអស់គ្នាសុទ្ធតែជាអ្នកឌីជីថល ។ យើងមិនមានព្រីនបន្ថែមអីទៀតទេ ។
   c. បុគ្គលិក ROV៖ វាល្អតើដែលអ្វីៗទាំងអស់ជាឌីជីថលនោះ ប៉ុន្តែយើងក៏ចង់មានឯកសារជាព្រីនខ្លះដែរសម្រាប់អ្នកបោះឆ្នោតដែលពេញចិត្តរបៀបនេះជាង ។
4. បុគ្គលិក ROV៖ តើមានគំនិតស្ដីពីប្រព័ន្ធផ្សព្វផ្សាយអ្វីទៀតទេ? តើស្ថានីយ៍វិទ្យុទេ?
   a. អ្នកចូលរួម៖ ស្ថានីយ៍វិទ្យុមាន FM 92.3, AM 1170 (Radio Zindagi) និង AM 1310 (Radio Mirchi) ។
   b. អ្នកចូលរួម៖ ស្ថានីយ៍វិទ្យុមានការពេញនិយមខ្លាំងណាស់ ។ អ្នកអាចបើកវាឡើង ហើយគ្រប់គ្នាស្តាប់វា ។
   c. អ្នកចូលរួម៖ ស្ថានីយ៍វិទ្យុទាំងបីនោះមានការពេញនិយមខ្លាំងណាស់ ។ មានបទចម្រៀងជាច្រើន ប៉ុន្តែគេក៏ទទួលអ្នកទូរសព្ទហៅចូលដែរ ។
   d. អ្នកចូលរួម៖ មានកម្មវិធីជួលម៉ោងច្រើន ។
   e. អ្នកចូលរួម៖ អ្នកអាចទិញម៉ោង 15 នាទីពីពួកគេ ហើយពិភាក្សាជាមួយពួកគេ ។
   f. បុគ្គលិក ROV៖ តើគេមានការផ្សាយជាភាសាអង់គ្លេសទេ?
   g. អ្នកចូលរួម៖ គេមានភាគច្រើនបំផុតជាភាសាហ៊ីនឌី តែគេក៏មានជាភាសាអង់គ្លេសដែរ ។
   h. បុគ្គលិក ROV៖ ប្រសិនបើអ្នកមានគំនិតអ្វីបន្ថែមទៀតពីស្ថានីយ៍វិទ្យុ ឬទូរទស្សន៍នោះ សូមផ្ញើអ៊ីម៉ែលមកយើងតាម voterschoice@rov.sccgov.org

5. បុគ្គលិក ROV៖ ឱកាសផ្សេងៗទៀតដែលយើងចង់និយាយប្រាប់ដល់អ្នកទាំងអស់គ្នានោះគឺអំពីគណៈកម្មាធិការពីរដែលយើងមាន៖ គណកម្មការផ្តល់ឱវាទលើលទ្ធភាពទទួលបាននៃសេវាភាសា (LAAC) និងគណៈកម្មាធិការផ្តល់ឱវាទលើលទ្ធភាពនៃការចេញចូលកន្លែងបោះឆ្នោត (VAAC) ។ យើងពិតជាកំពុងស្វែងរកអ្នកស្ម័គ្រចិត្តចូលរួមក្នុងគណៈកម្មាធិការរបស់យើងដើម្បីជួយយើងពិនិត្យឡើងវិញនូវឯកសារផ្សព្វផ្សាយទាំងឡាយ ឯកសារផ្តល់ជូន សូមផ្តល់ឲ្យយើងនូវធាតុចូលចំពោះបញ្ហានេះ ។ VAAC គឺផ្តោតទៅលើមនុស្សចាស់ជរា និងអ្នកបោះឆ្នោតដែលមានពិការភាពជាង ។ LAAC តំណាងឲ្យគណៈកម្មាធិការភាសាផ្សេងៗគ្នា ។ យើងកំពុងស្វែងរកតំណាងសម្រាប់ភាសាហ៊ីនឌីសម្រាប់ LAAC ។
   a. អ្នកចូលរួម៖ តើត្រូវចំណាយពេលប៉ុន្មានទៅ?
   b. បុគ្គលិក ROV៖ យើងបានសម្រេចប្រជុំមួយខែម្តង និងអាចប្រចាំត្រីមាសនាពេលអនាគត ។ មានអ៊ីម៉ែលក្រុមសម្រាប់គណៈកម្មាធិការសម្រាប់នរណាម្នាក់ចង់ពិភាក្សាបន្ថែមលើបញ្ហានានា ។ គណៈកម្មាធិការនឹងប្រជុំប្រចាំខែយ៉ាងហោចណាស់រហូតដល់ការបោះឆ្នោតខែមិនា ។
6. បុគ្គលិក ROV៖ ឱកាសមួយទៀតនោះគឺសម្ព័ន្ធអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ។ នេះមិនមែនតម្រូវដោយច្បាប់នោះទេ ប៉ុន្តែគោលបំណងនៃសម្ព័ន្ធភាពនេះគឺដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត និងប្រាប់ពួកគេឲ្យដឹងពីអ្វីនឹងមកដល់ ។ ការផ្តោតការយកចិត្តទុកដាក់របស់ក្រុមនេះគឺការអប់រំដល់អ្នកបោះឆ្នោត និងសម្រាប់ពលរដ្ឋដែលចង់ចែកចាយសារបន្ត ។ យើងអាចទៅដល់សហគមន៍ និងធ្វើបទបង្ហាញអំពីច្បាប់ VCA ។ យើងក៏អាចបណ្តុះបណ្តាលគ្រូបង្គោល ដែលយើងបណ្តុះបណ្តាលអ្នក ហើយបន្ទាប់មកអ្នកអាចទៅបណ្តុះបណ្តាលអ្នកផ្សេងនៅក្នុងសហគមន៍របស់អ្នក ។ យើងអាចផ្តល់ជូនឯកសារសម្រាប់ចែកចាយនិងបទបង្ហាញនានា ដែលចាំបាច់ដើម្បីបញ្ចេញសារផ្សព្វផ្សាយ ។ យើងត្រូវការជំនួយទាំងអស់ដែលយើងអាចទទួលបានដើម្បីអប់រំប្រជាជនដែលត្រូវបោះឆ្នោតអំពីច្បាប់ VCA ។ កិច្ចប្រជុំជាការចាប់ផ្តើមធ្វើឡើងសម្រាប់ VEOC គឺនៅថ្ងៃទី 8 ខែសីហា ។
   a. បុគ្គលិក ROV៖ ដោយសារតែខោនធីរបស់យើងមានលក្ខណៈចម្រុះជាតិសាសន៍នោះ អ្វីដែលសំខាន់នោះគឺការរៀបចំសារដាច់ដោយឡែកសម្រាប់សហគមន៍នីមួយៗជាភាសារបស់គេធ្វើដោយអ្នកមានឥទ្ធិពលនិងជាតំណាងដែលពួកគេជឿជាក់ ។ វាពិតជាប្រសើរណាស់ដែលយើងបានចូលមកធ្វើបទបង្ហាញដល់អ្នក ប៉ុន្តែវាពិតជាមានប្រសិទ្ធិភាពច្រើនជាងនេះសម្រាប់អ្នកផ្ទាល់ទៅផ្តល់ដំណឹងដល់សហគមន៍របស់អ្នក ហើយបញ្ជាក់ពីសារសំខាន់នៃការបោះឆ្នោត ។ VEOC នឹងបំពាក់ដល់អ្នកនូវធនធាននិងកញ្ចប់ឧបករណ៍សម្រាប់ការបណ្តុះបណ្តាល ដូច្នេះហើយអ្នកអាចធ្វើវាដោយខ្លួនអ្នកនៅតាមព្រះវិហារ អង្គការរបស់អ្នក កន្លែងធ្វើការរបស់អ្នក ផ្ទះរបស់អ្នក កន្លែងទាំងឡាយដែលអាចធ្វើវាបាន ។ គោលបំណងគឺថាសហគមន៍ទាំងឡាយដែលជាប្រពៃណីទៅហើយមិនទទួលបានសេវាជិតដល់នោះ នឹងដឹងជាក់លាក់នូវពេលវេលា របៀប និងទីកន្លែងដែលត្រូវបោះឆ្នោតនៅពេលការបោះឆ្នោតចូលមកដល់ ។ គម្រោងគឺត្រូវមានសិក្ខាសាលាមួយសម្រាប់សហគមន៍ភាសានីមួយៗ ដូច្នេះវាមានប្រយោជន៍ត្រូវដឹងពីទីកន្លែងត្រូវទៅ និងអ្នកដែលត្រូវទាក់ទងដើម្បីរៀបចំសិក្ខាសាលាទាំងនេះ ។ យើងនឹងរីករាយទៅកាន់កន្លែងដែលអ្នកស្ថិតនៅ ។
7. អ្នកចូលរួម៖ បណ្ណាល័យជាកន្លែងល្អសម្រាប់ធ្វើការផ្សព្វផ្សាយ ។
   a. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ បណ្ណាល័យជាដៃគូដ៏អស្ចារ្យតាំងពីដើមរៀងមករបស់យើងសម្រាប់ដាក់ហិបទម្លាក់សន្លឹកឆ្នោតមណ្ឌលបោះឆ្នោត និងធ្វើបទបង្ហាញនានា ។
   b. បុគ្គលិក ROV៖ នៅពេលកាន់តែកៀកទៅនឹងការបោះឆ្នោត យើងនឹងព្រីនឯកសារឲ្យបានច្រើនសម្រាប់ចែកចាយនៅតាមបណ្ណាល័យ ក្រុមហ៊ុនក្នុងមូលដ្ឋាន អគាររដ្ឋាភិបាលក្រុង កន្លែងអ៊ូអរនានា - ដូច្នេះមនុស្សនឹងដឹងកាន់តែច្រើន ។
8. បុគ្គលិក ROV៖ យើងនឹងស្វែងរកបុគ្គលិកជំនួយបន្ថែមដើម្បីជួយកិច្ចការនៅតាមមណ្ឌលបោះឆ្នោត ។ មានការផ្លាស់ប្តូរបន្តិចពីរបៀបដែលធ្វើពីមុនមក ។ យើងនឹងនៅតែមានអ្នកស្ម័គ្រចិត្តដែលនឹងទទួលបានកំរៃចំពោះការងារសម្រាប់រយៈពេលមួយថ្ងៃ ឬពីរថ្ងៃ ប៉ុន្តែយើងនឹងជួលបុគ្គលិកជំនួយបន្ថែមរហូតដល់ទៅ 1500-2000 នាក់ ។ អ្នកទាំងនេះនឹងត្រូវជានិយោជិតខោនធី ដែលនឹងត្រូវឆ្លងកាត់ដំណើរការជ្រើសរបស់ខោនធីទាំងមូលតែម្តង ហើយនឹងត្រូវសុំឲ្យទៅធ្វើការសម្រាប់រយៈពេលប្រហែលជាពីរសប្តាហ៍ ។ វានឹងជាបញ្ហាប្រឈមដើម្បីស្វែងរកមនុស្សដ៏ច្រើនទាំងនេះឲ្យធ្វើការទៅតាមចំនួនថ្ងៃដែលត្រូវការ ដូច្នេះប្រសិនបើអ្នកមានសំណួរឬទំនាក់ទំនងសម្រាប់អ្នកដែលអាចធ្វើការនៅតាមមណ្ឌលបោះឆ្នោតបាន សូមកុំស្ទាក់ស្ទើទាក់ទងមកយើងតាម voterschoice@rov.sccgov.org ។

VIII.**ផ្សេងៗ**

*មតិចូលរួមជាសាធារណៈ/សំណួរ ៖*

1. អ្នកចូលរួម៖ តើអ្វីទៅជាភាពខុសគ្នារវាងការបោះឆ្នោតបណ្តោះអាសន្ននិងការបោះឆ្នោតមានលក្ខខណ្ឌនោះ?
   a. បុគ្គលិក ROV៖ ពីមុនមក ការបោះឆ្នោតបណ្តោះអាសន្នគឺដោយសារតែទៅកាន់ការិយាល័យបោះឆ្នោតខុស ហើយត្រូវបោះបណ្តោះអាសន្នដោយសារតែអ្នកមិនមានឈ្មោះក្នុងបញ្ជី ។ ជាធម្មតាវាដោយសារតែយើងមិនអាចផ្ទៀងផ្ទាត់ការចុះឈ្មោះរបស់អ្នកបោះឆ្នោតបាន ថាតើគេនៅសកម្មនៅឡើយនាពេលនោះឬអត់ ។ បច្ចុប្បន្ននេះជាមួយនឹងការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ (CVR) ដែលសម្រាប់អ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះ ហើយចង់ទៅចុះឈ្មោះនោះ គេអាចបំពេញព័ត៌មានចុះឈ្មោះរបស់គេ ហើយបន្ទាប់មកបំពេញលើសន្លឹកឆ្នោតផ្លូវការ ដាក់វាចូលទៅក្នុងស្រោមសំបុត្រ ហើយនៅពេលវាត្រឡប់មកដល់ការិយាល័យរបស់យើង យើងនឹងចុះឈ្មោះអ្នកបោះឆ្នោត ហើយជាចុងក្រោយនោះគឺរាប់សន្លឹកឆ្នោតរបស់គេថាជាបានការ ។

2. អ្នកចូលរួម៖ ប្រសិនបើបុគ្គលចេញទៅខាងក្រៅរដ្ឋនៅក្នុងកំឡុងពេលបោះឆ្នោត បានចុះឈ្មោះក្នុងរដ្ឋ California ហើយមិនអាចត្រឡប់មកខោនធីបាននោះ តើគេបោះឆ្នោតយ៉ាងដូចម្ដេចទៅ?
    a. បុគ្គលិក ROV៖ អ្នកបោះឆ្នោតភាគច្រើនបំផុតនោះស្នើសុំសន្លឹកឆ្នោតឲ្យផ្ញើទៅកាន់កន្លែងដែលគេកំពុងស្ថិតនៅ ។ ឧទាហរណ៍ អ្នកបោះឆ្នោតបានចុះឈ្មោះលំនៅដ្ឋានរបស់គេនៅខោធី Santa Clara ប៉ុន្តែពួកគេចង់ឲ្យផ្ញើវាទៅ New York ។ ពួកគេផ្ដល់ដល់យើងនូវអាសយដ្ឋានផ្ញើសំបុត្រ ហើយយើងអាចផ្ញើសន្លឹកឆ្នោតដល់ពួកគេ ។
    b. អ្នកចូលរួម៖ តើនោះនឹងត្រូវធ្វើជាមុន ត្រឹមត្រូវទេ?
    c. បុគ្គលិក ROV ៖ ពិតជាត្រឹមត្រូវ ។
3. អ្នកចូលរួម៖ តើចំនួនភាគរយនៃអ្នកបោះឆ្នោតតាមសំបុត្រកាលពីការបោះឆ្នោតប្រធានាធិបតីចុងក្រោយនេះមានប៉ុន្មាន ហើយអ្វីទៅជាចំនួនដែលអ្នករំពឹងទុកនោះ? មនុស្សជាច្រើនត្រូវចុះឈ្មោះបោះឆ្នោតតាមសំបុត្រ ដូច្នេះតើអត្រាភាគរយដែលរំពឹងទុកមានប៉ុន្មាន?
    a. បុគ្គលិក ROV៖ សម្រាប់ឆ្នាំ 2020 វាពិបាកពេកទេដើម្បីធ្វើការព្យាករណ៍ចំណុចនេះ ។ ជាធម្មតានៅពេលយើងនៅកាន់តែកៀកយើងស្ទង់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងសហគមន៍ និងអ្វីដែលយើងឮ យើងនឹងបញ្ចេញវានៅពេលកាន់តែកៀកជាមួយនឹងការប៉ាន់ប្រមាណដ៏ជាក់លាក់មួយ ។ វាជាការព្យាករណ៍ផ្អែកជាដំបូងទៅលើព័ត៌មានស្ថិតិនាពេលកន្លងមក ប៉ុន្តែខ្ញុំមិនមានព័ត៌មានស្ថិតិនោះជាប់នឹងខ្ញុំទេ ។ ការបោះឆ្នោតបឋមនៅក្នុងខែមិថុនា ជាធម្មតាមានការចេញមកបោះឆ្នោតតិចជាងនៅក្នុងការបោះឆ្នោតសាកល ដូច្នេះហើយយើងនឹងពិនិត្យមើលការបោះឆ្នោតនាពេលកន្លងមកដើម្បីឲ្យប្រាកដថាយើងកំពុងស្ថិតនៅលើគោលដៅ ប៉ុន្តែយើងក៏នឹងកែតម្រូវវានៅក្រោយពេលយើងផ្ញើចេញសន្លឹកឆ្នោតទាំងនោះ ។ ពួគេអាចដឹងបានតាមចំនួនសន្លឹកឆ្នោតដែលត្រឡប់មកវិញតាមប្រៃសណីយ៍ តើលឿនប៉ុណ្ណា និងបន្ទាប់មកយើងចាប់ផ្ដើមធ្វើការកែតម្រូវ ។ ជាធម្មតាយើងមានអត្រា 5% នៃអ្វីដែលកើតឡើង ប៉ុន្តែយើងនឹងផ្អែកទៅលើវាដើម្បីទទួលបានការប៉ាន់ប្រមាណមួយដែលប្រសើរជាងមុនបន្ទាប់ពីយើងផ្ញើសន្លឹកឆ្នោតចេញដើម្បីចាំមើលថាតើមានចំនួនប៉ុន្មានត្រឡប់មកវិញ ។

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

# គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់លទ្ធភាពដែលអាចចេញចូលបាន

មជ្ឈមណ្ឌលរស់នៅដោយឯករាជ្យ Silicon Valley

25 N. 14th Street Suite 1000, San Jose, CA 95112

បន្ទប់គណៈកម្មការ

ថ្ងៃពុធ ទី 10 ខែ កក្កដា ឆ្នាំ 2019

ម៉ោង 11:00 ព្រឹក ដល់ម៉ោង 12:45 ថ្ងៃត្រង់

**វត្តមានអ្នកចូលរួម ៖**

សិទ្ធិពិការភាពនៃរដ្ឋ California, នាយកដ្ឋានស្តារនិតិសម្បទា, ការិយាល័យប៉ូលីសនៃខោនធី Santa Clara, មជ្ឈមណ្ឌលរស់ដោយឯករាជ្យនៃ Silicon Valley, សិទ្ធិជនស៊ីវិលនៃរដ្ឋ California

**វត្តមានបុគ្គលិកចូលរួម ៖**

Shannon Bushey, Vanessa Hamm, Magdalena Sta Maria, Shelby Galaviz, Priscilla Favela, Allen Ocampo, Lance Nottle, Rachel Jung, Janora Davis, Darren Tan, Alfred Gonzales, Patricia Lopez, Eric Kurhi, Aaron Wong, Mike Fong

**ចំណុចសកម្មភាព ៖**

- បញ្ជូនលក្ខណៈវិនិច្ឆ័យ 14 សម្រាប់លទ្ធភាពដែលអាចចេញចូលបាន តំណភ្ជាប់ទៅទម្រង់មតិយោបល់, និងទម្រង់មតិយោបល់ pdf

I. **សេចក្តីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA), អ្នកបោះឆ្នោតនឹងអាចជ្រើសរើសពីរបៀបពេលវេលា និងទីកន្លែងដែលពួកគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ទម្លាក់សន្លឹកឆ្នោតរបស់គេតាមប្រអប់ដាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

## III. គោលដៅនៃគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងការចូលរួមពីសហគមន៍ ។

## IV. ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងប្រអប់ដាក់សន្លឹកឆ្នោត

ROV នឹងប្រមូលមតិយោបល់ចូលរួមពីសាធារណជនដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ទីតាំងមណ្ឌលបោះឆ្នោត និងកន្លែងដើម្បីដាក់ប្រអប់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាធំទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមរម្យដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

មតិចូលរួម/សំណួរពីសាធារណជន៖

1. អ្នកចូលរួម ៖ ចុះចំណែកមណ្ឌល Billy DeFrank ដែលចុះតាមផ្លូវវិញនោះយ៉ាងម៉េចដែរ ?
    a. បុគ្គលិក ROV ៖ យើងអាចធ្វើការពិចារណាចំពោះរឿងនេះ ។
2. អ្នកចូលរួម ៖ ចុះចំណែកមណ្ឌលសហគមន៍វិញនោះ ?
    a. បុគ្គលិក ROV ៖ យើងកំពុងតែពិនិត្យនៅបណ្ណាល័យ , មណ្ឌលសហគមន៍, ព្រះវិហារ, រាប់ទាំងស្ថានីយ៍ពន្លត់អគ្គិភ័យផងដែរសម្រាប់ប្រអប់ដាក់សន្លឹកឆ្នោត ។ ប្រសិនបើអ្នកមានទីតាំងដាក់លាក់ណាមួយ យើងក៏ចង់ទទួលព័ត៌មានពីកន្លែងទាំងនោះផងដែរ ។
3. អ្នកចូលរួម ៖ ចុះចំណែកមហាវិទ្យាល័យតាមសហគមន៍ និងសាលារៀនវិញ ?
    a. បុគ្គលិក ROV ៖ យើងកំពុងជជែកជាមួយនាយកសាលានៅសប្តាហ៍នេះ ហើយយើងកំពុងស្ថិតក្នុងដំណើរការនៃការបញ្ជាក់ជាមួយនឹង West Valley និង San Jose ។
    b. បុគ្គលិក ROV ៖ យើងកំពុងធ្វើការចរចារតម្លៃនៅខណៈនេះ ដូចនេះ ប្រសិនបើមាននរណាម្នាក់ដែលមានទំនាក់ទំនងនៅកន្លែងនោះ សូមមេត្តាផ្តល់ដំណឹងមកយើងខ្ញុំ ។
4. អ្នកចូលរួម ៖ ចុះចំណែកហាងលក់គ្រឿងទេសវិញនោះ ? ប្រាកដណាស់ គឺជាវិធីប្រសើរបំផុតសម្រាប់ដាក់ប្រអប់សន្លឹកឆ្នោតនៅទីនោះ ។
    a. បុគ្គលិក ROV ៖ ប្រសិនបើវាមានទីតាំងទំនេរធំល្មមគ្រប់គ្រាន់ ។
5. អ្នកចូលរួម ៖ អ្នកដឹងហើយថាហាង Spirit ទាំងនោះតែងបង្កើតឡើងនៅរដូវកាលបុណ្យ ហាឡូវីន ខ្ញុំចង់ដឹងថាប្រសិនតើកន្លែងទាំងនោះអាចប្រើប្រាស់បាន ឬក៏អត់ ?
    a. បុគ្គលិក ROV ៖ ដាក់បានលុះត្រាតែវាអាចប្រើប្រាស់បាននៅខែ មិនា ។
6. អ្នកចូលរួម ៖ ចុះចំណែកផ្សារទំនើប Valco វិញនោះ ? ខ្ញុំប្រាកដថាវាទំនេរក្នុងពេលឥលូវនេះ ។ មានចំណតរថយន្តច្រើន និងទីធ្លាធំទូលាយ ។
7. អ្នកចូលរួម ៖ ខ្ញុំមានបទពិសោធន៍ថ្មីថ្មោងជាមួយនឹងមណ្ឌល Vista, តែយើងខ្ញុំកំពុងធ្វើការទៅលើទីតាំង San Jose ដែលជាជម្រើសមួយក្នុងជម្រើសផ្សេងទៀត (101 និងវិថី Bascom Ave) ។
    a. បុគ្គលិក ROV ៖ នោះពិតជាប្រសើរណាស់ !

8. អ្នកចូលរួម ៖ តើអ្នកអាចប្រើស្ថានីយ៍ប៉ូលីសថ្មីដែលស្ថិតនៅ San Jose ភាគខាងត្បូង ដែលមិនទាន់បានប្រើប្រាស់នៅឡើយនោះបានទេ ?
    a. បុគ្គលិក ROV ៖ យើងប្រាកដជាធ្វើការពិចារណា; យើងនឹងពិនិត្យជាមួយមណ្ឌលសហគមន៍ ។
    b. បុគ្គលិក ROV ៖ របៀបដែលទីក្រុងធ្វើប្រតិបត្តិការ បើពាក់ព័ន្ធនឹងមណ្ឌលសហគមន៍ មានស្ថាប័នមួយដែលគ្រប់គ្រងមណ្ឌលសហគមន៍ ។ យើងបានធ្វើការទាក់ទងទៅស្ថាប័ននោះក៏ដូចជាការិយាល័យអ្នកគ្រប់គ្រងក្រុង ។ ហើយពួកគេស្ថិតក្នុងទីតាំងឆ្ងាយ បើនិយាយពីនាយកដ្ឋានប៉ូលីសនៅ San Jose, ដូចនេះយើងខ្ញុំដាក់សំណើរមុនគេ ។
9. អ្នកចូលរួម ៖ Costco នឹងជាកន្លែងមួយល្អសម្រាប់មណ្ឌលចល័ត ។
    a. បុគ្គលិក ROV ៖ យើងកំពុងស្ថិតក្នុងការពិចារណា ថាតើយើងខ្ញុំនឹងត្រូវដំណើរការមណ្ឌលចល័ត ឬក៏អត់នោះ ។
10. អ្នកចូលរួម ៖ នៅមាន Western Digital ទៀត (តំបន់ Great Oaks) ។ មាន Orchard Supply (Cottle/East Capitol) ។
11. តើអ្នកមានធ្លាប់គិត ក្នុងការដាក់ប្រអប់បោះឆ្នោតនៅការិយាល័យប្រៃសណីយ៍ នៅតាមប្រអប់សំបុត្រឬទេ ?
    a. បុគ្គលិក ROV ៖ តើយើងដែលពិចារណាអំពីការមើលទៅលើទីតាំង USPS នៅការិយាល័យប្រៃសណីយ៍សម្រាប់ប្រអប់បោះឆ្នោតរបស់យើងឬអត់ ?
    b. បុគ្គលិក ROV ៖ ខ្ញុំមិនគិតថាពួកគេចង់ធ្វើបែបនេះទេ ព្រោះពួកគេនឹងទទួលបានកម្រៃនៅពេលដែលអ្នកបោះឆ្នោតទម្លាក់សន្លឹកឆ្នោតតាមរយៈការិយាល័យរបស់ពួកគេ ។ អ្នកបោះឆ្នោតក៏ប្រហែលជានឹងភាន់ច្រឡំផងដែរ ។
    c. អ្នកចូលរួម ៖ អ្នកអាចនឹងទទួលបានសំបុត្រជាញឹកញាប់ក្នុងប្រអប់ដាក់សន្លឹកឆ្នោតរបស់អ្នក ។
    d. អ្នកចូលរួម៖ ក្រែងពួកវាមានពណ៌ខុសគ្នាពីប្រអប់សំបុត្រស្តង់ដាដែលមានពណ៌ខៀវមែនទេ ?
    e. បុគ្គលិក ROV ៖ យើងអាចពិចារណាលើចំណុចនោះបាន ។
12. អ្នកចូលរួម ៖ ចុះនៅរោងភាពយន្តវិញយ៉ាងម៉េចដែរ?
    a. បុគ្គលិក ROV ៖ អាចទៅរួច ។
13. អ្នកចូលរួម ៖ យើងខ្ញុំអាចផ្តល់កន្លែងរបស់យើង (SVILC) ជាមណ្ឌលបោះឆ្នោត ឬជាទីតាំងនៃប្រអប់ដាក់សន្លឹកឆ្នោត ។
    a. បុគ្គលិក ROV ៖ យើងប្រាកដជាធ្វើការពិនិត្យ ហើយមើលថាតើយើងអាចដាក់ប្រអប់ដាក់សន្លឹកឆ្នោតនៅទីនេះបានឬទេ ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលការចូលរួមពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្រ្តីបោះឆ្នោតដែលនិយាយពីរភាសា ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖ (មិនមាន)*

## VI. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត

ROV នឹងប្រមូលការចូលរួមពីសាធារជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*ការធ្វើបទបង្ហាញស្តីពី RAVBM ដោយ ROV និងដោយសមាជិក VAAC*

មតិចូលរួម/សំណួរពីសាធារណជន ៖

1. អ្នកចូលរួម ៖ យើងខ្ញុំកំពុងប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីដាក់វានៅទីតាំងនោះ ។ (ដោយសំដៅទៅលើ LAAC/VAAC)
2. អ្នកចូលរួម ៖ តើយើងនឹងទទួលបានខ្សែណាមួយលើប្រអប់បោះឆ្នោតឬទេ ?
    a. បុគ្គលិក ROV ៖ តើនេះជាតម្រូវការមួយក្នុងចំណោមតម្រូវការផ្សេងទៀតឬ ?
    b. បុគ្គលិក ROV ៖ ទេ, វាជាតម្រូវការផ្នែកកម្ពស់ច្រើនជាង ។ ជំនួសឲ្យការទាញ វានឹងជាការរុញទៅវិញ ។ ដោយគ្មានសំពាធខ្លាំង ឬអ្វីមួយឡើយ ។
3. អ្នកចូលរួម ៖ ដូចនេះ ខ្ញុំយល់ថាអ្នកគួរតែព្រីនវាចេញ ប៉ុន្តែក្រោយមកយ៉ាងម៉េចទៀត ? (ដោយសំទៅលើការណែនាំសម្រាប់ RAVBM – *ទាញយកឯកសារវិលត្រលប់*)
    a. អ្នកចូលរួម ៖ ការទាញយកនិយាយថា ដាក់វាលើកុំព្យូទ័ររបស់អ្នក ប៉ុន្តែមិនមែនព្រីនវាចេញទេ ។ នោះជាអ្វីដែលគាត់ចង់និយាយ ។
    b. អ្នកចូលរួម ៖ ចុចត្រង់នេះដើម្បីព្រីនសន្លឹកឆ្នោតរបស់អ្នកចេញ ហើយបញ្ជូនវាចូល, ចូរបញ្ជាក់ឲ្យបានច្បាស់ ។
    c. បុគ្គលិក ROV ៖ នោះជាមតិកែលម្អដ៏ប្រសើរសម្រាប់ LAAC/VAAC ។
4. អ្នកចូលរួម ៖ តើគេហទំព័ររបស់អ្នកនឹងមាន EAP បកប្រែជាភាសាផ្សេងឬទេ ?
    a. បុគ្គលិក ROV ៖ បាទ/ចាស EAP នឹងមានជាភាសាដែលបានតម្រូវទាំងអស់ ។
5. អ្នកចូលរួម ៖ ខ្ញុំសូមស្នើឲ្យអ្នកទាក់ទងទៅកាន់មណ្ឌលមនុស្សចាស់ជរា និងមន្ទីរឯករាជ្យ ។ ម្តាយរបស់ខ្ញុំរស់ដោយត្រូវការជំនួយក្នុងការមើលថែទាំ ។ គាត់អាយុជិត 95 ឆ្នាំហើយ ។ គាត់មានសមត្ថភាពក្នុងការបោះឆ្នោត តែគាត់មិនអាចកាន់ខ្មៅដៃបានទេ ។ គាត់មិនអាចអានបាន

ទេ ដោយសារគាត់ងងឹតភ្នែក ។ ដូចនេះមានរឿងជាច្រើនដែលកើតឡើងនៅទីនោះ ហើយខ្ញុំបានឲ្យគាត់បញ្ជូនសន្លឹកឆ្នោតរបស់គាត់ទៅកន្លែងរបស់គាត់ ហើយវាបានបាត់ភ្លាមៗ ដូចនេះមានបញ្ហាខ្លះៗដែលកំពុងកើតឡើងនៅកន្លែងទាំងនោះ ហើយវាជាកន្លែងដែលមនុស្សប្រហែល 100 នាក់នៅទីនោះ ។ ប៉ុន្តែមនុស្សជាច្រើនទាំងនេះមិនបានដឹងថាពួកគេអាចចុះឈ្មោះបោះឆ្នោតបានទេ មិនចាំបាច់និយាយដល់ការបោះឆ្នោត ហើយនឹងការរាប់សន្លឹកឆ្នោតរបស់ពួកគេនោះឡើយ ។ ហើយម្តាយរបស់ខ្ញុំមានការបារម្ភខ្លាំងអំពីរឿងនេះ ហើយក៏បារម្ភផងដែរថាវាមិនមែនជាដំណើរការដែលងាយស្រួលសម្រាប់គាត់ទេ ដូចកាលពីមុនពេលដែលគាត់គ្រាន់តែយកវាមក ហើយបំពេញ រួចផ្ញើវាជាការស្រេច ។ ពួកគេមិនអាចធ្វើបែបនេះបានទេ ហើយពួកគេទាំងអស់គ្នាក៏មិនមែនមនុស្សចាស់ទាំងអស់ដែរ ។ មានមនុស្សក្មេងៗជាច្រើនដែលនៅទីនោះ ហើយមិនមានមនុស្សជាច្រើនដែលមានគ្រួសារហើយបានចូលរួមនោះទេ ។ ហើយដូចនេះមន្ទីរមើលថែមិនអាចជួយពួកគាត់បានទេ បើទោះជាមានមណ្ឌលបោះឆ្នោតនៅក្នុងតំបន់ទាំងនោះក៏ដោយ ។ មនុស្សទាំងនេះត្រូវការការទាក់ទង ពួកគេត្រូវការរាប់បញ្ចូលព្រោះ ប្រសិនបើពួកគេចង់ទម្លាក់សន្លឹកឆ្នោតរបស់ពួកគេ ពួកគេត្រូវតែជួលរថយន្ត ហើយវានឹងមានតម្លៃថ្លៃ ។ ហើយបើគ្រាន់តែដើម្បីការបោះឆ្នោតទេនោះ ពួកគាត់នឹងមិនធ្វើវាឡើយ ។ ខ្ញុំសូមធ្វើការធានាចំពោះអ្នក ។ ពួកគាត់ត្រូវការលទ្ធភាពដែលអាចចេញចូលទៅបោះឆ្នោតនៅកន្លែងទាំងនេះបន្ថែមទៀត ហើយនេះគឺបានបញ្ចប់ដោយវិទ្យាល័យ Prospect ។ គាត់នៅ Westgate Villa ។ វានៅវិថី Main Ave ។ ហើយពួកគេរស់នៅដោយឯករាជ្យនៅទីនោះ ។ ហើយអគារមនុស្សចាស់ជរាគឺនៅជិតបង្កើយ ។ អ្នកប្រហែលជាអាចធ្វើបាននៅ Villa Fontana ផងដែរ ។

a. បុគ្គលិក ROV ៖ យើងប្រាកដជានឹងធ្វើការពិនិត្យទីតាំងនោះ ។ យើងទទួលយកគ្រប់មតិស្តីពីទីតាំង ហើយបន្ទាប់មកយើងត្រូវពិនិត្យថាតើវាមានកន្លែងចតរថយន្តដោយឥតគិតថ្លៃឬអត់ ហើយនឹងរឿងផ្សេងៗទៀតដូចគ្នានេះដែរ ។
b. អ្នកចូលរួម ៖ មិនមានកន្លែងចតរថយន្តច្រើននៅទីនោះទេ ។ វានឹងជាបញ្ហាមិនខាន ។
c. បុគ្គលិក ROV ៖ យើងនឹងនៅតែធ្វើការពិនិត្យលើវា ។
d. បុគ្គលិក ROV ៖ ដោយមើលទៅលើទស្សនៈនៃការផ្សព្វផ្សាយ ការលើកបញ្ហានេះមកនិយាយគឺជារឿងល្អ ។ ហើយគំនិតស្តីពីហិបទម្លាក់សន្លឹកឆ្នោតអាចដោះស្រាយតម្រូវការនៃការផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ ។

6. អ្នកចូលរួម ៖ តើអ្នកប្រើប្រាស់ទិន្នន័យជំរឿនតាមរបៀបណា ដើម្បីដឹងពីកន្លែងរស់នៅរបស់ជនពិការនោះ ?
   a. បុគ្គលិក ROV ៖ ព័ត៌មាននេះត្រូវបានប្រមូលលើជំរឿន ហើយជាពិសេសគឺការធ្វើស្ថិតិសហគមន៍ប្រជាជនអាមេរិក ។
   b. អ្នកចូលរួម ៖ ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែបានធ្វើស្ថិតិនោះឡើយ ។

c. បុគ្គលិក ROV ៖ នោះជាកត្តាប្រឈម ។ ប៉ុន្តែនេះជាផ្នែកមួយនៃមូលហេតុដែលយើងនៅទីនេះ ។ ប្រសិនបើអ្នកដឹងពីកន្លែងណាមួយជាក់លាក់ដែលជាការប្រមូលផ្តុំនៃមណ្ឌលរស់នៅឯករាជ្យ នេះវាជាអ្វីដែលយើងចង់ដឹង ។

7. អ្នកចូលរួម ៖ តើអ្នកទទួលបានការផ្ញើសំបុត្រដោយឥតគិតថ្លៃជាមួយ RAVBM នោះឬទេ ?
    a. បុគ្គលិក ROV ៖ មានច្បាប់អចិន្ត្រៃយ៍ជាមួយការិយាល័យប្រៃសណីយ៍ដែលចែងថា ប្រសិនបើអ្នក បិទតែម ឬតិចជាងចំនួនដែលតម្រូវដោយប្រៃសណីយ៍ នោះ ROV នឹងធ្វើការទូទាត់តម្លៃជូន ។
8. អ្នកចូលរួម ៖ រឿងដែលពិសេសបំផុតគឺប្រើប្រាស់ស្រោមសំបុត្រ VBM របស់អ្នក ។
    a. អ្នកចូលរួម៖ ប៉ុន្តែតើពួកគេនឹងមិនទទួលបានវាទេឬ (ស្រោមសំបុត្រ VBM) ប្រសិនបើពួកគេធ្វើរឿងនេះ ?
    b. បុគ្គលិក ROV ៖ អ្នករាល់គ្នាទទួលបានសន្លឹកឆ្នោត VBM ។
    c. អ្នកចូលរួម ៖ អូ ពួកគេទទួលបានទាំងពីរ ? បន្ទាប់មកនោះមិនមែនជាបញ្ហាទៀតទេ។ ល្អខ្លាំងណាស់ ។
9. អ្នកចូលរួម ៖ រាប់បញ្ចូលស្លាកសញ្ញា "សន្លឹកឆ្នោត" ក្នុងកញ្ចប់ RAVBM ។
10. អ្នកចូលរួម ៖ ប្រសិនបើមនុស្សទូទៅមិនត្រូវបានជម្រាបជូនថា ពួកគេគួរតែរក្សាសន្លឹកឆ្នោតរបស់ពួកគេនៅក្នុងស្រោមសំបុត្រ VBM ហើយប្រសិនបើពួកគេមិនអាចឃើញសញ្ញាលើសន្លឹកឆ្នោតដែលបានព្រីនចេញទេ នោះវានឹងជាបញ្ហាមិនខាន ។ ដូចនេះអ្នកគួរតែធ្វើវាឲ្យបានច្បាស់លាស់ ។
11. អ្នកចូលរួម ៖ បង្កើតសារផ្សព្វផ្សាយជាសាធារណៈ "រក្សាស្រោមសំបុត្រ បោះឆ្នោតតាមប្រៃសណីយ៍របស់អ្នក"
    a. បុគ្គលិក ROV ៖ យើងពិតជាអាចបន្ថែមចំណុចនេះលើគេហទំព័ររបស់យើងខ្ញុំបាន ។
12. អ្នកចូលរួម ៖ ដាក់រន្ធនៅចុងទាំងសងខាងនៃសន្លឹកឆ្នោត VBM ដែលជាកន្លែងអ្នកត្រូវចុះហត្ថលេខា ដូចនេះមនុស្សច្រើនផ្សេងទៀតនឹងបានដឹងពីកន្លែងដែលត្រូវចុះហត្ថលេខា ព្រោះនេះជាសារៈប្រយោជន៍មួយ ។
13. អ្នកចូលរួម ៖ ចុះចំណែកវីដេអូនៃ "វត្ថុដែលមិនត្រូវបោះបង់ចោល ?"
    a. បុគ្គលិក ROV ៖ ចូលចិត្តវីដេអូស្តីអំពី RAVBM របស់យើងខ្ញុំ ហើយរក្សាស្រោមសំបុត្ររបស់អ្នក ។ នេះជាគំនិតល្អ ។
14. អ្នកចូលរួម ៖ តើតំណភ្ជាប់គេហទំព័រ RAVBM មានសុវត្ថិភាពឬទេ ?
    a. បុគ្គលិក ROV ៖ បាទ/ចាស វាមានសុវត្ថិភាព ។
15. អ្នកចូលរួម ៖ តើអ្នកនិយាយដូចម្តេចចំពោះកូដ RAVBM QR ?
    a. បុគ្គលិក ROV ៖ វាជាការថតចម្លងនូវអ្វីដែលអ្នកបានធ្វើការបោះឆ្នោត ដូចនេះប្រសិនយើងត្រូវការព្រីនលើឧបករណ៍តាមតម្រូវការ នោះយើងចាំបាច់ត្រូវថតចម្លងសន្លឹកឆ្នោតនេះបានដោយសារវាស្ថិតក្នុងទម្រង់សន្លឹកក្រដាស់ ។ នៅពេលដែលយើងត្រលប់ចូលក្នុង

ការិយាល័យរបស់យើងវិញ យើងមិនអាចផ្តល់សេចក្តីថតចម្លងនេះទៅក្នុងម៉ាស៊ីនអានសន្លឹកឆ្នោតបានទេ ។ ប៉ុន្តែ ប្រសិនបើយើងអាចស្កេនកូដ QR បាន វានឹងព្រីនចេញនូវអ្វីដែលដូចគ្នានៅលើសន្លឹកឆ្នោតដែលបានបោះឆ្នោតរបស់អ្នកផងដែរ ។

b. អ្នកចូលរួម ៖ តើមនុស្សគ្រប់គ្នាដែលមានម៉ាស៊ីនអានកូដ QR អាចអានវាបានមែនទេ ?
c. បុគ្គលិក ROV ៖ QR គឺធ្វើឡើងដើម្បីអានដោយម្ចាស់ដែលបង្កើតសន្លឹកឆ្នោតតែប៉ុណ្ណោះ ។

16. អ្នកចូលរួម ៖ អ្នកនិយាយថា "លទ្ធភាពអាចចេញចូលបាន" តើមានន័យថាយ៉ាងម៉េច ?
    a. បុគ្គលិក ROV ៖ អ្នកបោះឆ្នោតដែលជាទាហាន ឬ អ្នកបោះឆ្នោតនៅខាងក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព ។
    b. អ្នកចូលរួម ៖ តើពួកគេអាចប្រើ JAWS លើគេហទំព័រតាមរយៈតំណរភ្ជាប់ RAVBM បានឬទេ ?
    c. បុគ្គលិក ROV ៖ យើងដាក់បញ្ចូលគ្នាទាំងអស់នៃសេចក្តីណែនាំស្តីពីព័ត៌មានអ្នកបោះឆ្នោតខោនធីរបស់យើងដែលមានលើគេហទំព័រ ដូចនេះអ្នកអាចប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួននៅផ្ទះ ហើយវានឹងអានព័ត៌មានជូនអ្នក ។ ហើយប្រសិនបើអ្នករកឃើញបញ្ហាណាមួយជាមួយគេហទំព័ររបស់យើង សូមផ្តល់ព័ត៌មានមកយើង ។ វាអាចជាកំហុសក្នុងការដំឡើង ។ យើងព្យាយាមធ្វើឲ្យរឿងគ្រប់យ៉ាងឲ្យអាចទាញយកមកប្រើប្រាស់បាន ។

17. អ្នកចូលរួម ៖ តើដំណើរការវាដោយប្រើសម្លេង ឬអ្នកត្រូវតែប្រើប្រាស់ម៉ៅស៍ ?
    (សំដៅលើ RAVBM) ឧទាហរណ៍ថា ខ្ញុំបានឲ្យកុំព្យូទ័រទៅម្តាយខ្ញុំ ហើយគាត់មិនដឹងពីការប្រើប្រាស់កុំព្យូទ័រនោះឡើយ ។ គាត់អាយុ 95 ឆ្នាំ ហើយមានជំងឺក្រិនសរីរាង្គ ។ គាត់ងងឹតភ្នែក ហើយថ្លង់ ប៉ុន្តែនៅមានស្មារតីល្អ ។ ដូចនេះ ប្រសិនបើគាត់អាចដាក់កាសត្រចៀកនោះគាត់អាចប្រើប្រាស់វាដើម្បីឆ្លើយតបតាមពាក្យសម្តី ។ តើមានដែលពិចារណាក្នុងការប្រើប្រាស់ដំណើរការដោយប្រើសម្លេងឬទេ ?
    a. អ្នកចូលរួម៖ ខ្ញុំដឹងថាពួកគេមានវា ។
    b. បុគ្គលិក ROV ៖ វាមិនមែនស្ថិតនៅលើប្រព័ន្ធរបស់យើងខ្ញុំទេ វាស្ថិតលើប្រព័ន្ធដែលបុគ្គលនោះមានតែប៉ុណ្ណោះ ។
    c. អ្នកចូលរួម ៖ អ្នកបាត់បង់ក្រុមមនុស្សជាច្រើនដែលត្រូវការដំណើរការដោយប្រើសម្លេង ។
    d. អ្នកចូលរួម ៖ មានបច្ចេកវិទ្យាដូចនេះមែន តែប្រហែលជាយើងត្រូវពិចារណាលើការពិនិត្យលើកុំព្យូទ័រយួរដៃដែលមានសមត្ថភាពបែបនេះ ដែលតម្រូវឲ្យមនុស្សណាម្នាក់ទៅតម្លើងវានៅមុខមនុស្សគ្រប់គ្នាដែលត្រូវប្រើប្រាស់វា បន្ទាប់មកត្រូវដើរចេញ ។
    e. អ្នកចូលរួម៖ តើអ្នកមានកម្មវិធីពិសេសណាដែលអាចយល់ ឬក៏កម្មវិធីនេះអាចមានសមត្ថភាពដូចនេះបានទេ ? កម្មវិធីដូចនោះគឺថ្លៃ ។
    f. អ្នកចូលរួម៖ ប្រហែល ROV អាចប្រើប្រាស់កុំព្យូទ័រយួរដៃ ពីរ ឬ បីគ្រឿងដែលដំឡើងដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗគ្នា ។
    g. អ្នកចូលរួម ៖ បន្ទាប់មកយើងអាចធ្វើការពិនិត្យវា ហើយធ្វើឲ្យវាដូចដើមវិញ ។

h. បុគ្គលិក ROV ៖ យើងអាចពិភាក្សាពីវាបន្ថែម ។ យើងអាចពិនិត្យលើរឿងនេះបាន ។ យើងកំពុងព្យាយាមផ្តល់ជូននូវកម្មវិធី ហើយខ្ញុំសូមទោសដែលវាប្រហែលជាមិនអាចគ្របដណ្តប់បានលើពិការភាពជាច្រើនផ្សេងៗគ្នារបស់មនុស្សម្នាក់ៗបាន មិនថាពួកគេប្រើប្រាស់កុំព្យូទ័រប្រភេទណាក៏ដោយ ។

i. អ្នកចូលរួម ៖ ប៉ុន្តែជារឿយៗយើងមិនដែលគិតទៅដល់មនុស្សដែលស្ថិតក្នុងស្ថានភាពទាំងនេះទេ ។

18. អ្នកចូលរួម ៖ តើមានឧបករណ៍ជំនួយផ្សេងទៀតទៅលើប្រព័ន្ធនៃការបោះឆ្នោតឬទេ (ម៉ាស៊ីនប្រើសញ្ញា និងដង្ហើម) ដោយគិតទៅលើសម្លេង ?

a. បុគ្គលិក ROV ៖ មានឧបករណ៍គូសសញ្ញាសន្លឹកឆ្នោត ដែលអនុញ្ញាតឲ្យអ្នកធ្វើបានមុខងារច្រើនជាមួយឧបករណ៍នេះ ។ មានឧបករណ៍ដូចជាម៉ាស៊ីនប្រើសញ្ញា និងដង្ហើម, ប៊ូតុងធំ, ប៊ូតុងទិសដៅ ប៉ុន្តែខ្ញុំមិនដឹងថាមានម៉ាស៊ីនដំណើរការដោយសម្លេងនោះទេ ។

b. អ្នកចូលរួម ៖ ខ្ញុំដឹងថាគេមានម៉ាស៊ីនប្រភេទនេះ តែវាមិនមាននៅរដ្ឋ California ទេ ។

c. អ្នកចូលរួម ៖ តើមនុស្សដែលងងឹត និងថ្លង់ត្រូវធ្វើយ៉ាងម៉េចទៅ ? ប្រសិនបើអ្នកងងឹតផងហើយថ្លង់ផង ។

d. បុគ្គលិក ROV ៖ សម្រាប់មនុស្សដែលពិការភ្នែក យើងនឹងប្រើប្រាស់ឧបករណ៍អានលើអេក្រង់ ។

e. អ្នកចូលរួម ៖ តើពួកគេមានសន្លឹកឆ្នោតប្រើអក្សរមនុស្សពិការភ្នែកឬទេ ?

f. អ្នកចូលរួម ៖ ប្រសិនបើអ្នកមានក្តារចុចអក្សរសម្រាប់មនុស្សពិការ នោះអ្នកអាចប្រើបាន ។ ពួកគាត់អាចអានខ្សែបន្ទាត់អក្សរ ហើយនៅពេលចុះទៅតាមបន្ទាត់អក្សរ វានឹងចាប់ផ្តើមសារថ្មីនៃក្តារចុចសម្រាប់មនុស្សពិការភ្នែក ដូចនេះពួកគេអាចអានបែបនេះបាន ។

g. អ្នកចូលរួម ៖ ចុះបើវិញ្ញាណទាំងបីពិការទាំងអស់នោះ ?

h. អ្នកចូលរួម ៖ យើងនឹងធ្វើការពិនិត្យករណីនេះ ។ វាជារឿងដែលល្អដែលលើកចំណុចនេះឡើង ។

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលការចូលរួមពីសាធារណជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*មតិចូលរួម/សំណួរពីសាធារណជន៖*

1. អ្នកចូលរួម ៖ បន្ថែមពីលើការបោះឆ្នោតជាក់ស្តែង យើងក៏ត្រូវចុះឈ្មោះប្រជាជនផងដែរ ។ ការលើកឡើងពីទីកន្លែងដូចជា ផ្សារទំនើប ឬកន្លែងដែលមានការប្រមូលផ្តុំមនុស្ស គឺជាកន្លែងដែលប្រសើរដើម្បីផ្សព្វផ្សាយការចុះឈ្មោះអ្នកបោះឆ្នោត ។

a. បុគ្គលិក ROV ៖ ត្រូវហើយ យើងខ្ញុំឯកភាព ។ យើងជាធម្មតាធ្វើកម្មវិធីផ្សព្វផ្សាយ ប្រហែលជា 250 ព្រឹត្តិការណ៍ ។ ខ្ញុំមានតែបុគ្គលិកចំនួនបីនាក់នៅក្នុងក្រុមផ្សព្វផ្សាយប៉ុណ្ណោះ តែពួកគេធ្វើព្រឹត្តការណ៍ចំនួន 250 នៅពិធីបុណ្យផ្សេងៗ ។ ប្រសិនបើមាននរណាម្នាក់ស្នើយើង "សូមមកចូលរួមក្នុងកម្មវិធីរបស់យើង" យើងនឹងចូលរួម ។ ហើយយើងជាក់ស្តែងកំពុងតែធ្វើបទបង្ហាញ VCA កាន់តែច្រើនឡើងៗក្នុងពេលឥលូវនេះ ។ ហើយធ្វើការផ្សព្វផ្សាយថា អ្នកអាចចុះឈ្មោះអនឡាញបាន ។

2. អ្នកចូលរួម ៖ តើអ្នកធ្វើលើបណ្តាញផ្សព្វផ្សាយផ្សេងទៀតឬទេ ក្រៅពីបណ្តាញបោះពុម្ពផ្សព្វផ្សាយ ? ទូរទស្សន៍ ?

a. បុគ្គលិក ROV ៖ ប្រាកដណាស់ យើងកំពុងតែធ្វើនៅលើបណ្តាញផ្សព្វផ្សាយសង្គម បណ្តាញបោះពុម្ពផ្សព្វផ្សាយ និងលើវិទ្យុ ។ យើងខ្ញុំកំពុងតែព្យាយាមដើម្បីទទួលបាន PSA, ដោយរកមើលកាសែត និងទីកន្លែងដែលយើងអាចដាក់បញ្ចូលព័ត៌មានបាន ។

3. អ្នកចូលរួម ៖ អ្នកអាចដាក់កាតប៉ូស្តាល់ក្នុងរថយន្តដឹកជនពិការ ឬមនុស្សចាស់ជរា ។ អ្នកត្រូវតែដំឡើងវាជាមួយអ្នកបើកបរ ។

a. បុគ្គលិក ROV ៖ ត្រូវហើយ នេះជាគំនិតដ៏ល្អមួយ ។

4. អ្នកចូលរួម ៖ តើអ្នកអាចបន្ថែមអក្សរស្នាបនៅពីក្រោមកាតប៉ូស្តាល់បានទេ ?

a. បុគ្គលិក ROV ៖ តើមានការផ្តល់សេវាបែបនេះ ដែលយើងអាចទាញយកប្រយោជន៍បានឬទេ ?

b. អ្នកចូលរួម ៖ ចាត់ឲ្យក្រុមកាយរិទ្ធក្មេងប្រុស/កាយរិទ្ធក្មេងស្រី ដើរចែកខិត្តប័ណ្ណនៅតំបន់ដែលមានអ្នករស់នៅត្រូវការជំនួយថៃទាំនៅក្នុងម៉ោងធ្វើការ ។

មន្ត្រីអគ្រានុក្កូលដ្ឋានអ្នកបោះឆ្នោតខោនធី Santa Clara

# ផែនការរដ្ឋបាលបោះឆ្នោត (EAP)

## របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់អ្នកនិយាយភាសាជប៉ុន

សាខាបណ្ណាល័យ Joyce Ellington
491 E. Empire St., San Jose, CA 95112
បន្ទប់សហគមន៍
ថ្ងៃព្រហស្បត្តិ៍ទី 11 ខែកក្កដា ឆ្នាំ 2019
ម៉ោង 4:30 ល្ងាច ដល់ម៉ោង 6:00 ល្ងាច

**វត្តមានអ្នកចូលរួម ៖**
សមាជិកម្នាក់មកពីសាធារណៈនៃសហគមន៍ជនជាតិជប៉ុន

**វត្តមានបុគ្គលិក ៖**
Shannon Bushey, Vanessa Hamm, Andrea Solorio, Michael Borja, Magdalena Sta Maria, Priscilla Favela, Janora Davis, Patricia Lopez, Allen Ocampo, Linh Nguyen, Michelle Tran, Adrian Garcia, Paulo Chang, Alfred Gonzales, Eric Kurhi, Rachel Jung, Liz Oviedo, Chipo Mulenga, George Hiu, Mike Davis, Martin Ayala, Smita Shah, Lorenzo Castaneda, Diane Castaneda, Ruth Luo, Chenxi Ye

**ចំណុចសកម្មភាព ៖**

- អ្នកចូលរួមត្រូវផ្ញើរតំណភ្ជាប់ទៅកាន់ ROV ទាក់ទងនឹងចំណុចដែលបានពិភាក្សារួច
    - នឹងធ្វើការទាក់ទងទៅគាត់សម្រាប់វិទ្យុ Sakura Radio
    - ដើម្បីបញ្ជូនបញ្ជីនៃក្រុមសហគមន៍ជនជាតិជប៉ុននៅក្នុងបណ្តាញសង្គមដូចជា Facebook
    - ដើម្បីទាក់ទងគ្រូភាសាជប៉ុនសម្រាប់លទ្ធភាពក្នុងការបណ្តុះបណ្តាលការអប់រំអ្នកបោះឆ្នោត (កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលរបស់ VEOC)
    - ផ្តល់ជូនបញ្ជីសាលាភាសាជប៉ុនសម្រាប់សិក្ខាសាលាផ្នែកភាសា
    - ដើម្បីបញ្ជូនបន្តមតិត្រឡប់ទៅកាន់បណ្តាញរបស់គាត់

I. **សេចក្តីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

II. **ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់ពួកគេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃ ដើម្បីធ្វើការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

1. បុគ្គលិក ROV បានផ្តល់ទិដ្ឋភាពសង្ខេបទូទៅនៃសេចក្តីលម្អិតរបស់ VCA ដោយចាប់ផ្តើមពីពីភាសាដែល ROV នឹងធ្វើការទៅលើបញ្ហានេះ ព្រមទាំងការផ្លាស់ប្តូរពីកន្លែងបោះឆ្នោតទៅមណ្ឌលបោះឆ្នោត ។
2. បុគ្គលិក ROV បានជជែកអំពីភ័ស្តុភារនៃមណ្ឌលបោះឆ្នោត និងថាតើយើងត្រូវផ្តល់ជូនភាសានៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗដោយរបៀបណា ។
3. បុគ្គលិក ROV បានផ្តល់ទិដ្ឋភាពសង្ខេបទូទៅអំពីម៉ូដែលទីកន្លែងបោះឆ្នោតទៅម៉ូដែល VCA ។

III. **គោលដៅនៃផែនការរដ្ឋបាលបោះឆ្នោត**

ផែនការរដ្ឋបាលបោះឆ្នោតបង្ហាញពីរបៀបដែលមន្ត្រីអគ្រានុក្កូលដ្ឋានអ្នកបោះឆ្នោត (ROV) នឹងអនុវត្តន៍ការផ្លាស់ប្តូរទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងការចូលរួមទទួលបានពីសហគមន៍ ។

*ការពិភាក្សា*

1. បុគ្គលិក ROV ៖ យើងកំពុងស្វែងរកមតិយោបល់ត្រឡប់សម្រាប់ EAP ជាពិសេសសម្រាប់សហគមន៍ជនជាតិជប៉ុន ប៉ុន្តែយើងបើកចំហរចំពោះមតិត្រឡប់ណាមួយសំដៅសម្រាប់ការអភិវឌ្ឍន៍នៃសេចក្តីព្រាង EAP ៖ ដែលយើងគួរតែធ្វើការផ្សព្វផ្សាយ ទីតាំងមណ្ឌលបោះឆ្នោត ហើយត្រូវដាក់ហិបទម្លាក់សន្លឹកឆ្នោតក្នុងសហគមន៍នៅកន្លែងណា ។

IV. **ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត**

ROV កំពុងស្វែងរកការចូលរួមជាសាធារណៈដើម្បីជួយដល់ខោនធី ក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់មណ្ឌលបោះឆ្នោត និងកន្លែងដាក់ហិបទម្លាក់សន្លឹកឆ្នោត។ មណ្ឌលបោះឆ្នោតចាំបាច់មានលទ្ធភាពអាចចេញចូលបាន ហើយមានទីធ្លាគ្រប់គ្រាន់ដើម្បីផ្តល់សេវាកម្មបានត្រឹមត្រូវទៅដល់អ្នកបោះឆ្នោតខោនធី Santa Clara ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖*

1. បុគ្គលិក ROV ៖ តើអ្នកមានការណែនាំណាមួយស្តីពីទីតាំងសម្រាប់ដាក់ហិបទម្លាក់សន្លឹកឆ្នោតឬទេ ?
    a. អ្នកចូលរួម ៖
        i. ទីធ្លាសាលា Stanford គឺពិតជាល្អខ្លាំងណាស់ ។ មានផ្សារកសិករដែលជាទីពេញនិយមមួយកន្លែងនៅ Palo Alto ហើយវាជាផ្សារធំជាងគេនៅក្នុងរដ្ឋ California ។ វាជារឿងដែលប្រសើរប្រសិនបើមានស្តង់នៅទីនោះ ហើយនៅកន្លែងណាក៏បានតាមវិថី California Ave. ឬក៏នៅទីប្រជុំជន Palo Alto ។ នេះនឹងអាចក្តោបបានប្រជាសាស្ត្រយ៉ាងច្រើន ។ Palo Alto និង Mountain View មានវិហារព្រះពុទ្ធសាសនា នេះអាចជាទីតាំងល្អបំផុតដើម្បីធ្វើការផ្សព្វផ្សាយទៅដល់សហគមន៍ជនជាតិជប៉ុន ។

V. **លទ្ធភាពទទួលបានជំនួយផ្នែកភាសា**

ROV នឹងប្រមូលការចូលរួមពីសាធារណៈជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖*

1. បុគ្គលិក ROV ៖ តើអ្នកគិតថាអ្វីដែលមានសារៈប្រយោជន៍សម្រាប់សាមគ្គីភាព ?
    a. អ្នកចូលរួម ៖ រឿងដែលពិបាកបំផុតគឺសម្រាប់ជនជាតិជប៉ុនដែលនិយាយបានតែភាសាជប៉ុន និងជនជាតិជប៉ុនកាត់អាមេរិកដែលចូលចិត្តប្រើប្រាស់តែភាសាអង់គ្លេស ។

VI. **លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត**

ROV នឹងប្រមូលការចូលរួមពីសាធារណៈជនដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖ (មិនមាន)*

VII. **ឱកាសផ្សព្វផ្សាយ**

ROV នឹងប្រមូលការចូលរួមពីសាធារណៈជនដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*សំណួរ/ការចូលរួមពីសាធារណៈជន ៖*

1. បុគ្គលិក ROV ៖ យើងខ្ញុំកំពុងព្យាយាមប្រមូលព័ត៌មានស្តីពីវិធីដែលយើងមិនទាន់បានដឹងនៅឡើយ ដោយរាប់ទាំងការផ្សព្វផ្សាយ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការផ្សព្វផ្សាយផ្សេងៗ ។ តើយើងអាចទាក់ទងសហគមន៍ជាក់លាក់ណាមួយដោយរបៀបណា ? Next-door គឺជាឧបករណ៍ផ្សព្វផ្សាយដ៏អស្ចារ្យមួយ ។ យើងខ្ញុំកំពុងស្វែងរកគំនិតយោបល់ ។ តើអ្នកលក់អ្វីដែលមានប្រយោជន៍ក្នុងសហគមន៍ជនជាតិជប៉ុន ?
    i. អ្នកចូលរួម ៖ កីឡា Bay Area, វិទ្យុ Sakura Radio, ទូរទស្សន៍ជប៉ុន (ឆានែលដាច់ដោយឡែក), [Vivid Navigation](), J-Weekly ។ ជនជាតិជប៉ុនកាត់អាមេរិកជាទូទៅចង់ប្រើប្រាស់តែភាសាអង់គ្លេសប៉ុណ្ណោះ ។
2. បុគ្គលិក ROV ៖ ចុះចំណែកប្រព័ន្ធផ្សព្វផ្សាយសង្គមវិញ?
    a. អ្នកចូលរួម ៖ ប្រជាជនជប៉ុនចូលចិត្ត Facebook និង Twitter ។ សកលវិទ្យាល័យ Stanford ក៏មានក្រុមមួយដែលធ្វើការជាមួយសហគមន៍ដែលនិយាយតែភាសាជប៉ុនផងដែរ ។ សមាគមន៍ Stanford ជប៉ុនគឺជាក្រុមល្អមួយដែលគួរធ្វើការទំនាក់ទំនង ។
3. បុគ្គលិក ROV ៖ តើមានក្រុមសហគមន៍ជនជាតិជប៉ុននៅលើបណ្តាញសង្គម Facebook ដែលមានទំនាក់ទំនងជាក់លាក់ចំពោះខោនធី Santa Clara ?
    a. អ្នកចូលរួម ៖ សហគមន៍ជនជាតិជប៉ុនចូលចិត្តឆែកមើល Twitter hashtags ជា "ភាសាជប៉ុន ។" ពួកគេស្វែងរកជាប្រចាំដោយប្រើ hashtags ។ ឧទាហរណ៍ ប្រសិនបើអ្នកបកប្រែ "ការបោះឆ្នោតជ្រើសរើសបេក្ខជនប្រធានាធិបតីឆ្នាំ 2020 ជាភាសាជប៉ុន ពួកគេនឹងស្វែងរកវាតាមរយៈ hashtag ។"
4. បុគ្គលិក ROV ៖ យើងមាន Nishi Bei Weekly; តើអ្នកធ្លាប់ស្គាល់វាឬទេ ? យើងក៏មាន Stanford Daily ដែលជាធនធានភាសាជប៉ុនមួយ ។ ពលរដ្ឋជប៉ុនកាត់មេរិកជាធម្មតាអាន Nishi Bei Weekly ។
5. បុគ្គលិក ROV ៖ តើអ្នកធ្លាប់ស្គាល់ក្រុងជប៉ុននៅ San Jose ឬទេ ? ខ្ញុំមិនធ្លាប់ស្គាល់ទេ ព្រោះខ្ញុំតែងតែនៅសាលា។
6. បុគ្គលិក ROV ៖ យើងមានកម្មវិធីមួយដែលយើងបណ្តុះបណ្តាលគ្រូបង្គោលដើម្បីជួយក្នុងការផ្សព្វផ្សាយការអប់រំដល់អ្នកបោះឆ្នោត។ តើអ្នកមានទំនាក់ទំនងជាមួយអង្គការណាមួយដែរឬទេ ?
    a. អ្នកចូលរួម ៖ សាលាមនុស្សពេញវ័យ Palo Alto មានថ្នាក់ជាភាសាជប៉ុន ។ នោះអាចជាសហគមន៍ដ៏ល្អមួយដែលអាចភ្ជាប់ទំនាក់ទំនង និងធ្វើកិច្ចប្រជុំការបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាលបាន ។ ហើយក៏មានវិទ្យាល័យ Gunn ផងដែរ ដែលផ្តល់ថ្នាក់ភាសាជប៉ុន និងគ្រូភាសាជប៉ុន ។
7. បុគ្គលិក ROV ៖ Rachel Jung គឺជាអ្នកទទួលបន្ទុកចំពោះសម្ព័ន្ធផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត ហើយប្រសិនបើអ្នកចាប់អារម្មណ៍ អ្នកអាចទាក់ទង Rachel បាន ។
8. បុគ្គលិក ROV ៖ បានពន្យល់ពីគោលបំណងនៃសម្ព័ន្ធផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត ។ ដោយសារចំនួនអ្នកចុះឈ្មោះបោះឆ្នោតក្នុងខោនធី Santa Clara ធៀបទៅនឹងក្រុមអ្នកផ្សព្វផ្សាយរបស់មន្ត្រីអគ្រានុក្រូលដ្ឋានអ្នកបោះឆ្នោតខោនធី Santa Clara ដែលមានសមាជិកបីនាក់ យើងខ្ញុំត្រូវការជំនួយពីបងប្អូនដែលមកពីអង្គការតាមសហគមន៍ផ្សេងៗគ្នា ជាមួយការអប់រំដល់អ្នកបោះឆ្នោតក្នុងបរិមាណច្រើន ។
    a. អ្នកចូលរួម ៖ ហើយក៏មានពិធីបុណ្យរដូវក្តៅដ៏ធំមួយនៅដើមខែសីហា ដែលអាចធ្វើការដាក់ស្តង់បាន ។
9. បុគ្គលិក ROV ៖ តើអ្នកធ្លាប់ស្គាល់មជ្ឈមណ្ឌលវប្បធម៌ណាមួយដែលបង្រៀនភាសាអង់គ្លេសដល់អ្នកនិយាយភាសាជប៉ុនឬទេ?
    a. អ្នកចូលរួម ៖ ស្គាល់ សាលាមនុស្សពេញវ័យ Palo Alto ហើយសាលានេះបង្រៀនសិស្សក្រៅប្រទេស ។ វិហារព្រះពុទ្ធសាសនាអាចជាកន្លែងមួយដែលគួរតែធ្វើការពិចារណាផងដែរ ជាពិសេសវិហារដែលពាក់ព័ន្ធនឹងជនជាតិជប៉ុន ។ ផ្សារកសិករ Palo Alto គឺជាកន្លែងល្អមួយដើម្បីធ្វើការផ្សព្វផ្សាយព្រោះផ្សារនោះមានលក់បន្លែមកពីអាស៊ីជាច្រើន ហើយក៏មានកសិករជប៉ុនកាត់អាមេរិកផងដែរ ។ មានកន្លែងមួយដែលមានការបង្រៀនវគ្គសិក្សាផ្សេងៗជាភាសា

ជប៉ុន ដែលបង្រៀនរៀងរាល់ថ្ងៃសៅរ៍ ។ សិស្សគឺជាជនជាតិជប៉ុនដែលនិយាយតែមួយភាសា ហើយក៏មានសិក្ខាសាលាភាសាជប៉ុនដែលជាកន្លែងល្អមួយសម្រាប់សាលានេះ ។

10. បុគ្គលិក ROV ៖ តើអ្នកធ្លាប់ស្គាល់ក្រុងជប៉ុននៅ Tycho ឬទេ ?
    a. អ្នកចូលរួម ៖ ស្គាល់ វាគឺសហគមន៍/ក្លឹបនៅ San Jose ហើយក៏មានសមាគមន៍វាយស្គរផ្សេងទៀតនៅក្នុងទីក្រុងផ្សេងៗគ្នា ។ សមាគមន៍ Tycho មានទំនាក់ទំនងគ្នាក្នុងក្រុងផ្សេងៗគ្នា ។ សមាគមន៍ទាំងនោះអាចជាបណ្ដាញទំនាក់ទំនងមួយដ៏ល្អ ។

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara
# គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP)
## កំណត់ហេតុកិច្ចប្រជុំពិគ្រោះយោបល់ទូទៅ

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត
1555 Berger Dr., Building 2, San Jose, CA 95112
សាលប្រជុំ
ថ្ងៃសៅរ៍ទី 13 ខែកក្កដា ឆ្នាំ2019
ម៉ោង 1:00 រសៀល ដល់ 2:30 រសៀល

**វត្តមានអ្នកចូលរួម៖**
សមាជិកដប់ប្រាំបីរូបពីសាធារណជន

**វត្តមានបុគ្គលិកចូលរួម៖**
Shannon Bushey, Vanessa Hamm, Magdalena Sta Maria, Shelby Galaviz, Allen Ocampo, Priscilla Favela, Linh Nguyen, Janora Davis, Alfred Gonzales, Patricia Lopez, Amy Sun, Chenxi Ye, Robert Weidlin, Michelle Tran, Matt Moreles, Mike Fong, Lillian Tsai

**ចំណុចសកម្មភាព៖**

- ធ្វើបច្ចុប្បន្នភាពតំណភ្ជាប់ឯកសារផ្សព្វផ្សាយទៅនឹង EAPs នៅលើគេហទំព័ររបស់រដ្ឋលេខាធិការ (SOS) ចំណែកឯតំណភ្ជាប់ចាស់ៗត្រូវបានរក្សាទុកជាឯកសារដោយ SOS

I. **សេចក្តីណែនាំ**

*ស្វាគមន៍អ្នកចូលរួម*

II. **ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត**

ជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) អ្នកបោះឆ្នោតបច្ចុប្បន្ននេះនឹងអាចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដែលគេអាចបោះឆ្នោតបាន ។ អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតតាមសំបុត្រ ការទម្លាក់សន្លឹកឆ្នោតរបស់គេតាមហិបទម្លាក់សន្លឹកឆ្នោត ឬមានរយៈពេលរហូតដល់ទៅ 11 ថ្ងៃដើម្បីបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយ ។

*បទបង្ហាញស្តីពី VCA ត្រូវបានធ្វើឡើង*

III. **បំណងនៃគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត**

គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោតដាក់ចេញនូវរបៀបដែលមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងអនុវត្តការផ្លាស់ប្តូរទាំងឡាយទាក់ទងនឹងច្បាប់ VCA ហើយនឹងត្រូវធ្វើឡើងរួមគ្នាជាមួយនឹងធាតុចូលទទួលបានពីសហគមន៍ ។

*សេចក្តីសង្ខេបពីកាលបរិច្ឆេទ ធនធាន និងគោលបំណង*

IV. **ការជ្រើសរើសមណ្ឌលបោះឆ្នោត/ទីតាំងហិបទម្លាក់សន្លឹកឆ្នោត**

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីក្នុងការកំណត់ទីតាំងដែលមានសក្តានុពលសម្រាប់មណ្ឌលបោះឆ្នោតនិងទីតាំងហិបទម្លាក់សន្លឹកឆ្នោត ។ មណ្ឌលបោះឆ្នោតចាំបាច់ត្រូវតែអាចចេញចូលបាន ហើយមានទីធ្លាទូលាយគ្រប់គ្រាន់ដើម្បីផ្តល់សេវាឲ្យបានសមស្របដល់ពលរដ្ឋនៅក្នុងខោនធី Santa Clara ។

*មតិចូលរួមជាសាធារណៈ/សំណួរៈ*

1. អ្នកចូលរួមៈ តើហិបទម្លាក់សន្លឹកឆ្នោតមានសុវត្ថិភាពប៉ុណ្ណា?
    a. បុគ្គលិក ROV៖ វាត្រូវបានដាក់ច្រវាក់និងចាក់សោរជាប់មិនអាចលើកបាន ។ នៅម៉ោង 8:00 នៅយប់បោះឆ្នោត ហិបទាំងនោះត្រូវចាក់សោរបិទ ។ យើងមានច្រវាក់ការពារ យើងមានត្រាបិទហិបឆ្នោតដែលត្រូវបង់លេខ ដូច្នេះនៅពេលអ្នកបើកវានៅយប់នោះ អ្នកកត់ត្រាលេខនោះទុក ហើយនៅពេលអ្នកត្រឡប់មកវិញលេខនោះត្រូវតែនៅទីនោះ ។
2. អ្នកចូលរួមៈ តើអ្នកអាចនិយាយពីទីតាំង 11 ថ្ងៃ និង ទីតាំង 4 ថ្ងៃបានទេ? តើទីតាំងទាំងនោះនឹងទទេស្អាតនៅពេលយប់ ឬ សកម្មរស់រវើក ឆ្នោតរក្សាទុកនៅទីនោះ?
    a. បុគ្គលិកROV៖ ទីតាំងទាំងឡាយនឹងត្រូវធានាសន្តិសុខ ។ ចំណែកឯសន្លឹកឆ្នោតវិញ វានឹងត្រូវរក្សាទុកក្នុងទ្រុងចាក់សោរនៅខាងក្នុងមណ្ឌលបោះឆ្នោត ។ បច្ចុប្បន្ននេះ សន្លឹកឆ្នោតផ្ទាល់ យើងមានប្រព័ន្ធបោះឆ្នោតថ្មី បញ្ជីបោះឆ្នោតអេឡិចត្រូនិកថ្មី ម៉ាស៊ីនព្រីនសន្លឹកឆ្នោតថ្មីតាមតម្រូវការថ្មី ។ ដូច្នេះបច្ចុប្បន្ននេះ យើងមិនមានហិបឆ្នោត និងហិបសន្លឹកឆ្នោតព្រីនទុកមុនទៀតទេ ប៉ុន្តែឥឡូវនេះយើងមានរាប់ពាន់សន្លឹកប្រភេទខុសៗគ្នាជាអេឡិចត្រូនិកអាចព្រីនបាន ។ យើងនឹងមិនយកសំបកកេសសន្លឹកឆ្នោតចេញរាល់យប់ទៀតទេ ។ យើងនឹងយកវាចេញនៅចុងបញ្ចប់នៃថ្ងៃបោះឆ្នោត
3. អ្នកចូលរួមៈ បញ្ហាដែលនឹកឃើញនោះគឺថា ខ្ញុំតែងតែបោះឆ្នោតនៅឯសាលាក្នុងសង្កាត់របស់ខ្ញុំដែលស្ថិតនៅម្ខាងផ្លូវ ប៉ុន្តែឥឡូវនេះដោយសារតែមានច្រើនថ្ងៃក្នុងការបោះឆ្នោតនោះ វានឹងមិនអាចឲ្យសាលាធ្វើជាទីតាំងមណ្ឌលបោះឆ្នោតបានទេ ។
    a. បុគ្គលិក ROV៖ វាអាចនឹងរារាំងយើងមិនឲ្យប្រើប្រាស់សាលាមួយចំនួនបានមែន ហើយដោយសារយើងស្វែងរកទីតាំងដែលធំជាងមុន ដូចជាមណ្ឌលខ្ពាតធំ និងមិនមែនជាការិយាល័យបោះឆ្នោតទេ ជាច្រើននៃការិយាល័យបោះឆ្នោតពីមុនមកនឹងលែងប្រើទៀតហើយដូចជាសាលារៀន បណ្ណាល័យ អគារចតរថយន្តបុគ្គល ។ល។

4. អ្នកចូលរួម៖ តើវាជាហិបឆ្នោតដែលអាចបោះបាន 24 ម៉ោងមែនទេ? (ហិបទម្លាក់សន្លឹកឆ្នោត)
    a. បុគ្គលិក ROV៖ យើងមានហិបមួយចំនួនដែលអាចបោះបាន 24 ម៉ោង ប៉ុន្តែហិបមួយកន្លែងដែលលើកឡើងពីខាងដើមដែលស្ថិតនៅឯការិយាល័យស្មៀនក្រុងនោះ នឹងអាចបោះបានតែនៅក្នុងពេលម៉ោងធ្វើការទេ ។ ឧទាហរណ៍ ប្រសិនបើការិយាល័យបើកនៅម៉ោង 8 ព្រឹក - 5 ល្ងាចនោះ ហិបទម្លាក់សន្លឹកឆ្នោតនឹងអាចបោះបានតែចន្លោះម៉ោង 8 ព្រឹក - 5 ល្ងាចប៉ុណ្ណោះ ។
5. អ្នកចូលរួម៖ ចុះនៅតាមផ្សារទំនើបវិញយ៉ាងម៉េចដែរ? តើអ្នកបានទាក់ទងទៅពួកគេដើម្បីដាក់មណ្ឌលបោះឆ្នោតទេ?
    a. បុគ្គលិក ROV៖ មែនហើយ យើងបានទាក់ទងទៅកាន់ផ្សារទំនើបមួយចំនួនដែរ ទោះជាយ៉ាងណាក៏ដោយទីតាំងមួយចំនួនទាមទារឲ្យយើងបង់ថ្លៃ $5,000/ថ្ងៃ ហើយយើងពិតជាកំពុងតែរកមធ្យោបាយបញ្ចុះតម្លៃ ។
6. អ្នកចូលរួម៖ តើមានមធ្យោបាយអ្វី ដើម្បីប្តឹងជំទាស់ទៅនឹងការសម្រេចចិត្តលើមណ្ឌលបោះឆ្នោតទេ? ក្នុងករណីដែលយើងយល់ថាវាមិនសមស្របសម្រាប់សហគមន៍នោះ ។
    a. បុគ្គលិក ROV៖ អ្នកអាចផ្តល់ឲ្យយើងនូវមតិត្រឡប់ហើយយើងអាចនិងពិនិត្យពិចារណាលើវា ។ យើងនឹងអាចពន្យល់មូលហេតុដែលយើងមានអារម្មណ៍ថាយើងចាំបាច់ត្រូវប្រើវា ។ ប្រហែលជាទីតាំងតែមួយដែលទំនេរសម្រាប់ចំនួនថ្ងៃដាក់លាក់ដោយចំណតជនមានពិការភាពភាគច្រើន ប៉ុន្តែយើងពិតជាមានមូលហេតុរបស់យើង សម្រាប់ការជ្រើសរើសនិងមិនជ្រើសរើសទីតាំងនោះ ។ មណ្ឌលបោះឆ្នោតទាំងអស់របស់យើងត្រូវតែបើកទៅដល់មនុស្សគ្រប់គ្នា ។
7. អ្នកចូលរួម៖ ខ្ញុំរស់នៅក្បែរមណ្ឌល Eastridge និង King, Tropicana និងផ្សារទំនើបទាំងនោះហាក់ដូចជាមានពលរដ្ឋវៀតណាមច្រើន ។
    a. បុគ្គលិក ROV៖ អរគុណណាស់យើងនឹងពិនិត្យមើលសំណើនេះ ។

## V. លទ្ធភាពទទួលបានជំនួយផ្នែកភាសា

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពទទួលបានផ្នែកភាសា ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។ ជាឧទាហរណ៍នោះមានបញ្ចូលទាំងសំណូមពរសម្រាប់សហគមន៍ប្រើភាសាដែលមិនសូវទទួលបានសេវាឲ្យបានជិតដល់តាំងពីដើមរៀងមក និងការជ្រើសរើសមន្ត្រីបោះឆ្នោតដែលនិយាយពីរភាសា ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ តើមានមណ្ឌលជាក់លាក់ណានឹងដាក់បុគ្គលិកចេះពីរភាសាទេ?
    a. បុគ្គលិក ROV៖ ពិតមែនហើយ សម្រាប់ភាសារបស់យើង យើងមានប្រាំភាសា (អង់គ្លេស អេស្ប៉ាញ ចិន វៀតណាម តាកាឡុក) ដែលត្រូវបានកំណត់ដោយសហព័ន្ធ ដែលមាន

គ្រប់ឯកសារដែលយើងផលិត ។ យើងមានពីរភាសាគឺ ជប៉ុន & កូរ៉េ ដែលត្រូវបានកំណត់ដោយរដ្ឋ ។ ហើយភាសាពីរផ្សេងទៀតគឺ ខ្មែរ & ហ៊ីនឌី យើងនឹងបន្តផ្តល់ជូយដោយសារតែវាត្រូវបានកំណត់ពីមុនមកហើយ ប៉ុន្តែវាលែងទៀតហើយ ហើយយើងមិនចង់យកអ្វីមួយដែលបានផ្តល់ហើយចេញដែរ ។ ដូច្នេះយើងផ្តល់ភាសាសរុបចំនួនប្រាំបួន ។ សម្រាប់ពេលដែលទើបដាក់ចូលលើកទី1 យើងនឹងធ្វើឲ្យផុតនិងហួសពីអ្វីដែលច្បាប់តម្រូវ និងត្រៀមសន្លឹកឆ្នោតផ្លូវការជាភាសាទាំងប្រាំបួននោះ ។ ទេ មានសន្លឹកឆ្នោតតាមទូរសារច្រើនជាងមុននៅតាមមណ្ឌលបោះឆ្នោតសម្រាប់ភាសាទាំងបួនផ្សេងទៀតនោះ ។

VI. **លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត**

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីជួយដល់ខោនធីតាមមធ្យោបាយផ្សេងៗក្នុងការផ្តល់ឲ្យមានលទ្ធភាពចូលរួមសម្រាប់អ្នកបោះឆ្នោតជាជនចាស់ជរា និងអ្នកដែលមានពិការភាព ដើម្បីឲ្យអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់អាចយល់បានពីដំណើរការបោះឆ្នោត និងទទួលបានសន្លឹកឆ្នោតដោយស្មើភាពគ្នា ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ ដាក់លេខទូរសព្ទនៅលើប័ណ្ណប្រៃសណីយ៍ VCA & LAAC/VAAC ។ មិនមែនគ្រប់គ្នាសុទ្ធតែមានអ៊ីនធឺណែតទេ ។
    a. បុគ្គលិក ROV៖ ពិតមែនហើយ ។
2. អ្នកចូលរួម៖ តើ “X” នៅទទួលយកថាជាហត្ថលេខាទេ?
    a. បុគ្គលិក ROV៖ ត្រឹមត្រូវ ។
    b. អ្នកចូលរួម៖ តើអ្នកត្រូវពិនិត្យហត្ថលេខាតាមរបៀបណាទៅ?
    c. អ្នកចូលរួម៖ តើអ្នកផ្ទៀងផ្ទាត់អ្នកបោះឆ្នោត ដែលបានចុះហត្ថលេខាសញ្ញា “X” មានបញ្ហាសមត្ថភាពផ្នែកខួរក្បាលមែនទេ? តើអ្នកបញ្ជាក់ថាពួកគេបានផ្លាស់ទីលំនៅដូចម្តេច?
    d. បុគ្គលិក ROV៖ យើងទទួលបានបញ្ជីឈ្មោះអ្នកដែលចៅក្រមបានប្រកាសថាមានបញ្ហាផ្លូវចិត្តមិនប្រក្រតីដើម្បីបោះឆ្នោតបាន ។ ដូច្នេះយើងយកវាចេញពីបញ្ជីរបស់យើង ។ មានតែប៉ុណ្ណឹងអ្វីដែលយើងអាចធ្វើបានទាក់ទងទៅនឹងបញ្ហាផ្នែកនេះ ។ បច្ចុប្បន្ននេះ គ្រប់គ្នាអាចបំពេញទម្រង់ចុះឈ្មោះបានជាមួយនឹងទោសបញ្ញត្តិនៃការស្បថបំពាន ។ ជាមួយនឹងព័ត៌មានរបស់គេ ប្រព័ន្ធទូទាំងរដ្ឋ យើងចាំបាច់ត្រូវមានយ៉ាងហោចណាស់ក៏យើងត្រូវមានលេខបួនខ្ទង់នៃលេខសន្តិសុខសង្គម ឬ លេខប័ណ្ណសម្គាល់ខ្លួនរដ្ឋ California របស់យើង ។ ប្រព័ន្ធធ្វើបច្ចុប្បន្នភាពភ្លាមៗ ហើយបញ្ជាក់ថាលេខនោះពិតជាទាក់ទងទៅនឹងឈ្មោះអ្នក ។
    e. អ្នកចូលរួម៖ នៅពេលខ្ញុំឃើញមនុស្សដើរកាន់ឈើច្រត់និងជិះរទេះចូលទៅកាន់តំបន់ចុះឈ្មោះនោះ ។ នោះជារឿងពិតមែនឬ?
        i. បុគ្គលិក ROV៖ ដូច្នេះយើងមិនអនុញ្ញាតឲ្យបដិសេធនរណាម្នាក់មានសិទ្ធិដើម្បីបោះឆ្នោតបានទេ ។

ii. អ្នកចូលរួម៖ ថ្វីបើពួកគេមិននិយាយដោយផ្ទាល់ អ្នកខ្លះនិយាយជំនួសពួកគេ ។

iii. បុគ្គលិក ROV៖ យើងមិនអាចសួរថាគាត់មានពិការភាពអ្វី ។ យើងមិនមានសិទ្ធិទេ ដែលនោះជាច្បាប់ ។ ដើម្បីអាចប្រើ “X” ជាហត្ថលេខាបាន អ្នកចាំបាច់ត្រូវចុះឈ្មោះឡើងវិញ បំបំពេញផ្នែកនៃប្រអប់បញ្ជាក់ថាអ្នកត្រូវបានគេជួយចុះឈ្មោះឲ្យ ដោយចាំបាច់ត្រូវផ្តល់ព័ត៌មានរបស់បុគ្គលនោះនៅទីនោះ ហើយអ្នកត្រូវបញ្ជាក់ដោយប្រើសញ្ញា "X" ។ នៅពេលឯកសារត្រូវបានដំណើរការភ្លាម ពេលនោះវាចូលទៅក្នុងប្រព័ន្ធ ។ ដូច្នេះនៅពេលគេចូលទៅបោះឆ្នោត វានឹងបង្ហាញឡើង ។ ប៉ុន្តែមានច្បាប់ហាមយើងពីការធ្វើរឿងជាក់លាក់មួយចំនួន ។ ដូច្នេះ ប្រសិនបើគ្មានអ្វីជាលាយលក្ខណ៍អក្សរពីយថៅក្រមទេ នោះយើងមិនអាចបដិសេធពួកគេភ្លាមៗបានទេ ។

## VII. ឱកាសផ្សព្វផ្សាយ

ROV នឹងប្រមូលធាតុចូលពីសាធារណជន ដើម្បីកំណត់ពីទីតាំងនិងវិធីផ្សព្វផ្សាយដើម្បីឲ្យបានលទ្ធផលប្រសើរបំផុតទៅដល់អ្នកបោះឆ្នោតរបស់ខោនធីនិងអប់រំពួកគេពីការផ្លាស់ប្តូរនានានៅក្នុងការបោះឆ្នោតដែលនឹងមកដល់ជាមួយនឹងច្បាប់ VCA ។

*មតិចូលរួមជាសាធារណៈ/សំណួរ៖*

1. អ្នកចូលរួម៖ តើអ្នកអាចនិយាយបានដែរទេ ថាតើខោនធីអ្នកធ្វើការសម្របសម្រួលច្រើនប៉ុណ្ណាជាមួយពួកគេ (ខោនធីផ្សេងៗទៀតដែលបានអនុវត្ត EAP រួចហើយនោះ) បញ្ចូលយកចំណុចដែលបានរៀនសូត្រនោះ?
    a. បុគ្គលិក ROV ៖ ប្រាកដណាស់។ នៅក្នុងឆ្នាំ 2018 ជាឆ្នាំទីមួយដែលច្បាប់នេះមាន ដោយមានខោនធីចំនួនប្រាំដែលបានអនុវត្តនិងដំណើរការជាមួយនឹងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត ។ មកដល់ថ្ងៃនេះ មានខោនធីសរុបចំនួនដប់បួនហើយដែលកំពុងអនុវត្តនៅក្នុងឆ្នាំ 2020 ដែលស្មើនឹងពាក់កណ្តាលនៃការចុះឈ្មោះ ។ ដូច្នេះបើទោះបីមានខោនធី 58 ក៏ពិតមែន ដប់បួនខោនធីនៃយើងគឺច្រើនជាងពាក់កណ្តាលនៃអ្នកបោះឆ្នោតដែលនឹងអនុវត្តច្បាប់នេះ ។ យើងបានធ្វើការនិងប្រាស្រ័យទាក់ទងជាមួយនឹងខោនធីប្រាំផ្សេងទៀត សម្រាប់រយៈពេលជាងមួយឆ្នាំនោះ ។ យើងបានចុះធ្វើដំណើរការសិក្សា ។ យើងបានទៅដល់ការិយាល័យរបស់គេ ។ យើងបានជួបជាមួយនឹងដៃគូរបស់គេ ។ យើងបានទៅដល់ San Mateo ។ យើងបានទៅដល់ Sacramento ។ យើងមានក្រុមការងារច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត មានទំនាក់ទំនងជាមួយខោនធីផ្សេងៗទៀតពាសពេញរដ្ឋ ។ យើងបានត្រៀមរៀបចំរកឲ្យឃើញនូវចំណុចដែលអាចនឹងជាបញ្ហាទាំងឡាយ ។
2. អ្នកចូលរួម៖ ក្នុងសង្កាត់របស់ខ្ញុំ មួយខែម្តង មានកិច្ចប្រជុំប្រចាំខែ ។ ប្រសិនបើយើងអាចមានតំណាងនៅទីនោះ វាអាចតាមពិតទៅជួយប្រមូលមនុស្សឲ្យមកជុំគ្នា ប៉ុន្តែវានឹងពិតជាពាំនាំព័ត៌មានចេញទៅដល់សង្កាត់ ។

a. បុគ្គលិក ROV៖ នោះពិតជាគំនិតល្អណាស់ ហើយយើងស្ថិតនៅលើផ្នត់គំនិតដូចគ្នាចំពោះចំណុចនេះនៅក្នុងនាយកដ្ឋានរបស់យើង ។ VEOC គឺជាសម្ព័ន្ធភាពដែលយើងបានចាប់ផ្តើមឡើង ដែលមិនតម្រូវដោយច្បាប់ឲ្យធ្វើនោះទេ ហើយការយកចិត្តទុកដាក់របស់វា គឺទៅលើការចូលរួមរបស់អ្នកបោះឆ្នោត ហើយនិងធ្វើការបញ្ចេញសារ ។ យើងពិតជាអាចចេញក្រៅនិងធ្វើបទបង្ហាញបាន ។

b. អ្នកចូលរួម៖ ខ្ញុំសូមសួរថា យើងមានអ្នកនិយាយពីរភាសាគឺ អេស្ប៉ាញ

c. បុគ្គលិក ROV៖ យើងក៏អាចធ្វើវានោះបានដែរ ។

3. អ្នកចូលរួម៖ តើ ROV បានទាក់ទងទៅកាន់សមាគមបំពេញដល់សហគមន៍ San Jose ទេ?

   a. បុគ្គលិក ROV៖ យើងបានបន្ថែមស្មៀនក្រុងទាំងអស់ សមាជិកក្រុមប្រឹក្សាក្រុងទាំងអស់ នាយកគ្រប់គ្រងសាលាក្រុងទាំងអស់ ទៅគ្រប់អ៊ីម៉ែលទាំងអស់ដែលយើងផ្ញើចេញព័ត៌មាននេះនិងអ្វីដែលកំពុងកើតមានឡើង ។ ខ្ញុំពិតជាមិនប្រាកដថា តើយើងបានផ្សព្វផ្សាយសាររបស់យើងដើម្បីពង្រីកព័ត៌មានឲ្យទៅដល់សហគមន៍របស់អ្នកនៅខណៈពេលដែលឯកសារផ្សព្វផ្សាយកំពុងត្រូវបាន ។

4. អ្នកចូលរួម៖ តើឯកសារផ្សព្វផ្សាយនឹងត្រូវរួចរាល់ត្រឹមថ្ងៃទី6 ខែសីហាមែនទេ? (National Night Out)

   a. បុគ្គលិក ROV៖ ខ្ញុំដឹងថាការិយាល័យរបស់យើងមានតារាងមួយនៅទីនោះ ។

5. អ្នកចូលរួម៖ ចុះការបង្ហោះផ្សាយ/ព័ត៌មានផ្សព្វផ្សាយនៅលើវីដេអូតាមស្ថានីយ៍ប្រេងយ៉ាងម៉េចដែរ?

   a. បុគ្គលិក ROV៖ នោះពិតជាសំណូមពរដ៏ល្អ យើងអាចពិនិត្យឡើងវិញចំពោះផ្នែកនេះ ។ នេះជាគំនិតល្អ ។

6. អ្នកចូលរួម៖ ប្រព័ន្ធផ្សព្វផ្សាយសង្គមចាំបាច់ណាស់ ។ ប្រសិនបើអ្នកអាចធ្វើជារូបភាពព័ត៌មានមានចលនា វានឹងជួយខ្លាំងណាស់ ។

   a. បុគ្គលិក ROV៖ ខ្ញុំយល់ស្របតាមគំនិតនោះ ។ យើងមាន *Facebook, Twitter, Instagram, Nextdoor*, ហើយយើងមានវីដេអូនៅលើ *YouTube* ។ ដូច្នេះ យើងបានធ្វើការផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ យើងក៏កំពុងពិនិត្យទៅលើសារព័ត៌មានបោះពុម្ព វិទ្យុ TV និងសិទ្ធិប្រើយីហោក្រុមហ៊ុនកីឡា ។

7. អ្នកចូលរួម៖ The Sunnyvale Sun

8. អ្នកចូលរួម៖ VTA Busses and Light Rail

9. អ្នកចូលរួម៖ Evergreen Times

10. អ្នកចូលរួម៖ តើអ្នកនឹងទាក់ទងទៅកាន់មហាវិទ្យាល័យសហគមន៍ក្នុងមូលដ្ឋានទេ?

    a. បុគ្គលិក ROV៖ ពិតមែនហើយ យើងនឹងធ្វើ ។ យើងជិតនឹងទទួលបានមហាវិទ្យាល័យសហគមន៍ West Valley ជាមណ្ឌលបោះឆ្នោតទៅហើយ ។ យើងបានចុះកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋ San Jose ដើម្បីដាក់មណ្ឌលបោះឆ្នោត ។

11. អ្នកចូលរួម៖ តើអ្នកមានផែនការធ្វើការផ្សព្វផ្សាយច្បាប់ VCA នៅតាមកម្មវិធីបុណ្យក្រុងនានាទេ?
    a. បុគ្គលិក ROV៖ យើងធ្វើប្រហែល 250 ព្រឹត្តិការណ៍ផ្សព្វផ្សាយនៅក្នុងឆ្នាំនេះ ។ យើងមានផែនការចូលរួមពិធីបុណ្យសិល្បៈនិងស្រា និងយើងចូលរួមកិច្ចប្រជុំសហគមន៍ទាំងអស់ ។ យើងទើបតែបានបញ្ចប់ការកំណត់ពណ៌ថ្មីរបស់យើង ដូច្នេះឯកសារផ្សព្វផ្សាយថ្មីរបស់យើងនឹងចេញផ្សព្វផ្សាយនាពេលរនេះ ។
12. អ្នកចូលរួម៖ តើយើងអាចមានជង់កាតព័ត៌មានដើម្បីចែកបន្តទៅឲ្យកិច្ចប្រជុំសហគមន៍របស់យើងបានទេ?
    a. បុគ្គលិក ROV៖ យើងពិតជាពេញចិត្តគំនិតនេះណាស់ពីព្រោះនោះគឺជាវិធីដែលយើងពង្រីកការផ្សព្វផ្សាយព័ត៌មាន ។ អ្នកអាចផ្ញើអ៊ីម៉ែលស្នើសុំជង់មកយើងបាន ។ នោះពិតជារបៀបដែលយើងត្រូវការជំនួយពីអ្នក ។
13. អ្នកចូលរួម៖ ប្រហែលជាគួរពិចារណា San Jose Giants ទេ?
14. អ្នកចូលរួម៖ ចុះឧទ្យានផ្ទះចល័តវិញយ៉ាងម៉េចដែរ?
15. អ្នកចូលរួម៖ ពេលការបោះឆ្នោតជិតចូលមកដល់ ខ្ញុំចង់ផ្តល់អនុសាសន៍ឲ្យទៅតំបន់ប្រជុំជនដោយយកប័ណ្ណមួយថង់ធំ ហើយចែកវាទៅដល់អង្គការសិល្បៈ និងហាងកាហ្វេទាំងឡាយ ។
    a. បុគ្គលិក ROV៖ មែនហើយ នោះពិតជាសំណូមពរដ៏ល្អ ។ ប្រសិនបើអ្នកទៅហាងកាហ្វេមួយចំនួន យើងអាចផ្ញើឲ្យអ្នក 100 ប័ណ្ណប្រៃសណីយ៍ ហើយប្រសិនបើអ្នកអាចបិទផ្សាយនៅតាមហាងនីមួយៗដែលអ្នកបានទៅ ធ្វើបែបនឹងប្រាកដជាជួយដល់យើង ។
16. អ្នកចូលរួម៖ ដោយសារតែលែងមានសង្កាត់បោះឆ្នោតទៀតហើយនោះ និងនៅខែមិនា ឆ្នាំ 2020 នឹងជាពេលបោះឆ្នោតប្រធានាធិបតី។
    a. បុគ្គលិក ROV៖ អ្នកអាចនិយាយពីការបដិសេធមិនធ្វើសេចក្តីថ្លែងការណ៍ ថាអ្នកមិនពាក់ព័ន្ធនឹងគណបក្សណាមួយឡើយ ។ យើងរៀបចំសេចក្តីជូនដំណឹងដល់ពួកគេមុនពេលយើងផ្ញើសន្លឹកឆ្នោតទៅឲ្យ ហើយសួរតើគេចង់យកគណបក្សណាមួយទេ ។ យើងចង់សួរពួកគេក្រែងលោពួកគេចង់បានសន្លឹកឆ្នោតមួយនៃគណបក្សទាំងនោះ (ដែលអនុញ្ញាតឲ្យគេប្តូរ) ជំនួសឲ្យការបដិសេធមិនធ្វើសេចក្តីថ្លែងការណ៍របស់គេ ហើយគេនឹងផ្ញើវាត្រឡប់មកយើងវិញ ឬទាក់ទងមកយើង ។ ប្រសិនបើដោយប្រការណាមួយនោះពួកគេមិនបានធ្វើទេនោះ ពួកគេអាចទៅកាន់មណ្ឌលបោះឆ្នោត ហើយប្រាប់បុគ្គលនៅទីនោះថាពួកគេចង់ប្តូរ ហើយយើងនឹងព្រីនសន្លឹកឆ្នោតថ្មីឲ្យពួកគេ ។

## VIII. ភាសាផ្សេងៗទៀត

1. អ្នកចូលរួម៖ តើអ្នកការពារមិនឲ្យមនុស្សម្នាក់មិនឲ្យបោះឆ្នោតបានច្រើនដងតាមរបៀបណា?
    a. បុគ្គលិក ROV៖ ប្រព័ន្ធរបស់យើងតាមដានគ្រប់សន្លឹកឆ្នោត ដែលត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតរបស់យើងដែលបានចុះឈ្មោះបោះឆ្នោត ។ យើងឥឡូវនេះនឹងមានតារាងមួយ ហើយពួកគេភ្ជាប់ទៅកាន់ប្រព័ន្ធរបស់យើងតាមរយៈបណ្តាញអ៊ីនធឺណិតដែលបានសុវត្ថិភាព ។ ហើយប្រសិនបើអ្នកបានជាបោះឆ្នោតពីរដងដោយចៃដន្យនោះ សន្លឹកឆ្នោតទីមួយដែលជាសន្លឹកឆ្នោតត្រូវរាប់ ហើយប្រព័ន្ធនឹងបង្ហាញវា ។

2. អ្នកចូលរួម៖ តើធ្វើដូចម្តេច ប្រសិនបើនរណាម្នាក់បានបោះឆ្នោតជំនួសឈ្មោះអ្នកនោះ?
    a. បុគ្គលិក ROV៖ យើងធ្វើការប្រៀបធៀបហត្ថលេខានៅការិយាល័យរបស់យើង ។ រាល់សន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានស្កេននៅពេលវាចូលមក ។ យើងប្រើមនុស្សដើម្បីផ្ទៀងផ្ទាត់ហត្ថលេខា ។ ហើយប្រសិនបើបុគ្គលជាអ្នកពិនិត្យគិតថាវាមិនត្រូវគ្នាដោយប្រការណាមួយនោះ វានឹងត្រូវធ្វើការពិនិត្យឡើងវិញលើកទីពីរ និងលើកទីបី ហើយនឹងបញ្ជូនទៅអ្នកគ្រប់គ្រង និងប្រធានគ្រប់គ្រង ។
3. អ្នកចូលរួម៖ តើអ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកបានទេ?
    a. បុគ្គលិក ROV៖ ពិតជាបាន យើងមានប្រព័ន្ធអនឡាញនោះ ។
4. អ្នកចូលរួម៖ តើវានឹងក្លាយជាសន្លឹកឆ្នោតកាត់ពេលចេញទេ?
    a. បុគ្គលិក ROV៖ ការលុបថ្ងៃកើតឡើងដូចគ្នាទៅនឹងវាធ្លាប់មានពីរឆ្នាំកន្លងមកនេះ ។ គូសក្រោយថៃមបីខែ ។ ប្រសិនបើវាត្រូវបានវាយត្រាប្រៃសណីយ៍ចំថ្ងៃបោះឆ្នោត ហើយយើងទទួលវាបានដល់ការិយាល័យរបស់យើងក្នុងរយៈពេលបីថ្ងៃ វានឹងមានសុពលភាពដែលនៅតែបន្តនៅក្រោមគំរូថ្មីនេះ ។
5. អ្នកចូលរួម៖ តើការប្រើបុគ្គលិកវិញវានឹងខុសគ្នាយ៉ាងម៉េចប្រៀបធៀបទៅនឹងការិយាល័យបោះឆ្នោតនោះ?
    a. បុគ្គលិក ROV៖ ខ្លះនៃផែនការនេះមិនទាន់ត្រូវបានសម្រេចនៅឡើយទេ ។ យើងកំពុងតែពិនិត្យមើលលទ្ធភាពផ្តល់ការបណ្តុះបណ្តាលបីម៉ោងម្តងទៀត ។ ធ្វើការពីមួយទៅបួនថ្ងៃជាមន្ត្រីបោះឆ្នោតស្ម័គ្រចិត្ត ។ ប៉ុន្តែយើងមានឱកាសថ្មី "ជំនួយបន្ថែមដល់និយោជិតខោនធី" ។ ជំហានបន្ថែមមួយជំហាននឹងត្រូវបំពេញបែបបទអនឡាញ ។ ការបណ្តុះបណ្តាលសម្រាប់រយៈពេលប្រាំពីរថ្ងៃ ធ្វើការដប់មួយថ្ងៃ សម្រាប់រយៈពេលពីរទៅបីសប្តាហ៍ ។
    b. អ្នកចូលរួម៖ សម្រាប់ខែមិនា និងវិច្ឆិកាមែនទេ?
    c. បុគ្គលិក ROV៖ ចាប់ពីពេលនេះតទៅ ។
6. អ្នកចូលរួម៖ តើមានអ្នកបោះឆ្នោតប៉ុន្មាននាក់ នៅក្នុងខោនធី Santa Clara?
    a. បុគ្គលិក ROV៖ អ្នកបោះឆ្នោត 911, 000 នាក់
7. អ្នកចូលរួម៖ តើការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌជាអ្វីដែលថ្មីមែនទេ?
    a. បុគ្គលិក ROV៖ វាចាប់ផ្តើមក្នុងឆ្នាំ 2017 ប៉ុន្តែនៅពេលនោះយើងមិនមានការបោះឆ្នោតទូទាំងខោនធីទេ ដូច្នេះហើយគេទើបចាប់ផ្តើមឮអំពីវារហូតដល់ឆ្នាំ 2018 ហើយមនុស្សពីរបីពាន់នាក់ប្រើវាចាប់ពីពេលនោះមក ។ ប៉ុន្តែយើងរំពឹងថានឹងមានមនុស្សកាន់តែច្រើនប្រើវានៅក្នុងឆ្នាំ 2020 ប្រមាណជាដប់ពាន់អ្នក ។
8. អ្នកចូលរួម៖ តើបុគ្គលិកប្រភេទណា ដែលអ្នកមានដើម្បីធានាថាសុច្ចរិតភាពនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងនេះដែលទទួលស្គាល់ស្របតាមច្បាប់នោះ?

a. បុគ្គលិក ROV៖ រដ្ឋទាំងមូលឥឡូវនេះមានមូលដ្ឋានទិន្នន័យអ្នកបោះឆ្នោតទូទាំងរដ្ឋគឺ VoteCal ។ ដូច្នេះ យើងត្រូវបានភ្ជាប់និងទាញយកព័ត៌មានពីរដ្ឋលេខាធិការ ស្ថិតិប្រជាជន ក្រសួងយានយន្ត ក្រសួងកែប្រែឡើងវិញ និងក្រសួងផ្ដន្ទាទោសបទឧក្រិដ្ឋ ។ ដូច្នេះ មានប្រព័ន្ធមួយដែលមានសុវត្ថិភាពទាំងមូលតាមរយៈរដ្ឋដែលភ្ជាប់ទៅកាន់ខោនធីទាំងអស់នាពេលបច្ចុប្បន្ននេះ ។

9. អ្នកចូលរួម៖ មនុស្សអាចនឹងទៅកាន់ Gilroy Outlet និងបោះឆ្នោត តើវាបង្ហាញថាពួកគេបានបោះឆ្នោតនៅក្នុងសង្កាត់នោះ ឬពួកគេនឹងស្វែងរកសង្កាត់បោះឆ្នោតជាក់ស្តែងរបស់គេបាន?
   a. បុគ្គលិក ROV៖ យើងនៅតែមានសង្កាត់នៅក្នុងប្រព័ន្ធរបស់យើងដោយសារតែនោះជារបៀបដែលយើងត្រូវបានកំណត់ឲ្យរាយកាណ៍ពីសេចក្ដីថ្លែងពីការបោះឆ្នោតរបស់យើង ។ លទ្ធផលរបស់យើងចេញតាមមណ្ឌល ។ ត្រូវហើយ យើងមានសង្កាត់ ប៉ុន្តែនឹងមានមណ្ឌលបោះឆ្នោត ។ អ្នកមិនត្រូវបានចាត់តាំងទៅកាន់មណ្ឌលបោះឆ្នោតដូចអ្នកត្រូវបានចាត់តាំងទៅតាមសង្កាត់អញ្ចឹងដែរ ។ ប៉ុន្តែយើងនឹងរាយការណ៍លទ្ធផលទៅតាមសង្កាត់ ។
   b. បុគ្គលិក ROV៖ ហើយអ្នកនឹងទទួលបានសន្លឹកឆ្នោតត្រឹមត្រូវរបស់អ្នក ដែលអ្នកត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ដូច្នេះវាមិនមែនជាសន្លឹកឆ្នោតទូទៅទេ ។
   c. អ្នកចូលរួម៖ វាជាសន្លឹកឆ្នោតតាមតម្រូវការ ។ ដូច្នេះ អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកបើទោះជាអ្នកនៅទីណាក៏ដោយ ។
   d. អ្នកចូលរួម៖ ខ្ញុំគ្រាន់តែឆ្ងល់ពីវិធីដែលវាត្រូវបានគេដាក់បញ្ចូលជាតារាងយ៉ាងម៉េច? ដូច្នេះ វានៅតែបន្តទាក់ទងមកវិញហើយសួរថា នេះនឹងបង្ហាញនៅក្នុងសង្កាត់ ដោយសារតែគណបក្សនយោបាយនិងយុទ្ធនាការនយោបាយប្រើប្រាស់ទិន្នន័យនោះ ។
   e. បុគ្គលិក ROV៖ អ្នកនៅតែភ្ជាប់មកជាមួយនូវសង្កាត់សម្រាប់រាយការណ៍ពីគោលបំណង ។ ទីតាំងគឺគ្រាន់តែជាទីតាំង ។

10. អ្នកចូលរួម៖ តើតួនាទីរបស់អ្នកសង្កេតការណ៍បោះឆ្នោតប៉ះពាល់យ៉ាងម៉េចខ្លះ?
   a. បុគ្គលិក ROV៖ ខ្ញុំមិនជឿថាយើងបានបញ្ចប់វានៅឡើយទេប៉ុន្តែយើងកំពុងពិនិត្យទៅលើមធ្យោបាយដើម្បីអាចផ្សាយនៅលើអ៊ីធឺណិត តាមអេឡិចត្រូនិក ។

11. អ្នកចូលរួម៖ តើអ្នកឆ្លើយតបចំពោះការព្រួយបារម្ភទាក់ទងនឹងការសម្ងាត់ដោយប្រើប្រាស់ប្រព័ន្ធបោះឆ្នោតថ្មីយ៉ាងដូចម្ដេច?
   a. បុគ្គលិក ROV៖ វាគ្មានអ្វីផ្លាស់ប្ដូរទេ ។ អ្នកនៅតែអាចទៅកាន់មណ្ឌលបោះឆ្នោត ដើម្បីប្រគល់នូវសន្លឹកឆ្នោតដែលព្រីនរួច ឬអ្នកអាចបោះឆ្នោតតាមម៉ាស៊ីនដែលអាចបោះឆ្នោតបាន ។ ហើយបន្ទាប់មកអ្នកដាក់វាចូលទៅក្នុងម៉ាស៊ីនរាប់ ។ វាគ្មានអ្វីពាក់ព័ន្ធអ្វីនឹងឈ្មោះរបស់អ្នកទេ ។ វាគ្រាន់តែស្កេនសន្លឹកឆ្នោតក្រដាសដែលអ្នកដាក់ចូល។ សន្លឹកឆ្នោតក្រដាស VBM ដែលចូលមកដល់ យើងដំណើរការវានៅក្នុងស្ថានភាពពីលើចុះក្រោមធ្វើបែបនេះយើងគ្មានឃើញអ្វី ក្រៅពីផ្នែកខាងមុខនៃស្រោមសំបុត្រជាមួយនឹង

អាសយដ្ឋានមកកាន់ការិយាល័យរបស់យើង ។ យើងតែងតែធ្វើការជាមួយសន្លឹកឆ្នោតនៅក្នុងក្រុមកម្រិតអប្បរមាចំនួនពីរក្រុម ដើម្បីរក្សាឲ្យបាននូវភាពអនាមិក បើទោះជាវាស្ថិតក្នុងហិបឆ្នោត ឬក្នុងកន្លែងបោះឆ្នោតក៏ដោយ ។

b. អ្នកចូលរួម៖ ខ្ញុំយល់នូវនិតិវិធីទាំងនោះ អ្វីដែលខ្ញុំមិនយល់នោះគឺថាតើអ្នកទាំងពីររក្សានូវភាពអនាមិកនៃសន្លឹកឆ្នោតយ៉ាងដូចម្តេច និងក៏ដូចជាសុពលភាពថាតើមាននរណាម្នាក់បាន ឬមិនបានបោះឆ្នោតពីរដងឬអត់ ។
c. បុគ្គលិក ROV៖ យើងធ្វើបែបនេះនៅពេលយើងបើកសន្លឹកឆ្នោត ។ យើងនឹងរាប់សន្លឹកឆ្នោតម្នាក់តែមួយសន្លឹកប៉ុណ្ណោះ ទីមួយ ហើយយើងមិនបើកវាទាំងអស់ទេ ។ វាពុំមានភ្ជាប់ទៅនឹងបុគ្គលណាមួយជាក់លាក់ទេ ។ វាប្រឆាំងនឹងច្បាប់ចំពោះការតាមដានបុគ្គលពីរបៀបបោះឆ្នោតរបស់គេ។
d. អ្នកចូលរួម៖ វាមិនច្បាស់សោះចំពោះខ្ញុំថាតើនឹងមានហិបធំសម្រាប់សន្លឹកឆ្នោតរាយប៉ាយក៏សន្លឹកឆ្នោតទាំងអស់នោះនឹងត្រូវច្រកចូលស្រោមសំបុត្រ ។
e. បុគ្គលិក ROV៖ ទេ មិនមែនសន្លឹកឆ្នោតទាំងអស់នឹងច្រកចូលស្រោមសំបុត្រទេ មានតែសន្លឹកឆ្នោតបណ្តោះអាសន្នឬសន្លឹកឆ្នោតមានលក្ខខណ្ឌតែប៉ុណ្ណោះត្រូវដាក់ចូល ។ សន្លឹកឆ្នោតទាំងអស់ផ្សេងទៀតនឹងត្រូវដាក់ចូលទៅហិបឆ្នោត ។

12. អ្នកចូលរួម៖ តើអ្នកនៅតែរក្សាទុកដោយមានស្តុតបិទដែលអាចហែកផ្តាច់បានដើម្បីអ្នកអាចហៅមកបានក្នុងរយៈពេល 30 ថ្ងៃក្រោយមែនទេ?
    a. បុគ្គលិក ROV៖ ពិតជាអញ្ចឹងមែនហើយ ។

**County of Santa Clara**
Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

## សវនាការសាធារណៈស្តីពី EAP
## របៀបវីរៈ

I. **សូមស្វាគមន៍**

II. **បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃច្បាប់ VCA**

III. **បទបង្ហាញស្តីពី VBM**
   a. កញ្ចប់ VBM
   b. ហិបទម្លាក់សន្លឹកឆ្នោត
   c. RAVBM

IV. **បទបង្ហាញស្តីពីផែនទី GIS**

V. **បទបង្ហាញស្តីពីប្រតិបត្តិការសង្កាត់បោះឆ្នោត**
   a. មណ្ឌលបោះឆ្នោត
   b. ការដាក់និងបណ្តុះបណ្តាលបុគ្គលិកនៅតាមមណ្ឌលបោះឆ្នោត
   c. ការផ្សព្វផ្សាយ

VI. **បទបង្ហាញស្តីពីទម្រង់សន្លឹកឆ្នោត**
   a. ការផ្តល់ជំនួយផ្នែកភាសា

VII. **បទបង្ហាញពីកិច្ចការសាធារណៈនិងនីតិកម្ម**
   a. ការផ្សាយពាណិជ្ជកម្ម (ប្រព័ន្ធផ្សព្វផ្សាយ)
   b. ការផ្សព្វផ្សាយ

VIII. **បទបង្ហាញស្តីពីការងារភ័ស្តុភារសម្រាប់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត**
   a. សន្តិសុខក្នុងការបោះឆ្នោត
   b. កញ្ចប់សន្លឹកឆ្នោតត្រូវបញ្ជូនត្រឡប់មកវិញ
   c. គ្រឿងបរិក្ខារបោះឆ្នោត

IX. **ការពិភាក្សា**
   a. ការបោះឆ្នោតតាមសំបុត្រ *(10 នាទី)*
   b. ទីតាំងទម្លាក់សន្លឹកឆ្នោត *(10 នាទី)*
   c. មណ្ឌលបោះឆ្នោត *(10 នាទី)*

d. លទ្ធភាពទទួលបានជំនួយផ្នែកភាសា *(10 នាទី)*

e. លទ្ធភាពទទួលបានការចូលរួមក្នុងការបោះឆ្នោត *(10 នាទី)*

f. ការផ្សព្វផ្សាយ *(10 នាទី)*

g. ប្រព័ន្ធបោះឆ្នោត & សន្តិសុខ*(10 នាទី)*

# County of Santa Clara

Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

---

**សវនាការសាធារណៈអំពី EAP**

**កំណត់ហេតុនៃកិច្ចប្រជុំ**

ថ្ងៃសុក្រ, 30 សីហា , 2019

បន្ទប់គណៈកម្មការ

ម៉ោង 5:30 ដល់ 7:30 ល្ងាច

70 W. Hedding St., San Jose, CA 95110

## I. សូមស្វាគមន៍

a. សេចក្តីណែនាំដោយ Shannon Bushey មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara ។ ការិយាល័យនៃមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) កំពុងទន្ទឹងរងចាំទទួលនូវមតិយោបល់ត្រឡប់ចំពោះគម្រោងរដ្ឋបាលបោះឆ្នោត (EAP) ។ ជម្រើសជាច្រើនដើម្បីផ្តល់មតិយោបល់ត្រឡប់អាចធ្វើឡើងបានតាមទម្រង់ជាក្រដាស និងតាមអនឡាញនៅលើទម្រង់មួយដែលអាចដាក់ពាក្យបាន ។

b. ROV ទទួលខុសត្រូវទៅលើវិធានចាំផ្ទះ ច្បាប់មូលដ្ឋាន និងទិដ្ឋភាពទូទៅនៃរបៀបវីរៈ ។ ROV ចាប់ផ្តើមបើកអញ្ជើញការចូលរួមរបស់គណៈកម្មាធិការផ្តល់ឱវាទលើលទ្ធភាពទទួលបាននៃសេវាភាសា (LAAC) និងគណៈកម្មាធិការផ្តល់ឱវាទលើលទ្ធភាពនៃការចេញចូលកន្លែងបោះឆ្នោត (VAAC) របស់ ROV ។ ប័ណ្ណផ្តល់មតិយោបល់ត្រូវបានណែនាំ និងចង្អុលបង្ហាញគ្មានបក្សពួកនិយម ។ ROV ក៏បានសំណូមពរមិនឲ្យមានការទះដៃ ឬជំទាស់ចំពោះការផ្តល់មតិយោបល់ឡើយ ។

c. បុគ្គលិក ROV ដែលជាអ្នកឯកទេសតាមមុខជំនាញ (SME) ត្រូវបានណែនាំឲ្យជួយផ្តល់ចម្លើយទៅដល់សំណួរនានា ចំណែកឯការបកប្រែភាសាក៏មានផ្តល់ជូនជាច្រើនភាសាផងដែរ ។

d. ការណែនាំខ្លួនរបស់ប្រធានផ្នែកជាបុគ្គលិករបស់ ROV ។

## II. បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត(VCA)

a. តំណភ្ជាប់ទៅកាន់ការផ្សាយបន្តផ្ទាល់តាមអនឡាញនៃសវនាការសាធារណៈ:
    i. https://www.youtube.com/watch?v=WxALTnXIVXc

b. ឯកសារបទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃច្បាប់ VCA៖
    i. បទបង្ហាញ – https://youtu.be/WxALTnXIVXc?t=1253
    ii. ការអនុវត្តន៍នៃច្បាប់ VCA នឹងត្រូវចាប់ផ្តើមដោយការបោះឆ្នោតបឋមប្រធានាធិបតីដែលចាប់ផ្តើមនៅថ្ងៃទី 3 ខែមីនា ឆ្នាំ 2020
    iii. រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រ (VBM) –
        1. ស្រោមសំបុត្រដែលបានបង់ថ្លៃតែម្បរួច
        2. ហិបទម្លាក់សន្លឹកឆ្នោតផ្លូវការ

3. បោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន

iv. មានរហូតដល់ទៅ 120 មណ្ឌលដែលមានសក្ដានុពលនៅទូទាំងខោនធី –

1. សេវាថ្មីបន្ថែម
2. ម៉ាស៊ីនបោះឆ្នោតថ្មី
3. បោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន

v. មានកាន់តែច្រើនថ្ងៃដើម្បីបោះឆ្នោតមុន –

1. មណ្ឌលបោះឆ្នោតនឹងបើកដំណើរការរហូតដល់ទៅដប់ថ្ងៃមុនថ្ងៃបោះឆ្នោត

vi. បោះឆ្នោតនៅក្នុងថ្ងៃតែមួយ –

1. ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ៖ ចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃតែមួយ

vii. បង្កើតឡើងនូវគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) ដោយផ្ដោតទៅលើ –

1. ទីតាំងមណ្ឌលបោះឆ្នោត
2. លទ្ធភាពទទួលបាន
3. ជំនួយផ្នែកភាសា
4. ការអប់រំ និង ការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត
5. ធាតុចូល/មតិយោបល់ត្រឡប់របស់សហគមន៍

viii. កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្ដីពី EAP ដែលបានរៀបចំកន្លងមក –

1. (2) ទូទៅ, (2) លទ្ធភាពទទួលបាន, វៀតណាម, ខ្មែរ, តាកាឡុក, អេស្ប៉ាញ, ចិន, កូរ៉េ, ហ៊ីនឌី, និង ជប៉ុន ។ នៅក្នុងកិច្ចប្រជុំទាំងអស់ យើងបានប្រមូលធាតុចូលពីសហគមន៍ដើម្បីរៀបចំចេញជាពង្រាង EAP

ix. តារាងកំណត់ពេលវេលា EAP –

1. ច្បាប់ពង្រាង > មតិយោបល់សាធារណៈ > កែសម្រួលលើពង្រាង > មតិយោបល់សាធារណៈ > ពង្រាងចុងក្រោយ

c. មតិយោបល់ ROV៖ យើងទទួលបានមតិយោបល់ត្រឡប់ និងមតិយោបល់នានាជាង 200 ។ ផែនការ EAP របស់យើងបានដាក់បង្ហោះតាមអនឡាញជាងមួយខែមកហើយ ។ តំណភ្ជាប់ទៅកាន់ធនធាន VCA ៖ https://www.sccgov.org/sites/rov/VCA/Pages/home.aspx

## III. បទបង្ហាញខាងផ្នែកបោះឆ្នោតតាមសំបុត្រ

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=1543

b. កញ្ចប់បោះឆ្នោតតាមសំបុត្រ (VBM)៖

i. ទិដ្ឋភាពទូទៅនៃការចុះឈ្មោះអ្នកបោះឆ្នោតត្រឹមថ្ងៃ 11/06/2018

ii. អ្នកបោះឆ្នោតដែលបានចុះឈ្មោះម្នាក់នឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រមួយសន្លឹក

iii. ហិបទម្លាក់សន្លឹកឆ្នោតត្រូវបានកំណត់សម្រាប់អ្នកបោះឆ្នោតចំនួន 15,000 នាក់

iv. សន្លឹកឆ្នោតផ្លូវការគំរូ, ស្រោមសំបុត្រសម្រាប់ផ្ញើត្រឡប់, សេចក្ដីណែនាំពី VBM, និងស្ទីកឺត្រូវបានដាក់បញ្ចូលនៅក្នុងកញ្ចប់នីមួយៗ

v. ទិដ្ឋភាពទូទៅនិងរូបភាពនៃការផ្ញើសម្ភារៈសន្លឹកឆ្នោតនិងសេចក្ដីណែនាំសម្រាប់យោធា/អ្នកក្រៅប្រទេស

c. ហឹបសន្លឹកឆ្នោតផ្លូវការ៖

i. បច្ចុប្បន្ននេះ ROV មានទីតាំងប្រហែលជា 90 កន្លែង (រាប់បញ្ចូលទាំងទីតាំងស្ថិតនៅខាងក្នុងនិងខាងក្រៅ) –

1. បណ្ណាល័យខោនធី/ទីក្រុង
2. សាលារៀន និង សាកលវិទ្យាល័យ
3. អគារខោនធី
4. សាលាក្រុង

ii. សន្តិសុខរបស់សន្លឹកឆ្នោតទម្លាក់ចូល –

1. ខ្សែកាបចាក់សោរ
2. ការបិទភ្ជិត
3. ការអនុលោមតាម ADA

d. លទ្ធភាពអាចបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM)

i. សម្រាប់យោធា អ្នកបោះឆ្នោតនៅក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព

ii. ទិដ្ឋភាពទូទៅនៃតំណភ្ជាប់ដែលអាចចូលទៅកាន់ការបោះឆ្នោតបានសម្រាប់កំណែប្រែជាអេឡិចត្រូនិកនៃសន្លឹកឆ្នោត អ្នកបោះឆ្នោតត្រូវតែព្រីនសន្លឹកឆ្នោតរបស់ខ្លួន ហើយផ្ញើវាត្រឡប់មកកាន់ ROV ដើម្បីឲ្យសន្លឹកឆ្នោតអាចរាប់បាន ។ ការជ្រើសរើសសន្លឹកឆ្នោតត្រូវបានជ្រើសរើសជាអេឡិចត្រូនិកតាមប្រព័ន្ធអ៊ីនធឺណិត ។ នេះជាតំណភ្ជាប់ដែលអាចចូលទៅកាន់ការបោះឆ្នោតបាន៖ https://www.sccgov.org/sites/rov/Voting/Pages/Voting-Accessibility.aspx

iii. តំណភ្ជាប់ចូលទៅកាន់វីដេអូណែនាំអំពី RAVBM ដោយប្រើប្រាស់ Democracy Live https://youtu.be/LRZ8HllghQc?t=1438

## IV. បទបង្ហាញរបស់ផ្នែកប្រព័ន្ធព័ត៌មានផែនទីភូមិសាស្ត្រ

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2189

b. ជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោតដោយការប្រើសប្រាស់ទិន្នន័យ៖

c. កក្តាទាំងឡាយនៃទីតាំងមណ្ឌលបោះឆ្នោត

i. អគារ
ii. សេដ្ឋកិច្ចសង្គម
iii. ភូមិវិទ្យា

d. ធនធានទិន្នន័យ៖

i. ការស្ទង់មតិសហគមន៍អាមេរិកកាំង –

1. ទិន្នន័យនៃការស្ទង់មតិសហគមន៍អាមេរិកកាំង (ACS) ថ្មីៗបំផុត
2. ធ្វើឡើងនៅក្នុងឆ្នាំ 2017
3. ដោយក្រសួងជំរឿនប្រជាជនអាមេរិកកាំង

ii. ទិន្នន័យមូលដ្ឋានរបស់ ROV ខោនធី Santa Clara –

1. ការរាប់ចំនួនអ្នកចុះឈ្មោះនាពេលបច្ចុប្បន្ន
2. ការបោះឆ្នោត

iii. មធ្យោបាយធ្វើដំណើរសាធារណៈ –

1. អាជ្ញាធរមិជ្រលងគមនាគមន៍ (VTA)
2. ក្រសួងគមនាគមន៍ California

iv. ទិន្នន័យ GIS ខោនធី –

1. ផ្លូវកាត់កណ្តាល
2. ខ្សែបន្ទាត់ព្រំប្រទល់ក្រុង

e. កត្តាភូមិសាស្ត្រ៖

i. ខ្សែបន្ទាត់ព្រំប្រទល់មណ្ឌលបោះឆ្នោតសម្រាប់ការដាក់ពង្រាយទីតាំង –

1. សម្រាប់មណ្ឌលបោះឆ្នោតមួយដែលដំណើរការរយៈពេល 11 ថ្ងៃ ត្រូវមានអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 50,000 នាក់ ។
   - ការប៉ាន់ស្មានតំបន់មណ្ឌលបោះឆ្នោតមានចំនួន 25 កន្លែង
2. មណ្ឌលបោះឆ្នោតមួយដំណើរការរយៈពេល 4 ថ្ងៃសម្រាប់អ្នកបោះឆ្នោតចំនួន 10,000 នាក់
   - ការប៉ាន់ស្មានតំបន់មណ្ឌលបោះឆ្នោតមានចំនួន 120 កន្លែង
3. ហឹបសន្លឹកឆ្នោតផ្លូវការ
   - ការប៉ាន់ស្មានទីតាំងហិបទម្លាក់សន្លឹកឆ្នោតមានចំនួន 80

ii. ការបង្កើតនូវខ្សែបន្ទាត់ព្រំប្រទល់ –

1. ខ្សែបន្ទាត់ព្រំប្រទល់ក្រុង
2. តំបន់ជុំវិញ
3. ផ្លូវសំខាន់ៗ
4. ផ្លូវក្នុងមូលដ្ឋាន

f. កត្តាសេដ្ឋកិច្ចសង្គមដោយប្រើប្រាស់ដំណោះស្រាយបច្ចេកវិទ្យាពង្រីកប្រសិទ្ធិភាពការសម្រេចចិត្ត (DOTS) ដើម្បីដាក់ពិន្ទុនូវកត្តាដូចខាងក្រោម៖

i. មធ្យោបាយធ្វើដំណើរសាធារណៈ
ii. លំនាំចរាចរ
iii. មជ្ឈមណ្ឌលប្រជាជន
iv. ភាសាប្រើប្រាស់ដោយជនជាតិភាគតិច
v. ពិការភាព
vi. កម្មសិទ្ធិភាពលើយានយន្តមានកម្រិតទាប
vii. ចំណូលទាប
viii. ការប្រើប្រាស់ការបោះឆ្នោតតាមសំបុត្រ
ix. ការចុះឈ្មោះអ្នកបោះឆ្នោតមានកម្រិតទាប

## V. បទបង្ហាញរបស់ផ្នែកប្រតិបត្តិការតាមសង្កាត់

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2474
b. ទិដ្ឋភាពទូទៅពីមណ្ឌលបោះឆ្នោត៖
   i. មានប្រមាណជាដល់ទៅ 125 មណ្ឌលនៅទូទាំងខោនធី Santa Clara ដំណើរមុននិងរួមទាំងថ្ងៃបោះឆ្នោតផង
   ii. អ្នកបោះឆ្នោតនឹងមានដប់មួយថ្ងៃរួមទាំងថ្ងៃចុងសប្តាហ៍ពីរផងដើម្បីបោះឆ្នោត
   iii. 20% នឹងបើកដំណើរការនៅថ្ងៃ 22 ខែកុម្ភៈ ឆ្នាំ 2020៖ ដប់ថ្ងៃមុនថ្ងៃបោះឆ្នោត
   iv. 80% នឹងបើកដំណើរការនៅថ្ងៃ 29 ខែកុម្ភៈ ឆ្នាំ 2020៖ បីថ្ងៃមុនថ្ងៃបោះឆ្នោត
   v. បច្ចេកវិទ្យាបោះឆ្នោតថ្មីនឹងជួយឲ្យអ្នកបោះឆ្នោតអាចបោះឆ្នោតនៅទីណាក៏បាននៅក្នុងខោនធី Santa Clara
   vi. នឹងផ្តល់ឲ្យមាននូវសេវាច្រើនបំផុតនៅតាមការិយាល័យរបស់មន្ត្រីគ្រប់បញ្ជីបោះឆ្នោត
c. ការអនុវត្តន៍មណ្ឌលបោះឆ្នោត៖
   i. ម៉ោងនៃប្រតិបត្តិការ –
      1. 8 ម៉ោងក្នុងមួយទីតាំង, ពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 ល្ងាចនៅថ្ងៃបោះឆ្នោត
   ii. គោលការណ៍ណែនាំពីមណ្ឌលបោះឆ្នោតទៅតាមច្បាប់ VCA –
      1. គ្រប់តំបន់ដែលមានចំនួនអ្នកបោះឆ្នោត 50K ចាំបាច់ត្រូវមានមណ្ឌលបោះឆ្នោតដែលបើកដំណើរការរយៈពេលដប់មួយថ្ងៃចំនួនមួយ
      2. គ្រប់តំបន់ដែលមានចំនួនអ្នកបោះឆ្នោត 10K ចាំបាច់ត្រូវមានមណ្ឌលបោះឆ្នោតដែលបើកដំណើរការរយៈពេលបួនថ្ងៃចំនួនមួយ
   iii. បន្ទាត់កាត់ជាក្រឡាចត្រង្គផែនទីខោនធី Santa Clara –
      1. ដើម្បីព្យាករណ៍ចំនួនមណ្ឌលបោះឆ្នោតដែលចាំបាច់សម្រាប់ខែមីនា និងខែវិច្ឆិកា ឆ្នាំ 2020
      2. ជំនួយក្នុងការជ្រើសរើសទីតាំងជាអតិបរមាទៅតាមលក្ខខណ្ឌតម្រូវផ្នែកភូមិសាស្ត្រមួយចំនួន
   iv. ការជ្រើសរើសទីតាំង –
      1. 14 ទីតាំងស្ថិតក្រោមការពិចារណា
      2. ទីតាំងដែលទំនេរនិងចម្រុះនៃលក្ខខណ្ឌផ្សេងៗ
d. ការដាក់និងបណ្តុះបណ្តាលបុគ្គលិកនៅតាមមណ្ឌលបោះឆ្នោត៖
   i. ប្រចាំម៉ោង៖ ជំនួយបន្ថែមដល់បុគ្គលិកការងារខោនធី –
      1. ការងារដឹកនាំ៖ ទទួលខុសត្រូវរួមទៅលើដំណើរការបោះឆ្នោត និងកំណត់ទិសដៅលំហូរធនធាន
      2. ជំនួយ៖ បុគ្គលិកគាំទ្រ, បុគ្គលិកជំនួយអ្នកបោះឆ្នោត
   ii. បុគ្គលិកទទួលបានប្រាក់ឧបត្ថម្ភ៖ អ្នកស្ម័គ្រចិត្ត, សិស្សវិទ្យាល័យ –
      1. ជំនួយ៖ បុគ្គលិកគាំទ្រ, បុគ្គលិកជំនួយអ្នកបោះឆ្នោត
      2. អ្នកធ្វើបដិសណ្ឋារកិច្ច៖ ទទួលស្វាគមន៍ ផ្តល់ជំនួយ ណែនាំទៅកាន់សេវាសមស្រប

iii. ពេលវេលានៃការជួលឲ្យបម្រើការ* (រួមទាំងថ្ងៃបណ្ដុះបណ្ដាល និងថ្ងៃបោះឆ្នោត) –
1. ការងារដឹកនាំ៖ 21 ថ្ងៃ
2. បុគ្គលិកជំនួយនិងអ្នកធ្វើបដិសណ្ឋារកិច្ច៖ 14 ថ្ងៃ
iv. សម្រាប់ព័ត៌មានបន្ថែម, សូមចូលទៅកាន់៖ www.sccvote.org

e. គោលដៅការងារផ្សព្វផ្សាយ៖
i. បញ្ជាក់ឲ្យច្បាស់ពីដំណើរការផ្លាស់ប្ដូរគំរូការបោះឆ្នោត និងជម្រាបដល់អ្នកបោះឆ្នោតឲ្យបានដឹងពីការកែប្រែនានាដែលនឹងចូលមកដល់
ii. ការអប់រំនិងការធ្វើឲ្យកាន់តែប្រសើរឡើងនូវបទពិសោធន៍របស់អ្នកបោះឆ្នោត
iii. បង្ហាញនិងបង្កើនការចូលរួមនៅក្នុងសហគមន៍ដែលធ្វើមិនបានល្អ
iv. សូមស្វាគមន៍ការចូលរួមរបស់សាធារណជន
v. កសាងភាពជាដៃគូដើម្បីពង្រីកឱកាសចូលរួមរបស់ពលរដ្ឋនៅក្នុងសហគមន៍ទាំងអស់ (ការអប់រំអ្នកបោះឆ្នោត និងសម្ព័ន្ធភាពផ្សព្វផ្សាយ)
vi. ផ្ដល់ឯកសារអប់រំដល់អ្នកបោះឆ្នោត, ធនធានសម្រាប់ពលរដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន

## VI. បទបង្ហាញរបស់ផ្នែកទម្រង់សន្លឹកឆ្នោត

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2819
b. ភាសាទាំងឡាយដែលតម្រូវដោយសហព័ន្ធ៖
i. អង់គ្លេស
ii. ចិន
iii. អេស្ប៉ាញ
iv. តាកាឡុក
v. វៀតណាម
c. ភាសាទាំងឡាយដែលតម្រូវដោយរដ្ឋ៖
i. កូរ៉េ
ii. ខ្មែរ
d. ភាសាទាំងឡាយដែលតម្រូវឲ្យមានពីមុនមក៖
i. ហ៊ីនឌី
ii. ជប៉ុន
e. សម្រាប់ការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីថ្ងៃទី 3 ខែមីនាឆ្នាំ 2020, សន្លឹកឆ្នោតផ្លូវការនឹងត្រូវព្រីនជាភាសាដូចខាងក្រោម៖
i. អង់គ្លេស
ii. ចិន
iii. អេស្ប៉ាញ
iv. តាកាឡុក
v. វៀតណាម
vi. កូរ៉េ

vii. ខ្មែរ
viii. ជប៉ុន
ix. ហ៊ីនឌី

f. សន្លឹកឆ្នោតគ្រប់ភាសាទាំងអស់នឹងត្រូវផលិតឡើងតាមទម្រង់ដូចខាងក្រោម៖
    i. សន្លឹកឆ្នោតជាក្រដាសសម្រាប់ម៉ាស៊ីនស្កេនអុបទិខល
    ii. សន្លឹកឆ្នោតអាចប្រើបានដោយស្ទាបលើអេក្រង់
    iii. សន្លឹកឆ្នោតអាចប្រើប្រាស់បានជាសំឡេង
    iv. សន្លឹកឆ្នោតអាចប្រើបានពីចម្ងាយសម្រាប់យោធា, អ្នកបោះឆ្នោតនៅក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព
g. សន្លឹកឆ្នោតបង្កើតឡើងក្នុងអំឡុងការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី គំនូសបម្រួញបង្ហាញពីលក្ខណៈខុសគ្នារវាងឆ្នាំ 2016 និងឆ្នាំ 2020 ៖ https://youtu.be/WxALTnXIVXc?t=2918
    i. BLD នឹងផលិតសន្លឹកឆ្នោតច្រើនទ្វេរដងនៅក្នុងឆ្នាំ 2020 ធៀបទៅនឹងឆ្នាំ 2016
h. សេចក្តីណែនាំព័ត៌មានសម្រាប់អ្នកបោះឆ្នោតនៅក្នុងខោនធី (CVIGS) និងអ៊ីប៊ុក៖
    i. មណ្ឌលបោះឆ្នោតនិងគេហទំព័រ sccvote.org នឹងមាន CVIGS និង អ៊ីប៊ុក ដែលនឹងត្រូវបកប្រែជាភាសាអងគ្លេស, ចិន, អេស្ប៉ាញ, កាតាឡុក, និងវៀតណាម
i. ការអនុវត្តន៍ច្បាប់ VCA៖
    i. ពង្រីកសេវាភាសានៅទូទាំងខោនធី
    ii. ផ្តល់ជំនួយផ្នែកភាសានៅតាមណ្ឌលបោះឆ្នោត
    iii. បង្កើនសម្ភារៈសន្លឹកឆ្នោតពីរភាសា

## VII. បទបង្ហាញរបស់ផ្នែកកិច្ចការសាធារណៈនិងនីតិកម្ម

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=3053
b. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយដោយផ្ទាល់៖
    i. កាសែត
    ii. ទូរទស្សន៍
    iii. វិទ្យុ
    iv. តាមអនឡាញ
c. ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត
    i. ផ្តល់ព័ត៌មានថ្មីៗទៅកាន់ប្រព័ន្ធផ្សព្វផ្សាយជានិច្ច = ធ្វើឲ្យសាធារណជនដឹងពីព័ត៌មានថ្មីៗជានិច្ច
        1. ជម្រើសបោះឆ្នោតថ្មីៗជាច្រើន
        2. ប្រព័ន្ធបោះឆ្នោតថ្មី
        3. ជម្រើសដែលអាចទទួលបានថ្មីនិងភាសាជាច្រើន
d. ការផ្សាយពាណិជ្ជកម្ម៖
    i. យុទ្ធនាការកន្លងមក – ការជ្រើសរើស, ការបោះឆ្នោតតាមសំបុត្រ
    ii. គ្រប់វេទិការទាំងអស់ – ព្រីន, TV, វិទ្យុ, អនឡាញ, រថយន្តក្រុង

e. យុទ្ធនាការធំជាងមុនសម្រាប់ការផ្សព្វផ្សាយ៖
    i. កាលពីមុនពីប្រាំមួយទៅប្រាំបីសប្តាហ៍មុនការបោះឆ្នោត
    ii. ការផ្សព្វផ្សាយពាណិជ្ជកម្មនឹងចាប់ផ្តើមនៅក្នុងខែកញ្ញា ដំណើរការផ្សព្វផ្សាយក្នុងរយៈពេលប្រាំមួយខែ
    iii. ក្រោយពីថ្ងៃឈប់សម្រាករហូតដល់មុនការបោះឆ្នោតនៅថ្ងៃទី 3 ខែមីនា

f. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទៅតាមភាសា៖
    i. ពង្រីកបញ្ជីឈ្មោះរបស់យើង
    ii. ធាតុចូលពីកិច្ចប្រជុំគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត
    iii. ការបោះពុម្ពផ្សាយសម្រាប់អ្នកទិញទំនិញ,វិទ្យុ, ក៏អាចមានតាមទូរទស្សន៍
    iv. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទៅតាមភាសាផ្សេងៗរួមមាន –
        1. Nichi Bei
        2. La Oferta
        3. Philippine News
        4. Viên Thao Television
        5. SOH
        6. Silconeer
        7. India West Best Indian Newspaper តាមព្រីន និងតាមអនឡាញ
    v. មាតិកាសំខាន់ៗ –
        1. ជាក់លាក់ទៅតាមសហគមន៍
        2. ខ្សែទូរស័ព្ទជំនួយដល់អ្នកបោះឆ្នោតដោយមិនគិតថ្លៃសម្រាប់ភាសានានា
        3. សន្លឹកឆ្នោតក្នុងទម្រង់ដែលអាចបោះបាន
        4. បោះឆ្នោតតាមសំបុត្រដែលអាចធ្វើទៅបានពីចម្ងាយ
    vi. ប្រព័ន្ធផ្សព្វផ្សាយសង្គម –
        1. http://www.facebook.com/sccvote/
        2. https://www.instagram.com/sccvote/
        3. https://twitter.com/sccvote/
        4. https://www.youtube.com/user/sccvote
        5. Nextdoor: @sccvote
    vii. Sports Franchises –
        1. San Francisco 49ers
        2. San Jose Sharks
        3. San Jose Earthquakes

## VIII. បទបង្ហាញរបស់ផ្នែកភ័ស្តុភារសម្រាប់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=3318

b. សន្តិសុខក្នុងការបោះឆ្នោត៖
    i. ប្រើប្រាស់ប្រព័ន្ធតាមដានសម្រាប់គ្រឿងបរិក្ខារបោះឆ្នោត

c. កញ្ចប់សន្លឹកឆ្នោតត្រូវបញ្ជូនត្រឡប់៖
    i. ប្រតិបត្តិការដឹកជញ្ជូន –
        1. បញ្ជូនមកដល់ចន្លោះពី 1-2 ថ្ងៃ
        2. ចន្លោះពី 3-4 ទីតាំងក្នុងមួយរថយន្ត

3. ចន្លោះពី 8-30 រថយន្ត / បុគ្គលិកប្រហែលជា 60 នាក់
4. បុគ្គលិក ELVS ចំនួនពីរនាក់គាំទ្រដោយបុគ្គលិកមណ្ឌលបោះឆ្នោតនៅពេលបញ្ជូនទៅដល់
5. ទីតាំងដាក់ចុះ
6. ការវេចខ្ចប់ដោយប្រើយុទ្ធសាស្ត្រដាក់កូដពណ៌ទៅតាមមណ្ឌលបោះឆ្នោត
7. យុទ្ធសាស្ត្រវេចខ្ចប់ដោយវិធានការសន្តិសុខសម្រាប់គ្រឿងបរិក្ខារងាយប៉ះពាល់
8. លក្ខខណ្ឌតម្រូវសម្រាប់សម្ភារៈផ្គត់ផ្គង់

ii. មជ្ឈមណ្ឌលភ័ស្តុភារនិងសម្ភារៈផ្គត់ផ្គង់
1. រថយន្តធំមួយគ្រឿងនិងរថយន្តធនតូចនឹងត្រូវដាក់ពង្រាយនៅទូទាំងខោនធី ផ្ទុកទៅដោយសម្ភារៈផ្គត់ផ្គង់សម្រាប់មណ្ឌលបោះឆ្នោត បច្ចេកវិទ្យាគាំទ្រ, គ្រឿងបរិក្ខារសម្រាប់ជំនួសថ្មី និងសម្ភារៈផ្គត់ផ្គង់បន្ថែមនានា

iii. ភ័ស្តុភារបញ្ជូនសន្លឹកឆ្នោតត្រឡប់ –
1. ការដឹកជញ្ជូន
2. ការដឹកជញ្ជូនហិបទម្លាក់សន្លឹកឆ្នោត VBM

d. គ្រឿងបរិក្ខារបោះឆ្នោត៖

i. ម៉ាស៊ីនបោះឆ្នោត –
1. មានដល់ទៅ (3) ក្នុងមួយមណ្ឌលបោះឆ្នោត

ii. ឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បាន –
1. មានដល់ទៅ (8) ក្នុងមួយមណ្ឌលបោះឆ្នោត

iii. បញ្ជីបោះឆ្នោតថ្មីអេឡិចត្រូនិក –
1. មានដល់ទៅ (11) ក្នុងមួយមណ្ឌលបោះឆ្នោត

iv. ម៉ាស៊ីព្រីនសន្លឹកឆ្នោតតាមតម្រូវការ –
1. មានដល់ទៅ (5) ក្នុងមួយមណ្ឌលបោះឆ្នោត

v. ម៉ាស៊ីនស្កេនសន្លឹកឆ្នោតខ្នាតតូច –
1. មានដល់ទៅ (8) ក្នុងមួយមណ្ឌលបោះឆ្នោត

vi. ម៉ាស៊ីនស្កេនសន្លឹកឆ្នោតខ្នាតធំ –
1. មានដល់ទៅ (10) ក្នុងមួយមណ្ឌលបោះឆ្នោត

vii. ស្ថានីយ៍ត្រួតពិនិត្យសន្លឹកឆ្នោតឡើងវិញ –
1. មានដល់ទៅ (16) ក្នុងមួយមណ្ឌលបោះឆ្នោត

e. កញ្ចប់សន្លឹកឆ្នោតនិងការបិទភ្ជិត៖

i. រក្សាសន្តិសុខនិងរក្សាទុកសន្លឹកឆ្នោតនៅក្នុងទីតាំងដើម្បីអាចទាញយកដុំសន្លឹកឆ្នោតមកបាន

f. គម្រោងនិងផែនការបច្ចេកវិទ្យា៖

i. ប្រព័ន្ធទូរសព្ទ Cisco (សេវាបម្រើអតិថិជនទាន់ចិត្ត)
ii. លំដាប់ផែនការគាំទ្រផ្នែកបច្ចេកវិទ្យា (ការបន្តផ្តល់សេវា)
iii. រក្សាតំណភ្ជាប់បណ្តាញទៅកាន់មណ្ឌលបោះឆ្នោតកុំឲ្យដាច់

iv. សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត (ការយល់ដឹងពីការប្រុងប្រៀបជាមុន)
v. តាមដានប្រព័ន្ធបច្ចេកវិទ្យា (ការផ្ទៀងផ្ទាត់)
vi. ប្រព័ន្ធគ្រប់គ្រងទ្រព្យ (គណនេយ្យភាព)

## IX. ការចែកចាយប័ណ្ណផ្តល់មតិយោបល់

## X. ការពិភាក្សា

a. អ្នកចូលរួម (សំណួរ 1)៖ តើខោនធីផ្សេងៗទៀតមានបានអនុវត្តិច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតប្រកបដោយជោគជ័យទេ?

i. ការឆ្លើយតបរបស់ ROV៖ នៅក្នុងឆ្នាំ 2018 មានខោនធីចំនួនប្រាំដែលបានអនុវត្ត VCA និងនៅឆ្នាំ 2020 នឹងមានខោនធីសរុបរហូតដល់ទៅ 14 ដែលនឹងអនុវត្ត ព្រមទាំងអនុវត្តិវាម្តងទៀត ។ វាស្មើនឹង 50 ភាគរយនៃការចុះឈ្មោះរបស់រដ្ឋ ។ ខោនធីរបស់យើងកំពុងតែបានធ្វើការជាមួយរដ្ឋនិងខោនធីនានាមួយឆ្នាំកន្លងមកនេះ ហើយបានជួបជាមួយនឹងផ្នែកដែលពាក់ព័ន្ធនានា ដើម្បីសួរនូវសំណួរជាក់លាក់នានាដែលបានអនុវត្តិការងារនោះកន្លងមកនៅក្នុងខោនធីដទៃផ្សេងទៀត ។ យើងបានធ្វើសន្និសិទតាមទូរសព្ទទូទាំងរដ្ឋជាច្រើនដង ។ យើងកំពុងតែបានធ្វើការជាមួយខោនធីផ្សេងៗទៀតនិងរដ្ឋ ។ ខោនធីទាំងអស់បានអនុវត្តិប្រកបដោយជោគជ័យ ហើយយើងអាចមើលឃើញពីអ្វីដែលជាបញ្ហាប្រឈមរបស់ពួកគេកំពុងមាន ។ បញ្ហាប្រឈមទាំងឡាយរួមមាន ការជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោត ពីព្រោះចំនួននៃថ្ងៃដែលទីតាំងចាំបាច់ត្រូវបើកដំណើរការនិងពេលដំណើរការដែលចាំបាច់នៅតាមការិយាល័យរបស់យើងប្រៀបធៀបវាទៅនឹងការិយាល័យបោះឆ្នោតដែលត្រូវការពេលបើកដំណើរការតែមួយថ្ងៃនោះ ។ បច្ចុប្បន្ននេះ ជាមួយនឹងទីតាំងទាំង 125 របស់យើង យើងមិនអាចប្រើប្រាស់បានច្រើនឡើយនូវការិយាល័យបោះឆ្នោតដែលយើងធ្លាប់ប្រើពីមុនមកដោយសារតែទំហំ លទ្ធភាពចេញចូល និងការចតយានយន្តនោះ ។ យើងធ្លាក់មកនៅ 20% ចុងក្រោយដែលត្រូវស្វែងរកទីតាំង ។ បញ្ហាមួយទៀតនោះគឺការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោត និងបុគ្គលិកជំនួយបន្ថែម ។ គឺដូចគ្នាទៅនឹងពេលវេលាកំណត់សម្រាប់ទីតាំងដែរ យើងត្រូវការស្វែងរកមនុស្សដែលអាចធ្វើការពីពីរទៅបីសប្តាហ៍នៅតាមមណ្ឌលបោះឆ្នោត ។ នៅពេលយើងទទួលបានមតិយោបល់ត្រឡប់ទាំងអស់រួចមក យើងនឹងផ្តោតទៅលើការជ្រើសរើសនិយោជិកជំនួយបន្ថែម ហើយយើងនឹងបន្តដំណើរការជ្រើសរើសបុគ្គលិកដែលទទួលបានប្រាក់ឧបត្ថម្ភ ។

ii. ការឆ្លើយតបរបស់ ROV៖ អ្នកស្ម័គ្រចិត្តទាំងអស់ដែលបានជួយយើងកន្លងមកដែលពួកគេជួយយើងតែមួយថ្ងៃ ។ បច្ចុប្បន្នយើងនឹងត្រូវការជំនួយរហូតដល់ទៅ 11 ថ្ងៃ ។ ការធ្វើកាលវិភាគនឹងត្រូវជួបការលំបាក ។ យើងនឹងចាំបាច់សុំឲ្យមនុស្សដាក់ពាក្យធ្វើជានិយោជិកខោនធីបើទោះបីជាវាជាកិច្ចសន្យាជួលរយៈពេលខ្លីក៏ដោយ ។ បញ្ហាប្រឈមគឺត្រូវស្វែងរកបុគ្គលិករយៈពេលខ្លីដើម្បីជួយយើងសម្រាប់រយៈពេលពេញមួយចុងសប្តាហ៍ ។ គ្រឿងបរិក្ខានឹងថ្មី ហើយអ្វីៗគ្រប់យ៉ាងនឹងចាំបាច់ត្រូវរៀបចំឡើងវិញនិងបណ្តុះបណ្តាលឡើងវិញ ។ ពួកគេត្រូវប្តេជ្ញាចិត្តចូលរួមវគ្គសិក្សាក៏ដូចជាការបណ្តុះបណ្តាលផងដែរ ។ យើងនឹងមានបញ្ហាប្រឈមជាច្រើន ហើយយើងនឹងត្រូវរៀនបណ្តើរធ្វើបណ្តើរ ។

b. អ្នកចូលរួម (សំណួរ 2)៖ មណ្ឌលបោះឆ្នោតបើកដំណើរការ 13 ម៉ោង ចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ប៉ុន្តែបើកដំណើរការបានតែ 8 ម៉ោងប៉ុណ្ណោះ តើមណ្ឌលបោះឆ្នោតទាំងនោះបិទមិនដំណើរការ 5 ម៉ោង ឬក៏ត្រូវបិទនិងត្រូវបើកដោយមិនរលូនមែនទេ?
    i. ការឆ្លើយតបរបស់ ROV៖ នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងត្រូវបើកដំណើរការចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ។ នៅមុនថ្ងៃបោះឆ្នោត ហើយនិងរយៈពេល 10 ថ្ងៃមុន ពេលវេលាមណ្ឌលបោះឆ្នោតនឹងត្រូវរៀបចំឲ្យរួចជាស្រេច ប៉ុន្តែពួកគេនឹងពង្រាយ ដោយមានមណ្ឌលខ្លះនឹងបើកដំណើរការច្រើននៅពេលល្ងាច និងខ្លះទៀតនៅក្នុងពេលព្រឹក ។
    ii. ការឆ្លើយតបរបស់ ROV៖ ដើម្បីបញ្ជាក់ពីតម្រូវការសម្រាប់មណ្ឌលមួយចំនួនដែលបើកដំណើរការមុនថ្ងៃបោះឆ្នោតនោះ វានឹងត្រូវបើកដំណើរការយ៉ាងហោចណាស់ក៏ 8 ម៉ោងដែរក្នុងមួយថ្ងៃ ។ នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងត្រូវបើកដំណើរការចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ។
c. អ្នកចូលរួម (សំណួរ 3)៖ តើពាក្យថា "សង្កាត់" ប្រើបានយ៉ាងដូចម្តេចនៅក្រោមប្រព័ន្ធបោះឆ្នោតថ្មី?
    i. ការឆ្លើយតបរបស់ ROV៖ យើងនឹងនៅតែមានប្រើសង្កាត់ ដោយយើងនឹងរៀបចំអ្នកបោះឆ្នោតយើងទៅតាមសង្កាត់សម្រាប់គោលបំណងបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យសង្កាត់មិនសំខាន់ដូចមុនទៀតទេ ពីព្រោះយើងអាចទៅបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បានដែរ ។ ពុំមានទំនាក់ទំនងគ្នាទេរវាងពាក្យថាសង្កាត់ និងមណ្ឌលបោះឆ្នោតនោះ ។ សង្កាត់ក្លាយជាផ្នែករបាយការណ៍ស្តីពីភូមិសាស្ត្រ ។ នៅពេលអ្នកមើលទៅសេចក្តីថ្លែងពីការបោះឆ្នោតរបស់យើង ដែលយើងបានបំបែកជាតូចៗនូវលទ្ធផលបោះឆ្នោតទៅជាសង្កាត់ វានឹងនៅតែមានពាក្យសង្កាត់នៅតែពាក់ព័ន្ធជាមួយវា ។ បច្ចុប្បន្ននេះ យើងអាចទៅកាន់មណ្ឌលបោះឆ្នោតណាមួយដែលយើងជ្រើសរើសទៅបាន ។
d. អ្នកចូលរួម (សំណួរ 4)៖ តើខ្សែព្រំប្រទល់ចំនួនប្រជាជន 50k និង 10k គ្របដណ្តប់ទៅលើការប្រែប្រួលចំនួនប្រជាជននៅពេលថ្ងៃទេ?
    i. ការឆ្លើយតបរបស់ ROV៖ ទិន្នន័យរបស់យើងគឺផ្អែកទៅលើការចុះឈ្មោះរបស់អ្នកបោះឆ្នោតនាពេលបច្ចុប្បន្នរបស់យើង ដោយបន្ថែមចំនួន 50 ភាគរយបន្ថែមនៃចំនួនប្រជាជនដែលមិនបានចុះឈ្មោះ ។ តាមរយៈទិន្នន័យជំរឿន យើងរាប់លំនៅដ្ឋាននិងអាសយដ្ឋាន ។ សម្រាប់ពេលថ្ងៃ ទិន្នន័យតាមដានកន្លែងដែលមនុស្សបោះឆ្នោតមិនបាន ។
e. អ្នកចូលរួម (សំណួរ 5)៖ តើការបោះឆ្នោតធ្វើទៅយ៉ាងដូចម្តេចនៅតាមមណ្ឌលបោះឆ្នោតដែលដំណើរការ 8 ម៉ោងក្នុងមួយថ្ងៃ ត្រូវរក្សាដំណើរការរហូតដល់មណ្ឌលបោះឆ្នោតបិទនៅយប់ថ្ងៃបោះឆ្នោតមែនទេ?
    i. ការឆ្លើយតបរបស់ ROV៖ សន្លឹកឆ្នោតភាគច្រើននោះគឺនៅតាមមណ្ឌលបោះឆ្នោតនឹងត្រូវដាក់ចូលទៅក្នុងលិបិក្រមបញ្ជីបោះឆ្នោត ដែលអ្នកបោះឆ្នោតនឹងបញ្ចូលវាទៅក្នុងម៉ាស៊ីន ។ វានឹងរក្សាលទ្ធផលទុកនៅក្នុងប្រព័ន្ធចងចាំខាតឌ្រីច ហើយលិបិក្រមនឹងទម្លាក់ខាតឌ្រិចចុះទៅក្នុងប្រអប់ចាក់សោរដ៏គត់មត់មួយ ។ យើងនឹងទទួលខុសត្រូវចំពោះសន្លឹកឆ្នោតនៅពេលបញ្ចប់មួយថ្ងៃៗ ។ យើងនឹងបើកត្រាបិទភ្ជិត ហើយដឹកជញ្ជូនវាត្រឡប់មកវិញ រក្សាទុកដោយសុវត្ថិភាពនៅក្នុងការិយាល័យរបស់យើងពីមួយយប់ទៅមួយយប់ ។ យើងពិតជាមានពិធិការការពារជាច្រើនដំណាក់កាលដែលយើងត្រូវអនុវត្តតាម ។ សន្លឹកឆ្នោតដែលបោះរួចភាគច្រើននឹងត្រូវដាក់ចូលទៅក្នុងបញ្ជីរនោះ ។ លើកលែងតែចំពោះសន្លឹកឆ្នោតបណ្តោះអាសន្ន ឬសន្លឹកឆ្នោតអ្នកចុះឈ្មោះដោយមានលក្ខខណ្ឌ (CVR) ឬសន្លឹកឆ្នោត VBM ទេ ដែលមគេបោះចោល ។ ដូចគ្នាទៅនឹងការិយាល័យបោះឆ្នោតពីដើមដែរ យើង

នឹងវាយត្រាភ្ជិតនិងរក្សាស្បោងដាក់សន្លឹកឆ្នោតឲ្យមានសុវត្ថិភាពនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ សន្លឹកឆ្នោតទាំងនោះនឹងត្រូវដាក់នៅក្នុងស្រោមសំបុត្រដាក់ចូលទៅក្នុងហិបសន្លឹកឆ្នោតដោយនៅចុងក្រោយយើងនឹងកាត់ត្រាភ្ជិតហើយដឹកជញ្ជូនវាទៅកាន់ការិយាល័យរបស់យើង ។ យើងមានផែនការត្រៀមរួចជាស្រេចក្នុងករណីដែលយើងប្រឈមជាមួយនឹងចំនួនមនុស្សចូលរួមច្រើន ហើយយើងត្រូវការហិបសន្លឹកឆ្នោតបន្ថែមជាចាំបាច់នោះ យើងនឹងមានទ្រុងដែកចល័តទីបាននៅលើរទេះដែលយើងនឹងដាក់បន្ថែមនូវហិបសន្លឹកឆ្នោតនៅក្នុងទ្រុងសុវត្ថិភាពនោះ ។

f. អ្នកចូលរួម (សំណួរ 6)៖ មើលនៅលើគេហទំព័រ និងផែនការសកម្មភាពអ្នកបោះឆ្នោតនោះ យើងមានចំនួនប្រជាជនដែលគ្មានទីលំនៅកើនឡើងនៅលើរបាយការណ៍ខោនធីនាពេលថ្មីៗនេះ ។ ខ្ញុំឆ្ងល់ថាតើយើងមានផែនការដែលអាចឲ្យអ្នកបោះឆ្នោតបោះបានសម្រាប់ពលរដ្ឋរស់នៅម្តុំយើងដែលគ្មានផ្ទះសម្បែងនោះបានទេ ។ នៅមុនច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតនោះ ខ្ញុំបានមើលត្រួសៗនៅលើគេហទំព័រនិងរកឃើញនូវលើគេហទំព័ររបស់សម្ព័ន្ធជាតិនៃភាពគ្មានទីលំនៅ ពួកគេមានព័ត៌មានល្អៗស្តីពីសិទ្ធិបោះឆ្នោតសម្រាប់ជនគ្មានផ្ទះសម្បែង ប៉ុន្តែវាមិនត្រូវបានធ្វើបច្ចុប្បន្នភាពដោយដាក់បញ្ចូលនូវអ្វីដែលយើងមានសម្រាប់ច្បាប់ស្តីពីសិទ្ធិរបស់អ្នកបោះឆ្នោតនោះទេ ។ ខ្ញុំយល់ថាការផ្សព្វផ្សាយនឹងពិបាកទៅដល់ក្រុមប្រជាជនប្រភេទនេះ ប៉ុន្តែតើមានទីកន្លែងដែលពួកគេអាចទៅដើម្បីស្វែងយល់ពីសិទ្ធិបោះឆ្នោតរបស់ពួកគេទេ ហើយថាតើវាជះឥទ្ធិពលដល់ច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោតយ៉ាងម៉េចដែរ ?

i. ការឆ្លើយតប៖ ដើម្បីស្វែងយល់អំពីសិទ្ធិបោះឆ្នោតរបស់គេ ពួកគេអាចមកកាន់ការិយាល័យរបស់យើង ពួកគេអាចទូរសព្ទមកកាន់យើងនៅពេលណាក៏បាន យើងមានព័ត៌មាននៅលើគេហទំព័ររបស់យើង ដែលអាចថាមិនចូលប្រើប្រាស់បានគ្រប់ពេល ប៉ុន្តែនៅតាមមណ្ឌលបោះឆ្នោតសម្រាប់រយៈពេល 11 ថ្ងៃ ពួកគេអាចទៅកាន់មណ្ឌលណាមួយនៃមណ្ឌលបោះឆ្នោតទាំងនោះ យើងអាចផ្តល់ដល់ពួកគេនូវព័ត៌មានស្តីពីសិទ្ធិរបស់ពួកគេ ហើយយើងអាចចុះឈ្មោះឲ្យពួកគេបាន ។ ពួកគេក៏អាចបោះឆ្នោតជា CVR និងបោះឆ្នោតតាមរយៈសន្លឹកឆ្នោត CVR បានផងដែរ ។ តើខ្ញុំឆ្លើយសំណួររបស់អ្នកទេ?

ii. ការឆ្លើយតបរបស់អ្នកចូលរួម៖ បាទ /ចាំះ ខ្ញុំពិតជាមិនអាចរកវាឃើញនៅលើគេហទំព័រទេ ដែលនោះធ្វើឲ្យខ្ញុំមានការព្រួយបារម្ភខ្លះ ពីព្រោះបច្ចុប្បន្ននេះកម្រិតលទ្ធភាពចូលរួមបានរបស់អ្នកបោះឆ្នោតមានច្រើនណាស់ ដែលវាជាការប្រសើរបំផុតមិនធ្លាប់មានពីមុនមក ប៉ុន្តែតើនោះមានន័យថាវានឹងអាចចូលរួមបានដោយក្រុមប្រជាជនដែលគ្មានផ្ទះសម្បែងទេ?

iii. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំះ វាពិតណាស់ ពួកគេគប្បីមានលទ្ធភាពចូលរួមបានដូចគ្នាទៅនឹងអ្នកបោះឆ្នោតដទៃផ្សេងទៀតដែរ ។ បច្ចុប្បន្ននេះយើងចុះឈ្មោះឲ្យ ប្រសិនបើនរណាម្នាក់មិនមានអាសយដ្ឋានដើម្បីបញ្ចូលក្នុងបញ្ជីលំនៅដ្ឋានរបស់គេ យើងអាចយកលេខផ្លូវកាត់ ដូច្នេះយើងអាចផ្តល់ឲ្យពួកគេនូវប្រភេទសន្លឹកឆ្នោតជាក់លាក់ ។

iv. ការឆ្លើយតបរបស់អ្នកចូលរួម៖ ប្រសិនបើពួកគេត្រូវប្តូរ RV របស់គេរៀងរាល់ 72 ម៉ោងនោះ តើនោះដំណើរការយ៉ាងដូចម្តេចប្រសិនបើផ្លូវកាត់ខុសគ្នារាល់ដងនោះ?

v. ការឆ្លើយតបរបស់ ROV៖ នៅពេលគេចេញទៅបោះឆ្នោត គេអាចចុះឈ្មោះឡើងវិញបាន ហើយគេអាចប្តូរការចុះឈ្មោះរបស់គេបានតាមអនឡាញបានរាល់ថ្ងៃទៅតាមទីកន្លែងដែលគេចង់បោះឆ្នោត ។ ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌនឹងអនុញ្ញាតឲ្យយើងបោះឆ្នោតបាននៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន ។

g. អ្នកចូលរួម (សំណួរ 7)៖ សម្រាប់ព្រំប្រទល់បោះឆ្នោត 10k និង 50k និងទាក់ទងទៅនឹងទិន្នន័យពេលថ្ងៃសម្រាប់ខោនធី Palo Alto ចំនួនប្រជាជនបោះឆ្នោតរបស់ខ្លួនមានរហូតដល់បីដងនៅពេលថ្ងៃ ។ ខ្ញុំសម្បាយចិត្តដែលអ្នកធ្វើការនៅក្នុងទីតាំងមណ្ឌលបោះឆ្នោតមានចំនួនប្រជាជន 50k ប៉ុន្តែខោនធី Palo Alto អាចមានចរាចរណ៍ចង្អៀតនៅលើផ្លូវ 101 ហើយវាពិបាកនិយាយពីរបៀបដែលអ្នកបោះឆ្នោតជ្រើសរើសបោះឆ្នោតជាមួយនឹងពេលវេលាពង្រីកបន្ថែម ។ ខ្ញុំបារម្ភថាតំបន់មួយចំនួននឹងត្រូវមានសុទ្ធតែមនុស្ស ដែលកំពុងរស់នៅទីនោះ ឬអាចមិនរស់នៅទីនោះ ប៉ុន្តែពួកគេរស់នៅក្នុង San Jose ហើយអ្នកកំពុងរាប់ការបោះឆ្នោតរបស់គេនៅក្នុង San Jose ជាចំនួនមណ្ឌលបោះឆ្នោតរបស់គេ ។ តើមានមធ្យោបាយអីក្នុងកំឡុងពេលចាប់ផ្តើមការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតី ដែលយើងនឹងតាមដានពីលក្ខណៈដែលតំបន់មួយចំនួនកំពុងត្រូវបានប្រើប្រាស់ច្រើនជាង ហើយតំបន់ផ្សេងៗទៀតត្រូវបានប្រើប្រាស់តិចជាងនោះ?

   i. ការឆ្លើយតបរបស់ ROV៖ យើងនឹងអាចមើលឃើញមានមណ្ឌលបោះឆ្នោតមួយចំនួនមានសកម្មភាពច្រើនជាង មានសន្លឹកឆ្នោតដែលបានបោះច្រើនជាង ។ល។ ប្រហែលជានៅពេលអនាគតយើងអាចស្វែងរកមណ្ឌលបោះឆ្នោតបន្ថែមនៅក្នុងតំបន់ទាំងនោះ ហើយសម្រាប់ការបោះឆ្នោតនេះយើងពិតជាអាចយកមកពិចារណា ដើម្បីឲ្យឃើញថាតើយើងអាចបង្កើនបាននៅក្នុងតំបន់ជាក់លាក់មួយចំនួន ។

   ii. ការឆ្លើយតបរបស់ ROV៖ យើងចង់យកចំនួនប្រជាជននៅពេលថ្ងៃមកពិចារណា ប៉ុន្តែមិនមានទិន្នន័យដែលអាចរកបាន ។ នៅក្នុងតំបន់ដែលយើងគិតថានឹងមានការងារច្រើនដែលស្ថិតនៅជិតប្រហាក់ប្រហែលទៅនឹងស្តង់ដាទីក្រុងនោះ យើងបានព្យាយាមធ្វើឲ្យចំនួនតូចជាង 50k បន្តិចហើយនៅក្នុងតំបន់លំនៅដ្ឋានយើងអាចដាក់មនុស្សបានច្រើនជាង ។

h. អ្នកចូលរួម (សំណួរ 8)៖ អ្វីកើតឡើងនៅពេលនរណាម្នាក់បោះឆ្នោតដោយសំបុត្រហើយសម្រេចចិត្តបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតវិញ ។

   i. ការឆ្លើយតបរបស់ ROV៖ ប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតរបស់យើងនឹងអាចចូលបានពីគ្រប់មណ្ឌលបោះឆ្នោតតាមរយៈឧបករណ៍បោះឆ្នោតអេឡិចត្រូនិក ។ យើងនឹងអាចមើលដឹងថាតើបុគ្គលនេះបានបោះឆ្នោតហើយឬនៅ ។ យើងអាចប្តូរពីការចុះហត្ថលេខានៅលើបញ្ជីឈ្មោះទៅប្រើម៉ាស៊ីនស្កេនរកឈ្មោះវិញ ។ បច្ចុប្បន្ននេះបុគ្គលិកនឹងអាចរកមើលឈ្មោះរបស់អ្នកឃើញនៅលើឧបករណ៍បោះឆ្នោតអេឡិចត្រូនិករបស់យើង ហើយអាចចូលទៅកាន់ព័ត៌មានដែលនឹងជាព័ត៌មានស្តីពីការចុះឈ្មោះបោះឈ្មោះថ្មីៗរបស់អ្នក ហើយនិងព័ត៌មានបោះឆ្នោតដោយសំបុត្រ ។ យើងនឹងអាចប្រាប់អ្នកបានប្រសិនបើអ្នកបោះឆ្នោតបានបោះឆ្នោតរួច ហើយអាចដឹងបានប្រសិនបើគាត់បានបោះ – យើងនឹងមិនផ្តល់សន្លឹកឆ្នោតដល់អ្នកទាំងនោះដែលបានបោះរួចនោះទេ ។ មានសន្លឹកឆ្នោតបណ្តោះអាសន្ន (PV) ផងដែរ -- យើងមិនអាចបដិសេធសិទ្ធិបោះឆ្នោតរបស់នរណាម្នាក់បានឡើយនៅពេលពួកគេមកកាន់ការិយាល័យបោះឆ្នោត ប៉ុន្តែប្រសិនបើយើងកំណត់បានថាបុគ្គលម្នាក់នោះបានបោះឆ្នោតរួច ហើយគេនៅតែទាមទារបោះទៀត យើងនឹងអនុញ្ញាតឲ្យពួកគេបោះបាន ប៉ុន្តែពួកគេត្រូវតែដាក់សន្លឹកឆ្នោតរបស់គេចូលទៅក្នុងស្រោមសំបុត្របណ្តោះអាសន្ន ដែលត្រូវបានរក្សាទុកដាច់ដោយឡែក ហើយមិនត្រូវបានរាប់បញ្ចូលនៅឯមណ្ឌលបោះឆ្នោតឡើយ ។ ស្រោមសំបុត្រ PV នឹងត្រឡប់មកកាន់ការិយាល័យយើងវិញ ហើយយើងនឹងរកមើលព័ត៌មានរបស់គេដែលគេបានបំពេញនៅលើស្រោមសំបុត្រ ។ សន្លឹកឆ្នោតនឹងមិនត្រូវបានបើកឡើយប្រសិនបើពួកគេបានបោះរួចហើយនោះ ។

i. អ្នកចូលរួម (សំណួរ 9)៖ តើម៉ាស៊ីនរាប់សន្លឹកឆ្នោតរបស់អ្នកត្រូវបានផ្តាច់ចេញពីអ៊ីនធឺណិតទេ ប្រសិនបើមិនបានផ្តាច់ទេ តើអ្នកអាចធានាថាវាមិនត្រូវបានវាយប្រហារបានទេ?

    i. ការឆ្លើយតបរបស់ ROV៖ ប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើងគឺត្រូវបានផ្តាច់ចេញទាំងស្រុងពីអាកាស មានន័យថាវាស្ថិតនៅលើបណ្តាញកំព្យូទ័រឯកជនដែលម៉ាស៊ីនគណនាត្រូវបានភ្ជាប់ទៅខ្លួនវាតែប៉ុណ្ណោះ ហើយនឹងភ្ជាប់ទៅកាន់ម៉ាស៊ីនរាប់មេតែប៉ុណ្ណោះ ។ ពួកវាមិនត្រូវបានប៉ះពាល់ទៅនឹងបណ្តាញកុំព្យូទ័រផ្ទៃក្នុងរបស់ខោនធី ឬ ប្រព័ន្ធអ៊ីនធឺណិតខាងក្រៅឡើយ ។ ឧបករណ៍គណនាសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ សុទ្ធតែមិនស្ថិតនៅលើប្រព័ន្ធអ៊ីនធឺណិតទាំងអស់ ពួកវាមិនបញ្ជូនលទ្ធផលត្រឡប់មកយើងវិញទេ យើងដោយផ្ទាល់ត្រូវតែយកដុំឧបករណ៍ផ្ទុកទិន្នន័យចេញពីម៉ាស៊ីន ហើយត្រូវបើកដឹកវាយកត្រឡប់មកកាន់ការិយាល័យវិញដោយផ្ទាល់ ។ យើងក៏បានត្រៀមប្រូតាកូលសុវត្ថិភាពជាច្រើនរួចជាស្រេចដែរ យើងនឹងយក USBs ដែលស្ថិតនៅខាងក្រៅបណ្តាញ ហើយដោតភ្ជាប់វាទៅនឹងម៉ាស៊ីនណាមួយដែលត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើង ។ នៅពេលយើងបង្ហោះលទ្ធផលនៅលើគេហទំព័ររបស់យើង វាមិនត្រូវបានញូនចេញតាមប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើងទេ ។ អ្វីដែលយើងកំពុងធ្វើគឺយើងកំពុងបញ្ចេញលទ្ធផលមួយច្បាប់ ហើយរក្សាវាដាក់នៅលើឧបករណ៍ផ្ទុកទិន្នន័យ USB ហើយក៏ដើរយកវាទៅដាក់នៅម៉ាស៊ីនមួយទៀតដែលត្រូវបានភ្ជាប់ទៅនឹងអ៊ីនធឺណិត ហើយយើងបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធ ។ លទ្ធផលដែលអ្នកមើលឃើញនៅតាមផ្ទះជាច្បាប់ចតចម្លង ដូច្នេះប្រសិនបើនរណាម្នាក់វាយប្រហារនៅលើគេហទំព័រដែលបង្ហាញលទ្ធផល ពួកគេនឹងមិនកែប្រែការបោះឆ្នោតឡើយ ។ ក្រោយពី USBs ត្រូវបានដោតចូលទៅនឹងឧបករណ៍ហើយ វានឹងត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក ធ្វើបែបនេះវាមិនត្រឡប់មកវិញ និងប៉ះពាល់ដល់បណ្តាញសុវត្ថិភាពយើងឡើយ ។

j. អ្នកចូលរួម (សំណួរ 10)៖ តើខ្ញុំដូចជាបានឮអ្នកនិយាយពីការគណនាឬរាប់សន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតក្រោយការបិទបញ្ចប់នៅយប់បោះឆ្នោតទេ?

    i. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំ៎ នៅពេលអ្នកបោះឆ្នោតទៅបោះឆ្នោត ពួកគេនឹងយកសន្លឹកឆ្នោតរបស់គេទៅកាន់ម៉ាស៊ីនគណនាសម្លេងឆ្នោត ។ ប្រព័ន្ធបោះឆ្នោតនឹងប្រាប់គេថា តើគេបានបោះលើស គូសខុសលើសន្លឹកឆ្នោត ឬជ្រើសរើសជម្រើសច្រើនពេក ។ នៅពេលគេដាក់សន្លឹកឆ្នោតឲ្យឆ្លងកាត់បរិក្ខាបោះឆ្នោត ហើយបោះវាភ្លាម សន្លឹកឆ្នោតនឹងត្រូវបានគណនាចូលទៅក្នុងប្រព័ន្ធបោះឆ្នោត ហើយវាក៏ទម្លាក់សន្លឹកឆ្នោតចូលទៅក្នុងប្រអប់សុវត្ថិភាពមួយ ។ នៅទីបញ្ចប់នៃយប់បោះឆ្នោត ខាឌ្រីចនឹងត្រូវយកត្រឡប់ទៅកាន់ការិយាល័យ ROV ដែលជាកន្លែងយើងភ្ជាប់វាទៅនឹងប្រព័ន្ធរបស់យើង ហើយបញ្ជីឆ្នោតទាំងអស់នឹងចេញមកជាមួយគ្នាពីអ្វីដែលយើងបង្ហោះផ្សាយនៅយប់បោះឆ្នោត ។

k. អ្នកចូលរួម (សំណួរ 11)៖ តើឧបករណ៍ស្កែនតារាងសន្លឹកឆ្នោតចាប់យកសញ្ញាគូសខុសនៅលើសន្លឹកឆ្នោត ហើយបញ្ជូនវាត្រឡប់ទៅកាន់អ្នកបោះឆ្នោតដើម្បីកែតម្រូវទេ?

    i. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំ៎ វាទើបតែត្រូវបានពន្យល់រួចអម្បាញ់មិញ ។

l. អ្នកចូលរួម (សំណួរ 12)៖ ខ្ញុំគិតថាអ្នកបានឆ្លើយវារួចហើយ ។ ខ្ញុំបារម្ភពីពេលដែលវាត្រូវបានគណនារាល់ថ្ងៃ ។ ខ្ញុំបានឮរឿងរាវជាច្រើនពីការបោះឆ្នោតដែលត្រូវបានគេប្តូរ ។ ខ្ញុំគិតថានៅពេលអ្នកនិយាយពីសុវត្ថិភាព ខ្ញុំនៅតែបារម្ភថាទំរាំដល់ពេលពួកគេទទួលបានលទ្ធផល ការបោះឆ្នោតត្រូវបានប្តូរ ។ ចុះបើក្នុងករណីដែលពួកគេបានបោះឆ្នោត ហើយពួកគេយល់ថាពួកគេមិនចង់បោះឆ្នោតអញ្ចឹងទេ តើមានមធ្យោបាយអ្វីដែលអាចកែប្រែការបោះឆ្នោតរបស់គេបានទេ?

i. ការឆ្លើយតបរបស់ ROV៖ យើងនឹងផ្តល់នូវជម្រើសពីរនៅក្នុងមណ្ឌលបោះឆ្នោត ។ ជម្រើសមួយនឹងត្រូវយកសន្លឹកឆ្នោតក្រដាសដោយផ្ទាល់ ហើយគូសនៅលើជម្រើសទាំងឡាយរបស់អ្នកដោយគ្មានផ្ទាំងជ្រើសរើសជាអេឡិចត្រូនិក ។ របៀបម្យ៉ាងទៀតនោះ យើងនឹងមានឧបករណ៍គូសសន្លឹកឆ្នោតជាអេឡិចត្រូនិកផ្តល់ឱ្យ ។ វាមានលក្ខណៈដូចជាការស្ទាបលើផ្ទៃអេក្រង់ដែលយើងប្រើនាពេលបច្ចុប្បន្ននេះ ប៉ុន្តែជំនួសឲ្យការដាក់សន្លឹកឆ្នោតនៅលើអង្គចងចាំរបស់ម៉ាស៊ីននោះ វានឹងព្រីនសន្លឹកឆ្នោតចេញមកដោយមានការជ្រើសរើសទៅតាមអ្វីដែលបានគូសនៅលើវា ។ អ្នកបោះឆ្នោតនឹងមានឱកាសដើម្បីពិនិត្យមើលវាឡើងវិញ និងបញ្ចូលសន្លឹកឆ្នោតរបស់គេទៅក្នុងឧបករណ៍គណនាសម្លេងឆ្នោត ។ មានក្រដាសសន្លឹកឆ្នោតព្រៀងដែលអ្នកបោះឆ្នោតមានឱកាសដើម្បីផ្ទៀងផ្ទាត់និងធ្វើឲ្យប្រាកដថាការជ្រើសរើសត្រូវបានគូសត្រឹមត្រូវមុននឹងពួកគេបោះវា ។

ii. ការឆ្លើយតបរបស់ ROV៖ នៅក្នុងរដ្ឋ California យើងក៏បានកំណត់ឲ្យមានការធ្វើសវនកម្មក្រោយការបោះឆ្នោតផងដែរ នៅតាមកន្លែងដែលយើងនឹងកំណត់ប៉ាន់គំរូដោយចៃដន្យទៅលើសន្លឹកឆ្នោតក្រដាស និងការរាប់សន្លឹកឆ្នោតក្រដាសដោយផ្ទាល់ដៃ ហើយប្រៀបធៀបវាទៅនឹងលទ្ធផលនៃការបោះឆ្នោត។ យើងអាចចាប់យកបានប្រសិនបើមានលំនាំដូចៗគ្នានៃអ្វីមួយដែលកើតឡើងចំពោះលទ្ធផលចេញមកពីសកម្មភាពទុច្ចរិតឬជាកំហុសសុទ្ធសាធ ។ ជាមួយនឹងគ្រឿងបរិក្ខារថ្មី យើងនឹងមានមុខងារមួយដែលត្រូវបានគេហៅថាជាការវិនិច្ឆ័យ ។ ប្រសិនបើអ្នកបោះឆ្នោតបង្កើតឲ្យមានកំហុសនៅលើរបៀបគូសសន្លឹកឆ្នោត ហើយបណ្តាលឲ្យម៉ាស៊ីនអានខុស យើងអាចបដិសេធចោលនូវជម្រើសដែលបានគូសនៅលើវា ហើយត្រូវប្រាកដថាជម្រើសជាចេតនារបស់អ្នកបោះឆ្នោតត្រូវបានជ្រើសរើសយក ។ អ្វីដែលប្រព័ន្ធបោះឆ្នោតធ្វើនោះគឺបង្កើតនូវការធ្វើសវនាកម្មសាកល្បងទៅលើសកម្មភាពណាមួយដែលយើងបានធ្វើនៅលើសន្លឹកឆ្នោតទាំងនោះ ។ ជាទូទៅយើងមានអ្នកសង្កេតការណ៍ចូលមក ហើយយើងអាចបង្ហាញដល់ពួកគេពីគន្លងគ្រប់សន្លឹកឆ្នោតនីមួយៗ និងបង្ហាញដល់ពួកគេនូវរូបភាពនៃសន្លឹកឆ្នោត ក៏ដូចជាស្វែងរកសន្លឹកឆ្នោតក្រដាសផងដែរ ។ យើងអាចប្រៀបធៀបអ្វីដែលធ្វើនេះ ទៅនឹងអ្វីដែលប្រព័ន្ធបោះឆ្នោតបានអាន រាប់ និងបានបង្ហាញការជ្រើសរើសនៅលើសន្លឹកឆ្នោតនីមួយៗ ។

m. ការឆ្លើយតបរបស់ ROV៖ ប្រសិនបើពួកគេបានបោះសន្លឹកឆ្នោតរបស់គេរួច ពោលគឺនៅពេលវាត្រូវបានបោះភ្លាម ពួកគេនឹងអាចកែប្រែវាបាននៅពេលនោះ ។ យើងមានកម្រិតនៃតម្លាភាពនិងលទ្ធភាពសវនកម្មខ្ពស់ ដូច្នេះយើងគិតថានេះនឹងជាប្រព័ន្ធមួយដែលមានសុវត្ថិភាពបំផុត ។ យើងអាចបង្ហាញឲ្យមើលពីដំណើរនោះបានដល់នរណាម្នាក់ដែលចាប់អារម្មណ៍ ។

## XI. សេចក្តីសន្និដ្ឋាន

a. សេចក្តីសន្និដ្ឋានរបស់ ROV៖ សូមថ្លែងអំណរគុណចំពោះការចូលរួម, មតិយោបល់ និងមតិត្រឡប់របស់អ្នកទាំងអស់គ្នា ។ យើងនៅតែបន្តទទួលយកនូវមតិត្រឡប់រហូតដល់ថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 2019 ។ យើងក៏នឹងមានសវនាការសាធារណៈបន្ថែមទៀតនៅថ្ងៃពុធ ទី 4 ខែកញ្ញា ឆ្នាំ 2019 នៅក្នុងតំបន់មួយចំនួន ប៉ុន្តែចាប់ពីម៉ោង 6 ដល់ ម៉ោង 8 ល្ងាច ។

**County of Santa Clara**
Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

**សវនាការសាធារណៈអំពី EAP**

**កំណត់ហេតុនៃកិច្ចប្រជុំ**

ថ្ងៃពុធ ទី4 ខែកញ្ញាឆ្នាំ2019

បន្ទប់គណៈកម្មការ

ម៉ោង 6:00 ដល់ ម៉ោង 8:00 ល្ងាច

70 W. Hedding St., San Jose, CA 95110

## I. សូមស្វាគមន៍

a. សេចក្តីណែនាំដោយ Shannon Bushey មន្រ្តីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara ។ ការិយាល័យនៃមន្រ្តីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) កំពុងទន្ទឹងរងចាំទទួលនូវមតិយោបល់ត្រឡប់ចំពោះគម្រោងរដ្ឋបាលបោះឆ្នោត (EAP) ។ ជម្រើសជាច្រើនដើម្បីផ្តល់មតិយោបល់ត្រឡប់អាចធ្វើឡើងបានតាមទម្រង់ជាក្រដាស និងតាមអនឡាញនៅលើទម្រង់មួយដែលអាចដាក់ពាក្យបាន ។

b. ROV ទទួលខុសត្រូវទៅលើវិធានចាំផ្ទះ ច្បាប់មូលដ្ឋាន និងទិដ្ឋភាពទូទៅនៃរបៀបវីរៈ ។ ROV ចាប់ផ្តើមបើកអញ្ជើញការចូលរួមរបស់គណៈកម្មាធិការផ្តល់ឱវាទលើលទ្ធភាពទទួលបាននៃសេវាភាសា (LAAC) និងគណៈកម្មាធិការផ្តល់ឱវាទលើលទ្ធភាពនៃការចេញចូលកន្លែងបោះឆ្នោត (VAAC) របស់ ROV ។ ប័ណ្ណផ្តល់មតិយោបល់ត្រូវបានណែនាំ និងចង្អុលបង្ហាញគ្មានបក្សពួកនិយម ។ ROV ក៏បានសំណូមពរមិនឲ្យមានការទះដៃ ឬជំទាស់ចំពោះការផ្តល់មតិយោបល់ឡើយ ។

c. បុគ្គលិក ROV ដែលជាអ្នកឯកទេសតាមមុខជំនាញត្រូវបានណែនាំឲ្យជួយផ្តល់ចម្លើយទៅដល់សំណួរនានា ចំណែកឯការបកប្រែភាសាក៏មានផ្តល់ជូនជាច្រើនភាសាផងដែរ ។

d. ការណែនាំខ្លួនរបស់ប្រធានផ្នែកជាបុគ្គលិករបស់ ROV ។

## II. បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត(VCA)

a. តំណភ្ជាប់ទៅកាន់ការផ្សាយបន្តផ្ទាល់តាមអនឡាញនៃសវនាការសាធារណៈ:
   i. https://www.youtube.com/watch?v=WxALTnXIVXc

b. ឯកសារបទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃច្បាប់ VCA៖
   i. បទបង្ហាញ – https://youtu.be/WxALTnXIVXc?t=1253
   ii. ការអនុវត្តន៍នៃច្បាប់ VCA នឹងត្រូវចាប់ផ្តើមដោយការបោះឆ្នោតបឋមប្រធានាធិបតីដែលចាប់ផ្តើមនៅថ្ងៃទី 3 ខែមីនា ឆ្នាំ 2020
   iii. គ្រប់អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះ នឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រ (VBM) –
      1. ស្រោមសំបុត្រដែលបានបង់ថ្លៃតែម្សូច
      2. ហិបទម្លាក់សន្លឹកឆ្នោតផ្លូវការ
      3. បោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន

iv. មានរហូតដល់ទៅ 120 មជ្ឈមណ្ឌលដែលមានសក្តានុពលនៅទូទាំងខោនធី –
    1. សេវាថ្មីបន្ថែម
    2. ម៉ាស៊ីនបោះឆ្នោតថ្មី
    3. បោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន
v. មានច្រើនថ្ងៃជាងមុនដើម្បីបោះឆ្នោតមុនកាលកំណត់
    1. មណ្ឌលបោះឆ្នោតនឹងបើកដំណើរការរហូតដល់ទៅដប់ថ្ងៃមុនថ្ងៃបោះឆ្នោត
vi. បោះឆ្នោតនៅក្នុងថ្ងៃតែមួយ –
    1. ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ៖ ចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃតែមួយ
vii. បង្កើតឡើងនូវគម្រោងរដ្ឋបាលដើម្បីការបោះឆ្នោត (EAP) ដោយផ្តោតទៅលើ –
    1. ទីតាំងមណ្ឌលបោះឆ្នោត
    2. លទ្ធភាពទទួលបាន
    3. ជំនួយផ្នែកភាសា
    4. ការអប់រំ និង ការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត
    5. ធាតុចូល/មតិយោបល់ត្រឡប់របស់សហគមន៍
viii. កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី EAP ដែលបានរៀបចំកន្លងមក –
    1. (2) ទូទៅ, (2) លទ្ធភាពទទួលបាន, វៀតណាម, ខ្មែរ, តាកាឡុក, អេស្ប៉ាញ, ចិន, កូរ៉េ, ហ៊ីនឌី, និង ជប៉ុន ។ នៅក្នុងកិច្ចប្រជុំទាំងអស់ យើងបានប្រមូលធាតុចូលពីសហគមន៍ដើម្បីរៀបចំចេញជាពង្រៀង EAP
ix. តារាងកំណត់ពេលវេលា EAP –
    1. ច្បាប់ពង្រៀង > មតិយោបល់សាធារណៈ > កែសម្រួលលើពង្រៀង > មតិយោបល់សាធារណៈ > ពង្រៀងចុងក្រោយ

**c.** មតិយោបល់ ROV៖ យើងទទួលបានមតិយោបល់ត្រឡប់ និងមតិយោបល់នានាជាង 200 ។ ផែនការ EAP របស់យើងបានដាក់បង្ហោះតាមអនឡាញជាងមួយខែមកហើយ ។ តំណភ្ជាប់ទៅកាន់ធនធាន VCA ៖ https://www.sccgov.org/sites/rov/VCA/Pages/home.aspx

## III. បទបង្ហាញខាងផ្នែកបោះឆ្នោតតាមសំបុត្រ

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=1543

b. កញ្ចប់បោះឆ្នោតតាមសំបុត្រ (VBM)៖
   i. ទិដ្ឋភាពទូទៅនៃការចុះឈ្មោះអ្នកបោះឆ្នោតត្រឹមថ្ងៃ 11/06/2018
   ii. អ្នកបោះឆ្នោតដែលបានចុះឈ្មោះម្នាក់នឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រមួយសន្លឹក
   iii. ហិបទម្លាក់សន្លឹកឆ្នោតត្រូវបានកំណត់សម្រាប់អ្នកបោះឆ្នោតចំនួន 15,000 នាក់
   iv. សន្លឹកឆ្នោតផ្លូវការគំរូ, ស្រោមសំបុត្រសម្រាប់ផ្ញើត្រឡប់, សេចក្តីណែនាំពី VBM, និងស្ទីកឺត្រូវបានដាក់បញ្ចូលនៅក្នុងកញ្ចប់នីមួយៗ
   v. ទិដ្ឋភាពទូទៅនិងរូបភាពនៃការផ្ញើសម្ភារៈសន្លឹកឆ្នោតនិងសេចក្តីណែនាំសម្រាប់យោធា/អ្នកក្រៅប្រទេស

c. ហឹបសន្លឹកឆ្នោតផ្លូវការ៖

i. បច្ចុប្បន្ននេះ ROV មានទីតាំងប្រហែលជា 90 កន្លែង (រាប់បញ្ចូលទាំងទីតាំងស្ថិតនៅខាងក្នុងនិងខាងក្រៅ) –

1. បណ្ណាល័យខោនធី/ទីក្រុង
2. សាលារៀន និង សាកលវិទ្យាល័យ
3. អគារខោនធី
4. សាលាក្រុង

ii. សន្តិសុខរបស់សន្លឹកឆ្នោតទម្លាក់ចូល –

1. ខ្សែកាបចាក់សោរ
2. ការបិទភ្ជិត
3. ការអនុលោមតាម ADA

d. លទ្ធភាពអាចបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM)

i. សម្រាប់យោធា អ្នកបោះឆ្នោតនៅក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព

ii. ទិដ្ឋភាពទូទៅនៃតំណភ្ជាប់ដែលអាចចូលទៅកាន់ការបោះឆ្នោតបានសម្រាប់កំណែប្រែជាអេឡិចត្រូនិកនៃសន្លឹកឆ្នោត អ្នកបោះឆ្នោតត្រូវតែព្រីនសន្លឹកឆ្នោតរបស់ខ្លួន ហើយផ្ញើវាត្រឡប់មកកាន់ ROV ដើម្បីឲ្យសន្លឹកឆ្នោតអាចរាប់បាន ។ ការជ្រើសរើសសន្លឹកឆ្នោតត្រូវបានជ្រើសរើសជាអេឡិចត្រូនិកតាមប្រព័ន្ធអ៊ីនធឺណិត ។ នេះជាតំណភ្ជាប់ដែលអាចចូលទៅកាន់ការបោះឆ្នោតបាន៖ https://www.sccgov.org/sites/rov/Voting/Pages/Voting-Accessibility.aspx

iii. តំណភ្ជាប់ចូលទៅកាន់វីឌីអូណែនាំអំពី RAVBM ដោយប្រើប្រាស់ Democracy Live https://youtu.be/LRZ8HllghQc?t=1438

## IV. បទបង្ហាញរបស់ផ្នែកប្រព័ន្ធព័ត៌មានផែនទីភូមិសាស្ត្រ

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2189

b. ជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោតដោយការប្រើសប្រាស់ទិន្នន័យ៖

c. កត្តាទាំងឡាយនៃទីតាំងមណ្ឌលបោះឆ្នោត

i. អគារ
ii. សេដ្ឋកិច្ចសង្គម
iii. ភូមិវិទ្យា

d. ធនធានទិន្នន័យ៖

i. ការស្ទង់មតិសហគមន៍អាមេរិកកាំង –

1. ទិន្នន័យនៃការស្ទង់មតិសហគមន៍អាមេរិកកាំង (ACS) ថ្មីៗបំផុត
2. ធ្វើឡើងនៅក្នុងឆ្នាំ 2017
3. ដោយក្រសួងជំរឿនប្រជាជនអាមេរិកកាំង

ii. ទិន្នន័យមូលដ្ឋានរបស់ ROV ខោនធី Santa Clara –

1. ការរាប់ចំនួនអ្នកចុះឈ្មោះនាពេលបច្ចុប្បន្ន
2. ការបោះឆ្នោត

iii. មធ្យោបាយធ្វើដំណើរសាធារណៈ –
   1. អាជ្ញាធមិជ្រលងគមនាគមន៍ (VTA)
   2. ក្រសួងគមនាគមន៍ California
iv. ទិន្នន័យ GIS ខោនធី –
   1. ផ្លូវកាត់កណ្តាល
   2. ខ្សែបន្ទាត់ព្រំប្រទល់ក្រុង

e. កត្តាភូមិសាស្ត្រ៖
   i. ខ្សែបន្ទាត់ព្រំប្រទល់មណ្ឌលបោះឆ្នោតសម្រាប់ការដាក់ពង្រាយទីតាំង –
      1. សម្រាប់មណ្ឌលបោះឆ្នោតមួយដែលដំណើរការរយៈពេល 11 ថ្ងៃ ត្រូវមានអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 50,000 នាក់ ។
         a. ការប៉ាន់ស្មានតំបន់មណ្ឌលបោះឆ្នោតមានចំនួន 25 កន្លែង
      2. មណ្ឌលបោះឆ្នោតដំណើរការ 4 ថ្ងៃមួយសម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 10,000 នាក់
         a. ការប៉ាន់ស្មានតំបន់មណ្ឌលបោះឆ្នោតមានចំនួន 120 កន្លែង
      3. ហឹបសន្លឹកឆ្នោតផ្លូវការ
         a. ការប៉ាន់ស្មានទីតាំងហិបទម្លាក់សន្លឹកឆ្នោតមានចំនួន 80
   ii. ការបង្កើតនូវខ្សែបន្ទាត់ព្រំប្រទល់ –
      1. ខ្សែបន្ទាត់ព្រំប្រទល់ក្រុង
      2. តំបន់ជុំវិញ
      3. ផ្លូវសំខាន់ៗ
      4. ផ្លូវក្នុងមូលដ្ឋាន

f. កត្តាសេដ្ឋកិច្ចសង្គមដោយប្រើប្រាស់ដំណោះស្រាយបច្ចេកវិទ្យាពង្រីកប្រសិទ្ធិភាពការសម្រេចចិត្ត (DOTS) ដើម្បីដាក់ពិន្ទុនូវកត្តាដូចខាងក្រោម៖
   i. មធ្យោបាយធ្វើដំណើរសាធារណៈ:
   ii. លំនាំចរាចរ
   iii. មជ្ឈមណ្ឌលប្រជាជន
   iv. ភាសាប្រើប្រាស់ដោយជនជាតិភាគតិច
   v. ពិការភាព
   vi. កម្មសិទ្ធិភាពលើយានយន្តមានកម្រិតទាប
   vii. ចំណូលទាប
   viii. ការប្រើប្រាស់ការបោះឆ្នោតតាមសំបុត្រ
   ix. ការចុះឈ្មោះអ្នកបោះឆ្នោតមានកម្រិតទាប

## V. បទបង្ហាញរបស់ផ្នែកប្រតិបត្តិការតាមសង្កាត់

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2474

b. ទិដ្ឋភាពទូទៅពីមណ្ឌលបោះឆ្នោត

   i. មានមណ្ឌលបោះឆ្នោតប្រមាណជា 125 មណ្ឌលនៅទូទាំងខោនធី Santa Clara ដែលចាប់ដំណើរការនៅមុននិងរួមទាំងថ្ងៃបោះឆ្នោតផង ។

   ii. អ្នកបោះឆ្នោតនឹងមានដប់មួយថ្ងៃរួមទាំងថ្ងៃចុងសប្តាហ៍ពីរផងដើម្បីបោះឆ្នោត

   iii. 20% នឹងបើកដំណើរការនៅថ្ងៃ 22 ខែកុម្ភៈ ឆ្នាំ 2020៖ ដប់ថ្ងៃមុនថ្ងៃបោះឆ្នោត

   iv. 80% នឹងបើកដំណើរការនៅថ្ងៃ 29 ខែកុម្ភៈ ឆ្នាំ 2020៖ បីថ្ងៃមុនថ្ងៃបោះឆ្នោត

   v. បច្ចេកវិទ្យាបោះឆ្នោតថ្មីនឹងជួយឲ្យអ្នកបោះឆ្នោតអាចបោះឆ្នោតនៅទីណាក៏បាននៅក្នុងខោនធី Santa Clara

   vi. នឹងផ្តល់ឲ្យមាននូវសេវាច្រើនបំផុតនៅតាមការិយាល័យរបស់មន្ត្រីគ្រប់បញ្ជីបោះឆ្នោត

c. ការអនុវត្តន៍មណ្ឌលបោះឆ្នោត៖

   i. ម៉ោងនៃប្រតិបត្តិការ –

      1. 8 ម៉ោងក្នុងមួយទីតាំង, ពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 ល្ងាចនៅថ្ងៃបោះឆ្នោត

   ii. គោលការណ៍ណែនាំពីមណ្ឌលបោះឆ្នោតទៅតាមច្បាប់ VCA –

      1. គ្រប់តំបន់ដែលមានចំនួនអ្នកបោះឆ្នោត 50K ចាំបាច់ត្រូវមានមណ្ឌលបោះឆ្នោតដែលបើកដំណើរការរយៈពេលដប់មួយថ្ងៃចំនួនមួយ

      2. គ្រប់តំបន់ដែលមានចំនួនអ្នកបោះឆ្នោត 10K ចាំបាច់ត្រូវមានមណ្ឌលបោះឆ្នោតដែលបើកដំណើរការរយៈពេលបួនថ្ងៃចំនួនមួយ

   iii. បន្ទាត់កាត់គ្នាជាក្រឡាចត្រង្គនៃផែនទីខោនធី Santa Clara –

      1. ដើម្បីព្យាករណ៍ចំនួនមណ្ឌលបោះឆ្នោតដែលចាំបាច់សម្រាប់ខែមីនា និងខែវិច្ឆិកា ឆ្នាំ 2020

      2. ជំនួយក្នុងការជ្រើសរើសទីតាំងជាអតិបរមាទៅតាមលក្ខខណ្ឌតម្រូវផ្នែកភូមិសាស្ត្រមួយចំនួន

   iv. ការជ្រើសរើសទីតាំង –

      1. 14 ទីតាំងស្ថិតក្រោមការពិចារណា

      2. ទីតាំងដែលទំនេរនិងចម្រុះនៃលក្ខខណ្ឌផ្សេងៗ

d. ការដាក់និងបណ្តុះបណ្តាលបុគ្គលិកនៅតាមមណ្ឌលបោះឆ្នោត៖

   i. ប្រចាំម៉ោង៖ ជំនួយបន្ថែមដល់បុគ្គលិកការងារខោនធី –

      1. ការងារដឹកនាំ៖ ទទួលខុសត្រូវរួមទៅលើដំណើរការបោះឆ្នោត និងកំណត់ទិសដៅលំហូរធនធាន

      2. ជំនួយ៖ បុគ្គលិកគាំទ្រ, បុគ្គលិកជំនួយអ្នកបោះឆ្នោត

   ii. បុគ្គលិកទទួលបានប្រាក់ឧបត្ថម្ភ៖ អ្នកស្ម័គ្រចិត្ត, សិស្សវិទ្យាល័យ –

      1. ជំនួយ៖ បុគ្គលិកគាំទ្រ, បុគ្គលិកជំនួយអ្នកបោះឆ្នោត

      2. អ្នកធ្វើបដិសណ្ឋារកិច្ច៖ ស្វាគមន៍, ជួយ, បង្ហាញឬជូនអ្នកបោះឆ្នោតទៅខ្សែសេវាកម្មសមស្រប

   iii. ពេលវេលានៃការជួលឲ្យបម្រើការ* (រួមទាំងថ្ងៃបណ្តុះបណ្តាល និងថ្ងៃបោះឆ្នោត) –

      1. ការងារដឹកនាំ៖ 21 ថ្ងៃ

      2. បុគ្គលិកជំនួយនិងអ្នកធ្វើបដិសណ្ឋារកិច្ច៖ 14 ថ្ងៃ

iv. សម្រាប់ព័ត៌មានបន្ថែម, សូមចូលទៅកាន់៖ www.sccvote.org

e. គោលដៅការងារផ្សព្វផ្សាយ៖

i. បញ្ជាក់ឲ្យច្បាស់ពីដំណើរការផ្លាស់ប្ដូរគំរូការបោះឆ្នោត និងជម្រាបដល់អ្នកបោះឆ្នោតឲ្យបានដឹងពីការកែប្រែនានាដែលនឹងចូលមកដល់

ii. ការអប់រំនិងការធ្វើឲ្យកាន់តែប្រសើរឡើងនូវបទពិសោធន៍របស់អ្នកបោះឆ្នោត

iii. បង្ហាញនិងបង្កើនការចូលរួមនៅក្នុងសហគមន៍ដែលធ្វើមិនបានល្អ

iv. សូមស្វាគមន៍ការចូលរួមរបស់សាធារណជន

v. កសាងភាពជាដៃគូដើម្បីពង្រីកឱកាសចូលរួមរបស់ពលរដ្ឋនៅក្នុងសហគមន៍ទាំងអស់ (ការអប់រំអ្នកបោះឆ្នោត និងសម្ព័ន្ធភាពផ្សព្វផ្សាយ)

vi. ផ្ដល់ឯកសារអប់រំដល់អ្នកបោះឆ្នោត, ធនធានសម្រាប់ពលរដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន

## VI. បទបង្ហាញរបស់ផ្នែកទម្រង់សន្លឹកឆ្នោត

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=2819

b. ភាសាទាំងឡាយដែលតម្រូវដោយសហព័ន្ធ៖

i. អង់គ្លេស

ii. ចិន

iii. អេស្ប៉ាញ

iv. តាកាឡុក

v. វៀតណាម

c. ភាសាទាំងឡាយដែលតម្រូវដោយរដ្ឋ៖

i. កូរ៉េ

ii. ខ្មែរ

d. ភាសាទាំងឡាយដែលតម្រូវឲ្យមានពីមុនមក៖

i. ហ៊ីនឌី

ii. ជប៉ុន

e. សម្រាប់ការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីថ្ងៃទី 3 ខែមីនាឆ្នាំ 2020, សន្លឹកឆ្នោតផ្លូវការនឹងត្រូវព្រីនជាភាសាដូចខាងក្រោម៖

i. អង់គ្លេស

ii. ចិន

iii. អេស្ប៉ាញ

iv. តាកាឡុក

v. វៀតណាម

vi. កូរ៉េ

vii. ខ្មែរ

viii. ជប៉ុន

ix. ហ៊ីនឌី

f. សន្លឹកឆ្នោតគ្រប់ភាសាទាំងអស់នឹងត្រូវផលិតឡើងតាមទម្រង់ដូចខាងក្រោម៖
   i. សន្លឹកឆ្នោតជាក្រដាសសម្រាប់ម៉ាស៊ីនស្កែនអុបទីខល
   ii. សន្លឹកឆ្នោតអាចប្រើបានដោយស្ទាបលើអក្សរក្រង់
   iii. សន្លឹកឆ្នោតអាចប្រើប្រាស់បានជាសំឡេង
   iv. សន្លឹកឆ្នោតអាចប្រើបានពីចម្ងាយសម្រាប់យោធា, អ្នកបោះឆ្នោតនៅក្រៅប្រទេស ឬអ្នកបោះឆ្នោតដែលមានពិការភាព
g. សន្លឹកឆ្នោតបង្កើតឡើងក្នុងអំឡុងការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី គំនូសបម្រួញបង្ហាញពីលក្ខណៈខុសគ្នារវាងឆ្នាំ 2016 និងឆ្នាំ 2020 ៖ https://youtu.be/WxALTnXIVXc?t=2918
   i. BLD នឹងផលិតសន្លឹកឆ្នោតច្រើនទ្វេរដងនៅក្នុងឆ្នាំ 2020 ធៀបទៅនឹងឆ្នាំ 2016
h. សេចក្តីណែនាំព័ត៌មានសម្រាប់អ្នកបោះឆ្នោតនៅក្នុងខោនធី (CVIGS) និងបញ្ជីបោះឆ្នោតថ្មីអេឡិចត្រូនិក
   i. មណ្ឌលបោះឆ្នោតនិងគេហទំព័រ sccvote.org នឹងមាន CVIGS និង បញ្ជីបោះឆ្នោតថ្មីអេឡិចត្រូនិកដែលនឹងត្រូវបកប្រែជាភាសាអង់គ្លេស, ចិន, អេស្ប៉ាញ, តាកាឡុក, និងវៀតណាម
i. ការអនុវត្តន៍ច្បាប់ VCA៖
   i. ពង្រីកសេវាភាសានៅទូទាំងខោនធី
   ii. ផ្តល់ជំនួយផ្នែកភាសានៅតាមមណ្ឌលបោះឆ្នោត
   iii. បង្កើនសម្ភារៈសន្លឹកឆ្នោតពីរភាសា

## VII. បទបង្ហាញរបស់ផ្នែកកិច្ចការសាធារណៈនិងនីតិកម្ម

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=3053
b. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយដោយផ្ទាល់៖
   i. កាសែត
   ii. ទូរទស្សន៍
   iii. វិទ្យុ
   iv. តាមអនឡាញ
c. ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត
   i. ផ្តល់ព័ត៌មានថ្មីៗទៅកាន់ប្រព័ន្ធផ្សព្វផ្សាយជានិច្ច = ធ្វើឲ្យសាធារណជនដឹងពីព័ត៌មានថ្មីៗជានិច្ច
      1. ជម្រើសបោះឆ្នោតថ្មីៗជាច្រើន
      2. ប្រព័ន្ធបោះឆ្នោតថ្មី
      3. ជម្រើសដែលអាចទទួលបានថ្មីនិងភាសាជាច្រើន
d. ការផ្សាយពាណិជ្ជកម្ម៖
   i. យុទ្ធនាការកន្លងមក – ការជ្រើសរើស, ការបោះឆ្នោតតាមសំបុត្រ
   ii. គ្រប់វេទិកាទាំងអស់ – ព្រីន, TV, វិទ្យុ, អនឡាញ, រថយន្តក្រុង
e. យុទ្ធនាការធំជាងមុនសម្រាប់ការផ្សព្វផ្សាយ៖
   i. កាលពីមុនពីប្រាំមួយទៅប្រាំបីសប្តាហ៍មុនការបោះឆ្នោត
   ii. ការផ្សព្វផ្សាយពាណិជ្ជកម្មនឹងចាប់ផ្តើមនៅក្នុងខែកញ្ញា ដំណើរការផ្សព្វផ្សាយក្នុងរយៈពេលប្រាំមួយខែ
   iii. ក្រោយពីថ្ងៃឈប់សម្រាករហូតដល់មុនការបោះឆ្នោតនៅថ្ងៃទី 3 ខែមីនា

f. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទៅតាមភាសា៖
   i. ពង្រីកបញ្ជីឈ្មោះរបស់យើង
   ii. ធាតុចូលពីកិច្ចប្រជុំគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត
   iii. ការបោះពុម្ពផ្សាយសម្រាប់អ្នកទិញទំនិញ,វិទ្យុ, ក៏អាចមានតាមទូរទស្សន៍
   iv. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទៅតាមភាសាផ្សេងៗរួមមាន –
      1. Nichi Bei
      2. La Oferta
      3. Philippine News
      4. Viên Thao Television
      5. SOH
      6. Silconeer
      7. India West Best Indian Newspaper តាមព្រីន និងតាមអនឡាញ
   v. មាតិកាសំខាន់ៗ –
      1. ដាក់លាក់ទៅតាមសហគមន៍
      2. ខ្សែទូរស័ព្ទជំនួយដល់អ្នកបោះឆ្នោតដោយមិនគិតថ្លៃសម្រាប់ភាសានានា
      3. សន្លឹកឆ្នោតក្នុងទម្រង់ដែលអាចបោះបាន
      4. បោះឆ្នោតតាមសំបុត្រដែលអាចធ្វើទៅបានពីចម្ងាយ
   vi. ប្រព័ន្ធផ្សព្វផ្សាយសង្គម –
      1. http://www.facebook.com/sccvote/
      2. https://www.instagram.com/sccvote/
      3. https://twitter.com/sccvote/
      4. https://www.youtube.com/user/sccvote
      5. Nextdoor: @sccvote
   vii. Sports Franchises –
      1. San Francisco 49ers
      2. San Jose Sharks
      3. San Jose Earthquakes

## VIII. បទបង្ហាញរបស់ផ្នែកភ័ស្តុភារសម្រាប់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត

a. តំណភ្ជាប់ទៅកាន់បទបង្ហាញ៖ https://youtu.be/WxALTnXIVXc?t=3318
b. សន្តិសុខក្នុងការបោះឆ្នោត៖
   i. ប្រើប្រាស់ប្រព័ន្ធតាមដានសម្រាប់គ្រឿងបរិក្ខារបោះឆ្នោត
c. កញ្ចប់សន្លឹកឆ្នោតត្រូវបញ្ជូនត្រឡប់៖
   i. ប្រតិបត្តិការដឹកជញ្ជូន –
      1. បញ្ជូនមកដល់ចន្លោះពី 1-2 ថ្ងៃ
      2. ចន្លោះពី 3-4 ទីតាំងក្នុងមួយរថយន្ត
      3. ចន្លោះពី 8-30 រថយន្ត / បុគ្គលិកប្រហែលជា 60 នាក់
      4. បុគ្គលិក ELVS ចំនួនពីរនាក់គាំទ្រដោយបុគ្គលិកមណ្ឌលបោះឆ្នោតនៅពេលបញ្ជូនទៅដល់
      5. ទីតាំងដាក់ចុះ
      6. ការវេចខ្ចប់ដោយប្រើយុទ្ធសាស្ត្រដាក់កូដពណ៌ទៅតាមមណ្ឌលបោះឆ្នោត
      7. យុទ្ធសាស្ត្រវេចខ្ចប់ដោយវិធានការសន្តិសុខសម្រាប់គ្រឿងបរិក្ខារងាយប៉ះពាល់
      8. លក្ខខណ្ឌតម្រូវសម្រាប់សម្ភារៈផ្គត់ផ្គង់

ii. មជ្ឈមណ្ឌលភស្តុភារនិងសម្ភារៈផ្គត់ផ្គង់
    1. រថយន្តធំមួយគ្រឿងនិងរថយន្តធនតូចនឹងត្រូវដាក់ពង្រាយនៅទូទាំងខោនធី ផ្ទុកទៅដោយសម្ភារៈផ្គត់ផ្គង់សម្រាប់មណ្ឌលបោះឆ្នោត បច្ចេកវិទ្យាគាំទ្រ, គ្រឿងបរិក្ខារសម្រាប់ជំនួសថ្មី និងសម្ភារៈផ្គត់ផ្គង់បន្ថែមនានា
iii. ភស្តុភារបញ្ជូនសន្លឹកឆ្នោតត្រឡប់ –
    1. ការដឹកជញ្ជូន
    2. ការដឹកជញ្ជូនហិបទម្លាក់សន្លឹកឆ្នោត VBM

d. គ្រឿងបរិក្ខារបោះឆ្នោត៖
    i. ម៉ាស៊ីនបោះឆ្នោត –
        1. មានដល់ទៅ (3) ក្នុងមួយមណ្ឌលបោះឆ្នោត
    ii. ឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បាន –
        1. មានដល់ទៅ (8) ក្នុងមួយមណ្ឌលបោះឆ្នោត
    iii. បញ្ជីបោះឆ្នោតថ្មីអេឡិចត្រូនិក –
        1. មានដល់ទៅ (11) ក្នុងមួយមណ្ឌលបោះឆ្នោត
    iv. ម៉ាស៊ីព្រីនសន្លឹកឆ្នោតតាមតម្រូវការ –
        1. មានដល់ទៅ (5) ក្នុងមួយមណ្ឌលបោះឆ្នោត
    v. ម៉ាស៊ីនស្កេនសន្លឹកឆ្នោតខ្នាតតូច –
        1. មានដល់ទៅ (8) ក្នុងមួយមណ្ឌលបោះឆ្នោត
    vi. ម៉ាស៊ីនស្កេនសន្លឹកឆ្នោតខ្នាតធំ –
        1. មានដល់ទៅ (10) ក្នុងមួយមណ្ឌលបោះឆ្នោត
    vii. ស្ថានីយ៍ត្រួតពិនិត្យសន្លឹកឆ្នោតឡើងវិញ –
        1. មានដល់ទៅ (16) ក្នុងមួយមណ្ឌលបោះឆ្នោត

e. កញ្ចប់សន្លឹកឆ្នោតនិងការបិទភ្ជិត៖
    i. រក្សាសន្តិសុខនិងរក្សាទុកសន្លឹកឆ្នោតនៅក្នុងទីតាំងដើម្បីអាចទាញយកដុំសន្លឹកឆ្នោតមកបាន

f. គម្រោងនិងផែនការបច្ចេកវិទ្យា៖
    i. ប្រព័ន្ធទូរសព្ទ Cisco (សេវាបម្រើអតិថិជនទាន់ចិត្ត)
    ii. លំដាប់ផែនការគាំទ្រផ្នែកបច្ចេកវិទ្យា (ការបន្តផ្តល់សេវា)
    iii. រក្សាតំណភ្ជាប់បណ្តាញទៅកាន់មណ្ឌលបោះឆ្នោតកុំឲ្យដាច់
    iv. សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត (ការយល់ដឹងពីការប្រុងប្រៀបជាមុន)
    v. តាមដានប្រព័ន្ធបច្ចេកវិទ្យា (ការផ្ទៀងផ្ទាត់)
    vi. ប្រព័ន្ធគ្រប់គ្រងទ្រព្យ (គណនេយ្យភាព)

## IX. ការចែកចាយប័ណ្ណផ្តល់មតិយោបល់

## X. ការពិភាក្សា

a. អ្នកចូលរួម (សំណួរ 1)៖ តើខោនធីផ្សេងៗទៀតមានបានអនុវត្តច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតប្រកបដោយជោគជ័យទេ?

   i. ការឆ្លើយតបរបស់ ROV៖ នៅក្នុងឆ្នាំ 2018 មានខោនធីចំនួនប្រាំដែលបានអនុវត្ត VCA និងនៅឆ្នាំ 2020 នឹងមានខោនធីសរុបរហូតដល់ទៅ 14 ដែលនឹងអនុវត្ត ព្រមទាំងអនុវត្តិវាម្តងទៀត ។ វាស្មើនឹង 50 ភាគរយនៃការចុះឈ្មោះរបស់រដ្ឋ ។ ខោនធីរបស់យើងកំពុងតែបានធ្វើការជាមួយរដ្ឋនិងខោនធីនានាមួយឆ្នាំកន្លងមកនេះ ហើយបានជួបជាមួយនឹងផ្នែកដែលពាក់ព័ន្ធនានា ដើម្បីសួរនូវសំណួរជាក់លាក់នានាដែលបានអនុវត្តការងារនោះកន្លងមកនៅក្នុងខោនធីដទៃផ្សេងទៀត ។ យើងបានធ្វើសន្និសិទតាមទូរសព្ទទាំងរដ្ឋជាច្រើនដង ។ យើងកំពុងតែបានធ្វើការជាមួយខោនធីផ្សេងៗទៀតនិងរដ្ឋ ។ ខោនធីទាំងអស់បានអនុវត្តប្រកបដោយជោគជ័យ ហើយយើងអាចមើលឃើញពីអ្វីដែលជាបញ្ហាប្រឈមរបស់ពួកគេកំពុងមាន ។ បញ្ហាប្រឈមទាំងឡាយរួមមាន ការជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោត ពីព្រោះចំនួននៃថ្ងៃដែលទីតាំងចាំបាច់ត្រូវបើកដំណើរការនិងពេលដំណើរការដែលចាំបាច់នៅតាមការិយាល័យរបស់យើងប្រៀបធៀបវាទៅនឹងការិយាល័យបោះឆ្នោតដែលត្រូវការពេលបើកដំណើរការតែមួយថ្ងៃនោះ ។ បច្ចុប្បន្ននេះ ជាមួយនឹងទីតាំងទាំង 125 របស់យើង យើងមិនអាចប្រើប្រាស់បានច្រើនឡើយនូវការិយាល័យបោះឆ្នោតដែលយើងធ្លាប់ប្រើពីមុនមកដោយសារតែទំហំ លទ្ធភាពចេញចូល និងការចតយានយន្តនោះ ។ យើងធ្លាក់មកនៅ 20% ចុងក្រោយដែលត្រូវស្វែងរកទីតាំង ។ បញ្ហាមួយទៀតនោះគឺការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោត និងបុគ្គលិកជំនួយបន្ថែម ។ គឺដូចគ្នាទៅនឹងពេលវេលាកំណត់សម្រាប់ទីតាំងដែរ យើងត្រូវការស្វែងរកមនុស្សដែលអាចធ្វើការពីពីរទៅបីសប្តាហ៍នៅតាមមណ្ឌលបោះឆ្នោត ។ នៅពេលយើងទទួលបានមតិយោបល់ត្រឡប់ទាំងអស់រួចមក យើងនឹងផ្តោតទៅលើការជ្រើសរើសនយោជិកជំនួយបន្ថែម ហើយយើងនឹងបន្តដំណើរការជ្រើសរើសបុគ្គលិកដែលទទួលបានប្រាក់ឧបត្ថម្ភ ។

   ii. ការឆ្លើយតបរបស់ ROV៖ អ្នកស្ម័គ្រចិត្តទាំងអស់ដែលបានជួយយើងកន្លងមកដែលពួកគេជួយយើងតែមួយថ្ងៃ ។ បច្ចុប្បន្នយើងនឹងត្រូវការជំនួយរហូតដល់ទៅ 11 ថ្ងៃ ។ ការធ្វើកាលវិភាគនឹងត្រូវជួបការលំបាក ។ យើងនឹងចាំបាច់សុំឲ្យមនុស្សដាក់ពាក្យធ្វើជានយោជិកខោនធីបើទោះបីជាវាជាកិច្ចសន្យាជួលរយៈពេលខ្លីក៏ដោយ ។ បញ្ហាប្រឈមគឺត្រូវស្វែងរកបុគ្គលិករយៈពេលខ្លីដើម្បីជួយយើងសម្រាប់រយៈពេលពេញមួយចុងសប្តាហ៍ ។ គ្រឿងបរិក្ខារនឹងថ្មី ហើយអ្វីៗគ្រប់យ៉ាងនឹងចាំបាច់ត្រូវរៀបចំឡើងវិញនិងបណ្តុះបណ្តាលឡើងវិញ ។ ពួកគេត្រូវប្តេជ្ញាចិត្តចូលរួមវគ្គសិក្សាក៏ដូចជាការបណ្តុះបណ្តាលផងដែរ ។ យើងនឹងបញ្ហាប្រឈមជាច្រើន ហើយយើងនឹងត្រូវរៀនបណ្តើរធ្វើបណ្តើរ ។

b. អ្នកចូលរួម (សំណួរ 2)៖ មណ្ឌលបោះឆ្នោតបើកដំណើរការ 13 ម៉ោង ចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ប៉ុន្តែបើកដំណើរការបានតែ 8 ម៉ោងប៉ុណ្ណោះ តើមណ្ឌលបោះឆ្នោតទាំងនោះបិទមិនដំណើរការ 5 ម៉ោង ឬក៏ត្រូវបិទនិងត្រូវបើកដោយមិនរលូនមែនទេ?

   i. ការឆ្លើយតបរបស់ ROV៖ នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងត្រូវបើកដំណើរការចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ។ នៅមុនថ្ងៃបោះឆ្នោត ហើយនិងរយៈពេល 10 ថ្ងៃមុន ពេលវេលាមណ្ឌលបោះឆ្នោតនឹងត្រូវរៀបចំឲ្យរួចជាស្រេច ប៉ុន្តែពួកគេនឹងពង្រាយ ដោយមានមណ្ឌលខ្លះនឹងបើកដំណើរការច្រើននៅពេលល្ងាច និងខ្លះទៀតនៅក្នុងពេលព្រឹក ។

ii. ការឆ្លើយតបរបស់ ROV៖ ដើម្បីបញ្ជាក់ពីតម្រូវការសម្រាប់មណ្ឌលមួយចំនួនដែលបើកដំណើរការមុនថ្ងៃបោះឆ្នោតនោះ វានឹងត្រូវបើកដំណើរការយ៉ាងហោចណាស់ក៏ 8 ម៉ោងដែរក្នុងមួយថ្ងៃ ។ នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងត្រូវបើកដំណើរការចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 ល្ងាច ។

c. អ្នកចូលរួម (សំណួរ 3)៖ តើពាក្យថា "សង្កាត់" ប្រើបានយ៉ាងដូចម្តេចនៅក្រោមប្រព័ន្ធបោះឆ្នោតថ្មី?

i. ការឆ្លើយតបរបស់ ROV៖ យើងនឹងនៅតែមានប្រើសង្កាត់ ដោយយើងនឹងរៀបចំអ្នកបោះឆ្នោតយើងទៅតាមសង្កាត់សម្រាប់គោលបំណងបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យសង្កាត់មិនសំខាន់ដូចមុនទៀតទេ ពីព្រោះយើងអាចទៅបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បានដែរ ។ ពុំមានទំនាក់ទំនងគ្នាទេរវាងពាក្យថាសង្កាត់ និងមណ្ឌលបោះឆ្នោតនោះ ។ សង្កាត់ក្លាយជាផ្នែករបាយការណ៍ស្តីពីភូមិសាស្ត្រ ។ នៅពេលយើងមើលទៅសេចក្តីពីការបោះឆ្នោតរបស់យើង ដែលយើងបានបំបែកជាតូចៗនូវលទ្ធផលបោះឆ្នោតទៅជាសង្កាត់ វានឹងនៅតែមានពាក្យសង្កាត់នៅតែពាក់ព័ន្ធជាមួយវា ។ បច្ចុប្បន្ននេះ យើងអាចទៅកាន់មណ្ឌលបោះឆ្នោតណាមួយដែលយើងជ្រើសរើសទៅបាន ។

d. អ្នកចូលរួម (សំណួរ 4)៖ តើខ្សែព្រំប្រទល់ចំនួនប្រជាជន 50k និង 10k គ្របដណ្តប់ទៅលើការប្រែប្រួលចំនួនប្រជាជននៅពេលថ្ងៃទេ?

i. ការឆ្លើយតបរបស់ ROV៖ ទិន្នន័យរបស់យើងគឺផ្អែកទៅលើការចុះឈ្មោះរបស់អ្នកបោះឆ្នោតនាពេលបច្ចុប្បន្នរបស់យើង ដោយបន្ថែមចំនួន 50 ភាគរយបន្ថែមនៃចំនួនប្រជាជនដែលមិនបានចុះឈ្មោះ ។ តាមរយៈទិន្នន័យជំរឿន យើងរាប់លំនៅដ្ឋាននិងអាសយដ្ឋាន ។ សម្រាប់ពេលថ្ងៃ ទិន្នន័យតាមដានកន្លែងដែលមនុស្សបោះឆ្នោតមិនបាន ។

e. អ្នកចូលរួម (សំណួរ 5)៖ តើការបោះឆ្នោតធ្វើទៅយ៉ាងដូចម្តេចនៅតាមមណ្ឌលបោះឆ្នោតដែលដំណើរការ 8 ម៉ោងក្នុងមួយថ្ងៃ ត្រូវរក្សាដំណើរការរហូតដល់មណ្ឌលបោះឆ្នោតបិទនៅយប់ថ្ងៃបោះឆ្នោតមែនទេ?

i. ការឆ្លើយតបរបស់ ROV៖ សន្លឹកឆ្នោតភាគច្រើននោះគឺនៅតាមមណ្ឌលបោះឆ្នោតនឹងត្រូវដាក់ចូលទៅក្នុងលិបិក្រមបញ្ជីបោះឆ្នោត ដែលអ្នកបោះឆ្នោតនឹងបញ្ចូលវាទៅក្នុងម៉ាស៊ីន ។ វានឹងរក្សាលទ្ធផលទុកនៅក្នុងប្រព័ន្ធចងចាំខាតឌ្រីច ហើយលិបិក្រមនឹងទម្លាក់ខាតឌ្រិចចុះទៅក្នុងប្រអប់ចាក់សោរដ៏គត់មត់មួយ ។ យើងនឹងទទួលខុសត្រូវចំពោះសន្លឹកឆ្នោតនៅពេលបញ្ចប់មួយថ្ងៃៗ ។ យើងនឹងបើកត្រាបិទភ្ជិតហើយដឹកជញ្ជូនវាត្រឡប់មកវិញ រក្សាទុកដោយសុវត្ថិភាពនៅក្នុងការិយាល័យរបស់យើងពីមួយយប់ទៅមួយយប់ ។ យើងពិតជាមានពិធិការការពារជាច្រើនដំណាក់កាលដែលយើងត្រូវអនុវត្តតាម ។ សន្លឹកឆ្នោតដែលបោះរួចភាគច្រើននឹងត្រូវដាក់ចូលទៅក្នុងបញ្ជីរនោះ ។ លើកលែងតែចំពោះសន្លឹកឆ្នោតបណ្តោះអាសន្ន ឬសន្លឹកឆ្នោតអ្នកចុះឈ្មោះដោយមានលក្ខខណ្ឌ (CVR) ឬ សន្លឹកឆ្នោត VBM ទេ ដែលគេបោះចោល ។ ដូចគ្នាទៅនឹងការិយាល័យបោះឆ្នោតពីដើមដែរ យើងនឹងវាយត្រាភ្ជិតនិងរក្សាស្បោងដាក់សន្លឹកឆ្នោតឲ្យមានសុវត្ថិភាពនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ សន្លឹកឆ្នោតទាំងនោះនឹងត្រូវដាក់នៅក្នុងស្រោមសំបុត្រដាក់ចូលទៅក្នុងហិបសន្លឹកឆ្នោតដោយនៅចុងក្រោយយើងនឹងកាត់ត្រាភ្ជិតហើយដឹកជញ្ជូនវាទៅកាន់ការិយាល័យរបស់យើង ។ យើងមានផែនការត្រៀមរួចជាស្រេចក្នុងករណីដែលយើងប្រឈមជាមួយនឹងចំនួនមនុស្សចូលរួមច្រើន ហើយយើងត្រូវការហិបសន្លឹកឆ្នោតបន្ថែមជាចាំបាច់នោះ យើងនឹងមានទ្រុងដែកចល័តទីបាននៅលើរទេះដែលយើងនឹងដាក់បន្ថែមនូវហិបសន្លឹកឆ្នោតនៅក្នុងទ្រុងសុវត្ថិភាពនោះ ។

f. អ្នកចូលរួម (សំណួរ 6)៖ មើលនៅលើគេហទំព័រ និងផែនការសកម្មភាពអ្នកបោះឆ្នោតនោះ យើងមានចំនួនប្រជាជនដែលគ្មានទីលំនៅកើនឡើងនៅលើរបាយការណ៍ខោនធីនាពេលថ្មីៗនេះ ។ ខ្ញុំឆ្ងល់ថាតើយើងមានផែនការដែលអាចឲ្យអ្នកបោះឆ្នោតបោះបានសម្រាប់ពលរដ្ឋរស់នៅម្តុំយើងដែលគ្មានផ្ទះសម្បែងនោះបានទេ ។ នៅមុនច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតនោះ ខ្ញុំបានមើលត្រួសៗនៅលើគេហទំព័រនិងរកឃើញនូវលើគេហទំព័ររបស់សម្ព័ន្ធជាតិនៃភាពគ្មានទីលំនៅ ពួកគេមានព័ត៌មានល្អៗស្តីពីសិទ្ធិបោះឆ្នោតសម្រាប់ជនគ្មានផ្ទះសម្បែង ប៉ុន្តែវាមិនត្រូវបានធ្វើបច្ចុប្បន្នភាពដោយដាក់បញ្ចូលនូវអ្វីដែលយើងមានសម្រាប់ច្បាប់ស្តីពីសិទ្ធិរបស់អ្នកបោះឆ្នោតនោះទេ ។ ខ្ញុំយល់ថាការផ្សព្វផ្សាយនឹងពិបាកទៅដល់ក្រុមប្រជាជនប្រភេទនេះ ប៉ុន្តែតើមានទីកន្លែងដែលពួកគេអាចទៅដើម្បីស្វែងយល់ពីសិទ្ធិបោះឆ្នោតរបស់ពួកគេទេ ហើយថាតើវាជះឥទ្ធិពលដល់ច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោតយ៉ាងម៉េចដែរ ?

   i. ការឆ្លើយតប៖ ដើម្បីស្វែងយល់អំពីសិទ្ធិបោះឆ្នោតរបស់គេ ពួកគេអាចមកកាន់ការិយាល័យរបស់យើង ពួកគេអាចទូរសព្ទមកកាន់យើងនៅពេលណាក៏បាន យើងមានព័ត៌មាននៅលើគេហទំព័ររបស់យើងដែលអាចថាមិនចូលប្រើប្រាស់បានគ្រប់ពេល ប៉ុន្តែនៅតាមមណ្ឌលបោះឆ្នោតសម្រាប់រយៈពេល 11 ថ្ងៃ ពួកគេអាចទៅកាន់មណ្ឌលណាមួយនៃមណ្ឌលបោះឆ្នោតទាំងនោះ យើងអាចផ្តល់ដល់ពួកគេនូវព័ត៌មានស្តីពីសិទ្ធិរបស់ពួកគេ ហើយយើងអាចចុះឈ្មោះឲ្យពួកគេបាន ។ ពួកគេក៏អាចបោះឆ្នោតជា CVR និងបោះឆ្នោតតាមរយៈសន្លឹកឆ្នោត CVR បានផងដែរ ។ តើខ្ញុំឆ្លើយសំណួររបស់អ្នកទេ?
   ii. ការឆ្លើយតបរបស់អ្នកចូលរួម៖ បាទ /ចាំះ ខ្ញុំពិតជាមិនអាចរកវាឃើញនៅលើគេហទំព័រទេ ដែលនោះធ្វើឲ្យខ្ញុំមានការព្រួយបារម្ភខ្លះ ពីព្រោះបច្ចុប្បន្ននេះកម្រិតលទ្ធភាពចូលរួមបានរបស់អ្នកបោះឆ្នោតមានច្រើនណាស់ ដែលវាជាការប្រសើរបំផុតមិនធ្លាប់មានពីមុនមក ប៉ុន្តែតើនោះមានន័យថាវានឹងអាចចូលរួមបានដោយក្រុមប្រជាជនដែលគ្មានផ្ទះសម្បែងទេ?
   iii. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំះ វាពិតណាស ពួកគេគប្បីមានលទ្ធភាពចូលរួមបានដូចគ្នាទៅនឹងអ្នកបោះឆ្នោតដទៃផ្សេងទៀតដែរ ។ បច្ចុប្បន្ននេះយើងចុះឈ្មោះឲ្យ ប្រសិនបើនរណាម្នាក់មិនមានអាសយដ្ឋានដើម្បីបញ្ចូលក្នុងបញ្ជីលំនៅដ្ឋានរបស់គេ យើងអាចយកលេខផ្លូវកាត់ ដូច្នេះយើងអាចផ្តល់ឲ្យពួកគេនូវប្រភេទសន្លឹកឆ្នោតជាក់លាក់ ។
   iv. ការឆ្លើយតបរបស់អ្នកចូលរួម៖ ប្រសិនបើពួកគេត្រូវប្តូរ RV របស់គេរៀងរាល់ 72 ម៉ោងនោះ តើនោះដំណើរការយ៉ាងដូចម្តេចប្រសិនបើផ្លូវកាត់ខុសគ្នារាល់ដងនោះ?
   v. ការឆ្លើយតបរបស់ ROV៖ នៅពេលគេចេញទៅបោះឆ្នោត គេអាចចុះឈ្មោះឡើងវិញបាន ហើយគេអាចប្តូរការចុះឈ្មោះរបស់គេបានតាមអនឡាញបានរាល់ថ្ងៃទៅតាមទីកន្លែងដែលគេចង់បោះឆ្នោត ។ ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌនឹងអនុញ្ញាតឲ្យយើងបោះឆ្នោតបាននៅតាមមណ្ឌលបោះឆ្នោតមួយណាក៏បាន ។

g. អ្នកចូលរួម (សំណួរ 7)៖ សម្រាប់ព្រំប្រទល់បោះឆ្នោត 10k និង 50k និងទាក់ទងទៅនឹងទិន្នន័យពេលថ្ងៃសម្រាប់ខោនធី Palo Alto ចំនួនប្រជាជនបោះឆ្នោតរបស់ខ្លួនមានរហូតដល់បីដងនៅពេលថ្ងៃ ។ ខ្ញុំសប្បាយចិត្តដែលអ្នកធ្វើការនៅក្នុងទីតាំងមណ្ឌលបោះឆ្នោតមានចំនួនប្រជាជន 50k ប៉ុន្តែខោនធី Palo Alto អាចមានចរាចរណ៍ចង្អៀតនៅលើផ្លូវ 101 ហើយវាពិបាកនិយាយពីរបៀបដែលអ្នកបោះឆ្នោតជ្រើសរើសបោះឆ្នោតជាមួយនឹងពេលវេលាពង្រីកបន្ថែម ។ ខ្ញុំបារម្ភថាតំបន់មួយចំនួននឹងត្រូវមានសុទ្ធតែមនុស្ស ដែលកំពុងរស់នៅទីនោះ ឬអាចមិនរស់នៅទីនោះ ប៉ុន្តែពួកគេរស់នៅក្នុង San Jose ហើយអ្នកកំពុងរាប់ការបោះឆ្នោតរបស់គេនៅក្នុង San Jose ជាចំនួនមណ្ឌលបោះឆ្នោតរបស់គេ ។ តើមានមធ្យោបាយអីក្នុងកំឡុងពេលចាប់ផ្តើមការបោះឆ្នោតបឋម

ជ្រើសរើសប្រធានាធិបតី ដែលយើងនឹងតាមដានពីលក្ខណៈដែលតំបន់មួយចំនួនកំពុងត្រូវបានប្រើប្រាស់ច្រើនជាង ហើយតំបន់ផ្សេងៗទៀតត្រូវបានប្រើប្រាស់តិចជាងនោះ?

i. ការឆ្លើយតបរបស់ ROV៖ យើងនឹងអាចមើលឃើញមានមណ្ឌលបោះឆ្នោតមួយចំនួនមានសកម្មភាពច្រើនជាង មានសន្លឹកឆ្នោតដែលបានបោះច្រើនជាង ។ល។ ប្រហែលជានៅពេលអនាគត យើងអាចស្វែងរកមណ្ឌលបោះឆ្នោតបន្ថែមនៅក្នុងតំបន់ទាំងនោះ ហើយសម្រាប់ការបោះឆ្នោតនេះ យើងពិតជាអាចយកមកពិចារណា ដើម្បីឲ្យឃើញថាតើយើងអាចបង្កើនបាននៅក្នុងតំបន់ជាក់លាក់មួយចំនួន ។

ii. ការឆ្លើយតបរបស់ ROV៖ យើងចង់យកចំនួនប្រជាជននៅពេលថ្ងៃមកពិចារណា ប៉ុន្តែមិនមានទិន្នន័យដែលអាចរកបាន ។ នៅក្នុងតំបន់ដែលយើងគិតថានឹងមានការងារច្រើនដែលស្ថិតនៅជិតប្រហាក់ប្រហែលទៅនឹងស្តង់ដាទីក្រុងនោះ យើងបានព្យាយាមធ្វើឲ្យចំនួនតូចជាង 50k បន្តិច ហើយនៅក្នុងតំបន់លំនៅដ្ឋានយើងអាចដាក់មនុស្សបានច្រើនជាង ។

h. អ្នកចូលរួម (សំណួរ 8)៖ អ្វីកើតឡើងនៅពេលនរណាម្នាក់បោះឆ្នោតដោយសំបុត្រហើយសម្រេចចិត្តបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតវិញ ។

i. ការឆ្លើយតបរបស់ ROV៖ ប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតរបស់យើងនឹងអាចចូលបានពីគ្រប់មណ្ឌលបោះឆ្នោតតាមរយៈឧបករណ៍បោះឆ្នោតអេឡិចត្រូនិក ។ យើងនឹងអាចមើលដឹងថាតើបុគ្គលនេះបានបោះឆ្នោតហើយឬនៅ ។ យើងអាចប្តូរពីការចុះហត្ថលេខានៅលើបញ្ជីឈ្មោះទៅប្រើម៉ាស៊ីនស្កែនរកឈ្មោះវិញ ។ បច្ចុប្បន្ននេះបុគ្គលិកនឹងអាចរកមើលឈ្មោះរបស់អ្នកឃើញនៅលើឧបករណ៍បោះឆ្នោតអេឡិចត្រូនិករបស់យើង ហើយអាចចូលទៅកាន់ព័ត៌មានដែលនឹងជាព័ត៌មានស្តីពីការចុះឈ្មោះបោះឈ្មោះថ្មីៗរបស់អ្នក ហើយនិងព័ត៌មានបោះឆ្នោតដោយសំបុត្រ ។ យើងនឹងអាចប្រាប់អ្នកបានប្រសិនបើអ្នកបោះឆ្នោតបានបោះឆ្នោតរួច ហើយអាចដឹងបានប្រសិនបើគាត់បានបោះ – យើងនឹងមិនផ្តល់សន្លឹកឆ្នោតដល់អ្នកទាំងនោះដែលបានបោះរួចនោះទេ ។ មានសន្លឹកឆ្នោតបណ្តោះអាសន្ន (PV) ផងដែរ -- យើងមិនអាចបដិសេធសិទ្ធិបោះឆ្នោតរបស់នរណាម្នាក់បានឡើយ នៅពេលពួកគេមកកាន់ការិយាល័យបោះឆ្នោត ប៉ុន្តែប្រសិនបើយើងកំណត់បានថាបុគ្គលម្នាក់នោះបានបោះឆ្នោតរួច ហើយគេនៅតែទាមទារបោះទៀត យើងនឹងអនុញ្ញាតឲ្យពួកគេបោះបាន ប៉ុន្តែពួកគេត្រូវតែដាក់សន្លឹកឆ្នោតរបស់គេចូលទៅក្នុងស្រោមសំបុត្របណ្តោះអាសន្ន ដែលត្រូវបានរក្សាទុកដាច់ដោយឡែក ហើយមិនត្រូវបានរាប់បញ្ចូលនៅឯមណ្ឌលបោះឆ្នោតឡើយ ។ ស្រោមសំបុត្រ PV នឹងត្រឡប់មកកាន់ការិយាល័យយើងវិញ ហើយយើងនឹងរកមើលព័ត៌មានរបស់គេដែលគេបានបំពេញនៅលើស្រោមសំបុត្រ ។ សន្លឹកឆ្នោតនឹងមិនត្រូវបានបើកឡើយប្រសិនបើពួកគេបានបោះរួចហើយនោះ ។

i. អ្នកចូលរួម (សំណួរ 9)៖ តើម៉ាស៊ីនរាប់សន្លឹកឆ្នោតរបស់អ្នកត្រូវបានផ្តាច់ចេញពីអ៊ីនធឺណិតទេ ប្រសិនបើមិនបានផ្តាច់ទេ តើអ្នកអាចធានាថាវាមិនត្រូវបានវាយប្រហារបានទេ?

i. ការឆ្លើយតបរបស់ ROV៖ ប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើងគឺត្រូវបានផ្តាច់ចេញទាំងស្រុងពីអាកាស មានន័យថាវាស្ថិតនៅលើបណ្តាញកំព្យូទ័រឯកជនដែលម៉ាស៊ីនគណនាត្រូវបានភ្ជាប់ទៅខ្លួនវាតែប៉ុណ្ណោះ ហើយនឹងភ្ជាប់ទៅកាន់ម៉ាស៊ីនរាប់មេតែប៉ុណ្ណោះ ។ ពួកវាមិនត្រូវបានប៉ះពាល់ទៅនឹងបណ្តាញកុំព្យូទ័រផ្ទៃក្នុងរបស់ខោនធី ឬ ប្រព័ន្ធអ៊ីនធឺណិតខាងក្រៅឡើយ ។ ឧបករណ៍គណនាសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ សុទ្ធតែមិនស្ថិតនៅលើប្រព័ន្ធអ៊ីនធឺណិតទាំងអស់ ពួកវាមិនបញ្ជូនលទ្ធផលត្រឡប់មកយើងវិញទេ យើងដោយផ្ទាល់ត្រូវតែយកដុំឧបករណ៍ផ្ទុកទិន្នន័យចេញពីម៉ាស៊ីន ហើយត្រូវបើកដឹកវាយកត្រឡប់មកកាន់ការិយាល័យវិញដោយផ្ទាល់ ។ យើងក៏បានត្រៀមប្រូតាកូលសុវត្ថិភាពជាច្រើនរួចជា

ស្រេចដែរ យើងនឹងយក USBs ដែលស្ថិតនៅខាងក្រៅបណ្តាញ ហើយដោតភ្ជាប់វាទៅនឹងម៉ាស៊ីនណាមួយដែលត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើង ។ នៅពេលយើងបង្ហោះលទ្ធផលនៅលើគេហទំព័ររបស់យើង វាមិនត្រូវបានបញ្ជូនចេញតាមប្រព័ន្ធរាប់សន្លឹកឆ្នោតរបស់យើងទេ ។ អ្វីដែលយើងកំពុងធ្វើគឺយើងកំពុងបញ្ចេញលទ្ធផលមួយច្បាប់ ហើយរក្សាវាដាក់នៅលើឧបករណ៍ផ្ទុកទិន្នន័យ USB ហើយក៏ដើរយកវាទៅដាក់នៅម៉ាស៊ីនមួយទៀតដែលត្រូវបានភ្ជាប់ទៅនឹងអ៊ីនធឺណិត ហើយយើងបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធ ។ លទ្ធផលដែលអ្នកមើលឃើញនៅតាមផ្ទះជាច្បាប់ចតចម្លង ដូច្នេះប្រសិនបើនរណាម្នាក់វាយប្រហារនៅលេគេហទំព័រដែលបង្ហាញលទ្ធផល ពួកគេនឹងមិនកែប្រែការបោះឆ្នោតឡើយ ។ ក្រោយពី USBs ត្រូវបានដោតចូលទៅនឹងឧបករណ៍ហើយ វានឹងត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក ធ្វើបែបនេះវាមិនត្រឡប់មកវិញ និងប៉ះពាល់ដល់បណ្តាញសុវត្ថិភាពយើងឡើយ ។

j. អ្នកចូលរួម (សំណួរ 10)៖ តើខ្ញុំដូចជាបានឮអ្នកនិយាយពីការគណនាឬរាប់សន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតក្រោយការបិទបញ្ចប់នៅយប់បោះឆ្នោតទេ?
    i. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំះ នៅពេលអ្នកបោះឆ្នោតទៅបោះឆ្នោត ពួកគេនឹងយកសន្លឹកឆ្នោតរបស់គេទៅកាន់ម៉ាស៊ីនគណនាសម្លេងឆ្នោត ។ ប្រព័ន្ធនឹងឲ្យពួកគេដឹងថាតើគេបោះលើស បោះខ្វះ ឬជ្រើសរើសច្រើនជម្រើសពេក ។ នៅពេលគេចាប់ផ្តើមដំណើរការវាតាមគ្រឿងបរិក្ខារហើយគេបោះសន្លឹកឆ្នោតភ្លាមនោះ នៅពេលនោះវានឹងគណនាវាចូលទៅក្នុងប្រព័ន្ធ ហើយទម្លាក់សន្លឹកឆ្នោតរបស់ពួកគេចូលទៅក្នុងបន្ទុកដែលមានសុវត្ថិភាពមួយ ។ ក្រោយយប់បោះឆ្នោតត្រូវបានបិទបញ្ចប់ ខាតទ្រីចនឹងត្រូវនាំយកត្រឡប់មកកាន់ការិយាល័យចុះបញ្ជីបោះឆ្នោត ដែលជាកន្លែងយើងនឹងដាក់បញ្ចូលវាទៅក្នុងប្រព័ន្ធរបស់យើង ហើយការគណនាទាំងអស់នៃសន្លឹកឆ្នោតទាំងអស់នឹងមកជាមួយអ្វីដែលយើងបានបង្ហោះនៅយប់បោះឆ្នោត ។

k. អ្នកចូលរួម (សំណួរ 11)៖ តើឧបករណ៍ស្កេនតារាងសន្លឹកឆ្នោតចាប់យកសញ្ញាគូសខុសនៅលើសន្លឹកឆ្នោតហើយបញ្ជូនវាត្រឡប់ទៅកាន់អ្នកបោះឆ្នោតដើម្បីកែតម្រូវទេ?
    i. ការឆ្លើយតបរបស់ ROV៖ បាទ /ចាំ វាទើបតែត្រូវបានពន្យល់រួចអម្បាញ់មិញ ។

l. អ្នកចូលរួម (សំណួរ 12)៖ ខ្ញុំគិតថាអ្នកបានឆ្លើយវារួចហើយ ។ ខ្ញុំបារម្ភពីពេលដែលវាត្រូវបានគណនារាល់ថ្ងៃ ។ ខ្ញុំបានឮរឿងរាវជាច្រើនពីការបោះឆ្នោតដែលត្រូវបានគេប្តូរ ។ ខ្ញុំគិតថានៅពេលអ្នកនិយាយពីសុវត្ថិភាព ខ្ញុំនៅតែបារម្ភថាទំរាំដល់ពេលពួកគេទទួលបានលទ្ធផល ការបោះឆ្នោតត្រូវបានប្តូរ ។ ចុះបើក្នុងករណីដែលពួកគេបោះឆ្នោត ហើយពួកគេយល់ថាពួកគេមិនចង់បោះឆ្នោតអញ្ចឹងទេ តើមានមធ្យោបាយអ្វីដែលអាចកែប្រែការបោះឆ្នោតរបស់គេបានទេ?
    i. ការឆ្លើយតបរបស់ ROV៖ យើងនឹងផ្តល់នូវជម្រើសពីរនៅក្នុងមណ្ឌលបោះឆ្នោត ។ ជម្រើសមួយនឹងត្រូវយកសន្លឹកឆ្នោតក្រដាសដោយផ្ទាល់ ហើយគូសនៅលើជម្រើសទាំងឡាយរបស់អ្នកដោយគ្មានផ្ទាំងជ្រើសរើសជាអេឡិចត្រូនិក ។ របៀបម្យ៉ាងទៀតនោះ យើងនឹងមានឧបករណ៍គូសសន្លឹកឆ្នោតជាអេឡិចត្រូនិកផ្តល់ឱ្យ ។ វាមានលក្ខណៈដូចជាការស្ទាបលើផ្ទៃអេក្រង់ដែលយើងប្រើនាពេលបច្ចុប្បន្ននេះ ប៉ុន្តែជំនួសឲ្យការដាក់សន្លឹកឆ្នោតនៅលើអង្គចងចាំរបស់ម៉ាស៊ីននោះ វានឹងព្រីនសន្លឹកឆ្នោតចេញមកដោយមានការជ្រើសរើសទៅតាមអ្វីដែលបានគូសនៅលើវា ។ អ្នកបោះឆ្នោតនឹងមានឱកាសដើម្បីពិនិត្យមើលវាឡើងវិញ និងបញ្ចូលសន្លឹកឆ្នោតរបស់គេទៅក្នុងឧបករណ៍គណនាសម្លេងឆ្នោត ។ មានក្រដាសសន្លឹកឆ្នោតព្រៀងដែលអ្នកបោះឆ្នោតមានឱកាសដើម្បីផ្ទៀងផ្ទាត់និងធ្វើឲ្យប្រាកដថាការជ្រើសរើសត្រូវបានគូសត្រឹមត្រូវមុននឹងពួកគេបោះវា ។

ii. ការឆ្លើយតបរបស់ ROV៖ នៅក្នុងរដ្ឋ California យើងក៏បានកំណត់ឲ្យមានការធ្វើសវនកម្មក្រោយការបោះឆ្នោតផងដែរ នៅតាមកន្លែងដែលយើងនឹងកំណត់ប៉ាន់គំរូដោយចៃដន្យទៅលើសន្លឹកឆ្នោតក្រដាស និងការរាប់សន្លឹកឆ្នោតក្រដាសដោយផ្ទាល់ដៃ ហើយប្រៀបធៀបវាទៅនឹងលទ្ធផលនៃការបោះឆ្នោត។ យើងអាចចាប់យកបានប្រសិនបើមានលំនាំដូចៗគ្នានៃអ្វីមួយដែលកើតឡើងចំពោះលទ្ធផលចេញមកពីសកម្មភាពទុច្ចរិតឬជាកំហុសសុទ្ធសាធ ។ ជាមួយនឹងគ្រឿងបរិក្ខារថ្មី យើងនឹងមានមុខងារមួយដែលត្រូវបានគេហៅថាជាការវិនិច្ឆ័យ ។ ប្រសិនបើអ្នកបោះឆ្នោតបង្កើតឲ្យមានកំហុសនៅលើរបៀបគូសសន្លឹកឆ្នោត ហើយបណ្តាលឲ្យម៉ាស៊ីនអានខុស យើងអាចបដិសេធចោលនូវជម្រើសដែលបានគូសនៅលើវា ហើយត្រូវប្រាកដថាជម្រើសជាចេតនារបស់អ្នកបោះឆ្នោតត្រូវបានជ្រើសរើសយក ។ អ្វីដែលប្រព័ន្ធបោះឆ្នោតធ្វើនោះគឺបង្កើតនូវការធ្វើសវនាកម្មសាកល្បងទៅលើសកម្មភាពណាមួយដែលយើងបានធ្វើនៅលើសន្លឹកឆ្នោតទាំងនោះ ។ ជាទូទៅយើងមានអ្នកសង្កេតការណ៍ចូលមក ហើយយើងអាចបង្ហាញដល់ពួកគេពីគន្លងគ្រប់សន្លឹកឆ្នោតនីមួយៗ និងបង្ហាញដល់ពួកគេនូវរូបភាពនៃសន្លឹកឆ្នោត ក៏ដូចជាស្វែងរកសន្លឹកឆ្នោតក្រដាសផងដែរ ។ យើងអាចប្រៀបធៀបអ្វីដែលធ្វើនេះ ទៅនឹងអ្វីដែលប្រព័ន្ធបោះឆ្នោតបានអាន រាប់ និងបានបង្ហាញការជ្រើសរើសនៅលើសន្លឹកឆ្នោតនីមួយៗ ។

m. ការឆ្លើយតបរបស់ ROV៖ ប្រសិនបើពួកគេបានបោះសន្លឹកឆ្នោតរបស់គេរួច ពោលគឺនៅពេលវាត្រូវបានបោះភ្លាម ពួកគេនឹងអាចកែប្រែវាបាននៅពេលនោះ ។ យើងមានកម្រិតនៃតម្លាភាពនិងលទ្ធភាពសវនកម្មខ្ពស់ ដូច្នេះយើងគិតថានេះនឹងជាប្រព័ន្ធមួយដែលមានសុវត្ថិបំផុត ។ យើងអាចបង្ហាញឲ្យមើលពីដំណើរនោះបានដល់នរណាម្នាក់ដែលចាប់អារម្មណ៍ ។

## XI. សេចក្តីសន្និដ្ឋាន

a. សេចក្តីសន្និដ្ឋានរបស់ ROV៖ សូមថ្លែងអំណរគុណចំពោះការចូលរួម, មតិយោបល់ និងមតិត្រឡប់របស់អ្នកទាំងអស់គ្នា ។ យើងនៅតែបន្តទទួលយកនូវមតិត្រឡប់រហូតដល់ថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 2019 ។ រយៈពេលសម្រាប់សាធារណជនផ្តល់មតិយោបល់មួយទៀតនឹងបើកនៅពេលសេចក្តីពង្រៀងដែលកែសម្រួលរួចត្រូវបានចេញផ្សាយ ។

**County of Santa Clara**

**Registrar of Voters**

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314

www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

## កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាលទ្ធភាពប្រើប្រាស់ភាសា

1400 Parkmoor Ave., San Jose, CA 95126

បន្ទប់ Cupertino B

ថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 ម៉ោង 3:00 រសៀល

I. ការណែនាំ
   a. បុគ្គលិកការិយាល័យកាន់បញ្ជីអ្នកបោះឆ្នោត (ROV)
   b. សមាជិកគណៈកម្មាធិការ

II. គោលបំណងនៃកិច្ចប្រជុំ
   a. ការចូលរួមរបស់សមាជិក និងសាធារណៈ
   b. ROV
   c. ការបង្កើតបេសកកម្ម

III. ការបង្កើតគោលការណ៍ណែនាំ និងគោលដៅនៃកិច្ចប្រជុំ
   i. ច្បាប់មូលដ្ឋាន
   ii. ការរំពឹងទុករបស់សមាជិក៖ ឯកសារចែកជូន

IV. ការពិភាក្សាទូទៅនៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA)
   a. ទិដ្ឋភាពទូទៅ
      i. ការផ្លាស់ប្តូរពីគំរូកន្លែងបោះឆ្នោតតាមបែបប្រពៃណី
      ii. លក្ខខណ្ឌតម្រូវភាសាសម្រាប់ VCA
      iii. គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត
   b. សំណួរ

V. មតិត្រឡប់ សំណួរនិង / ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ

VI. ការជ្រើសរើសសមាជិកថ្មី

VII. កិច្ចប្រជុំបន្ទាប់៖ ថ្ងៃទី 19 ខែមិថុនា ពេលវេលា និងទីតាំងតែមួយ
   a. មជ្ឈមណ្ឌលមិនស្វែងរកកម្រៃ Sobrato
   b. ការបង្កើតរបៀបវារៈ
   c. គំនិតសម្រាប់កិច្ចប្រជុំ និងកាលបរិច្ឆេទបន្ថែម

VIII. សេចក្តីប្រកាស

IX. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

*កន្លែងទាំងនេះជាកន្លែងដែលអាចចូលប្រើប្រាស់បាន។ សម្រាប់សំណើសុំឯកសារក្នុងទម្រង់ដែលប្រើប្រាស់បាន សេវាកម្មបកប្រែផ្ទាល់មាត់ ឧបករណ៍ជំនួយក្នុងការស្តាប់ ឬទីស្នាក់អាស្រ័យផ្សេងទៀត សូមធ្វើការទំនាក់ទំនងដោយទូរសព្ទទៅកាន់ ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត ឬផ្នែកបម្រើសេវារដ្ឋបាល តាមរយៈលេខ៖ (408) 918-9169 ឬ អាចធ្វើសំណើតាមរយៈអ៊ីមែលទៅកាន់ voterschoice@rov.sccgov.org ដោយមិនយឺតជាងប្រាំថ្ងៃធ្វើការមុនថ្ងៃប្រជុំ។*

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara
# គណៈកម្មាធិការប្រឹក្សាការទទួលបានភាសា (LAAC)
## កំណត់ហេតុនៃកិច្ចប្រជុំ

1400 Parkmoor Ave., San Jose, CA 95126
បន្ទប់ Cupertino B
ថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 ម៉ោង 3:00 រសៀល

**វត្តមានសមាជិក៖** Erin Choi, Charlotte Roman, Sophia Kao, Jessica Ho, Nicole Wong, Yeshi Teklemichael

**វត្តមានបុគ្គលិក៖** Shannon Bushey, Darren Tan, Virginia Bloom, Robert Wiedlin, Lorenzo Castaneda, Amy Sun, Thuytien Bui, Smita Shah, Michael Borja, Paulo Chang, Eimear Duncan, Edwin Torralba, Ruth Luo, Rachel Jung, Alfred Gonzalez, Stephanie Duarte, Ralph Murrieta Jr., Chenxi Ye, Bob Nguyen, Mike Fong, Carmelita Aldana, Julia Saenz, Lance Nottle, Liz Oviedo, Anazay Rivera, Chipo Mulenga, Shierry Anne Mangligot

**ចំណុចសកម្មភាព៖**

- ផ្ញើអ៊ីមែលទៅសមាជិកនូវឯកសារដែលរំពឹងទុកសមាជិក voterschoice.org និងទម្រង់ SOS គេហទំព័រ VCA
- ផ្នែកប្រតិបត្តិការក្នុងតំបន់ ក្នុងការផ្ញើនាមបណ្ណទៅសមាជិកគណៈកម្មាធិការអំពីព្រឹត្តិការណ៍ជនភៀសខ្លួននៅថ្ងៃសុក្រក្រោយ (6/14/19)

I. សេចក្តីណែនាំ - Darren Tan ប្រធានផ្នែកសេវាកម្មរដ្ឋបាលបានផ្តល់ជូនដូចខាងក្រោម៖
   a. ការស្វាគមន៍ដល់សមាជិក
   b. ការណែនាំបុគ្គលិក
   c. បុគ្គលិកកាន់បញ្ជីអ្នកបោះឆ្នោត (ROV)
   d. សមាជិកគណៈកម្មាធិការ

II. គោលបំណងនៃកិច្ចប្រជុំ
   a. ការចូលរួមរបស់សមាជិក និងសាធារណៈ
      i. តើអ្នកចង់ឃើញអ្វីខ្លះពីកិច្ចប្រជុំ?

         *ការចូលរួមរបស់អ្នកចូលរួម*

         1. ដើម្បីជាជំនួយដល់អតិថិជន/អ្នកជំងឺនៃមជ្ឈមណ្ឌលអ្នកចូលរួមក្នុងការចុះឈ្មោះបោះឆ្នោត
         2. ចូលរួមចំណែកក្នុងសហគមន៍ជនអន្តោប្រវេសន៍ជំនាន់ទីមួយ និងសហគមន៍កោះ-អាស៊ីប៉ាស៊ីហ្វិក (API) ។
         3. ចូលរួមជាមួយសមាជិកសហគមន៍សម្រាប់ VCA ដែលអាចត្រូវការសិក្ខាសាលាសម្រាប់ភាសាផ្សេងៗគ្នា
         4. ពលរដ្ឋម្នាក់បានត្រៀមខ្លួនរួចជាស្រេចដើម្បីចូលរួម និងមានភាពរីករាយក្នុងការចូលរួម
         5. ណែនាំសហគមន៍សេវាកម្មកូរ៉េសម្រាប់សហការជាមួយអង្គការផ្សេងៗគ្នា។ ភ្ជាប់ទំនាក់ទំនងជាមួយជនជាតិកូរ៉េជំនាន់មនុស្សចំណាស់ដែលមានភាពពិបាកជាមួយភាសាអង់គ្លេស។ ក៏ចង់បកប្រែទៅសហគមន៍កូរ៉េទាក់ទងនឹងការអនុវត្តថ្មីចំពោះ SB450 VCA ។
         6. ភាគច្រើននៅក្នុងសហគមន៍អេត្យូពីមិននិយាយភាសាអង់គ្លេសទេ ហើយពួកគេភាគច្រើនមិនចូលរួមក្នុងការចូលរួមរបស់ពលរដ្ឋទេ។ សង្ឃឹមថាភាសានោះមិនក្លាយជាឧបសគ្គទេ ហើយពួកគេនឹងស្វែងរកវេទិកានៅក្នុងតំបន់មួយចំនួន។

b. ROV

1. តើកន្លែងណាដែលសហគមន៍ត្រូវការភាសារបស់អ្នក?
2. យើងចង់ភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍
3. យើងចង់ចែករំលែកសេវាកម្មដែលយើងផ្តល់ជូន
4. យើងកំពុងស្វែងរកការចូលរួមពីសហគមន៍របស់យើង
5. កំពុងស្វែងរកមតិត្រឡប់

c. ការបង្កើតបេសកកម្ម

i. លោក Tan បានលើកឡើងថាបញ្ហានេះនឹងត្រូវបានពិភាក្សា និងអភិវឌ្ឍក្នុងកិច្ចប្រជុំបន្ទាប់

III. ការបង្កើតគោលការណ៍ណែនាំ និងគោលដៅនៃកិច្ចប្រជុំ

a. ច្បាប់មូលដ្ឋាន

b. ការរំពឹងទុករបស់សមាជិក៖ ឯកសារចែកជូន

c. *សំណួរអ្នកចូលរួម*

1. តើសមាជិកនឹងអាចជួយក្នុងការបង្កើតរបៀបវារៈដែរឬទេ?
   a. ការឆ្លើយតប៖ បាទ/ចាស សមាជិកនឹងទទួលបានឱកាសនៅឯកិច្ចប្រជុំនីមួយៗ ដើម្បីពិភាក្សាក្នុងការបន្ថែមចំណុចនានាទៅក្នុងរបៀបវារៈបន្ទាប់
2. ការរំពឹងទុក នៅពេលមានមតិត្រឡប់ត្រូវបានលើកឡើង តើអ្នកនឹងមាននីតិវិធីឆ្លើយតប ឬប្រាស្រ័យទាក់ទងជាមួយក្រុមនោះដែរឬទេ?
   a. ការឆ្លើយតប៖ បាទ/ចាស រាល់មតិត្រឡប់ទាំងអស់នឹងត្រូវបានតាមដាន និងទទួលស្គាល់
3. ស្នើសុំឲ្យគណៈកម្មាធិការដឹងនៅពេលយោបល់ និងមតិត្រឡប់ណាមួយផ្តល់មក

IV. ការពិភាក្សាទូទៅអំពីច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) ដោយលោក Paulo Chang អ្នកសម្របសម្រួលផ្នែកប្រតិបត្តិការរៀបចំការបោះឆ្នោតប្រតិបត្តិការក្នុងតំបន់

i. ទិដ្ឋភាពទូទៅ

ii. ការផ្លាស់ប្តូរពីគំរូកន្លែងបោះឆ្នោតតាមបែបប្រពៃណី

iii. លក្ខខណ្ឌតម្រូវភាសាសម្រាប់ VCA

iv. គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

*សំណួរអ្នកចូលរួម*

v. តើកន្លែងណា ហើយយើងនឹងធ្វើយុទ្ធសាស្ត្រមណ្ឌលបោះឆ្នោតដោយរបៀបណា (VC)?

1. ការឆ្លើយតប៖ មានអាណត្តិផ្អែកលើដង់ស៊ីតេប្រជាជនដែលកំណត់តំបន់សម្រាប់កន្លែងដែលគេគួរកំណត់ដាក់មណ្ឌលបោះឆ្នោត។ ទីតាំងសក្តានុពលនៃមណ្ឌលបោះឆ្នោតនឹងត្រូវបានពិភាក្សានៅឯកិច្ចប្រជុំនាពេលអនាគត ហើយការធ្វើបច្ចុប្បន្នភាពចំពោះទីតាំងដែលបានកំណត់នឹងត្រូវបានផ្តល់ជូន

vi. តើអ្នកមានព័ត៌មានសម្រាប់ទីតាំងដែលមានចំនួនប្រជាជនច្រើនទេ?

1. ការឆ្លើយតប៖ ព័ត៌មានអំពី VC ទាំងអស់នឹងត្រូវផ្តល់ជូនដោយក្រសួង

vii. តើយើងអាចប្រើសាលារៀន និងបរិវេណមហាវិទ្យាល័យបានទេ?

1. ការឆ្លើយតប៖ បាទ/ចាស ។

viii. តើភាសាខុសគ្នាចំនួន 8 មានអ្វីខ្លះ?

1. ភាសាចំនួន 4 ត្រូវបានតម្រូវ ហើយ 2 ផ្សេងទៀតត្រូវបានតម្រូវដោយរដ្ឋ។ ភាសាចំនួន 2 បន្ថែមទៀតត្រូវបានកំណត់ដោយរដ្ឋដែល ROV នៅតែទទួលស្គាល់
2. ភាសា៖ អេស្ប៉ាញ វៀតណាម ចិន តាហ្គាល (4 ត្រូវបានកំណត់) ហិណ្ឌូ ខ្មែរ កូរ៉េ ជប៉ុន

ix. តើយើងនឹងមានការបោះឆ្នោតនៅខែវិច្ឆិកា ឆ្នាំ 2019 ឬ?

1. ការឆ្លើយតប៖ នៅពេលនេះ មិនមានសំណើណាមួយត្រូវបានធ្វើឡើងដោយក្រុង ឬសង្កាត់ទេ។ ថ្ងៃផុតកំណត់ក្នុងការដាក់បញ្ជូនសំណើសម្រាប់ការបោះឆ្នោតនាខែវិច្ឆិកាគឺថ្ងៃទី 3 ខែកក្កដាសម្រាប់គណៈអភិបាលគ្រប់គ្រង និងថ្ងៃទី 9 ខែសីហា សម្រាប់ក្រុងនានា

x. តើអ្នកត្រូវប្តេជ្ញាចិត្តធ្វើការជាមួយ VC ពេញមួយថ្ងៃ ឬពេញមួយសប្តាហ៍ដែរឬទេ?

1. ការឆ្លើយតប៖ បុគ្គលិកដែលដាក់ពាក្យសុំធ្វើជាបុគ្គលិក VC នឹងត្រូវបានស្នើសុំឱ្យធ្វើការសម្រាប់រយៈពេលទាំងមូលនៃ VC ។ ភាគីនានាមានចាប់អារម្មណ៍ដែលចង់ធ្វើការមួយថ្ងៃនៅតែអាចស្ម័គ្រចិត្តបាន

xi. ជំរឿននឹងចាប់ផ្តើមនៅប្រហែលខែមីនា ឆ្នាំ 2020 តើមានអ្វីកើតឡើង ប្រសិនបើនរណាម្នាក់ទៅមណ្ឌលបោះឆ្នោត ហើយសុំជំនួយអំពីជំរឿន។ ចំពោះអ្នកខ្លះ ពួកគេមានតែមួយ។ វាអាចមានការភាន់ច្រឡំខ្លះជាមួយអ្នកជំងឺរបស់ពួកគេ ។

1. ការឆ្លើយតប៖ ROV ភ្ជាប់ទំនាក់ទំនងជាមួយប្រជាជនជំរឿន ដើម្បីរកគំនិតមើលថាតើអាចរួមបញ្ចូលជំរឿន និង ROV នៅទីតាំងមួយចំនួនដែរឬទេ
2. ការឆ្លើយតប៖ បច្ចុប្បន្ន ROV កំពុងធ្វើការជំរឿនប្រជាជននៅតាមក្រុមសហគមន៍ទាំងអស់ ។

xii. តើយើងបាននឹងកំពុងធ្វើការជាមួយក្រុមប្រឹក្សាក្រុងដែរឬទេ?

1. ការឆ្លើយតប៖ ROV បានរួមបញ្ចូលការប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាក្រុង ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់ខ្លួនសម្រាប់ VCA

xiii. តើអ្នកនឹងធ្វើអ្វីជាមួយភាសាដែលមិនចាំបាច់?

1. ការឆ្លើយតប៖ កន្លងមក ការិយាល័យបានព្យាយាមផ្សព្វផ្សាយទៅដល់សហគមន៍ភាសាជាច្រើនតាមដែលអាចធ្វើបាន ដើម្បីមើលថាតើវាអាចជួយឱ្យពួកគេមកបោះឆ្នោតបានយ៉ាងដូចម្តេច
2. *ការឆ្លើយតបរបស់អ្នកចូលរួម៖* បានធ្វើការជាមួយអង្គការនានាក្នុងសង្កាត់ដែលមានភាសាដែលមិនទាន់បានកំណត់ ។ ពួកគេបានប្រើសមាជិកសហគមន៍ ដើម្បីជួយ ។ អ្នកក៏ត្រូវបានអនុញ្ញាតឱ្យនាំយកជំនួយការពីរនាក់ ដើម្បីជួយដល់ការបោះឆ្នោតរបស់ពួកគេ

xiv. តើយើងនឹងមានសន្លឹកឆ្នោតផ្លូវការចំនួន 8 ដែលបានបកប្រែហើយឬនៅ?

1. ការឆ្លើយតប៖ គោលដៅរបស់ ROV គឺត្រូវមានការបកប្រែជា 8 ភាសាជាសន្លឹកឆ្នោតផ្លូវការ

xv. តើអ្នកមានគម្រោងផ្តោតលើតំបន់គោលដៅជាមួយអ្នកនិយាយភាសាជាក់លាក់ទេ?

1. ការឆ្លើយតប៖ បាទ/ចាស។ គោលបំណងមួយក្នុងគោលបំណងរបស់ LAAC គឺដើម្បីជួយក្នុងការកំណត់តំបន់គោលដៅ

xvi. អ្នកស្ម័គ្រចិត្ត៖ ប្រសិនបើអ្នកមានបញ្ហាក្នុងការជ្រើសរើសជំនួយការ តើអ្នកនឹងជ្រើសរើសនិស្សិត ឬអ្នកស្ម័គ្រចិត្តដែលអាចធ្វើជាអ្នកស្ម័គ្រចិត្តដែរឬទេ ។

1. ការឆ្លើយតប៖ បាទ/ចាស

xvii. EAP តើពួកគេបែងចែកដាច់ដោយឡែកពី LAAC មែនទេ?

1. មនុស្សមួយចំនួនដែលមានការថែទាំកុមារអាចមានភាពលំបាក ។
2. វាពិតជាលំបាកណាស់ក្នុងការចូលរួមសហគមន៍ ជាពិសេសសម្រាប់ការបោះឆ្នោត។ តើមានវិធីឱ្យពួកគេចូលរួមព្រឹត្តិការណ៍សហគមន៍ផ្សេងទៀតទេ? វាអាចទាក់ទាញមនុស្សមួយក្រុមធំ។ ដូចជាព្រះវិហារបោះបង់ចោលកិច្ចប្រជុំជាក្រុមដែរ ROV កំពុងចូលរួមព្រឹត្តិការណ៍សហគមន៍ដែលមានស្រាប់ ។
3. តើយើងទាក់ទងដោយរបៀបណា?
    a. ការឆ្លើយតបចំពោះសំណួរ 1-3៖ ក្រុមការងារផ្សព្វផ្សាយផ្នែកប្រតិបត្តិការក្នុងតំបន់បង្កើតព្រឹត្តិការណ៍ផ្សព្វផ្សាយជាច្រើនក្នុងមួយខែ។ ហើយតែងតែស្វែងរកព្រឹត្តិការណ៍ និងអង្គការនានា ដើម្បីចុះទៅទស្សនកិច្ច។ ប្រសិនបើគណៈកម្មាធិការដឹងអំពីរឿងណាមួយ ក្រុមផ្សព្វផ្សាយនឹងធ្វើការណែនាំបន្ត
4. សំណួរបើកចំហរបញ្ចប់ ឬតើអ្នកនឹងបង្ហាញសេចក្តីព្រាងសំរាប់ EAP ដែរឬទេ?

a. ការឆ្លើយតប៖ បាទ/ចាស ។ កិច្ចប្រជុំជាសាធារណៈរបស់ EAP គឺជាវេទិកាបើកចំហមួយ ដើម្បីផ្តល់ឱកាសសួរសំណួរទាក់ទងនឹង VCA

5. តើសេចក្តីបិទប្រកាស EAP ត្រូវបានបកប្រែយ៉ាងហោចណាស់នៅលើចំណងជើងដែរឬទេ

a. ការឆ្លើយតប៖ ឯកសារ EAP នឹងត្រូវបានបកប្រែជា 8 ភាសា

xviii. តើ (25) មណ្ឌលបោះឆ្នោតរយៈពេល 11 ថ្ងៃត្រូវបានទាមទារដែរឬទេ? តើអ្នកនឹងមានឆន្ទៈកែតម្រូវលេខដោយផ្អែកលើមតិត្រឡប់ដែលអ្នកទទួលបានឬទេ?

1. ការឆ្លើយតប៖ បាទ/ចាស មានការតម្រូវនូវចំនួន VC ដែលត្រូវការបើកសម្រាប់មនុស្សម្នាក់

xix. តើម៉ោងធ្វើការមានចំនួនប៉ុន្មានម៉ោង?

1. ការឆ្លើយតប៖ VC តម្រូវឱ្យបើកសម្រាប់រយៈពេល 8 ម៉ោងក្នុងមួយថ្ងៃ និង 13 ម៉ោងនៅថ្ងៃបោះឆ្នោត។ ពេលវេលាសម្រាប់ VCs ជាក់លាក់នឹងបើកមុន និងក្រោយ ប៉ុន្តែមិនមាននរណាម្នាក់ត្រូវបានគេស្គាល់អត្តសញ្ញាណនៅពេលនេះទេ

*ការចូលរួម ROV បន្ថែមទៅ VCA*

xx. បញ្ហាប្រឈមជាមួយការជួល

xxi. គំនិតនៃការចែករំលែកការធ្វើដំណើរ

xxii. យុទ្ធសាស្ត្រ VCA

xxiii. វានឹងមានសេវាកម្មបកប្រែសំឡេង

xxiv. យើងនឹងចែករំលែកបច្ចេកវិទ្យាបោះឆ្នោត នៅពេលពួកគេអាចប្រើបាន

xxv. យើងនឹងដាក់យុទ្ធសាស្ត្រដើម្បីដាក់អ្នកបកប្រែមួយចំនួននៅក្នុងតំបន់

b. សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី

i. តើអ្នកស្ម័គ្រចិត្តក្មេងជាងគេមានអាយុប៉ុន្មាន?

1. ការឆ្លើយតប៖ មានអាយុ 16 ឆ្នាំដោយមានការយល់ព្រមពីឪពុកម្តាយ អាណាព្យាបាល និងសាលារៀន

V. គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត (EAP)

a. សេចក្តីណែនាំស្តីពី EAP

b. អញ្ជើញសមាជិកចូលរួមកិច្ចប្រជុំពិគ្រោះយោបល់នាពេលអនាគត

VI. មតិត្រឡប់ សំណួរនិង / ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ

VII. ការជ្រើសរើសសមាជិកថ្មី

a. ROV បានផ្តល់ព័ត៌មានថ្មីៗលើទម្រង់ពិគ្រោះយោបល់សាធារណៈ EAP ដែលអាចបំពេញតាមអ៊ីនធឺណិតបាន

VIII. កិច្ចប្រជុំបន្ទាប់៖ ថ្ងៃទី 19 ខែមិថុនា ពេលវេលា និងទីតាំងតែមួយ

a. មជ្ឈមណ្ឌលមិនស្វែងរកកម្រៃ Sobrato

b. ការបង្កើតរបៀបវារៈកិច្ចប្រជុំបន្ទាប់

i. ទាក់ទងអ្នកពាក់ព័ន្ធ

ii. រៀបរាប់សង្ខេបទិដ្ឋភាពទូទៅ VCA ឡើងវិញ

iii. គំនិតនៃមណ្ឌលបោះឆ្នោត

iv. VEOC ដែលគ្របដណ្តប់

c. គំនិតសម្រាប់កិច្ចប្រជុំ និងកាលបរិច្ឆេទបន្ថែម

i. សមាជិកគណៈកម្មាធិការ ដើម្បីមតិត្រឡប់លើទីតាំង និងពេលវេលាសម្រាប់កិច្ចប្រជុំ

IX. សេចក្តីប្រកាស

X. សំណួរ និងចម្លើយគណៈកម្មាធិការ – សំណួរត្រូវបានគេចោទសួរពេញអង្គប្រជុំ ហើយសម័យប្រជុំសំណួរ និងចម្លើយមិនបានទទួលសំណួរបន្ថែមទេ

XI. កិច្ចប្រជុំបានផ្អាកនៅម៉ោង 5:00 ល្ងាច

**County of Santa Clara**

**Registrar of Voters**

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314

www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

---

### កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាលទ្ធភាពប្រើប្រាស់ភាសា

1400 Parkmoor Ave., San Jose, CA 95126
បន្ទប់ Cupertino B
ថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2019 ម៉ោង 3:00 រសៀល

I. ការណែនាំ
  a. សមាជិកគណៈកម្មាធិការថ្មី (បើមាន)

II. ចំណុចតាមដានពីអង្គប្រជុំមុន
  a. ការពិនិត្យឡើងវិញនូវកំណត់ហេតុ
  b. ការជ្រើសរើសសមាជិកសម្រាប់ភាសាចាំបាច់
  c. ការបង្កើតបេសកកម្ម

III. កាលវិភាគអង្គប្រជុំ
  a. ភាពញឹកញាប់
    i. កាលបរិច្ឆេទ
    ii. ពេលវេលា
  b. ទីតាំងសក្ដានុពល

IV. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត
  a. ផែនទីមណ្ឌលបោះឆ្នោត (ផ្នែកផែនទី)
    i. 11 ថ្ងៃ
    ii. 4 ថ្ងៃ
    iii. ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត
  b. ផែនការផ្សព្វផ្សាយ (ផ្នែកកិច្ចការសាធារណៈ និងនីតិកម្ម)
  c. ឯកសារដែលបានបកប្រែភាសា (ផ្នែកភស្តុភារបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត)

V. ការជ្រើសរើស និងការផ្សព្វផ្សាយ (សមាជិកដែលបានណែនាំ)
  a. ការជ្រើសរើសសមាជិកថ្មី

VI. ការបង្កើតរបៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់

VII. សេចក្ដីប្រកាស

VIII. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

*កន្លែងទាំងនេះជាកន្លែងដែលអាចចូលប្រើប្រាស់បាន ។ សម្រាប់សំណើសុំឯកសារក្នុងទម្រង់ដែលប្រើប្រាស់បាន សេវាកម្មបកប្រែផ្ទាល់មាត់ ឧបករណ៍ជំនួយក្នុងការស្ដាប់ ឬទីស្នាក់អាស្រ័យផ្សេងទៀត សូមធ្វើការទំនាក់ទំនងដោយទូរសព្ទទៅកាន់ ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត ឬផ្នែកបម្រើសេវារដ្ឋបាល តាមរយៈលេខ៖ (408) 918-9169 ឬ អាចធ្វើសំណើតាមរយៈអ៊ីមែលទៅកាន់ voterschoice@rov.sccgov.org ដោយមិនយឺតជាងប្រាំថ្ងៃធ្វើការមុនថ្ងៃប្រជុំ ។*

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្ត្រីកាន់បញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara

# គណៈកម្មាធិការប្រឹក្សាការទទួលបានភាសា (LAAC)

## កំណត់ហេតុនៃកិច្ចប្រជុំ

1400 Parkmoor Ave., San Jose, CA95126
បន្ទប់ Cupertino B
ថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2019 ម៉ោង 3:00 រសៀល

**វត្តមានរបស់សមាជិក៖** Erin Choi ព្រឹទ្ធបុរស Maryl មកពីសិល្បៈភាសានៅមហាវិទ្យាល័យ Evergreen Valley, Yeshi Teklemichael, Efrain Delgado មកពី Civic Engagement ALA, Jonathan Stein មកពីកម្មវិធីសិទ្ធិបោះឆ្នោតអាស៊ីច្បាប់ Caucus, Jessica Ho និង Katherine Power (ការហៅទូរស័ព្ទជាក្រុម) ទាំងពីរមកពីសេវាវេជ្ជសាស្ត្រនៅភាគពាយព្យ

**វត្តមានរបស់បុគ្គលិក៖ :** Michael Borja, Shannon Bushey, Vanessa Hamm, Andrea Solorio, Michael Borja, Magdalena Sta Maria, Priscilla Favela, Janora Davis, Allen Ocampo, Robert Wiedlin, Lynh Nguyen, Virginia Bloom, Michelle Tran, Christina Rivera, Adrian Garcia, Paulo Chang, Alfred Gonzales, Eric Kurhi, Jacob Salazar, Rachel Jung, Smita Shah, Liz Oviedo, Chipo Mulenga, Edwin Torralba, Thuy Tien Bui, Jose Posadas, Aaron, Jacob Salazar, Stephanie Duarte, Carmelita Aldana, Mike Fong, Virginia Bloom, Darren Tan

**ចំណុចសកម្មភាព៖**

- Jonathan នឹងផ្ញើ CBO របស់គាត់ទៅ Rachel.jung@rov.sccgov.org
- Delgado ដើម្បីផ្ញើបញ្ជី CBO ទៅ Rachel.jung@rov.sccgov.org
- បណ្ដាញអ៊ីមែលដែលត្រូវចាប់ផ្ដើមជាមួយសមាជិក
- ជួយផ្ញើអង្គការណាមួយតាមកាលវិភាគ EAP និងអាចបំពេញទម្រង់មតិត្រឡប់ ឬផ្ញើអ៊ីមែលមតិត្រឡប់ទៅកាន់ voterschoice@rov.sccgov.org
- ប្រសិនបើអ្នកដឹងពីទីតាំងណាមួយដែលសមស្របនឹងលក្ខណៈវិនិច្ឆ័យសម្រាប់មណ្ឌលបោះឆ្នោត សូមផ្ញើអ៊ីមែល voterschoice@rov.sccgov.org
- Erin ផ្ដល់ជូន Eric នូវកម្មវិធីដែលត្រូវការ
- ផ្ដល់ជូន Marylin នូវព័ត៌មានស្ដីពីការហៅជាក្រុម Skype

## I. ការស្វាគមន៍ និងការណែនាំ - Darren Tan ប្រធានគ្រប់គ្រងផ្នែកសេវាកម្មរដ្ឋបាលបានផ្ដល់ជូនដូចខាងក្រោម៖

i. ការណែនាំដល់បុគ្គលិក

ii. សមាជិកគណៈកម្មាធិការ

- គណៈកម្មាធិការនៅតែទទួលយកពាក្យសុំ នេះគឺជាវេទិកាសាធារណៈសម្រាប់អ្នករាល់គ្នាចូលរួម និងផ្ដល់នូវមតិត្រឡប់ និងយោបល់ផ្សេងៗ ។

## II. អង្គប្រជុំមុនដែលមានការអនុម័ត

i. សមាជិកដែលត្រូវពិនិត្យមើល និងអនុម័តកំណត់ហេតុ

## III. ចំណុចដែលអាចធ្វើសកម្មភាពបាន

i. ការជ្រើសរើសសមាជិកសម្រាប់ភាសាចាំបាច់ ។ ROV កំពុងធ្វើការផ្សព្វផ្សាយដល់សហគមន៍ផ្សេងៗតាមរយៈអ៊ីមែល ហៅចេញ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រធានគ្រប់គ្រងទីក្រុង និងស្មៀនក្រុង ។ សមាជិកគណៈកម្មាធិការនិយាយភាសាអេស្ប៉ាញគឺមានសារៈសំខាន់ណាស់ ។ ឈ្មោះទំនាក់ទំនងមួយចំនួនត្រូវបានផ្ដល់ដោយសមាជិកគណៈកម្មាធិការមួយចំនួន៖

- ACII
- PACT
- Siren
- Somos Mayfair
- ភាពជាដៃគូជំនាញអគារ
- ហ្វីលីពីន LED

- សំឡេងមូស្លីមអាមេរិក
- VIVO
- កិច្ចប្រជុំតុមូលអាមេរិកវៀតណាម
- សេវាកម្មសហគមន៍បេះដូងដ៏ពិសិដ្ឋ
- មជ្ឈមណ្ឌលសមភាព PARS

## IV. ការបង្កើតបេសកកម្ម

i. ពាក្យភាសាដែលត្រឹមត្រូវត្រូវតែបានប្រើជាសេចក្តីពន្យល់មួយចំនួនចំពោះកង្វះខាត ពោល ជំនាញភាសាអង់គ្លេសមានកម្រិត ។ អ្នកសិក្សាភាសាអង់គ្លេសត្រូវបានប្រើជាធម្មតា ។ ROV BLD ប្រើអ្នកបោះឆ្នោតដែលនិយាយភាសាផ្សេងក្រៅពីអង់គ្លេស ។ អ្នកខ្លះបានលើកឡើងថា "វេទិកា" ដូចដែលផ្តល់ជូនធ្វើការជាមួយគ្នាលើបញ្ហាមួយចំនួន ។

## V. កាលវិភាគអង្គប្រជុំ

i. Darren បានបញ្ជាក់ជាថ្មីម្តងទៀតដល់ក្រុមនូវគោលដៅសម្រាប់សមាជិកគណៈកម្មាធិការទាំងអស់មានសិទ្ធិចូលប្រជុំ ។ ការពិភាក្សាលើប្រេកង់ពេលវេលា ថ្ងៃនៃអង្គប្រជុំ ។ អ្នកចូលរួមខ្លះបានស្នើឱ្យមានទីតាំងរបស់កិច្ចប្រជុំ ប៉ុន្តែដោយសារតែចំណតរថយន្ត និងបញ្ហាកន្លែងផ្សេងៗទៀត វាត្រូវបានគេសម្រេចចិត្តថាទីតាំងល្អបំផុតគឺ Sobrato ព្រោះវាងាយស្រួលសម្រាប់សមាជិកទាំងអស់ ។ វាត្រូវបានសម្រេចដោយគណៈកម្មាធិការ ដើម្បីឱ្យមានវាម្តងក្នុងមួយខែ ។ ថ្ងៃធ្វើការ លើកលែងថ្ងៃសុក្រ ពេលព្រឹកចាប់ពីម៉ោង 10 ព្រឹកដល់ម៉ោង 12 ថ្ងៃត្រង់ ឬម៉ោង 3 រសៀលដល់ម៉ោង 5 ល្ងាច ។ Darren បានស្នើឱ្យពិនិត្យមើលគេហទំព័ររបស់យើងសម្រាប់ធនធាន ។ http://www.sccvote.org/voterschoice

ii. សំណួរអ្នកចូលរួម៖
តើមានវិធីពិគ្រោះយោបល់ជាមួយសមាជិកដែរឬទេ? សមាជិក LAAC ខ្លះមិនមានប្រាស្រ័យទាក់ទងគ្នាទេ?
ការឆ្លើយតប៖ ROV មានបណ្តាញអ៊ីមែលមួយដែលពួកគេអាចធ្វើការប្រាស្រ័យទាក់ទងបាន ។

## VI. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត

i. Shannon Bushey បានប្រគល់កាលវិភាគ EAP ដល់សមាជិកដោយមានគោលដៅប្រមូលធាតុចូលពីសហគមន៍ ពោលយោបល់សម្រាប់ការផ្សាយពាណិជ្ជកម្ម ទីតាំងប្រអប់សន្លឹកឆ្នោត។ល ។ ROV កំពុងប្រមូលការចូលរួម សេចក្តីព្រាងត្រូវតែត្រូវបង្ហាញ 14 ថ្ងៃមុនថ្ងៃ EAP ថ្ងៃទី 30 ខែសីហា ឆ្នាំ 2019 សវនាការ / កិច្ចប្រជុំ BOS ។ សូមមើលគេហទំព័ររបស់ ROV សម្រាប់ព័ត៌មានបន្ថែមអំពី LAAC, VAAC និង EAP ។ ជួយជ្រើសរើសមនុស្សឱ្យចូលរួម ។ SOS មានធនធានជាច្រើនលើ EAP ដើម្បីយោង ។

ii. សំណួរអ្នកចូលរួម៖
អ្នកស្ម័គ្រចិត្ត៖ តើព័ត៌មានមានភាពទាក់ទងនឹងការចូលប្រើភាសានៅក្នុង EAP ដែរឬទេ? ស្នើសុំឱ្យមានសេចក្តីព្រាងត្រៀមរួចរាល់ 2 សប្តាហ៍មុនថ្ងៃទី 30 ខែសីហា ដើម្បីពិនិត្យឡើងវិញដោយសមាជិកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ LAAC បន្ទាប់ ។ តាមលេខកូដបោះឆ្នោត មានរយៈពេលពិនិត្យមើល 2 សប្តាហ៍ ។ NAPA បានចេញផ្សាយ EPA របស់ពួកគេនៅសប្តាហ៍នេះ ដើម្បីបញ្ចប់វានៅរដូវស្លឹកឈើជ្រុះ ។ រាល់ខោនធីនីមួយៗបានចេញផ្សាយជាភាសាអង់គ្លេស បន្ទាប់មកបកប្រែ ។

ការឆ្លើយតប៖ សេចក្តីព្រាងគួរតែត្រៀមរួចរាល់ឆាប់ៗពីព្រោះវាត្រូវការការបកប្រែ ហើយត្រូវការពេល 3 ទៅ 4 សប្តាហ៍ ដើម្បីបកប្រែមុនកិច្ចប្រជុំនៅថ្ងៃទី 30 ខែសីហា និងមួយទៀតត្រូវធ្វើវិសោធនកម្ម ដើម្បីរួមបញ្ចូល ។ ROV បានចុះកិច្ចសន្យាជាមួយអ្នកលក់ខាងក្រៅ ដើម្បីបកប្រែឯកសារ ROV ហើយត្រូវបានបញ្ជាក់ដោយខោនធី ។ ការពិភាក្សាទាក់ទងនឹងសន្លឹកឆ្នោតជាផ្លូវការក្នុងភាសាដែលមានភាសាចាំបាច់ចំនួន 8 ផ្សេងគ្នានឹងកើតឡើង ។ ROV បានស្វែងរកជំនួយពីគណៈកម្មាធិការសម្រាប់ជម្រើសអំពីវិធីផ្សព្វផ្សាយនៅក្នុងសហគមន៍ភាសាផ្សេងគ្នា ។

## VII. ការបង្ហាញផែនទីនៃមណ្ឌលបោះឆ្នោត និងការពិភាក្សាទូទៅដោយ Aaron Wong, ផ្នែកផែនទី

a. ទិដ្ឋភាពទូទៅ
b. 11 ថ្ងៃ
c. 4 ថ្ងៃ
d. ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត
e. លក្ខណៈវិនិច្ឆ័យចំនួន 14 សម្រាប់ជ្រើសរើសទីតាំង
f. Morgan Hill និងតំបន់ជនបទនឹងនៅដដែលក្នុងមួយ ROV

i. សំណួរអ្នកចូលរួម៖
ធ្លាប់មានមណ្ឌលបោះឆ្នោត 800 កន្លែងនៅក្នុងផែនទីមានតិចជាង 100 តើមណ្ឌល 120 នឹងត្រូវពង្រាយយ៉ាងដូចម្តេច?
ការឆ្លើយតប៖ ផែនទីដែលកំពុងបង្ហាញមានអ្នកបោះឆ្នោតចំនួន 50,000 នាក់ យើងមានផែនទីមួយទៀតដែលបែងចែកដោយ 10,000 នាក់។ មណ្ឌល

បោះឆ្នោតខ្លះបើករយៈពេល 11 ថ្ងៃ និងកន្លែងផ្សេងទៀតសម្រាប់រយៈពេល 4 ថ្ងៃ។ លក្ខខណ្ឌតម្រូវ 11 ថ្ងៃគឺត្រូវមាន 1 សម្រាប់រាល់អ្នកបោះឆ្នោត 50,000 នាក់ ហើយ 4 ថ្ងៃបើកសម្រាប់រាល់ 10,000 នាក់។ ROV នឹងបន្ថែមប្រអប់ឆ្នោតអ្នកបោះឆ្នោត។ ផ្នែកកិច្ចការសាធារណៈ និងនីតិកម្មរបស់ ROV គឺ

ii. ក្នុងឧទាហរណ៍នីមួយៗអ្នកនឹងមានឯកតានីមួយៗនៅលើផែនទីដែលបានកំណត់តំបន់ តើអ្នកកំពុងធ្វើការវិភាគមែនទេ? តើអ្នកនឹងចែករំលែកជាសាធារណៈនៅកន្លែងដែលមណ្ឌលបោះឆ្នោតបានកំណត់មែនទេ? Napa អង្គុយជជែកជាមួយអ្នកតស៊ូមតិសហគមន៍ និងសន្ទនា និងបង្ហាញតម្លាភាព តើអ្នកនឹងធ្វើដូចគ្នាដែរឬទេ?

ការឆ្លើយតប៖ ការប្រើប្រាស់ទិន្នន័យពីជំរឿនពីភាសា ហើយយើងអាចបង្ហាញប្រភេទសហគមន៍ទាំងនេះដែលផ្តល់សេវាកម្មជាក់លាក់ ។ ROV នឹងធ្វើផែនទីផ្ទាល់ខ្លួន និងផ្សំជាមួយផែនទីកម្តៅរបស់អង្គការ Mindy ។ ROV នឹងចែករំលែកដល់សាធារណៈជន ដែលជាកន្លែងមណ្ឌលបោះឆ្នោត ។

iii. Napa អង្គុយជជែកជាមួយអ្នកតស៊ូមតិសហគមន៍ និងសន្ទនា និងបង្ហាញតម្លាភាព តើអ្នកនឹងធ្វើដូចគ្នាដែរឬទេ?

ការឆ្លើយតប៖ យើងនឹងមានទម្រង់ខ្លះនៃរឿងនោះ ។ ហើយយើងកំពុងរក្សាកំណត់ត្រាអំពីចំនួនដែលពួកគេកំពុងផ្តល់ ហើយយើងនឹងព្យាយាមចែករំលែកឱ្យអស់ពីសមត្ថភាព ។

iv. ទីតាំងប្រអប់ឆ្នោត តើពួកវានៅខាងក្រៅ ឬខាងក្នុង? ទីតាំងខាងក្រៅ តើមានទីតាំងនៅខាងក្រៅអគាររដ្ឋាភិបាលឬ? តើអ្នកបានពិចារណាហាងលក់គ្រឿងទេស និងទីតាំងចរាចរណ៍ច្រើនផ្សេងទៀតទេ? ខ្ញុំទទួលស្គាល់ថាពួកវាផ្តល់នូវគុណសម្បត្តិ ប៉ុន្តែមានមនុស្សច្រើនជាងនេះទៅទៀតដែលធ្វើដំណើរទៅកាន់ Safeway និង Walmart បើប្រៀបធៀបទៅនឹងសាលាក្រុង ។ ពេងកុ valley fair មានផ្លូវដែលមនុស្សទៅទីនោះច្រើនជាងការិយាល័យខោនធី ។

ការឆ្លើយតប៖ ភាគច្រើនគឺផ្នែកខាងក្រៅ ប្រអប់ដែកដែលត្រូវបានរចនាឡើងសម្រាប់អាកាសធាតុ និងរយៈពេល 24/7 ។ ផ្នែកខាងក្នុងភាគច្រើននៅក្នុងសាលាក្រុង ។ បណ្ណាល័យទីក្រុង មហាវិទ្យាល័យ ការិយាល័យរដ្ឋាភិបាល យើងកំពុងស្វែងរកកន្លែងចំនួន 78 ហើយបើកចំហរចំពោះការផ្តល់យោបល់ ។ យើងក៏កំពុងពិនិត្យមើលស្ថានីយអគ្គិភ័យផងដែរ ។

v. នរណាម្នាក់អាចឈប់នៅទីតាំងណាមួយមែនទេ? យើងកំពុងនិយាយអំពីមនុស្សដែលនៅជុំវិញតំបន់នោះរួចហើយ ។ សំណើសុំច្បាប់ថ្មីនៅក្នុងអង្គនីតិកម្មដែលនឹងបន្ថែមទៅក្នុងបញ្ជីចំនួន 1 ដែលជាបរិវេណមហាវិទ្យាល័យ តើអ្នកកំពុងគិតដល់មហាវិទ្យាល័យសហគមន៍ SJSU ក្នុងការវិភាគមែនទេ ។

ការឆ្លើយតប៖ យើងកំពុងនិយាយជាមួយមនុស្សគ្រប់គ្នា ហើយយើងបានចុះទៅ SJSU ហើយប្រហែលជាមហាវិទ្យាល័យ សហគមន៍ West Valley និងមហាវិទ្យាល័យផ្សេងទៀត ប៉ុន្តែពួកវាត្រូវតែបើកចំហរជាសាធារណៈ ហើយមិនត្រឹមតែនិស្សិតប៉ុណ្ណោះទេ ។

**VIII. ការផ្សាយពាណិជ្ជកម្ម និងកិច្ចពិភាក្សាផ្សព្វផ្សាយដោយ Eric Kurhi កិច្ចការសាធារណៈ និងនីតិកម្ម ។**

a. សេចក្តីណែនាំអំពី PLA
b. ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយតាមអ៊ីនធឺណិត និងកាសែត ឬ PSA ណាមួយប្រាប់យើងឱ្យដឹង ជាពិសេសប្រសិនបើវាមិនគិតថ្លៃ
c. វិធីទាក់ទងទៅសហគមន៍ផ្សេងៗ ការបោះពុម្ពផ្សាយ និងគំនិតផ្សេងទៀតអ្វីខ្លះ
d. បណ្តាញផ្សព្វផ្សាយសង្គម
e. ទីតាំងដែលមានសក្តានុពល - អ្នកណាម្នាក់អាចចូលសាលបាន សូមប្រាប់ ROV ឱ្យបានដឹង

*ការផ្តល់យោបល់របស់អ្នកចូលរួម៖* ទីតាំងដែលអាចធ្វើបានសម្រាប់ការផ្សាយពាណិជ្ជកម្ម៖

- សាលារៀន ការផ្សាយពាណិជ្ជកម្មនៅលើឡានក្រុង និងពេងកុន ពោល ESSJ Eastridge ដែលមានប្រជាជនច្រើននិយាយភាសាអង់គ្លេស និងអេស្ប៉ាញ ។
- រឿងកូរ៉េ តែងតែមានការផ្សាយពាណិជ្ជកម្មចំនួន 2 តាមតម្រូវការ ។ ភាសាអង់គ្លេសមិនអីទេប៉ុន្តែមានអក្សររត់។ ជនជាតិវៀតណាមភាគច្រើនមើលរឿងភាគកូរ៉េ ។ Erin Choi នឹងផ្ញើទៅបុគ្គលិករបស់ ROV នូវបញ្ជីមួយ ។
- KTSF, Sing-Tao, SkyLink, On Demand, ប៉ុស្តិ៍ហ្វីលីពីន ABS-CBN តាមរយៈព័ត៌មានហ្វីលីពីនពេលល្ងាច ។ ព្រឹត្តិការណ៍ពិសេសរបស់ប្រទេសហ្វីលីពីននៅរដូវក្តៅនៅ មណ្ឌល Staples, ពិធីបុណ្យ Adobo, និងនៅ សួនយូញៀនស្ទ័ ។
- ប្រជាជនសហគមន៍អាស៊ីខាងត្បូងស្ថិតនៅក្នុងកម្មវិធី What's App បង្កើតអត្ថបទជាក្រុម និងមានក្រុមជជែកពហុជាតិ ។ អ្នកអាចបង្កើតក្រុមដែលមានទិសដៅតែមួយជាមួយរដ្ឋបាលដែលអាចធ្វើការប្រកាសបាន ។ ជំនួសឱ្យបញ្ជីសំបុត្រ ពួកគេទើបតែមានក្រុមកម្មវិធី What's App ហើយបានក្លាយជាព្រឹត្តិប័ត្រសហគមន៍ ។ សម្រាប់ការបោះពុម្ពផ្សាយ មានទស្សនាវដ្តីព្រឹត្តិប័ត្រព័ត៌មានដូចជាឥណ្ឌាខាងលិចដែលជាទស្សនាវដ្តីលេចធ្លោជាងគេមួយ ។
- WeChat មានប្រព័ន្ធរដ្ឋាភិបាលមិនច្បាស់មួយដែលរដ្ឋាភិបាលចិនត្រួតពិនិត្យកម្មវិធី ប៉ុន្តែត្រូវប្រុងប្រយ័ត្ន ។

- ការផ្សព្វផ្សាយតាម Facebook
- Viber ការជួបជុំនៅព្រះវិហារ និកាយផ្សេងៗ និងវិហារអ៊ីស្លាម ។ យើងបានដាក់ការផ្សាយពាណិជ្ជកម្មនៅក្នុងចំណតរថយន្តក្នុងអំឡុងពេលព្រះវិហារ ។ Yeshi ដើម្បីផ្តល់ព័ត៌មាន ជារៀងរាល់ឆ្នាំយើងមានការចូលរួមពី 4 ទៅ 5 ពាន់នាក់ យើងរីករាយនឹងរៀបចំស្តង់ ។

**IX. មតិត្រឡប់ សំណួរនិង / ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ**

**X. ការជ្រើសរើសសមាជិកថ្មី**

**XI. កិច្ចប្រជុំបន្ទាប់៖**

i. កាលបរិច្ឆេទទំនួលខុសត្រូវដោយសារតែទីតាំង ។
   - ថ្ងៃពុធទី 17 និង 24 ខែកក្កដា
   - ទីតាំង
   - ម៉ោង 10 ព្រឹកដល់ 12 យប់ ឬ 3 រសៀលដល់ 5 ល្ងាច

ii. ការបង្កើតរបៀបវារៈកិច្ចប្រជុំបន្ទាប់
   - បញ្ជីនៃភារកិច្ចដែលនឹងមកដល់ ។ ដើម្បីជួយចាប់ផ្តើមគិតនាពេលខាងមុខ ។
   - តើអ្វីទៅជាផែនការរបស់អ្នកសម្រាប់ការជ្រើសរើសបុគ្គលិកស្វែងមតិពីរភាសា តើវិធីសាស្ត្របែបប្រពៃណីមានអ្វីខ្លះ ហើយតើអ្នកកំពុងបំពេញបន្ថែមយ៉ាងដូចម្តេច? មានវិធីជាច្រើនដើម្បីទាក់ទងសហគមន៍ តើព្រឹត្តិការណ៍អ្វីខ្លះដែលអ្នកគ្រោងនឹងចូលរួម? ថ្ងៃទី 14 ខែតុលាជាឧទាហរណ៍មួយនៃសហគមន៍អេត្យូពី ។ យើងអាចបញ្ចូលបញ្ជីរឹងមាំ និងបន្តបំពេញបញ្ជីបន្ថែមទៀត ។
   - VCA ត្រូវការឈ្មោះទំនាក់ទំនងបោះឆ្នោតចំនួន 3 តាមអ៊ីមែល តើអ្នកអាចចែករំលែកនូវលក្ខណៈរបស់អ្នកផ្ញើសារបានទេ តើពួកគេត្រូវបានបកប្រែទំហំ និងអាចមើលឃើញយ៉ាងដូចម្តេចមុនពេលពួកគេចេញទៅក្រៅ ។ វាជាការប្រសើរណាស់ក្នុងការចែករំលែកវាជាទម្រង់ព្រាង ។ បញ្ចូលសហគមន៍នៅដំណាក់កាលដំបូងនៅក្នុងដំណើរការនឹងមានប្រយោជន៍ ។
   - ROV នឹងដាក់ចំណុចទាំងនេះនៅក្នុងរបៀបវារៈ ។

**XII. សេចក្តីប្រកាស**

**XIII. សំណួរ និងចម្លើយគណៈកម្មាធិការ** - សំណួរត្រូវបានគេចោទសួរពេញអង្គប្រជុំ ហើយសម័យប្រជុំសំណួរ និងចម្លើយមិនបានទទួលសំណួរបន្ថែមទេ ។

**XIV. កិច្ចប្រជុំបានផ្អាកនៅម៉ោង 5:00 ល្ងាច**

**County of Santa Clara**

**Registrar of Voters**

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314

www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

## កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាលទ្ធភាពប្រើប្រាស់ភាសា

1400 Parkmoor Ave., San Jose, CA95126
បន្ទប់ Cupertino B
ថ្ងៃទី 17 ខែកក្កដាឆ្នាំ 2019 ម៉ោង 2 រសៀល

I. ការណែនាំ
   a. សមាជិកគណៈកម្មាធិការថ្មី (បើមាន)

II. ចំណុចតាមដានពីអង្គប្រជុំមុន
   a. ការពិនិត្យឡើងវិញនូវកំណត់ហេតុ
   b. ការបង្កើតបេសកកម្ម

III. បញ្ចប់ភ័ស្តុភារកិច្ចប្រជុំ
   a. ទីតាំងមជ្ឈមណ្ឌល
   b. ភាពញឹកញាប់នៃកិច្ចប្រជុំ៖ ប្រចាំខែ (ត្រូវបានបញ្ជាក់ក្នុងកិច្ចប្រជុំលើកមុន)
      i. រហូតដល់ខែធ្នូ
      ii. ប្រចាំត្រីមាសបន្ទាប់ពីការបញ្ចប់នៃការបោះឆ្នោត
   c. ការពិភាក្សាជាសហប្រធាន (សមាជិកដែលបានស្នើ)

IV. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត
   a. ការប្រឹក្សា EAP
   b. ឯកសារបោះឆ្នោត
   c. ការអប់រំអ្នកបោះឆ្នោត និងសម្ព័ន្ធភាពផ្សព្វផ្សាយ
   d. RAVBM៖ បទបង្ហាញដោយផ្នែកបោះឆ្នោតដោយផ្ញើតាមសំបុត្រ (ពេលវេលាអនុញ្ញាត)

V. ការជ្រើសរើសបុគ្គលិក និងផ្សព្វផ្សាយ

VI. ការបង្កើតរបៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់

VII. សេចក្តីប្រកាស

VIII. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

*កន្លែងទាំងនេះជាកន្លែងដែលអាចចូលប្រើប្រាស់បាន ។ សម្រាប់សំណើសុំឯកសារក្នុងទម្រង់ដែលប្រើប្រាស់បាន សេវាកម្មបកប្រែផ្ទាល់មាត់ ឧបករណ៍ជំនួយក្នុងការស្តាប់ ឬទីស្នាក់អាស្រ័យផ្សេងទៀត សូមធ្វើការទំនាក់ទំនងដោយទូរសព្ទទៅកាន់ ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត ឬផ្នែកបម្រើសេវារដ្ឋបាល តាមរយៈលេខ៖ (408) 918-9169 ឬ អាចធ្វើសំណើតាមរយៈអ៊ីមែលទៅកាន់ voterschoice@rov.sccgov.org ដោយមិនយឺតជាងប្រាំថ្ងៃធ្វើការមុនថ្ងៃប្រជុំ ។*

**County of Santa Clara**
Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

## កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ដើម្បីអ្នកបោះឆ្នោតអាចបោះឆ្នោតបាន

1555 Berger Drive, San Jose, CA
95112 Berger សាលប្រជុំ
ថ្ងៃទី7 ខែមិថុនា ឆ្នាំ2019 ម៉ោង 3:00 រសៀល

I. **សេចក្តីណែនាំ**
   a. បុគ្គលិកគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត (ROV)
   b. សមាជិកគណៈកម្មាធិការ

II. **គោលបំណងនៃកិច្ចប្រជុំ**
   a. ការចូលរួមរបស់សមាជិក និងធាតុចូលពីសាធារណៈ
   b. ROV
   c. ការបង្កើតបេសកកម្ម

III. **ការបង្កើតគោលការណ៍ណែនាំ និងគោលដៅនៃកិច្ចប្រជុំ**
   i. ច្បាប់មូលដ្ឋាន
   ii. ការរំពឹងទុករបស់សមាជិក៖ ឯកសារចែកជូន

IV. **ការពិភាក្សាទូទៅលើច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA)**
   a. ទិដ្ឋភាពទូទៅ
      i. ការផ្លាស់ប្តូរពីគំរូការិយាល័យបោះឆ្នោតពីមុនមក
      ii. លក្ខខណ្ឌតម្រូវពីលទ្ធភាពអាចចេញចូលបានសម្រាប់ច្បាប់ VCA
      iii. គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត
   b. សំណួរ

V. **មតិត្រឡប់ សំណួរនិង/ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ**

VI. **ការជ្រើសរើសសមាជិកថ្មី**

VII. **កិច្ចប្រជុំបន្ទាប់៖ ថ្ងៃទី18 ខែមិថុនា ពេលវេលា និងទីតាំងដំដែល**
   a. សាលប្រជុំ ROV
   b. ការបង្កើតរបៀបវារៈ
   c. គំនិតសម្រាប់កិច្ចប្រជុំ និងកាលបរិច្ឆេទបន្ថែម

VIII. **សេចក្តីប្រកាស**

IX. **សំណួរ និងចម្លើយនៃកិច្ចពិភាក្សា**

*កន្លែងទាំងនេះជាកន្លែងដែលអាចប្រើប្រាស់បាន ។ សំណើសុំឯកសារជាទម្រង់ដែលអាចទទួលយកបាន សេវាបកប្រែភាសា ឧបករណ៍ជំនួយការស្តាប់ ឬកន្លែងស្នាក់នៅផ្សេងទៀត គប្បីធ្វើឡើងដោយទូរសព្ទទៅកាន់មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត ផ្នែកសេវារដ្ឋបាលតាមទូរសព្ទលេខ (408) 918-9169 ឬ ដោយផ្ញើអ៊ីម៉ែលនូវសំណើរបស់អ្នកទៅកាន់ voterschoice@rov.sccgov.org ដោយមិនឲ្យយឺតជាងប្រាំថ្ងៃធ្វើការមុនកិច្ចប្រជុំ ។*

# មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara
# គណៈកម្មាធិការប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC)
## កំណត់ហេតុនៃកិច្ចប្រជុំ

1555 Berger Drive, San Jose, CA 95112
អាគារ 2
ថ្ងៃទី7 ខែមិថុនា ឆ្នាំ2019 ម៉ោង 3:00 រសៀល

**វត្តមានសមាជិកចូលរួម៖** Fred Nisen, Yeshi Teklemichael (តាម Skype), Christine Fitzgerald, Lisa Quan (តាម Skype), Nelly Cabuslay, Lisa Cohn, Matt Cohn, James Cohn. (សមាជិកពីសាធារណៈ)

**វត្តមានបុគ្គលិកចូលរួម៖** Darren Tan, Matt Moreles, Virginia Bloom, Rachel Jung, Julie Fletes, Ruth Luo, Edwin Torralba, Alfred Gonzales, Mike Fong, Michael Borja, Eimear Duncan, Robert Wiedlin, Paulo Chang, Lance Nottle, Natalie Goolsby, Kim Sharpe, Bob Nguyen, Chenxi Ye, Patricia Lopez, Magdalena Santa Maria, Vanessa Hamm, Shelby Galaviz, Andrea Solorio, Liz Oviedo, Michelle Tran, Amy Sun, Smita Shah, Kelly Phan, Chipo Mulenga

**ចំណុចសកម្មភាព៖**

- យកគំរូបេសកកម្មទៅចូលរួមកិច្ចប្រជុំបន្ទាប់របស់ VAAC ។
- យកផែនទីទៅចូលរួមកិច្ចប្រជុំបន្ទាប់ដើម្បីបង្ហាញពីទីតាំងដែលមានសក្តានុពលជាមណ្ឌលបោះឆ្នោត ។ បញ្ជូនព័ត៌មានបន្តទៅកាន់សមាជិកឲ្យបានមុនពេលប្រជុំ ។

**I. ការណែនាំ៖**

លោក Darren Tan នាយកគ្រប់គ្រងសេវារដ្ឋបាលបានធ្វើការសម្របសម្រួលកិច្ចប្រជុំ ។ គាត់បានស្វាគមន៍និងថ្លែងអំណរគុណដល់សមាជិកគណៈកម្មការសម្រាប់វត្តមានចូលរួមរបស់ពួកគេ ។ លោក Tan ក៏បានសុំអភ័យទោសជំនួសឲ្យមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតដែលគាត់មិនអាចមកចូលរួមកិច្ចប្រជុំនេះបាន ។

**II. គោលបំណងនៃកិច្ចប្រជុំ**

a. ធាតុចូលពីសមាជិកនិងសាធារណៈ៖

*មតិឆ្លើយតបរបស់អ្នកចូលរួម*

i. សារៈសំខាន់នៃការបង្កើតភាពជាដៃគូជាមួយនឹងសហគមន៍ពលរដ្ឋមានពិការភាព ការទន្ទឹងរងចាំដោយរីករាយជាពន់ពេកចំពោះការចូលរួមកាន់តែច្រើនពីសំណាក់សហគមន៍ ។

ii. ពិនិត្យទៅលើគ្រប់ផ្នែកទាំងអស់នៃលទ្ធភាពដែលអាចទទួលបានមិនមែនគ្រាន់តែទីតាំងទេ ប៉ុន្តែរួមទាំងបច្ចេកវិទ្យាផងដែរ ។

b. ROV

i. ដើម្បីប្រមូលធាតុចូលពីគណៈកម្មាធិការនិងសមាជិកសាធារណៈ ដោយហេតុថានាយកដ្ឋានមានគម្រោងជាច្រើនសម្រាប់ និងបង្កើតការអនុវត្តនៃច្បាប់ VCA

c. ការបង្កើតបេសកកម្ម

i. ស្វែងរកនូវបេសកកម្មមួយដែលច្បាស់លាស់និងមិនសុាំញ៉ាំឆ្ពោះទៅមុខ ។

# សេចក្តីបន្ថែម L – របៀបវារៈនិងកំណត់ហេតុនៃកិច្ចប្រជុំ VAAC

## III. ការបង្កើតគោលការណ៍ណែនាំ និងគោលដៅនៃកិច្ចប្រជុំ

a. ច្បាប់មូលដ្ឋាន

i. ការរំពឹងទុករបស់សមាជិកៈ

លោក Tan បានផ្តល់នូវការពន្យល់ពីការរំពឹងទុករបស់សមាជិកក្នុងនាមទស្សនៈរបស់ ROV ។ គាត់បានលើកឡើងថា យើងនឹងនៅតែទទួលយកពាក្យស្នើសុំចូលជាសមាជិកគណៈកម្មការរហូតដល់យើងឈានទៅដល់សមាជិកភាព គណៈកម្មការមានភាពរឹងមាំថែមទៀត ។

*ធាតុចូលរបស់អ្នកចូលរួមៈ*

1. មកទល់នឹងពេលនេះ តើយើងក្នុងនាមជា ROV ធ្វើការសម្រេចយ៉ាងម៉េចចំពោះពាក្យសុំចូលជាសមាជិកនោះ?
    a. ការឆ្លើយតបៈ បច្ចុប្បន្ននេះ ROV ទទួលយកពាក្យសុំចូលរួមក្នុង VAAC ទាំងអស់ ។ នៅពេលដែលសមាជិកភាពដ៍រឹងមាំត្រូវបានបង្កើតឡើងហើយ គណៈកម្មការនឹងសម្រេចពីចំនួនចុងក្រោយនៃសមាជិក
2. តើមានសមាជិកប៉ុន្មាននាក់ ដែលយើងរំពឹងថានឹងទទួលបាន ដោយផ្អែកលើគោលការណ៍ណែនាំរបស់រដ្ឋលេខាធិការ (SOS)?
    a. ការឆ្លើយតបៈ តាម SOS យោងទៅលើការរាប់ចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនោះ គួរតែមានសមាជិកចំនួនប្រាំពីរ (7) នាក់
3. តើមានអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចប៉ុន្មាននាក់ នៅក្នុងខោនធី Santa Clara?
    a. បច្ចុប្បន្ននេះយើងមានអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចជាង 900,000នាក់នៅក្នុងខោនធី Santa Clara

## IV. ការពិភាក្សាទូទៅលើច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA)

a. ទិដ្ឋភាពទូទៅផ្តល់ដោយ Paulo Chang ប្រធានគ្រប់គ្រងផ្នែកប្រតិបត្តិការមណ្ឌលៈ

i. ការផ្លាស់ប្តូរពីគំរូការិយាល័យបោះឆ្នោតពីមុនមក

ii. លក្ខខណ្ឌតម្រូវភាសាសម្រាប់ច្បាប់ VCA

iii. គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

iv. ធាតុចូលទាំងអស់បានមកពីសមាជិកគណៈកម្មការនឹងត្រូវពិចារណាសម្រាប់ EAP

v. ឯកសារចែកជូនត្រូវបានផ្តល់ទៅដល់សមាជិកគណៈកម្មការសម្រាប់កិច្ចប្រជុំ EAP នីមួយៗ

b. សំណួរ

*ពីអ្នកចូលរួមៈ*

i. នៅកិច្ចប្រជុំ EAP តើភាពដែលអាចទទួលបាននឹងត្រូវលើកយកមកពិភាក្សាទេ ឬវាជាការព្រួយបារម្ភទេ?

ii. តើអ្វីនឹងត្រូវលើកយកមកពិភាក្សានៅកិច្ចប្រជុំ EAP?

iii. តើនឹងមានកិច្ចប្រជុំ EAP ច្រើនទេ? តើកិច្ចប្រជុំទាំងនោះនឹងចាប់ផ្តើមឡើងនៅសប្តាហ៍ក្រោយមែនទេ?

iv. តើនឹងមានតែកិច្ចប្រជុំមួយប៉ុណ្ណោះផ្តោតទៅលើភាពដែលអាចទទួលបានឬ?

1. ការឆ្លើយតបចំពោះសំណួរ 1-4៖ មានកិច្ចប្រជុំ EAP ចំនួន 11 ដែលបានកំណត់ក្នុងកាលវិភាគរួច ។ កិច្ចប្រជុំទាំងនេះមានលក្ខណៈជាវេទិការ ដែលសាធារណៈនឹងមានឱកាសផ្តល់នូវធាតុចូលនិងសួរជាសំណួរនានា ។ កិច្ចប្រជុំនីមួយៗមានការផ្តោតទៅលើសហគមន៍ ប៉ុន្តែសមាជិកណាម្នាក់ពីសាធារណៈក៏អាចចូលរួមក្នុងកិច្ចប្រជុំណាមួយបានដែរ ។ កិច្ចប្រជុំ EAP ដែលផ្តោតទៅលើភាពដែលអាចទទួលបាន ត្រូវបានកំណត់កាលវិភាគនៅថ្ងៃព្រហស្បត៏ ទី13 ខែមិថុនា

v. តើអ្នករំពឹងថា នៅពេលណាទើប EAP ត្រូវបានចាប់ផ្តើមព្រៀង?

1. ការឆ្លើយតបៈ កាលបរិច្ឆេទកំណត់របស់នាយកដ្ឋានដើម្បីបញ្ចប់ពង្រាង EAP គឺដប់បួន (14) ថ្ងៃមុនពេលកិច្ចប្រជុំ EAP ជាសាធារណៈដែលបានកំណត់ធ្វើនៅថ្ងៃទី30 ខែសីហា ។

vi. តើអ្នកនឹងធ្វើអ្វីដើម្បីផ្សព្វផ្សាយពីកិច្ចប្រជុំទាំងនេះ? អ្នកចូលរួមបានលើកឡើងថាគាត់មិនបានឮពីកិច្ចប្រជុំរហូតដល់ថ្ងៃនេះ ហើយគាត់ព្រួយបារម្ភថាអាចមានមនុស្សច្រើននាក់ដែលមិនបានដឹងពីកិច្ចប្រជុំនេះ ។

1. ការឆ្លើយតប៖ ROV បានប្រមូលយកនូវមូលដ្ឋានទិន្នន័យនៃព័ត៌មានទំនាក់ទំនងជាអ៊ីម៉ែល ដែលរួមមានភាគីពាក់ព័ន្ធ CBOS មន្ត្រីខោនធីនិងក្រុង និងមណ្ឌលសិក្សាធិការ/ពិសេស ។ យើងបានផ្ញើអ៊ីម៉ែលទៅកាន់អ្នកដែលមានក្នុងបញ្ជីទំនាក់ទំនងនេះ ។ ក្រុមការងារផ្សព្វផ្សាយរបស់ផ្នែកប្រតិបត្តិការមណ្ឌល ក៏ចូលរួមក្នុងព្រឹត្តិការណ៍ដែលមានសកម្មភាពជាច្រើន ត្រូវបានធ្វើការផ្សព្វផ្សាយដែរ ។ កិច្ចប្រជុំជាសាធារណៈទាំងអស់ក៏ត្រូវបានបង្ហោះផ្សាយនៅលើគេហទំព័រសាធារណៈរបស់នាយកដ្ឋានដែរ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលកិច្ចប្រជុំថ្មីត្រូវបានធ្វើឡើង ។

vii. ក្នុងអំឡុងពេលនេះ នឹងមានបញ្ជីនៃមណ្ឌលបោះឆ្នោតដាច់ដោយឡែកមួយទៀត នៅមុនធ្វើការបោះពុម្ពផ្សាយ ដូច្នេះយើងអាចមើលឃើញថាពួកគេនឹងអាចទទួលបានកម្រិតណា?

1. ការឆ្លើយតប៖ ROV កំពុងតែស្វែងរកមណ្ឌលបោះឆ្នោតយ៉ាងសកម្មនៅឡើយសម្រាប់ការបោះឆ្នោតក្នុងខែមិនានេះ ។ ទីតាំងជាច្រើនកំពុងត្រូវបានស្វែងរកហើយទីតាំងមួយចំនួនកំពុងតែធ្វើការចរចា ។ ផ្នែកប្រតិបត្តិការមណ្ឌលនឹងមានពង្រាងជាច្រើននៃទីតាំងទំនេរដែលត្រូវបានបញ្ជាក់រួចហើយសម្រាប់កិច្ចប្រជុំ VAAC បន្ទាប់

viii. ខិត្តប័ណ្ណព័ត៌មានមួយចំនួនមិនអាចទទួលបានទេ ឬក៏មានលក្ខណៈងាយស្រួលអានតាមអេក្រង់ដែរ បានកំណត់ថ្ងៃ និងកាលបរិច្ឆេទហើយ តែមិនទាន់បានកំណត់ម៉ោងនៅឡើយ ។ ពិចារណាទៅលើសារដែលមានអត្ថបទងាយៗ ថ្ងៃ កាលបរិច្ឆេទ និងម៉ោងច្បាស់ៗតែម្តង ។

1. ការឆ្លើយតប៖ ROV នឹងច្បាស់ណាស់ទទួលយកធាតុចូលនេះទៅពិចារណានៅពេលផ្ញើចេញនូវអ៊ីម៉ែលទំនាក់ទំនងនាពេលអនាគត

## V. មតិត្រឡប់ សំណួរនិង/ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ

*ធាតុចូលរបស់អ្នកចូលរួម*

a. អាចជាគំនិតល្អត្រូវមានសហប្រធាននៅកិច្ចប្រជុំធំៗ និងកិច្ចប្រជុំនាពេលអនាគត ។

b. តើអ្នកបានពិចារណាទៅលើពេលវេលាផ្សេងគ្នា ដែលអាចដំណើរការបានប្រសើរជាងសម្រាប់សមាជិកទេ?

i. ការឆ្លើយតប៖ បាទ/ចាស ។ ROV ចង់ឲ្យមានគណៈកម្មការផ្តល់ព័ត៌មានស្តីពីទីតាំងកាលបរិច្ឆេទ និងភាពញឹកញាប់នៃកិច្ចប្រជុំ VAAC ។

## VI. ការជ្រើសរើសសមាជិកថ្មី

លោក Tan ស្នើសុំឲ្យសមាជិកគណៈកម្មការផ្តល់ព័ត៌មានពីកិច្ចប្រជុំបន្តទៅកាន់មិត្តភក្តិ ឬសហការី និងអ្នកទំនាក់ទំនងផ្សេងទៀតដែលគេអាចមាននៅពេលដែលនាយកដ្ឋាននៅបន្តកិច្ចខិតខំប្រឹងប្រែងការងារផ្សព្វផ្សាយរបស់ខ្លួននោះ ។ គាត់ក៏បានជម្រាបដល់សមាជិកគណៈកម្មការទាំងអស់ថា សំណូមពរទាំងអស់របស់គេចំពោះកាលបរិច្ឆេទ និងព័ត៌មានទំនាក់ទំនងដែលគេបានផ្តល់មកនោះ ត្រូវបានធ្វើការទាក់ទងទៅហើយ ។ មានការឆ្លើយតបជាវិជ្ជមាន ហើយយើងរំពឹងនឹងកើនឡើងនៅពេលយើងបន្តទៅមុខទៀតនោះ ។

## VII. កិច្ចប្រជុំបន្ទាប់៖

លោក Tan បានប្រកាសថាកិច្ចប្រជុំបន្ទាប់នឹងធ្វើឡើងនៅថ្ងៃទី18 ខែមិថុនា តាមពេលវេលា និងទីតាំងដដែលគឺសាលប្រជុំ Berger ។ គាត់ក៏បានពិភាក្សាពីការបង្កើតរបៀបវារៈ ហើយបានស្នើសុំធាតុចូលពីអ្នកចូលរួមផងដែរ ។

a. *សំណើពីអ្នកចូលរួម៖* ការសួរនាំពីលទ្ធផលក្រោយកិច្ចប្រជុំ EAP

b. គំនិតសម្រាប់កិច្ចប្រជុំនិងកាលបរិច្ឆេទបន្ថែម៖

i. លោក Tan បានបញ្ជាក់ថា ROV បើកចំហរចំពោះការធ្វើដំណើរទៅកាន់ទីតាំងផ្សេងដែលងាយស្រួលសម្រាប់សមាជិក ។

ii. អ្នកចូលរួមបានសំណូមពរឲ្យមានកិច្ចប្រជុំនៅទីតាំងរបស់គាត់ដោយហេតុថាវាងាយស្រួលចូលរួមរបស់សាធារណជន ។

# សេចក្តីបន្ថែម L – របៀបវារៈនិងកំណត់ហេតុនៃកិច្ចប្រជុំ VAAC

## VIII. សេចក្តីប្រកាស

a. លោក Tan បានប្រកាសពីកិច្ចប្រជុំ EAP ដែលបានកំណត់ធ្វើនៅថ្ងៃទី12 ខែមិថុនា

b. សមាជិកគណៈកម្មការក៏ត្រូវបានប្រកាសប្រាប់ពីវីដេអូដែលពួកគេកំពុងតែរៀបចំផលិតស្តីពីការលើកកម្ពស់សេវាកម្មដល់សហគមន៍ជនមានពិការភាព ។ វាបើកចំហរដល់អ្នកគ្រប់គ្នាដែលចង់ចូលរួម ។ វាមានដប់មួយសំណួរ ។

## IX. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

a. គំនិតពីអ្នកចូលរួមៈ មានកន្លែងមើលថៃក្នុងការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ដើម្បីជួយដល់អ្នកទាំងនោះដែលមានពិការភាព ។

b. *សំណួរអ្នកចូលរួមៈ* តើអ្នកបានទាក់ទងទៅកាន់អង្គការសហគមន៍ផ្សេងទៀតទាក់ទងនឹងកិច្ចប្រជុំទេ?

   i. ការឆ្លើយតបៈ បាទ/ចាស ក្រុមផ្សព្វផ្សាយប្រតិបត្តិការតាមមណ្ឌលមានបញ្ជីឈ្មោះអង្គការទាំងឡាយដែលគេទាក់ទងទៅកាន់ ។ នាយកដ្ឋានតែងតែស្វែងរកអ្នកផ្តល់នូវព័ត៌មានទំនាក់ទំនងបន្ថែមទៀត

c. *សំណួរអ្នកចូលរួមៈ* តើអ្នកមានការជូនដំណឹងពីកិច្ចប្រជុំ EAP នៅលើគេហទំព័រទេ?

   i. ការឆ្លើយតបៈ បាទ/ចាស ។

## X. កិច្ចប្រជុំត្រូវបានពន្យារហូតដល់ម៉ោង 4:30 ល្ងាច

**County of Santa Clara**
Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

**កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ដើម្បីអ្នកបោះឆ្នោតអាចបោះឆ្នោតបាន**
1555 Berger Drive, San Jose, CA 95112
សាលប្រជុំ Berger
ថ្ងៃទី18 ខែមិថុនា ឆ្នាំ2019 ម៉ោង 3:30 រសៀល

I. សេចក្តីណែនាំ
    a. សមាជិកគណៈកម្មាធិការថ្មី (បើមាន)

II. ចំណុចតាមដានពីអង្គប្រជុំមុន
    a. ការពិនិត្យឡើងវិញនូវកំណត់ហេតុនៃកិច្ចប្រជុំ
    b. ការសាកសួរពីលទ្ធផលក្រោយកិច្ចប្រជុំ EAP
        i. *កិច្ចប្រជុំស្តីពីភាពដែលអាចទទួលបានលើកទីពីរត្រូវបានបន្ថែមនៅថ្ងៃទី10 ខែកក្កដា*
    c. ការបង្កើតបេសកកម្ម

III. កាលវិភាគអង្គប្រជុំ
    a. ភាពញឹកញាប់
        i. កាលបរិច្ឆេទ
        ii. ម៉ោង
    b. ទីតាំងសក្តានុពល

IV. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត
    a. ផែនទីមណ្ឌលបោះឆ្នោត (ផ្នែកផែនទី)
        i. 11 ថ្ងៃ
        ii. 4 ថ្ងៃ
        iii. ទីតាំងហិបទម្លាក់សន្លឹកឆ្នោត
    b. គម្រោងផ្សព្វផ្សាយ (ផ្នែកកិច្ចការសាធារណៈ និងនីតិកម្ម)

V. ការជ្រើសរើស និងការផ្សព្វផ្សាយ (សមាជិកដែលបានណែនាំ)
    a. ការជ្រើសរើសសមាជិកថ្មី

VI. ការបង្កើតរបៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់

VII. សេចក្តីប្រកាស

VIII. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

*កន្លែងទាំងនេះជាកន្លែងដែលអាចប្រើប្រាស់បាន ។ សម្រាប់សំណើសុំឯកសារក្នុងទម្រង់ដែលប្រើប្រាស់បាន សេវាកម្មបកប្រែផ្ទាល់មាត់ ឧបករណ៍ជំនួយក្នុងការស្តាប់ ឬទីស្នាក់អាស្រ័យផ្សេងទៀត សូមធ្វើការទំនាក់ទំនងដោយទូរសព្ទទៅកាន់ ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត ឬផ្នែកបម្រើសេវារដ្ឋបាល តាមរយៈលេខ៖ (408) 918-9169 ឬ អាចធ្វើសំណើតាមរយៈអ៊ីមែលទៅកាន់ voterschoice@rov.sccgov.org ដោយមិនយឺតជាងប្រាំថ្ងៃធ្វើការមុនថ្ងៃប្រជុំ ។*

VOTER'S CHOICE
Registrar of Voters
Santa Clara County

# មន្រ្តីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara

# គណៈកម្មាធិការប្រឹក្សាលទ្ធភាពបោះឆ្នោត (VAAC)

## កំណត់ហេតុនៃកិច្ចប្រជុំ

1555 Berger Drive, San Jose, CA 95112
អាគារ 2
ថ្ងៃទី18 ខែមិថុនា ឆ្នាំ2019 ម៉ោង 3:30 រសៀល

**វត្តមានសមាជិកចូលរួម៖** Fred Nisen, Monique Moore, Yeshe Telemichael (តាម Skype), Jennifer Lucas, Matt, James and Lisa Cohn, Christine Fitzgerald (តាម Skype)

**វត្តមានបុគ្គលិកចូលរួម៖** Shannon Bushey, Darren Tan, Virginia Bloom, Eimear Duncan, Rachel Jung, Alfred Gonzales, Paulo Chang, Liz Oviedo, Mike Fong, Martin Weakley, Eric Kurhi, Ruby Naranjo, Christina Rivas-Louie, Carmelita Aldana, Iliena Hernandez, Michael Borja, Janora Davis, Smita Shah, Robert Wiedlin, Lorenzo Castaneda, Aaron Wong, Jose Posadas.

**ចំណុចសកម្មភាព៖**

- តើខោនធីត្រូវបានអនុញ្ញាតឲ្យទាក់ទង DMV (ក្រសួងយានយន្ត) ដើម្បីសួរកអ្នកដែលមានកាតជនពិការដើម្បីយើងអាចទាក់ទងទៅកាន់ពួកគេដែរឬទេ?

I. **ការស្វាគមន៍និងការណែនាំ** – Darren Tan, សេវារដ្ឋបាលនិង Shannon Bushey ពី ROV ។
   i. ការណែនាំដល់បុគ្គលិក
   ii. សមាជិកគណៈកម្មាធិការ
      - គណៈកម្មាធិការបានរំឭកដល់សមាជិកថា ការចូលរួមមិនចាំបាច់ទាល់តែគេជាសមាជិកនោះទេ ការចូលរួមកិច្ចប្រជុំនិងធាតុចូលតែងតែត្រូវបានលើកទឹកចិត្តជានិច្ច ។

II. **អង្គប្រជុំមុនដែលមានការអនុម័ត**
   i. សមាជិកគណៈកម្មការពុំមានពេលដើម្បីពិនិត្យទៅលើកំណត់ហេតុកិច្ចប្រជុំពីមុនមកទេ

III. **ចំណុចដែលអាចធ្វើសកម្មភាពបាន**
   i. សង្ខេបចំណុចសំខាន់ៗពីកិច្ចប្រជុំ EAP ទាក់ទងនឹងមណ្ឌលបោះឆ្នោត ហិបទម្លាក់សន្លឹកឆ្នោត ការផ្សាយពាណិជ្ជកម្មនិងការផ្សព្វផ្សាយ
   ii. ធាតុចូលពីអ្នកស្ម័គ្រចិត្ត៖ ខោនធី San Mateo មានអ្នកចាំស្វាគមន៍អ្នកបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ។ ធ្វើការពិចារណាទៅលើពិការភាពដែលមិនអាចមើលឃើញ ។ សមាជិកម្នាក់បានលើកឡើងថាការិយាល័យរបស់គេធ្វើការពាក់ព័ន្ធការលើកកម្ពស់ការយល់ដឹងពីពិការភាព ។ DRC មានកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ។ ទាំងនេះជាមធ្យោបាយងាយស្រួលដើម្បីសម្រេចគោលដៅទាំងនេះ ។ មធ្យោបាយងាយៗដែលកំពុងត្រូវបានមើលរំលងនៅតាមមណ្ឌលបោះឆ្នោត ។
   iii. ការឆ្លើយតបរបស់ ROV៖ ROV មានឆន្ទៈចូលរួមក្នុងការបណ្តុះបណ្តាលរបស់អង្គការរបស់ពួកគេ ដើម្បីមើលវាពីទស្សនៈផ្សេង ។ គោលដៅរបស់ ROV គឺត្រូវធ្វើឲ្យពលរដ្ឋមានអារម្មណ៍ប្រកបដោយផាសុខភាពនៅតាមមណ្ឌលបោះឆ្នោតដើម្បីស្នើសុំជំនួយ ។ សមាជិកមិនចាំបាច់ត្រូវរងចាំរហូតដល់មានកិច្ចប្រជុំទើបផ្តល់ធាតុចូលនោះទេ ពួកគេអាចសរសេរអ៊ីម៉ែល និងចែករំលែកធនធានរបស់គេដោយសេរី ។

## IV. ការបង្កើតបេសកកម្ម

i. ឯកសារចែកជូនពីបេសកកម្មនិងគោលដៅរបស់ខោនធីផ្សេង ត្រូវបានផ្តល់ដល់គណៈកម្មការសម្រាប់ជាគំរូដើម្បីជួយណែនាំដល់ពួកគេក្នុងការបង្កើតនូវបេសកកម្មនិងគោលដៅរបស់យើង ។ សមាជិកត្រូវបានលើកទឹកចិត្តឲ្យផ្តល់នូវធាតុចូល គោលដៅ និងគំនិតនានារបស់គេ ដើម្បីជួយដល់យើងសម្រេចជាចុងក្រោយនូវសេចក្តីថ្លែងពីបេសកកម្មរបស់គណៈកម្មការ ។ រំពឹងថានឹងមានពាក្យ "បរិយាប័ន្ន និងដែលអាចទទួលបាន" នឹងត្រូវបានដាក់បញ្ចូល ។

ii. អ្នកស្ម័គ្រចិត្តៈ ខោនធី San Francisco មានការប្រុងប្រៀបខ្ពស់ណាស់ ព្រមទាំងគំនិតសហការនិងភាពជាដៃគូរបស់គេ ។ ត្រូវប្រាកដថាបេសកកម្មងាយស្រួលយល់ យោងទៅដល់គេហទំព័រ DRC សម្រាប់សេចក្តីថ្លែងរបស់ VAAC សម្រាប់ជាគំនិត ។ សារសាមញ្ញកាន់តែប្រសើរ រូបភាពឲ្យធំ មិនត្រូវលង់ជ្រៅទៅក្នុងសេចក្តីពិស្តារ ។

## V. កាលវិភាគអង្គប្រជុំ

i. ភាពញឹកញាប់៖
- ROV ចង់បានធាតុចូលទាំងអស់ដែលចាំបាច់ដើម្បីឲ្យទាន់កាលបរិច្ឆេទកំណត់សម្រាប់ពង្រាង EAP ។ នៅពេលកាន់តែកៀកទៅនឹងការបោះឆ្នោត វាអាចស្ថិតស្ថេរមានតែ ត្រូវប្រជុំប្រចាំត្រីមាសនិងកិច្ចប្រជុំតាមភាពចាំបាច់ដែលអាចធ្វើបាន ឬអ៊ីម៉ែលសមាជិកសម្រាប់ធាតុចូលរបស់ពួកគេស្តីពីបញ្ហាទាំងឡាយណាដែលអាចកើតមានឡើង ។
- សមាជិកបានសំណូមពរឲ្យប្រជុំមួយខែម្តង ។

ii. ម៉ោង៖
- សមាជិកមួយចំនួនពេញចិត្តប្រជុំពេលព្រឹក និងអ្នកផ្សេងពេលរសៀលដោយសារតែកាលវិភាគរបស់ពួកគេ ។ ROV បានសំណូមពរចំពោះជម្រើសពេលប្រជុំដែលអាចធ្វើបានរវាងពេលព្រឹកនិងពេលរសៀលនោះឲ្យយកសំណើទាំងពីរ ។

iii. ទីតាំង៖
- សមាជិកខ្លះបានសម្តែងនូវការព្រួយប្រារម្ភថា ប្រជុំនៅច្រើនកន្លែងនឹងធ្វើឲ្យមានច្រឡំដល់សមាជិក ហើយកម្រិតប្តេជ្ញាចិត្តអាចទាប ។ មនុស្សចង់ប្រជុំនៅកន្លែងដែលគេធ្លាប់ស្គាល់ដោយថាវាងាយជាងសម្រាប់ពួកគេទៅចូលរួម ។
- ROV នឹងរៀបចំកាលវិភាគកិច្ចប្រជុំទៅតាមទីតាំងសំណូមពរដោយសមាជិក ។ គោលបំណងនៃគណៈកម្មការគឺធ្វើយ៉ាងណាឲ្យសមាជិកនិងអ្នកដែលមានសក្តានុពលជាសមាជិកទាំងអស់អាចចូលរួមបាន ។ គោលបំណងនៃការធ្វើឡើងនៅតាមទីតាំងផ្សេងគ្នាគឺដើម្បីឲ្យនាយកដ្ឋានបានទៅស្គាល់គ្រប់តំបន់ទាំងអស់នៃខោនធី ។ គោលដៅគឺដើម្បីផ្តោតទៅលើតំបន់ដែលមានអ្នកចាប់អារម្មណ៍ភាគច្រើនរស់នៅ និងធ្វើទីនោះជាកន្លែងកណ្តាលសម្រាប់ប្រជុំ ។ សំណូមពរមួយពីខោនធីផ្សេង ដែលបានអនុវត្តច្បាប់ CVA នោះ គឺសម្រាប់ ROV ចេញទៅគ្រប់តំបន់ទាំងអស់នៃសហគមន៍ ។ មូលហេតុមួយរបស់ ROV ក្នុងការធ្វើកម្មវិធីផ្សព្វផ្សាយរបស់ខ្លួននោះ គឺត្រូវពន្យល់ដល់ពលរដ្ឋចំនួនដ៏ធំនៅក្នុងសហគមន៍ដែលមិនបានដឹងពីច្បាប់ CVA ។ ROV ចាំបាច់ត្រូវអនុវត្តតួនាទីរបស់ខ្លួនដើម្បីកៀរដល់សហគមន៍ឲ្យបានកាន់តែទូលំទូលាយ ។ នេះនឹងបន្ថែមចូលទៅក្នុងរបៀបវារៈនាពេលអនាគត ។

## VI. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត

i. ការបង្ហាញផែនទីនៃមណ្ឌលបោះឆ្នោត និងការពិភាក្សាទូទៅដោយ Aaron Wong, ផ្នែកផែនទី
- 11 ថ្ងៃ
- 4 ថ្ងៃ
- ទីតាំងហិបទម្លាក់សន្លឹកឆ្នោត

i. Aron បានពន្យល់ពីការបំបែកផែនទីនីមួយៗឲ្យកាន់តែស៊ីជម្រៅ ដោយបង្ហាញពីការបែងចែកតំបន់នានាជា 11 និង 4 ថ្ងៃសម្រាប់ទីតាំងដែលសក្តានុពលធ្វើជាមណ្ឌលបោះឆ្នោត ។ នឹងមានមណ្ឌលបោះឆ្នោតចំនួន 1 សម្រាប់អ្នកបោះឆ្នោតចំនួន 50,000 នាក់សម្រាប់រយៈពេល 11 ថ្ងៃ និង 1 មណ្ឌលបោះឆ្នោតសម្រាប់អ្នកបោះឆ្នោត 10,000 នាក់សម្រាប់រយៈពេល 4 ថ្ងៃ ។ វាក៏ត្រូវបានពន្យល់ផងដែរថា ROV ត្រូវបានប្រើប្រាស់ជំរឿនសម្រាប់បំបែកផែនទីឲ្យកាន់តែពិស្តារ ។ អ្នកបោះឆ្នោតទាំងអស់នឹងទទួលបាន

ព័ត៌មានស្តីពី VCs នៅក្នុង CVIG ។ គេហទំព័រ ROV នឹងមានទំព័រមួយឈ្មោះថា 'ទីតាំងដែលស្ថិតនៅជិតខ្ញុំបំផុត' សម្រាប់ទីតាំងហិបទម្លាក់សន្លឹកឆ្នោតទាំងអស់ ។ Shannon បានពន្យល់អំពីហិបទម្លាក់សន្លឹកឆ្នោត និងចំនួនហិបដែលត្រូវការ ។ សម្រាប់មណ្ឌលបោះឆ្នោតចល័ត មានលក្ខខណ្ឌជាក់លាក់និងគោលការណ៍ណែនាំ សម្រាប់ ROV ដើម្បីអនុវត្ត ។ ASL នឹងត្រូវឲ្យចាត់ចែងតាមរយៈ Voiance, Facetime/ការប្រជុំតាមវីដេអូ ។ សុំឲ្យសមាជិកទាំងអស់អ៊ីម៉ែលនូវសំណូមពរទាំងឡាយនៃ VCs ទៅកាន់ ROV @ Voters Choice ។

iii. កិច្ចពិភាក្សារបស់សមាជិក៖ មិនមែនមនុស្សទាំងអស់មិនបង្ហាញថាមានពិការភាពតាមរយៈជំរឿននោះទេ ។ វាពិតជាពិបាកកំណត់នូវតំបន់ជាក់លាក់ដែលមនុស្សមានពិការភាព ។ ព្រួយបារម្ភពីរភាពដែលអាចចេញចូលបានរបស់ពលរដ្ឋនៅតំបន់ដាច់ស្រយាលក្នុងខោនធីខាងត្បូង និងរបស់អ្នក VCs ទាំងនោះ ។ ចាំបាច់ត្រូវផ្សព្វផ្សាយច្រើនម៉ោងតាមសំបុត្រ ។ ទៅចូលរួមប្រជុំតាមទីប្រជុំជនដើម្បីលើកយកបញ្ហា និងបង្ហាញពីភាពចាំបាច់សម្រាប់ VCs ។ ត្រូវប្រាកដថា ហិបទម្លាក់សន្លឹកឆ្នោតស្ថិតនៅកម្ពស់សមស្របសម្រាប់មនុស្សគ្រប់ៗគ្នា ។ ការព្រួយបារម្ភទាក់ទងនឹងការប្រើប្រាស់ Facetime និង សន្និបាទតាមវីដេអូត្រូវបានលើកឡើង ដែលវានឹងចាំបាច់ត្រូវមានអេក្រង់ធំបង្ហាញពេញមួយជំហរខ្លួនសម្រាប់គោលបំណងបកប្រែ ។

## VII. ការផ្សាយពាណិជ្ជកម្ម និងកិច្ចពិភាក្សាផ្សព្វផ្សាយដោយ Eric Kurhi កិច្ចការសាធារណៈ និងនីតិកម្ម ។

i. របៀបដែលការផ្សព្វផ្សាយទៅដល់សហគមន៍ អ្វីដែលការបោះពុម្ពផ្សាយ និងគំនិតផ្សេងៗទៀត ។

ii. សំណូមពរ/សំណួរសមាជិក - តើខោនធីត្រូវបានអនុញ្ញាតឲ្យទាក់ទង DMV (ក្រសួងយានយន្ត) ដើម្បីសួររកអ្នកដែលមានកាតជនពិការដើម្បីយើងអាចទាក់ទងទៅកាន់ពួកគេ? (ការឆ្លើយតប៖ នេះមិនទំនងជាទៅរួចទេ ប៉ុន្តែ ROV នឹងពិចារណាស្វែងយល់និងធ្វើការកៀគរពិចារណាទៅដល់បញ្ហាប្រឈមដែលកើតចេញពីការទំនាក់ទំនង បង្កើតឲ្យមានបញ្ហាប្រឈមបែប Hashtag) ។

## VIII. មតិត្រឡប់សំណួរនិង/ឬកង្វល់សាធារណៈមានសារៈសំខាន់ចំពោះគណៈកម្មាធិការ

## IX. ការជ្រើសរើសសមាជិកថ្មី

## X. កិច្ចប្រជុំបន្ទាប់

i. ការបង្កើតរបៀបវារៈកិច្ចប្រជុំបន្ទាប់

- ការរំឭកពីកិច្ចប្រជុំ EAP លើកទីពីរស្តីពីភាពដែលអាចទទួលបាន
- តីតាំងនាពេលអនាគតសម្រាប់កិច្ចប្រជុំ VAAC
- របៀបជ្រើសរើសសមាជិកថ្មី
- ផែនទី ការផ្សព្វផ្សាយ និងមណ្ឌលបោះឆ្នោត ។ (បន្តកិច្ចសន្ទនាពីកិច្ចប្រជុំនេះ)

## XI. សេចក្តីប្រកាស

## XII. **សំណួរ និងចម្លើយនៃកិច្ចពិភាក្សា** - សំណួរត្រូវបានសួរតាំងពីដើមដល់ចប់នៃកិច្ចប្រចុំ ហើយម៉ោងសំណួរចម្លើយមិនមានទទួលបានសំណួរបន្ថែមទៀតទេ ។

## XIII. កិច្ចប្រជុំត្រូវបានពន្យាដល់ម៉ោង 4:45 ល្ងាច

**County of Santa Clara**
Registrar of Voters

1555 Berger Drive, Bldg. 2
San Jose, CA 95112
Mailing Address: PO Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) FAX: (408) 998-7314
www.sccvote.org

VOTER'S CHOICE
Registrar of Voters
Santa Clara County

## កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ដើម្បីអ្នកបោះឆ្នោតអាចបោះឆ្នោតបាន

25 N. 14th St., Suite 1000, San Jose
មជ្ឈមណ្ឌលរស់នៅដោយ Independent Silicon Valley
ថ្ងៃទី16 ខែកក្កដា ឆ្នាំ2019 ម៉ោង 10:00 ព្រឹក

I. សេចក្តីណែនាំ
   a. សមាជិកគណៈកម្មាធិការថ្មី (បើមាន)

II. ចំណុចតាមដានពីអង្គប្រជុំមុន
   a. ការពិនិត្យឡើងវិញនូវកំណត់ហេតុនៃកិច្ចប្រជុំ
   b. សរុបលទ្ធផលកិច្ចប្រជុំ EAP ពីភាពដែលអាចទទួលយកបាន
   c. ការបង្កើតបេសកកម្ម

III. បញ្ចប់ភ័ស្តុភារកិច្ចប្រជុំ
   a. ទីតាំងមជ្ឈមណ្ឌល
      i. អ្វីដែលបានស្នើ៖ SVILC
   b. ភាពញឹកញាប់នៃកិច្ចប្រជុំ៖ ប្រចាំខែ (ត្រូវបានបញ្ជាក់ក្នុងកិច្ចប្រជុំលើកមុន)
      i. រហូតដល់ខែធ្នូ
      ii. ប្រចាំត្រីមាសបន្ទាប់ពីការបញ្ចប់នៃការបោះឆ្នោត
   c. សហប្រធានពិភាក្សា (សមាជិកដែលត្រូវស្នើឡើងដោយ LAAC)

IV. ផែនការរដ្ឋបាលរៀបចំការបោះឆ្នោត
   a. ឯកសារបោះឆ្នោត
   b. RAVBM៖ ការធ្វើបទបង្ហាញដោយផ្នែកបោះឆ្នោតតាមសំបុត្រ
   c. ការអប់រំអ្នកបោះឆ្នោត និងសម្ព័ន្ធភាពផ្សព្វផ្សាយ

V. ការជ្រើសរើសបុគ្គលិក និងផ្សព្វផ្សាយ។
   a. ព្រឹត្តិប័ត្រព័ត៌មាន SCDD (សូមអរគុណ Jennifer!)

VI. ការបង្កើតរបៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់

VII. សេចក្តីប្រកាស

VIII. សំណួរ និងចម្លើយនៃកិច្ចពិភាក្សា

*កន្លែងទាំងនេះជាកន្លែងដែលអាចប្រើប្រាស់បាន ។ សម្រាប់សំណើសុំឯកសារក្នុងទម្រង់ដែលប្រើប្រាស់បាន សេវាកម្មបកប្រែផ្ទាល់មាត់ ឧបករណ៍ជំនួយក្នុងការស្តាប់ ឬទីស្នាក់អាស្រ័យផ្សេងទៀត សូមធ្វើការទំនាក់ទំនងដោយទូរសព្ទទៅកាន់ ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត ឬផ្នែកបម្រើសេវារដ្ឋបាល តាមរយៈលេខ៖ (408) 918-9169 ឬ អាចធ្វើសំណើតាមរយៈអ៊ីមែលទៅកាន់ voterschoice@rov.sccgov.org ដោយមិនយឺតជាងប្រាំថ្ងៃធ្វើការមុនថ្ងៃប្រជុំ ។*

# សេចក្តីបន្ថែម M – គម្រោងអប់រំនិងផ្សព្វផ្សាយពិស្តារ

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោតខោនធី Santa Clara (ROV) ប្តេជ្ញាចិត្តធ្វើពិធភាពការចូលរួមរបស់អ្នកបោះឆ្នោតក្នុងចំណោមពលរដ្ឋនៅក្នុងខោនធី ។ គម្រោងអប់រំនិងផ្សព្វផ្សាយដាក់ចេញនូវសកម្មភាពផ្សេងៗដែលអាចធ្វើបានក្នុងគោលបំណងបង្កើននូវភាពជាដៃគូសហគមន៍ ពង្រីកឱកាសចូលរួមពីពលរដ្ឋ និងលើកកម្ពស់បទពិសោធន៍ចូលរួមរបស់អ្នកបោះឆ្នោតជាមួយនឹងមណ្ឌលបោះឆ្នោតគំរូ ។ សកម្មភាព ដូចខាងក្រោមត្រូវបានគ្រោងសម្រាប់ការអនុវត្តក្នុងឆ្នាំទីមួយ ។

## ប្រភេទការងារផ្សព្វផ្សាយ៖

- <u>ការផ្សព្វផ្សាយតាមបែបប្រពៃណី</u>៖ សកម្មភាពដូចរាយខាងក្រោមបង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការអប់រំនិងផ្សព្វផ្សាយពីគម្រោង ROV និងចូលរួមពេញមួយឆ្នាំដោយមិនគិតពីការបោះឆ្នោតតាមកំណត់ ។ នៅតាមសកម្មភាពទាំងនេះ ROV ផ្តល់ឯកសារស្តីពីការអប់រំដល់អ្នកបោះឆ្នោត ធនធានឯកសាររដ្ឋាភិបាលនិងពលរដ្ឋ របស់របរការិយាល័យចុះបញ្ជីបោះឆ្នោត និងការពិភាក្សាស៊ីជម្រៅទៅដល់សាធារណជន ។
    - ការដាក់សំណើជាផ្លូវការ – ព្រឹត្តិការណ៍ផ្សព្វផ្សាយទូទៅស្ថិតនៅក្រោមសំណើផ្លូវការដើម្បីផ្តល់ធនធាន ឯកសារ ការអប់រំដល់អ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត និងការជ្រើសរើសមន្ត្រីបោះឆ្នោត ។
    - ការទទួលរៀបចំស្តង់ផ្សព្វផ្សាយ – ដើម្បីឆ្លើយតបទៅតាមសំណើសុំរៀបចំព្រឹត្តិការណ៍ខ្នាតធំក្រៅអគារ ពីធីបុណ្យ និងសន្និបាតនោះ យើងផ្តល់ធនធាន ឯកសារ ការអប់រំដល់អ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត និងការជ្រើសរើសមន្ត្រីបោះឆ្នោត ។
    - ការបណ្តុះបណ្តាលការចុះឈ្មោះអ្នកបោះឆ្នោត – ដើម្បីឆ្លើយតបទៅតាមសំណើរបស់បុគ្គល/អង្គភាពនោះ យើងផ្តល់ការបណ្តុះបណ្តាលពីរបៀបធ្វើជាអ្នករៀបចំកម្មវិធីជម្រុញអ្នកបោះឆ្នោតផ្អែកទៅលើធនធានសម្ភារៈពីរដ្ឋលេខាធិការ ។
    - បទបង្ហាញពីការអប់រំដល់អ្នកបោះឆ្នោត – ដើម្បីឆ្លើយតបតាមសំណើ/អង្គភាពនានានោះ បទបង្ហាញពីការអប់រំដល់អ្នកបោះឆ្នោតក្តោបទៅលើការផ្លាស់ប្តូរទាំងឡាយនៅក្នុងច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត ច្បាប់ 101 សិទ្ធិបោះឆ្នោត និងរបៀបចុះឈ្មោះបោះឆ្នោត/ការចុះឈ្មោះបោះឆ្នោតមុន ។
    - កម្មវិធីទាក់ទាញការចុះឈ្មោះអ្នកបោះឆ្នោតតាមវិទ្យាល័យ – សម្របសម្រួល និងជួយក្នុងការរៀបចំកម្មវិធីជម្រុញការចុះឈ្មោះអ្នកបោះឆ្នោត ។
    - ព្រឹត្តិការណ៍បង្កើតបណ្តាញ/ព្រឹត្តិការណ៍ពលរដ្ឋនានា – វត្តមានចូលរួមនិងការកសាងភាពជាដៃគូនៅតាមព្រឹត្តិការណ៍សហគមន៍និងព្រឹត្តិការណ៍គាំទ្រសម្រាប់សភាពាណិជ្ជកម្មក្រុងផ្សេងៗ មណ្ឌលក្រុមប្រឹក្សាក្រុង ។ល។

- <u>កម្មវិធីផ្សព្វផ្សាយជាក់លាក់ពីច្បាប់ជម្រើសអ្នកបោះឆ្នោត</u>៖ ROV កំពុងតែធ្វើផែនការសកម្មភាពអប់រំ និងផ្សព្វផ្សាយបែបថ្មី ដោយផ្ដល់ព័ត៌មានយ៉ាងសកម្មអំពីការផ្លាស់ប្ដូរទាំងឡាយនាពេលខាងមុខ និងសូមស្វាគមន៍នូវធាតុចូលពីបុគ្គលនិងសហគមន៍នៅគ្រប់ជំហាននៃដំណើរការអនុវត្ត ។ សកម្មភាពរាយដូចខាងក្រោម តំណាងឲ្យប្រភេទទាំងឡាយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយដែល ROV នឹងធ្វើជាអ្នកទទួលភ្ញៀវ អ្នកចូលរួម និងសហការជាមួយសមាជិកនិងអង្គការនៃខោនធី Santa Clara៖
    - បទបង្ហាញ
    - ម៉ោងពិភាក្សា ឬ សំណួរចម្លើយ
    - ការកសាងភាពជាដៃគូ (កិច្ចប្រជុំដោយផ្ទាល់ជាមួយនឹង CBOs)
    - សិក្ខាសាលា (សម្រាប់សហគមន៍មានតម្រូវការផ្នែកភាសានិងលទ្ធភាពចូលរួម)
    - កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្គោល (TTT) (បណ្ដុះបណ្ដាលដៃគូផ្សព្វផ្សាយដើម្បីរៀបចំសារសម្រាប់ខ្លួនឯងនិងងាយយល់)
    - គ្រឿងបរិក្ខារបោះឆ្នោត/ម៉ាស៊ីនកត់ត្រា

**ការធ្វើឈ្មោះនិម្មិត/សារ**៖ ខោនធី Santa Clara បានធ្វើសេចក្ដីសម្រេចចិត្តដោយមានការឯកភាពគ្នាដើម្បីកំណត់អាទិភាពទៅលើព័ត៌មានត្រូវផ្សព្វផ្សាយអំពីមណ្ឌលបោះឆ្នោត និងសេវាដែលពួកគេនឹងអាចផ្ដល់ឲ្យបាន ដោយរាប់បញ្ចូលទាំងព័ត៌មានអំពីអ្នកបោះឆ្នោតគ្រប់គ្នាទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍ ។ ដោយពីចារណាទៅលើចំនួនអ្នកបោះឆ្នោត 75-80% នៅក្នុងខោនធីរបស់យើង គឺជាអ្នកបោះឆ្នោតតាមសំបុត្រនោះ ROV ចង់ផ្ដោតទៅលើអ្នកបោះឆ្នោតដែលនឹងរងការប៉ះពាល់ខ្លាំងបំផុតដោយការផ្លាស់ប្ដូរ៖ អ្នកបោះឆ្នោតដែលពេញចិត្តទៅបោះឆ្នោតដោយផ្ទាល់ ។ ខោនធីដែលបានអនុវត្ត VCA ហើយបានរៀបចំការបោះឆ្នោតរួចក្រោមគំរូមណ្ឌលបោះឆ្នោតដែលបានលើកឡើង ដែលការយកចិត្តទុកដាក់របស់គេទៅលើការបោះឆ្នោតតាមសំបុត្រប្រហែលជាបានធ្វើឲ្យអ្នកបោះឆ្នោតមានការភាន់ច្រឡំពីថ្ងៃបោះឆ្នោតដោយសារតែគេមិនបានផ្ដល់ព័ត៌មានពីទីតាំងមណ្ឌលបោះឆ្នោតថ្មី និងដំណើរការផ្លាស់ប្ដូរទាំងមូល ។

## តារាងពេលវា/ដំណាក់កាលផ្សព្វផ្សាយ៖

- <u>ដំណាក់កាល 1៖ កក្កដា - កញ្ញា 2019</u>
    - បារបណ្ដុះបណ្ដាលគ្រូបង្គោល & សិក្ខាសាលានានា
        - 8 សីហា 2019 – ពិធីដាក់ឲ្យដំណើរការកម្មវិធីសម្ព័ន្ធភាពដើម្បីការអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត (VEOC) ដោយសហការជាមួយ Silicon Valley at Home
        - 7 កញ្ញា 2019 – កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្គោល

            - ការសហការជាមួយនឹងសហគមន៍ស្ត្រី ដើម្បីភាពជាអ្នកដឹកនាំដោយស្មើភាព 2020 & ការិយាល័យ SCC នៃគោលនយោបាលស្តីពីស្ត្រី
        - 18 កញ្ញា 2019 – សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ VCA (ពិការភាព)
            - កិច្ចសហប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌល Vista សម្រាប់ជនពិការភ្នែក និងកំសោយការមើល
        - តុលា 2019 – សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ VCA (ភាសា)
            - កិច្ចសហប្រតិបត្តិការជាមួយនឹងសេវាសហគមន៍កូរ៉េអាមេរិកាំង
        - តុលា/វិច្ឆិកា 2019 – សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ VCA (ភាសា)
            - កិច្ចសហការជាមួយតុមូលវៀតណាមអាមេរិកាំង
    - ការផ្សព្វផ្សាយដល់សិស្សវិទ្យាល័យ
        - ការចុះឈ្មោះអ្នកបោះឆ្នោតជាសិស្សវិទ្យាល័យរដ្ឋនៅទាំងខោនធី និងការអប់រំពីច្បាប់ VCA
            - ត្រូវបានដឹកនាំដោយសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី និងសមាគមស្ត្រីសាកលវិទ្យាល័យអាមេរិកាំង
            - កិច្ចសហការជាមួយនឹងការិយាល័យ SCC នៃគោលនយោបាយស្តីពីស្ត្រី និងការិយាល័យ SCC នៃការអប់រំ
- <u>ដំណាក់កាលទី 2៖ តុលា-ធ្នូ 2019</u>
    - ផ្តល់បទបង្ហាញ សម្ភារៈ & ឯកសារព័ត៌មាន & ធ្វើកម្មវិធីសំណួរចម្លើយ (Q&A) ជាមួយនឹងសហគមន៍ក្នុងសង្កាត់ & PTA នៅក្នុងខោនធី San Jose
        - កិច្ចសហការជាមួយនឹង Silicon Valley at Home
    - ផ្សព្វផ្សាយដល់និស្សិតមហាវិទ្យាល័យ
        - ធ្វើការជាមួយនឹងសមាគមនិស្សិតនិងបុគ្គលិកសិក្សានៅ៖
            - San Jose សាកលវិទ្យាល័យរដ្ឋ
            - សាកលវិទ្យាល័យ Santa Clara
            - សាកលវិទ្យាល័យ Stanford (ថ្នាក់ឧត្តម & ក្រោយឧត្តមសិក្សា)
            - មហាវិទ្យាល័យសហគមន៍
    - ក្រុមហ៊ុនសាជីវកម្ម
    - ក្រុមហ៊ុនអាជីវកម្មខ្នាតតូចនិងស្ថិតក្នុងមូលដ្ឋាន
    - សិក្ខាសាលា

        - វិច្ឆិកា 2019-មករា 2020 - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (ពិការភាព)
            - សហការជាមួយនឹងមជ្ឈមណ្ឌលរស់នៅដោយឯករាជ្យ Cilicon Valley
        - វិច្ឆិកា 2019-មករា 2020 - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (ពិការភាព)
            - សហការជាមួយនឹងមជ្ឈមណ្ឌលភូមិភាគ San Andreas
        - វិច្ឆិកា 2019-មករា 2020 - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (ពិការភាព)
            - សហការជាមួយនឹងក្រុមប្រឹក្សារដ្ឋស្ដីពីពិការភាពអភិវឌ្ឍន៍
        - វិច្ឆិកា 2019-មករា 2020 - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (ភាសា)
            - សហការជាមួយសហគមន៍ចិន
- <u>ដំណាក់កាលទី 3៖ ខែមករា & កុម្ភៈ 2020</u>
    - ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ
    - យុទ្ធសាស្ត្រផ្សព្វផ្សាយទៅកាន់សហគមន៍គោលដៅ/សហគមន៍ដែលមិនទទួលបានសេវាជិតដល់តាំងពីដើមមក
    - សមាគមនៅក្នុងសង្កាត់ & PTA (សមាគមមាតាបិតានិងគ្រូបង្រៀន) (ខោនធី ជើង & ត្បូងធី)
    - កិច្ចសហការជាមួយមន្ត្រីជាប់ឆ្នោត ដើម្បីផ្សព្វផ្សាយពីការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតី & ច្បាប់ VCA
        - អ្នកគ្រប់គ្រងខោនធី
        - សមាជិកក្រុមប្រឹក្សាក្រុង
        - សមាជសភា
        - តំណាងរាស្ត្រ
        - ក្រុមប្រឹក្សាមណ្ឌលសិក្សាធិការ
    - សិក្ខាសាលា
        - មករា/កុម្ភៈ 2020 - សិក្ខាសាលាស្ដីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកពោះឆ្នោត (ភាសា)
            - សហការជាមួយសហគមន៍វៀតណាម
        - មករា/កុម្ភៈ 2020 - សិក្ខាសាលាស្ដីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្ដីពីជម្រើសរបស់អ្នកពោះឆ្នោត (ភាសា)

- សហការជាមួយសហគមន៍អេស្ប៉ាញ

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (ភាសា)

  - សហការជាមួយសហគមន៍តាកាឡុក

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (ភាសា)

  - សហការជាមួយសហគមន៍ជប៉ុន

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (ភាសា)

  - សហការជាមួយសហគមន៍ហ៊ីនឌី

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត & ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត (ភាសា)

  - សហការជាមួយសហគមន៍ខ្មែរ

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោតជាមួយនឹងជនគ្មានទីពំនាក់អាស្រ័យ

  - សហការជាមួយការិយាល័យ SCC នៃជំនួយផ្នែកលំនៅដ្ឋាន, កម្មវិធីថែទាំសុខភាពជនគ្មានទីលំនៅនៅ Valley, និងការថែទាំសុខភាពអ្នកជំងឺគ្មានទីលំនៅ & ក្រុមផ្តល់ប្រឹក្សាគ្រួសារ

▪ មករា/កុម្ភៈ 2020 - សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត ជាមួយមហាវិទ្យាល័យសហគមន៍ Evergreen និងមហាវិទ្យាល័យក្រុង San Jose

  - សហការជាមួយក្រុមប្រឹក្សាសមធមិភាពជាអ្នកដឹកនាំរបស់ស្ត្រី

# ឧបសម្ព័ន្ធ N – វិធានការបង្ការ

អ្នកកាន់កាប់បញ្ជីអ្នកបោះឆ្នោត (ROV) មានវិធានការបង្ការរួចជាស្រេចដូចតទៅនេះ ដើម្បីបញ្ចៀសការបង្អាក់ណាមួយលើដំណើរការបោះឆ្នោតដែលអាចកើតមានឡើង ៖

## វិធានការសន្តិសុខតាមស្តង់ដារ

ដើម្បីដាក់កំហិតលើការចូលទៅកាន់ឯកសារ និងបរិក្ខារទាក់ទងនឹងការបោះឆ្នោត និងទប់ស្កាត់ការបង្អាក់ណាមួយដែលអាចកើតមានឡើងនៅទីបំផុត ៖

- បុគ្គលិកត្រូវបានតម្រូវឲ្យពាក់ស្លាកសម្គាល់ ID ដែលត្រូវបានចេញដោយខោនធី ឬក្រសួង ។
- អ្នកទស្សនា ឬអ្នកដែលមិនមែនជាបុគ្គលិក ដែលចូលមកក្នុងការិយាល័យរបស់ក្រសួង ហួសពីតុទទួលភ្ញៀវខាងមុខ ត្រូវអមដំណើរដោយបុគ្គលិកដែលអ្នកទស្សនានេះកំពុងជួប ។
- បន្ទប់ម៉ាស៊ីនកុំព្យូទ័រមេ និងបន្ទប់បោះឆ្នោតរបស់ក្រសួងត្រូវតែធ្វើឲ្យមានសុវត្ថិភាពជានិច្ចដោយប្រើស្លាកកំណត់លើការចូលទៅក្នុង និងកាមេរ៉ាឃ្លាំមើល ។

## ការថតចម្លងទុកទិន្នន័យក្នុងបណ្តាញកុំព្យូទ័រ និងម៉ាស៊ីនមេ

ដើម្បីទប់ស្កាត់ការបង្អាក់លំហូរព័ត៌មាន ប្រសិនបើបណ្តាញកុំព្យូទ័រឬម៉ាស៊ីនមេចម្បងមិនដំណើរការ ៖

- សកម្មភាពប្រព័ន្ធគ្រប់គ្រងការបោះឆ្នោត (EMS), ប្រព័ន្ធរៀបចំការបោះឆ្នោត, ទម្រង់សន្លឹកឆ្នោត, និងការរចនាប្លង់របស់ក្រសួង នឹងមានទីតាំងស្ថិតនៅមជ្ឈមណ្ឌលទិន្នន័យដែលធានាសុវត្ថិភាពរបស់ខោនធី ។
- ការបម្រុងទុកសម្រាប់ទិន្នន័យនេះកើតឡើងដោយស្វ័យប្រវត្តិហើយត្រូវបានរៀបចំសម្រាប់ការដាក់ពង្រាយប្រសិនបើម៉ាស៊ីនមេមិនដំណើរការ ។
- ការផ្លាស់ប្តូរដែលបានធ្វើចំពោះទិន្នន័យអ្នកបោះឆ្នោត ប្រព័ន្ធរៀបចំការបោះឆ្នោតនិង EMS ត្រូវបានបម្រុងទុកតាមកាលវិភាគជាទៀងទាត់ ។

### បម្រុងទុកសំណុំឧបករណ៍របស់មណ្ឌលបោះឆ្នោត

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើបរិក្ខារណាមួយប្រែទៅជាមិនអាចប្រើប្រាស់បាន ៖

- ប្រសិនបើ មជ្ឈមណ្ឌលបោះឆ្នោតទទួលរងហេតុការណ៍ណាមួយដែលធ្វើឲ្យបរិក្ខារបច្ចុប្បន្នរបស់ខ្លួនមិនអាចប្រើបាន នោះក្រសួងមានបរិក្ខារបន្ថែមដែលអាចប្រើបាន ដូច្នេះហើយមជ្ឈមណ្ឌលបោះឆ្នោតអាចបន្តដើម្បីដំណើរការបោះឆ្នោត ។
- ប្រសិនបើមិនមានឧបករណ៍បន្ថែមទេ នោះមជ្ឈមណ្ឌលបោះឆ្នោតមានសមត្ថភាពប្រតិបត្តិការដោយប្រើដៃបាន ។

### បរិក្ខារដែលបាត់

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើមានបរិក្ខារណាមួយបាត់បង់ ៖

- ប្រសិនបើមណ្ឌលបោះឆ្នោតមួយបានបាត់បរិក្ខារ នោះអ្នកគ្រប់គ្រងមណ្ឌលបោះឆ្នោតនឹងជូនដំណឹងទៅកាន់ការិយាល័យគោលរបស់ ROV ។
- ការផ្គត់ផ្គង់ចេញពីរថយន្តដឹកទំនិញចល័ត ដែលរក្សាទុកបរិក្ខារបោះឆ្នោតបម្រុងនឹងត្រូវបានចាត់ចែងដោយបុគ្គលិកឃ្លាំង ។
- បុគ្គលិកឃ្លាំងយ៉ាងតិចពីររូបនឹងចែកចាយបរិក្ខារ និងគ្រឿងផ្គត់ផ្គង់ណាមួយចេញពីរថយន្តដឹកទំនិញចល័តទៅកាន់មណ្ឌលបោះឆ្នោតនេះ ដើម្បីធានាសន្តិសុខនៃការផ្គត់ផ្គង់ និងបរិក្ខារនៅមណ្ឌលបោះឆ្នោត ។

### បរិក្ខារផ្គត់ផ្គង់បម្រុងទុកសម្រាប់ការបោះឆ្នោត

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើបរិក្ខារផ្គត់ផ្គង់សម្រាប់ការបោះឆ្នោតណាមួយទៅជាប្រើមិនបាន ឬបានបាត់ ៖

- ហិបចម្លងតាមហិបដើមដែលត្រូវបានរៀបចំសម្រាប់បុគ្គលិកមណ្ឌលបោះឆ្នោតនឹងត្រូវបានរក្សាទុក ។
- អ្នកសម្របសម្រួលមណ្ឌលបោះឆ្នោតទទួលខុសត្រូវសម្រាប់ការរក្សាទុកបរិក្ខារផ្គត់ផ្គង់បម្រុងទុកសម្រាប់ការបោះឆ្នោតនេះ ។

- ក្នុងករណីដែលកន្លែងមួយចាំបាច់ត្រូវផ្លាស់ប្តូរទីតាំង ហើយបុគ្គលិកមិនអាចប្រមូលបរិក្ខារបច្ចុប្បន្នរបស់ពួកគេបាន នោះបរិក្ខារផ្គត់ផ្គង់បម្រុងនឹងត្រូវបញ្ជូនទៅកាន់កន្លែងថ្មី ប្រសិនបើអាចធ្វើបាន ។

## អវត្តមានបុគ្គលិកមណ្ឌលបោះឆ្នោត

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើ បុគ្គលិកមណ្ឌលបោះឆ្នោត មិនបានមកធ្វើការនៅក្នុងវេនដែលត្រូវបានកំណត់ទុករបស់ពួកគេ ៖

- អ្នកគ្រប់គ្រងមណ្ឌលបោះឆ្នោតនឹងទាក់ទងការិយាល័យ ROV ដើម្បីទទួលបានបុគ្គលិកជំនួសសម្រាប់មណ្ឌលបោះឆ្នោតនេះ ។
- បញ្ជីបុគ្គលិកបម្រុងដែលបានទទួលការបណ្តុះបណ្តាល នឹងត្រូវរក្សាទុក ដោយការិយាល័យគោលរបស់ ROV ។

## បុគ្គល ឬវត្ថុគួរឲ្យសង្ស័យ

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើ បុគ្គល ឬវត្ថុដែលគួរឲ្យសង្ស័យណាមួយលេចឡើង ៖

- អ្នកគ្រប់គ្រងមណ្ឌលបោះឆ្នោតនឹងទាក់ទងអាជ្ញាធរសន្តិសុខ ដោយអាស្រ័យទៅតាមស្ថានភាព ។

## ប្រព័ន្ធហាត្ថកម្ម

ដើម្បីទប់ស្កាត់ការបង្អាក់ណាមួយនៅក្នុងដំណើរការបោះឆ្នោត ប្រសិនបើ បរិក្ខារបោះឆ្នោតអេឡិចត្រូនិកប្រែទៅជាប្រើមិនបាន ៖

- គ្រប់មុខងារប្រើប្រាស់ទាំងអស់អាចដំណើរការបានតាមរយៈដំណើរការហាត្ថកម្ម ។

## ឧបសម្ព័ន្ធ O - ផែនការជាយថាភាព

គោលបំណងនៃផែនការជាយថាភាពគឺ ដើម្បីប្រកាសឲ្យដំណើរការអនុវត្តក្នុងអំឡុងពេលបោះឆ្នោតក្នុងករណីនៃភាពអាសន្ន ឬ ឧបទ្ទវហេតុផ្សេងៗដែលអាចរារាំងនាយកដ្ឋានមិនអាចឲ្យបម្រើដល់សាធារណជនបាននិង/ឬរៀបចំការបោះឆ្នោតបាន ។ ក្នុងអំឡុងករណីរដ្ឋមានភាពអាសន្ន មានតែអភិបាលរដ្ឋទេដែលអាចពន្យារភារកិច្ចរៀបចំការបោះឆ្នោតរបស់នាយកដ្ឋាន ។[1]

ផែនការទាំងនេះនឹងត្រូវប្រើរួមជាមួយនឹងផែនការសម្រាប់ភាពអាសន្ន និងផែនការសម្រាប់ការថែទាំនិងជម្រកស្នាក់នៅរបស់ខោនធី Santa Clara (ដែលស្ថិតនៅលើប្រព័ន្ធអ៊ីនត្រាណិតរបស់ខោនធី) និងផែនការមានភាពអាសន្នរបស់រដ្ឋលេខាធិការ (SOS) បាន ។

នាយកដ្ឋានវាស់វែងការឆ្លើយតបរបស់ខ្លួនចំពោះភាពអាសន្នបានទៅតាមកម្រិតនៃព្រឹត្តិការណ៍ដែលត្រូវបានបង្កើតឡើងដោយភាពអាសន្ន ។ ដូចមុនៗអញ្ចឹងដែរ ប្រសិនបើនិយោជិតម្នាក់បានដឹងពីស្ថានភាពមានអាសន្នដែលដឹកាអនុវត្តច្បាប់ ឬជំនួយផ្នែកវេជ្ជសាស្ត្រនោះ គាត់ត្រូវទូរសព្ទទៅលេខ 911 និងជូនដំណឹងទៅកាន់ប្រធានគ្រប់គ្រងតាមជាន់ ។

### សូមចងចាំថា សុវត្ថិភាពផ្ទាល់ខ្លួនមានសារៈសំខាន់ជាងឯកសារទាំងឡាយនៅក្នុងការិយាល័យទៅទៀត ។

### អ្វីត្រូវចាប់យកទៅជាមួយមុនគេ (ក្នុងករណីមានជំលៀសចេញ)

- ប្រសិនបើមានពេលធ្វើបែបនេះ ហើយបើធ្វើបែបហ្នឹងទៅមិនបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពផ្ទាល់ខ្លួនទេនោះ បុគ្គលិកអាចប្រមូលយក ឬ រក្សាឲ្យបាននូវរបស់ដូចខាងក្រោម ដែលរាយតាមលំដាប់លំដោយនៃភាពសំខាន់៖
    1. សន្លឹកឆ្នោត (សន្លឹកឆ្នោតដែលបានបោះរួចត្រូវយកមុន អ្វីៗផ្សេងទៀតត្រូវយកបន្ទាប់)
    2. សាច់ប្រាក់ និងមូលប្បទានប័ត្រ និងហិបសាច់ប្រាក់បន្តិចបន្តួច

### ការការពារនិងរក្សាឡើងវិញនូវអ្វីៗដែលសំខាន់ និងកំណត់ត្រាផ្សេងៗ (ក្នុងអំឡុងពេលអាសន្ន)

- របស់ខាងក្រោមត្រូវបានចាត់ទុកជាកំណត់ត្រាសំខាន់និងចាំបាច់ ហើយគប្បីត្រូវបានយកចេញពីអគារប្រសិនបើអាចធ្វើទៅបាន អាស្រ័យទៅលក្ខណៈនិងទំហំនៃភាពអាសន្ន ។
    1. សន្លឹកឆ្នោតបានរាប់ និង សន្លឹកឆ្នោតមិនបានរាប់
    2. ម៉ាស៊ីនបម្រើមេ
    3. ឧបករណ៍រក្សាទុកទិន្នន័យអេឡិចត្រូនិកដទៃទៀត
    4. បញ្ជីអ្នកបោះឆ្នោត
    5. សាច់ប្រាក់ និងមូលប្បទានប័ត្រនៅក្នុងហិបសាច់ប្រាក់បន្តិចបន្តួច

[1] GC§8571

## សន្តិសុខកុំព្យូទ័រ

- ប្រសិនបើមិនមានពេលបិទម៉ាស៊ីនកុំព្យូទ័រលើតុទេនោះ បុគ្គលិកគួរតែចាក់សោរម៉ាស៊ីនរបស់គេដោយប្រើ Ctrl+Alt+Delete ។
- មូលហេតុត្រូវធ្វើបែបនេះគឺ ងាយសង្កត់ប៊ូតុងបិទបើកតែម្តងអាចនឹងមិនគ្រប់គ្រាន់ដើម្បីផ្តាច់ការភ្ជាប់ហើយបិទវាទាំងស្រុងបាន ។
- ប្រសិនបើគ្មានចរន្តអគ្គិសនីទេ បុគ្គលិកគួរតែរងចាំស្តាប់ការណែនាំពីនាយកដ្ឋានសេវាកម្ម & ដំណោះស្រាយបច្ចេកវិទ្យា (TSS) អំពីវិធីប្រសើរបំផុត ដើម្បីដោះស្រាយជាមួយរឿងកុំព្យូទ័រ ។

## សន្លឹកឆ្នោតបានរាប់ និង សន្លឹកឆ្នោតមិនបានរាប់

- ជាទូទៅបើទោះជាបានរាប់ឬមិនបានរាប់ក៏ដោយ ក៏សន្លឹកឆ្នោតត្រូវបានរក្សាទុកនៅក្នុងមណ្ឌលទៅតាមមណ្ឌលរបស់វាដែរ ហើយត្រូវបានរក្សាវាទុកនៅក្នុងបន្ទប់សន្លឹកឆ្នោតដែលមានសន្តិសុខរហូតទាល់តែវារួចរាល់សម្រាប់យកទៅរក្សាទុកដាក់នៅកន្លែងចុងក្រោយ ។ ក្រោយពីសន្លឹកឆ្នោតត្រូវបានរាប់ វាត្រូវបានរក្សាទុកនៅទីតាំងដែលមានសន្តិសុខដាច់ដោយឡែកមួយ ។ សន្លឹកឆ្នោតដែលមិនទាន់ត្រូវបានរាប់ត្រូវបានចាត់ទៅតាមចំណាត់ថ្នាក់ និងរក្សាទុកទៅតាមស្ថានភាពរបស់វា៖
    1. សន្លឹកឆ្នោតនៅតែស្ថិតនៅក្នុងស្រោមសំបុត្រ ដោយមិនត្រូវបានរក្សាទុក និងមិនទាន់ត្រូវបានពិនិត្យហត្ថលេខានៅឡើយ
    2. សន្លឹកឆ្នោតនៅតែស្ថិតក្នុងស្រោមសំបុត្រ ត្រូវបានរៀបទៅតាមមណ្ឌល ហត្ថលេខាត្រូវបានពិនិត្យ
    3. សន្លឹកឆ្នោតស្ថិតនៅក្រៅស្រោមសំបុត្រហើយស្ថិតនៅក្នុងហិបទៅតាមលេខមណ្ឌល
- **<u>សម្គាល់</u>៖** សន្លឹកឆ្នោតអាចត្រូវស្ថិតនៅបណ្តោះអាសន្នក្នុងស្ថានីយ៍ការងារ ដើម្បីធ្វើការពិនិត្យហត្ថលេខាឬនៅក្នុងបន្ទប់ពិនិត្យសន្លឹកឆ្នោត ។
- ប្រសិនបើភាពអាសន្នកើតឡើងដែលតម្រូវឲ្យបុគ្គលិកត្រូវយកសន្លឹកឆ្នោតចេញពីអគារនោះ បុគ្គលិកត្រូវបិទហិបឆ្នោតនិងស្កុតឬធុង ហើយយកវាចេញទៅកាន់ទីតាំងថ្មី ។
- ប្រសិនបើវាមិនអាចត្រូវបានយកចេញពីអគារបានទេនោះ សន្លឹកឆ្នោតនឹងត្រូវរក្សាទុកនៅក្នុងបន្ទប់ដែលមានសន្តិសុខមួយ ។
- សន្លឹកឆ្នោតមិនទាន់ប្រើ សន្លឹកឆ្នោតមិនត្រូវបានចេញ គួរតែរក្សាទុកសិនប្រសិនបើគ្មានពេលយកវាចេញទេនោះ។ ប្រសិនបើមានពេល ROV ឬអ្នកដែលទទួលការចាត់តាំងនឹងប្រាប់ទៅបុគ្គលិកពីអ្វីត្រូវធ្វើចំពោះសន្លឹកឆ្នោតមិនទាន់ប្រើ មិនទាន់ត្រូវបានចេញនោះ ។

## ការរំខានចំពោះការធ្វើបច្ចុប្បន្នភាពប្រវត្តិព័ត៌មានអ្នកបោះឆ្នោត ឬដាច់បណ្តាញ

- ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅការិយាល័យកណ្តាលរបស់ ROV ។
- ប្រសិនបើភាពរអាក់រអួលកើតមានតែនៅមណ្ឌលបោះឆ្នោតណាមួយជាក់លាក់ ហើយមានរយៈពេលយូរជាង 30 នាទី ឬក៏ចំនួនម៉ោងច្រើនលើសលប់អាស្រ័យលើវត្តមានអ្នកបោះឆ្នោតនោះ អ្នកបោះឆ្នោត

នឹងត្រូវបានណែនាំឲ្យទៅកាន់មណ្ឌលបោះឆ្នោតមួយផ្សេងទៀត ឬផ្តល់ជម្រើសឲ្យទៅបោះឆ្នោតបណ្តោះអាសន្នបាន ។

- ប្រសិនបើភាពរអាក់រអួលកើតឡើងនៅទូទាំងខោនធីនោះ បុគ្គលិកមណ្ឌលបោះឆ្នោតអាចចេញសន្លឹកឆ្នោតបណ្តោះអាសន្នបានតាមរយៈឧបករណ៍បោះឆ្នោតអេឡិចត្រូនិក ប្រសិនបើអាចនៅក្នុងស្រោមសំបុត្របណ្តោះអាសន្ន ប្រសិនបើបុគ្គលិកអាចកំណត់ប្រភេទសន្លឹកឆ្នោតត្រឹមត្រូវបាន ឬក៏មណ្ឌលសម្រាប់អ្នកបោះឆ្នោតបាន ។
- សូមទុកដាក់ក្រដាសកំណត់ត្រារបស់អ្នកបោះឆ្នោតទាំងអស់និងព័ត៌មាន ដើម្បីបញ្ចូលទៅក្នុង EIMS នៅពេលប្រព័ន្ធចាប់ដំណើរការឡើងវិញភ្លាម ។
- ផ្នែកប្រព័ន្ធបោះឆ្នោតនឹងទាក់ទងទៅកាន់ក្រុមហ៊ុនផ្គត់ផ្គង់ទាំងឡាយភ្លាម ហើយដោះស្រាយបញ្ហាឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។

## ការដាច់ចរន្តអគ្គិសនី

- ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅការិយាល័យកណ្តាលរបស់ ROV ។
- ប្រសិនបើដាច់ចរន្តអគ្គិសនីលើសពី 15 នាទី អ្នកបោះឆ្នោតនឹងត្រូវណែនាំឲ្យទៅកាន់មណ្ឌលបោះឆ្នោតមួយផ្សេងទៀត ។
- សាធារណជននឹងត្រូវបានជូនដំណឹងតាមគេហទំព័រ សារតាមទូរសព្ទ សារព័ត៌មាន វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។

## អាកាសធាតុអាក្រក់ខ្លាំង

- ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅការិយាល័យកណ្តាលរបស់ ROV ។
- ប្រសិនបើមណ្ឌលបោះឆ្នោតមិនអាចទាក់ទងបាន ឬ មិនមានសុវត្ថិភាពដោយសារតែអាកាសធាតុនោះ មណ្ឌលបោះឆ្នោតបម្រុងនឹងត្រូវទាក់ទង ហើយនឹងត្រូវរៀបចំតម្លើងដើម្បីដំណើរការភ្លាមៗ ។
- សាធារណជននឹងត្រូវបានជូនដំណឹងតាមគេហទំព័រ សារតាមទូរសព្ទ សារព័ត៌មាន វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។

## អគ្គិភ័យ ឬមហន្តរាយផ្សេងទៀត

- បុគ្គលិកទាំងអស់និងអ្នកបោះឆ្នោតជាដំបូងត្រូវតែបានជំលៀសចេញដោយសុវត្ថិភាព ។
- ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅការិយាល័យកណ្តាលរបស់ ROV ។
- ប្រសិនបើមានពេល បុគ្គលិកមណ្ឌលបោះឆ្នោតនឹងអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖
    1. សូមយកសន្លឹកឆ្នោតដែលបានបោះរួចដោយសុវត្ថិភាពចេញពីកន្លែងនោះ (សន្លឹកឆ្នោតបោះតាមសំបុត្រ បន្ទះចងចាំសម្រាប់គ្រឿងបរិក្ខារ សន្លឹកឆ្នោតក្រដាសចេញពីហិបឆ្នោតពណ៌ខ្មៅ និងសន្លឹកឆ្នោតសម្រាប់អ្នកចុះឈ្មោះមានលក្ខខណ្ឌ)
    2. រក្សាសន្តិសុខ/បិទដំណើរការកុំព្យូទ័រប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោត (EIMS) របស់គេ
    3. រក្សាសន្តិសុខ/បិទគ្រឿងបរិក្ខារបោះឆ្នោតទាំងអស់
    4. យកកុំព្យូទ័រ/គ្រឿងបរិក្ខារដែលមាន ប្រសិនបើអាចធ្វើបាន

- ការិយាល័យកណ្តាលរបស់ ROV នឹងជូនដំណឹងដល់សាធារណជនតាមគេហទំព័រ សារជាសម្លេងតាមទូរសព្ទ សារព័ត៌មាន វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។ និងផ្តល់ព័ត៌មានដល់សាធារណជនពីមណ្ឌលបោះឆ្នោតដែលគេអាចបោះបាន ។
- មណ្ឌលបោះឆ្នោតជំនួស នឹងត្រូវបានរៀបចំភ្លាមៗតាមដែលអាចធ្វើទៅបាន ។

## ការមិនដំណើរការគ្រឿងបរិក្ខារបោះឆ្នោត

- ក្នុងខណៈដែលប្រធានមណ្ឌលបោះឆ្នោតដោះស្រាយបញ្ហាបាន សន្លឹកឆ្នោតក្រដាសអាចត្រូវបានចេញឲ្យទៅអ្នកបោះឆ្នោតបាន ។
- ប្រធានមណ្ឌលបោះឆ្នោតនឹងអនុវត្តទៅតាមសេចក្តីណែនាំស្តីពីដំណោះស្រាយបញ្ហាដែលត្រូវបានផ្តល់នៅក្នុងសៀវភៅណែនាំពីមណ្ឌលបោះឆ្នោត ។
- ប្រសិនបើមិនអាចដោះស្រាយបានទេ ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅកាន់ការិយាល័យកណ្តាលរបស់ ROV ។
- ROV នឹងចាត់វិធានការតាមជំហានសមស្របដូចជាធ្វើការបញ្ជូនជំនួយបច្ចេកទេសទៅដល់គោលដៅ ឬបញ្ជូនគ្រឿងបរិក្ខារជំនួសថ្មី ។

## ម៉ាស៊ីនបញ្ជូនសន្លឹកឆ្នោតឈប់ដំណើរការ

- ប្រធានមណ្ឌលបោះឆ្នោតនឹងអនុវត្តទៅតាមសេចក្តីណែនាំពីការដោះស្រាយបញ្ហាដូចដែលបានផ្តល់ជូននៅក្នុងសៀវភៅណែនាំពីមណ្ឌលបោះឆ្នោតសម្រាប់សម្រាប់បុគ្គលិក ។
- ប្រសិនបើមិនអាចដោះស្រាយបានទេ ប្រធានមណ្ឌលបោះឆ្នោតនឹងទាក់ទងទៅកាន់ការិយាល័យកណ្តាលរបស់ ROV ដើម្បីសម្របសម្រួលការបញ្ជូនម៉ាស៊ីនបញ្ជូនសន្លឹកឆ្នោតពីគ្រឿងបរិក្ខារបោះឆ្នោតដែលបានបម្រុងទុក ។
- ប្រសិនបើម៉ាស៊ីនបញ្ជូនសន្លឹកឆ្នោតនៅតែមិនដំណើរការ ឧបករណ៍គូសន្លឹកឆ្នោតនឹងត្រូវប្រើនៅមណ្ឌលបោះឆ្នោត ។
- ប្រសិនបើមានការដាច់ភ្លើងកើតឡើងនៅតាមមណ្ឌលបោះឆ្នោត ម៉ាស៊ីនភ្លើងនឹងត្រូវប្រើដើម្បីការពារកុំមានភាពរអាក់រអួលនៅក្នុងដំណើរការបោះឆ្នោត ។
- ប្រសិនបើការដាច់ភ្លើងនៅតែបន្តកើតឡើងនៅក្រោយការប្រើម៉ាស៊ីនភ្លើងនោះ សន្លឹកឆ្នោតដែលបានព្រីនបម្រុងនោះ នឹងត្រូវចេញទៅឲ្យអ្នកបោះឆ្នោត ។
- ប្រសិនបើសន្លឹកឆ្នោតព្រីនបម្រុងទុកអស់ ROV នឹងទទួលយកសន្លឹកឆ្នោតដែលសរសេរដោយដៃដោយផ្អែកទៅលើសន្លឹកឆ្នោតបម្រុងចុងក្រោយ ។

### បរាជ័យក្នុងការភ្ជាប់អ៊ីនធឺណិត

- ប្រធានមណ្ឌលបោះឆ្នោតនឹងអនុវត្តទៅតាមសេចក្តីណែនាំស្តីពីដំណោះស្រាយបញ្ហាដែលត្រូវបានផ្តល់នៅក្នុងសៀវភៅណែនាំពីមណ្ឌលបោះឆ្នោតសម្រាប់បុគ្គលិក ។
    - ប្រសិនបើមិនអាចដោះស្រាយបានទេ ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវទាក់ទងទៅកាន់ការិយាល័យកណ្តាលរបស់ ROV ។
    - ROV នឹងចាត់វិធានការទៅតាមជំហានសមស្រប ដូចជាធ្វើការទាក់ទងទៅកាន់សេវាព័ត៌មានខោនធី ឬ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតដើម្បីទទួលបានសេវាគាំទ្រអតិថិជន ។
- ប្រសិនបើការដាច់អ៊ីនធឺណិតមានរយៈពេលយូរជាង 15 នាទីនោះ បុគ្គលិកមណ្ឌលបោះឆ្នោតអាចចេញសន្លឹកឆ្នោតបណ្តោះអាសន្នបានតាមរយៈឧបករណ៍បោះឆ្នោតអេឡិចត្រូនិកប្រសិនបើអាច ក្នុងស្រោមសំបុត្របណ្តោះអាសន្ន ។
- បុគ្គលិកមណ្ឌលបោះឆ្នោតនឹងទុកដាក់ក្រដាសកំណត់ត្រារបស់អ្នកបោះឆ្នោតទាំងអស់ និងព័ត៌មានសម្រាប់បុគ្គលិកបោះឆ្នោត ដើម្បីបញ្ចូលទៅក្នុង EIMS នៅការិយាល័យកណ្តាលរបស់ ROV ។
- ប្រសិនបើការដាច់អ៊ីនធឺណិតយូរជាងមួយម៉ោង ឬចំនួនម៉ោងច្រើនលើសលប់អាស្រ័យលើវត្តមានអ្នកបោះឆ្នោតនោះ អ្នកបោះឆ្នោតនឹងត្រូវបានណែនាំឲ្យទៅកាន់មណ្ឌលបោះឆ្នោតមួយផ្សេងទៀត ។ សាធារណជននឹងត្រូវបានជូនដំណឹងតាមគេហទំព័រ ROV សារតាមទូរសព្ទ សារព័ត៌មាន វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។

### មណ្ឌលបោះឆ្នោតមិនអាចប្រើបាន

- ប្រសិនបើមណ្ឌលបោះឆ្នោតមិនអាចប្រើបានដោយហេតុផលណាមួយនោះ ប្រធានមណ្ឌលបោះឆ្នោតនឹងត្រូវជូនដំណឹងទៅកាន់ការិយាល័យកណ្តាលរបស់ ROV ។
- បញ្ជីឈ្មោះមណ្ឌលបោះឆ្នោតបម្រុងនឹងត្រូវរក្សាដោយការិយាល័យកណ្តាលរបស់ ROV ។
- បុគ្គលិកកាន់ឃ្លាំងនឹងជួយដល់បុគ្គលិកមណ្ឌលបោះឆ្នោតក្នុងការប្តូរ និងរៀបចំមណ្ឌលបោះឆ្នោតថ្មី ។
- សាធារណជននឹងត្រូវបានជូនដំណឹងពីការផ្លាស់ប្តូរតាមគេហទំព័រ ROV សារតាមទូរសព្ទ សារព័ត៌មាន វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។

### មណ្ឌលបោះឆ្នោតបម្រុង

- ROV អាចនឹងចាត់មណ្ឌលបោះឆ្នោតជំនួសថ្មីយឺតនៅថ្ងៃបោះឆ្នោត ។
- មណ្ឌលបោះឆ្នោតថ្មីត្រូវតែស្ថិតនៅជិតមណ្ឌលបោះឆ្នោតដើមឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ហើយសេចក្តីជូនដំណឹងនឹងត្រូវបិទប្រកាសនៅតាមមណ្ឌលធ្វើការបង្ហាញអ្នកបោះឆ្នោតទៅកាន់ទីតាំងថ្មី ។

### លើកកម្ពស់សន្តិសុខ (ការរំពឹកកម្រិត #1)

ក្នុងករណីវិធានការសន្តិសុខដែលត្រូវលើកកម្ពស់ដូចត្រូវបានកំណត់ដោយ ROV ឬ ការអនុវត្ត ច្បាប់ នៅពេលសមស្រប ROV អាចស្នើសុំការអនុញ្ញាតទៅកាន់ការិយាល័យប្រធានសេវាពេលអាសន្នដើម្បីៈ

- អ្នកបោះឆ្នោតចូលនិងចេញពីអគារបោះឆ្នោតដើម្បីបោះឆ្នោត
- បុគ្គលិកបន្តរាប់សន្លឹកឆ្នោត ឬ
- សាធារណជនចូលទៅបំពេញការងារអាជីវកម្មជាប្រក្រតី

### ជំលៀសសាធារណជន និងបុគ្គលិក (ការរំពឹកកម្រិត #2)

វិធានការដូចខាងក្រោមអាចត្រូវបានអនុវត្តដោយបុគ្គលិកចាត់តាំងសម្រាប់ការជំលៀសបន្ថែមទៅលើវិធានសន្តិសុខស្តង់ដារនិងដែលត្រូវលើកកម្ពស់ដូចបានពិភាក្សាខាងលើៈ

- ផ្តល់ព័ត៌មានដល់សាធារណជនឲ្យជំលៀសភ្លាមៗដោយភាពស្ងប់ស្ងាត់ទៅតាមច្រកចេញដែលជិតបំផុតប្រសិនបើសម្លេងកណ្តឹងរោទ៍ឡើង ។
- ជួយដល់សមាជិកសាធារណជនទាំងអស់ រាប់បញ្ចូលទាំងអ្នកដែលមានពិការភាព ឬដែលត្រូវការជំនួយក្នុងការជំលៀស ។
- ចាក់សោរទ្វារនិងរក្សាសន្តិសុខកំណត់ត្រាសំខាន់ៗនិងសន្លឹកឆ្នោត ។
- ដើរឆ្ពោះទៅកាន់ទីជួបជុំដែលបានកំណត់ហើយនៅជុំគ្នាទីនោះ ។
- ROV នឹងអនុញ្ញាតទៅលើទីតាំងជម្រើសថ្មី ។
- បង្ហោះសារពីភាពអាសន្នតាមសារជាសម្លេងតាមទូរសព្ទ និងនៅលើអគារ ។
- បញ្ជូនបន្តប្រព័ន្ធទូរសព្ទរបស់នាយកដ្ឋានទៅកាន់ទីតាំងជម្រើសថ្មី ប្រសិនបើអាចធ្វើបាន ។
- ផ្តល់ព័ត៌មានទៅកាន់បុគ្គលិក ដែលមិនស្ថិតនៅក្នុងអគារ តាមទូរសព្ទដៃពីស្ថានភាពអគារ ។
- និយោជិតដែលត្រូវបានចាត់តាំងមុននឹងពិនិត្យនៅតាមជាន់នីមួយៗហើយបិទទ្វារក្រោយចាកចេញ ។

### ការជំលៀសចេញនៅថ្ងៃបោះឆ្នោត

នៅក្នុងករណីដែលការជំលៀសត្រូវបានធ្វើឡើងដោយនាយកដ្ឋាននៅថ្ងៃបោះឆ្នោតនោះ ជំហានដូចខាងក្រោមត្រូវបានអនុវត្តបន្ថែមទៅលើជំហានទាំងឡាយដែលបានលើកឡើងខាងលើៈ

- បញ្ចប់ដំណើរការសន្លឹកឆ្នោតភ្លាម ហើយរក្សាទុកសន្លឹកឆ្នោតនិងគ្រឿងបរិក្ខាររៀបចំបញ្ជីដោយចាក់សោរទ្វារចូលទៅកាន់បន្ទប់សន្លឹកឆ្នោតនិងបន្ទប់រាប់សន្លឹកឆ្នោត ។ រៀបសន្លឹកឆ្នោតដែលមិនត្រូវបានរាប់ដែលត្រូវបានរក្សាទុករួចហើយនៅក្នុងបន្ទប់ដែលមានសុវត្ថិភាព ។
- សន្លឹកឆ្នោតនៅតាមស្ថានីយ៍ការងារសម្រាប់ការពិនិត្យហត្ថលេខានឹងត្រូវដាក់នៅក្នុងបន្ទប់សន្លឹកឆ្នោតដែលមានសុវត្ថិភាព ។
- សន្លឹកឆ្នោតដែលទើបទទួលបាន ប៉ុន្តែមិនត្រូវបានរៀបនិងបែងចែកនៅឡើយ ដែលត្រូវបានរក្សាទុកនៅក្នុងបន្ទប់ដាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាព ។
- ផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតទៅតាមលក្ខណៈដែលសមស្របបំផុតសម្រាប់ករណីអាសន្ន ពីទីតាំងកន្លែងជម្រើសថ្មីដែលការបោះឆ្នោតនឹងធ្វើឡើងប្រសិនបើមាន ។
- បិទផ្សាយនៅលើអគារពីទីតាំងហិបទម្លាក់សន្លឹកឆ្នោតដែលមាននៅពាសពេញខោនធី ។

## ភាពអាសន្នប៉ះពាល់ដល់មណ្ឌលបោះឆ្នោតមួយឬច្រើន

ក្នុងករណីដែលភាពអាសន្នប៉ះពាល់ដល់មណ្ឌលបោះឆ្នោតមួយឬច្រើន ការប្តូរទីតាំងនិង/ឬការរួមបញ្ចូលគ្នានៃមណ្ឌលបោះឆ្នោតអាចតម្រូវឲ្យធ្វើ។ ស្ថិតក្នុងកាលៈទេសៈដូចនេះ នីតិវិធីដូចខាងក្រោមត្រូវតែអង្កេតដោយមន្ត្រីបោះឆ្នោត ។

- បិទស្លាកសញ្ញាណែនាំដល់អ្នកបោះឆ្នោតពីការប្តូរទីតាំងដោយនាំពួកគេទៅកាន់កន្លែងនិងហិបទម្លាក់សន្លឹកឆ្នោតថ្មី ។
- ប្រមូលយកសន្លឹកឆ្នោតដែលបានបោះទាំងអស់ ហើយរក្សាទុកវានៅក្នុងស្បោងដែលអាចបិទភ្ជិតបាន ប្រសិនបើអាចធ្វើបាន ។
- ប្រមូលយកហិបឆ្នោត សន្លឹកឆ្នោតដែលមិនបានបោះ ហើយនិងតារាងឈ្មោះអ្នកបោះឆ្នោត ហើយដឹកជញ្ជូនវាទៅកាន់ទីតាំងថ្មី ។
- យ៉ាងហោចណាស់ក៏មានមន្ត្រីបោះឆ្នោតពីរនាក់ ឬ អ្នកត្រួតពិនិត្យ ត្រូវស្ថិតនៅជាមួយនឹងសន្លឹកឆ្នោតពីមណ្ឌលបោះឆ្នោតនីមួយៗនៅគ្រប់ពេលនិងតាមដានឲ្យដឹងថាសន្លឹកឆ្នោតត្រូវបានបញ្ជូនដោយសុវត្ថិភាព ទៅកាន់ទីតាំងមណ្ឌលបោះឆ្នោតថ្មី ។
- ប្រសិនបើអាច នាយកដ្ឋាននឹងបញ្ជូនខ្សែចងបិទថ្មីទៅតាមតម្រូវការ ។

## ភាពបន្ទាន់ប៉ះពាល់ដល់ខ្សែប្រមូល ឬបុគ្គលិកឈរជើងនៅតាមទីតាំង ។

ក្នុងករណីមានភាពអាសន្នកើតឡើង ដែលជះឥទ្ធិពលលើមធ្យោបាយប្រមូលសន្លឹកឆ្នោត ឬលើបុគ្គលិកនៅតាមកន្លែងការងារនោះ បុគ្គលិកនាយកដ្ឋាននឹងជូនដំណឹងទៅកាន់មន្ត្រីបោះឆ្នោតដែលកំពុងស្ថិតនៅជាមួយនឹងស្ថានភាពទីតាំង ។

## ការអោយអំណាច

ក្នុងករណីមានភាពអាសន្ននោះ មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការប្រតិបត្តិការនាយកដ្ឋាន ។ ប្រសិនបើ ROV មិនមានវត្តមានដើម្បីសម្រេចចិត្តបានទេ អំណាចទាំងស្រុងត្រូវផ្ទេរទៅកាន់ជំនួយការមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROVs) ។ ប្រសិនបើអ្នកទាំងពីរមិនមានវត្តមានអាចធ្វើការសម្រេចចិត្តបានទេនោះ អំណាចត្រូវផ្ទេរទៅកាន់បុគ្គលិកខ្ពស់បំផុតដែលមានវត្តមាន ។

នៅពេលស្ថិតនៅកន្លែងដែលសុវត្ថិភាព ROV និងបុគ្គលិកដែលត្រូវបានចាត់តាំងរបស់គាត់ត្រូវជួបគ្នាដើម្បីធ្វើការវាយតម្លៃពីផលប៉ះពាល់ ប្រសិនបើអាច ត្រូវចាប់ផ្តើមដំណើរការប្រព័ន្ធឡើងវិញ និងកំណត់ថាតើប្រតិបត្តិការមួយណាដែលគួរ ឬមិនអាចបន្តបានដោយផ្អែកទៅលើលក្ខណៈនៃភាពអាសន្ន ។ លទ្ធផលនៃកិច្ចប្រជុំនេះនឹងត្រូវបញ្ជូនបន្តទៅកាន់បុគ្គលិកតាមទូរសព្ទដៃនិងលេខទូរសព្ទផ្ទះ ។

## ការប្រាស្រ័យទាក់ទងក្នុងអំឡុងពេលនិងក្រោយភាពអាសន្ន

ជាទូទៅ ប្រធាននាយកដ្ឋាននឹងប្រកាសទាក់ទងនឹងការចាប់ផ្តើមនៃការជំលៀស ។ បុគ្គលិកការិយាល័យទាំងអស់និងសមាជិកទាំងឡាយនៃសាធារណជន នឹងត្រូវបានណែនាំពីច្រកចេញដែលត្រូវប្រើដោយអារម្មណ៍ស្ងប់ស្ងាត់ទៅតាមការបញ្ជា និងកន្លែងត្រូវជួបជុំទៅតាមពិធីជំលៀស ។

នាយកដ្ឋាននឹងប្រើវិធីសាស្ត្រទំនាក់ទំនងដូចខាងក្រោម ជាមួយនឹងនិយោជិតក្នុងអំឡុងពេល និងក្រោយភាពអាសន្ន៖

- ទូរសព្ទដៃ
- សារជាសម្លេងតាមទូរសព្ទរបស់នាយកដ្ឋាន
- ការផ្ញើសារ
- ទូរសព្ទផ្ទះ

មន្ត្រីសន្តិសុខនឹងអនុវត្តតួនាទីដោយហៅនៅតាមកន្លែងជំលៀសបន្ទាប់ពីបោសសំអាតអគាររួច ។ នៅពេលដែលនិយោជិតទាំងអស់ត្រូវបានចាត់ចូលនោះ អាជ្ញាធរទាំងឡាយដែលកំពុងស្ថិតនៅនឹងកន្លែងធ្វើការជូនដំណឹង ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសមាជិកក្រុមនិងមិនត្រូវបានរាប់បញ្ចូលនៅក្នុងអំឡុងពេលហៅទូរសព្ទទេនោះ ត្រូវជូនដំណឹងទៅអាជ្ញាធរភ្លាមៗ ។ សុវត្ថិភាពអ្នកសម្របសម្រួលឬការគ្រប់គ្រង នឹងប្រាប់ទៅបុគ្គលិកពីស្ថានភាពនិងលទ្ធភាពដែលអាចបញ្ចូលឡើងវិញបាន ។

### សារដែលបានថតទុកមុន

ខ្លឹមសារនៃសារពីភាពអាសន្ន ដោយផ្អែកទៅលើលក្ខណៈនៃភាពអាសន្ន ។ ប្រធានគ្រប់គ្រងសេវារដ្ឋបាលសេវាទទួលខុសត្រូវដើម្បីធានាថាជាសារថ្មី ដើម្បីឲ្យសាធារណជនទទួលបានការជូនដំណឹងតាមរយៈសារដែលបញ្ជូនចេញស្តីពីទីតាំងបោះឆ្នោតថ្មីប្រសិនបើភាពអាសន្នកើតឡើងនៅថ្ងៃបោះឆ្នោតនោះ ។

### ការសាកល្បង/ការតម្រង់ទិសបុគ្គលិកថ្មី

និយោជិតថ្មីត្រូវបានជូនដំណឹងពីខ្លឹមសារនៃគោលនយោបាយនេះដោយប្រធានរបស់គេ ។ បុគ្គលិកទាំងអស់នឹងស៊ាំទៅនឹងកន្លែងជួបជុំគ្នា ។ នាយកដ្ឋាននឹងរៀបចំការសាកល្បងតាមពេលវេលាផ្សេងៗនៅក្នុងវដ្តបោះឆ្នោតដើម្បីឲ្យបុគ្គលិកទាំងអស់អាចស៊ាំទៅនឹងផែនការភាពអាសន្នរបស់នាយកដ្ឋាន ។

### យុទ្ធសាស្ត្របណ្តុះបណ្តាលសម្រាប់បុគ្គលិកនាយកដ្ឋាន

នាយកដ្ឋានរក្សាទុកសំណុំឯកសារដែលមានដាក់បញ្ចូលនូវព័ត៌មានស្តីពីសុវត្ថិភាពជាមូលដ្ឋាននិងភាពមានអាសន្ន ព្រមទាំងច្បាប់ថតចម្លងនៃផែនការនេះមួយច្បាប់ ។ បន្ថែមលើនេះទៀត ការត្រៀមលក្ខណៈសម្រាប់ភាពអាសន្នប្រចាំត្រីមាស និងកិច្ចប្រជុំពីនីតិវិធី និងត្រូវធ្វើការសាកល្បងដោយផ្ទាល់យូរៗម្តង ។

គោលការណ៍ណែនាំនេះនឹងត្រូវពិនិត្យវាយតម្លៃឡើងវិញនិងធ្វើបច្ចុប្បន្នភាពនៅមុនការបោះឆ្នោតនីមួយៗ ។ គោលការណ៍ណែនាំចុងក្រោយគួរតែត្រូវបញ្ចប់ក្នុងរយៈពេល 120 ថ្ងៃនៅមុនថ្ងៃបោះឆ្នោត ។

# ឧបសម្ព័ន្ធ P – គំនូសបំព្រាងមណ្ឌលបោះឆ្នោតដែលបានស្នើឡើង



June 2018 Election County Outreach Events

| **Date: Jan-18** | **Events** |
|---|---|
| 1/14/2018 | Mankar San Kranti |
| 1/15/2018 | MLK Luncheon |
| 1/20/2018 | Womens March |
| 1/21/2018 | St. Marks Episcopal Church |
| Feb-18 | |
| **Date: Feb-18** | **Events** |
| 2/2/2018 | Buena Vista Community Meeting |
| 2/2/2018 | African American Flag raising Ceremony |
| 2/8/2018 | State of the City |
| 2/11/2018 | Lunar New Year Celebration |
| 2/16/2018 | TET Festival |
| 2/17/2018 | TET Festival |
| 2/18/2018 | TET Festival |
| 2/21/2018 | District 3 Community Leadership |
| 2/22/2018 | Business Mixer |
| 2/23/2018 | Winter Walk Oakridge Mall |
| 2/24/2018 | Go Red Heart |
| 2/24/2018 | Vietnamese New Year |
| 2/25/2018 | BWNC Chinese New Yar |
| 2/27/2018 | KACS Staff Meeting |
| Mar-18 | |
| **Date: Mar-18** | **Events** |
| 3/2/2018 | Silcon Valley Korean Federation Meeting |
| 3/3/2018 | Silicon Valley School and Camp Fair |
| 3/8/2018 | H Mart Grand Opening |
| 3/9/2018 | Neighborhood Nights Camden |
| 3/9/2018 | Neighborhood Nights Bascom |
| 3/10/2018 | Hispanic Chamber Summit |
| 3/10/2018 | Mexica New Year |
| 3/11/2018 | Venture Christian Church Service |
| 3/11/2018 | Mexica New Year |
| 3/17/2018 | Rana Holi Festival |
| 3/18/2018 | New Community Baptist Church |
| 3/20/2018 | Silicon Valley Korean Federation Meeting |
| 3/21/2018 | Celebrate Norouz Persian New Year |
| 3/22/2018 | USCIS |
| 3/23/2018 | Unity Dinner- Indo American Community Federation |
| 3/24/2018 | Easter Egg Hunt |
| 3/24/2018 | Kennedy 50th Anniversary |
| 3/26/2018 | Pathway to Citizenship Resource Fair |
| 3/31/2018 | Easter Egg Hunt |
| 3/31/2018 | Sizdeh Bedar |
| Apr-18 | |
| **Date: Apr-18** | **Events** |
| 4/1/2018 | Sizdeh Bedar |

| | |
|---|---|
| 4/7/2018 | Bay Area Kids Book Fair |
| 4/7/2018 | 15th Annual Cesar Chavez |
| 4/8/2018 | Cupertino- HOLI Festival |
| 4/13/2018 | West Valley Senior Walk |
| 4/13/2018 | Neighborhood Nights Almaden |
| 4/13/2018 | Neighborhood Nights Bascom |
| 4/13/2018 | Neighborhood Nights Willow Glen |
| 4/15/2018 | New Vision Church |
| 4/21/2018 | Nakland Resource Fair |
| 4/21/2018 | 9th International Childrens Festival |
| 4/21/2018 | Citizenship Day |
| 4/21/2018 | Curpertino Earth & Arbor Day |
| 4/22/2018 | Sofa Festival |
| 4/24/2018 | USCIS |
| 4/26/2018 | Bridges to Action |
| 4/26/2018 | FilAM Chamber Business Mixer |
| 4/26/2018 | YWCA Stand Against Racism |
| 4/28/2018 | Education 4 Liberation |
| 4/28/2018 | Cherry Blossom Festival |
| 4/28/2018 | Community Resource Fair |
| 4/28/2018 | MACLA Family Art Day |
| 4/29/2018 | Festival Del Nino |
| 4/29/2018 | Kidney Action Day |
| 4/29/2018 | Cherry Blossom Festival |
| 4/22/2018 | New Hope Church |
| May-18 | |
| **Date: May-18** | **Events** |
| 5/1/2018 | May Day |
| 5/4/2018 | Buena Vista Meet and Greet |
| 5/5/2018 | Korean Parent Apprecian Day |
| 5/5/2018 | Alviso Cinco De Mayo Festival |
| 5/6/2018 | Mac Down |
| 5/11/2018 | Neighborhood Nights South Side |
| 5/11/2018 | Neighborhood Nights Camden |
| 5/12/2018 | Berryessa Art & Wine Festival |
| 5/18/2018 | SJ Job Corps |
| 5/20/2018 | Hakone Matsuri |
| 5/22/2018 | Mountain View Senior Resource Fair |
| 5/24/2018 | USCIS |
| 5/26/2018 | Mushroom Mardi Gras |
| 5/27/2018 | Mushroom Mardi Gras |
| 5/6/2018 | Philippine Consulate Outreach |
| 5/6/2018 | Emmanuel Presbyterian Church |
| 5/8/2018 | Gubernatorial Debate Wath Party |
| 5/11/2018 | SARC Legislative Luncheon |
| 5/11/2018 | Neighborhood Nights Almaden |
| 5/5/2018 | Cupertino Volunteer Fair |

| | |
|---|---|
| 5/6/2018 | Silicon Valley Bikes Festival |
| 5/20/2018 | Campbell Boogie Festival |
| 5/20/2018 | Punjabi Mela |
| **Date: Jun-18** | **Events** |
| 6/3/2018 | Sunnyvale Art & Wine Festival |
| 6/8/2018 | Senior Health Fair |
| 6/9/2018 | Dia de Portugal Festival |
| 6/9/2018 | Project Hope Spring Fling |
| 6/14/2018 | USCIS |
| 6/15/2018 | World Refugee Day |
| 6/16/2018 | Juneteenth |
| 6/16/2018 | Alzheimers Forum |
| 6/23/2018 | Blossom Festival |
| 6/25/2018 | Korean Flag Raising Ceremony |
| 6/27/2018 | Viva Parks Hellyer Park |
| 6/29/2018 | Naturalization Ceremony |
| 6/16/2018 | Vasona Concert-Naked Booleggers |
| 6/23/2018 | Fountain Blues Festival |
| Jul-18 | |
| **Date: July-18** | **Events** |
| 7/2/2018 | Viva Parks AbornSan Kranti |
| 7/3/2018 | Viva parks Mt Pleasant |
| 7/11/2018 | Sunnyvale Concert |
| 7/12/2018 | Viva Parks Mayfair |
| 7/13/2018 | Neighborhood Nights Bascom |
| 7/14/2018 | Los Altos Art & Wine Festival |
| 7/15/2018 | Los Altos Art & Wine Festival |
| 7/18/2018 | Viva Parks McLaughlin |
| 7/18/2018 | Sunnyvale Summer Concert |
| 7/19/2018 | Viva Parks Roosevelt |
| 7/21/2018 | Wellness Village Day |
| 7/22/2018 | Philippine Consular |
| 7/25/2018 | Viva Parks Welch |
| 7/26/2018 | USCIS |
| 7/26/2018 | Viva Parks Children of the Rainbow |
| 7/27/2018 | Santa Clara Concert in the Park |
| 7/28/2018 | Veggie Fest |
| 7/28/2018 | Milpitas Preschool Resource Fair |
| 7/29/2018 | Summer Picnic |
| 7/29/2018 | Teeyan Festival |
| 7/30/2018 | Viva Parks Brigadon |

November 2018 Election County Outreach Events

| Date: Aug-18 | Events |
|---|---|
| 8/1/2018 | Sunnyvale Summer Series |
| 8/1/2018 | Viva Parks Ramac |
| 8/2/2018 | Viva Parks Hillview |
| 8/3/2018 | Santa Clara Street Dance |
| 8/3/2018 | Diversity Day |
| 8/4/2018 | Acoustic Open Mic |
| 8/4/2018 | Swadesh Festival |
| 8/7/2018 | National Night Out (NNO) Newhall |
| 8/7/2018 | NNO-Gilroy Wheeler |
| 8/7/2018 | NNO-Gilroy Monticelli |
| 8/7/2018 | NNO-Emma Prusch |
| 8/7/2018 | NNO- St. James |
| 8/7/2018 | NNO-Bibleway |
| 8/7/2018 | NNO-Cadillac Winchester |
| 8/7/2018 | NNO-Delmas |
| 8/9/2018 | NNO-Milpitas |
| 8/10/2018 | District 1 Eats |
| 8/11/2018 | San Jose Jazz |
| 8/11/2018 | Kids N Fun |
| 8/11/2018 | VACC Summer Picnic |
| 8/12/2018 | San Jose Jazz Festival |
| 8/14/2018 | Viva Parks Capitol |
| 8/17/2018 | Santa Clara Concert in the Park |
| 8/18/2018 | Vietnamese Caregivers Conference |
| 8/19/2018 | End of Summer Festival |
| 8/20/2018 | Viva Parks Aborn |
| 8/21/2018 | NNO Mountain House |
| 8/21/2018 | Viva Parks Mt. Pleasant |
| 8/22/2018 | Sunnyvale Summer Series |
| 8/23/2018 | USCIS |
| 8/23/2018 | Viva Parks Emma Prusch |
| 8/24/2018 | Saratoga Eats |
| 8/25/2018 | Palo Alt Festival of the Arts |
| 8/25/2018 | Community Resource Fair |
| 8/25/2018 | SV Pride |
| 8/26/2018 | Palo Alto Festival of the Arts |
| 8/26/2018 | SV PRIDE |
| 8/26/2018 | Cambrian Celebration |
| 8/28/2018 | Viva Parks McLaughlin |
| 8/29/2018 | Sunnyvale Summer Series |
| 8/10/2018 | San Jose Jazz Festival |
| 8/30/2018 | FilAm Chamber |
| 8/29/2018 | KACS |
| **Date: Sep-18** | **Events** |
| 9/1/2018 | Fatherhood Conference |

| | |
|---|---|
| 9/1/2018 | SEIU Rise UP |
| 9/2/2018 | Sonido Clash |
| 9/8/2018 | Project Hope |
| 9/8/2018 | Mediterranen Festival |
| 9/9/2018 | Mediterannean Festival |
| 9/12/2018 | EVC Voter Reg Drive |
| 9/12/2018 | McKinley Bonita NA |
| 9/12/2018 | Sheriff Candidate |
| 9/13/2018 | CONNECT 2018 |
| 9/14/2018 | NN Willow Glen |
| 9/14/2018 | YMCA Welcome Week |
| 9/14/2018 | NN Bascom |
| 9/14/2018 | School of Art |
| 9/15/2018 | SV Fall |
| 9/15/2018 | Ganesh Festival |
| 9/16/2018 | Santa Clara Art & Wine |
| 9/16/2018 | Ganesh Festival |
| 9/19/2018 | Ice Cream Social |
| 9/20/2018 | USCIS |
| 9/21/2018 | Moon Festival |
| 9/21/2018 | Back to School Night |
| 9/22/2018 | Conscious San Jose |
| 9/22/2018 | Moon Festival |
| 9/23/2018 | Cathedral of Faith |
| 9/23/2018 | Viva Calle |
| 9/23/2018 | SoFA Festival |
| 9/23/2018 | Moon Festival |
| 9/25/2018 | NVRD Santa Clara Library |
| 9/25/2018 | NVRD YMCA Alameda |
| 9/27/2018 | Nova Job Fair |
| 9/27/2018 | Pros and Cons of Ballot |
| 9/29/2018 | Moon Festival |
| 9/29/2018 | Hispanic Heritage Month |
| 9/30/2018 | SV Gala |
| 9/30/2018 | Womens Conference |
| 9/22/2018 | Chu-Suk Thanksgiving |
| 9/26/2018 | Valley Church |
| 9/16/2018 | Venture Church |
| 9/21/2018 | KACS Seminar |
| 9/23/2018 | Korean Baptist Church of SJ |
| 9/30/2018 | Korean United methodist Church SCV |

| **Date: Oct-18** | | **Events** |
|---|---|---|
| | 10/2/2018 | Orchard City Indivisible |
| | 10/3/2018 | Gavilan Health Fair |
| | 10/3/2018 | Pros an Cons Presentation |
| | 10/4/2018 | Disability Awareness Day |
| | 10/6/2018 | BNHW Kickoff Week |

| | | |
|---|---|---|
| | 10/7/2018 | Tamale Festival |
| | 10/7/2018 | Day on the Bay |
| | 10/10/2018 | Indian Health Center |
| | 10/10/2018 | Fire Safety Town Hall |
| | 10/12/2018 | Neighborhood Nights Bascom |
| | 10/12/2018 | Neighborhood Nights Almaden |
| | 10/13/2018 | Pumpkins in the Park |
| | 10/13/2018 | Fall Family Festival |
| | 10/16/2018 | Senior Resource Fair |
| | 10/17/2018 | SCU Registration Drive |
| | 10/19/2018 | FestivALL |
| | 10/20/2018 | ALPA Heritage Month |
| | 10/21/2018 | Dia de los Muertos |
| | 10/21/2018 | Health Fair |
| | 10/21/2018 | St Maria Goretti |
| | 10/24/2018 | Project Ohana |
| | 10/25/2018 | USCIS |
| | 10/30/2018 | Hillview Library |
| | 10/16/2018 | When We All Vote |
| | 10/7/2018 | New Vision Church |
| | 10/12/2018 | Civic Engagement Networking |
| | 10/14/2018 | Emmanuel Presbyterian Church |
| **Date: Nov-18** | | **Events** |
| | 11/1/2018 | Gavilan Transfer Day |
| | 11/9/2018 | Neighborhood Nights Alameda |
| | 11/10/2018 | Girls Advisory Networking |
| | 11/11/2018 | BAYVP Diwali 2018 |
| | 11/17/2018 | Empowering Community |
| | 11/18/2018 | Sonido Clash |
| **Date: Dec-18** | | Event |
| | 12/14/2018 | Berryessa Neighborhood Nights |

<u>ការស្រាវជ្រាវសំណួរចម្លើយពីច្បាប់ VCA</u>

## តើអ្វីទៅជាច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California? តើច្បាប់នេះប្តូររបៀបដែលខ្ញុំបោះឆ្នោតយ៉ាងដូចម្តេចខ្លះ?

ច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California (VCA) អភិបាលរដ្ឋ California Jerry Brown បានចុះហត្ថលេខាលើសេចក្តីស្នើច្បាប់ដែលមានលក្ខណៈជាប្រវត្តិសស្រ្តនេះឲ្យចូលជាច្បាប់កាលពីថ្ងៃទី29 ខែកញ្ញា ឆ្នាំ 2016 ។ ស្ថិតក្រោមច្បាប់នេះ អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់នឹងត្រូវផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រមកតាមប្រៃសណីយ៍ (VBM) បានដោយចាប់ផ្តើមក្នុងរយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ដោយមិនគិតថាគេបានចុះឈ្មោះជាអ្នកបោះឆ្នោតតាម VBM ឬក៏អត់នោះទេ ។ ការិយាល័យបោះឆ្នោតតាមសង្កាត់តាំងតែពីដើមមកមានជាង 800 នៅទូទាំងខោនធី នឹងត្រូវជំនួសដោយមណ្ឌលបោះឆ្នោតចំនួន 22 ដែលដំណើរការរយៈពេល 11 ថ្ងៃ និងមណ្ឌលបោះឆ្នោតចំនួន 88 ដែលនឹងដំណើរការរយៈពេល 4 ថ្ងៃ ជាមួយនឹងទីតាំងហិបទម្លាក់សន្លឹកឆ្នោតចំនួន 91 កន្លែងទៀត ។ បន្ថែមទៅលើការផ្ញើត្រឡប់តាមប្រៃសណីយ៍នូវសន្លឹកឆ្នោតដែលបានបោះរួចនោះ អ្នកបោះឆ្នោតក៏អាចទៅកាន់មណ្ឌលបោះឆ្នោតណាមួយដើម្បីបោះឆ្នោតដោយផ្ទាល់បានដែរ ។ អ្នកបោះឆ្នោតក៏អាចទម្លាក់សន្លឹកឆ្នោតរបស់គេនៅតាមមណ្ឌលបោះឆ្នោតណាមួយ ឬនៅតាមទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយក៏បានដែរ ។

## តើការបោះឆ្នោតលើកទីមួយដែលខោនធី Santa Clara នឹងរៀបចំឡើងក្រោមច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត California នឹងរៀបចំធ្វើឡើងនៅពេលណា?

នៅថ្ងៃទី9 ខែមេសា ឆ្នាំ2019 គណៈកម្មការគ្រប់គ្រងរបស់ខោនធី Santa Clara បានអនុញ្ញាតឲ្យមន្រ្តីគ្រប់គ្រងបញ្ជីបោះឆ្នោតរៀបចំការបោះឆ្នោតក្រោមគំរូមណ្ឌលបោះឆ្នោត ។ ការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីថ្ងៃទី 3 ខែមិនា ឆ្នាំ2020 នឹងជាការបោះឆ្នោតលើកដំបូងត្រូវបានរៀបចំឡើងក្រោមច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត California ។

## តើការបោះឆ្នោតទាំងអស់នឹងត្រូវរៀបចំឡើងដោយគំរូថ្មីនេះនាពេលអនាគតនៅក្នុងខោនធី Santa Clara ទេ?

គំរូថ្មីនេះនឹងមានឥទ្ធិពលទៅដល់ការបោះឆ្នោតតាមកំណត់ដែលធ្វើឡើងជាទៀងទាត់ទាំងអស់ ។ ការបោះឆ្នោតពិសេសដែលចំកាលបរិច្ឆេទផ្សេងអាចនឹងត្រូវដំណើរការផ្សេងអាស្រ័យទៅលើសំណើរបស់យុត្តាធិការឲ្យមានការបោះឆ្នោត ។

## ហេតុអ្វីបានជាខោនធី Santa Clara ជ្រើសរើសអនុវត្តច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត?

ខោនធី Santa Clara ទទួលអនុវត្តច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោត (VCA) ដើម្បីធ្វើទំនើបកម្មការបោះឆ្នោតឲ្យឆ្លើយតបទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកបោះឆ្នោត ដែលបច្ចុប្បន្ននេះមានអ្នកបោះឆ្នោតតាមសំបុត្រ 78% ។ VCA នឹងធ្វើឲ្យការបោះឆ្នោតកាន់តែងាយស្រួលជាងមុនដោយផ្ដល់ដល់អ្នកបោះឆ្នោតនូវជម្រើសច្រើនជាងមុន របៀបបោះឆ្នោត ពេលវេលាបោះឆ្នោត និងកន្លែងបោះឆ្នោត ។ ជំនួសឲ្យការកំណត់ឲ្យបោះឆ្នោតបានតែការិយាល័យបោះឆ្នោតមួយដែលត្រូវបានកំណត់នៅថ្ងៃបោះឆ្នោតនោះ អ្នកបោះឆ្នោតឥឡូវនេះនឹងអាចបោះឆ្នោតដោយផ្ទាល់នៅតាមមណ្ឌលបោះឆ្នោតណាមួយស្ថិតនៅក្នុងខោនធី Santa Clara បានឆាប់ក្នុងរយៈពេលដប់ (10) ថ្ងៃមុនថ្ងៃបោះឆ្នោត ។ នៅការិយាល័យចុះបញ្ជីបោះឆ្នោត ដែលមានអាសយដ្ឋាន 1555 Berger Drive, Building 2, San Jose, CA 95112 បានឆាប់ក្នុងរយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត តាមសំបុត្រ ឬ ដោយការទម្លាក់សន្លឹកឆ្នោតដែលបានបោះឆ្នោតនៅក្នុងហិបទម្លាក់សន្លឹកឆ្នោតផ្លូវការ ។

## តើអ្វីទៅជាអត្ថប្រយោជន៍នៃច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោតនោះ?

ច្បាប់ស្ដីពីជម្រើសរបស់អ្នកបោះឆ្នោតផ្ដល់នូវជម្រើសច្រើនជាងមុននៅក្នុងការបោះឆ្នោត៖

- អ្នកបោះឆ្នោតបច្ចុប្បន្ននេះអាចជ្រើសរើសទីកន្លែង ពេលវេលា និងរបៀបដែលពួកគេបោះឆ្នោតបាន ។
- អ្នកបោះឆ្នោតមានច្រើនថ្ងៃជាងមុនដើម្បី បោះឆ្នោតចាប់ផ្ដើមបានដប់ថ្ងៃមុនថ្ងៃបោះឆ្នោត ដោយរាប់បញ្ចូលទាំងចុងសប្ដាហ៍និងថ្ងៃឈប់សម្រាកផង ។
- អ្នកបោះឆ្នោតអាចចុះឈ្មោះបោះឆ្នោតនិងបោះឆ្នោតនៅថ្ងៃជាមួយគ្នានៅមណ្ឌលបោះឆ្នោតបាន ។
- អ្នកបោះឆ្នោតមានទីតាំងច្រើនជាងមុនដើម្បីបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត ។

## តើសេវាអ្វីខ្លះនឹងត្រូវផ្ដល់ឲ្យអ្នកបោះឆ្នោតដែលនិយាយភាសាជាចំបងផ្សេងពីអង់គ្លេសនោះ?

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) ផ្ដល់សេវាប្រាំបីភាសា ។ ភាសាចំនួនបួនត្រូវបានកំណត់ដោយសហព័ន្ធ៖ អេស្ប៉ាញ ចិន កាតាឡុក និងវៀតណាម ។ ភាសាពីរដែលត្រូវបានកំណត់ដោយរដ្ឋមាន ខ្មែរ និង កូរ៉េ ហើយនៅសល់ភាសាពីរទៀត ហ៊ិនឌី និងជប៉ុនត្រូវបានផ្ដល់ជាប្រវត្តិសាស្ត្រដោយ ROV ។ សន្លឹកឆ្នោតផ្លូវការ ការចុះឈ្មោះដោយមានលក្ខខណ្ឌ ស្រោមសំបុត្រសន្លឹកឆ្នោតបណ្ដោះអាសន្ន និងមណ្ឌលបោះឆ្នោតទាំងអស់ និងស្លាកសញ្ញាទីតាំងទម្លាក់សន្លឹកឆ្នោតផ្លូវការ នឹងត្រូវបកប្រែជាភាសាទាំងប្រាំបីនេះ ។ សេចក្ដីណែនាំដែលមានព័ត៌មានស្ដីពីការបោះឆ្នោត (CVIGs) នឹងមានទាំងបួន

ភាសាកំណត់ដោយសហព័ន្ធ ។ បន្ថែមលើនេះទៀត បុគ្គលិកមណ្ឌលបោះឆ្នោតចេះពីរភាសា អាចនឹងត្រៀមរួចជាស្រេចដើម្បីជួយដល់ភាសាផ្សេងទៀត និងក្រៀមភាសានិយាយនៅក្នុងខោនធី ។

## តើអ្វីទៅជាមណ្ឌលបោះឆ្នោត?

មណ្ឌលបោះឆ្នោតគឺជាការិយាល័យបោះឆ្នោតជាសកលដែលបានចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងខោនធីដែលអាចនឹងបោះឆ្នោតបាន ។ នឹងមានប្រមាណ 110 មណ្ឌលបោះឆ្នោតនៅទូទាំងខោនធី Santa Clara ។

## តើពលរដ្ឋនឹងដឹងបានដោយរបៀបណាពីការផ្លាស់ប្តូរពីការិយាល័យបោះឆ្នោតទៅមណ្ឌលបោះឆ្នោតនោះ?

មន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត (ROV) នឹងទាក់ទងទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយនៅក្នុងខោនធី Santa Clara ដោយផ្ញើសំបុត្រពីរ (2) ផ្សេងគ្នា ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីគំរូការបោះឆ្នោតថ្មី ការបោះឆ្នោតនាពេលខាងមុខ និងកន្លែងដែលពួគេអាចស្វែងរកព័ត៌មានបន្ថែមបានអំពីការផ្លាស់ប្តូរទាំងនេះ ។

## តើជំនួយក្នុងការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតមានអ្វីខ្លះ?

មណ្ឌលបោះឆ្នោតនីមួយៗនឹងត្រូវបំពាក់ដោយឧបករណ៍សម្រាប់គូសសញ្ញាលើសន្លឹកឆ្នោតយ៉ាងតិចបី (3) ដែលមានលក្ខណៈស្របតាមច្បាប់ ADA ដើម្បីអនុញ្ញាតដល់អ្នកបោះឆ្នោតមានពិការភាពអាចបោះឆ្នោតបានដោយឯករាជ្យនិងដោយសម្ងាត់បាន ។ អ្នកបោះឆ្នោតនៅតែអាចនាំមកជាមួយនូវអ្នកជួយចំនួនពីរ (2) នាក់ ដើម្បីជួយដល់ពួកគេក្នុងអំឡុងពេលដំណើរការបោះឆ្នោត ដរាបណាពួកគេមិនមែនជានិយោជករបស់អ្នកបោះឆ្នោត ឬជាតំណាងឲ្យសហជីពទេនោះ ។ បន្ថែមលើនេះទៀត អ្នកបោះឆ្នោតដែលចង់បោះឆ្នោតដោយស្រួលពីផ្ទះគេមកនោះ ក៏នឹងមានជម្រើសផងដែរដើម្បីដាក់ពាក្យសុំនិងទទួលបានការបោះតាមប្រព័ន្ធបោះឆ្នោតតាមប្រៃសណីយ៍ពីចម្ងាយ (RAVBM) បាន ។ ប្រព័ន្ធ RAVBM នឹងផ្ញើអ៊ីម៉ែលទៅអ្នកបោះឆ្នោតទាំងនោះដោយមានតំណភ្ជាប់ដើម្បីទាញយកសន្លឹកឆ្នោតផ្លូវការរបស់គេ ជាមួយនឹងសេចក្តីណែនាំស្តីពីរបៀបបំពេញសន្លឹកឆ្នោតរបស់គេ និងរបៀបផ្ញើវាត្រឡប់ទៅកាន់ ROV វិញ ។ មណ្ឌលបោះឆ្នោតក៏នឹងមានជំនួយជាពីរភាសាដែរ អ្នកបោះឆ្នោតអាចទូរសព្ទទៅកាន់ការិយាល័យ (ROV) មានលេខ (408) 299-VOTE ដើម្បីស្វែងយល់ពីជំនួយផ្នែកភាសាដែលផ្តល់ឲ្យ ។

**តើខ្ញុំអាចរកមណ្ឌលបោះឆ្នោតដែលជិតបំផុតបានតាមរបៀបណា?**

ចាប់ផ្តើម 30 ថ្ងៃមុនការបោះឆ្នោតនីមួយៗនោះ តារាងបញ្ជីឈ្មោះមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោតនឹងមាននៅក្នុងសេចក្តីណែនាំដែលមានព័ត៌មានស្តីពីការបោះឆ្នោត (CVIG) និងនៅលើគេហទំព័រមន្ត្រីគ្រប់គ្រងបញ្ជីបោះឆ្នោត https://www.sccgov.org

**តើមានអ្នកនៅក្នុងរដ្ឋ California** ណាម្នាក់បោះឆ្នោតនៅមណ្ឌលបោះឆ្នោតក្នុងខោនធី **Santa Clara** ទេ?

គ្មានទេ មានតែអ្នកទាំងនោះដែលបានចុះឈ្មោះ ឬមានលក្ខណៈសម្បត្តិអាចចុះឈ្មោះបាននៅក្នុងខោនធី Santa Clara អាចនឹងបោះឆ្នោតបាន ។

**តើមណ្ឌលបោះឆ្នោតបើកដំណើរការនៅចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកទេ?**

មណ្ឌលបោះឆ្នោតនឹងបើកដំណើរការឲ្យបានឆាប់ដប់ (10) ថ្ងៃមុនថ្ងៃបោះឆ្នោត ។ នេះរាប់បញ្ចូលទាំងពីរ (2) ចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកដោយសារតែត្រូវចំ ។

**តើត្រូវមានមណ្ឌលបោះឆ្នោតប៉ុន្មាននៅក្នុងខោនធី Santa Clara?**

ចំនួនមណ្ឌលបោះឆ្នោតត្រូវបានកំណត់ដោយផ្អែកទៅតាមចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធីក្នុងរយៈពេល 88 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ផ្អែកលើចំនួនសរុបការចុះឈ្មោះសម្រាប់ខែមិនាឆ្នាំ 2020 ដែលបានព្យាករណ៍ទុកនោះ ខោនធី Santa Clara តម្រូវឲ្យមានមណ្ឌលបោះឆ្នោតចំនួន 20 សម្រាប់ដំណើរការរយៈពេល 11 ថ្ងៃនិងរហូតដល់ទៅ 80 មណ្ឌលបោះឆ្នោតសម្រាប់ដំណើរការរយៈពេល 4 ថ្ងៃ ។ ដើម្បីបម្រើដល់អ្នកបោះឆ្នោតឲ្យបានកាន់តែប្រសើរជាងមុននោះ ខោនធី Santa Clara មានបំណងផ្តល់មណ្ឌលបោះឆ្នោតចំនួន 22 សម្រាប់ដំណើរការរយៈពេល 11 ថ្ងៃ និង 88 មណ្ឌលបោះឆ្នោតសម្រាប់ដំណើរការរយៈពេល 4 ថ្ងៃ ។

**តើកត្តាអ្វីដែលទប់ស្កាត់បុគ្គលមិនឲ្យបោះឆ្នោតបានពីរដងដោយទៅមណ្ឌលបោះឆ្នោតពីរផ្សេងគ្នានោះ?**

រដ្ឋ California បានអនុវត្តមូលដ្ឋានទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោតទូទាំងរដ្ឋដែលគេស្គាល់ថា VoteCal ។ ខោនធីទាំងអស់នឹងអាចកំណត់បានប្រសិនបើអ្នកបោះឆ្នោតបានបោះនៅកន្លែងណាមួយនៅក្នុងរដ្ឋ California រួចហើយនោះ ។ ខោនធី Santa Clara នឹងប្រើប្រាស់បញ្ជីឈ្មោះអ្នកបោះឆ្នោត (e-pollbooks) អេឡិចត្រូនិក ដើម្បីភ្ជាប់ទៅនឹងមូលដ្ឋានទិន្នន័យនេះ ហើយការស្រាវជ្រាវទៅលើការចុះឈ្មោះបោះឆ្នោតក្បែរនឹងជាក់ស្តែង ។

**ខ្ញុំបានទៅការិយាល័យបោះឆ្នោតក្នុងសង្កាត់របស់ខ្ញុំច្រើនឆ្នាំហើយ ។ តើខ្ញុំអាចនៅតែបោះឆ្នោតនៅការិយាល័យបោះឆ្នោតចាស់របស់ខ្ញុំបានទេនៅថ្ងៃបោះឆ្នោត?**

មិនអាចបានទេ លើកលែងតែការិយាល័យបោះឆ្នោតចាស់របស់អ្នកឥឡូវក្លាយជាមណ្ឌលបោះឆ្នោត ។

**ខ្ញុំមិនបានស្នើសុំជាអ្នកបោះឆ្នោតតាមសំបុត្ររហូតនោះទេ ហេតុអ្វីខ្ញុំទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រទៅវិញ?**

ជាមួយនឹងមាត្រានៃច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California (VCA) និងការអនុម័តគណៈកម្មការគ្រប់គ្រងរបស់ខោនធី Santa Clara រួចមកនោះ រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធី Santa Clara ទាំងអស់ ចាប់ផ្តើម 29 ថ្ងៃមុនការបោះឆ្នោត ។ នេះធ្វើឲ្យអ្នកបោះឆ្នោតសម្រេចជ្រើសរើសពីរបៀប ពេលវេលា និងទីកន្លែងដើម្បីបោះឆ្នោត ។

**តើអ្វីទៅជាហិបទម្លាក់សន្លឹកឆ្នោតផ្លូវការ?**

ហិបទម្លាក់សន្លឹកឆ្នោតផ្លូវការមានសន្តិសុខ អាចចេញចូលបាន ហើយកន្លែងដាក់ត្រូវបានចាក់សោរទុកសម្រាប់ឲ្យអ្នកបោះឆ្នោតទម្លាក់ស្រោមសំបុត្រសន្លឹកឆ្នោតបោះតាមសំបុត្រចាប់ផ្តើមឡើងក្នុងរយៈពេល 29 ថ្ងៃមុនការបោះឆ្នោត ។ ហិបទម្លាក់សន្លឹកឆ្នោតមាននៅតាមទីតាំងរបស់វាក្នុងអំឡុងម៉ោងធ្វើការជាប្រក្រតី ។ មិនចាំបាច់មានការបិទតែមប្រៃសណីយ៍ទេនៅពេលប្រើហិបទម្លាក់ឆ្នោតនោះ ។

**តើត្រូវមានហិបទម្លាក់សន្លឹកឆ្នោតផ្លូវការប៉ុន្មាននៅក្នុងខោនធី Santa Clara?**

ចំនួនហិបទម្លាក់សន្លឹកឆ្នោតផ្លូវការត្រូវបានកំណត់ដោយផ្អែកទៅតាមចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធីក្នុងរយៈពេល 88 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ផ្អែកទៅលើការព្យាករណ៍ចំនួនអ្នកបោះឆ្នោដែលបានចុះត្រឹមការបោះឆ្នោតខែមិនា ឆ្នាំ 2020 ខោនធី Santa Clara តម្រូវឲ្យមានហិបទម្លាក់សន្លឹកឆ្នោតប្រមាណជា 67 ហិប ។ ទោះបីយ៉ាងណាដើម្បីបម្រើដល់អ្នកបោះឆ្នោតឲ្យបានកាន់តែប្រសើរជាងមុននោះ ខោនធី Santa Clara មានបំណងឲ្យមានទីតាំងទម្លាក់សន្លឹកឆ្នោតចំនួន 91 កន្លែង ។

**តើហិបទម្លាក់សន្លឹកឆ្នោតផ្លូវការមានសុវត្ថិភាពទេ?**

ហិបទម្លាក់សន្លឹកឆ្នោតផ្លូវការមានសុវត្ថិភាព ត្រូវបានចាក់សោរ និងត្រូវបានធ្វើឡើងពីវត្ថុធាតុដើមដែលជាប់ស៊ិតធន់នឹងការបំផ្លេចបំផ្លាញ ការប្តូរទីតាំង និងអាកាសធាតុអាក្រក់ខ្លាំងបាន ។ សន្លឹកឆ្នោតត្រូវបានប្រមូលយកចេញពីហិបទម្លាក់សន្លឹកឆ្នោត

ដោយបុគ្គលិកការិយាល័យគ្រប់គ្រងបញ្ជីបោះឆ្នោតទៅតាមកាលវិភាគជាទៀងទាត់ ។ សន្លឹកឆ្នោតនឹងត្រូវគេមកទទួលយកនៅថ្ងៃចន្ទ ពុធ និងសុក្រ ចាប់ផ្តើមឡើងក្នុងរយៈពេល 25 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ចាប់ផ្តើមឡើងដប់ (10) ថ្ងៃមុនថ្ងៃបោះឆ្នោត សន្លឹកឆ្នោតនឹងត្រូវមកទទួលយកជារៀងរាល់ថ្ងៃ ។

## តើខោនធីជ្រើសរើសមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោតយ៉ាងដូចម្តេច?

ខោនធីធ្វើការជាមួយសហគមន៍ដើម្បីទទួលយកសំណូមពរនិងធាតុចូលនានាស្តីពីមណ្ឌលបោះឆ្នោតនិងទីតាំងហិបទម្លាក់សន្លឹកឆ្នោត ។ សូមផ្ញើអ៊ីម៉ែលទៅកាន់ voterschoice@rov.sccgov.org ជាមួយនឹងសំណូមពរសម្រាប់ទីតាំងដែលអាចប្រើបាន ។ មុននឹងប្រើប្រាស់ទីតាំងទាំងអស់ត្រូវបានធ្វើការស្ទង់មតិដោយការិយាល័យចុះបញ្ជីបោះឆ្នោត ដើម្បីធានាថាវាមានច្រកចេញចូលសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពបាន ។ នៅពេលណាទីតាំងត្រូវបានធ្វើការស្ទង់មតិហើយនោះ ការិយាល័យរបស់យើងនឹងធ្វើការដោយផ្ទាល់ជាមួយនឹងទីតាំងដើម្បីបញ្ជាក់ពីភាពទំនេរសម្រាប់រយៈពេលតម្រូវកំណត់ឡើងដោយក្រមបោះឆ្នោត California 4005 ។

## តើខ្ញុំអាចទម្លាក់សន្លឹកឆ្នោតដែលបានបោះរបស់ខ្ញុំនៅកន្លែងណា?

សន្លឹកឆ្នោតអាចទម្លាក់បាននៅតាមមណ្ឌលបោះឆ្នោត ទីតាំងទម្លាក់សន្លឹកឆ្នោត ឬការិយាល័យចុះបញ្ជីបោះឆ្នោតដែលស្ថិតនៅ 1555 Berger Drive, Building 2, San Jose, CA 95112 ។

## តើមានលក្ខខណ្ឌតម្រូវអ្វីខ្លះដែល ត្រូវពិចារណាសម្រាប់ការជ្រើសរើសមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោតនោះ?

ក្រមបោះឆ្នោត California 4005 ត្រូវបានផ្អែកទៅលើលក្ខខណ្ឌតម្រូវមួយចំនួនដែលត្រូវតែពិចារណានៅពេលជ្រើសរើសមណ្ឌលបោះឆ្នោតនិងទីតាំងហិបទម្លាក់សន្លឹកឆ្នោត ។ ទាំងនេះរួមមានៈ

- ទីតាំងស្ថិតនៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ
- ចំងាយនិងពេលវេលាអ្នកបោះឆ្នោតត្រូវធ្វើដំណើរដោយរថយន្តផ្ទាល់ខ្លួនមធ្យោបាយធ្វើដំណើរសាធារណៈ
- មានចំណតរថយន្តមិនគិតថ្លៃនិងអាចចេញចូលបាន
- លំនាំចរាចរណ៍
- សហគមន៍ដែលមានការប្រើប្រាស់ការបោះឆ្នោតតាមសំបុត្រចាប់តាំងពីដើមរៀងមក
- មណ្ឌលប្រជាជន

- សហគមន៍ប្រើភាសាជនជាតិភាគតិច
- អ្នកបោះឆ្នោតដែលមានពិការភាព
- សហគមន៍ដែលមានអត្រាម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប
- សហគមន៍មានប្រាក់ចំណូលទាប
- សហគមន៍អ្នកបោះឆ្នោតដែលមានលក្ខណៈសម្បត្តិបោះបាន ដែលមិនទាន់បានចុះឈ្មោះដើម្បីបោះឆ្នោត ហើយអាចនឹងត្រូវបោះនៅថ្ងៃចុះឈ្មោះអ្នកបោះឆ្នោតតែម្តង ។
- ចំនួនប្រជាជនស្ថិតនៅឯកោដោយសារកត្តាទីតាំងភូមិសាស្ត្រ
- សមត្ថភាពសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពដើម្បីអាចបោះឆ្នោតបានដោយសម្ងាត់ និងឯករាជ្យ
- តម្រូវការដែលអាចកើតឡើងសម្រាប់មណ្ឌលបោះឆ្នោតបន្ថែមទៅនឹងចំនួនមណ្ឌលបោះឆ្នោតត្រូវបានកំណត់ និងតម្រូវការសម្រាប់មណ្ឌលបោះឆ្នោតបន្ថែមដើម្បីបើកសម្រាប់រយៈពេលខ្លីជាងធម្មតា

## ខ្ញុំមានទីតាំងដែលអាចធ្វើជាមណ្ឌលបោះឆ្នោត ឬ ទីតាំងហិបទម្លាក់សន្លឹកឆ្នោតបាន តើខ្ញុំត្រូវប្រាប់ឲ្យអ្នកបានដឹងតាមរបៀបណា?

យើងតែងតែស្វែងរកទីតាំងដែលមានសក្តានុពលសម្រាប់ធ្វើជាមណ្ឌលបោះឆ្នោត និងទីតាំងហិបទម្លាក់សន្លឹកឆ្នោតដើម្បីបម្រើដល់សហគមន៍ ។ ទីតាំងដែលមានសក្តានុពលត្រូវតែធ្វើការស្ទង់មតិដោយការិយាល័យបោះឆ្នោត ដើម្បីធានាពីភាពដែលអាចចេញចូលបាន ក៏ដូចជាតម្រូវការផ្សេងទៀតត្រូវបានឆ្លើយតបផងដែរ ។ ដើម្បីផ្តល់អនុសាសន៍ពីទីតាំង ឬដើម្បីទទួលបានព័ត៌មានបន្ថែមអំពីលក្ខខណ្ឌតម្រូវទាំងឡាយដើម្បីអាចធ្វើជាមណ្ឌលបោះឆ្នោតបាន សូមទាក់ទងមកកាន់យើងខ្ញុំតាមអ៊ីម៉ែល ឬ ទូរសព្ទតាម voterschoice@rov.sccgov.org ឬ (408) 299-VOTE ។

## តើការិយាល័យមន្ត្រីគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោតខោនធី Santa Clara មានផ្តល់អែបតាមទូរសព្ទដល់អ្នកបោះឆ្នោតប្រើទេ?

ពិតជាមាន កម្មវិធីទូរសព្ទដៃ SCCVOTE Mobile App អាចទាញយកមកបានដោយមិនគិតថ្លៃ ដើម្បីដាក់លើឧបករណ៍ចល័ត (ឧទា. Apple, Android) ។ មុខងារមួយចំនួនដែលត្រូវបានផ្តល់រួមមាន៖

- ឆាប់រហ័សនិងងាយស្រួលចូលទៅចុះឈ្មោះបោះឆ្នោតតាមអនឡាញ
- ពិនិត្យស្ថានភាពការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក

- ស្វែងរកមណ្ឌលបោះឆ្នោត និងទីតាំងហិបទម្លាក់សន្លឹកឆ្នោតដែលជិតបំផុតចាប់ពីរយៈពេល 28 ថ្ងៃមុនថ្ងៃបោះឆ្នោត

## ROV - សំណួរចម្លើយការចុះឈ្មោះអ្នកបោះឆ្នោត

### តើខ្ញុំចុះឈ្មោះបោះឆ្នោតតាមរបៀបណា?

មានរបៀបផ្សេងៗគ្នាដើម្បីចុះឈ្មោះបោះឆ្នោតបាននៅក្នុងខោនធី Santa Clara៖

- ចុះឈ្មោះតាមអនឡាញដោយប្រើតំណភ្ជាប់ខាងក្រោម៖ www.registertovote.ca.gov
- បំពេញទម្រង់ចុះឈ្មោះបោះឆ្នោត (មាននៅតាមស្ទើរតែគ្រប់ការិយាល័យរដ្ឋាភិបាល បណ្ណាល័យសាធារណៈ ការិយាល័យប្រៃសណីយ៍ និងនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត (ROV)
- ស្នើសុំទម្រង់ចុះឈ្មោះបោះឆ្នោតឲ្យផ្ញើតាមប្រៃសណីយ៍ទៅអ្នកដោយទូរសព្ទទៅកាន់ការិយាល័យ ROV តាមលេខ (408) 299-VOTE ឬលេខមិនគិតថ្លៃ (866) 430-VOTE

### តើខ្ញុំអាចប្រើ P.O. របស់ខ្ញុំបានទេ សូមផ្ញើមកតាម Box ធុរកិច្ច ឬសំបុត្រទម្លាក់តាមអាសយដ្ឋានរបស់ខ្ញុំដូចគ្នាទៅនឹងអាសយដ្ឋាននៅពេលខ្ញុំចុះឈ្មោះបានទេ?

ទេមិនបានទេ អ្នកអាចនឹងត្រូវប្រើ P.O. របស់អ្នក ផ្ញើមកបានតាម Box ធុរកិច្ច ឬសំបុត្រទម្លាក់តាមអាសយដ្ឋានដូចគ្នានឹងអាសយដ្ឋានផ្ញើសំបុត្រតែប៉ុណ្ណោះ ។ អាសយដ្ឋានគេហដ្ឋានត្រូវការដើម្បីកំណត់ពីមណ្ឌលបោះឆ្នោតរបស់អ្នក ។

### ខ្ញុំជាជនគ្មានទីលំនៅ ។ តើខ្ញុំចុះឈ្មោះបោះឆ្នោតតាមរបៀបណា?

អាសយដ្ឋានគេហដ្ឋានត្រូវការដើម្បីកំណត់ពីមណ្ឌលបោះឆ្នោតរបស់អ្នក ។ ប្រសិនបើមិនមានអាសយដ្ឋានដែលរួមមានលេខផ្ទះ និងឈ្មោះផ្លូវទេ អ្នកត្រូវផ្តល់នូវការពិពណ៌នាពីទីតាំងដែលអ្នកគិតថាជាផ្ទះរបស់អ្នក ឬទីលំនៅ (ដូចជាផ្លូវកាត់គ្នា ឬកន្លែងសម្គាល់) ដើម្បីយើងអាចបង្កើតមណ្ឌលរបស់អ្នកបាន ។ ប្រសិនបើអ្នកផ្តល់ផ្លូវកាត់គ្នា ឬកន្លែងសម្គាល់ អ្នកត្រូវផ្តល់នូវអាសយដ្ឋានផ្ញើសំបុត្រផងដែរ ដូចជា P.O ជាដើម ។ Box ធុរកិច្ច អាសយដ្ឋានហិបទម្លាក់សន្លឹកឆ្នោត សម្រាប់ការិយាល័យចុះបញ្ជីបោះឆ្នោតដើ្បផ្ញើឯកសារបោះឆ្នោតរបស់អ្នកតាមប្រៃសណីយ៍ ។ អាសយដ្ឋានគេហដ្ឋាននៅតែតម្រូវឲ្យមាននៅលើទម្រង់ចុះឈ្មោះ ។

### តើប័ណ្ណសម្គាល់អ្វីខ្លះដែល តម្រូវឲ្យប្រើសម្រាប់ការចុះឈ្មោះនោះ?

ប័ណ្ណបើកបរ ឬ ID រដ្ឋ California ត្រូវបានតម្រូវពេលអ្នកចុះឈ្មោះបោះឆ្នោតលើកដំបូង

នៅក្នុងរដ្ឋ California ។ អ្នកដាក់ពាក្យស្នើសុំទាំងឡាយណាដែលមិនមានឯកសារទាំងពីរនេះ អាចផ្តល់នូវលេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់គេ ។

## តើធ្វើដូចម្តេចទើបខ្ញុំដឹងថាការចុះឈ្មោះរបស់ខ្ញុំត្រូវបានទទួលរួចហើយនោះ?

ប័ណ្ណផ្តល់សេចក្តីជូនដំណឹងនឹងត្រូវផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលប្រាំមួយសប្តាហ៍ចាប់ពីថ្ងៃដែលបានដាក់ពាក្យចុះឈ្មោះរបស់អ្នក ។ សូមទាក់ទងមកកាន់ការិយាល័យរបស់យើងតាម (408) 299-VOTE ប្រសិនបើអ្នកមិនទទួលបានការជូនដំណឹងទេនោះ ។

## តើខ្ញុំពិនិត្យស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំបានតាមរបៀបណា?

ដើម្បីពិនិត្យស្ថានភាពការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក៖

- សូមចូលទៅកាន់គេហទំព័ររដ្ឋលេខាធិការ (SOS) ដោយប្រើតំណភ្ជាប់ដូចខាងក្រោម៖ https://voterstatus.sos.ca.gov
- ចូលទៅរកមើលឈ្មោះរបស់អ្នកតាមកម្មវិធីរកឈ្មោះអ្នកបោះឆ្នោតរបស់ខោនធី Santa Clara ដោយប្រើតំណភ្ជាប់ខាងក្រោម៖ https://eservices.sccgov.org/rov/
- ការិយាល័យចុះបញ្ជីបោះឆ្នោតខោនធី Santa Clara តាមលេខ 408) 299-8683

## តើចាំបាច់ត្រូវទៅចុះឈ្មោះឡើងវិញនៅពេលណា?

អ្នកត្រូវចុះឈ្មោះបោះឆ្នោតឡើងវិញនៅពេលណាដែលអ្នកផ្លាស់ប្តូរ៖

- ឈ្មោះ
- អាសយដ្ឋានស្នាក់នៅ
- គណបក្សនយោបាយ

## ហេតុអ្វីបានជាការរក្សាការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំឲ្យនៅថ្មីមានសារៈសំខាន់?

ការចុះឈ្មោះបោះឆ្នោតរបស់អ្នកគួរតែមានលំនៅដ្ឋានរស់នៅបច្ចុប្បន្ន និងអាសយដ្ឋានផ្ញើសំបុត្រដើម្បីធានាថាអ្នកទទួលបានឯកសារបោះឆ្នោតត្រឹមត្រូវ ។ សំបុត្របោះឆ្នោតមិនត្រូវបានបញ្ជូនបន្តឡើយ ។

## ខ្ញុំមិនបានបោះឆ្នោតនៅក្នុងការបោះឆ្នោតចុងក្រោយនេះ តើខ្ញុំចាំបាច់ត្រូវចុះឈ្មោះឡើងវិញទេ?

អ្នកត្រូវចុះឈ្មោះបោះឆ្នោតដរាបណាអ្នកនៅតែរស់នៅតាមអាសយដ្ឋានដដែល ហើយបានបោះឆ្នោតនៅក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ ។ ដើម្បីពិនិត្យមើលស្ថានភាពចុះឈ្មោះរបស់អ្នកបាន សូមចូលទៅកាន់គេហទំព័រការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតតាមតំណភ្ជាប់ខាងក្រោម៖ https://eservices.sccgov.org/rov/ ឬហៅទូរសព្ទទៅ

កាន់លេខ (408) 299-VOTE ។

**ខ្ញុំបានខកខានមិនបានចុះឈ្មោះតាមកាលបរិច្ឆេទ (15 ថ្ងៃមុនថ្ងៃបោះឆ្នោត) តើខ្ញុំនៅតែអាចបោះបានទេ?**

ត្រឹមត្រូវ អ្នកអាចទាញយកផលប្រយោជន៍នៃជម្រើសការចុះឈ្មោះមានលក្ខខណ្ឌថ្មីមានរយៈពេល 14 ថ្ងៃមុន និងចំថ្ងៃបោះឆ្នោត ។ ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌត្រូវបានផ្តល់ជូននៅតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងនៅតាមមណ្ឌលបោះឆ្នោត ហើយនឹងអនុញ្ញាតឲ្យចុះឈ្មោះនិងបោះបណ្តោះអាសន្នបាន ។

**តើអ្វីទៅជាការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ (CVR)?**

ប្រសិនបើអ្នកបោះឆ្នោតមិនបានចុះឈ្មោះដើម្បីបោះឆ្នោតឲ្យបានត្រឹមថ្ងៃ 15 ថ្ងៃទៅតាមកាលបរិច្ឆេទកំណត់ការចុះឈ្មោះអ្នកបោះឆ្នោតទេនោះ នៅក្នុងការបោះឆ្នោតភាគច្រើន គេអាចចុះឈ្មោះបោះឆ្នោតដោយមានលក្ខខណ្ឌ និងបោះឆ្នោតដោយសន្លឹកឆ្នោត CVR នៅការិយាល័យចុះឈ្មោះបោះឆ្នោតខោនធី Santa Clara តាមអាសយដ្ឋាន 1555 Berger Drive, Building 2, San Jose, CA 95112 ក្នុងអំឡុងពេល 14 ថ្ងៃមុននិងដោយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផង ឬក៏នៅតាមមណ្ឌលបោះឆ្នោតណាមួយរបស់យើងឲ្យបានឆាប់ត្រឹមរយៈពេលដប់ (10) ថ្ងៃមុននិងដោយរាប់បញ្ចូលថ្ងៃបោះឆ្នោតផងដែរ ។

**តើការចុះឈ្មោះ CVR ចូលជាធរមាននៅពេលណា?**

ការចុះឈ្មោះមានលក្ខខណ្ឌបានចូលជាធរមានកាលពីថ្ងៃទី1 មករា ឆ្នាំ 2007 បន្ទាប់ពីឯកសារផ្ទុកទិន្នន័យការចុះឈ្មោះអ្នកបោះឆ្នោតទូទាំងរដ្ឋត្រូវបានផ្ទៀងផ្ទាត់រួច ។

**តើការចុះឈ្មោះ CVR ត្រូវបានចាត់ទុកដូចគ្នានឹងការចុះឈ្មោះដទៃទាំងអស់ទេ?**

ត្រឹមត្រូវ ការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌនឹងត្រូវបានចាត់ទុកនិងដំណើរការដូចគ្នាទៅការចុះឈ្មោះដទៃផ្សេងទៀតដែរ ។

**តើសន្លឹកឆ្នោត CVR អាចត្រូវផ្ញើតាមប្រៃសណីយ៍មកខ្ញុំបានទេ?**

មិនបានទេ សន្លឹកឆ្នោត CVR អាចចេញឲ្យបានតែបុគ្គលមកកាន់ការិយាល័យចុះបញ្ជីបោះឆ្នោត ឬមកកាន់ មណ្ឌលបោះឆ្នោតដោយផ្ទាល់ទេ ចាប់ផ្តើមរយៈពេលដប់ថ្ងៃមុនថ្ងៃបោះឆ្នោត ក៏ដូចជាថ្ងៃបោះឆ្នោតផងដែរ ។

**តើខ្ញុំត្រូវការធ្វើអ្វីខ្លះ ដើម្បីបោះឆ្នោតសន្លឹកឆ្នោត CVR បាន?**

អ្នកបោះឆ្នោតដែលមានសក្តានុពលត្រូវបំពេញទម្រង់ចុះឈ្មោះបោះឆ្នោត ហើយបន្ទាប់មកក៏បោះឆ្នោតនៅតាមការិយាល័យចុះបញ្ជីបោះឆ្នោត ឬ មណ្ឌលបោះឆ្នោតណាមួយក្នុងខោនធី ។ សូមកត់សម្គាល់ថា សន្លឹកឆ្នោតការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌមិនអាចយកចេញបានពីអគារ និងយកត្រឡប់មកវិញនៅកាលបរិច្ឆេទក្រោយបានទេ ។ សន្លឹកឆ្នោតការចុះឈ្មោះអ្នកបោះឆ្នោនមានលក្ខខណ្ឌជាសន្លឹកឆ្នោតបណ្តោះអាសន្ន ដែលនឹងត្រូវដំណើរការក្រោយការផ្ទៀងផ្ទាត់នៃការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌចប់ ។

## តើខ្ញុំនឹងអាចពិនិត្យមើលថាតើសន្លឹកឆ្នោត CVR របស់ខ្ញុំត្រូវបានរាប់ ឬមិនរាប់បានទេ?

ពិតជាបាន សូមពិនិត្យស្ថានភាពសន្លឹកឆ្នោតរបស់អ្នកនៅការិយាល័យរបស់យើងតាមទូរសព្ទលេខ (408) 299-VOTE ឬ ដោយចូលទៅកាន់គេហទំព័ររដ្ឋលេខាធិការ (SOS) ដោយប្រើតំណភ្ជាប់ដូចខាងក្រោម៖ www.sos.ca.gov/elections/ballot-status

## ខ្ញុំបានក្លាយជាពលរដ្ឋថ្មីក្រោយកាលបរិច្ឆេទចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ តើអ្នកអាចនៅតែចុះឈ្មោះបោះឆ្នោតបានទេ?

ពិតជាបាន បុគ្គលទាំងឡាយណាដែលក្លាយជាពលរដ្ឋដោយសញ្ជាតូបនីយកម្មក្រោយបិទការចុះឈ្មោះ (15 ថ្ងៃមុនថ្ងៃបោះឆ្នោត) អាចគ្រាន់តែចុះឈ្មោះនិងបោះឆ្នោតនៅតាមការិយាល័យចុះបញ្ជីបោះឆ្នោតនៅចន្លោះ 14 ថ្ងៃ និងការបិទបញ្ចប់ការបោះឆ្នោតនៅម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោតតែប៉ុណ្ណោះ ។ ពលរដ្ឋថ្មីត្រូវបង្ហាញនូវវិញ្ញាបនប័ត្រសញ្ជាតូបនីយកម្ម ដែលត្រូវមានកាលបរិច្ឆេទសញ្ជាតូបនីយកម្ម ដែលស្ថិតនៅក្រោយកាលបរិច្ឆេទបិទការបោះឆ្នោត ហើយគេត្រូវតែប្រកាសថាគេមានលំនៅដ្ឋាននៅក្នុងខោនធី Santa Clara ដោយត្រូវផ្តល់នូវលិខិតបញ្ជាក់ និងវិញ្ញាបនប័ត្រពីពិធីប្រកាសភាពជាពលរដ្ឋ ។

## តើខ្ញុំលុបការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំនៅក្នុងខោនធី Santa Clara បានតាមរបៀបណា?

ការចុះឈ្មោះអ្នកបោះឆ្នោតអាចត្រូវបានលុបចោលបានតាមរយៈរបៀបដូចខាងក្រោម៖

1. សូមព្រីន បំពេញ និងចុះហត្ថលេខាលើទម្រង់សំណើសុំលុបការចុះឈ្មោះបោះឆ្នោតដោយប្រើប្រាស់តំណភ្ជាប់ខាងក្រោម ដែលផ្តល់ដោយរដ្ឋលេខាធិការ (SOS) ដោយប្រើតំណភ្ជាប់ដូចខាងក្រោម៖ https://elections.cdn.sos.ca.gov/pdfs/cancellation-request-form.pdf

2. ព្រីន បំពេញ និងចុះហត្ថលេខាលើទម្រង់ស្នើសុំបោះឆ្នោត (VARF) ដោយប្រើតំណភ្ជាប់ខាងក្រោម៖ https://www.sccgov.org/sites/rov/Register/Documents/VARF_318.pdf
3. ពង្រាងសំណើជាលាយល័ក្ខអក្សរដោយមានឈ្មោះរបស់អ្នក អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត និងហត្ថលេខាបញ្ជាក់ថា អ្នកឈប់ចង់ឲ្យចុះឈ្មោះនៅក្នុងខោនធី Santa Clara ទៀតហើយ៖
    a. ផ្ញើសំបុត្រទៅកាន់ការិយាល័យចុះបញ្ជីបោះឆ្នោតខោនធី Santa Clara ដែលស្ថិតនៅ 1555 Berger Drive, Building 2, San Jose, CA 95112 ។
    b. ផ្ញើច្បាប់ស្កេនតាមអ៊ីម៉ែលទៅកាន់ voterinfo@rov.sccgov.org ឬ
    c. តាមទូរសារទៅកាន់លេខ (408) 998-7314 ។

## តើខ្ញុំជូនដំណឹងទៅការិយាល័យបោះឆ្នោតពីការទទួលមរណភាពរបស់អ្នកបោះឆ្នោតបានតាមរបៀបណា?

ការិយាល័យបោះឆ្នោតទទួលការធ្វើបច្ចុប្បន្នភាពប្រចាំខែពីរដ្ឋនូវចំនួនអ្នកទទួលមរណភាពទាំងអស់នៅក្នុងខោនធី Santa Clara ។ ដើម្បីធ្វើសំណើសុំលុបការចុះឈ្មោះរបស់អ្នកបោះឆ្នោតដែលស្លាប់ចោលបាន សមាជិកគ្រួសារផ្ទាល់អាចទូរសព្ទមកកាន់ការិយាល័យរបស់យើងតាមលេខ (408) 299-VOTE ។

## ខ្ញុំជឿថាខ្ញុំបានចុះឈ្មោះរួចហើយ ប៉ុន្តែមិនអាចរកកំណត់ត្រាឃើញដោយប្រើកម្មវិធីស្វែងរកឈ្មោះអ្នកបោះឆ្នោត ។

នៅពេលប្រើកម្មវិធីស្វែងរកឈ្មោះអ្នកបោះឆ្នោតរបស់ខោនធី Santa Clara សូមវាយចូលអាសយដ្ឋានគេហដ្ឋានរបស់អ្នកនិងថ្ងៃខែឆ្នាំកំណើតតាមទម្រង់ mm/dd/yyyy ។ ប្រសិនបើអ្នកនៅតែមិនអាចរកកំណត់ត្រារបស់អ្នកឃើញទេ សូមទូរសព្ទមកកាន់ការិយាល័យរបស់យើងតាមលេខ (408) 299-VOTE ដើម្បីធ្វើការផ្ទៀងផ្ទាត់ ។

## តើខ្ញុំអាចចុះហត្ថលេខាលើញត្តិទាមទារបានទេប្រសិនបើខ្ញុំមិនត្រូវបានចុះឈ្មោះឲ្យបោះឆ្នោតនោះ?

មិនបានទេ អ្នកប្រាកដជាត្រូវបានចុះឈ្មោះជាអ្នកបោះឆ្នោតនៅតាមអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកដែលមាននៅលើសំណុំឯកសារដើម្បីឲ្យហត្ថលេខារបស់អ្នកមានសុពលភាពនៅលើញត្តិទាមទារនោះបាន ។

## ខ្ញុំបានទទួលសំបុត្រពីអ្នកនយោបាយនិងការហៅទូរសព្ទចូលជាច្រើនមកផ្ទះរបស់ខ្ញុំ ។ តើពួកគេបានទទួលព័ត៌មានខ្ញុំមកពីណា?

ព័ត៌មាននេះអាចទទួលបានពីប្រភពផ្សេងៗគ្នា ដោយរាប់បញ្ចូលទាំងបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតផងដែរ ។ ច្បាប់បច្ចុប្បន្ននេះអនុញ្ញាតឲ្យទិន្នន័យចុះឈ្មោះអ្នកបោះឆ្នោតផ្តល់ទៅបុគ្គលឬក្រុមទាំងឡាយដែលត្រូវបានអនុញ្ញាត និងត្រូវប្រើសម្រាប់គោលបំណងការងារបោះឆ្នោត ការងាររដ្ឋាភិបាល ការសិក្សាស្រាវជ្រាវ ឬគោលបំណងស្រាវជ្រាវផ្នែកនយោបាយ ។ ប្រសិនបើអ្នកចង់លុបលេខទូរសព្ទចេញពីការចុះឈ្មោះរបស់អ្នក សូមទូរសព្ទមកកាន់ការិយាល័យរបស់យើងតាមលេខ (408) 299-VOTE ។

## ហេតុអ្វីក្រសួងយានយន្ត (DMV) ត្រូវចូលរួមពាក់ព័ន្ធក្នុងការចុះឈ្មោះអ្នកបោះឆ្នោត?

ច្បាប់ចុះឈ្មោះបោះឆ្នោតថ្នាក់ជាតិឆ្នាំ 1993 អនុញ្ញាតឲ្យបុគ្គលធ្វើអាជីវកម្មនៅការិយាល័យ DMV ចុះឈ្មោះបោះឆ្នោត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានកំណត់ត្រាការចុះឈ្មោះបោះឆ្នោតបាន ។ ច្បាប់នេះច្រើនតែត្រូវបានស្គាល់ថា “ច្បាប់អ្នកបោះឆ្នោតយានយន្ត” អនុញ្ញាតឲ្យសាធារណជនឲ្យចុះឈ្មោះបោះឆ្នោត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានបោះឆ្នោតរបស់គេបានក្នុងអំឡុងពេលដំណើរការប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណ (ID) នៅ DMV បាន ។ ប្រសិនបើបេក្ខជនដាក់ពាក្យសុំបំពេញពាក្យស្នើសុំប័ណ្ណបើកបរ អត្តសញ្ញាណប័ណ្ណ ឬ ការផ្លាស់ប្តូរអាសយដ្ឋាន ទាំងតាមអនឡាញ តាមអ៊ីម៉ែល ឬ មកដោយផ្ទាល់នោះពួកគេត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិដោយរដ្ឋលេខាធិការ California (លើកលែងតែគេជ្រើសរើសយកការបដិសេធទេ) ។ ច្បាប់នេះក៏អនុញ្ញាតឲ្យមានការចុះឈ្មោះទុកមុនចំពោះពលរដ្ឋ California ដែលមានសិទ្ធិបោះឆ្នោត ដោយមានអាយុ 16 ឬ 17 ឆ្នាំ ដើម្បីឲ្យពួកគេអាចចុះឈ្មោះបោះឆ្នោតបានដោយស្វ័យប្រវត្តិនៅពេលមានអាយុចូល 18 ឆ្នាំ ។

## តើវាពិតទេដែលបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសពលរដ្ឋឲ្យបំពេញភារកិច្ចជាគណៈវិនិច្ឆ័យនោះ?

ពិតមែនហើយ តួនាទីកាត់សេចក្តីរបស់គណៈវិនិច្ឆ័យត្រូវបានទាញចេញពីសំណុំឯកសារចុះឈ្មោះអ្នកបោះឆ្នោត និងកំណត់ត្រារបស់ DMV ។

## ហេតុអ្វីបានខ្ញុំទទួលបានឲ្យធ្វើជាគណៈវិនិច្ឆ័យកាត់សេចក្តីច្រើនដងម្លេះ?

ប្រសិនបើឈ្មោះរបស់អ្នកលើប័ណ្ណបើកបរចេញមកខុសពីនៅលើកំណត់ត្រាការឈ្មោះអ្នកបោះឆ្នោតនោះ អ្នកអាចនឹងទទួលនូវការជូនដំណឹងច្រើនដង ។ ដើម្បីដោះស្រាយស្ថានភាពនេះ សូមបំពេញទម្រង់ចុះឈ្មោះបោះឆ្នោតថ្មីហើយផ្ញើវាត្រឡប់មកកាន់ការិយាល័យចុះបញ្ជីបោះឆ្នោត ដោយមានឈ្មោះរបស់អ្នកព្រីនមកដូចគ្នាទៅនឹង

ឈ្មោះនៅលើប័ណ្ណបើកបរ ឬក៏បំពេញការចុះឈ្មោះអ្នកបោះឆ្នោតថ្មីតាមប្រព័ន្ធអនឡាញតាមតំណភ្ជាប់ដូចខាងក្រោម៖ www.sos.ca.gov ។ ស្នងការគណៈវិនិច្ឆ័យអាចជ្រើសរើសសមាជិកគណៈវិនិច្ឆ័យចេញពីបញ្ជីផ្តល់ដោយ DMV (ក្រសួងយានយន្ត) និងការិយាល័យស្នងការខោនធី ។ ការធ្វើបច្ចុប្បន្នភាពកំណត់ត្រាអ្នកបោះឆ្នោតរបស់អ្នកដើម្បីឲ្យត្រូវគ្នាទៅនឹងប័ណ្ណបើកបរ ឬ ID របស់អ្នកអាចនឹងលុបចោលការជុំនុំក្តីរបស់អ្នកបានច្រើន ។

## ROV - សំណួរចម្លើយការចុះឈ្មោះអ្នកបោះឆ្នោត

### តើខ្ញុំគួររំពឹងថាសន្លឹកឆ្នោតរបស់ខ្ញុំនឹងមកដល់នៅពេលណា?

សន្លឹកឆ្នោតត្រូវបានផ្ញើតាមប្រៃសណីយ៍ចាប់ផ្តើមក្នុងរយៈពេល 29 ថ្ងៃមុនបោះឆ្នោត ។ ប្រសិនបើអ្នកមិនបានទទួលសន្លឹកឆ្នោតរបស់អ្នកក្នុងរយៈពេលពីរសប្តាហ៍មុនការបោះឆ្នោតទេនោះ សូមទូរសព្ទមកកាន់ការិយាល័យរបស់យើងតាមលេខ (408) 299-VOTE ។

### បច្ចុប្បន្នខ្ញុំកំពុងស្ថិតនៅបណ្តោះអាសន្នក្រៅប្រទេសឬរដ្ឋ ។ តើខ្ញុំអាចសុំឲ្យផ្ញើសន្លឹកឆ្នោតខ្ញុំមកកាន់អាសយដ្ឋានផ្សេងបានទេ?

បាន សូមទូរសព្ទទៅកាន់ការិយាល័យចុះបញ្ជីបោះឆ្នោតតាមលេខ (408) 299-VOTE ហើយសន្លឹកឆ្នោតនឹងត្រូវផ្ញើទៅកាន់អាសយដ្ឋានបណ្តោះអាសន្ននោះ ។

### តើខ្ញុំទទួលសន្លឹកឆ្នោតជំនួសថ្មីតាមរបៀបណា?

សូមទូរសព្ទមកកាន់ការិយាល័យចុះបញ្ជីបោះឆ្នោតខោនធី Santa Clara តាមលេខ (408) 299-VOTE to ស្នើសុំសន្លឹកឆ្នោតជំនួសថ្មី ។ សន្លឹកឆ្នោតជំនួសថ្មីក៏មាននៅតាមមណ្ឌលបោះឆ្នោតស្ថិតក្នុងខោនធី Santa Clara ដែរ ឬនៅការិយាល័យចុះបញ្ជីបោះឆ្នោតដែលស្ថិតនៅ 1555 Berger Drive, Building 2, San Jose, CA 95112 ។

### តើខ្ញុំត្រូវការបិទតែមប្រៃសណីយ៍ដើម្បីផ្ញើសន្លឹកឆ្នោតខ្ញុំទេ?

មិនចាំបាច់ទេ ខោនធីនឹងបង់ថ្លៃសម្រាប់តែមប្រៃសណីយ៍ ។

### តើខ្ញុំអាចដឹងពីស្ថានភាពសន្លឹកឆ្នោតខ្ញុំបានដោយរបៀបណា?

ស្ថានភាពនៃសន្លឹកឆ្នោតរបស់អ្នកនឹងអាចដឹងបានចាប់ផ្តើមក្នុងរយៈពេល 29 ថ្ងៃមុនការបោះឆ្នោតនីមួយៗ ។ អ្នកអាចពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតរបស់អ្នកបានដោយចូលទៅកាន់តំណភ្ជាប់ដូចខាងក្រោមនេះ៖
https://eservices.sccgov.org/rov/?tab=ab

## តើខ្ញុំបោះឆ្នោតយ៉ាងដូចម្តេចទៅបើខ្ញុំជាយោធា ឬកំពុងរស់នៅក្រៅប្រទេសនោះ?

អ្នកបោះឆ្នោតជាយោធាឬអ្នករស់នៅក្រៅប្រទេសនោះ មានជម្រើសដើម្បីដាក់ពាក្យស្នើសុំប្រើប្រព័ន្ធបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) ដែលផ្ញើអ៊ីម៉ែលទៅកាន់អ្នកបោះឆ្នោតដោយមានតំណភ្ជាប់ដើម្បីទាញយកសន្លឹកឆ្នោតផ្លូវការរបស់គេ ព្រមជាមួយនឹងសេចក្តីណែនាំស្តីពីរបៀបបំពេញសន្លឹកឆ្នោតរបស់គេ និងរបៀបផ្ញើវាត្រឡប់មកកាន់ការិយាល័យចុះបញ្ជីបោះឆ្នោតវិញ ។

ប្រសិនបើសន្លឹកឆ្នោតមិនមកដល់ក្នុងរយៈពេលបួន (4) សប្តាហ៍មុនការបោះឆ្នោតទេនោះ សូមទាក់ទងការិយាល័យចុះបញ្ជីបោះឆ្នោតសម្រាប់ការជំនួសថ្មីតាមរយៈទូរសព្ទលេខ៖ (408) 299-VOTE ឬ (866) 430-VOTE ទូរសារលេខ (408) 998-7314 ឬអ៊ីម៉ែល votebymail@rov.sccgov.org ។

## តើថ្ងៃចុងក្រោយត្រូវផ្ញើសន្លឹកឆ្នោតរបស់ខ្ញុំត្រឡប់មកវិញគឺថ្ងៃណា?

សន្លឹកឆ្នោតដែលបានបោះរួចត្រូវផ្ញើតាមប្រៃសណីយ៍ត្រូវតែមានត្រាប្រៃសណីយ៍ ឬនៅមុនថ្ងៃបោះឆ្នោត ហើយត្រូវទទួលបានដោយការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត (ROV) មិនឲ្យយឺតជាងបីថ្ងៃក្រោយការបោះឆ្នោត ។ ទម្លាក់សន្លឹកឆ្នោតនៅតាមទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយ ឬ មណ្ឌលបោះឆ្នោតណាមួយស្ថិតក្នុងខោនធី Santa Clara ឬនៅការិយាល័យ ROV ដែលស្ថិតនៅ 1555 Berger Drive, Building 2, San Jose, CA 95112 ដោយមិនឲ្យយឺតជាងម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត ។

## កូនប្រុស/កូនស្រីរបស់ខ្ញុំនៅឆ្ងាយឯសាលា ។ តើខ្ញុំអាចទទួលយកសន្លឹកឆ្នោតរបស់ពួកគេបានទេ?

សន្លឹកឆ្នោតនឹងត្រូវផ្ញើដោយស្វ័យប្រវត្តិតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានផ្ញើសំបុត្ររបស់គេ ។ គេអាចទូរសព្ទមកកាន់ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតតាមលេខ (408) 299-VOTE ដើម្បីស្នើសុំសន្លឹកឆ្នោតរបស់គេផ្ញើទៅកាន់អាសយដ្ឋានរបស់ពួកគេបាន ។ ប្រសិនបើចាំបាច់ត្រូវទទួលយកសន្លឹកឆ្នោតជំនួសថ្មីសម្រាប់ពួកគេនោះ អ្នកអាចធ្វើដូចគ្នានេះបានដែរដោយត្រូវចុះហត្ថលេខាលើសំណើសុំពីកូនប្រុស ឬ កូនស្រីរបស់អ្នកអនុញ្ញាតឲ្យអ្នកធ្វើដូច្នេះបាន ។

### ខ្ញុំបាត់ស្រោមសំបុត្រសម្រាប់សន្លឹកឆ្នោតរបស់ខ្ញុំ តើខ្ញុំត្រូវធ្វើដូចម្តេច? តើខ្ញុំត្រូវផ្ញើវាចូលមកតាមរបៀបណា?

អ្នកបោះឆ្នោតអាចទទួលយកស្រោមសំបុត្រសន្លឹកឆ្នោតថ្មីបាននៅតាមមណ្ឌលបោះឆ្នោតណាមួយ ឬទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយ ដែលស្ថិតនៅក្នុងខោនធី Santa Clara ឬនៅការិយាល័យ ROV ដែលស្ថិតនៅ 1555 Berger Drive, Building 2, San Jose, CA 95112 ។ ស្រោមសំបុត្រសន្លឹកឆ្នោតជំនួសថ្មីអាចត្រូវបានទទួលយកនៅទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយនៅក្នុងខោនធី Santa Clara ។ សូមកុំភ្លេចបំពេញព័ត៌មានដែលបានស្នើសុំនិងចុះហត្ថលេខានៅកន្លែងដែលបង្ហាញ ។ សូមប្រើស្រោមសំបុត្រទទេ ហើយសរសេរចូលព័ត៌មានដូចខាងក្រោមពីខាងក្រៅ៖ ឈ្មោះ អាសយដ្ឋានគេហដ្ឋាន និងហត្ថលេខា ។ សូមបញ្ចូលនូវសេចក្តីថ្លែងដូចតទៅនេះ “ខ្ញុំសូមប្រកាសក្រោមទោសបញ្ញត្តិនៃសក្ខីភាពទុច្ចរិតថា៖ ខ្ញុំជាពលរដ្ឋរស់នៅក្នុងខោនធី Santa Clara រដ្ឋ California ដែលជាកន្លែងខ្ញុំបោះឆ្នោត ខ្ញុំមានឈ្មោះដូចមាននៅលើស្រោមសំបុត្រនេះ ខ្ញុំមិនបានដាក់ពាក្យស្នើសុំ និងមិនមានបំណងដាក់ពាក្យស្នើសុំសន្លឹកឆ្នោតពីយុត្តាធិការផ្សេងសម្រាប់ការបោះឆ្នោតនេះទេ” ។ សូមដាក់សន្លឹកឆ្នោតដែលបានបោះចូលនិងបិទឲ្យជិតក្នុងស្រោមសំបុត្រដោយមានព័ត៌មានដូចខាងលើ ។ ស៊កស្រោមសំបុត្រសន្លឹកឆ្នោតដែលបានបោះចូលទៅស្រោមសំបុត្រផ្ញើចេញដាច់ដោយឡែកមួយទៀត ហើយផ្ញើវាទៅកាន់ ROV ។

## <u>ROV – សំណួរចម្លើយស្តីពីសេវាបេក្ខជន</u>

### តើនរណាជាតំណាងរាស្ត្រដែលត្រូវបានជ្រើសរើសរបស់ខ្ញុំ?

ព័ត៌មានស្តីពីតំណាងដែលត្រូវបានជ្រើសរើស អាចទទួលបានដោយទូរសព្ទទៅកាន់ការិយាល័យចុះបញ្ជីបោះឆ្នោតតាមលេខ (408) 299-VOTE ឬប្រើតំណភ្ជាប់ខាងក្រោម៖ https://www.sccgov.org/sites/rov/Info/Documents/Office-Holders-List.pdf

### តើខ្ញុំអាចឈរឈ្មោះសម្រាប់ការិយាល័យដែលត្រូវបោះឆ្នោតជ្រើសរើសតាមរបៀបណា?

អ្នកអាចស្វែងរកព័ត៌មានស្តីពីរបៀបឈរឈ្មោះសម្រាប់ការិយាល័យដែលត្រូវបោះឆ្នោតជ្រើសរើសបានតាមតំណភ្ជាប់ដូចខាងក្រោម៖ https://www.sccgov.org/sites/rov/Info/Pages/CandidateINFO.aspx

### តើខ្ញុំអាចរកលទ្ធផលនៃការបោះឆ្នោតកន្លងទៅនៅឯណាបាន?

អ្នកអាចស្វែងរកលទ្ធផលនៃការបោះឆ្នោតកន្លងទៅបានតាមតំណភ្ជាប់ដូចខាងក្រោម៖ https://www.sccgov.org/sites/rov/Resources/Pages/PastEResults.aspx

**តើខ្ញុំអាចដាក់វិធានការនៅលើសន្លឹកឆ្នោតតាមរបៀបណា?**

អ្នកអាចស្វែងរកព័ត៌មានស្តីពីវិធានការបានតាមតំណភ្ជាប់ដូចខាងក្រោម៖ https://www.sccgov.org/sites/rov/Info/Pages/Recalls.aspx

**តើខ្ញុំបោះឆ្នោតដកតំណែងមន្ត្រីដែលបានជាប់ឆ្នោតតាមរបៀបណា?**

អ្នកអាចស្វែងរកព័ត៌មានស្តីពីការបោះឆ្នោតដកតំណែងបានតាមតំណភ្ជាប់ដូចខាងក្រោម៖ https://www.sccgov.org/sites/rov/Info/Pages/Recalls.aspx